ហ៊ុន សែន

# 10 ឆ្នាំ នៃ ដំណើរកម្ពុជា

1979 ~ 1989

# អារម្ភកថា

ខ្ញុំសរសេរសៀវភៅនេះ ក្នុងបំណងកត់ត្រាទុកនូវព្រឹត្តិការណ៍ខ្លះ ដែលបានឆ្លងកាត់រយៈពេល ១០ ឆ្នាំកន្លងមក និងការប៉ាន់ស្មានខ្លះនៃការវិវត្តន៍សភាពការណ៍ ដែលអាចកើតមាននៅពេលខាងមុខ ព្រមទាំងគំនិតខ្លះសំរាប់ការដោះស្រាយបញ្ហាមួយចំនួនដែលនៅសេសសល់ក្នុងបញ្ហានយោបាយ ក៏ដូចជាការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គម។

សៀវភៅនេះគ្មានចរិតជាការអប់រំផ្នែកនយោបាយ និងទ្រឹស្តីទេ ហើយក៏គ្មានលក្ខណៈជាគោលជំហររួមរបស់បក្ស និងរដ្ឋាភិបាលដែរ ប៉ុន្តែ ខ្ញុំជឿជាក់ថា វាក៏អាចនាំមកនូវការរួមវិភាគទានសំរាប់ការយល់ដឹងមួយផ្នែកដែរ ពិសេសសំរាប់ប្អូនៗ ក្មួយៗ ជំនាន់ក្រោយ។

ខ្ញុំសូមឧទ្ទិសសៀវភៅនេះ ចំពោះវិញ្ញាណក្ខន្ធអ្នកទាំងឡាយ ដែលបានពលី ដើម្បីបុព្វហេតុជាតិ និងប្រជាជន ចំពោះអ្នកទាំងឡាយដែលបានស្លាប់យ៉ាងសែនខ្លោចផ្សាក្នុងរបបស្រេកឈាម ប៉ុល ពត ព្រមទាំងឧទ្ទិសដល់ស្នាដៃនៃមនុស្សគ្រប់ៗរូប ដែលបានចូលរួមកសាង និងការពារប្រទេស ក្នុងរយៈពេល ១០ ឆ្នាំកន្លងមក។

អាស្រ័យដោយការគាបសង្កត់អំពីពេលវេលាដោយត្រូវធ្វើការផង ចរចារកសន្តិភាពនៅទីក្រុងហ្សាការតា និងការចរចាជាមួយភាគីខ្មែរបដិបក្ខផង ទើបការសរសេរសៀវភៅនេះ មិនបានគ្រប់ជ្រុងជ្រោយ។ ជាងនេះទៀត ការសរសេរសៀវភៅនេះ ចំពេលដែលសភាពការណ៍កម្ពុជា និងជុំវិញកម្ពុជាកំពុងមានការវិវត្តន៍ប្រែប្រួលយ៉ាងលឿន និងស្មុគស្មាញ។

សង្ឃឹមថា នឹងមានការយោគយល់ និងអធ្យាស្រ័យពីសំណាក់អ្នកអាន។

**ហ៊ុន សែន**

# មាតិការឿង

<u>ផ្នែកទី ១</u>

## ការវិវត្តន៍នៃសភាពការណ៍យោធា នយោបាយ

ប្រភពកើតឡើងនៃបញ្ហាកម្ពុជា និងការដួលរលំនៃរបប ប៉ុល ពត......២
ថ្ងៃមុនប្រឆាំង ប៉ុល ពត ថ្ងៃនេះរួមជាមួយ ប៉ុល ពត ប្រឆាំង
ប្រជាជនកម្ពុជា ........................................................... ១៩
យុទ្ធសាស្ត្របីដំណាក់កាល និងការរើបំរះត្រដរខ្យល់លើកទីមួយ ...... ២៨
សម្ព័ន្ធភាពនៃបងប្អូនដែលជាសត្រូវនឹងគ្នា ................................. ៣៥
ការរើបំរះត្រដរខ្យល់លើកទីពីរ និងជំហានថយក្រោយ
ខាងយុទ្ធសាស្ត្រ ........................................................... ៥៤
យុទ្ធសាស្ត្រថ្មី របស់ពួក ប៉ុល ពត ............................................. ៧៥
ការបែកបាក់ នៃកម្លាំងប្រឆាំង................................................... ៨៧
ពីការប្រឈមមុខ ដល់ការចរចា, បដិវត្តន៍បានផ្ទេរដំណាក់កាល,
ការផ្លាស់ប្តូរសម្ព័ន្ធភាព ...................................................... ១១៦
ភាពរអាក់រអួល និងឧបសគ្គ ..................................................... ១៥៨

<u>ផ្នែកទី ២</u>

## ការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ រយៈពេល ១០ ឆ្នាំ ភាពចាំបាច់ និងកិច្ចការត្រូវដោះស្រាយ

សមិទ្ធិផល ១០ ឆ្នាំ ខាងវិស័យសេដ្ឋកិច្ច និងកិច្ចការត្រូវបន្ត............១៧៤
សមិទ្ធិផល ១០ ឆ្នាំ ខាងវិស័យសង្គមកិច្ច វប្បធម៌
និងកិច្ចការត្រូវបន្ត..............................................................២៥៨

ផ្នែកទី ៣

ការកសាងកម្លាំង........................................................៣១៥

ផ្នែកទី ៤

ផ្លូវដោមុខ....................................................................៣៣១
សង្គ្រាម និងសន្តិភាព.....................................................៣៣៥
ការកែងម្រង់...............................................................៣៦៩

**ផ្នែកទី ១**

# ការវិវត្តន៍នៃ
# សភាពការណ៍យោដា នយោចាយ

## ប្រភពកើតឡើងនៃបញ្ហាកម្ពុជា
## និង ការដួលរលំនៃរបប ប៉ុល ពត

*គួររំលឹកឡើងវិញ អំពីប្រវត្តិអតីតកាល ដែលប្រទេសកម្ពុជាបានឈានចេញពីសន្តិភាពចូលទៅក្នុងសង្គ្រាម។ សង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិកចំពោះវៀតណាម បានរាតទឹមកដល់កម្ពុជា នៅថ្ងៃ ១៨ មីនា ឆ្នាំ ១៩៦៩ តាមរយៈនៃប្រតិបត្តិការតាមផ្លូវអាកាស ដែលមានឈ្មោះជាសម្ងាត់ថា "ការស្រស់ស្រូបពេលព្រឹក" នោះគឺយន្តហោះយុទ្ធសាស្ត្រ បេ ៥២ ដែលហោះចេញពីមូលដ្ឋានអាមេរិកនៅកោះ Guam ឆ្ពោះទៅប្រទេសវៀតណាម ហើយដែលក្នុងអំឡុងពេលហោះហើរនោះ បានទទួលនូវបទបញ្ជាអោយមកទម្លាក់គ្រាប់បែកនៅកម្ពុជា ដែលគេបានទម្លាក់អស់ចំនួន ៣.៦៣០ គ្រាប់។ នេះជាផែនការដ៏សម្ងាត់របស់ប្រធានាធិបតីអាមេរិក Nixon ដើម្បីរើបំរះពីការជាប់ផុងក្នុងសង្គ្រាមនៅវៀតណាម។ ពិតមែនតែកម្ពុជា មិនទាន់ធ្លាក់ទាំងស្រុងទៅក្នុងសង្គ្រាម ប៉ុន្តែការឈឺចាប់របស់ប្រជាជនដែលគ្មានអ្វីការពារខ្លួន ក៏បានកើតឡើង។ សន្តិភាពដែលខ្វះស្ថិរភាពសំរាប់ប្រជាជននៅតាមព្រំដែន បណ្តាលមកពីសង្គ្រាមឈ្លានពានដ៏យូររបស់អាមេរិកនៅវៀតណាមក៏ត្រូវបាត់បង់ទៅដែរ ហើយសន្តិភាព និងឯករាជ្យរបស់ប្រទេសជាតិទាំងមូល ក៏ត្រូវទទួលការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ។*

*ថ្ងៃ ១៨ មីនា ១៩៧០ ភ្នាក់ងារសេអ៊ីអា(C.I.A)នៅភ្នំពេញ បានជំរុញ*

អោយ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ដែលជាដំណាក់កាលចាប់ផ្តើមសង្គ្រាម ហើយក៏ជាដំណាក់កាលបញ្ចប់នូវយុគសម័យអភិវឌ្ឍន៍ដោយសន្តិភាព និងអព្យាក្រិត្យភាព របស់ប្រទេសកម្ពុជាដែរ។

ការទម្លាក់គ្រាប់បែក ដែលចាប់ផ្តើមតាំងពី ១២ ខែ មុនថ្ងៃកើតមានរដ្ឋប្រហារដណ្តើមអំណាចរបស់ លន់ នល់ និងក្រោយពេលដែលរដ្ឋការ លន់ នល់ ឡើងកាន់អំណាច មិនបានជួយកែលំអសភាពការណ៍ដែលចេះតែអាក្រក់ទៅៗ នៃពួកឈ្លានពានអាមេរិក នៅវៀតណាមខាងត្បូងនោះទេ។ ដូចនេះ សេតវិមានបានសំរេចប្រើការឈ្លានពានវិស័យយោធាដោយទ្រង់ទ្រាយធំ វាយសំរុកចូលកម្ពុជា ហើយការសំរេចចិត្តនេះ ត្រូវបាន Nixon ប្រកាសផ្សាយតាមទូរទស្សន៍អាមេរិក នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៧០ ដែលក្នុងនោះ Nixon បានអោយនិយមន័យអំពីការវាយសំរុកចូលឈ្លានពានកម្ពុជាថា ជា "អន្តរាគមន៍ចាំបាច់ ដើម្បីការពារទាហានអាមេរិកនៅវៀតណាម"។ ដូច្នេះមានន័យថា អាមេរិកបានឈ្លានពានប្រទេសមួយរួចទៅហើយ។ ដើម្បីជួយទាហានអាមេរិកនៅប្រទេសដែលខ្លួនឈ្លានពានទីមួយនោះ ចាំបាច់ត្រូវតែឈ្លានពានប្រទេសទីពីរទៀត។ គួររំលឹកដែរថា មុនពេលអាមេរិកសំរេចធ្វើការឈ្លានពានកម្ពុជាដោយទ្រង់ទ្រាយធំ និងដោយចំហរនេះ សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកទំងន់ ១០៤.០០០ តោន មកលើកម្ពុជារួចទៅហើយ គិតពីថ្ងៃ ១៨ ខែមីនា ឆ្នាំ ១៩៦៩ មក ដែលបានធ្វើអាយប្រជាជនស៊ីវិលរាប់ម៉ឺននាក់ត្រូវទទួលរងគ្រោះដោយសារសង្គ្រាមឥតប្រកាសដ៏សាហាវនេះ។

ក្រោយរដ្ឋប្រហារ ១៨ មីនា ១៩៧០ និងក្រោយពេលដែលអាមេរិកបាននាំកងទ័ព ទាំងអាមេរិក ទាំងកងទ័ពនៃរដ្ឋការព្រៃនគរ ចូលមក

កម្ពុជា សភាពការណ៍មានការផ្លាស់ប្តូរក្រឡាប់ចក្រនៅទូទាំងប្រទេស ទីណាក៏ត្រូវចូលក្នុងភ្នក់ភ្លើងសង្គ្រាមទាំងអស់ យើងបានជួបតែនឹង វិនាសកម្មទាំងអាយុជីវិត សាច់ឈាម ទាំងទ្រព្យសម្បត្តិ។ល។ ទោះបីជា អាមេរិកបានដកកងទ័ពថ្មើរជើងចេញពីកម្ពុជាក៏ដោយ ក៏អាមេរិកនៅតែ បន្តសង្គ្រាមតាមផ្លូវអាកាស រហូតដល់ខែសីហា ឆ្នាំ ១៩៧៣ ទើបបាន បញ្ចប់ ហើយបន្តផ្តល់ជំនួយខាងយោធាអោយរបប លន់ នល់ ធ្វើសង្គ្រាម តមកទៀត រហូតដល់ថ្ងៃដួលរលំជាស្ថាពរ។

ក្នុងសង្គ្រាមដ៏កាចសាហាវ រយៈពេលជាង ៥ ឆ្នាំនេះ ដោយសារ អន្តរាគមន៍យោធារបស់អាមេរិក និងពួកក្បត់ស្និតអាមេរិក បានធ្វើអោយ ជីវិតប្រជាជនកម្ពុជាជាង ៦០០.០០០ នាក់ត្រូវស្លាប់ សំណង់ សេដ្ឋកិច្ច វប្ប ធម៌ ភូមិករ ផ្ទះសម្បែង សត្វពាហនៈ ដីស្រែ ព្រៃឈើ ចំការកៅស៊ូ រោង ចក្រ សហគ្រាស ជាច្រើន ត្រូវវិនាស និងត្រូវបំផ្លិចបំផ្លាញខ្ទេចខ្ទី មិនតែ ប៉ុណ្ណោះត្រូវបំផ្លាញដោយការប្រើប្រាស់អាវុធគីមីទៀតផង។ តាមប្រភព ព័ត៌មាន ដែលយើងសរុបបាន អាមេរិក បានទម្លាក់គ្រាប់បែកនៅកម្ពុជា ចំនួនជាង ៥០០.០០០ គ្រាប់ (គឺគ្រាប់បែកមួយគ្រាប់សំរាប់ប្រជាជន ១៥ នាក់) ព្រមទាំងគ្រាប់បែកណាប៉ាល់ រាប់ពាន់តោនទៀតផង។

ការឈ្លានពានរបស់ចក្រពត្តិអាមេរិកនៅកម្ពុជា បានតម្រូវឲ្យប្រជា ជនកម្ពុជាក្រោកឡើងតស៊ូដើម្បីរំដោះជាតិ ហើយការតស៊ូនេះបានរីក ធំធាត់ជាជំហានៗ មានដំបន់រំដោះដ៏ធំទូលាយ ដែលរហូតមកដល់ ដើមឆ្នាំ ១៩៧៥ កម្លាំងរំដោះជាតិត្រួតត្រាបានទឹកដី ជាង ៩០ ភាគរយ ឯរដ្ឋការ លន់ នល់ នៅកាន់កាប់តែទីក្រុងធំៗ តែប៉ុណ្ណោះ។ ការតស៊ូ របស់ប្រជាជនកម្ពុជា ជាការតស៊ូរួមរបស់បណ្តាប្រជាជាតិនៅឥណ្ឌូចិន

ប្រឆាំងនឹងការឈ្លានពានរបស់ចក្រពត្តិអាមេរិក។ ជោគជ័យរបស់ប្រជាជនវៀតណាម-ឡាវ ក្នុងការតស៊ូប្រឆាំងអាមេរិក បានរួមចំណែកយ៉ាងសំខាន់ និងពិតប្រាកដ ដល់ជ័យជំនះរបស់កម្លាំងរំដោះជាតិ នៅកម្ពុជា ក្នុងការផ្តួលរំលំរបបស្និទ្ធអាមេរិករបស់ លន់ នល់ នាថ្ងៃ ១៧ មេសា ១៩៧៩។

រដ្ឋប្រហាររបស់ លន់ នល់ និងការចូលឈ្លានពានរបស់អាមេរិក គឺជាមូលហេតុដំបូងនៃការផ្ទេរដំណាក់កាលសន្តិភាព ចូលក្នុងដំណាក់កាលសង្គ្រាម។ ប្រទេសជាតិត្រូវបែកបាក់ធ្ងន់ធ្ងរ រាប់ទាំងស្មារតី និងចិត្តសាស្ត្រសង្គមផង។ ពេលរបប លន់ នល់ ដួលរលំនាថ្ងៃ ១៧ មេសា ១៩៧៥ ប្រជាជនកម្ពុជាម្នាក់ៗ សង្ឃឹមថានឹងបានឯករាជ្យ មានសន្តិភាព ហើយអាចបង្រួបបង្រួមជាតិឡើងវិញ ដើម្បីកសាងប្រទេស។ ប្រទេសជាច្រើនលើសកលលោកដែលគាំទ្រការតស៊ូរបស់ប្រជាជនកម្ពុជា ប្រឆាំងការឈ្លានពានកាន់កាប់របស់អាមេរិក សុទ្ធតែបានសំដែងនូវការអបអរសាទរ ចំពោះជ័យជំនះដ៏ត្រចះត្រចង់នេះ។ ប៉ុន្តែផ្ទុយទៅវិញ របបថ្មីចូលជំនួសមិនបានប៉ុន្មានម៉ោងផង វិនាសកម្មក៏កើតឡើងយ៉ាងធ្ងន់ធ្ងរជាងពេលមុនទៅទៀត។ សង្គ្រាមបានផ្ទេរពីដំណាក់កាលសង្គ្រាមចំហរមកសង្គ្រាមសម្ងាត់ ពីការឈ្លានពានរបស់បរទេស ដើម្បីត្រួតត្រា និងកាប់សម្លាប់ជាតិខ្មែរ ទៅជាសង្គ្រាមសម្លាប់ជាតិឯង បំរើផលប្រយោជន៍ប្រទេសដ៏ទៃ។ ម្តងនេះ មិនមែនជាសង្គ្រាមដោយគ្រាប់បែក បេ ៥២ គ្រាប់បែកណាប៉ាល់ គ្រាប់ផ្លោងដូចពីមុនទេ តែជាសង្គ្រាមសម្លាប់មនុស្សនឹងពូថៅ កាំបិត ត្បូងចប ចំពុះទុង កាំភ្លើង និងទារុណកម្មរាប់រយប្រភេទខុសៗ គ្នា រាប់ទាំងទារុណកម្មបង្អត់អាហារផង។ លើកនេះ មិនមែនគ្រាន់

តែ មនុស្សធ្លាប់បដិបក្ខខាងនយោបាយនឹងគ្នាតែប៉ុណ្ណោះទេ ដែលត្រូវសម្លាប់ និងទទួលទារុណកម្ម តែ ប្រជាជនក្រីក្រស្លូតត្រង់ កម្មាភិបាល យុទ្ធជន ដែលធ្លាប់រួមតស៊ូជាមួយគ្នា រហូតដល់មិត្តភ័ក្រជិតស្និទ្ធ ហើយជាកម្មាភិបាលជាន់ខ្ពស់ដូចគ្នាទៀតក៏ត្រូវសម្លាប់ និងធ្វើទារុណកម្មដែរ។ ម្តងនេះ មិនមែនគ្រោះថ្នាក់សម្រាប់តែមនុស្សធំប៉ុណ្ណោះទេ តែកុមារ តូចៗ មិនទាន់ដឹងក្តី ក៏រងគ្រោះថ្នាក់ដែរ គឺគ្រោះថ្នាក់ទាំងពូជៗ តកូនតចៅ រហូតដល់វត្ថុគ្មានវិញ្ញាណ ដូចជាសាលារៀន មន្ទីរពេទ្យ វត្តអារាម ទីក្រុង ផ្សារ ធនាគារ ។ល។ ក៏ត្រូវបំផ្លិចបំផ្លាញផងដែរ។ ពោលគឺម្តងនេះ យើងគ្មាននៅសេសសល់អ្វី ក្រៅពីបាតដៃទទេ ហើយរង់ចាំថ្ងៃស្លាប់នោះឡើយ។ ទ្រឹស្តីបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជា បានជំរុញពួក ប៉ុល ពត អោយ នាំប្រជាជនកម្ពុជា ទៅដល់ជ្រោះនៃការប្រល័យពូជសាសន៍។ ការបដិវត្តន៍ទាំងស្រុងលើគ្រប់ផ្នែក និងដោយដាច់ខាត បានតម្រូវអោយពួកនេះ ធ្វើអំពើដ៏សែនព្រៃផ្សៃ មិនអាចរកវិធីកែប្រែបាន ទោះបី ពួកវាបានដឹងខ្លួនថា ជ្រុលខុសហើយក៏ដោយ។

គ្រាន់តែក្នុងរយៈពេល ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃប៉ុណ្ណោះ ប្រជាជនកម្ពុជាចំនួន ៣.៣១៤.៧៦៨ នាក់ បានត្រូវសម្លាប់ ហើយរចនាសម្ព័ន្ធសង្គម ក៏ដូចជាទ្រព្យសម្បត្តិបានត្រូវបំផ្លិចបំផ្លាញខ្ទេចខ្ទីអស់។ នេះជាសង្គ្រាមផ្ទៃក្នុងដ៏សាហាវដែលមិនធ្លាប់មាន ក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ។

ព្រមជាមួយ នឹងការអនុវត្តន៍នយោបាយប្រល័យពូជសាសន៍នៅក្នុងប្រទេស នយោបាយក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ នៃបន ប៉ុល ពត គឺជានយោបាយបិទទ្វារជាមួយពិភពលោកខាងក្រៅ ដែលស្តែងឡើងតាមការកាត់ផ្តាច់ទំនាក់ទំនងការទូត និងការបណ្តេញ

អ្នកការទូតនៃប្រទេសជាច្រើន និងបុគ្គលិកនៃអង្គការអន្តរជាតិ ចេញពីទីក្រុងភ្នំពេញ។ ជាមួយនោះ ក៏បានបង្កឡើងនូវភាពតានតឹងជាមួយប្រទេសជិតខាង ដូចជាការឈ្លានពាន ទៅលើប្រទេសថៃ ដែលកាសែតបាងកកប៉ុស្ត៍ តែងបានលើកមកនិយាយនៅឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៨ ការឈ្លានពានទៅលើឡាវ ហើយធ្ងន់ធ្ងរបំផុតគឺការឈ្លានពានទៅលើ បណ្ដាខេត្តនៃភាគខាងត្បូងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលក្នុងពេលនោះ ប៉ុល ពត បានប្រមូលផ្ដុំ ១៩ កងពលធំ ក្នុងចំណោម ២៣ កងពលធំនៅតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម វាយលុកចូល សម្លាប់មនុស្ស គោក្របី ដុតផ្ទះសម្បែង បំផ្លាញភូមិករ ទ្រព្យសម្បត្តិ ដំណាំដាំដុះអស់ជាច្រើន។

នយោបាយក្នុងប្រទេស និងក្រៅប្រទេសដ៏ល្ងង់ខ្លៅរបស់ពួក ប៉ុល ពត គឺជាមូលហេតុនៃការដួលរលំយ៉ាងឆាប់រហ័សនៃរបបស្រេកឈាមនេះ។

នយោបាយប្រល័យពូជសាសន៍របស់ពួក ប៉ុល ពត បាននាំដល់ការក្រោកឈរឡើងតស៊ូរបស់ប្រជាជនកម្ពុជា នេះជាភាពចាំបាច់ខានមិនបាន។ យើងគួររំលឹកថា អំពើឃោឃៅរបស់ពួក ប៉ុល ពត បានកើតមានឡើង មិនមែនតែនៅក្រោយថ្ងៃ ១៧ មេសា ១៩៧៥ ប៉ុណ្ណោះទេ គឺបានកើតមានតាំងពីមុនប្រទេសបានរំដោះទៅទៀត គ្រាន់តែពេលនោះមាននៅដោយកន្ទ្រង់ខ្វះៗ ហើយធ្វើក្នុងភាពស្ងាត់ស្ងៀម ពិសេសនៅដំបន់ណាដែលបានរំដោះហើយៗ ពួក លន់ នល់ លែងទៅកាន់កាប់វិញបាន ដែលនៅទីនោះ គេលែងត្រូវការមាគ៌ាប្រជាជាតិ គេលែងត្រូវការប្រមូលកម្លាំងប្រឆាំងនឹងសត្រូវហើយ ព្រោះមិនមែនជាដំបន់

ប្រទាញប្រទង់រវាង លន់ នល់ និងដំបន់រំដោះ។ ដូច្នេះ វាអាចអនុវត្តនូវមាគ៌ាប្រជាធិបតេយ្យ ឬការធ្វើបដិវត្តន៍សង្គមនិយមតាមគំនិតរបស់ពួកវាបាន។ ការសម្រិតសម្រាំងក្នុងជួរប្រជាជន ក្នុងជួរកម្មាភិបាល យុទ្ធជន ក៏បានចាប់ផ្តើមឡើង ឯមាគ៌ាសហករណ៍ផលិតកម្ម ក៏បានធ្វើនៅកន្លែងមួយចំនួន ដែលមានកន្លែងខ្លះ ឈានទៅធ្វើរួម ស៊ីរួមហើយដែរ។

ក្នុងស្ថានភាពនេះ ក៏បានបង្កើតឲ្យមានការតស៊ូរបស់ប្រជាជន និងអ្នកស្នេហាជាតិយើង ប្រឆាំងនឹងពួក ប៉ុល ពត តាំងពីមុនឆ្នាំ ១៩៧៥ ហើយក្រោយឆ្នាំ ១៩៧៥ កម្លាំងនេះបានរីកជាបណ្តើរៗ ទោះបីនៅដំបន់ខុសៗ គ្នា និងដោយឡែកៗពីគ្នាក៏ដោយ។ ការបង្ក្រាបមានលក្ខណៈឃោរឃៅបំផុត ដោយទ្រង់ទ្រាយធំ និងដោយចំហររបស់ពួក ប៉ុល ពត ទៅលើបណ្តាខេត្តនៃភូមិភាគបូព៌ាទិសនាខែឧសភា ឆ្នាំ ១៩៧៨ បានធ្វើអោយមានការក្រោកឈរឡើងរបស់ប្រជាជន កម្មាភិបាល យុទ្ធជនទូទាំងភូមិភាគ ធ្វើអោយកម្លាំងតស៊ូប្រឆាំងពួក ប៉ុល ពត មានការរីកចំរើនយ៉ាងឆាប់រហ័ស ហើយឈានទៅបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នាថ្ងៃ២ ធ្នូ ១៩៧៨ ដែលបង្កលក្ខណៈអោយការវាយសំរុករំដោះប្រទេសជាតិ ប្រព្រឹត្តិទៅបានក្នុងពេលដ៏ឆាប់។

គួររំលឹកឡើងវិញ អំពីការរៀបចំកម្លាំង ដើម្បីរំដោះប្រទេសជាតិរបស់ចលនាបដិវត្តនាពេលនោះ។ ដូចបានលើកឡើងខាងលើថា កម្លាំងស្នេហាជាតិ បានកកើតឡើងនៅកន្លែងខុសៗ គ្នា និងពេលវេលាខុសៗ គ្នា ហើយបានមកប្រមូលផ្តុំក្នុងរណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ បើយើងពិនិត្យ មុនពេលបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា កម្លាំងយោធារបស់យើងនៅទូទាំងប្រទេសពេលនោះ មានប្រហែល

៣០ កងវរៈសេនាតូច ដែលប្រមូលផ្តុំសំខាន់នៅភូមិភាគបូព៌ាទិស ភូមិភាគឥសាន និងខេត្តកោះកុង។ ពិនិត្យលើចំនួននេះ ឃើញថាមានច្រើនបន្តិច តែបើប្រៀបធៀបជាមួយចំនួនកងទ័ព ប៉ុល ពត ដែលមានរហូត ២៣ កងពលនោះ ឃើញថាចំនួននេះនៅតិចណាស់ ហើយលក្ខណៈសម្បត្តិនៃការតស៊ូពេលនេះមានការលំបាកច្រើន បើប្រៀបធៀបទៅនឹងការតស៊ូប្រឆាំងចក្រពត្តិអាមេរិក។ ការមិនចាយប្រាក់ ការប្រមូលប្រជាជនអោយទៅរស់នៅ ក្នុងបរិវេណប្រមូលផ្តុំ ធ្វើរួមស៊ីរួម បានធ្វើអោយចលនាតស៊ូរបស់យើងជួបការលំបាក គឺយើងពិបាករកស្បៀងអាហារដើម្បីចិញ្ចឹមកម្លាំងរបស់យើង ដែលត្រូវចូលធ្វើសកម្មភាពជ្រៅក្នុងផ្ទៃប្រទេស។ ក្នុងការប្រៀបធៀបកម្លាំងរបៀបនេះ បានចោទឡើងនូវបញ្ហាថា តើត្រូវរង់ចាំកសាងកម្លាំងអោយបានធំសិន ចាំវាយសំរុករំដោះប្រទេស ឬក៏ត្រូវរំដោះប្រទេសភ្លាម? ពេលនោះ អាស្រ័យដោយខ្វះកម្លាំងក៏មានការគិតគូររបស់កម្មាភិបាលយើងខ្លះថា ត្រូវខិតខំវាយដណ្តើមយកភូមិភាគឥសាន និងភូមិភាគបូព៌ាទិសធ្វើជាឈ្នាន់សិនហើយកសាងកម្លាំង ដើម្បីបន្តទៅវាយរំដោះភ្នំពេញ និងកន្លែងដទៃផ្សេងទៀត។ សភាពការណ៍ក្នុងរបប ប៉ុល ពត សម្រាប់ប្រជាជាតិ និងប្រជាជនយើង បើប្រៀបធៀបទៅនឹងជំងឺ គឺជាជំងឺដែលត្រូវសង្គ្រោះបន្ទាន់ មិនអាចរង់ចាំ ឬពន្យាពេលបានទេ ដូច្នេះ ចាំបាច់ត្រូវរំដោះប្រទេស និងប្រជាជនជាបន្ទាន់។

តើត្រូវរំដោះប្រទេសយ៉ាងដូចម្តេច ក្នុងសភាពការណ៍ដែលយើងខ្វះកម្លាំង បើប្រៀបធៀបទៅនឹងកម្លាំងរបស់ពួក ប៉ុល ពត ដែលមានចំនួនយ៉ាងច្រើន ហើយបានទទួលជំនួយយ៉ាងសន្ធឹកសន្ធាប់ពីចិនផងនោះ ហើយដែលពេលនោះ ការឃុបឃិតចិន-អាមេរិក កំពុងឡើងដល់កំរិត

កំពូលទៀតផង។ ជាងនេះទៅទៀត ថ្វីត្បិតតែប្រទេសប៉ែកខាងលិចមួយចំនួន ក្នុងនោះមានប្រធានាធិបតីអាមេរិក *Carter* ជាអាទិ៍ បានចោទប្រកាន់ពួក ប៉ុល ពត ថា រំលោភលើសិទ្ធិមនុស្សនៅកម្ពុជាក៏ដោយ ក៏គ្មានប្រទេសប៉ែកខាងលិចណាមួយ ឬប្រទេសអាស៊ានណាមួយអើពើពីទុក្ខវេទនារបស់ប្រជាជនកម្ពុជាឡើយ។ ឯថៃជាប្រទេសមានព្រំដែនជាប់ជាមួយកម្ពុជាធ្លាប់ត្រូវពួក ប៉ុល ពត វាយប្រហារ ហើយទោះបីពេល ប៉ុល ពត កាន់អំណាចនៅលើទឹកដីកម្ពុជា មានជំរំបណ្តោះបណ្តាលកម្លាំងប្រឆាំងនឹងរដ្ឋាភិបាលថៃក៏ដោយ ក៏ដំណាក់កាលចុងក្រោយនៃរបប ប៉ុល ពត ថៃបានក្លាយទៅជាសមរភូមិក្រោយអោយកម្លាំង ប៉ុល ពត ក្នុងការធ្វើសង្គ្រាមប្រឆាំងប្រទេសវៀតណាម ប្រឆាំងកម្លាំងតស៊ូរបស់ប្រជាជនកម្ពុជា។ ហាក់ដូចជាបានដឹងមុន អំពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលជារបបក្រោមបង្គាប់ខ្លួននោះ ចិន បានធ្វើសកម្មភាពការទូតយ៉ាងមមាញឹកដើម្បីដោះស្រាយជម្លោះកម្ពុជា-ថៃ ដូចជានាថ្ងៃទី ៩ វិច្ឆិកា ១៩៧៨ តេង ស៊ីវពីង (*Deng Xiao Ping*) ដែលជាឧបនាយករដ្ឋមន្ត្រី សាធារណរដ្ឋប្រជាមានិតចិន បានធ្វើដំណើរទៅកាន់ប្រទេសថៃ ដើម្បីចរចាជាមួយមេដឹកនាំថៃដោយផ្តោតជាសំខាន់លើការដោះស្រាយជម្លោះកម្ពុជា-ថៃ ។ តេង ស៊ីវពីង បានធានាចំពោះអ្នកដឹកនាំថៃថា កងទ័ព ប៉ុល ពត នឹងមិនវាយប្រហារតំបន់ព្រំដែនថៃទៀតឡើយ។ ជាថ្នូរត្រឡប់មកវិញ ចិន បានទទួលការអនុញ្ញាតអោយប្រើប្រាស់ដែនអាកាសថៃ សំរាប់ការដឹកជញ្ជូនកសុ្តការផ្គត់ផ្គង់អោយកងទ័ព ប៉ុល ពត។ មុននោះប៉ុន្មានខែ គឺ នៅថ្ងៃ ១៤ កក្កដា ១៩៧៨ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសកម្ពុជាប្រជាធិបតេយ្យ បានទៅប្រទេសថៃ ហើយបានសន្យាជាមួយអ្នកដឹកនាំថៃថា នឹងបញ្ចប់នូវ

ការប្រទូស្តរាយផ្នែកយោធា ដែលបង្កឡើងដោយកម្ពុជាប្រជាធិបតេយ្យ ក្នុងរយៈពេលកន្លងមក។

ដូច្នេះ ដោយមានការជួយឧបត្ថម្ភពីចិន ពួក ប៉ុល ពត បានអូសទាញថៃ ធ្វើជាសមរភូមិក្រោយរបស់ខ្លួន ដែលកាន់តែជាហេតុធ្វើអោយពួក ប៉ុល ពត បានចិត្តក្នុងការប្រើដៃក្តៅ ជាមួយប្រជាជនកម្ពុជាផង និងឈ្លានពានវៀតណាមផង។ ដើម្បីទប់ស្កាត់នូវការរើបំរះរបស់ប្រជាជន និងការថ្កោលទោសពីសាធារណៈមតិលើសកលលោក ពួក ប៉ុល ពត ក៏បានត្រៀមផ្លាស់ប្តូរមុខមាត់នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដោយបានប្រមូលមកវិញនូវឥស្សរជន បញ្ញវន្ត ដែលមានឈ្មោះល្បីល្បាញមួយចំនួន ត្រៀមបញ្ចូលទៅក្នុងគណៈរដ្ឋមន្ត្រី ដើម្បីប្រែក្លាយអោយទៅជាទម្រង់រដ្ឋាភិបាលមួយប្រហាក់ប្រហែលរដ្ឋាភិបាល សីហនុ ពីមុន តែផែនការនេះមិនអាចធ្វើទៅបាន អាស្រ័យដោយការដួលរលំឆាប់រហ័សពេក។ ជាមួយនោះ ចិន ក៏ដូចជាពួក ប៉ុល ពត បានធ្វើសកម្មភាពការទូតដ៏មមាញឹកបំផុត ដោយលើកឡើងនូវរបស់ដែលហៅថា "ការឈ្លានពានរបស់វៀតណាមមកលើកម្ពុជា" ដែលជាការត្រៀមរៀបចំអុជអាលសាធារណមតិសម្រាប់ពេលមានអាសន្ននៃរបបកម្ពុជាប្រជាធិបតេយ្យ។

ឆ្លងតាមសភាពការណ៍នយោបាយ ទាំងក្នុងប្រទេស និងក្រៅប្រទេស ពេលនោះគ្មានច្រកណាចេញ ក្រៅពីការស្នើសុំជំនួយដ៏សប្បុរសពីសំណាក់សាធារណរដ្ឋសង្គមនិយមវៀតណាមនោះទេ។ ប្រទេសដែលមានលទ្ធភាពផ្តល់ជំនួយ និងមានលទ្ធភាពជួយ មានតែវៀតណាមមួយគត់ គួបនឹងការជួយឧបត្ថម្ភពីឡាវ និងបណ្តាប្រទេសសង្គមនិយម។ ថៃ ទោះបីបានជួយពួកខ្មែរសេរីជាច្រើនក្រុម ដែលពួកនេះមានគោលដៅ

ប្រឆាំង ប៉ុល ពត ក៏ដោយ នៅពេលនោះ មិនត្រឹមតែមិនអើពើចំពោះទុក្ខវេទនារបស់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ តែថែមទាំងគាំទ្រនយោបាយកាប់សម្លាប់របស់ ពួក ប៉ុល ពត ទៀតផង ដែលជាក់ស្តែង ថៃបានក្លាយជាមូលដ្ឋានបង្អែកខាងក្រោយអោយពួកកម្ពុជាប្រជាធិបតេយ្យរួចទៅហើយ។

ការឆ្លើយតបរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ចំពោះសំណូមពរប្រជាជនកម្ពុជា គឺបានបង្កឡើងនូវការប្រៀបធៀបកំលាំងថ្មី នៅលើសមរភូមិកម្ពុជា ជាបង្អែកក្រោយខ្នងដ៏រឹងមាំនៃកម្លាំងស្នេហាជាតិ ហើយបានធ្វើអោយកម្លាំងនេះរីកចំរើនធំធាត់យ៉ាងឆាប់រហ័ស មានលទ្ធភាពអាចឈានទៅវាយសម្រុកបាន។

នយោបាយប្រតិកិរិយាក្នុងប្រទេស និងក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ គឺជាវត្ថុធាតុពីរគួបផ្សំគ្នាសំរាប់អវសាននៃរបប ប៉ុល ពត។ ព្រមពេលដែលការបង្ក្រាប និងការកាប់សម្លាប់ចំពោះប្រជាជនកម្ពុជាបានប្រព្រឹត្តិទៅកាន់តែខ្លាំងនោះ កម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត បានប្រមូលផ្តុំកងទ័ពចំនួន ១៩ កងពល ក្នុងចំណោម ២៣ កងពល វាយសម្រុកចូលទៅលើតំបន់ព្រំដែន នៃ បណ្តាខេត្តភាគខាងត្បូងវៀតណាម ពិសេសនាខែធ្នូ ឆ្នាំ ១៩៧៨។ សភាពការណ៍គឺបានទុំជោរសម្រាប់ការបញ្ចប់ជីវិតរបបកម្ពុជាប្រជាធិបតេយ្យ ឱកាសនៃការធ្វើបដិវត្តន៍ប្រជាជនកម្ពុជា បានមកដល់ព្រមពេលគ្នា ដែលរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ទើបត្រូវបានបង្កើតឡើង។ ទោះបីលក្ខណសម្បត្តិអន្តរជាតិសំរាប់រណសិរ្សថ្មីរបស់យើង មិនទាន់អនុគ្រោះធំទូលាយក៏ដោយ ក៏លក្ខណៈសម្បត្តិផ្ទៃក្នុង មានភាពអនុគ្រោះអោយការធ្វើកុប្បកម្មរបស់ប្រជាជន

ដើម្បីផ្តួលរំលំពួក ប៉ុល ពត ហើយកត្តាដែលសំខាន់បំផុត គឺ ពួក ប៉ុល ពត ត្រូវបាត់បង្អែកខាងនយោបាយពីប្រជាជន។ ប្រជាជនចង់កំហឹងយ៉ាងខ្លាំងចំពោះរបបនេះ កម្លាំងបដិវត្តបានរីកធំធាត់ ព្រមពេលដែលកម្លាំងយោធា ប៉ុល ពត ត្រូវកងទ័ពវៀតណាមវាយបំបាក់យ៉ាងធ្ងន់ធ្ងរពិសេស នាថ្ងៃទី ២២ ធ្នូ ១៩៧៨។

ការដែលវៀតណាម បានវាយបំបាក់បណ្តាកងទ័ពដែលល្អបំផុត និងកងពលផ្សេងទៀត ស្ទើរតែទាំងអស់របស់ពួក ប៉ុល ពត បានធ្វើអោយការប្រៀបធៀបកម្លាំង កាន់តែមានភាពអនុគ្រោះអោយដល់កម្លាំងបដិវត្តកម្ពុជា ហើយធ្វើអោយសភាពការណ៍យោធាមានការវិវត្តន៍ឆាប់រហ័ស លើសពីការគ្រោងទុកទៅទៀត។ ឆ្លើយតបនឹងសេចក្តីអំពាវនាវរបស់ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា តែក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ កុប្បកម្មប្រជាជនបានរីករាលដាលទូទាំងប្រទេស។ កងទ័ពបដិវត្ត ដោយមានការជួយឧបត្ថម្ភពីកងទ័ពស្ម័គ្រចិត្តវៀតណាម និងមានការចូលរួម ពីសំណាក់ប្រជាជនដ៏ច្រើនកុះករនៅទូទាំងប្រទេសផង បានវាយសម្រុកយ៉ាងលឿន រំដោះបណ្តាខេត្តភាគខាងកើតប្រទេស ដែលក្នុងបណ្តាខេត្តនេះ ស្រុកមួយចំនួនបានរំដោះតាំងពីក្នុងរដូវវស្សាឆ្នាំ ១៩៧៨ មក ហើយតម្រង់មុខព្រួញចូលរំដោះទីក្រុងភ្នំពេញ នាថ្ងៃទី ៧ មករា ឆ្នាំ ១៩៧៩ និងបណ្តាខេត្តនៃភាគខាងលិចប្រទេស ជាបន្តបន្ទាប់រុញពួក ប៉ុល ពត អោយចូលទៅក្នុងប្រទេសថៃ និងព្រៃភ្នំភាគខាងលិចកម្ពុជា។

នយោបាយអត្តឃាតខ្លួនឯងរបស់ពួក ប៉ុល ពត បានជំរុញអោយសភាពការណ៍វិវត្តយ៉ាងឆាប់ សូម្បីតែ ហ្គេន ពាវ(Geng Biao) សមាជិក

*ការិយាល័យនយោបាយបក្សកុម្មុយនិស្តចិន ក៏បានទទួលស្គាល់ថា "ភ្នំពេញបានបាត់បង់ ៧ ខែមុនដែលគេបានព្រាងទុក"។ ដូច្នេះ ទាំងចិន ទាំងពួក ប៉ុល ពត មិនអាចរៀបចំអ្វីទាន់ទេ សូម្បីតែផែនការផ្លាស់ប្តូរមុខមាត់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរបស់ពួក ប៉ុល ពត ក៏ធ្វើមិនទាន់ផង។ ប៉ុន្តែជាសំណាងល្អ គេបានអូសទាញថៃ អោយធ្វើសមរភូមិក្រោយបានមុន ដែលនាំអោយគេអាចការពារកម្លាំងបានខ្លះ ក្នុងនោះមានទាំងទីប្រឹក្សាចិនដែលរត់ឆ្លងកាត់ព្រំដែនពីកម្ពុជាទៅថៃផង ហើយគេបានជម្លៀសសម្តេច សីហនុ និងឥស្សរជនមួយចំនួនចេញទៅទាន់ដើម្បីបង្កើតជាកម្លាំងប្រឆាំងរដ្ឋាភិបាលថ្មីរបស់យើងរហូតមកទល់សព្វថ្ងៃនេះ។*

*ការដួលរលំនៃរបប ប៉ុល ពត វាជាក្រឹត្យក្រមសត្យានុម័ត ដែលត្រូវតែកើតមានសម្រាប់សង្គមអយុត្តិធម៌ទាំងអស់ វាមិនមែនជាការដួលរលំដោយការឈ្លានពានរបស់បរទេស ដូចជា របប សីហនុ ដែលការដួលរលំនោះ ចេញមកពីការផ្តួលរំលំ និងឈ្លានពានរបស់អាមេរិក ដែលអាមេរិកបានដាក់ ក្នុងយុទ្ធសាស្ត្រឈ្លានពានឥណ្ឌូចិនទាំងមូលនោះទេ។ ការដួលរលំនៃរបប ប៉ុល ពត វាផ្ទុះចេញមកពីទំនាស់ផ្ទៃក្នុងរបស់វា។ ប្រសិនបើគ្មានការកាប់សម្លាប់ គ្មានការបង្ក្រាបនោះទេ វាពិតជាគ្មានការក្រោកឈរឡើងតស៊ូរបស់ប្រជាជនកម្ពុជា ហើយបើគ្មានកម្លាំងប្រជាជនកម្ពុជាតស៊ូ ក៏មិនអាចនាំដល់ការជួយឧបត្ថម្ភរបស់ វៀតណាមនោះដែរ។ វៀតណាម មិនអាចមកជួយបានទេ ប្រសិនបើគ្មានការតស៊ូរបស់ប្រជាជនកម្ពុជា ដែលត្រូវការជំនួយឧបត្ថម្ភពីខ្លួននោះ។ បញ្ហានេះ វាបានកើតមាននៅប្រទេសជាច្រើន នៅលើសកលលោកនេះ*

ដូចជានៅ អ៊ូហ្គង់ដា (*Ouganda*) ដែលត្រូវការជំនួយឧបត្ថម្ភពី តង់ហ្សានី (*Tanzanie*) ដើម្បីផ្តួលរំលំរបប អ៊ីឌី អាមីន (*Idi Amin*) ជាដើម។

ប្រភពកើតឡើងនៃបញ្ហាកម្ពុជា គឺនយោបាយប្រល័យពូជសាសន៍របស់ ប៉ុល ពត ហើយនោះគឺជាមូលហេតុដែលនាំដល់ការដួលរលំយ៉ាងឆាប់រហ័សនៃរបប ប៉ុល ពត ដែរ។ បញ្ហាកម្ពុជា វាចាប់កើតឡើងពីបញ្ហាផ្ទៃក្នុង បន្ទាប់មកវាបានកើតមានផ្នែកអន្តរជាតិ ដែលតភ្ជាប់ជាមួយផ្នែកផ្ទៃក្នុង ប៉ុន្តែផ្នែកផ្ទៃក្នុងវាជាឫសគល់នៃបញ្ហាទាំងមូល។ ពិតមែនហើយ គេអាចដឹងបានតាំងពីមុនម្ល៉េះថា តើពួក ប៉ុល ពត ឋិតនៅក្រោមឥទ្ធិពលរបស់ប្រទេសណា។ ចិន បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយពួក ប៉ុល ពត អោយអនុវត្តនយោបាយប្រល័យពូជសាសន៍នៅកម្ពុជា និងអោយធ្វើសង្គ្រាមប្រឆាំងនឹងប្រទេសជិតខាង ហើយចំនុចជាច្រើននៃនយោបាយរបស់ចិនចំពោះកម្ពុជា គឺយើងបានចុះផ្សាយក្នុងសៀវភៅស ដែលមានចំណងជើងថា "ឧក្រិដ្ឋកម្មរបស់អ្នកកាន់អំណាចចិន ចំពោះកម្ពុជា" បោះផ្សាយដោយក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា នាខែ មេសា ឆ្នាំ ១៩៨៤។

បដិវត្តន៍កម្ពុជា បានដើរត្រឹមត្រូវតាមក្រឹត្យក្រមនៃបដិវត្តន៍ ទោះបីជ័យជំនះថ្ងៃ ០៧ មករា ១៩៧៩ ត្រូវបានប្រើប្រាស់កម្លាំងពីរតួបផ្សំគ្នា គឺកម្លាំងជាតិ និងការជួយឧបត្ថម្ភពីកងទ័ពស្ម័គ្រចិត្តវៀតណាម ហើយដែលកងទ័ពវៀតណាម មានតួនាទីយ៉ាងសំខាន់ក្នុងការកំចាត់ពួក ប៉ុល ពត ក៏ដោយ ក៏កម្លាំងផ្ទាល់របស់បដិវត្តន៍កម្ពុជាមានតួនាទីកំណត់។ និយាយអោយខ្លីទៅការបដិវត្តន៍នៅប្រទេសណាក៏ដោយ គឺត្រូវតែប្រជាជនប្រទេសនោះជាអ្នកធ្វើ គ្មានប្រទេសណាមកជំនួសបានឡើយ។ ឯការជួយឧបត្ថម្ភពីខាង

ក្រៅ វាចេញមកពីសំណូមពរនៃកត្តាខាងក្នុង បើមិនដូច្នោះទេ វានឹងធ្លាក់ទៅក្នុងការឈ្លានពានផ្តួលរំលំ។ បដិវត្តន៍កម្ពុជា វិវត្តន៍ទៅតាមក្រឹត្យក្រមនេះឯង ពោលគឺមានចលនាតស៊ូបដិវត្តនៅខាងក្នុង បន្ទាប់មកទើបទាំដល់ការជួយឧបត្ថម្ភរបស់វៀតណាម ដែលការជួយឧបត្ថម្ភនេះ គឺឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាជនកម្ពុជា។

ជ័យជំនះថ្ងៃ ០៧ មករា ១៩៧៩ គឺជារបត់មួយក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលបានអនុញ្ញាតិអោយប្រជាជនរាប់លាន ដែលសេសសល់ពីស្លាប់ បានរស់រានមានជីវិតឡើងវិញ ហើយមានលទ្ធភាពនឹងកសាងជីវិតថ្មី ក្រោមរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ជាមួយនោះ ការរលំរលាយនៃកម្ពុជាប្រជាធិបតេយ្យ ដែលជាក្អែកភ្លើងបង្កភាពតានតឹងជាអចិន្ត្រៃយ៍ដល់សន្តិភាព ស្ថេរភាពនៅអាស៊ីអាគ្នេយ៍ ពិសេសជាមួយប្រទេសជិតខាងបានត្រូវរលត់ទៅដែរ។ ប្រជាជនកម្ពុជា-វៀតណាម-ឡាវ មានលទ្ធភាពនឹងស្តារឡើងវិញ នូវចំណងមិត្តភាពដែលបានត្រូវបាត់បង់ដោយរបប ប៉ុល ពត ហើយរស់នៅជិតខាងគ្នាដោយល្អដើម្បីកសាងប្រទេស បន្ទាប់ពីសង្គ្រាមអស់រយៈពេលយ៉ាងយូរមក។

ជ័យជំនះរបស់ប្រជាជនកម្ពុជាទៅលើរបបស្រេកឈាម ប៉ុល ពត បានបង្កើតឡើងនូវ ការសប្បាយរីករាយចំពោះមនុស្សរាប់លាន នៅបណ្តាប្រទេសជាច្រើន ដោយគេចាត់ទុកថា ជាជ័យជំនះនៃយុត្តិធម៌ និងមនុស្សធម៌។

ប៉ុន្តែ ការដួលរលំនៃរបស់ដែលហៅថា កម្ពុជាប្រជាធិបតេយ្យ និងការបង្កើតឡើងនូវរដ្ឋមួយដែលស្នេហាសន្តិភាព និងយុត្តិធម៌នៅលើទឹកដីកម្ពុជា មិនបានជាការពេញចិត្ត ចំពោះប្រទេសមួយចំនួនឡើយ

ពិសេសសំរាប់ ចិន ដែលជាមេកោយរបស់ពួក ប៉ុល ពត និងអាមេរិក ដែលបានចាកចេញពីឥណ្ឌូចិនទាំងអស់សង្ឃឹម ហើយចិញ្ចឹមចិត្តនឹងធ្វើការសងសឹកចំពោះវៀតណាម ចង់បង្កើនវត្តមានរបស់ខ្លួននៅអាស៊ីអាគ្នេយ៍ ហើយដែលកំពុងសកម្មក្នុងការអូសទាញ ចិន ចូលក្នុងល្បែងប្រឆាំងសហភាពសូវៀត ប្រឆាំងសង្គមនិយម។ ទាំងអស់នេះបានក្លាយទៅជាចំណុចជួបគ្នារវាងមហាអំណាចទាំងពីរ នៅលើរបស់ដែលហៅថា "បញ្ហាកម្ពុជា" ហើយដែលអ្នកទាំងពីរ បានខិតខំយ៉ាងខ្លាំងក្នុងការអូសទាញសម្ព័ន្ធមិត្ត ចូលក្នុងយុទ្ធសាស្ត្រប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ដូច្នេះទោះបីប្រទេសកម្ពុជាត្រូវបានរំដោះក៏ដោយ ប៉ុន្តែសង្គ្រាមក៏នៅមិនទាន់បានបញ្ចប់នៅឡើយទេ ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ ដែលយើងធ្លាប់ហៅសភាពការណ៍នេះថាជា "ដំណាក់កាលមានសន្តិភាពផង និងមានសង្គ្រាមផង"។

ថ្ងៃ ៧ មករា ១៩៧៩ ទឹកដី និងប្រជាជនកម្ពុជា ត្រូវបានរំដោះពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ប៉ុន្តែ ដូចបានដឹងរួចមកហើយថា របប ប៉ុល ពត គ្មានបានបន្សល់ទុកអ្វីក្រៅពីផលវិបាករាប់មិនអស់ដែលប្រជាជន និងរដ្ឋអំណាចថ្មី ត្រូវដោះស្រាយនោះទេ។ ទឹកដីបានរំដោះយ៉ាងឆាប់ តែស្ថិតនៅក្នុងស្ថានភាពដ៏ច្របូកច្របល់។ រដ្ឋអំណាចប្រតិកិរិយាបានដួលរលំទៅ រដ្ឋអំណាចថ្មីទើបបានកកើតឡើងមិនទាន់ពេញរូបរាង ជួរកម្មាភិបាលមិនមានគ្រប់គ្រាន់ ក្នុងពេលដែលប្រជាជនរាប់លាននាក់ ត្រូវទទួលការគំរាមកំហែងពីការអត់ឃ្លាន ព្រមទាំងត្រូវធ្វើដំណើរពេញផ្ទៃប្រទេស ដើម្បីស្វែងរកក្រុមគ្រួសារ និងវិលត្រឡប់ទៅស្រុកកំណើតវិញ។ ពួក ប៉ុល ពត ថ្វីត្បិតតែបានចាញ់ ប៉ុន្តែនៅតែ

មានគោលបំណងវិលត្រឡប់ មកដណ្ដើមរដ្ឋអំណាចនៅតាមមូលដ្ឋាន ក៏ដូចជានៅទូទាំងប្រទេស និងក្នុងពេលដែលកម្លាំងប្រដាប់អាវុធបដិវត្តកម្ពុជាមានតិច ហើយត្រូវបំពេញភារកិច្ចជួយប្រជាជន ឆ្លងកាត់នូវការលំបាកនាគ្រាដំបូងផងៗ ពេលនោះកម្លាំងប្រដាប់អាវុធយើងត្រូវបែកទៅនៅតាមខេត្តនិមួយៗ ពី ១ ឬ ២ កងវរៈសេនាតូចប៉ុណ្ណោះ។ មានតែទីក្រុងភ្នំពេញទេដែលមានប្រហែលមួយកងពលតូចៗ ក្នុងសភាពការណ៍បែបនេះ តម្រូវអោយបក្ស និងរដ្ឋ មានសំណូមពររក្សាទុកកងទ័ពស្ម័គ្រចិត្តវៀតណាមបន្តទៀត តាមរយៈសន្ធិសញ្ញាសន្តិភាព មិត្តភាព និងសហប្រតិបត្តិការ កម្ពុជា-វៀតណាម ចុះហត្ថលេខានៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ១៩៧៩ ក្នុងដំណើរទស្សនកិច្ចជាមិត្តភាព និងជាផ្លូវការរបស់គណៈប្រតិភូជាន់ខ្ពស់បក្ស និងរដ្ឋ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដឹកនាំដោយ នាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង នៅកម្ពុជា។ គោលបំណងសំខាន់ ក្នុងការរក្សាទុកវត្តមានកងទ័ពវៀតណាមនៅកម្ពុជា គឺដើម្បីប្រឆាំងនឹងការវិលត្រឡប់មកកាន់អំណាចសាជាថ្មីរបស់ពួក ប៉ុលពត ការពារភាពសុខសាន្តរបស់ប្រជាជនកម្ពុជា ប្រឆាំងនឹងការគំរាមកំហែងពីអានុភាពប្រតិកិរិយាគ្រប់ប្រភេទ។

ការគួបផ្សំកម្លាំងពីរ កម្ពុជា និងវៀតណាម បាននាំមកនូវស្ថិរភាពជាជំហានដំបូង ដើម្បីចាប់ផ្ដើមនូវកិច្ចការដែលត្រូវធ្វើ។

## ថ្ងៃមុនប្រឆាំង ប៉ុល ពត
## ថ្ងៃនេះរួមជាមួយ ប៉ុល ពត
## ប្រឆាំងប្រជាជនកម្ពុជា

សភាពការណ៍នាគ្រាដំបូងមានសភាពស្មុគ្រស្មាញ ទាំងនៅផ្ទៃក្នុងកម្ពុជា ទាំងសកម្មភាពអន្តរជាតិជុំវិញបញ្ហាកម្ពុជា។ នៅខាងក្រៅ ការឃុបឃិតជុំវិញបញ្ហាកម្ពុជាមានសកម្មភាពដ៏មមាញឹក។ ចិន បានសន្ទឹកបៀរដ៏ល្អមួយដើម្បីប្រើប្រាស់ក្នុងការឃុបឃិតជាមួយអាមេរិក អូសទាញប៉ែកខាងលិច និងអាស៊ាន អោយចូលក្នុងយុទ្ធសាស្ត្រប្រឆាំងឥណ្ឌូចិន ប្រឆាំងសហភាពសូវៀត អូសទាញទុន និងបច្ចេកទេស របស់អាមេរិក និងលោកខាងលិច ដើម្បីទំនើបភាវូបនីយកម្ម ៤ យ៉ាងរបស់ខ្លួន។ អាមេរិកក៏បានប្រើប្រាស់បញ្ហាកម្ពុជា ដើម្បីទាក់ទាញ ចិន ប្រឆាំងសូវៀត និងសងសឹកវៀតណាម ព្រមទាំងបង្កើន ឥទ្ធិពលខ្លួននៅអាស៊ីអាគ្នេយ៍ឡើងវិញ។ ព្រួញនៃមហាអំណាចទាំងពីរ បានបាញ់ចំគោលដៅតែមួយ ដែលតាមរយៈនៃបញ្ហានេះបានរុញអ្នកទាំងពីរអោយចូលជិតគ្នា ទោះបីគោលដៅជាយុទ្ធសាស្ត្រយូរអង្វែង មានការខុសគ្នាក៏ដោយ។ ចេញពីចំណុចរួមគ្នានេះ មហាអំណាចទាំងពីរ ចាប់ផ្តើមចលនាសម្ព័ន្ធមិត្ត ដើម្បីបង្កើតឡើងនូវរណសិរ្សប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវៀតណាម។

មុនពេលដែលរបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ដួលរលំ ចិន បានអូសទាញថៃអោយធ្វើជាសមរភូមិក្រោយរបស់ពួក ប៉ុល ពត រួចទៅ

ហើយសម្រាប់ពេលដែលវាចាញ់។ ក្រោយពេលរបបកូនជីងរបស់ខ្លួនដួលរលំក្នុង ដើម្បីស្រោចស្រង់នូវពួកកាកសំណល់ ប៉ុល ពត ហើយដើម្បីអាចបន្តសង្គ្រាមបានតទៅទៀតនោះ ចិនបានបញ្ជូន ហ្គេន ពាវ ដែលពេលនោះជា លេខាគណៈកម្មការយោធានៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ និង ហាន នានឡុង (*Han Nian-long*) អនុរដ្ឋមន្ត្រីការបរទេសចិន ទៅទីក្រុង បាងកក។ ក្នុងការជួបគ្នាជាសម្ងាត់ជាមួយនាយករដ្ឋមន្ត្រីថៃ នាថ្ងៃទី ១៣ មករា ១៩៧៩ ហ្គេន ពាវ បានសុំអោយថៃជួយផ្តល់ជំរកដល់ពួកបាក់ទ័ព ប៉ុល ពត សុំអោយចិនដឹកអាវុធឆ្លងកាត់ប្រទេសថៃទៅអោយពួក ប៉ុល ពត ព្រមទាំងសុំអោយថៃបញ្ចុះបញ្ចូលបណ្តាប្រទេសអាស៊ាន កុំអោយទទួលស្គាល់រដ្ឋាភិបាលថ្មីនៅកម្ពុជា។ កិច្ចព្រមព្រៀងមួយត្រូវបានបង្កើតឡើងក្នុងពេលជាមួយគ្នានេះ ស្តីពីការប្រើប្រាស់ទឹកដីថៃ ដើម្បីផ្គត់ផ្គង់ដល់ពួកបាក់ទ័ព ប៉ុល ពត។ ដើម្បីជាថ្នូរចំពោះការដែលថៃព្រមជួយពួក ប៉ុល ពត ចិនបានយល់ព្រមទទួលនូវការទាមទាររបស់ថៃ គឺ ចិន ត្រូវឈប់ផ្តល់ជំនួយអោយពួកកុម្មុយនិស្តស្និទ្ធនឹង ចិន ប្រឆាំងនឹងរដ្ឋាភិបាលថៃ។ ប្រការនេះ បាននាំដល់ភាពខ្ទេចខ្ទាំនៃ កម្លាំងកុម្មុយនិស្តម៉ៅនិយមនាប៉ុន្មានឆ្នាំក្រោយមក។ ក្រៅពីការទាក់ទាញថៃ ចិនបានខិតខំយ៉ាងសកម្ម ក្នុងការអូសទាញបណ្តាប្រទេសអាស៊ាន ដើម្បីចូលក្នុងរណសិរ្សប្រឆាំងកម្ពុជា និងវៀតណាម។ ដើម្បីធ្វើអោយបណ្តាប្រទេសអាស៊ាន ដែលធ្លាប់ព្រួយបារម្ភពីការជ្រៀតជ្រែករបស់ចិន ស្ងប់ចិត្ត ហើយចូលរួមរណសិរ្សជាមួយចិននោះ នៅខែ ១១ ឆ្នាំ ១៩៧៨ ក្នុងដំណើរទស្សនកិច្ចទៅប្រទេសថៃ តេង ស៊ីវពីង បានអំពាវនាវអោយថៃ និងបណ្តាប្រទេសអាស៊ាន រួមជាមួយចិន ប្រឆាំងអនុត្តរភាព

ពិភពលោក និងអនុត្តរភាពដំបន់ៗ គេង ស៊ីវពីង បានបញ្ជាក់ផងដែរនូវការសន្យារបស់ចិនគឺ "មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់បណ្តាប្រទេសអាស៊ាន"។ តាមការសង្កេតមើលអំពីយុទ្ធសាស្ត្រឃើញថា ចិនបានអនុវត្តយុទ្ធសាស្ត្រខុសប្លែកពីអាមេរិក ក្នុងការប្រឆាំងបណ្តាប្រទេសនៅឥណ្ឌូចិនៗ មុននោះ ក្នុងពេលអាមេរិកឈ្លានពានឥណ្ឌូចិន អាមេរិកបានអូសទាញបណ្តាប្រទេសអាស៊ាន អោយគាំទ្រខ្លួន តែអាមេរិក បានដើរពីមុខ ហើយអាស៊ានដើរពីក្រោយៗ ម្តងនេះ ចិនមានតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើសង្គ្រាមប្រឆាំងបណ្តាប្រទេសនៅឥណ្ឌូចិន ប៉ុន្តែបានរុញអាស៊ានអោយនៅពីមុខ ហើយចិននៅពីក្រោយ ដែលសំខាន់បំផុតគឺគេរុញថៃអោយទៅជាសមរភូមិមុខជាមួយ កម្ពុជា-វៀតណាម-ឡាវ តែដោយថៃជាសមាជិកនៃសមាគមអាស៊ាន គេអាចអូសទាញសមាជិកផ្សេងទៀតនៃអង្គការអាស៊ានដើម្បីប្រឈមមុខជាមួយឥណ្ឌូចិនៗ បញ្ហានេះ ចិន បានទទួលចំណេញយ៉ាងច្រើន ក្នុងការធ្វើសង្គ្រាមប្រឆាំងឥណ្ឌូចិនផង និងអូសទាញក្នុងការធ្វើទំនាក់ទំនងជាមួយអាស៊ានផងៗ បញ្ហានេះ ចិនទទួលជោគជ័យក្នុងការប្រមូលអាស៊ាន ប្រឆាំងបណ្តាប្រទេសឥណ្ឌូចិន ហើយស្ទើរតែគ្រប់សកម្មភាពការទូតទាក់ទងនឹងបញ្ហាកម្ពុជា អាស៊ានជាអ្នកឈរមុខ រាប់ទាំងសេចក្តីសំរេចរបស់អង្គការសហប្រជាជាតិផង គឺអាស៊ានជាអ្នកព្រាងឡើងៗ

នៅក្នុងប្រទេសថៃ ទន្ទឹមនឹងការមមាញឹកដើម្បីរៀបចំជំរកអោយពួកបាក់ទ័ព ប៉ុល ពត ការដឹកអាវុធ គ្រាប់រំសេវ ស្បៀងអាហារផ្តល់ដល់ពួកនេះ គេចាប់ផ្តើមបង្វែរទិស នៃក្រុមប្រដាប់អាវុធរបស់ពួកខ្មែរសេរីជាច្រើនក្រុម ដែលថៃធ្លាប់ជួយចិញ្ចឹម និងប្រើប្រាស់ ដើម្បីការពារព្រំដែន តាំងពីក្រោយរបប លន់ នល់ ដួលរលំនាឆ្នាំ ១៩៧៥ៗ

ខ្មែរសេរី គឺជាឈ្មោះនៃក្រុមប្រដាប់អាវុធ ដែលពួកស្តាំបំផុតប្រកាន់យកដោយខ្លួនឯង តាំងពីទសវត្សឆ្នាំ ៥០ មក។ ពួកនេះក៏ធ្លាប់ប្រឆាំងនឹងរាជាណាចក្រកម្ពុជា ដោយបានធ្វើអោយសម្តេច សីហនុ ជួបការលំបាកយ៉ាងខ្លាំង នៅពេលគាត់កាន់អំណាច ពីឆ្នាំ ១៩៥៤ មកដល់ឆ្នាំ ១៩៧០។ ទោះរបបណាកាន់អំណាចនៅកម្ពុជា ក៏មានកម្លាំងនេះធ្វើសកម្មភាពប្រឆាំងដែរ។ ក្រោយពេលរបប លន់ នល់ ដួលរលំ ទាហានបាក់ទ័ពរបស់ លន់ នល់ ដែលគេចរួចពីពួក ប៉ុល ពត បានទៅចូលរួមពង្រីកកម្លាំងពួកខ្មែរសេរី ដោយបានទទួលជំនួយពីថៃ និងបរទេសផ្សេងទៀត។ ក្នុងចន្លោះឆ្នាំ ១៩៧៥ ទៅចុងឆ្នាំ ១៩៧៨ ថៃបានប្រើកម្លាំងនេះ រួមចំណែកការពារព្រំដែន ប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ដែលក្រោយឆ្នាំ ១៩៧៩ ថៃហៅថា ជារបបស្របច្បាប់ ហើយស្ងាត់ស្ងៀមមិនលើកមកនិយាយ អំពីការដែលគេចិញ្ចឹមពួកខ្មែរសេរីពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដើម្បីប្រឆាំងអ្នកណានោះឡើយ។ ដូច្នេះក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ចុងឆ្នាំ ១៩៧៩ កម្លាំងខ្មែរសេរីនេះ មានគោលដៅប្រឆាំង ប៉ុល ពត ដែរ ប៉ុន្តែអាស្រ័យដោយមានរដ្ឋអំណាចថ្មីនៅកម្ពុជា ពួកគេក៏បង្វែរទិសពួកនេះ អោយប្រឆាំងជាមួយរដ្ឋអំណាចថ្មីទៅវិញ ហើយដែលក្រោយមក គេតម្រូវអោយមានសម្ព័ន្ធភាពរវាងបងប្អូនដែលជាសត្រូវនឹងគ្នា ក្នុងរដ្ឋាភិបាលចំរុះមួយ ដែលមានពួក ប៉ុល ពត នៅក្នុងនោះផង។ តាមអាចដឹងបាន ក្រុមប្រដាប់អាវុធខ្មែរសេរីមួយក្រុមដឹកនាំដោយឈ្មោះ អ៊ា ង៉ួន អតីតចៅកែត្បូងនៅប៉ៃលិន បាននាំគ្នាទម្លាក់អាវុធ បន្ទាប់ពីពួក ប៉ុល ពត ត្រូវដួលរលំ ប៉ុន្តែក្រុមនោះត្រូវទទួលការបង្ក្រាបយ៉ាងឃោឃៅពីអាជ្ញាធរយោធាថៃ ដែលបានបាញ់

សម្ងាប់មេទាហានរបស់ខ្មែរសេរីប្រមាណ ៣០ នាក់ ដើម្បីបង្ខំអោយក្រុមនេះកាន់អាវុធប្រឆាំងប្រជាជនកម្ពុជា។ ចុងក្រោយ គេរក្សាបានឈ្មោះ ព្រំ វីត អោយគ្រប់គ្រងកម្លាំងនេះ ទម្រាំ សឺន សាន មកដល់។ ឯឈ្មោះ អ៊ា ង៉ួន បានរត់ទៅជ្រកកោននៅប្រទេសសិរីលង្កា ដោយខ្លាចថៃសងសឹក ព្រោះខ្លួនមិនព្រមកាន់អាវុធប្រឆាំងប្រជាជនកម្ពុជា។

នៅក្រោមរបប ប៉ុល ពត ខ្មែរសេរីមិនអាចក្លាយទៅជាកម្លាំងយោធានិងនយោបាយដ៏ធំដុំបានទេ។ ថៃប្រើកម្លាំងនេះ គ្រាន់តែជាកម្លាំងទប់បន្ទាប់បន្សំប៉ុណ្ណោះ ដូច្នេះពួកនេះគ្មានអង្គការចាត់តាំងខាងនយោបាយនិងយោធាច្បាស់លាស់ទេ គឺគេចែកជាច្រើនក្រុមហើយរស់ដោយជំនួយបរទេស ការឆក់ប្លន់ និងរត់ពន្ធ។ នៅពេលពួកបាក់ទ័ពកៀរយកប្រជាជនទាំងបង្ខំចូលទៅក្នុងប្រទេសថៃ ហើយអាស្រ័យដោយការបង្វែរទិសខាងនយោបាយ ដែលស្របនឹងយុទ្ធសាស្ត្ររបស់ ថៃ-ចិន-អាមេរិក ហើយនោះ ពួកខ្មែរសេរីមានលទ្ធភាពដើម្បីជ្រើសរើសមនុស្សចូលទ័ពនិងបានរស់ដោយជំនួយអន្តរជាតិ ហើយលេចមុខមាត់ជាចំហ បន្ទាប់ពីការរស់ជាសម្ងាត់អស់រយៈពេលជាច្រើនឆ្នាំមក។ នៅខែតុលាឆ្នាំ ១៩៧៩ ពួកខ្មែរសេរី ៩ ក្រុម បានប្រមូលផ្តុំគ្នា បង្កើតឡើងនូវរបស់ដែលហៅថា រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ ក្រោមការដឹកនាំរបស់ សឺន សាន អតីតនាយករដ្ឋមន្ត្រីរាជាណាចក្រកម្ពុជា ដែលបាននិរទេសខ្លួនទៅរស់នៅប្រទេសបារាំង។

នៅមានក្រុមតូចៗ មួយចំនួនទៀត ដែលមិនព្រមចូលក្រុមហ៊ុនជាមួយ សឺន សាន គេបានបង្កើតឡើងនូវអង្គការចាត់តាំងមួយហៅថា មូលីណាកា (ចលនារំដោះជាតិកម្ពុជា)។ ចលនានេះត្រូវបានបង្កើត

ឡើងក្នុងឆ្នាំ ១៩៧៩ ដែលមាន គង់ ស៊ីលាស់ អតីតនាយទាហានរបស់ របប លន់ នល់ ដឹកនាំ (គង់ ស៊ីលាស់ ត្រូវគេបំពុលស្លាប់នារដូវក្ដៅ ឆ្នាំ ១៩៨១) បន្ទាប់មកមាន អ៊ិន តាំ អតីតនាយករដ្ឋមន្ត្រីសាធារណរដ្ឋខ្មែរ របស់ លន់ នល់ ដឹកនាំដោយប្រមូលផ្តុំក្រោមរណសិរ្ស "បង្រួបបង្រួមជាតិដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការ" ដឹកនាំដោយសម្តេចនរោត្តម សីហនុ ដែលបានបង្កើតឡើងនារដូវក្ដៅ ឆ្នាំ ១៩៨១។ កម្លាំងប្រដាប់អាវុធ មូលីណាកា ក្រោយមកបានក្លាយទៅជាកងទ័ពជាតិសីហនុនិយម ដែលដឹកនាំដោយ អ៊ិន តាំ ហើយត្រូវជំនួសដោយឧត្តមសេនីយ៍ ទៀប បែន ក្រោយ អ៊ិន តាំ លាឈប់នៅខែមករា ១៩៨៥ ហើយបន្តមកទៀតត្រូវជំនួសដោយ នរោត្តម រណឫទ្ធិ កូនប្រុសរបស់សម្តេច សីហនុ ក្រោយពេល ទៀប បែន ត្រូវបានដកហូតចេញពីតំណែង។

ដូច្នេះ នៅក្នុងប្រទេសថៃ ក្រៅពីពួកបាក់ទ័ព ប៉ុល ពត គេបានបង្វែរទិសក្រុមប្រដាប់អាវុធខ្មែរសេរីជាច្រើនក្រុម ហើយដែលចុងក្រោយបង្កើតបានជាក្រុមពីរ ដើម្បីរួមជាមួយខ្មែរក្រហម ប៉ុល ពត ប្រឆាំងប្រជាជនកម្ពុជា។

ក្រៅពីសម្ព័ន្ធភាពនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ ដែលគេខិតខំបង្កើតឡើង នៅមានយុទ្ធនាការដ៏ទូលំទូលាយ នៅកន្លែងផ្សេងទៀត ដើម្បីគាំទ្រនូវចលនាប្រឆាំងកម្ពុជា និងវៀតណាម សំខាន់គឺយុទ្ធនាការប្រមូលកម្លាំងនៅអង្គការសហប្រជាជាតិ។ នៅខែមករា ឆ្នាំ ១៩៧៩ ពួកគេបានជម្លៀសសម្តេច សីហនុ មកប៉េកាំង ហើយបញ្ជូនគាត់យ៉ាងប្រញាប់ប្រញាល់ទៅញ៉ូវយ៉ក ដើម្បីដើរតួជាតំណាងជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យនៅក្រុម

ប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ហើយបានធ្វើការចោទប្រកាន់កម្លាំង "ប្រឆាំងរបប ប៉ុល ពត" និងវៀតណាម ទោះបីជាគាត់មានអាកប្បកិរិយាយ៉ាងតឹងតែងបំផុត ចំពោះរបបកម្ពុជាប្រជាធិបតេយ្យនៃពួក ប៉ុល ពត ដែលបានធ្វើទារុណកម្មដ៏ថោកទាបចំពោះរូបគាត់ និងគ្រួសារ គឺសម្លាប់កូនគាត់ ៥ នាក់ និងចៅគាត់ ១៤ នាក់ក៏ដោយ។

ប៉ុន្មានថ្ងៃមុន ពួក ប៉ុល ពត បានស្រែកជេរសក្តិភូមិ ថ្កោលទោសសម្តេចជេរប្រទេច សម្តេច សីហនុ ថ្ងៃនេះគេបែរជាយក សម្តេច សីហនុ ធ្វើជាតំណាង។ អាមេរិក និងប្រទេសខាងលិចមួយចំនួន ថ្ងៃមុនបានថ្កោលទោសរបបកម្ពុជាប្រជាធិបតេយ្យ តែថ្ងៃនេះគេខិតខំគាំទ្រ និងការពារកម្ពុជាប្រជាធិបតេយ្យ ដោយជ្រកក្រោមផ្លាកគោរពគោលការណ៍អន្តរជាតិ សិទ្ធិស្វ័យសម្រេចប្រឆាំងការឈ្លានពានរបស់វៀតណាមទៅលើកម្ពុជា ហើយខិតខំការពារអោយខាងតែបាននូវសិទ្ធតំណាងរបស់របប ប៉ុល ពត នៅអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិផ្សេងទៀត ដើម្បីទប់ស្កាត់នូវការរលំរលាយខាងនយោបាយ ចំពោះពួកកាកសំណល់នៃកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងទប់ស្កាត់ការទទួលស្គាល់ពីអន្តរជាតិចំពោះរបបថ្មីនៅភ្នំពេញ។ សម្ព័ន្ធមិត្តអាមេរិកមួយចំនួនក៏ចាប់ផ្តើមប្រកាសឡើងនូវរបស់ដែលហៅថា "គាបសង្កត់ខាងនយោបាយការទូត និងហ៊ុំព័ទ្ធសេដ្ឋកិច្ចចំពោះវៀតណាម" ដើម្បីបង្ខំអោយវៀតណាមចេញពីកម្ពុជា។

នៅព្រំដែនវៀតណាម-ចិន ចិនបានលើកឡើងនូវរបស់ដែលហៅថា "ដាក់មេរៀនទី ១ អោយវៀតណាម"។ ថ្ងៃ ១៧ ខែ កុម្ភៈ ១៩៧៩ ចិនបានបញ្ជូនកងទ័ព ៦០ ម៉ឺននាក់ចូលឈ្លានពានវៀតណាម នៅតាមបណ្តោយព្រំដែនប្រវែងជាង ១០០០ គីឡូម៉ែត្រ បង្កឡើងនូវឧក្រិដ្ឋកម្ម

*ដោតជាំដោយឈាម ចំពោះប្រជាជនវៀតណាម។*

*យុទ្ធនាការទាំងអស់ ទាំងយោធា នយោបាយ ការទូត ទាំងសេដ្ឋកិច្ច ជុំវិញបញ្ហាកម្ពុជា ទោះបីគេមានគោលដៅយូរអង្វែងខុសគ្នា ហើយគេធៀតប្រើគ្នាដើម្បីឧត្តមភាពរៀងៗ ខ្លួនក៏ដោយ ក៏គេឯកភាពគ្នា លើគោលដៅផ្តួលរំលំរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ធ្វើអោយវៀតណាមចុះខ្សោយ បំបែកសាមគ្គីភាពរវាងកម្ពុជា-វៀតណាម-ឡាវ ដើម្បីត្រួតត្រា ព្រមទាំងគេឯកភាពគ្នាអំពីយុទ្ធវិធី ក្នុងការធ្វើអោយបញ្ហាកម្ពុជា ក្លាយទៅជាបញ្ហាអន្តរជាតិ ដោយខិតខំបំផុសឡើងនូវរបស់ដែលហៅថា "គ្រោះថ្នាក់នៃការឈ្លានពានរបស់វៀតណាម" គឺ វៀតណាមឈ្លានពានកម្ពុជា ហើយទាមទារយកបញ្ហានេះ ទៅដោះស្រាយនៅអង្គការសហប្រជាជាតិ។ ធ្លងតាមនោះ គេមានយុទ្ធនាការរាប់មិនអស់ ដើម្បីប្រឆាំងប្រជាជនកម្ពុជា។*

*នៅផ្ទៃក្នុងកម្ពុជាវិញ ក្រោយពេលរបប ប៉ុល ពត ដួលរលំ ធៀតឱកាសសភាពការណ៍កំពុងច្របូកច្របល់ និងមិនទាន់មានស្ថិរភាព ពួកខ្មែរប្រតិកិរិយា បានរៀបចំឡើងនូវអង្គការចាត់តាំងប្រឆាំងបដិវត្តន៍ជាច្រើនក្រុម រហូតដល់រៀបចំឡើងនូវរដ្ឋាភិបាលមួយ នៅក្រុងភ្នំពេញ នាខែឧសភា ឆ្នាំ ១៩៧៩ ដែលមានឈ្មោះ ហែម គ្រឹស្នា ជានាយករដ្ឋមន្ត្រី។ ពួកវាយល់ដោយអត្តនោម័តិថា ខាងរដ្ឋអំណាចបដិវត្តមិនអាចបំផ្លាញវាបានទេ។ គណបក្សប្រតិកិរិយា បានកកើតឡើងប្រហែលជិត ៥០ គណបក្សក្នុងរយៈពេលខុសៗ គ្នា ពីឆ្នាំ ១៩៧៩ មកឆ្នាំ ១៩៨១ ហើយភាគច្រើនសុទ្ធតែមានការបញ្ជាចេញពីប្រទេសថៃ ប៉ុន្តែ គណបក្សទាំងអស់គ្មានភ័ព្វវាសនា និង មានអាយុជីវិតបានយូរឡើយ ព្រោះកម្លាំងប្រជាជនបានគាបសង្កត់វា ធ្វើអោយរលំរលាយជាបន្តបន្ទាប់។ គណៈបក្សខ្លះរលាយ ហើយ*

នៅសល់មនុស្សរើងក្បាលខ្លះ ក៏ទៅបង្កើតគណបក្សថ្មីទៀត តែក៏ត្រូវរលាយជាបន្តទៀត ហើយដែលទីបំផុត ពួកមេក្លោងត្រូវឈរក្នុងក្រចកសេះចំពោះមុខតុលាការ និងបន្ទាប់មកត្រូវឈានដើងចូលពន្ធនាគារ។ ជនជាដៃដើងតូចតាច ត្រូវទទួលការអប់រំពីប្រជាជន និងរដ្ឋអំណាច ពួកមេក្លោងមួយចំនួនដែលរត់រួចពីមុខច្បាប់ ត្រូវភៀសខ្លួនចូលក្នុងប្រទេសថៃ ដែលមានមួយចំនួនបានចូលជាមួយក្រុម សីហនុ និង សឺន សាន។

## យុទ្ធសាស្ត្របីដំណាក់កាល និង ការបើបំរះត្រដរខ្យល់លើកដីមួយ

ក្នុងពេលដែលពួក ប៉ុល ពត ចាញ់ ពួកនេះស្ថិតក្នុងសភាពបាក់ទ័ព ដែលមិនមែនជាការដកថយមានរបៀបរៀបរយនោះឡើយ។ កម្មាភិបាល បុគ្គលិក និងកងឈ្លបនៅតាមកងផលិតតូច និងកងផលិតធំ "ភូមិ ឃុំ" ស្ទើរតែទូទៅ ត្រូវរំសាយនៅនឹងកន្លែង។ កម្មាភិបាល បុគ្គលិក ថ្នាក់ស្រុក តំបន់ ភូមិភាគមួយចំនួនធំ ត្រូវចាកចេញពីជួរពួក ប៉ុល ពត មករួមរស់ជាមួយប្រជាជនវិញ ហើយមួយចំនួនរត់ទៅតាមពួក ប៉ុល ពត។ ក្រៅពីនោះ ពួកនេះក៏បានកៀរប្រជាជនមួយចំនួនទៅភាគខាងលិចកម្ពុជា និងចូលទៅក្នុងប្រទេសថៃ ហើយដែលចាប់ពីខែ មីនា រហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៩ ប្រជាជនមួយភាគធំ បានរត់គេចពីពួក ប៉ុល ពត ត្រឡប់មកវិញ សំខាន់គឺពេលដែលកងទ័ពបដិវត្ត និងកងទ័ពវៀតណាមទៅវាយពួក ប៉ុល ពត ធ្វើអោយប្រជាជនទាំងនោះ បានឱកាសរត់គេចខ្លួន ហើយមួយចំនួនទៀតបានរត់ឆ្លងដែនពីថៃចូលមកកម្ពុជាវិញ។ ចំពោះកម្លាំងប្រដាប់អាវុធ អាស្រ័យដោយត្រូវបាក់យ៉ាងធ្ងន់ធ្ងរ ពីការវាយតបរបស់កងទ័ពវៀតណាម នាខែ ធ្នូ ឆ្នាំ ១៩៧៨ នៅពេលដែលពួកវាចូលទៅឈ្លានពានប្រទេសវៀតណាម និងអាស្រ័យដោយការវាយសំរុកយ៉ាងឆាប់រហ័សរបស់កងទ័ពបដិវត្ត និងកងទ័ពវៀតណាម បានធ្វើអោយអង្គភាពមួយចំនួនបង្ខំរំសាយកម្លាំងនៅនឹងកន្លែង ហើយអង្គភាពមួយចំនួនទៀតរក្សាបានតែក្បាលអង្គ

ភាពប៉ុណ្ណោះ អាស្រ័យដោយកម្មាភិបាល យុទ្ធជន ត្រូវចាកចេញពីជួរ ត្រឡប់ទៅរកគ្រួសារវិញ។ ក្នុងបណ្តាអង្គភាពកងទ័ពទាំងអស់ គឺមានតែភូមិភាគនិរតីរបស់ តា ម៉ុក មួយទេ ដែលរក្សាកម្លាំងបានច្រើនបង្គួរ ព្រោះភូមិភាគនេះទប់ទល់នឹងការវាយសំរុកតិចជាងគេ ហើយការសម្រិតសម្រាំងនៅផ្ទៃក្នុងក៏មានតិចៗ ចំពោះភូមិភាគបូព៌ាទិស ភូមិភាគឥសាន គឺត្រូវទទួលការវាយសំរុកពីកម្លាំងបដិវត្តក៏ធ្ងន់ធ្ងរ ហើយការសម្រិតសម្រាំងផ្ទៃក្នុងរបស់ពួក ប៉ុល ពត លើសមរភូមិនេះក៏ធ្ងន់ធ្ងរទៀត។ ដោយឡែក ភូមិភាគបូព៌ាទិស មិនមានសល់អង្គភាពចាស់ដែលធ្លាប់តស៊ូជាមួយអាមេរិកទេ ព្រោះអង្គភាពទាំងនេះភាគច្រើនបានចូលរួមប្រឆាំងជាមួយ ប៉ុល ពត ឯអង្គភាពកងពលរបស់ភូមិភាគ ដែលបានបញ្ជូនទៅមជ្ឈិមរួចហើយ ក្រោយពីមានព្រឹត្តិការណ៍បះបោរនៅភូមិភាគបូព៌ា កងពលនោះក៏ត្រូវទទួលការសម្រិតសម្រាំងផងដែរ។ ភូមិភាគផ្សេងទៀត ក៏សុទ្ធតែត្រូវប៉ះពាល់អំពីការវាយសំរុករបស់កម្លាំងបដិវត្ត និងការសម្រិតសម្រាំងផ្ទៃក្នុង។ ឯកងពលនៃកងទ័ពមជ្ឈិមស្ទើរតែទាំងអស់ ដែលបោះនៅជាប់ព្រំដែនវៀតណាមសុទ្ធតែត្រូវទទួលការខូចខាតយ៉ាងធ្ងន់ធ្ងរ មានតែប៉ុន្មានកងពលដែលបោះតាមព្រំដែនថៃទេ ដែលការពារកម្លាំងបានគ្រាន់បើ ប៉ុន្តែក៏ត្រូវទទួលការវាយលុកពីកម្លាំងបដិវត្តរយៈពេលក្រោយមកទៀត ពិសេសការវាយសំរុកពីកម្លាំងបដិវត្ត និងវៀតណាម នៅចុងរដូវក្តៅ ឆ្នាំ ១៩៧៩ នៅសំឡូត តាសាញ់។

អាស្រ័យដោយកម្លាំងត្រូវបែកបាក់ខ្ចាត់ខ្ចាយ ហើយក្បាលម៉ាស៊ីនបញ្ជា ត្រូវរត់រប៉ាត់រប៉ាយ ការប៉ុនប៉ងវាយបកដណ្តើមរដ្ឋអំណាចដោយកម្លាំងយោធារបស់ពួក ប៉ុល ពត នាដំណាក់កាលដំបូង មិនអាចអនុវត្ត

បានឡើយ ដូច្នេះ ពួក ប៉ុល ពត បានផ្លាស់ប្តូរយុទ្ធសាស្ត្រទៅកាន់ចរិត និងរូបភាពសង្គ្រាម "ទន្ទ្រាន និងផ្តួលរំលំ" ដោយខិតខំរកគ្រប់វិធី ដើម្បីរក្សា និងទន្ទ្រានយកដំបន់មួយចំនួន នៅតាមព្រំដែនកម្ពុជា-ថៃ សំដៅបង្កឡើងនូវប្រៀបជាយុទ្ធសាស្ត្រ ដោយបង្កើតឡើងនូវដំបន់ត្រួតពិនិត្យពីរ រដ្ឋាភិបាលពីរបដិបក្ខនឹងគ្នា ហើយបិតបេរព្រមៗ គ្នា នៅកម្ពុជា។

ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រសង្គ្រាមទន្ទ្រាន និងផ្តួលរំលំ ពួក ប៉ុល ពត បានបែងចែកសកម្មភាពសង្គ្រាមរបស់វា ជាបីដំណាក់កាល ដែលហៅថា យុទ្ធសាស្ត្របីដំណាក់កាល៖

ដំណាក់ទី ១ គឺដំណាក់កាលរក្សាការពារជាយុទ្ធសាស្ត្រ

ដំណាក់ទី ២ គឺដំណាក់កាលប្រទាញប្រទង់ជាយុទ្ធសាស្ត្រ

ដំណាក់ទី ៣ គឺដំណាក់កាលវាយសំរុកជាយុទ្ធសាស្ត្រ

ដំណាក់កាលរក្សាការពារជាយុទ្ធសាស្ត្ររបស់ ប៉ុល ពត គឺរក្សាអោយបាននូវកម្លាំង និងទីតាំងបង្អែកដែលនៅសេសសល់ ពិសេសតាមព្រំដែនកម្ពុជា-ថៃ ហើយក៏ខិតខំប្រមូលមកវិញនូវកម្លាំងដែលបានរំសាយ ពេលដែលពួកវាចាញ់។ ព្រមគ្នានឹងវិធានការណ៍ការពារកម្លាំង ពួក ប៉ុល ពត បានអនុវត្តសង្គ្រាមឈ្លប ពីខែ មិថុនា ឆ្នាំ ១៩៧៩ ហើយបើតាមទ្រឹស្តីដែលពួកវាលើកឡើង គឺ នៅពេលណាពួកវាបានបើកទូលាយដំបន់ដែលពួកវាគ្រប់គ្រងបាន ពី ២ ទៅ ៩ ហើយពង្រឹងពង្រីកដំបន់ឈ្លប និងទីតាំងឈ្លបបានពី ៣ ទៅ ៤ ភាគនៃទឹកដី បំព្រួញនូវដំបន់ដែលយើងគ្រប់គ្រងអោយទៅជាដំបន់ឈ្លបទាំងអស់ ហើយការប្រៀបធៀបកម្លាំង បើមានប្រហាក់ប្រហែលគ្នាហើយនោះ ពួកវានឹងបញ្ជូនចូលទៅ ក្នុងដំណាក់កាលប្រទាញប្រទង់លើគ្រប់ផ្នែក រួចហើយឈានទៅដំណាក់កាលវាយសំរុកជា

*យុទ្ធសាស្ត្រ ដើម្បីដណ្តើមអំណាច។*

*ពួក ប៉ុល ពត ក៏បានបែងចែកស្ថានភាពទឹកដីជា ៣ ដំបន់៖*

- *ដំបន់ខ្មាំងគ្រប់គ្រង*
- *ដំបន់ឈ្លប និងទីតាំងឈ្លប*
- *ដំបន់ខ្មាំងគ្រប់គ្រងបណ្តោះអាសន្ន (ខ្មាំងនៅទីនេះគឺ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាម)។*

*ដើម្បីបំរើដល់ការអនុវត្តយុទ្ធសាស្ត្របីដំណាក់កាល ខ្មាំងបានរៀបចំឡើងនូវកម្លាំង ៣ ផ្នែក គឺបណ្តាអង្គភាពប្រមូលផ្តុំ បណ្តាក្រុមប្រតិបត្តិការប្រដាប់អាវុធ និងកងកម្លាំងបង្កប់នៅភូមិឃុំ និងក្នុងអង្គការចាត់តាំងរដ្ឋអំណាចបដិវត្ត ហើយរៀបចំឡើងនូវកម្លាំងពីរប្រភេទ ដែលពួក ប៉ុល ពត ហៅជាឧទាហរណ៍ថា ការដើរជើងពីរ គឺទី ១ កងកម្លាំងប្រដាប់អាវុធ ដែលរួមមានកម្លាំងកងទ័ព និងកងឈ្លបប្រមូលផ្តុំ និងទី ២ គឺកងកម្លាំងនយោបាយរួមមាន កម្លាំងបង្កប់ធ្វើសកម្មភាពក្នុងជួរប្រជាជន។ ពួក ប៉ុល ពត បានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ការកសាងកម្លាំងបង្កប់ក្នុងប្រជាជន និងក្នុងជួររដ្ឋអំណាច ដែលគោលដៅរបស់វាជាជំហានដំបូងគឺប្រែក្លាយរដ្ឋអំណាចយើង អោយទៅជារដ្ឋអំណាចមុខពីរ ដែលមានរូបភាពជារដ្ឋអំណាចយើង តែខ្លឹមសារគឺបំរើអោយពួកវា។*

*តាមផែនការរបស់ ប៉ុល ពត ក្នុងរដូវវស្សាឆ្នាំ ១៩៧៩ ត្រូវចាត់តាំងកសាងអោយបានកងឈ្លបពី ៥០ ទៅ ៦០ ពាន់នាក់ នៅតាមភូមិឃុំគ្រប់ស្រុក ត្រូវមានកងឈ្លបប្រមូលផ្តុំ តិចបំផុត ១ កងអនុសេនាតូច និង ១០០ ក្រុមកងឈ្លប ដែលក្រុមនិមួយៗ មាន ១០ នាក់ គ្រប់យោធភូមិភាគ ភូមិភាគតូចត្រូវកសាងកងទ័ពអោយបានពី ១៥ ទៅ ២០ ពាន់*

ក្បាល ហើយភូមិភាគធំពី ២៥០០០ ទៅ ៣៥០០០ ក្បាល។

ពិនិត្យអំពីតួលេខនៃផែនការរបស់ពួក ប៉ុល ពត គឺហាក់ដូចជាវាកំពុងធ្វើលេខគុណ ក្នុងពេលដែលវាកំពុងដំណើរការធ្វើលេខចែក និងលេខសងនៅក្នុងជួរវា និងក្នុងជួរប្រជាជន។ ពួកវាភ្លេចគិតទៅដល់អ្វី ដែលពួកវាបានធ្វើចំពោះប្រជាជន មុនពេលដែលពួកវាត្រូវធ្លាក់ពីអំណាច។ បើប្រជាជនស្អប់ខ្ពើមវាយ៉ាងនេះ តើវាមានលទ្ធភាពឯណា ដើម្បីប្រមូលប្រជាជនចូលកងឈ្លប ចូលបំរើក្នុងជួរកងទ័ពដ៏សន្ធឹកសន្ធាប់យ៉ាងនេះបាន។ នេះមិនខុសពីផែនការរបស់អង្គការសម័យ ១ ហិកតា ៣ តោន ឬ ៦ តោននោះទេ ហើយទម្លាប់អត្តនោម័តិ វាបានក្លាយជាផ្នត់គំនិតរបស់ពួក ប៉ុល ពត រួចស្រេចទៅហើយ។ ក្រោយពីការប្រើប្រាស់កម្លាំងយោធាដើម្បីកំទេចប្រជាជនអស់រយៈពេលមិនយូរប៉ុន្មានផងពួក ប៉ុល ពត ចាប់គិតអំពីកម្លាំងនយោបាយ ដែលពួកវាវាយតម្លៃថា "កត្តាយោធាជាគន្លឹះ ដើម្បីសម្រេចភារកិច្ចចិត្តសាស្ត្រសង្គ្រាម តែកត្តាជាសារវ័ន្តជាង គឺកត្តានយោបាយ ដែលជាកងកម្លាំងប្រជាជន" ដែលពួកវាត្រូវតែយកចិត្តទុកដាក់កសាង។

ចូលដល់ក្រោយរដូវប្រាំង ឆ្នាំ ១៩៨០-១៩៨១ គឺពីរឆ្នាំក្រោយការអនុវត្តដំណាក់កាលរក្សាការពារជាយុទ្ធសាស្ត្រ ពួក ប៉ុល ពត អត្តនោម័តិកំណត់ថាកងកម្លាំងរបស់វាមានកម្លាំងគ្រប់គ្រាន់ ដើម្បីផ្លាស់ប្តូរបញ្ជូនទៅកាន់ដំណាក់កាលប្រទាញប្រទង់ជាយុទ្ធសាស្ត្រ។ ខ្មាំងបានបញ្ជូនកម្លាំងចូលមកផ្ទៃក្នុងកម្ពុជា ដែលមានភារកិច្ចសំខាន់គឺ សកម្មភាពឈ្លបវាយស្កាត់ទៅលើផ្លូវដឹកជញ្ជូនជាយុទ្ធសាស្ត្ររបស់យើង ពីផ្ទៃក្នុងទៅព្រំដែន ដើម្បីគាំទ្រដល់កម្លាំងរបស់វាក្នុងការជ្រៀតចូល មកកសាងទីតាំងក្នុង

ទឹកដីកម្ពុជា តក្លាប់នឹងទីតាំងរបស់វាក្នុងទឹកដីថៃ ព្រមទាំងគាំទ្រដល់កម្លាំងនៅផ្ទៃក្នុង កសាងបណ្តាទីតាំងលួចលាក់ នៅតាមដំបន់ចុងកាត់មាត់ញកដឹកជញ្ជូនចូលមកផ្ទៃក្នុង បើកទូលាយការកសាងមូលដ្ឋានបង្កប់ដើម្បីបំរើដល់សកម្មភាពឈ្លប។

ដោយមានការវាយតម្លៃខុស ពួក ប៉ុល ពត បានចាប់ផ្តើមផ្ទេរដំណាក់កាលពីការរក្សាការពារជាយុទ្ធសាស្ត្រ ដែលសំខាន់គឺ ការកសាងកម្លាំង ធ្វើសកម្មភាពឈ្លប ទៅកាន់ដំណាក់កាលប្រទាញប្រទង់ជាយុទ្ធសាស្ត្រ។ ដូច្នេះ ការរើបំរះត្រដរខ្យល់លើកទី ១ បានចាប់ផ្តើមឡើងជាមួយនឹងសកម្មភាពផ្សងព្រេងខាងយោធា ដែលមានទ្រង់ទ្រាយធំបន្តួរ ហើយមានចរិតសាហាវទៀតផង។ ក្នុងរយៈពេលនៃការរើបំរះលើកទី ១ ក្នុងឆ្នាំ ១៩៨១ ពួក ប៉ុល ពត បានចាត់តាំងសមរភូមិជា ៣ រណសិរ្ស៖ ទីមួយ រណសិរ្សខាងលិចទន្លេសាប ជារណសិរ្សចំណុចសំខាន់ចាំបាច់ត្រូវឈានទៅវាយយក, ទីពីរ រណសិរ្សខាងកើតទន្លេសាបជារណសិរ្សសំខាន់ដើម្បីអូសទាញប្រមូលកម្លាំងយើង និងកងទ័ពវៀតណាម ព្រមទាំងសហការជាមួយរណសិរ្សខាងលិចទន្លេសាប, ទីបី រណសិរ្សខាងកើតទន្លេមេគង្គ ជារណសិរ្សប្រយុទ្ធបោះស្មឹងបញ្ឈរជើងកម្លាំងយើង កុំអោយទៅជួយកន្លែងណាបាន។

យើងគួររំលឹកថា ការរើបំរះរបស់ខ្មាំង គឺធ្វើឡើងក្រោយរយៈពេល ៣ ឆ្នាំនៃការកសាងកម្លាំងប្រដាប់អាវុធរបស់យើង ដែលកងទ័ពរបស់យើងពេលនោះបានរៀបចំឡើងជា កងឯកភាពរហូតដល់ថ្នាក់កងពល និងក្រោយពេលដែលរដ្ឋអំណាចនៅគ្រប់លំដាប់ថ្នាក់ បានរៀបចំហើយរាប់ទាំងការបោះឆ្នោតជាសកលជ្រើសរើសរដ្ឋសភាផង។ សំខាន់ជាង

នេះទៀត ការរើបំរះនេះធ្វើឡើងក្រោយពេលដែលយើងបានបញ្ចប់ជាស្ថាពរនូវការអត់ឃ្លាន ហើយក៏ធ្វើឡើងក្រោយពេលផែនការកសាងកម្លាំងរបស់ពួក ប៉ុល ពត នៅមូលដ្ឋានមិនបានសម្រេចៗ ដូច្នេះ ការរើបំរះលើកទី ១ នេះ ទោះបីខ្មាំងបានខិតខំប្រមូលអស់នូវលទ្ធភាព និងកម្លាំង រាប់ទាំងសកម្មភាពផ្នែកទូតនៅខាងក្រៅផងក៏ដោយ ក៏ទីចុងបំផុត ពួកវាត្រូវទទួលយកបរាជ័យយ៉ាងសែនឈឺចាប់ មិនត្រឹមតែមិនបានទទួលជោគជ័យប៉ុណ្ណោះទេ តែថែមទាំងទទួលនូវការខូចខាតយ៉ាងធ្ងន់ធ្ងរទៀតៗ កងទ័ព និងប្រជាជនយើង ដោយមានការជួយឧបត្ថម្ភពីកងទ័ពស្ម័គ្រចិត្តវៀតណាម បានម្ចាស់ការវាយបកកំទេចផែនការរើបំរះរបស់ខ្មាំង ហើយបន្តសកម្មភាពវាយសំរុកជាប់ រហូតដល់យុទ្ធនាការនារដូវប្រាំងឆ្នាំ ១៩៨១-១៩៨២ ដែលយើងបោសសំអាតខ្មាំង ដោយកំទេចបានទីតាំងមួយចំនួន នៅតាមព្រំដែនកម្ពុជា-ថៃៗ

ការរើបំរះត្រដរខ្យល់លើកទី ១ ត្រូវបរាជ័យ ដូចនេះ ផែនការផ្ទេរដំណាក់កាលមិនអាចអនុវត្តបាន ខ្មាំងត្រូវស្ថិតក្នុងដំណាក់កាលកសាងកម្លាំង ហើយវាយឈ្លបតូចតាចបន្តទៅទៀតៗ

## សម្ព័ន្ធភាពនៃបដិបក្ខ ដែលជាសត្រូវនឹងគ្នា

*នៅពេលដែលមេបាត្រូវរ៉ូវគ្នាហើយ ជាធម្មតា គេតែងអោយកូនប្រុសកូនស្រី រៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ទោះជាអ្នកទាំងពីរមិនចុះសម្រុងគ្នាក៏ដោយ ក៏ត្រូវតែបង្ខំតាមទ្រឹស្តី និមិនធំជាងនាឡិ ដែលបានកើតមានតាំងពីជំនាន់ទុំទាវ នៃខេត្តត្បូងឃ្មុំ ក្នុងប៉ុន្មានទសវត្សរ៍មុនមកម្ល៉េះ។ អាពាហ៍ពិពាហ៍លើកនេះ មិនមែនជាបញ្ហាចំណងទាក់ទង រវាងនារីបុរសនោះឡើយ ប៉ុន្តែជាការផ្សំផ្គុំខាងនយោបាយ រវាងម្ខាងឆ្វេងបំផុតនិងម្ខាងទៀតស្តាំបំផុត ហើយដែលធ្លាប់ជាសត្រូវស៊ីសាច់ហុតឈាមជាមួយគ្នា។ ជាងនេះទៅទៀត នេះជាការផ្សំផ្គុំនៃកម្លាំងនយោបាយបីដែលបដិបក្ខនឹងគ្នា ប្រៀបដូចជាការចាប់ខ្លា សេះ ពពែ អោយនៅ ក្នុងទ្រុងជាមួយគ្នា។*

*ការឯកភាពរវាងមហាអំណាចទាំងពីរ ចិន និងអាមេរិក បាននាំដល់ការធ្វើសម្ព័ន្ធភាពរវាងកម្លាំងស្តាំ និងឆ្វេងនៅក្រៅប្រទេស ហើយក៏នាំដល់ការធ្វើសម្ព័ន្ធភាពរវាងកម្លាំងឆ្វេង និងស្តាំនៅកម្ពុជា ដើម្បីប្រឆាំងប្រជាជនកម្ពុជា។ ដូចបានលើកឡើងខាងលើហើយថា ក្រោយពេលដែល ប៉ុល ពត ចាញ់ភ្លាម នៅក្នុងប្រទេសថៃ គេបានខិតខំបង្វែរទិសខាងនយោបាយនៃក្រុមប្រដាប់អាវុធខ្មែរសេរី ដែលពីចន្លោះឆ្នាំ ១៩៧៥ មកចុងឆ្នាំ ១៩៧៨ ពួកនេះ ធ្លាប់បានប្រឆាំងពួក ប៉ុល ពត អោយបែរ*

ក្បាលមកប្រឆាំងប្រជាជនកម្ពុជាវិញ។ ទោះបីមិនទាន់ចូលស៊ុបទៅក្នុងសម្ព័ន្ធភាពជាមួយពួក ប៉ុល ពត ក៏ដោយ ក៏ជាននយោបាយ និងចិត្តសាស្ត្រពួកនេះបានរួមជាមួយពួក ប៉ុល ពត ហើយដែរ ព្រោះគេមានគោលដៅដូចគ្នា ក្នុងការប្រឆាំងប្រជាជនកម្ពុជា។

ចិន បានដឹងយ៉ាងច្បាស់អំពីការបាត់ប្រជាប្រិយភាព ទាំងក្នុងប្រទេស និងក្រៅប្រទេសរបស់ពួក ប៉ុល ពត ដែលជាមូលហេតុនាំដល់ការរង្គោះរង្គើនូវសិទ្ធិតំណាងរបស់ពួក ប៉ុល ពត នៅអង្គការសហប្រជាជាតិ នៅចលនាមិនចូលបក្សសម្ព័ន្ធ និងអង្គការអន្តរជាតិផ្សេងទៀត។ ថ្ងៃ ១៣ មករា ១៩៧៩ ក្នុងពេលចរចាជាមួយ អៀង សារី នៅទីក្រុង ប៉េកាំង តេង ស៊ាវពីង បានទូន្មានពួកខ្មែរក្រហមថា "ត្រូវបង្កើតនូវសម្ព័ន្ធភាពទូលំទូលាយមួយ ដោយមានការចូលរួមពីអ្នកជាតិនិយម និងអ្នកស្នេហាជាតិ ត្រូវបង្កើតរណសិរ្សរួបរួមជាមួយ សីហនុ និងត្រូវជៀសវាងការលើកតម្កើងនូវតួនាទីរបស់បក្សកុម្មុយនិស្ត"។ តាមការប្រៀនប្រដៅពីគ្រូអាចារ្យ ពួកខ្មែរក្រហមបានរៀបចំផែនការកែប្រែមុខមាត់ ហើយបង្កើនសកម្មភាពអូសទាញសម្ដេច សីហនុ និងសឺន សាន។ ក្នុងបទសម្ភាសន៍មួយជាមួយអ្នកកាសែត ឡឺម៉ុងដ៍ (*Le Monde*) ថ្ងៃ ៤ កញ្ញា ឆ្នាំ ១៩៧៩ នៅទីក្រុង ឡាហាវ៉ាន (*La Havane*) ពេលទៅចូលរួមសន្និសីទកំពូលប្រទេសមិនចូលបក្សសម្ព័ន្ធលើកទី *VI* តែមិនបានចូលប្រជុំ ខៀវ សំផន បានប្រកាសថា "នឹងដកខ្លួនចេញ ហើយប្រគល់ដំណែងអោយ សីហនុ ប្រសិនបើ សីហនុ ព្រមទទួលដឹកនាំរណសិរ្សមហាសាមគ្គីជាតិ ស្នេហាជាតិ និងប្រជាធិបតេយ្យ"។ ខ្មែរក្រហមហ៊ានទាំងនិយាយថា ពីថ្ងៃនេះទៅ ខ្លួនត្រៀមទទួលយកស្ដេច សីហនុ ជាប្រធាននៃរណសិរ្សបង្រួប

*បង្រួមជាតិ និងជាប្រធានរដ្ឋ កម្ពុជាប្រជាធិបតេយ្យផង។*

*ដើម្បីកែលំអមុខមាត់នៃកម្ពុជាប្រជាធិបតេយ្យ នៅចុងឆ្នាំ ១៩៧៩ ប៉ុល ពត បានប្រកាសលាលែងពីតំណែង ហើយប្រគល់តំណែងនាយករដ្ឋមន្ត្រី ទៅអោយ ខៀវ សំផន ក៏ប៉ុន្តែ ប៉ុល ពត នៅរក្សាទុកតំណែងជា អគ្គបញ្ជាការកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ ដែលជាតំណែងសំខាន់បំផុតក្នុងការបង្ហូរឈាមប្រជាជនកម្ពុជា។ ការដកខ្លួនចេញរបស់ ប៉ុល ពត គឺដើម្បីបំរើដល់ការអូសទាញសម្តេច សីហនុ និង សឺន សាន ផង ព្រមទាំងដើម្បីទាក់ទាញកម្លាំង ដែលរីករាយនឹងចងសម្ព័ន្ធភាពជាមួយខ្មែរក្រហម ប៉ុន្តែបដិសេធមិនទាក់ទងជាមួយ ប៉ុល ពត ផង។ បន្ទាប់មកទៀត ក្នុងន័យលុបបំបាត់នូវស្លាកស្នាមប្រេះឆាខាងនយោបាយ និងមនោគមវិជ្ជា ហើយដើម្បីឈានទៅបង្កើតសម្ព័ន្ធភាពជាមួយ សីហនុ និង សឺន សាន ពួក ប៉ុល ពត បានប្រកាសរំលាយបក្សកុម្មុយនិស្តកម្ពុជា នៅខែធ្នូ ឆ្នាំ ១៩៨១។ ទាំងអស់នេះ គឺជាអំពើបោកប្រាស់ដោយគ្មានការអៀនខ្មាស់ សំដៅបោកប្រាស់សាធារណមតិថា ពួក ប៉ុល ពត បានកែប្រែហើយ រហូតមានពេលខ្លះ ពួក ប៉ុល ពត បាននិយាយទទួលស្គាល់នូវកំហុសដែលពួកវាបានប្រព្រឹត្តិពីអតីតកាលខ្លះផង។*

*សំរាប់សម្តេច សីហនុ ការចូលរួមជាមួយពួក ប៉ុល ពត គឺជាការពិបាកប្រៀបដូចជាការទទួលថ្នាំពុល ដើម្បីធ្វើអត្តឃាតខ្លួនដូច្នេះដែរ ព្រោះគាត់ធ្លាប់បានដឹងពី ប៉ុល ពត ដែលក្នុងនោះ កូន និងចៅគាត់ជាច្រើនបានត្រូវពួក ប៉ុល ពត សម្លាប់។ ក្នុងសៀវភៅរបស់គាត់ ដែលមានចំនងជើងថា "អ្នកទោសរបស់ខ្មែរក្រហម" គាត់បានលើកបង្ហាញអំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមមកលើខ្លួនគាត់ គ្រួសារគាត់ ក៏ដូចជាចំពោះប្រជាជនកម្ពុជាដែរ។*

គាត់ថែមទាំងបាននិយាយដល់អ្វីដែលគាត់បានធ្វើ តែមិនបានសម្រេច គឺ ការសុំការជ្រកកោននយោបាយនៅសហរដ្ឋអាមេរិក និងបារាំង កាលពីពេលគាត់ទៅតំណាងអោយកម្ពុជាប្រជាធិបតេយ្យ នៅក្រុមប្រឹក្សាសន្តិភាពសហប្រជាជាតិក្នុងខែមករា ឆ្នាំ ១៩៧៩។ គាត់បានទាំងធ្លាប់ប្រកាសថា មិនចង់បន្តសកម្មភាពនយោបាយ ហើយក៏មិនចង់ចូលឡុកឡំ ក្នុងរឿងជាមួយខ្មែរក្រហមដែរ។ ប៉ុន្តែ ទោះបីសម្តេច សីហនុ ចង់ ឬមិនចង់ ក៏ត្រូវតែព្រមធ្វើតាមការបង្ខំរបស់ប្រទេសដែលគាត់ធ្លាប់ហៅថា ឪពុកធម៌ (*sponsors*) របស់កម្លាំងដែលប្រឆាំងប្រជាជនកម្ពុជា និងវៀតណាមដែរ។ សម្តេច សីហនុ តែងតែរំលឹកជារឿយៗ ថា ចូលត្រីភាគីដោយគេបង្ខំ ចូលត្រីភាគីទើបចិន ថៃ អាស៊ាន ផ្តល់ជំនួយ។ ក្នុងពេលជួបជាមួយតំណាងរណសិរ្សរបស់គាត់ កាលពីថ្ងៃ ០៨ តុលា ១៩៨៣ សីហនុ បានលើកឡើងថា "ចិន គេបានប្រាប់លោក សឺន សាន អោយប្រាប់ខ្ញុំថា គេមិនជួយទេបើខ្វះក្របខ័ណ្ឌ"។ គាត់បានបញ្ជាក់ថា "កាលខ្ញុំមិនទាន់ធ្វើប្រមុខរដ្ឋ ឬប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ គ្រាន់តែសុំទៅជួបកូនចៅនៅជំរំក្នុងប្រទេសថៃ ក៏ថៃគេអត់ព្រមអនុញ្ញាតអោយខ្ញុំទៅសួរសុខទុក្ខកូនចៅនៅក្នុងប្រទេសគេដែរ។ ទាល់តែធ្វើប្រធានកម្ពុជាប្រជាធិបតេយ្យសិន បានគេបើកទ្វារអោយចូល"។ គ្រាន់តែលើចំណុចពីរនេះ យើងឃើញច្បាស់ថា ចិន និងថៃ សហការគ្នាគាបសង្កត់ចំពោះសម្តេច សីហនុ ទាល់តែមានក្របខ័ណ្ឌទើប ចិន ជួយ។ ក្របខ័ណ្ឌនោះជាអ្វី គឺចូលជាមួយកម្ពុជាប្រជាធិបតេយ្យ ទាល់តែធ្វើប្រធានកម្ពុជាប្រជាធិបតេយ្យ ទើបថៃអោយចូលប្រទេសគេ។ ទាំងអស់នេះគឺលក្ខខណ្ឌខាងនយោបាយដ៏តឹងតែងសំរាប់ សីហនុ តែផ្នែកណានោះ ក៏ស្របនឹងយុទ្ធសាស្ត្រផ្ទាល់របស់គាត់ដែរ ដូច្នេះបាន

*ជាគាត់យល់ព្រមដឹកនាំក្រុមប្រដាប់អាវុធឈ្មោះ មូលីណាកា ហើយបង្កើតឡើងនូវរណសិរ្សបង្រួបបង្រួមជាតិដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹតសន្តិភាព និងសហប្រតិបត្តិការនារដូវក្តៅឆ្នាំ ១៩៨១ នៅ ព្យុង្គយ៉ាង (Pyong Yang) រដ្ឋធានីប្រទេសកូរ៉េខាងជើង ដែលជាដំណាក់កាលប្រុងប្រៀបឈានទៅធ្វើសម្ព័ន្ធភាពត្រីភាគី។*

*ចំពោះ សឺន សាន គាត់បានដឹកនាំក្រុមប្រដាប់អាវុធមួយ ដែលបញ្ចូលគ្នាដោយក្រុមតូចៗ ៩ ក្រុម ហើយបង្កើតឡើងនូវ រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនៅខែធ្នូ ឆ្នាំ ១៩៧៩។ ក្រុមនេះ ភាគច្រើនជាអតីតទាហាន លន់ នល់ ដែលពួកគេមិនត្រូវជាមួយពួកខ្មែរក្រហម ហើយក៏មិនស៊ីគ្នាជាមួយកម្លាំងរបស់ សីហនុ ដែរ។ ដូច្នេះ ការតម្រូវអោយក្រុម សឺន សាន ចូលរួមជាមួយក្រុមខ្មែរក្រហម និងក្រុម សីហនុ ក៏មិនមែនជាការងាយស្រួលឡើយ។ ប៉ុន្តែ ចំពោះក្រុម សឺន សាន ថៃ បានក្តាប់តាំងពីមុន ប៉ុល ពត ចាញ់ម្ល៉េះ ដូច្នេះការដាក់ការគាបសង្កត់ គឺជារឿងងាយទេ។ មុនឈានទៅដល់ការបង្កើតរដ្ឋាភិបាលចម្រុះ សឺន សាន ធ្លាប់បានធ្វើការងារមួយចំនួន ក្នុងន័យជាការចាប់ផ្តើមសម្ព័ន្ធភាពដោយផ្ទាល់ជាមួយ ប៉ុល ពត នោះគឺនៅខែ សីហា ១៩៨០ សឺន សាន បានរៀបចំយុទ្ធសាស្ត្រមួយហៅថា "យុទ្ធសាស្ត្ររួមសកម្ម" ដើម្បីប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលយុទ្ធសាស្ត្ររួមនេះ នឹងនាំដល់សហប្រតិបត្តិការខាងយោធាជាមួយពួក ប៉ុល ពត។ ក្រោយបន្តិច សឺន សាន ក៏បានផ្តើមគំនិតស្នើបង្កើតរដ្ឋាភិបាលបណ្តោះអាសន្ននៃពួកខ្មែរនៅក្រៅប្រទេស ដែលជាការផ្តល់នូវសញ្ញាភ្លើងបៃតង សំរាប់ការបង្កើតរដ្ឋាភិបាលចម្រុះ ក៏ដូចជា ដណ្តើមយកលទ្ធភាពឈានមុខខាងនយោបាយពីសម្តេច សីហនុ។ ប៉ុន្តែ ក្រុម សឺន*

*សាន និងខ្លួនគាត់ផ្ទាល់ ក៏កើតឡើងនូវការព្រួយបារម្ភយ៉ាងខ្លាំងអំពីការចូលរួមក្នុងរដ្ឋាភិបាលចម្រុះ ក្នុងពេលដែលកម្លាំងយោធារបស់គាត់ខ្សោយយ៉ាងខ្លាំង ដែលពេលនោះ សឺន សាន បានសុំអោយលោកខាងលិចផ្តល់អោយគាត់ "នូវដំបងដ៏រឹងមាំមួយអោយគាត់ មុននឹងអោយគាត់ចូលទ្រុងខ្លា" មានន័យថា ស្នើអោយលោកខាងលិចផ្តល់ជំនួយអោយរណសិរ្សគាត់ ជាពិសេសជំនួយយោធា។ ហើយគាត់ (សឺន សាន) ក៏មានភាពតឹងតែងជាមួយពួកខ្មែរក្រហមក្នុងការចែកឋានៈ តួនាទីដឹកនាំរដ្ឋាភិបាលចម្រុះ ដោយគាត់មិនចង់អោយ ខៀវ សំផន ដែលត្រូវធ្វើជាអនុប្រធានាធិបតី ទទួលបន្ទុកការបរទេសបន្ថែមនោះឡើយ ដោយខ្លាចថា ជំនួយបរទេសផ្តល់មក ពួកខ្មែរក្រហមយកម្នាក់ឯង ឬចែកមិនស្មើ។ ប៉ុន្តែ រាល់ការទាមទាររបស់ក្រុម សឺន សាន ត្រូវថៃសង្កត់ទាំងអស់ "លោក អ៊ិន តាំ ធ្លាប់បាននិយាយអំពីអ្វីដែលថៃសង្កត់ទៅលើពួក សឺន សាន មុនពេលចាត់តាំងរដ្ឋាភិបាលចម្រុះ ព្រោះពេលនោះលោក អ៊ិន តាំ បានតំណាងអោយក្រុម សីហនុ ចូលរួមចរចាបង្កើតរដ្ឋាភិបាលចម្រុះដែរ។ គួររំលឹកបន្តិចថា នៅពេលរួមតុបាយជាមួយគ្នាពីរលើក ថ្ងៃ ២៥ និង ថ្ងៃ ២៨ ខែ កក្កដា ១៩៨៨ ក្នុងឱកាសចូលរួមសន្និសីទក្រៅផ្លូវការ នៅទីក្រុង បូហ្គ័រ (Bogor) ប្រទេសឥណ្ឌូណេស៊ី លោក សឺន សាន និងឧត្តមសេនីយ៍ ថាច់ រ៉េន បាននិយាយប្រាប់ខ្ញុំថា "គេបង្ខំអោយគាត់ចូលរដ្ឋាភិបាលចម្រុះជាមួយខ្មែរក្រហម តាំងពីឆ្នាំ ១៩៧៩-១៩៨០ ម្ល៉េះ តែខ្ញុំមិនព្រម ហេតុដូចនេះ គេមិនផ្តល់ជំនួយអោយក្រុមខ្ញុំទេ លុះត្រាណាតែខ្ញុំចូលរដ្ឋាភិបាលចម្រុះទើបគេអោយជំនួយ ដូច្នេះ ចូលរដ្ឋាភិបាលចម្រុះគឺដើម្បីបានជំនួយតែប៉ុណ្ណោះ"។ ខ្ញុំមិនបានសួរគាត់អំពីមូលហេតុ ដែលគាត់ចូលរដ្ឋាភិបាលចម្រុះទេ តែគាត់ហាក់ដូចជាបានដឹងយ៉ាងច្បាស់ថា*

ពួកភ្នំពេញមិនត្រូវការខ្មែរក្រហមទេ បានជាគាត់ប្រញាប់ប្រញាល់ប្រាប់ខ្ញុំអំពី ការដែលគេបង្ខំគាត់អោយចូលជាមួយខ្មែរក្រហម។ វាពិតជាដូច្នេះមែន បើពិនិត្យពីសារជាតិ ក្រុម សឺន សាន មិនអាចចូលជាមួយក្រុមខ្មែរក្រហមបានឡើយ ប្រសិនបើគ្មានការបង្ខិតបង្ខំពីប្រទេសដែលមានឧបាយកលបង្កើតឡើងនូវរដ្ឋាភិបាលចម្រុះ។ ប្រទេសទាំងនេះ គេបែងចែកការកិច្ចគ្នាយ៉ាងច្បាស់ គឺ ចិន សង្កត់ខ្មែរក្រហម អោយផ្លាស់ប្តូរមុខមាត់ ហើយក៏សង្កត់ សីហនុ សឺន សាន ផងដែរ ឯថៃ-អាមេរិក-អាស៊ាន គឺទទួលការកិច្ចចលនា និងគាបសង្កត់លើ សីហនុ និង សឺន សាន។

វាមិនមែនជាការងាយស្រួលឡើយ ក្នុងការប្រមូលសត្រូវដែលធ្លាប់ស៊ីសាច់ហុតឈាមគ្នា អោយនៅជាមួយគ្នានោះ។ អស់រយៈពេលជិត ៣ ឆ្នាំនៃការគាបសង្កត់ ពួកគេនៅតែពុំទាន់ទទួលបានជោគជ័យ ក្នុងការបង្កើតនូវរដ្ឋាភិបាលចម្រុះ រវាងក្រុមទាំងបី។ ឯសភាពការណ៍វិវត្តកាន់តែគ្មានអំណោយផលសម្រាប់ពួកគេ ដោយនៅក្នុងប្រទេស កិច្ចការធំៗ ជាច្រើនត្រូវបានដោះស្រាយប្រកបដោយជោគជ័យ ពិសេសការបំបាត់ជាស្ថាពរនូវការអត់ឃ្លាន ដែលបន្សល់ទុកពីរបប ប៉ុល ពត ហើយប្រជាជនកម្ពុជា បានឆ្លងផុតនូវដំណាក់កាលដែលលំបាកបំផុតក្នុងពេលដែលការរើបំរះត្រដរខ្យល់របស់ពួក ប៉ុល ពត ត្រូវបរាជ័យយ៉ាងជូរចត់។ នៅក្រៅប្រទេស កិត្យានុភាពសាធារណរដ្ឋប្រជាមានិតកម្ពុជា បានត្រូវពង្រឹង និងពង្រីកឡើង ក្នុងពេលដែលទោសឧក្រិដ្ឋរបស់ពួក ប៉ុល ពត ពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែត្រូវបានសាធារណមតិថ្កោលទោស ដែលក្លាយទៅជាការគំរាមកំហែង សំរាប់សិទ្ធតំណាងរបស់ពួក ប៉ុល ពត នៅបណ្តាវេទិកាអន្តរជាតិទៀត។ នាខែកញ្ញា ឆ្នាំ ១៩៧៩

*សន្និសីទកំពូលប្រទេសមិនចូលបក្សសម្ព័ន្ធលើកទី ៦ បានបណ្តេញពួកឃាតករ ប៉ុល ពត ចេញ ហើយរក្សាអាសនៈកម្ពុជាអោយនៅទំនេរ ក្នុងអង្គការអន្តរជាតិនេះ។ មានប្រទេសមួយចំនួន បានស្នើទុកអាសនៈកម្ពុជានៅអង្គការសហប្រជាជាតិអោយនៅទំនេរ និងមានប្រទេសជាសមាជិកអង្គការសហប្រជាជាតិមួយចំនួន បានដកការទទួលស្គាល់ពីពួក ប៉ុល ពត ក្នុងនោះមានអង់គ្លេស និងអូស្ត្រាលីផងដែរ។ ក្នុងពេលដែលមានប្រទេសមួយចំនួនថែមទៀតទទួលស្គាល់ សាធារណរដ្ឋប្រជាមានិតកម្ពុជា អង្គការអន្តរជាតិជាច្រើន រាប់ទាំងអង្គការជាផ្នែករបស់អង្គការសហប្រជាជាតិផង បានមកធ្វើទំនាក់ទំនង និងដាក់តំណាងរបស់គេនៅភ្នំពេញ។*

*ភាពឯកោលើឆាកអន្តរជាតិ ដែលគេមើលឃើញថាកំពុងគំរាមកំហែងដល់ពួក ប៉ុល ពត បានធ្វើអោយចិន សហរដ្ឋអាមេរិក និង បណ្តាប្រទេសអាស៊ាន ព្រួយបារម្ភជាខ្លាំង។ ពួកគេខិតខំប្រើប្រាស់លទ្ធផលនៃការបោះឆ្នោតនៅអង្គការសហប្រជាជាតិ ស្តីពី "បញ្ហាកម្ពុជា" ដើម្បីធ្វើអោយស្របច្បាប់ដល់សកម្មភាពវិទ្ធង្សនារបស់ពួក ប៉ុល ពត ប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រើប្រាស់សន្ទឹកឆ្នោតនេះ ដើម្បីទប់ស្កាត់ការរលំរលាយនៃរបស់ដែលហៅថា កម្ពុជាប្រជាធិបតេយ្យ។ ជាមួយគ្នានេះ ពួកគេក៏ប្រញាប់ប្រញាល់សម្រុះសម្រួលសកម្មភាព ដើម្បីឈានទៅបង្កើតសម្ព័ន្ធភាពរវាងខ្មែរទាំង ៣ ក្រុមនៅក្រៅស្រុក ហើយយកសម្ព័ន្ធភាពនេះទៅបង្ហាញសហគមន៍អន្តរជាតិ អំពីភាពស្របច្បាប់នៃកម្លាំងតស៊ូ ដែលជាតុពិតគឺពួក ប៉ុល ពត នោះឯង។*

*ដោយមិនអាចរង់ចាំបានយូរតទៅទៀត ពួកមេផ្តើមគំនិតបង្កើតសម្ព័ន្ធ*

*ភាពត្រីភាគី បានបង្កើនការគាបសង្កត់ទៅលើ សីហនុ និង សឺន សាន ដើម្បីអោយចូលក្នុងសម្ព័ន្ធភាពជាមួយខ្មែរក្រហមបានឆាប់ៗ ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ១៩៨១ សីហនុ សឺន សាន ខៀវ សំផន បានជួបគ្នានៅក្រុង សិង្ហបុរី ដើម្បីរៀបចំជា "គណកម្មាធិការត្រីភាគី" ក្នុងទិសដៅបង្កើតរដ្ឋាភិបាលចម្រុះមួយ ហើយនៅថ្ងៃទី ២២ ខែ មិថុនា ១៩៨២ រដ្ឋាភិបាលចម្រុះមួយបានបង្កើតឡើងនៅក្រុង កូឡាឡាំពួរ (Kuala Lumpur) ប្រទេសម៉ាឡេស៊ីៗ* ***"បើគង់តែចូលក្រុមហ៊ុនដដែល ត្រូវដាក់ដើមទុនហើយត្រូវចែកចំណេញអោយបានច្រើន ទោះជាត្រូវដើរលើខ្នងអ្នកដទៃក៏ដោយចុះ"*** *ដូច្នេះ ក្រោយពីបង្កើតការយោគយល់គ្នាមួយនៅសិង្ហបុរី ស្ដីពីការបង្កើតរដ្ឋាភិបាលចម្រុះ ទាំងខ្មែរក្រហម ទាំង សីហនុ សឺន សាន សុទ្ធតែខិតខំស្វែងរកឧត្ដមភាពក្នុងរដ្ឋាភិបាលចម្រុះ ហើយធ្លៀតយកចំណេញពីរដ្ឋាភិបាលចម្រុះក្នុងគោលដៅដោយឡែកៗ ពីគ្នាៗ សម្ដេច សីហនុ ធ្លៀតប្រើនូវអ្វីដែលគាត់ហៅថា "របស់មានស្រាប់ដើម្បីបញ្ជូនខ្លួនគាត់ចូលក្នុងអង្គការសហប្រជាជាតិ" គាត់ចង់អោយខ្លួនគាត់ និងក្រុមរបស់គាត់ស្របច្បាប់នៅអង្គការសហប្រជាជាតិ ដោយមិនបាននឹកគិតថា គាត់បានជិះលើនាវាមួយជារបស់កម្ពុជាប្រជាធិបតេយ្យ ទាំងតួនាវា ទាំងម៉ាស៊ីន ទាំងប្រេងឥន្ធនៈ ទាំងសញ្ញាទង់ជ័យ ដែលបានកំណត់យ៉ាងច្បាស់ថា ពេលណាអ្នកដំណើរលែងត្រូវការជិះ ឬនាវាទៅមុខទៀតមិនរួច នាវានោះនឹងនៅជារបស់កម្ពុជាប្រជាធិបតេយ្យដដែលនោះទេៗ គាត់ចង់បោកប្រាស់ពួក ប៉ុល ពត តែមិនបានគិតដល់ការដែលពួក ប៉ុល ពត បោកប្រាស់គាត់វិញ ហើយបានច្រើនជាងការដែលគាត់បោកប្រាស់ពួកវាទៅទៀតទេៗ គាត់នឹកស្មានថា កិត្យានុភាពផ្ទាល់របស់គាត់អាចស្រូបយកមនុស្សក្នុងជួរពួក ប៉ុល ពត បាន ដោយ*

មិនបាននឹកដល់ការបំពាក់ដ៏រឹងមាំនូវស្មារតីប្រឆាំងសក្តិភូមិប្រឆាំង សីហនុ របស់ពួក ប៉ុល ពត ឡើយ។ គាត់នឹកស្មានថា ការចូលធ្វើប្រមុខនៃរបស់ ដែលហៅថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចម្រុះ អាចផ្តល់អោយគាត់ នូវការគាំទ្រពីសកលលោកក៏ដូចជាពីប្រជាជនកម្ពុជា ដូចកាលពីឆ្នាំ ១៩៧០ ដល់ ១៩៧៥ ដោយមិននឹកគិតថា នឹងមានប្រតិកម្មផ្ទុយពីនេះឡើយ។ គាត់ នឹកស្មានថា ពេលមានក្របខ័ណ្ឌក្នុងកម្ពុជាប្រជាធិបតេយ្យ គាត់អាចទទួល ជំនួយយោធាដ៏សន្ធឹកសន្ធាប់ពីប្រទេសនានា ពិសេសពីប្រទេសចិន ដែល ធ្លាប់បានប្រាប់គាត់ថា ទាល់តែចូលជាមួយកម្ពុជាប្រជាធិបតេយ្យទើបចិន ជួយ ដោយមិននឹកស្មានថាគ្មានពេលណាដែលចិននឹងជួយគាត់អោយមាន កម្លាំងយោធា អាចសង្កត់ពួកខ្មែរក្រហមបាននោះឡើយ។ គាត់នឹកស្មានថា តាមរយៈតួនាទីជាប្រធានកម្ពុជាប្រជាធិបតេយ្យ គាត់អាចធ្វើសីហនូបនីយ កម្មកម្លាំង ប៉ុល ពត ជារូបភាពសំបកក្រៅ គាបសង្កត់របបភ្នំពេញ និងសម្ព័ន្ធ មិត្តអោយទន់ភ្លន់ ទទួលយកលក្ខខណ្ឌដែលមានផលប្រយោជន៍អោយគាត់ ដោយមិននឹកស្មានដល់ នូវការប្រុងប្រយ័ត្នកាន់តែខ្លាំងរបស់ប្រជាជនកម្ពុជា និងសម្ព័ន្ធមិត្ត ចំពោះមុខនៃប៉ុលពតូបនីយកម្មកម្លាំងសីហនុខាងជាតុពិតនោះ ឡើយ។ គាត់នឹកស្មានថា ធ្វើប្រធានត្រីភាគីរបស់ពួក ប៉ុល ពត អាចធ្វើអោយ វៀតណាមទន់ភ្លន់ ហើយចរចាជាមួយគាត់ ដោយមិននឹកស្មានថា អំពើរបស់ គាត់ជារបងលួសបន្លាដ៏ក្រាស់រាំងវៀតណាម និងគាត់អោយនៅឆ្ងាយពីគ្នា ជាងពេលមុននោះឡើយ។ គាត់នឹកស្មានថា ការចូលជាមួយខ្មែរក្រហម អាច ទប់ស្កាត់នូវអំពើព្រៃផ្សៃរបស់ពួក ប៉ុល ពត បានដោយមិនបានគិតពីពួក ប៉ុល ពត បានឱកាសប្រើប្រាស់ឈ្មោះគាត់ ដើម្បីអនុវត្តអំពើព្រៃផ្សៃកាន់តែខ្លាំង មិនត្រឹមតែចំពោះប្រជាជនកម្ពុជាប៉ុណ្ណោះទេ តែថែមទាំងជាមួយកម្លាំងរបស់

គាត់ដែលជាសម្ព័ន្ធមិត្ត ប៉ុល ពត ក្នុងត្រីភាគីនោះទៀតផង។ ប្រការនេះហើយដែល សម្តេច សីហនុ បានមើលឃើញក្រោយរយៈពេល ៦ ឆ្នាំ នៅក្នុងរដ្ឋាភិបាលចម្រុះ ដែលធ្វើអោយគាត់សំរេចចិត្តចាកចេញពីប្រធានកម្ពុជាប្រជាធិបតេយ្យចម្រុះនាថ្ងៃទី ១០ ខែ កក្កដា ១៩៨៨។ ក្រៅពីបញ្ហារដ្ឋាភិបាលចម្រុះ សម្តេច សីហនុ នៅមានយុទ្ធសាស្ត្រដោយឡែកមួយ ក្នុងសង្គ្រាមនៅកម្ពុជា នោះគឺការអនុវត្តនយោបាយមុខពីរ ចំពោះសាធារណរដ្ឋប្រជាមានិតកម្ពុជា និងពួកខ្មែរក្រហម។ គាត់ឆ្លៀតប្រើកម្លាំងយោធារបស់ពួកខ្មែរក្រហមដើម្បីធ្វើអោយបដិវត្តន៍កម្ពុជាចុះខ្សោយ ធ្វើអោយវៀតណាមហូរឈាមហើយពេលខាងរបបភ្នំពេញវាយបកវិញ គឺពួកខ្មែរក្រហមជាអ្នកទទួលការខូចខាត ដូច្នេះទាំងរបបភ្នំពេញ ទាំងខ្មែរក្រហម សុទ្ធតែត្រូវរបួស ក្នុងពេលដែលគាត់ខិតខំកសាងកម្លាំងយោធាទុកក្នុងប្រទេសថៃ។ បើបញ្ចូលមកក្នុងប្រទេស ក៏ខិតខំជៀសវាងការប្រយុទ្ធ ដើម្បីរក្សាកម្លាំង ហើយប្រើប្រាស់កិត្យានុភាពអន្តរជាតិផ្ទាល់ខ្លួនគាត់ ដើម្បីបង្កុទុនខាងនយោបាយត្រៀមយកឧត្តមភាព ប្រសិនបើមានដំនោះស្រាយនយោបាយ។ ក្រោយពេលមានដំណោះស្រាយនយោបាយ ក៏គាត់នឹងនៅតែឆ្លៀតប្រើប្រាស់ទំនាស់រវាងខ្មែរក្រហម និងរបបភ្នំពេញ ដើម្បីគាត់មានឧត្តមភាពក្នុងការត្រួតត្រា។ ប្រការនេះបានបង្ហាញច្បាស់នូវសំដីរបស់គាត់ក្នុងការចរចាលើកទី ២ ហ៊ុន សែន-សីហនុ កាលពីថ្ងៃ ២០ មករា ១៩៨៨ ដោយលើកឡើងថា "បើខ្មែរក្រហមគំរាមកំហែងខ្ញុំ ខ្ញុំនឹងទៅជាមួយឯកឧត្តម ហ៊ុន សែន ទប់ទល់ជាមួយខ្មែរក្រហម ហើយបើ ឯកឧត្តម ហ៊ុន សែន គំរាមកំហែងខ្ញុំ ខ្ញុំនឹងទៅជាមួយខ្មែរក្រហម ប្រឆាំងឯកឧត្តម ហ៊ុន សែន វិញ"។

ក្រុមរបស់ សីហនុ និងខ្លួនសម្តេច សីហនុ ក៏មិនដែលបោះបង់ចោល

ឱកាសណាមួយ ក្នុងការវាយប្រហារទៅលើពួក សឺន សាន ដើម្បីកុំអោយពួកនេះមានលទ្ធភាពឈានមុខខាងនយោបាយ ឬយោធា ដែលវានឹងបង្កឡើងនូវការលំបាកសម្រាប់ក្រុមគាត់ អាស្រ័យដោយ ក្រុម សឺន សាន មានមនុស្សភាគច្រើនជាអ្នកប្រឆាំង សីហនុ ក្នុងពេល លន់ នល់ កាន់អំណាច។

ចំពោះ សឺន សាន ក៏ដូចគ្នា គាត់ក៏ត្រូវដណ្តើមឧត្តមភាព ក្នុងរដ្ឋាភិបាលចម្រុះ ហើយឆ្លៀតប្រើប្រាស់ការចូលរួមក្នុងរដ្ឋាភិបាលចម្រុះ ដើម្បីយកជំនួយពីចិន ដើម្បីអោយកម្លាំងគាត់ស្របច្បាប់នៅអង្គការសហប្រជាជាតិ ដែលធ្វើអោយខ្លួនគាត់ភ្លេចគិតដល់កៅអីនាយករដ្ឋមន្ត្រី ដែលគេអោយគាត់អង្គុយ នៅក្នុងផ្ទះរបស់អ្នកណា ហើយអ្នកណាធ្លាប់អង្គុយលើកៅអីនេះ អ្នកអង្គុយលើកៅអីនេះ ធ្លាប់បានធ្វើអ្វីខ្លះជាមួយគាត់ ក្រុមគ្រួសារគាត់ កម្លាំងគាត់ដឹកនាំសព្វថ្ងៃ និងប្រជាជនកម្ពុជា។

ជាងនេះទៅទៀត គាត់មិនបានគិតដល់សោះថា តើពួក ប៉ុល ពត បានចាត់ទុកគាត់ជាអ្វី ប្រហែលជាគាត់ខ្វះពត៌មានពីយុទ្ធសាស្ត្ររបស់ពួក ប៉ុល ពត ដែលចាត់ទុកគាត់ជាសម្ព័ន្ធមិត្តបណ្តោះអាសន្ន ក្នុងការប្រឆាំងកម្ពុជា និងវៀតណាម ហើយទូទាត់គាត់ក្នុងរយៈ ៤៨ ម៉ោងក្រោយពេលដែលពួកវាដណ្តើមបានរដ្ឋអំណាចទាំងស្រុង។

ជំនួយមានសារៈសំខាន់បំផុត សំរាប់កម្លាំង សឺន សាន ទោះជាត្រូវធ្វើសម្ព័ន្ធមិត្តជាមួយព្រាយបិសាចក៏ដោយចុះ អោយតែបានជំនួយ។ សម្តេច សីហនុ បានលើកឡើងនៅក្នុងការចរចាលើកទី ១ ហ៊ុន សែន-សីហនុ នៅ ហ្វែរអង់តាដឺន័រ (*Fere-en-Tardenois*) ប្រទេសបារាំង កាលពីថ្ងៃទី ០២-០៤ ធ្នូ ១៩៨៧ ថា "សឺន សាន មិនហ៊ានចរចាជាមួយ ឯកឧត្តម ហ៊ុន សែន ទេ ខ្លាចចិន កាត់ជំនួយ"។ សឺន សាន មានយុទ្ធសាស្ត្រ

ប្រហាក់ប្រហែលសម្តេច សីហនុ គឺ ធ្វើអោយពួកខ្មែរក្រហម និងរបបភ្នំពេញចុះខ្សោយ ធ្វើអោយកម្លាំងទាំងពីរវាយគ្នា មានរបួសរៀងៗ ខ្លួនដែលគេអាចឆ្កៀតយកចំណេញពីស្ថានការណ៍នេះ ដើម្បីបង្កើនកម្លាំងខ្លួនៗ នេះជា "យុទ្ធសាស្រ្តអង្គុយលើកំពូលភ្នំ មើលខ្លា និងសិង្ហខាំគ្នា"។ ប្រការនេះ កាន់តែបង្ហាញច្បាស់ទៅទៀត ក្នុងពេលហូបបាយជាមួយគ្នានៅល្ងាចថ្ងៃទី ២៥ កក្កដា ១៩៨៨ នៅទីក្រុង បូហ្គ័រ ប្រទេសឥណ្ឌូនេស៊ី ដោយ សឺន សាន បានលើកសំណូមពរចំពោះខ្ញុំថា "**សូមឯកឧត្តមកុំវាយកម្លាំងរបស់ខ្ញុំ ទុកអោយខ្ញុំមានតំបន់រំដោះផង ព្រោះពួកខ្មែរក្រហមគេមិនអោយពួកខ្ញុំមានតំបន់រំដោះទេ**"។ ថ្ងៃ ២៦ កក្កដា ១៩៨៨ ពេលចរចាទ្វេភាគីជាមួយប្រតិភូយើង សឺន សាន បានព្រួយបារម្ភយ៉ាងខ្លាំងអំពីគ្រោះថ្នាក់នៃពួកខ្មែរក្រហម។ ខ្ញុំបានប្រាប់ សឺន សាន ថា "បើឯកឧត្តមមិនអាចវាយខ្មែរក្រហមបានទេនោះ សូមកុំរួមជាមួយខ្មែរក្រហមវាយខ្ញុំ សុំឯកឧត្តមនៅអព្យាក្រឹតស្ងៀមចុះ"។ សឺន សាន បានឆ្លើយថា "ខ្ញុំនឹងយកបញ្ហាអព្យាក្រឹតទៅគិត"។ ក្នុងរដ្ឋាភិបាលចម្រុះ កម្លាំង សឺន សាន ក៏មានវិធីមួយទប់ស្កាត់ការរីកចំរើនធំធាត់នៃកម្លាំងរបស់ សម្តេច សីហនុ ដែរ ដែលជាហេតុនាំដល់ការប៉ះទង្គិចខាងយោធា រវាងកម្លាំងពីរនេះជាបន្តបន្ទាប់ និងច្រើនលើកច្រើនសា។ ឯយុទ្ធនាការខាងនយោបាយប្រឆាំងគ្នា មានកើតឡើងជាហូរហែរ តាំងពីភ្នាក់ងារតូចតាចរហូតដល់មន្ត្រីជាន់ខ្ពស់ តាំងពីការជៀលត្មេះគ្នាតាមអត្ថបទតូចតាចរហូត ដល់សារពត៌មានផ្លូវការ ហើយរហូតដល់ប្រមុខនៃកម្លាំងទាំងពីរក៏មានការប៉ះទង្គិចគ្នាយ៉ាងញឹកញាប់ដែរ។ ក្នុងទស្សនាវដ្តី នគរខ្មែរ លេខ ៦៦-៦៧ ខែ តុលា ឆ្នាំ ១៩៨៣ ដែលចុះផ្សាយសេចក្តីរាយ

ការណ៍របស់ សម្ដេច សីហនុ ជូនតំណាងនានានៃរណសិរ្សរួបរួមជាតិដើម្បី កម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិភាព សហប្រតិបត្តិការ កាលពីថ្ងៃ ០៨ តុលា ១៩៨៣ សម្ដេច សីហនុ បានលើកឡើងថា លោក សឺន សាន រើសមនុស្សអោយធ្វើការសុទ្ធតែមនុស្សដែលជេរ សីហនុ ខ្លាំងជាងគេបំផុត ដែលធ្លាញ់នឹងស៊ីសាច់ សីហនុ និងសំអុយ សីហនុ ដូចជា ទេព ណារ៉ុង អ្នកស្រី សួន កាសេត លោក ថាច់ រ៉េន លោក ហ៊ីង កន្ធុន លោក ឆាយ ហាន់ឆេង សុទ្ធតែជើងឯកខាងប្រឆាំង សីហនុ។ សម្ដេច សីហនុ បានលើកពីសំដីរបស់ ហ៊ីង កន្ធុន និងទេព ណារ៉ុង ដែលនិយាយថា "អញមកនេះ មិនមែនមកស៊ីសាច់អាយួនទេ អញមកស៊ីសាច់ សីហនុ តែម្ដង"។

វាពិតជាមានការពិបាកមែន មិនគ្រាន់តែជាមួយពួកខ្មែរក្រហម ដែលមានមនោគមវិជ្ជាឆ្វេងបំផុតប៉ុណ្ណោះទេ តែនៅរវាងកម្លាំងស្តាំដូចគ្នា ឬហៅថា អ្នកជាតិនិយមដូចគ្នាទៀតផង ដូច្នេះតើគេអាចរស់នៅក្នុងសម្ព័ន្ធភាពជាមួយគ្នារបៀបណា?

សំរាប់ពួកខ្មែរក្រហម ប៉ុល ពត "សម្ព័ន្ធភាពត្រីភាគី គឺមានចំណេញអោយពួកខ្មែរក្រហម បក្សសម្ព័ន្ធនេះស្មោះត្រង់ទាំងកាយទាំងចិត្តអោយពួកខ្មែរក្រហម"។

ចិន និងប្រទេស ដែលផ្ដល់ការគាំទ្រចំពោះពួកខ្មែរនៅក្រៅស្រុក បានដឹងយ៉ាងច្បាស់ អំពីគ្រោះថ្នាក់ដែលកំពុងគំរាមកំហែងចំពោះពួក ប៉ុល ពត។ អាមេរិក អាស៊ាន មិនមែនមិនដឹងអំពីឧក្រិដ្ឋកម្ម របស់ពួក ប៉ុល ពត មកលើប្រជាជនកម្ពុជានោះឡើយ ហើយគេក៏គ្មានបំណងអោយពួក ប៉ុល ពត ត្រឡប់មកកាន់អំណាចនៅកម្ពុជាវិញដែរ ប៉ុន្តែ

អាស្រ័យដោយផលប្រយោជន៍ជាយុទ្ធសាស្ត្ររបស់គេ ក្នុងការប្រឆាំងកម្ពុជា និងវៀតណាម ពួកគេត្រូវតែផ្តល់ការគាំទ្រចំពោះពួកខ្មែរក្រហម ដើម្បីបង្ហូរឈាមប្រជាជនកម្ពុជា និងវៀតណាម ព្រោះខ្មែរក្រហមមានកម្លាំងយោធា ដែលមានលទ្ធភាពធ្វើអោយវៀតណាមចេញឈាមពីខ្លួន ប៉ុន្តែខ្មែរក្រហមកំពុងប្រឈមមុខនឹងគ្រោះថ្នាក់នៃការបាត់តួនាទីខាងនយោបាយ។ ដើម្បីធ្វៀតប្រើលទ្ធភាពខាងយោធារបស់ខ្មែរក្រហម អាមេរិក អាស៊ាន ត្រូវតែដាក់ការគាបសង្កត់ចំពោះ សីហនុ និង សឺន សាន ដើម្បីអោយចូលទ្រុងខ្លា មានន័យថា ដើម្បីប្តូរយកនូវលទ្ធភាពខាងយោធារបស់ពួក ប៉ុល ពត អាមេរិក អាស៊ាន ត្រូវសងតម្លៃ ដោយការធ្វើសម្បទានខាងនយោបាយ តាមរយៈនៃការប្រើប្រាស់តួនាទី សីហនុ-សឺន សាន ដើម្បីបិទបាំងឧក្រិដ្ឋកម្មរបស់ពួក ប៉ុល ពត។

ការតថ្លៃគ្នាបានប្រព្រឹត្តទៅ ដូចជាការផ្លាស់ប្តូរទំនិញពិសេសមួយ។ ពួកខ្មែរក្រហមសុខចិត្តលះបង់នូវតំណែងប្រធានាធិបតី និងនាយករដ្ឋមន្ត្រីអោយ សីហនុ និង សឺន សាន ដើម្បីប្តូរមកវិញនូវការដែលសីហនុ និង សឺន សាន សុខចិត្តទទួលយកនូវក្របខ័ណ្ឌនៃកម្ពុជាប្រជាធិបតេយ្យ ទាំងរចនាសម្ព័ន្ធ ទាំងរដ្ឋធម្មនុញ្ញ ទាំងភ្លេងជាតិ សញ្ញាជាតិ ទង់ជាតិ គឺរក្សាទាំងអស់ ដែលពួក ប៉ុល ពត តែងតែនិយាយថា "ពួកយើង (ខ្មែរក្រហម) សុខចិត្តអោយ សីហនុ អង្គុយលើកៅអីដ៏ខ្ពស់របស់យើង ហើយយើងជាអ្នកសែង សែងទៅតាមផ្លូវណាស្រេចលើអ្នកសែង" មានន័យថាសម្ព័ន្ធភាពត្រីភាគីនៅក្នុង "កប៉ាល់របស់ពួក ប៉ុល ពត ហើយ ប៉ុល ពតជាអ្នកកាន់ចង្កូត"។ ប្រការមួយដែលចាំបាច់ត្រូវពិនិត្យអោយច្បាស់ គឺចិន និងពួក ប៉ុល ពត បានទាមទារបញ្ចូលនូវលក្ខខណ្ឌមួយក្នុងកិច្ចព្រម

ព្រៀងកូឡាឡាំពួរ ស្តីពីការបង្កើតរដ្ឋាភិបាលចម្រុះគឺ "ប្រសិនបើរដ្ឋាភិបាលចម្រុះទាល់ច្រក និងបែកបាក់ទៅ កម្ពុជាប្រជាធិបតេយ្យ ដែលមាន ខៀវ សំផន ជាប្រធាន មានសិទ្ធិធ្វើសកម្មភាពឡើងវិញ ក្នុងឋានៈជារដ្ឋកម្ពុជាប្រជាធិបតេយ្យស្របច្បាប់ និងពេញលក្ខណច្បាប់តែមួយគត់នៃប្រទេសកម្ពុជា" មានន័យថា ពួកខ្មែរក្រហមជាមេក្រុមហ៊ុន និងជាម្ចាស់កប៉ាល់ បើបែកបាក់គ្នា រកស៊ី ជាមួយគ្នាលែងបាន សុំចុះចេញតែខ្លួនចុះ គ្មានការកាត់កប៉ាល់ជាចំណែកៗ ដើម្បីចែកគ្នាឡើយ ហើយកប៉ាល់ ដែលមានឈ្មោះ កម្ពុជាប្រជាធិបតេយ្យ នឹងបន្តដំណើរដោយគ្មាន សីហនុ និង សឺន សាន។ សីហនុ សឺន សាន អុក ប៉ុល ពត មួយគោល ស៊ីបានកូនត្រីមួយ ឯ ប៉ុល ពត អុក ត្រឡប់មកវិញមួយសេះ ស៊ីបានទាំងទូក ទាំងគោល អស់ទាំងត្រីបក ស្ទើរតែនឹងស្លាប់ទាំងខុន (ស្តេច) ថែមទៀត។

ប៉ុល ពត បានឆ្លៀតយកចំណេញយ៉ាងច្រើនពីការបង្កើតរដ្ឋាភិបាលចម្រុះ។ វាគ្រាន់តែបានធ្វើសម្បទានដ៏តិចតួចអោយ សីហនុ សឺន សាន តែវាបានចំណេញមកវិញយ៉ាងច្រើន ក្នុងការរក្សាកៅអីវានៅអង្គការសហប្រជាជាតិ ហើយវាប្រើឈ្មោះ សីហនុ ដើម្បីចលនាអូសទាញប្រជាជនកម្ពុជាអោយទៅតាមវាទៀត។

ចិនក៏បានចំណេញយ៉ាងច្រើន ពីរដ្ឋាភិបាលចម្រុះ អាស្រ័យដោយពួក ប៉ុល ពត មានកម្លាំងខ្លាំងជាងគេ ហើយចិន ជាអ្នកផ្គត់ផ្គង់ដ៏សំខាន់នូវអាវុធគ្រាប់រំសេវ និងជំនួយផ្សេងៗ ទៀត អោយ ប៉ុល ពត និងក្រុមពីរផ្សេងទៀតនោះ បានធ្វើអោយចិនមានតួនាទីជាអ្នកបញ្ជាចំពោះរដ្ឋាភិបាលចម្រុះនេះ ហើយវាក៏បានបង្កើតនូវភាពងាយស្រួលដល់ការជ្រៀតជ្រែកដោយអាវុធពីសំណាក់ប្រទេសចិន តាមរយៈខ្មែរក្រហម ប្រឆាំងប្រជាជនកម្ពុជា

ផងដែរ។

ការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគី បានបញ្ចៀសនូវគ្រោះថ្នាក់ខាងនយោបាយចំពោះពួក ប៉ុល ពត បានមួយរយៈ ប៉ុន្តែ មិនអាចបញ្ចៀសនូវគ្រោះថ្នាក់នៃកម្លាំងយោធា ប៉ុល ពត ដែលត្រូវទទួលការបោសសំអាតជាប្រចាំពីប្រជាជនកម្ពុជានោះឡើយ ហើយក៏មិនបានជួយអោយ សីហនុ និង សឺន សាន ចេញផុតពីភាពទន់ខ្សោយខាងកម្លាំងយោធានោះដែរ។ **សំខាន់ជាងទៀត សម្ព័ន្ធភាពនៃបងប្អូនដែលជាសត្រូវនឹងគ្នា មិនបាននាំមកនូវការបញ្ចប់ទំនាស់ស៊ីសាច់ហុតឈាមគ្នានោះដែរ។** គេមិនបានដោះស្រាយនូវបញ្ហាឯកភាពគ្នា រវាងពួកខ្មែរនៅខាងក្រៅស្រុក សូម្បីបន្តិចណាក៏គ្មានដែរ។ ពួក ប៉ុល ពត បានខិតខំវាយប្រហារទៅលើ សីហនុ-សឺន សាន យ៉ាងខ្លាំង នៅថ្ងៃ ២៧ មិថុនា ១៩៨២ បន្ទាប់មក នៅថ្ងៃ ២៩ មិថុនា ១៩៨២ និងក្រោយមកទៀត នៅថ្ងៃ ០៨ ខែ កក្កដា ១៩៨២។ ប៉ុល ពត បានចេញសេចក្តីណែនាំជាបន្តបន្ទាប់ចំពោះផ្ទៃក្នុងវា អំពីការបង្កើតរដ្ឋាភិបាលចម្រុះ ដែលវាចាត់ទុកថាសំរេចជោគជ័យ ក្នុងការប្រមូលកម្លាំង សីហនុ-សឺន សាន ប្រឆាំងបដិវត្តន៍កម្ពុជា តែ ប៉ុល ពត ក៏បានអប់រំផ្ទៃក្នុងអោយប្រុងប្រយ័ត្ន អំពីឧបាយកលរបស់ សីហនុ និង សឺន សាន ដែលមានបំណងដណ្តើមអំណាចពី កម្ពុជាប្រជាធិបតេយ្យ។ តាមឯកសាររបស់ ប៉ុល ពត ថ្ងៃ ២៧ មិថុនា១៩៨២ បានវិភាគថា "ធាតុពិតរបស់ សីហនុ ជាសក្តិភូមិ ធាតុពិតរបស់ សឺន សាន ជានាយទុនកុំប្រាដ័រ ដែលអ្នកទាំងពីរមកដណ្តើមអំណាចពីកម្ពុជាប្រជាធិបតេយ្យយើង ដើម្បីបំរើវណ្ណៈគេ ដើម្បីជិះជាន់ជាតិ និងប្រជាជនតទៅទៀត" ហើយពួកវាបានលើកវិធានការ "ត្រូវប្រុងប្រយ័ត្នចំពោះឧបាយកលគ្រប់ប្រភេទរបស់ពួក សីហនុ និង សឺន សាន"។ តាំងពី

ពាក្យពេចន៍ ឃ្លានីមួយៗ នៃសេចក្តីថ្លែងការណ៍កូឡាឡាំពួរ ពួក ប៉ុល ពត បានបកស្រាយក្នុងប្រៀបជាអ្នកដើរលើ សីហនុ និង សឺន សាន ដូចជាពាក្យ "រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចម្រុះ" ដោយហាមឃាត់ក្នុងជួរវាកុំអោយប្រើពាក្យ "រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ" ដែលនាំអោយបាត់ភាពស្របច្បាប់នៃកម្ពុជាប្រជាធិបតេយ្យ។ ពួក ប៉ុល ពត បានកំណត់ច្បាស់តាំងពីដំបូងមកថា "សីហនុ-សឺន សាន ជាសម្ព័ន្ធមិត្តយុទ្ធវិធី ជាសម្ព័ន្ធមិត្តបណ្តោះអាសន្ន" ហើយដោយផ្អែកលើសារជាតិនៃទំនាស់វណ្ណៈ ចាំបាច់ត្រូវតែដោះស្រាយភ្លាម ក្រោយពេលដណ្តើមបានរដ្ឋអំណាច។ មិនចាំបាច់ដល់ពេលដណ្តើមបានអំណាចនោះឡើយ ពួក ប៉ុល ពត សីហនុ សឺន សាន បានប្រយុទ្ធគ្នាយ៉ាងតឹងតែង និងជាប្រចាំ ធ្វើអោយទាហាននៃក្រុម សីហនុ និង សឺន សាន ស្លាប់ និងរបួសយ៉ាងច្រើន ហើយដែលធ្វើអោយសម្តេច សីហនុ ប្រកាសលាលែងពីតំណែងច្រើនលើកច្រើនសា តាំងតែពីឆ្នាំនៃការបង្កើតរដ្ឋាភិបាលចម្រុះរហូតមកម្ល៉េះ។

ការបង្កើតរដ្ឋាភិបាលចម្រុះ ក៏មិនបានដោះស្រាយបញ្ហានៃការឯកភាពរវាងក្រុមប្រទេស ដែលជាមេផ្តើមគំនិតបង្កើតរដ្ឋាភិបាលនេះដែរ។ គេមានផលប្រយោជន៍ដោយឡែកៗ ពីគ្នា គេក៏ចង់ឆ្លៀតយកចំណេញ ពីសង្គ្រាមនៅកម្ពុជា តាមទិសដៅនយោបាយរបស់គេរៀងៗ ខ្លួន។ បញ្ហាចោទឡើងគឺ បញ្ហា "ប៉ុល ពត" និងកំរិតនៃ "ឥទ្ធិពលរបស់ ចិន ក្នុងដំបន់អាស៊ីអាគ្នេយ៍" ដែលប្រទេសអាស៊ានមួយចំនួន មានការព្រួយបារម្ភ ក្នុងពេលដែល ថៃទាក់ទិនជ្រៅក្នុងនយោបាយរបស់ ចិន។

ជាមួយនោះ ការបង្កើតរដ្ឋាភិបាលចម្រុះ ក៏មិនបានអូសទាញបណ្តាប្រទេស ក្នុងនោះមានប្រទេសប៉ែកខាងលិចផងដែរ អោយទទួលស្គាល់

*រដ្ឋាភិបាលចម្រុះនោះដែរទេ  អាស្រ័យដោយរដ្ឋាភិបាលនេះមានពួកខ្មែរក្រហម។*

*តើសម្ព័ន្ធភាពនៃបងប្អូន ដែលជាសត្រូវនឹងគ្នា មានការវិវត្តន៍របៀបណា យើងសូមលើកចំនុចខ្លះៗ ជំពាបបន្តនៅផ្នែកខាងក្រោយទៀត។*

## ការវាយបំបែកត្រីកោណលើកទី ២ និង
## ដំណាក់កាលក្រោយរបស់យុទ្ធសាស្ត្រ

*គួររំលឹកថា មុនការវាយបំបែកលើកទីមួយ និងក្នុងចន្លោះនៃការវាយបំបែកលើកទីមួយ និងលើកទីពីរ ពួក ប៉ុល ពត ក៏ដូចជាចៅហ្វាយរបស់គេ មានបំណងផ្តួលរំលំ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា តាមវិធានការយោធា។ ដូច្នេះ ក្នុងដំណាក់កាលនេះ គេប្រើប្រាស់ "វិធានការយោធាជាសំខាន់ គួបផ្សំនឹងវិធានការនយោបាយ សេដ្ឋកិច្ច ការទូត"។ រយៈពេលនោះ ទោះបីជាមានការអំពាវនាវពីបណ្តាប្រទេសឥណ្ឌូចិនអោយធ្វើការចរចាដោះស្រាយបញ្ហាកម្ពុជាដោយសន្តិវិធីក្តី ហើយទោះបីពួកអ្នកប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា និយាយដោយខ្លួនឯងថាចង់ដោះស្រាយបញ្ហាកម្ពុជាតាមផ្លូវនយោបាយក្តី ក៏ពួកគេគ្មានអើពើអ្វីចំពោះការចរចាដែរ ព្រោះការស្រមើស្រមៃក្នុងការផ្តួលរំលំកម្ពុជាតាមវិធានការយោធាកំពុងគ្របដណ្តប់ទៅលើគំនិតរបស់ពួកគេ។ ដូច្នេះការផ្សងព្រេងតាមផ្លូវយោធាត្រូវបន្តទៅទៀត ហោចណាស់ក៏ជាការគាបសង្កត់ ដើម្បីអោយយើងទទួលយកលក្ខខណ្ឌនយោបាយ ហើយជាបន្តទៀត គេនឹងផ្តួលតាមកម្លាំងយោធា។*

*ក្រោយបរាជ័យនៃការវាយបំបែកលើកទី ១ និងបរាជ័យនារដូវប្រាំងឆ្នាំ ១៩៨១-១៩៨២ ពួកសត្រូវនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើសកម្មភាពយ៉ាងខ្លាំងនៅខាងក្រៅ ដើម្បីបង្កើតឡើងនូវរបស់ដែលហៅ*

ថា "រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចម្រុះត្រីភាគី"។ ចិន បន្តលើកឡើងនូវអ្វីដែលគេហៅថា "មេរៀនទី ២ អោយវៀតណាម" ហើយត្រៀមនឹងធ្វើការគាបសង្កត់ចំពោះសហភាពសូវៀត ក្នុងពេលចរចា សូវៀត-ចិន តាមរយៈនៃការលើកឡើងនូវ "ឧបសគ្គបីក្នុងការកែលំអរទំនាក់ទំនងសូវៀត-ចិន"។

នៅក្នុងប្រទេស ពួក ប៉ុល ពត បានផ្លាស់ប្តូរយុទ្ធវិធី។ ក្រោយបាត់បង់ទីតាំងមួយចំនួននៅព្រំដែន ពួកវាផ្តើមគំនិតបញ្ជូនកម្លាំងចូលមកផ្ទៃក្នុង ដើម្បីបង្កការលំបាកអោយយើងនៅផ្ទៃក្នុងប្រទេស រាំងស្កាត់ការដឹកជញ្ជូនផ្គត់ផ្គង់នៅព្រំដែន បង្ខំអោយយើងដកកម្លាំងពីព្រំដែនមកទប់ទល់សភាពការណ៍នៅខាងក្នុង ដើម្បីពួកវាមានឱកាសដណ្តើមយកនូវទីតាំងដែលត្រូវបាត់ ហើយពង្រឹកថែមនូវទីតាំងតាមព្រំដែន កម្ពុជា-ថៃ ដើម្បីបង្កើតឡើងនូវរបស់ដែលហៅថា "ដំបន់ត្រួតពិនិត្យពីរ និងរដ្ឋាភិបាលពីរនៅកម្ពុជា"។ ការរៀបចំដំបន់ត្រួតពិនិត្យរបស់ពួកប្រឆាំងបដិវត្តន៍នៅពេលនេះ មិនមែនជាទីតាំងយោធាសុទ្ធសាធទេ តែគឺជាការរៀបចំមានចរិតជារចនាសម្ព័ន្ធសង្គមមួយ ដែលមានទាំងយោធា នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ រហូតដល់មានទីតាំងការទូត ដែលមានកន្លែងទទួលនូវសារតាំងអគ្គរដ្ឋទូតប្រទេសមួយចំនួន របស់ប្រធានកម្ពុជាប្រជាធិបតេយ្យចម្រុះនៅ ភ្នំមេឡៃ។ ពួកគេបានប្រើប្រាស់ជនភៀសខ្លួនធ្វើជាកម្លាំងនយោបាយ ហើយរុញទីតាំងជាបណ្តើរៗ ចេញពីដីថៃ ចូលមកក្នុងកម្ពុជា។ ខ្មាំងប៉ុនប៉ងប្រើប្រាស់បញ្ហានេះ ដើម្បីអោយមានលក្ខណៈស្របច្បាប់នៅអង្គការសហប្រជាជាតិ ប្រើប្រាស់ជាការឃោសនា បោកបញ្ឆោតអោយគេឯងឃើញថាកម្ពុជាប្រជាធិបតេយ្យ ដែលបានប្រជាជនដេញចេញពីអំណាចទៅហើយ

*នោះ បានត្រួតត្រាទឹកដី ហើយមានប្រជាជនមួយផ្នែកដែរ។ ខ្មាំងក៏បានប្រើប្រាស់ទីតាំងតាមព្រំដែនដើម្បីបញ្ជូនកម្លាំងចូលមកផ្ទៃក្នុង ដើម្បីបង្កអស្ថិរភាព ហើយរៀបចំកម្លាំងបង្កប់សម្ងាត់ ដើម្បីត្រៀមឱកាសដែលខ្មាំងហៅថា ដល់ដំណាក់កាលណាមួយនោះ ខ្មាំងនឹងអនុវត្តនូវយុទ្ធសាស្ត្រ "វាយដៃទាំងពីរ" ដើម្បីផ្តួលរំលំរដ្ឋអំណាចរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា គឺវាយពីព្រំដែនចូលមកផងគួបផ្សំនឹងកម្លាំងនៅផ្ទៃក្នុងបះបោរឡើងផង។*

*ខែ មិថុនា ១៩៨២ ប៉ុល ពត បានចេញបទបញ្ជាដល់ថ្នាក់ក្រោមរបស់វា អោយជំរុញកសាងកម្លាំងស្នូលសម្ងាត់ ចាត់តាំងកម្លាំងសម្ងាត់នៅតាមភូមិឃុំទាំងអស់ ហើយវាយពង្រេចពង្រើលកម្លាំងបដិវត្តកម្ពុជា និងកងទ័ពវៀតណាម។ ក្នុងពេលជាមួយគ្នានេះដែរ ពួក ប៉ុល ពត បានចេញបទបញ្ជាអោយវាយ "កំចាត់កំចាយរដ្ឋអំណាចភូមិឃុំ"* ***នេះជាជំហានថយក្រោយខាងនយោបាយ បើប្រៀបធៀបនឹងផែនការរបស់ពួក ប៉ុល ពត នាពេលមុនៗ*** *ពីឆ្នាំ ១៩៧៩ មក ពួក ប៉ុល ពត មានផែនការប្រែក្លាយរដ្ឋអំណាចបដិវត្តអោយទៅជារដ្ឋអំណាចមុខពីរ ប៉ុន្តែផែនការនេះមិនអាចអនុវត្តបាន ពោលគឺរដ្ឋអំណាចបដិវត្តមិនគ្រាន់តែមិនបំរើអោយខ្មាំង ប៉ុន្តែបែរជាកម្លាំងវាយខ្មាំងដ៏មានប្រសិទ្ធភាព ធ្វើអោយបរាជ័យនូវឧបាយកលខ្មាំងក្នុងការទន្ទ្រានដី ទន្ទ្រានយករដ្ឋអំណាច និងប្រជាជន ទន្ទ្រានខាងចិត្តសាស្ត្រប្រជាជន និងធ្វើអោយការរើបំរះប៉ុនប៉ងផ្ទេរចូលដំណាក់កាលប្រទាញប្រទង់ ត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរដែលតម្រូវអោយពួក ប៉ុល ពត ដកថយពីការប្រើវិធានការសន្តិវិធីទៅជាវិធានការដៃក្តៅ ដោយបញ្ជាអោយកម្លាំងវាវាយបំផ្លាញរដ្ឋអំណាច ភូមិ ឃុំ ដែលជាការបង្កើត*

ឡើងនូវការក្តៅក្រហាយ មិនត្រឹមតែចំពោះ ប្រជាជនប៉ុណ្ណោះទេ ថែម ទាំងពួកកម្មាភិបាល យុទ្ធជន ក្នុងកងកម្លាំង ប៉ុល ពត ផង ព្រោះការវាយ ភូមិ វាប៉ះពាល់ចំពោះគ្រួសាររបស់គេដែរៗ ចាប់ពីពេលនោះមក ពួក ប៉ុល ពត បានបង្កើនសកម្មភាពវាយទៅលើ គោលដៅស៊ីវិល ហើយខិតខំជៀស វាងនូវការប្រយុទ្ធជាមួយកម្លាំងយោធារបស់យើង និងយោធាវៀតណាមៗ

ក្រោយរដូវប្រាំងឆ្នាំ ១៩៨២-១៩៨៣ ពួក ប៉ុល ពត រៀបចំនូវផែន ការបើបំរះជាលើកទីពីរ ដើម្បីឈានទៅដំណាក់កាលវាយសំរុកដណ្តើម រដ្ឋអំណាចនៅទូទាំងប្រទេសៗ ខែមីនា ១៩៨៣ ប៉ុល ពត បានលើក ឡើងនូវផែនការ ២ ឆ្នាំ បំរុងនឹងឈានទៅដណ្តើមជ័យជំនះផ្តាច់ព្រ័ត្រ នៅឆ្នាំ ១៩៨៥ ហើយបើយឺតបំផុតនៅឆ្នាំ ១៩៨៦ៗ ពេលនោះ ខ្មាំង បានធ្វើការសន្និដ្ឋាននូវការប្រៀបធៀបកម្លាំងថា "ដើមឆ្នាំ ១៩៨៤ ដល់ ពាក់កណ្តាលឆ្នាំ ១៩៨៤ កម្លាំងយើង ១ ទល់នឹងខ្មាំង ១ ចុងឆ្នាំ ១៩៨៤ ដល់ដើមឆ្នាំ ១៩៨៥ កម្លាំងយើង ១ ទល់នឹងខ្មាំង ០,៨០ ឬ ០,៧០ គឺយើង ១០០ ទល់នឹងខ្មាំង ៨០ ឬ ៧០ ដូច្នេះដល់ឆ្នាំ ១៩៨៥ យើងឈានទៅវាយសំរុកដណ្តើមជ័យជំនះផ្តាច់ព្រ័ត្រ ហើយរំដោះ ប្រទេសកម្ពុជាទាំងស្រុង"ៗ ផ្អែកលើការវាយតម្លៃដ៏ល្ងិតល្ងង់នេះ ប៉ុល ពត មានផែនការចាត់ទុកឆ្នាំ ១៩៨៤ ជាឆ្នាំធ្វើអោយសភាពការណ៍ ផ្លាស់ប្តូរជាសារវ័ន្តៗ តាមទ្រឹស្តីរបស់ពួក ប៉ុល ពត គឺនៅពេលដែល បានឈានដល់ ដំណាក់កាលចុងក្រោយ នៃដំណាក់កាលប្រទាញ ប្រទង់ជាយុទ្ធសាស្ត្រហើយ កម្លាំងវានឹងប្រហាក់ប្រហែលគ្នាអំពីចំនួន ទ័ពជាមួយយើង និងមិត្តវៀតណាម គឺវានឹងប្រុងប្រៀបឈានទៅបើក ការវាយសំរុកជាយុទ្ធសាស្ត្រៗ ពេលនេះ ប៉ុល ពត បញ្ជាអោយកម្លាំង

របស់វាបង្កើនកងទ័ពស្រួចអោយបានឆាប់ ទាំងថ្មើរជើង ទាំងកាំភ្លើងធំ និងទ័ពពិសេស ដើម្បីវាយកំទេចនូវទីតាំងថ្នាក់អនុសេនាតូច អនុសេនាធំ វរៈសេនាតូចរបស់កងទ័ពយើង និងមិត្តវៀតណាម និងវាយយើងនៅតាមកំណាត់ផ្លូវ ដើម្បីបង្កឡើងនូវអានុភាពបើកការវាយសំរុកជាយុទ្ធសាស្ត្រ គឺការវាយសំរុកជាទូទៅ។

ដើម្បីអនុវត្តឧបាយកលនេះ ខែ មេសា ១៩៨៣ ប៉ុល ពត បានចេញសារាចរណែនាំមួយហៅថា "សកម្មភាពឈ្លបរំលំរដ្ឋអំណាចភូមិឃុំ និងកសាងរដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យ" ដែលន័យសំខាន់គឺជំរុញសកម្មភាពវាយបំផ្លាញភូមិ ឃុំ ដោយដាក់ផែនការអោយវាយសាចុះសាឡើង ហើយចាត់តាំងរដ្ឋអំណាចវាអោយបានពី ៣០ ទៅ ៤០ ភាគរយ នៅថ្នាក់ឃុំ នៅឆ្នាំ ១៩៨៤ និងពីដើមឆ្នាំ ១៩៨៥ ដល់ខែមិថុនា ១៩៨៥ ត្រូវចាត់តាំងរដ្ឋអំណាចថ្នាក់ឃុំអោយបានពី ៣០ ទៅ ៤០ ភាគរយទៀត ព្រមទាំងចាត់តាំងរដ្ឋអំណាចភូមិអោយបានពី ៦០ ទៅ ៩០ ភាគរយនៅខែ មីនា ឆ្នាំ ១៩៨៥ ហើយឈានទៅរំលាយរដ្ឋអំណាចបដិវត្តរហូតដល់ថ្នាក់ខេត្ត ដើម្បីចាត់តាំងរដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យ។

ពួក ប៉ុល ពត ថែមទាំងចេញសេចក្តីសំរេចលើកផែនការដ៏ទូលំទូលាយក្នុងការរំដោះ ដែលវាកំណត់ថា រដូវវស្សាឆ្នាំ ១៩៨៣ ត្រូវរំដោះអោយបានទាំងស្រុងនូវរណសិរ្សទី ១ គឺភាគខាងលិចទន្លេសាបទាំងអស់ និងរណសិរ្សទី ២ គឺ ភាគខាងកើតទន្លេសាបទាំងអស់ ហើយដល់រដូវប្រាំងឆ្នាំ ១៩៨៣-១៩៨៤ គឺត្រូវផ្តាច់ទាំងស្រុងនូវផ្លូវដែក និងផ្លូវជាតិលេខ ៥ លេខ ៦ និងលេខ ៧ ដើម្បីឯកោភ្នំពេញពីបណ្តាខេត្ត។

រាល់វិធានការដែលពួក ប៉ុល ពត បានលើកឡើង គឺជាការផ្សង

ព្រេងប្រកបដោយមហិច្ឆិតា "នេះជាការជាំចង្រៃនមិនប្រមាណផ្ទាំង" ដែលជាទម្លាប់របស់ពួក ប៉ុល ពត។

គួររំលឹកថា ទន្ទឹមនឹងការត្រៀមរើបំរះរបស់ពួក ប៉ុល ពត នៅផ្ទៃក្នុងកម្ពុជា ចិន និងពួកចក្រពត្តិ បានខិតខំធ្វើសកម្មភាពយ៉ាងខ្លាំង ដើម្បីប្រឆាំងបណ្តាប្រទេសនៅឥណ្ឌូចិន។ ថៃ ទន្ទឹមនឹងធ្វើសកម្មភាពយោធាដោយផ្ទាល់ក្នុងការឈ្លានពានកម្ពុជា និងជួយពួក ប៉ុល ពត គេនៅបានធ្វើការឈ្លានពានទៅលើភូមិបីនៅខេត្ត សាយ៉ាបូរី របស់ឡាវ បង្កអោយមានភាពតានតឹងជាខ្លាំង ក្នុងទំនាក់ទំនងរវាងប្រទេសទាំងពីរ។ ឯ ចិន បានលើកឡើងនូវរបស់ដែលហៅថា ដាក់មេរៀនទី ២ អោយវៀតណាម ដែលមានចំនុចចម្លែកមួយត្រង់ថា "មេរៀនទី ២ នេះ មិនបង្កអោយមានសង្គ្រាមរវាងវៀតណាម-ចិន ដូចមេរៀនទី ១ ឡើយ" មានន័យថា គេចង់ប្រើប្រាស់ការរើបំរះរបស់ពួក ប៉ុល ពត នៅកម្ពុជា គួបផ្សំទៅនឹងការបង្កចលាចលនៅទីក្រុងហូជីមិញ និងភាគខាងត្បូងវៀតណាម ដែលចិន បានធ្វើឡើងដើម្បីសង់សឹកវៀតណាម។ ពួកប្រតិកិរិយាអន្តរជាតិ បានដំណើរការយ៉ាងសកម្ម ដើម្បីរៀបចំអោយមានអស្ថិរភាពនៅភាគខាងត្បូងវៀតណាម តាមរយៈពួកប្រតិកិរិយាក្បត់បដិវត្តន៍នៅវៀតណាម ដែលក្នុងនោះមានទាំងការលួចបញ្ចូលនូវក្រដាសប្រាក់ក្លែងក្លាយរាប់រយលានដុង មកធ្វើវិច្ឆេទកម្មសេដ្ឋកិច្ចផង។ ខ្មាំងប៉ុនប៉ងធ្វើអោយភាគខាងត្បូងវៀតណាមចលាចល ដើម្បីអូសទាញកម្លាំងវៀតណាមនៅកម្ពុជាទៅទីនោះ ហើយបង្កឱកាសអោយពួក ប៉ុល ពត រើបំរះនៅកម្ពុជា។ ប៉ុន្តែ ឧបាយកលរបស់ខ្មាំង ក្នុងការប្រឆាំងបដិវត្តន៍វៀតណាម ត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរ ដែលចុងក្រោយ តុលាការប្រជាជនបដិវត្តទី

ក្រុងហូជីមិញ បានយកពួកនេះទៅកាត់ទោស នាចុងឆ្នាំ ១៩៨៤ ដែលមានទាំងជនបរទេសខ្លះផង។

គប្បីរំលឹកដែរថា ក្រោយការបង្ក្រាបប្រកបដោយជោគជ័យនៃសកម្មភាពអើបំរះរបស់ខ្មាំងលើកទី ១ និងជ័យជំនះរដូវប្រាំងឆ្នាំ ១៩៨១-១៩៨២ បក្ស និងរដ្ឋាភិបាលប្រទេសទាំងពីរ កម្ពុជា និងវៀតណាម បានពិនិត្យឃើញ នូវការរីកធំធាត់នៃកម្លាំងការពារជាតិរបស់កម្ពុជា ហើយបានឯកភាពគ្នាប្រកាសដកកងទ័ពវៀតណាមជាផ្នែកៗ ចេញពីកម្ពុជា ហើយបានដំណើរការដកជាលើកទី ១ ប្រមាណ ១០.០០០ នាក់ នៅខែ កក្កដា ឆ្នាំ ១៩៨២ និងក្រោយសន្និសីទកំពូលរបស់ប្រទេសទាំងបី នៅវៀងច័ន្ទ ឆ្នាំ ១៩៨៣ បានដំណើរការដកជាលើកទី ២ ដែលមានចំនួនប្រមាណ ១០.០០០ នាក់ទៀត។ ពិតមែនហើយ ការដកកងទ័ពស្ម័គ្រចិត្តវៀតណាមជាលើកដំបូង ត្រូវជួបនឹងព្រឹត្តិការណ៍មិនជាល្អប៉ុន្មានទេ អាស្រ័យដោយប្រជាជនមានការខ្លាចការវិលត្រឡប់របស់ពួក ប៉ុល ពត ដូច្នេះក៏បង្កើតឡើងនូវការព្រួយបារម្ភពីសំណាក់ប្រជាជនកម្ពុជា ដែលគេសុំកុំអោយមានការដកកងទ័ពវៀតណាម។ បក្ស និងរដ្ឋយើង បានពិនិត្យឃើញថា កម្លាំងផ្ទាល់របស់ប្រជាជនកម្ពុជា កំពុងរីកធំធាត់ពេញរូបពេញរាង ដែលអាចឈានទៅរ៉ាប់រងភារកិច្ចការពារប្រទេសដោយខ្លួនឯងជាបណ្តើរៗ ហើយព្រមទាំងបានកំណត់ជាគោលការណ៍ថា យើងធានាបានកំរិតណា គឺដកកងទ័ពវៀតណាមកំរិតនោះ ដែលធានាមិនអោយមានការប្របូកប្របល់ឡើយ។ ការព្រួយបារម្ភរបស់ប្រជាជន សំខាន់បណ្តាលមកពីមិនទុកចិត្តលើកម្លាំងខ្លួនឯង ដែលចាំបាច់យើងត្រូវអប់រំអំពីស្មារតី ខ្លួនទីពឹងខ្លួនអោយបានល្អ។

ពេលពួក ប៉ុល ពត វើបំរះជាលើកទី ២ នេះ គឺយើងអាចបង្រ្កាបបាន អាស្រ័យដោយកម្លាំងរបស់កម្ពុជាមានការរីកចំរើន ពិសេសកម្លាំងនៅមូលដ្ឋានដែលបង្កលក្ខណៈអោយកងទ័ពស្ម័គ្រចិត្តវៀតណាម ទោះបីនៅមានចំនួនតិច បើប្រៀបធៀបនឹងពេលមុន ដោយមានការដកទ័ពអស់ចំនួន ២ លើករួចមកហើយ បានប្រមូលផ្តុំរួមសហការជាមួយ កងទ័ពស្រួច និងកងទ័ពដំបន់របស់កម្ពុជា បំពេញភារកិច្ចសំខាន់ៗ ពិសេសគឺភារកិច្ចបង្រ្កាបនូវការវើបំរះរបស់ខ្មាំងនេះ។

ដើមឆ្នាំ ១៩៨៤ ការវើបំរះរបស់ខ្មាំងបានចាប់ផ្តើម។ ឈានចូលក្នុងរដូវប្រាំងក្លាម ខ្មាំងបានចាប់ផ្តើមវាយយើងក្លាម ដែលមានចរិតកាចសាហាវហើយមានទ្រង់ទ្រាយធំបង្គួរ ប៉ុនប៉ងកាច់បំបាក់កម្លាំងយើងនៅតំបន់មួយចំនួន ហើយសំខាន់គឺទប់ស្កាត់ការវាយសំរុកក្នុងរដូវប្រាំងរបស់យើង ហើយបន្តរក្សាភាពខ្លាំងរបស់វានៅព្រំដែន។ សំខាន់ជាងទៀត គឺ ប៉ុនប៉ងធ្វើអោយសភាពការណ៍អស្ថិរភាពនៅផ្ទៃក្នុង ដើម្បីបង្កប្រៀបឈានទៅវាយសំរុកផ្តាច់ព្រ័ត្រ ដែលផែនការរបស់វាត្រូវធ្វើនៅក្នុងឆ្នាំ ១៩៨៥។ យើងត្រូវទទួលស្គាល់ថា ពេលនោះកម្មាភិបាលរបស់យើងនៅកន្លែងមួយចំនួនអត្តនោម័តិ សន្តិភាពនិយម ខ្វះស្មារតីប្រុងប្រយ័ត្ន ដោយហេតុថាដើមឆ្នាំ ១៩៨៤ ជាបុណ្យខួបលើកទី ៥ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅមូលដ្ឋានមួយចំនួនរវល់នាំគ្នាធ្វើបុណ្យ ហើយសប្បាយនឹងជ័យជំនះ។ ខ្មាំងឆក់ឱកាសនេះ ដើម្បីវាយទៅលើកន្លែងមួយចំនួនបង្កអោយមានការខូចខាតដល់អាយុជីវិត និងទ្រព្យសម្បត្តិប្រជាជន។

ការវើបំរះរបស់ពួក ប៉ុល ពត ត្រូវទទួលការវាយបកយ៉ាងដំណំពីកម្លាំងយើង និងកងទ័ពវៀតណាម ដែលធ្វើអោយការវើបំរះនេះត្រូវ

រួញទៅវិញ។ ប្រការដែលពួក ប៉ុល ពត មិនអាចពង្រីកការវាយសំរុកបាន មានហេតុផលច្រើន តែហេតុផលសំខាន់បំផុត គឺគ្មានប្រជាជនគាំទ្រ ថែមទាំងត្រូវទទួលការវាយពីប្រជាជនមកវិញផង។ យើងម្ចាស់ការវាយសំរុក មិនត្រឹមតែទប់ទល់ប៉ុណ្ណោះទេ គឺយើងឈានទៅបើកការវាយសំរុកនៅតាមព្រំដែនកម្ពុជា-ថៃ ហើយដណ្តើមបាននូវទីតាំងមួយចំនួនដូចជា តាសាញ់ សំឡូត ណាមតា ចំណុចខ្ពស់ ៥៤៧ និងតាមប្រវែងបណ្តោយព្រំដែនកោះកុង ដែលធ្វើអោយខ្មាំងត្រូវបាត់បង់បង្អែកមួយចំនួនថែមទៀត។ ដូច្នេះ ជាទូទៅ ខ្មាំងគ្មានបានទទួលផលអ្វីពីការរើបំរះលើកទី ២ នេះទេ ហើយក៏មិនបានបង្កើតនូវប្រៀបជាយុទ្ធសាស្រ្តសំរាប់ឈានទៅបើកការវាយសំរុកក្នុងឆ្នាំ ១៩៨៥ ដូចដែលវាប៉ុនប៉ងនោះឡើយ។ ផ្ទុយទៅវិញ ក្រោយពេលបរាជ័យ ខ្មាំងត្រូវស្ថិតក្នុងសភាពការណ៍ការពារខ្លួននៅព្រំដែន ហើយដំណើរការវាយឈ្លបតូចតាចនៅផ្ទៃក្នុងជាបន្តទៅទៀត។

ក្នុងពេលពួក ប៉ុល ពត បរាជ័យនៅកម្ពុជា ចិនបានបង្កើនសកម្មភាពគាបសង្កត់នៅព្រំដែនចិន-វៀតណាម ដោយបានបាញ់កាំភ្លើងធំរាប់ម៉ឺនគ្រាប់ចូលក្នុងទឹកដីវៀតណាម ហើយមានកន្លែងខ្លះ និងពេលខ្លះ កងទ័ពថ្មើរជើងរបស់ចិន ក៏ចូលមកបង្កឧក្រិដ្ឋកម្មចំពោះប្រជាជនវៀតណាមផង។ ថៃ ក៏បានបង្កើនសកម្មភាពអន្តរាគមន៍ជួយពួក ប៉ុល ពត ដោយប្រើកាំភ្លើងធំបាញ់ស្កាត់ទ័ពយើង ដើម្បីការពារពួក ប៉ុល ពត រហូតប្រើកងថ្មើរជើង និងយន្តហោះវាយប្រហារលើកងទ័ពយើងដោយផ្ទាល់ទៀតផង។

ក្នុងឆ្នាំ ១៩៨៤ ខាងយើងអនុវត្តយុទ្ធវិធីខុសប្លែកពីឆ្នាំមុនៗ ដែល បណ្តា

អ្នកសង្កេតការណ៍យោធាប៉ែកខាងលិច ប្រចាំក្រុង បាងកក ទទួលស្គាល់ថាជា "ការផ្លាស់ប្តូរវិធីរបស់ក្រុងភ្នំពេញ និងវៀតណាម"។ ឆ្នាំមុនៗ យើងតែងបើកការវាយសំរុកនៅរដូវប្រាំង ហើយរដូវវស្សា ត្រូវដកមកពង្រឹងនៅខាងក្រោយវិញ ឯខ្មាំងក៏ឆ្លៀតឱកាសដណ្តើមយកទៅវិញនូវទីតាំងដែលត្រូវបាត់។ ប៉ុន្មានឆ្នាំមុន យើងមានការលំបាកច្រើន ក្នុងការដឹកជញ្ជូនផ្គត់ផ្គង់ចំពោះកម្លាំងយើងនៅព្រំដែនក្នុងរដូវវស្សា ដោយពេលនោះប្រព័ន្ធផ្លូវដឹកជញ្ជូនជួបការលំបាក សំខាន់ជាងទៀតកម្លាំងយើងនៅសមរភូមិក្រោយក៏មិនទាន់ធំធាត់រឹងមាំនៅឡើយ ដូច្នេះ ទាមទារការដកកម្លាំងពីព្រំដែនមកពង្រឹង ដល់រដូវប្រាំងទើបដំណើរការវាយសំរុកតាមព្រំដែនបន្តទៀត។ ឆ្នាំ ១៩៨៤ លក្ខណសម្បត្តិអនុគ្រោះច្រើន ដោយកម្លាំងនៅខាងក្រោយមានការរីកចំរើន ដែលបង្កភាពអនុគ្រោះអោយការបន្តវាយសំរុកនៅព្រំដែនទាំងក្នុងរដូវវស្សា ឬហោចណាស់ការពារទីតាំង ដែលយើងវាយដណ្តើមបានកាលពីរដូវប្រាំង។ ភាពចាំបាច់មួយ ដែលត្រូវតែមានការផ្លាស់ប្តូរវិធីក្នុងរដូវវស្សា ១៩៨៤ នោះ គឺការត្រូវបើកការវាយសំរុកនៅរដូវប្រាំង ១៩៨៤-១៩៨៥។

បក្សយើងបានកំណត់ថា សភាពការណ៍អនុគ្រោះសំរាប់ការវាយដណ្តើមយកចំណុចទាំងអស់ ដែលខ្មាំងបោះទីតាំងនៅតាមព្រំដែនកម្ពុជា-ថៃ លុបបំបាត់នូវស្ថានភាពជំបន់ត្រួតពិនិត្យពីរ និងរដ្ឋអំណាចពីរនៅកម្ពុជា។ មិនគ្រាន់តែត្រូវវាយដណ្តើម ហើយបោះបង់ចោលអោយខ្មាំងដណ្តើមយកទៅវិញនោះទេ ម្តងនេះវាយដល់កន្លែងណាត្រូវរក្សាកន្លែងនោះអោយបាន ហើយឈានទៅរាំងស្កាត់នូវការជ្រៀតដឹកអាវុធគ្រាប់រំសេវចូលមកផ្ទៃក្នុងប្រទេសផង។ ការិយាល័យនយោបាយមជ្ឈិមបក្សប្រជាជនបដិវត្ត

កម្ពុជារួមជាមួយគណៈបញ្ជាការកងទ័ពស្ម័គ្រចិត្តវៀតណាម បានពិភាក្សាគ្នាអស់រយៈពេលដ៏យូរ ដើម្បីរិះរកវិធានការទប់ស្កាត់កុំអោយមានការជ្រៀតចូលរបស់ខ្មាំងដែលទីបំផុតបានដើរដល់ការសន្និដ្ឋានថា "ត្រូវកសាងប្រព័ន្ធការពារព្រំដែនកម្ពុជា-ថៃ"។ ការិយាល័យនយោបាយមជ្ឈិមបក្សបានចេញសេចក្តីសំរេចចិត្តមួយនៅថ្ងៃទី ១២ កក្កដា ១៩៨៤ ស្តីពីការបង្កើនការការពារព្រំដែនកម្ពុជា-ថៃ។ មុនចេញសេចក្តីសំរេចចិត្តនេះ មានការពិភាក្សាយ៉ាងផុលផុសអំពីក្រុបខណ្ឌយុទ្ធសាស្ត្រ និងវិធីអនុវត្តន៍។ យើងបានវាយតម្លៃអំពីចរិត និងរូបភាពនៃសង្គ្រាមដែលខ្មាំងបាន និងកំពុងដំណើរការ និងអាចបន្តដំណើរការនាពេលខាងមុខ។ យើងបានពិនិត្យអំពីទំនាក់ទំនងរវាងសមរភូមិនៅព្រំដែនជាមួយសមរភូមិផ្ទៃក្នុង ដែលពេលនោះបក្សយើងបានកំណត់ថា យើងត្រូវប្រយុទ្ធនៅលើរណសិរ្សពីរ គឺនៅព្រំដែនផង និងនៅផ្ទៃក្នុងប្រទេសផង ព្រោះរណសិរ្សទាំងពីរនោះមានទំនាក់ទំនងជាមួយគ្នាបេះមិនដាច់។ ដើម្បីការពារនូវសុវត្ថិភាព និងភាពសុខសាន្តអោយប្រជាជននៅផ្ទៃក្នុងប្រទេស ត្រូវបង្កើនកិច្ចការពារព្រំដែន ត្រូវវាយយកចំណុចទាំងអស់ ដែលខ្មាំងកាន់កាប់ ហើយកសាងឡើងនូវប្រព័ន្ធការពារព្រំដែន ដើម្បីរាំងស្កាត់ការជ្រៀតចូលរបស់ខ្មាំងមកធ្វើសកម្មភាពនៅខាងផ្ទៃក្នុងប្រទេស ហើយចេញពីនោះ ត្រូវវាយកម្ទាំងនៅខាងក្នុងអោយបានខ្លាំង ដើម្បីពង្រឹងដល់កិច្ចការពារព្រំដែនវិញ។ បក្សយើងក៏បានវាយតម្លៃ អំពីឧបាយកលយូរអង្វែងរបស់អានុភាពប្រតិកិរិយាអន្តរជាតិ ក្នុងសង្គ្រាមនៅកម្ពុជា ក៏ដូចជានៅឥណ្ឌូចិន។ យើងបានសន្និដ្ឋានថា គ្មានពេលណាដែលពួកគេបោះបង់ចោលនូវឧបាយកលប្រឆាំងប្រជាជនកម្ពុជា និងបណ្តាប្រទេសនៅឥណ្ឌូចិនឡើយ។ ជាទម្លាប់

ក្នុងអតីតកាល ថៃដែលជាប្រទេស មានព្រំដែនជាមួយកម្ពុជា តែងតែធ្វើជាមូលដ្ឋានអោយពួកបរទេសប្រឆាំងកម្ពុជា និងឥណ្ឌូចិន ដោយហេតុការណ៍បានបង្ហាញច្បាស់បីជំនាន់មកហើយ គឺពេលជប៉ុនចូលមកអាស៊ីអាគ្នេយ៍ ថៃជាសម្ព័ន្ធមិត្តដ៏គួរអោយទុកចិត្តរបស់ជប៉ុនដើម្បីវាយបារាំងនៅឥណ្ឌូចិន ហើយថៃឆ្លៀតយកចំណេញពីស្ថានការណ៍នេះ ដើម្បីដណ្តើមយកខេត្តមួយចំនួនរបស់កម្ពុជា ដូចជា បាត់ដំបង សៀមរាប កំពង់ធំ ព្រះវិហារ។ ពេលជប៉ុនចាញ់ ហើយបន្ទាប់មកអាមេរិកចូលឈ្លានពានវៀតណាម ឡាវ និងកម្ពុជា ថៃមិនគ្រាន់តែជាមូលដ្ឋានដ៏សំខាន់របស់អាមេរិកប៉ុណ្ណោះទេ តែនៅបានចូលរួមក្នុងសង្គ្រាមនេះដោយផ្ទាល់ផង។ ពេលចិនត្រូវធ្វើសង្គ្រាមជាមួយបណ្តាប្រទេសនៅឥណ្ឌូចិន ថៃក៏បានចូលរួមជាមួយចិន។ ប្រសិនបើគ្មានប្រទេសថៃជាជំរកអោយពួក ប៉ុល ពត និងពួកខ្មែរបដិបក្ខផ្សេងទៀតទេនោះ ពួកនេះមិនអាចបិតបេរបានឡើយ។ ចាប់តាំងពីឆ្នាំ ១៩៨០ មក សាធារណរដ្ឋប្រជាមានិតកម្ពុជា បានលើកឡើងនូវសំណើជាច្រើន ដើម្បីកែលំអទំនាក់ទំនងជាមួយថៃ សំខាន់ដោះស្រាយជម្លោះតាមព្រំដែន ក្នុងនោះមានសំណើបង្កើតដំបន់សន្តិភាពតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដោយមានការត្រួតពិនិត្យពីអន្តរជាតិផង។ ប៉ុន្តែ មិនត្រឹមតែបានបដិសេធជាបន្តបន្ទាប់ប៉ុណ្ណោះទេ តែថៃមទាំងបង្កើនសកម្មភាពឈ្លានពានដោយផ្ទាល់ មកលើកម្ពុជាថែមទៀត។ ក្នុងអតីតកាល ទោះបីរបបណាកាន់អំណាចនៅកម្ពុជាក៏ដោយ ក៏ថៃតែងចិញ្ចឹមទុកនូវកម្លាំងមួយប្រឆាំងរដ្ឋអំណាចកម្ពុជាជានិច្ច។ កាលជំនាន់រាជាណាចក្រកម្ពុជា នៅលើទឹកដីថៃ មានកម្លាំងខ្មែរសេរីដើម្បីប្រឆាំងសម្តេចសីហនុ។ ដល់សម័យសាធារណរដ្ឋខ្មែររបស់ លន់ នល់ ថ្វីត្បិតតែខ្មែរសេរី

ជាច្រើនបានចូលជាមួយ លន់ នល់ ហើយថៃគាំទ្រ លន់ នល់ ក៏ដោយ ក៏នៅមានពួកខ្មែរសេរីមួយចំនួននៅក្នុងប្រទេសថៃដែរ។ ដល់មករបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ទោះបីថៃ មានទំនាក់ទំនងជាមួយរបបនេះក៏ដោយ ក៏ថៃបានជួយពួកប្រដាប់អាវុធខ្មែរសេរីជាច្រើនក្រុមអោយប្រឆាំងជាមួយកម្ពុជាប្រជាធិបតេយ្យ ហើយមកដល់រដ្ឋអំណាចសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺមានទាំងកម្លាំងច្រើនបំផុត និងស្តាំបំផុត ដែលថៃជួយទំនុកបំរុងដើម្បីប្រឆាំងកម្ពុជា។ ដូច្នេះ គ្មានរបបណាមួយនៅកម្ពុជាជៀសរួចពីការជ្រៀតជ្រែក និងប្រឆាំងពីសំណាក់ប្រទេសថៃនោះឡើយ។ នេះយើងមិនបានគិតដល់ប៉ុន្មានទសវត្សរ៍មុន ដែលថៃធ្លាប់បានរក្សាទុកនូវឈើយសឹករបស់ស្តេចខ្មែរនៅប្រទេសថៃ ដើម្បីត្រៀមប្រើប្រាស់ក្នុងការផ្តួលរំលំស្តេចខ្មែរអង្គណា ដែលមិនព្រមចុះញ៉មប្រទេសថៃនោះផង។

ពិនិត្យលើទម្លាប់នៃនយោបាយថៃ ដែលធ្លាប់ធ្វើមកលើប្រទេសកម្ពុជា កាន់តែធ្វើអោយយើងប្រុងប្រយ័ត្ន ពិសេសក្នុងសភាពការណ៍ដែលថៃចូលដៃជាមួយចិន ក្នុងសង្គ្រាមនៅកម្ពុជា។ ម្យ៉ាងទៀត ចំពោះការសំរេចធ្វើប្រព័ន្ធការពារព្រំដែន យើងបានដឹងយ៉ាងច្បាស់ថាវាមិន**បង្កើតនូវការព្រួយបារម្ភសំរាប់ប្រជាជនថៃនោះទេ ព្រោះនេះជាប្រព័ន្ធការពារខ្លួន មិនមែនជាឈ្នាន់ដើម្បីវាយលុកចូលប្រទេសថៃនោះឡើយ។**

យើងត្រូវធ្វើភារកិច្ចពីរក្នុងពេលជាមួយគ្នា គឺត្រូវវាយដណ្តើមទីតាំងខ្មាំងផង ហើយចាប់ដំណើរការកសាងប្រព័ន្ធការពារព្រំដែនផង។ ភារកិច្ចនេះធ្ងន់ធ្ងរ ហើយធំធេងណាស់ ប៉ុន្តែ អាស្រ័យដោយមាគ៌ា "សង្គ្រាមប្រជាជន" យើងមានលទ្ធភាពធ្វើបាន។ ពេលលើកបញ្ហាធ្វើប្រព័ន្ធការពារព្រំដែន យើងបានពិនិត្យយ៉ាងសំខាន់ ទៅលើលទ្ធភាពជាក់ស្តែង

*របស់ប្រជាជនយើង។ បដិវត្តន៍ជាបុព្វហេតុរបស់មហាជន ដូច្នេះសង្គ្រាមនេះ មានតែការចូលរួមរបស់ប្រជាជនទេ ទើបអាចយកជោគជ័យបាន "សង្គ្រាមការពារជាតិ ការពារសមិទ្ធិផលបដិវត្តរបស់ប្រជាជនទាំងមូល"។ ដូច្នេះ បានជាយើងអោយនិយមន័យទៅលើប្រព័ន្ធការពារព្រំដែនថា "ជាការពង្រឹងខឿនការពារជាតិរបស់ប្រជាជន" ដែលជានិយត្រឹមត្រូវបំផុតចំពោះសភាពការណ៍ និងភារកិច្ចជាប្រវត្តិសាស្ត្រនេះ។*

*គួររំលឹកផងដែរថា ក្នុងឆ្នាំ ១៩៨៤ ថ្វីត្បិតតែសភាពការណ៍អន្តរជាតិ និងដំបន់ ស្ថិតក្នុងភាពតានតឹងនៅឡើយក៏ដោយ ក៏ប៉ុន្តែការតស៊ូដើម្បីភាពធូរស្រាល រាំងស្កាត់នូវការរត់ប្រណាំងសព្វាវុធ និងនូវគ្រោះថ្នាក់នៃសង្គ្រាមនុយក្លេអ៊ែរ ដើម្បីសន្តិសហវិជ្ជមាន កំពុងរីករាលដាលទូទាំងសកលលោក។ នៅអាស៊ីអាគ្នេយ៍ មានសញ្ញាប្រាប់ថា និន្នាការប្រឈមមុខបានថយចុះ ហើយនិន្នាការចរចាបានកើនឡើង។ ការសន្ទនារវាងវៀតណាម ជាមួយឥណ្ឌូនេស៊ី និងប្រទេសមួយចំនួនទៀត ក្នុងប្រទេសអាស៊ាន បានរួមចំណែកដល់ការបន្ធូរបន្ថយភាពតានតឹងក្នុងដំបន់នេះ។ ប្រទេសមួយចំនួន និងឥស្សរជននយោបាយជាច្រើន ដោយបានយល់កាន់តែច្បាស់អំពីសភាពការណ៍នៅកម្ពុជា ពីភាពមិនប្រែក្រឡាស់នៃសភាពការណ៍កម្ពុជា បានតម្រូវអោយភាគីមានការពាក់ព័ន្ធចាប់ផ្តើមគិតពីដំណោះស្រាយនយោបាយសំរាប់បញ្ហាកម្ពុជា។ ពេលនេះ ហាក់ដូចជាបានបាត់បង់ទៅជាបណ្តើរៗ នូវ "ការស្រមើស្រមៃស្តីពីការផ្តួលរំលំសាធារណរដ្ឋប្រជាមានិតកម្ពុជាតាមផ្លូវយោធា"។ សកម្មភាពការទូតរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា តាមរយៈទស្សនកិច្ចនៃគណប្រតិភូរដ្ឋាភិបាល ដឹកនាំដោយរដ្ឋមន្ត្រីការបរទេសនៅប្រទេសមួយចំនួន*

បាននាំដល់ការពង្រីកទំនាក់ទំនងការទូត ជាមួយប្រទេសមួយចំនួនទៀត ពិសេសនៅទ្វីបអាហ្វ្រិក។ ការជួបប្រាស្រ័យរវាងរដ្ឋមន្ត្រីការបរទេសកម្ពុជា ជាមួយរដ្ឋមន្ត្រីការបរទេស ស៊ុយអែដ បារាំង ក្នុងដំណើរទស្សនកិច្ចនៅប្រទេសទាំងពីរ បានចាប់ផ្តើមស្វែងរកលទ្ធភាពនៃការជួបចរចា ហ៊ុន សែន-សីហនុ។ សូមបញ្ជាក់ថា នៅត្រីមាសទី ៤ ឆ្នាំ ១៩៨៤ មានការប៉ុនប៉ងជួបគ្នាជាសម្ងាត់មួយរវាង ហ៊ុន សែន និងសីហនុ នៅប្រទេសបារាំង។ ពេលនោះ ក្លូត សីសុង (*Claude Cheysson*) ដែលជារដ្ឋមន្ត្រីការបរទេសបារាំង បានផ្តើមគំនិតនឹងរៀបចំការជួបគ្នានេះ ដោយប្រើប្រាស់ក្រុមមិត្តភាពបារាំង-កម្ពុជានៃសភាបារាំង អោយអញ្ជើញខ្ញុំដែលពេលនោះជារដ្ឋមន្ត្រីការបរទេសទៅប្រទេសបារាំង ដើម្បីត្រៀមជួបជាមួយសម្តេច សីហនុ ប៉ុន្តែត្រូវអាក់ខានទៅវិញ អាស្រ័យដោយចិន និងខ្មែរក្រហម ដាក់ការគាបសង្កត់ចំពោះ សីហនុ ហើយចិន ក៏បានគំរាមដល់បារាំងតាមរយៈការប្រាប់សម្តេច សីហនុ ថា "បារាំងចង់ដាក់អាណានិគមឡើងវិញនៅកម្ពុជា" ហើយដែល ក្លូត សីសុង បាននិយាយប្រាប់ខ្ញុំក្នុងពេលស្រស់ស្រូបពេលព្រឹកជាមួយគ្នានាថ្ងៃ ១ ខែ ធ្នូ ១៩៨៤ ថា "ចិនបានបោះកំណាត់ឱសមកលើក្បាលបារាំង"។

យុទ្ធនាការរដូវប្រាំង ១៩៨៤-១៩៨៥ បានចាប់ផ្តើម។ ក្រោយពេលរក្សាស្ថានភាពវាយសំរុកក្នុងរដូវវស្សា និងក្រោយពេលត្រៀមរៀបចំលក្ខណសម្បត្តិទាំងកម្លាំងមនុស្ស ទាំងសម្ភារៈ និងស្មារតីរួចហើយ ការវាយសំរុកបានចាប់ផ្តើម។ អាវុធចាប់ផ្តើមផ្ទុះពីជំរំរបស់ពួក សឺន សានខាងលិច យានដង្កី និងណងចាន់។ នៅថ្ងៃទី ១៨ វិច្ឆិកា ១៩៨៤ យើងវាយដណ្តើមយកដំបន់ ២០៥ របស់ពួកសេរីកា ថ្ងៃ ១២ ធ្នូ ១៩៨៤ វាយ

ដណ្ដើមយកទីតាំង សុខសាន្ត ទី ១ ហើយយើងបន្តវាយជាប់រហូតលើកំណាត់ព្រំដែនទាំងអស់ ទាំងទីតាំងរបស់ ប៉ុល ពត ទាំងទីតាំងរបស់ សឺន សាន សីហនុ ហើយទីតាំងចុងក្រោយ គឺអគ្គសេនាធិការរបស់កម្លាំង សីហនុ នៅតាទុំ ដែលយើងវាយកំទេចនៅថ្ងៃទី ០៨ មិនា ១៩៨៥។ តែក៏មានទីតាំងលួចលាក់មួយត្រូវរត់ក្រោយគេ គឺជំបន់ ២០១ របស់សេរីកានៅភ្នំដងរែក ដែលយើងវាយដណ្ដើមនៅថ្ងៃ ០៥ សីហា ១៩៨៥ ក្នុងរដូវវស្សា។ ក្នុង ១៨ ទីតាំង មានទីតាំងមួយដែលសំខាន់ជាងគេ ហើយរឹងមាំជាងគេ គឺភ្នំមេឡៃ ដែលជាមូលដ្ឋានសំរាប់ការតាំងក្រសួងមន្ទីរ តំណាងអោយបក្សទាំងបី នៃរដ្ឋាភិបាលចម្រុះត្រីភាគី ហើយជាកន្លែងសំរាប់ប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ ទទួលសារតាំងពីឯកអគ្គរដ្ឋទូត នៃប្រទេសដែលគាំទ្ររបស់ដែលហៅថា កម្ពុជាប្រជាធិបតេយ្យ។ តាំងពីពេលបាត់បង់ទីតាំងនៅភ្នំមេឡៃមក នៅក្នុងសារព័ត៌មាន គេលែងឃើញ ឬឮនូវអ្វីដែលគេធ្លាប់ថា ស៊ីនហួ អាអេហ្វប៉េ អ៊ុយប៉េអ៊ី អាប៉េ។ល។ ផ្សាយពីទីក្រុងមេឡៃ ទៀតហើយ ហើយដែលប៉ុន្មានឆ្នាំមុន គេធ្លាប់ប្រើបញ្ហានេះដើម្បីឃោសនាអំពីអ្វីដែលគេហៅថា "តំបន់ត្រួតត្រាដោយកម្ពុជាប្រជាធិបតេយ្យ"។

ការបាត់បង់នូវទីតាំងតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ គឺជាបរាជ័យដ៏ជូរចត់នៃឧបាយកល «បង្កើតដំបន់ត្រួតពិនិត្យពីរ រដ្ឋាភិបាលពីរ បិតបេរព្រមៗ គ្នា នៅកម្ពុជា» ដើម្បីអនុវត្តនូវគោលដៅសង្គ្រាមទន្ទ្រាន និងផ្ដួលរំលំតាមផ្លូវយោធា។

ក្នុងពេលកំពុងទទួលការវាយសំរុក និងបន្ទាប់ពីការបាត់បង់នូវទីតាំងតាមព្រំដែនកម្ពុជា-ថៃ គេសង្កេតឃើញថា ខ្មាំងមានការប្រែប្រួល

ក្នុងយុទ្ធសាស្រ្ត និងវិធីធ្វើសង្រ្គាមនៅកម្ពុជា។ ប៉ុន្មានឆ្នាំមុន ពួកគេប៉ុនប៉ងផ្តួលរំលំសាធារណរដ្ឋប្រជាមានិតកម្ពុជា តាមផ្លូវយោធា ដូច្នេះគេប្រើវិធានការយោធាជាសំខាន់ គួបផ្សំនឹងសកម្មភាពនយោបាយ សេដ្ឋកិច្ច ការទូត ដើម្បីវាយយើង ប៉ុន្តែក្រោយបាត់បង់នូវទីតាំងតាមព្រំដែន ការស្រមើស្រមៃអំពីការផ្តួលរំលំតាមផ្លូវយោធា ហាក់ដូចជាបានធ្លាក់ទៅក្នុងការអស់សង្ឃឹម។ ដូច្នេះវិធានការពេលនេះ គឺគេប្រើវិធានការនយោបាយ សេដ្ឋកិច្ចជាសំខាន់ គួបផ្សំនឹងការវាយបំផ្លាញខាងយោធា។ តាមរយៈនោះ យើងពិនិត្យឃើញថា សង្រ្គាមចិត្តសាស្រ្ត សង្រ្គាមចារកម្ម សង្រ្គាមបំផ្លាញខាងសេដ្ឋកិច្ច និងសតិអារម្មណ៍ បានកើនឡើងខ្លាំងជាងមុន។

ចំពោះសកម្មភាពខាងយោធា ដើម្បីទប់ស្កាត់នឹងការវាយសំរុកនៅព្រំដែន បង្កឡើងនូវឱកាសដើម្បីដណ្តើមយកទៅវិញនូវទីតាំងដែលបានបាត់បង់ ហើយឆ្លៀតឱកាសពេលដែលការកសាងប្រព័ន្ធការពារព្រំដែន ទើបចាប់ផ្តើមដំណើរការថ្មីៗ ដែលនៅចន្លោះយ៉ាងធំទូលាយលើកំណាត់ព្រំដែន ហើយក៏ឆ្លៀតឱកាសពេលដែលយើងមានការធ្វេសប្រហែសនៅខាងក្នុង ខ្មាំងបានបញ្ជូនកម្លាំងចូលមកផ្ទៃក្នុងប្រទេស ដើម្បីធ្វើសកម្មភាព ប៉ុនប៉ងដាក់អោយយើងស្ថិតក្នុងស្ថានភាព "ស្បែករឹងសាច់ជ្រាយ"។ ស្បែករឹងគឺប្រៀបខ្លាំងរបស់បដិវត្តន៍នៅព្រំដែន រាប់ទាំងការធ្វើរបងការពារព្រំដែនផង ឯសាច់ជ្រាយ គឺការបង្កស្ថិរភាពនៅផ្ទៃក្នុង ដែលពួក ប៉ុល ពត ធ្វើឡើងដើម្បីបំផ្លាញយើង និងខិតខំអូសទាញកម្លាំងយើងពីព្រំដែន អោយចូលមកទប់ទល់សភាពការណ៍នៅផ្ទៃក្នុងប្រទេសវិញ ដើម្បីវាបានឱកាសដណ្តើមយកនូវទី

តាំងតាមព្រំដែនវិញ។

យើងត្រូវទទួលស្គាល់នូវការខ្វះខាតរបស់យើងក្នុងការអនុវត្តន៍ "វិធានការសរុប" ដើម្បីវាយខ្មាំង។ ចុងឆ្នាំ ១៩៨២ និង ដើមឆ្នាំ ១៩៨៥ យើងបានប្រមូលកម្លាំងយ៉ាងច្រើនទៅបំពេញភារកិច្ចវាយខ្មាំង និងធ្វើរបងការពារព្រំនៅដែន។ កងទ័ពស្រួចស្ទើរទាំងអស់ និងមួយភាគនៃកងទ័ពដំបន់របស់បណ្តាខេត្តក្រុងនៅខាងក្រោយ ត្រូវស្ថិតនៅព្រំដែន ហើយសេនាជន និងប្រជាជនមួយចំនួន ក៏ត្រូវធ្វើការកិច្ចនៅព្រំដែនដែរ។ ក្នុងពេលនោះ ដោយកម្លាំងនៅខាងក្រោយអនុវត្តមិនបានល្អនូវវិធានការការពារ គួបផ្សំនឹងការប្រើប្រាស់កម្លាំងសរុបដើម្បីវាយខ្មាំង និងសហការជាមួយការវាយសំរុកនៅព្រំដែនផង និងកន្លែងខ្លះ ដោយស្កប់ស្កល់ជាមួយជ័យជំនះ អត្តនោម័តិ ខ្វះការប្រុងប្រយ័ត្ន ជាហេតុនាំអោយខ្មាំងឆ្លៀតយកឱកាសនេះ ប្រើប្រាស់កម្លាំងវាជាក្រុមតូចៗ ដើម្បីបំផ្លាញ និងបង្កឡើងនូវអស្ថិរភាពនៅកន្លែងមួយចំនួន។

យើងត្រូវទទួលស្គាល់ថា ពេលនោះចលនាវាយខ្មាំងនៅផ្ទៃក្នុងប្រទេសដើរមិនទាន់ជោគជ័យ នៃការវាយខ្មាំងនៅតាមព្រំដែនទេ។ ប្រសិនបើពេលនោះ ចលនាវាយខ្មាំងនៅផ្ទៃក្នុងប្រទេសបានល្អ គួបផ្សំនឹងជោគជ័យដែលដណ្តើមបាននៅព្រំដែនគឺ យើងនឹងដាក់អោយខ្មាំងធ្លាក់ក្នុងសភាពការណ៍លំបាកជាងនេះទៅទៀត ប្រៀបដូចជា "ត្រីនៅលើជ្រុញ"។

អនុវត្តនូវវិធានការដាក់អោយបដិវត្តន៍ស្ថិតក្នុងសភាពការណ៍ "ស្បែករឹងសាច់ជ្រាយ" ពួក ប៉ុល ពត បានបញ្ជូនកម្លាំងចូលមកផ្ទៃក្នុង ហើយបែងចែកសមរភូមិកម្ពុជា ជាបីផ្នែក គឺ ផ្នែកទីមួយ រួមមានទន្លេសាប បណ្តាខេត្តជុំវិញ

បឹងទន្លេសាប និងតភ្ជាប់មកភ្នំពេញ ផ្នែកទីពីរ គឺដំបន់តាម ព្រំដែនកម្ពុជា-ថៃ ផ្នែកទីបី រួមមានដំបន់ដែលនៅសេសសល់ ពីដំបន់ ទីមួយ និងទីពីរ។ ខ្មាំង ប៉ុនប៉ងប្រើប្រាស់សមរភូមិទី ១ ធ្វើជាចំណុចសំខាន់ ក្នុងការអូសទាញបន្ទុយ កម្លាំងកងទ័ពស្រួចយើងនៅព្រំដែន អោយមកទប់ទល់នឹងខាងក្នុង ដើម្បី អោយកម្លាំងវានៅព្រំដែនមានឱកាសរើបំរះ និងទប់ទល់ជាមួយយើង ហើយប្រើប្រាស់ផ្នែកទីបី ធ្វើជាសមរភូមិឈ្លប ពង្រេចពង្រើល និងបោះស្នឹង ចងជើងកម្លាំងយើង នៅដំបន់ទាំងនេះ កុំអោយទៅជួយកន្លែងណាបាន។

ចុងរដូវប្រាំង ១៩៨៤-១៩៨៥ ការិយាល័យនយោបាយមជ្ឈិមបក្ស បានវាយតម្លៃយ៉ាងត្រឹមត្រូវនូវការវិវត្តន៍នៃសភាពការណ៍ ហើយបាន សន្និដ្ឋានច្បាស់ថា "ការប្រើប្រាស់កម្លាំងតូចតាចរបស់ខ្មាំងដើម្បីវាយ ឈ្លប មិនអាចដោះស្រាយបញ្ហាខាងយោធាបានទេ។ ដូច្នេះ មិនបាច់ដក យកកម្លាំងពីព្រំដែន មកទប់ទល់សភាពការណ៍នៅផ្ទៃក្នុងប្រទេស ឡើយ" ព្រំដែនត្រូវបន្តវាយខ្មាំងអោយបានខ្លាំង រក្សាទីតាំងធ្វើរបងការ ពារព្រំដែនអោយបានល្អ រាំងស្កាត់នូវការជ្រៀតចូលរបស់ខ្មាំង។ លើ មូលដ្ឋាននេះ យើងនឹងបន្ថយនូវកំរិតធ្វើសកម្មភាពរបស់ខ្មាំងនៅផ្ទៃក្នុង បាន។ ឯនៅផ្ទៃក្នុង ចាំបាច់ត្រូវកែសំរួលការរៀបចំឈរជើងនៃកម្លាំង យើង ដើម្បីវាយខ្មាំងអោយមានប្រសិទ្ធភាពខ្ពស់ជាង ត្រូវប្រើប្រាស់វិធាន ការសរុបដើម្បីវាយខ្មាំង បញ្ជូនកម្លាំងប្រដាប់អាវុធទៅឈរជើងនៅ ជនបទចុងកាត់មាត់ញក ដែលខ្មាំងធ្លាប់ចេញចូល និងឆ្លងកាត់ ដើម្បីធ្វើ ជាបង្អែកអោយចលនាវាយខ្មាំងរបស់ប្រជាជន។ ពេលនោះ មជ្ឈិមក៏ បានបញ្ជូនកម្មាភិបាលរាប់រយនាក់រួមជាមួយខេត្តក្រុង ចុះទៅ ពង្រឹង ចំណុចសំខាន់ៗ ដែរ។ ឆ្លងតាមវិធានការនេះ យើងរក្សាបាននូវប្រៀបជា

យុទ្ធសាស្ត្រក្នុងការវាយខ្មាំង ទាំងនៅព្រំដែន ទាំងនៅផ្ទៃក្នុងប្រទេស រុញខ្មាំងអោយធ្លាក់ក្នុងសភាពការណ៍កាន់តែលំបាកជាងមុន។

ដោយមិនអាចស្តារឡើងវិញនូវទីតាំងដែលបានបាត់បង់ ហើយដោយប្រព័ន្ធការពារព្រំដែនរបស់យើង បានក្លាយជាឧបសគ្គដ៏សំខាន់ក្នុងការផ្គត់ផ្គង់ និងបញ្ជាចំពោះកម្លាំងនៅខាងក្នុង ពួក ប៉ុល ពត បានបង្ខំចិត្តបំបែកកម្លាំងធំអោយទៅជាតូចៗ ដើម្បីងាយស្រួលចល័តគេចចេញពីការបោសសំអាតរបស់យើង ហើយងាយស្រួលក្នុងការដោះស្រាយស្បៀង។ មុនឆ្នាំ ១៩៨៥ ពួក ប៉ុល ពត ប្រមូលផ្តុំកម្លាំងមានទ្រង់ទ្រាយធំបង្គរនៅតាមទីតាំងតាមព្រំដែន និងក្នុងដីថៃ ប៉ុន្តែ ក្រោយការវាយលុក ១៩៨៤-១៩៨៥ កម្លាំងនេះត្រូវបំបែកជាក្រុមតូចៗ ដើម្បីជ្រៀតចូលមកផ្ទៃក្នុងប្រទេស។ ការបំបែកកម្លាំងធំ អោយទៅជាកម្លាំងតូចៗ គឺជា «ដំហានថយក្រោយផ្នែកយុទ្ធសាស្ត្រ»។ តាមទ្រឹស្តី ក៏ដូចជាតាមការជាក់ស្តែង នៅប្រទេសជាច្រើន ការកសាងកម្លាំងយោធាត្រូវដំណើរការពីតូចទៅធំ ប៉ុន្តែ ពួក ប៉ុល ពត ធ្វើដំណើរបញ្ច្រាសទិស គឺបំបែកពីធំមកតូចៗ វិញ។ ការប្រើប្រាស់កម្លាំងតូចៗ ដើម្បីវាយឈ្លបជាធម្មតាមិនអាចដោះស្រាយបញ្ហាខាងយោធាបានទេ។ វាគ្រាន់តែមានចរិតបំផ្លិចបំផ្លាញតែប៉ុណ្ណោះ។ ជាក់ស្តែង ពួក ប៉ុល ពត បានស្ថិតនៅក្នុងដំណាក់កាលវាយឈ្លបដដែល ហើយជាឈ្លបមានចរិតរាយប៉ាយតូចតាចជាងមុន ដែលភាគច្រើនធ្វើទៅលើគោលដៅស៊ីវិល ដើម្បីបំផ្លិចបំផ្លាញ និងឆក់ប្លន់ស្បៀង ដែលជាទូទៅពួកនេះមិនដែលបានវាយកាន់កាប់កន្លែងណាមួយឡើយ។ ការវាយដណ្តើមយកទីតាំងនៅតាមព្រំដែនកម្ពុជា-ថៃ និងការកសាងឡើងនូវប្រព័ន្ធការពារព្រំដែន បាន

វិញប្រាទខ្លាំងអោយធ្លាក់ក្នុងសភាពការណ៍ដ៏លំបាក មិនគ្រាន់តែសំរាប់ពួក ប៉ុល ពត ប៉ុណ្ណោះទេ ប៉ុន្តែកាន់តែលំបាកជាងទៀត សំរាប់កម្លាំងរបស់ សីហនុ និងសឺន សាន ដែលមានយុទ្ធសាស្ត្រការពារកម្លាំង។ ជោគជ័យនៃយុទ្ធនាការរដូវប្រាំងឆ្នាំ ១៩៨៤-១៩៨៥ បានបំពេញរយៈពេលស្ថិតនៅកម្ពុជារបស់កងទ័ពស្ម័គ្រចិត្តវៀតណាម បានពាក់កណ្តាល។ ក្នុងឆ្នាំ ១៩៨៤ ក្រោយពេលបានដកកងទ័ពវៀតណាមចំនួនបីលើករួចមកហើយ កម្ពុជា និងវៀតណាម បានប្រកាសថា កងទ័ពស្ម័គ្រចិត្តវៀតណាម នឹងដកចេញពីកម្ពុជាទាំងស្រុងក្នុងអំឡុងពី ៥ ទៅ ១០ ឆ្នាំ ប្រសិនបើគ្មានដំណោះស្រាយនយោបាយ។ បន្ទាប់ពីយុទ្ធនាការរដូវប្រាំងឆ្នាំ ១៩៨៤-១៩៨៥ បានបញ្ចប់ បក្ស និងរដ្ឋាភិបាលនៃប្រទេសទាំងពីរ បានពិនិត្យអំពីការប្រៀបធៀបកម្លាំងនៅកម្ពុជា។ ឆ្លងតាមជំហានរីកធំធាត់នៃកម្លាំងផ្ទាល់របស់បដិវត្តន៍កម្ពុជា និងការធ្លាក់ចុះនៃកម្លាំងប្រឆាំង គឺបានផ្តល់លទ្ធភាពអោយរដ្ឋាភិបាលទាំងពីរកំណត់សន្និដ្ឋានថា "កងទ័ពវៀតណាមនឹងបន្តដកជាផ្នែកៗ ជារៀងរាល់ឆ្នាំ ហើយនឹងដកទាំងស្រុងនៅឆ្នាំ ១៩៩០" ដែលជាកម្មវិធីដកកងទ័ពជាឯកតោភាគី ហើយនឹងអាចដកឆាប់ជាងពេលវេលានេះទៅទៀត ប្រសិនបើមានដំណោះស្រាយនយោបាយមួយសំរាប់បញ្ហាកម្ពុជា។ នាខែសីហា ឆ្នាំ ១៩៨៥ ក្នុងសេចក្តីថ្លែងការណ៍នៃសន្និសីទរដ្ឋមន្ត្រីការបរទេស កម្ពុជា-វៀតណាម-ឡាវ លើកទី ១១ ដែលប្រជុំនៅទីក្រុងភ្នំពេញ យើងបានប្រកាសអំពីកាលបរិច្ឆេទចុងក្រោយ នៃការដកកងទ័ពស្ម័គ្រចិត្តវៀតណាមនៅឆ្នាំ ១៩៩០។ ប្រការនេះបានបង្ហាញច្បាស់ពីភាពរីកធំធាត់នៃកម្លាំងបដិវត្តកម្ពុជា និងសុឆន្ទៈរបស់កម្ពុជា និងវៀតណាម ដែលចង់ដោះស្រាយបញ្ហាកម្ពុជា តាមផ្លូវ នយោបាយ។

## យុទ្ធសាស្ត្រថ្មី
## របស់ពួក ប៉ុល ពត

*ផែនការវាយសំរុក ផ្តួលរំលំសាធារណរដ្ឋប្រជាមានិតកម្ពុជា នាឆ្នាំ ១៩៨៥ មិនត្រឹមតែជួបនឹងបរាជ័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើអោយពួក ប៉ុល ពត ស្ថិតក្នុងសភាពការណ៍ដ៏លំបាក ដែលបង្ខំអោយពួកវាដកថយមួយជំហានផ្នែកយុទ្ធសាស្ត្រ ដោយត្រូវរំលាយកម្លាំងធំ ជាកម្លាំងតូចៗ ធ្វើសង្គ្រាមឈ្លប ដែលមានចរិតរាយប៉ាយ តម្រង់ទៅលើគោលដៅស៊ីវិលជាសំខាន់។* ***ការប្រែទិសពីការប្រើប្រាស់កម្លាំងយោធាជាសំខាន់ គួបផ្សំជាមួយសកម្មភាពនយោបាយ សេដ្ឋកិច្ច ការទូត ដើម្បីផ្តួលរំលំរដ្ឋអំណាចបដិវត្តតាមផ្លូវយោធា ទៅកាន់ការប្រើប្រាស់វិធានការនយោបាយ សេដ្ឋកិច្ច ជាសំខាន់ គួបផ្សំនឹងការវាយបំផ្លាញខាងយោធា បាននាំទៅដល់ការប្រែប្រួលនៃវិធីសកម្មភាពរបស់ ពួក ប៉ុល ពតៈ***

*ខ្មាំងបានផ្ទេរ ពីការប៉ុនប៉ងផ្តួលរំលំសាធារណរដ្ឋប្រជាមានិតកម្ពុជា តាមរយៈការបង្កើតដំបន់ត្រួតត្រា ឬកាន់កាប់ ដោយរំលំរដ្ឋអំណាចបដិវត្តនៅភូមិ ឃុំ រហូតដល់ថ្នាក់ខេត្ត ចាត់តាំងរដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យជាមុន រួចហើយទើបវាយសំរុកផ្តួលរំលំរដ្ឋអំណាចមជ្ឈិមជាក្រោយ ទៅជាវិធីធ្វើសកម្មភាពតាមការទន្ទ្រានដោយស្ងាត់ស្ងៀម សំខាន់នៅមូលដ្ឋានដែលពួកវាហៅថា អនុវត្តមាគ៌ាសង្គ្រាមប្រជាជន។ ខ្មាំងបានប្រមូលផ្តុំការខិតខំដើម្បីបំផ្លាញការកសាងមូលដ្ឋាន ដណ្តើម*

*ប្រជាជនពីបដិវត្តន៍។ ក្នុងរយៈពេលនោះ ពួក ប៉ុល ពត បានខិតខំយ៉ាងពេញទំហឹង ដល់ការស្តារឡើងវិញនូវស្មារតីរបស់នាយទាហាន និងពលទាហាន ដែលបានធ្លាក់ចុះយ៉ាងខ្លាំង បន្ទាប់ពីបរាជ័យរដូវប្រាំង ១៩៨៤-១៩៨៥ ហើយក៏បានកែសម្រួលរចនាសម្ព័ន្ធចាត់តាំងនៃកម្លាំងរបស់វាដើម្បីការស្ថិតស្ថេរ និងដើម្បីស្របតាមវិធីធ្វើសកម្មភាពថ្មី ពួកវាត្រូវបំបែកអង្គភាពជាផ្នែកតូចៗ ហើយដែលអង្គភាពមួយចំនួនពួកវាហៅថា ក្របខ័ណ្ឌយុទ្ធវិធីក្នុងកងពល ដើម្បីពង្រាយកម្លាំង ងាយស្រួលដោះស្រាយស្បៀង ងាយស្រួលចល័តគេចចេញពីការបោសសំអាត និងងាយស្រួលលួចចូលធ្វើសកម្មភាពក្នុងមូលដ្ឋាន។ ក្នុងការបំបែកកម្លាំង ពួក ប៉ុល ពត ក៏បានរៀបចំនូវក្រុមប្រតិបត្តិការឃោសនាទាក់ទង និងចាត់តាំងកម្លាំងបង្កប់ ដែលក្នុងកម្លាំងប្រតិបត្តិការនេះខ្មាំងបានអនុវត្តនូវយុទ្ធវិធី "មនោសញ្ចេតនា" គឺបញ្ជូនមនុស្សក្នុងកងទ័ពវា ដែលមានភូមិកំណើតនៅទីណា អោយទៅធ្វើសកម្មភាពនៅទីនោះ ដើម្បីអូសទាញតាមរយៈមនោសញ្ចេតនាគ្រួសារ។*

*ការអនុវត្តន៍នូវឧបាយកលជណ្តើមមូលដ្ឋាន ជណ្តើមប្រជាជនរបស់ពួក ប៉ុល ពត ធ្វើឡើងក្រោយពេលដែលបដិវត្តន៍បាន និងកំពុងដំណើរការកសាង និងពង្រឹងមូលដ្ឋាន ដែលបានក្លាយទៅជាឧបសគ្គដ៏ធំសំរាប់ផែនការរបស់ពួក ប៉ុល ពត។ ជាទូទៅ កម្លាំងរបស់ខ្មាំងត្រូវជួបនឹងកម្លាំងសម្ពាធពីរទិស គឺទិសនៅព្រំដែន និងទិសគាបសង្កត់នៅផ្ទៃក្នុង ដែលធ្វើអោយពួកវាពង្រីកសកម្មភាពមិនបានធំទូលាយ។ នៅព្រំដែន របងការពារព្រំដែនបានកសាងឡើង ធ្វើអោយខ្មាំងជួបការលំបាកក្នុងការចេញចូល សំខាន់ការដឹកជញ្ជូនអាវុធ គ្រាប់រំសេវ ស្បៀង*

អាហារ ចូលមកផ្ទៃក្នុងប្រទេស។ មុនចូលមកផ្ទៃក្នុងប្រទេស គេសាកល្បងធ្វងកាត់នឹងការស្លាប់ជាមុនសិន ហើយមានករណីខ្លះត្រូវពឹងផ្អែកការគាំទ្រពីកម្លាំងយោធាថៃផង។ តាមឯកសារសម្ងាត់មិនបញ្ចេញប្រភពមួយរបស់ថៃ ដែលនិយាយពី "ទិសជ្រៀតចូលរបស់បណ្ដាកងទ័ពខ្មែរត្រីភាគី" ក្នុងឆ្នាំ ១៩៨៧ បានលើកឡើងថា «កម្លាំងទាហានហ្វ្រង់ (Fran)» របស់ថៃ ក៏បានធ្វើការគាំពារតាមការទប់ស្កាត់ ឬតាមការបោះទ័ពឈរជើងបញ្ឆោតកងទ័ព ហេង សំរិន និងវៀតណាម។ តាមធម្មតាការជ្រៀតចូលនេះ ត្រូវប្រព្រឹត្តិទៅនៅពេលយប់ងងឹត ដោយឆ្លៀតប្រើប្រាស់ភូមិសាស្ត្រព្រៃភ្នំ ដើម្បីរក្សាការសម្ងាត់។ ដូច្នេះ ទាហានថៃបានចូលរួមធ្វើសកម្មភាពគាំទ្រ អោយការជ្រៀតចូលរបស់ពួកត្រីភាគីដែលយើងធ្លាប់ចំណាំថា ពេលណាថៃបង្កើនសកម្មភាពយោធានៅព្រំដែនគឺពិតជាមានការទាក់ទិនដល់ការជ្រៀតចូលមកផ្ទៃក្នុងប្រទេស របស់កម្លាំងបដិបក្ខ។ ឯកសារដដែលបានវាយតម្លៃថា "ភាគច្រើននៃបណ្ដាកម្លាំងដែលបានលបជ្រៀតចូលផ្ទៃក្នុងប្រទេសកម្ពុជា ហើយដែលរស់រានមានជីវិតត្រឡប់ទៅដល់ទីតាំងវិញនោះ គឺច្រើនតែមិនគ្រប់ចំនួនការបាត់បង់មានរហូតដល់ទៅ ៨០ ភាគរយ នៃចំនួនទ័ពនៅពេលចេញដំណើរអាស្រ័យដោយពួកគេត្រូវគូបដិបក្ខវាយកម្ទេច ហើយមានករណីជាច្រើនបានចេញសារភាពចំពោះពួក ហេង សំរិន អាស្រ័យដោយពួកគេពុំអាចទ្រាំទ្របាននូវការអត់ឃ្លាន លំបាកវេទនា ដាច់សង្វែងឃ្លាតចាកពីស្រុកភូមិជាយូរថ្ងៃ"។ ឯកសារបានបន្ថែមថា "វិធានការប្រើប្រាស់ជនទាំងឡាយដែលត្រូវចាត់តាំងអោយចូលមកធ្វើសកម្មភាពចារកម្ម គឺមានការដើរអម និងការត្រួតពិនិត្យរបស់មេបញ្ជាការដែលមានអាយុច្រើន

*ជាង ហើយមានគំនិតព្រៃផ្សៃផង។ ក្នុងករណីដែលគេមានមន្ទិលសង្ស័យទៅលើជនណាម្នាក់ ថាមានគំនិតចង់គេចរត់នោះ គឺគេនឹងបាញ់សម្លាប់ចោលភ្លាម ឬក៏ព្រលែងអោយដើរទៅជាន់មីនស្លាប់ទាំងក្រុមក៏មាន"។*

*អាស្រ័យដោយជួបការលំបាក ក្នុងការឆ្លងកាត់ព្រំដែនចូលមកធ្វើសកម្មភាពនៅខាងក្នុង លំបាកដឹកជញ្ជូនផ្គត់ផ្គង់ និងបញ្ហាកម្លាំងនៅផ្ទៃក្នុង បានធ្វើអោយសកម្មភាពកម្លាំងរបស់ ប៉ុល ពត នៅផ្ទៃក្នុងមានការថយចុះយ៉ាងច្រើន បើប្រៀបធៀបរយៈពេលមុនធ្វើរបងការពារព្រំដែន នាឆ្នាំ ១៩៨៤ និងក្រោយពេលដំណើរការកសាងរបងការពារព្រំដែន។ នាឆ្នាំ ១៩៨៥ សកម្មភាពខ្មាំងនៅផ្ទៃក្នុង ថយចុះជាង ៤០ ភាគរយ ហើយឆ្នាំបន្តបន្ទាប់តែងតែមានការថយចុះ ថយចុះទាំងចំនួនលើកធ្វើសកម្មភាព ទាំងកំរិតទ្រង់ទ្រាយនៃសកម្មភាព។ ពួកនៅផ្ទៃក្នុងជួបការលំបាកច្រើនជាងពួកនៅព្រំដែន អាស្រ័យដោយគេចូលកាន់តែជ្រៅ កាន់តែជួបការលំបាកអំពីការផ្គត់ផ្គង់ភស្តុភារ ដែលអង្គភាពភាគច្រើនត្រូវប្រើប្រាស់កម្លាំង ១ ឬរហូតដល់ ២ ភាគ ៣ ដើម្បីដឹកជញ្ជូន។ អង្គភាពស្ទើរទាំងអស់ ពុំមានទីតាំងស្ថិរភាព ឬស្ថិរភាពបន្តួរឡើយ គឺត្រូវចល័តជាប្រចាំ ដើម្បីគេចពីការបោសសំអាតនៃកម្លាំងបដិវត្ត ពោលគឺពួកវាជួបការលំបាកអំពីការទាក់ទងបញ្ជា ហើយវាកាន់តែពិបាកទៅទៀតសំរាប់ពួកមានជំងឺ និងមានរបួស ព្រោះគ្មានមន្ទីរពេទ្យ គ្មានថ្នាំព្យាបាល។ មានកន្លែងខ្លះដោយមិនអាចយកអ្នកជំងឺ ឬរបួសទៅជាមួយបាន ពួកមេបញ្ជាការ ប៉ុល ពត បានសម្លាប់អ្នកជំងឺ ឬរបួសចោលតែម្តង ដើម្បីកុំអោយខាងបដិវត្តចាប់បាន ឬចេញមកសារភាពជាមួយបដិវត្តន៍។*

ការរីកចំរើនរបស់បដិវត្តន៍ និងការរីកចំរើននៃជីវភាព របស់ប្រជាជនទាំងស្មារតី និងសម្ភារៈ ព្រមទាំងនយោបាយសណ្ដោសប្រណីរបស់បក្ស និងរដ្ឋាភិបាល បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្មារតី ពលទាហាន និងនាយទាហានខ្មាំង ធ្វើអោយការឃោសនាអកុសលរបស់ពួកមេបញ្ជាការខ្មាំងត្រូវអស់ប្រសិទ្ធភាពហើយជំរុញអោយពលទាហាន និងនាយទាហានខ្មាំងយ៉ាងច្រើនមកសុំចុះចូលជាមួយបដិវត្តន៍វិញ។

ដើម្បីស្ដារនូវសភាពការណ៍ ពួក ប៉ុល ពត បានរៀបចំផែនការពង្រឹងផ្ទៃក្នុង ដោយបញ្ជូនទាហានបាត់ស្មារតីចេញទៅព្រំដែនវិញ ហើយមានកន្លែងខ្លះ ពួកវាយល់ព្រមអោយទាហានវា ចេញសារភាពក្លែងក្លាយជាមួយបដិវត្តន៍ ដើម្បីដោះស្រាយការលំបាកអំពីស្មារតី អំពីស្បៀង ដើម្បីគេចចេញពីការកម្ទេចដោយកម្លាំងបដិវត្ត និងដើម្បីធ្វើជាស្ថលបង្កប់សំរាប់ពួកវាបន្តសង្គ្រាម។ ពួក ប៉ុល ពត ក៏បានដាក់ចេញនូវវិធានការ «យកសង្គ្រាមចិញ្ចឹមសង្គ្រាមនៅនឹងកន្លែង» សំខាន់គឺឆក់ប្លន់ និងលួចទិញស្បៀង និងគាបសង្កត់ អូសទាញយុវជននៅតំបន់ចុងកាត់មាត់ញក បំពេញអោយសាច់ទ័ពរបស់វា។ ការឆក់ប្លន់ស្បៀង ការទិញស្បៀង បានក្លាយជាភាពចាំបាច់របស់ពួក ប៉ុល ពត ដើម្បីការស្ថិតស្ថេរនៃកម្លាំងរបស់វា។ តាមប្រភពព័ត៌មានដែលនិយាយពីការជ្រៀតចូលមកផ្ទៃក្នុងប្រទេសកម្ពុជា របស់ កម្លាំងត្រីភាគី គឺមានការជួយពីប្រទេសមួយចំនួន។ ឯកសារមួយបាននិយាយថា "សកម្មភាពលួចជ្រៀតចូលកម្ពុជា ត្រូវប្រើពេល ៧ ថ្ងៃ ហើយបើចូលជ្រៅដល់ផ្ទៃក្នុងប្រទេស គឺត្រូវប្រើពេលអស់ ១៥ ថ្ងៃ។ ពួកនេះត្រូវយកតាមខ្លួននូវស្បៀងអាហារ ម្ហូបអាហារក្រៀម ភាគច្រើនជាគ្រឿងកំប៉ុង ហើយមានមួយចំនួនទៀត គឺ

មានការប្រើប្រាស់លុយរៀលរបស់រដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នផង។ លុយរៀលទាំងអស់នេះ ត្រូវបានប្រទេសជាមិត្តភក្តិផ្តល់អោយគេ ដូចជា សិង្ហបូរី តាមរយៈការលក់ដូរទំនិញជាមួយកម្ពុជា បន្ទាប់មកប្តូរជាលុយរៀល ហើយបញ្ជូនទៅអោយប្រទេសចិន អាមេរិក និងថៃ តាមកិច្ចសន្យាផ្ទៃក្នុង។

ក្រៅពីប្រាក់រៀលដែលពួកត្រីភាគីបានទទួលតាមរយៈប្រទេសដែលរកស៊ីផ្លាស់ប្តូរទំនិញជាមួយកម្ពុជា គេនៅប្រទះឃើញប្រាក់រៀលក្លែងក្លាយមួយចំនួនដែលកម្លាំងបដិបក្ខ បានប្រើប្រាស់បោកបញ្ឆោតប្រជាជនយើងយកស្បៀង ហើយដែលប្រាក់រៀលក្លែងក្លាយនេះ គេអាចដឹងតាមព័ត៌មានសម្ងាត់ថា បានបោះពុម្ពនៅបាងកក និងសិង្ហបូរី។ នៅមានការប្រើប្រាស់មាស ដុល្លារអាមេរិក និងទំនិញ ដើម្បីប្តូរស្បៀងពីប្រជាជន ដូច្នេះ ខ្មាំងអាចបន្ថយបានខ្លះនូវការលំបាកអំពីការដឹកជញ្ជូន ប៉ុន្តែក៏មិនអាចដោះស្រាយអោយមានស្ថិរភាពបានដែរ។ ជាទូទៅ ខ្មាំងគ្មានស្បៀងស្តុកបំរុង ហើយក្នុងសភាពការណ៍បែបនេះ ខ្មាំងពុំមានលទ្ធភាពនឹងធ្វើការប្រយុទ្ធអោយបានយូរដែរ ទោះជាពួកវាមានកាំភ្លើងគ្រាប់រំសេវគ្រប់គ្រាន់ហើយក៏ដោយ ក៏មិនអាចពង្រីកក្របខណ្ឌសង្គ្រាមអោយបានធំទូលាយដែរ។

ចូលដល់ឆ្នាំ ១៩៨៧ ពួក ប៉ុល ពត បានជំរុញអនុវត្តនូវ "យុទ្ធសាស្ត្របីកុំ" ហើយក៏បានដាក់ចេញនូវយុទ្ធសាស្ត្រ "កំចាត់ពីរ កសាងបី"។ យុទ្ធសាស្ត្របីកុំ មានចរិតបំផ្លាញការកសាងកម្លាំងបដិវត្ត ដែលខ្មាំងមើលឃើញថា វាជាគ្រោះថ្នាក់សំរាប់ពួកវា នោះគឺ កុំលក់ស្បៀងជូនរដ្ឋ កុំចូលកងទ័ពសេនាជន កុំទៅកសាងប្រព័ន្ធការពារព្រំដែន។

ដើមឆ្នាំ ១៩៨៧ គេសង្កេតឃើញថា ពួក ប៉ុល ពត ហាក់ដូចជាបាន

ដើរថយក្រោយមួយជំហានទៀត ខាងផ្នែកនយោបាយ ហើយដែលជំហានថយក្រោយនេះ កំពុងបន្តមានរហូតមកដល់សព្វថ្ងៃ។ នោះគឺការដែលពួកវាអនុវត្តវិធានការដៃក្ដៅចំពោះប្រជាជន។ ប៉ុន្មានឆ្នាំមុនពួក ប៉ុល ពត បានដើរថយក្រោយម្ដងរួចទៅហើយ គឺផ្ទេរពីការខិតខំប្រែក្លាយរដ្ឋអំណាចបដិវត្តនៅភូមិ ឃុំ អោយទៅជារដ្ឋអំណាចមុខពីរ ទៅជាការវាយបំផ្លាញរដ្ឋអំណាចភូមិ ឃុំទៅវិញ។ ប៉ុន្តែវានៅបន្តខិតខំកសាងកម្លាំងបង្កប់នៅក្នុងប្រជាជន។ ក្រោយពេលវាបរាជ័យក្នុងផែនការកសាងកម្លាំងបង្កប់ ពួកវាបានផ្ទេរទៅកាន់ការបង្ក្រាបដោយចូលបាញ់សម្លាប់ ឬចាប់បង្ខំយកទៅក្នុងព្រៃធ្វើការរៀនសូត្រ ឬយកទៅអោយជួយដឹកជញ្ជូនអោយពួកវា ដែលបង្កនូវរឿងក្ដៅក្រហាយកាន់តែខ្លាំងពីសំណាក់ប្រជាជន។ ក្នុងការចាប់ប្រជាជនយកទៅរៀនសូត្រក្នុងព្រៃមានចំណុចគួរអោយភ្ញាក់ផ្អើលមួយ ក្នុងយុទ្ធនាការខាងនយោបាយរបស់ពួក ប៉ុល ពត គឺការប្រុងប្រៀបយុទ្ធសាស្ត្រយូរអង្វែង "ដែលមានចែងក្នុងឯកសាររបស់ ប៉ុល ពត នាខែ មេសា ១៩៨៧" គឺការចាត់ទុកសីហនុ ជាសម្ព័ន្ធមិត្តយុទ្ធវិធី ដែលត្រូវសាមគ្គីផង តស៊ូផង។ សឺន សាន ជាសត្រូវគ្រោះថ្នាក់សំរាប់យូរអង្វែង តែត្រូវសហការចំពោះមុខក្នុងការប្រឆាំងវៀតណាម។ ឯកម្លាំងបដិវត្តកម្ពុជាសព្វថ្ងៃ ពួក ប៉ុល ពត ហាក់បីដូចជាមើលឃើញថា ជាសម្ព័ន្ធមិត្តយុទ្ធសាស្ត្រយូរអង្វែង ដើម្បីទប់ស្កាត់នឹងគ្រោះថ្នាក់នៃរបបសក្តិភូមិ នាយទុន ដែលអាចងើបក្បាលឡើងវិញនៅកម្ពុជា តាមរយៈ សីហនុ និងសឺន សាន។ មានចំណុចដែលគួរកត់សម្គាល់មួយទៀត គឺការដែលពួក ប៉ុល ពត ឃោសនាអោយប្រជាជនបោះឆ្នោតអោយ ខៀវ សំផន ប្រសិនជាមានដំណោះស្រាយនយោ

បាយហើយមានការបោះឆ្នោតៗ ដូច្នេះ ទន្ទឹមនឹងការប៉ុនប៉ងដណ្តើមអំណាចតាមផ្លូវយោធាមិនបានសំរេច ពួក ប៉ុល ពត ក៏ហាក់ដូចជាត្រៀមចូលរួម ក្នុងដំណោះស្រាយនយោបាយដែរ ហើយត្រៀមប្រឈមមុខជាមួយ សីហនុ ក្នុងការបោះឆ្នោត ក្នុងពេលដែលនៅខាងក្រៅ ពួកខ្មែរក្រហមប្រកាសក្តែងៗ ថា សីហនុ នឹងនៅជាប្រមុខរដ្ឋជារៀងរហូតរបស់កម្ពុជា។

ក្នុងពេលដែលសភាពការណ៍នយោបាយ មានការវិវត្តន៍យ៉ាងឆាប់ទៅរកដំណោះស្រាយនយោបាយអោយបញ្ហាកម្ពុជា ហើយដែលមិនអនុគ្រោះអោយពួក ប៉ុល ពត ទាំងនយោបាយ និងចិត្តសាស្ត្រ ក៏ដូចជាខាងយោធា ដើមឆ្នាំ ១៩៨៨ ពួក ប៉ុល ពត បានជំរុញអនុវត្តយុទ្ធសាស្ត្រកំចាត់ពីរកសាងបី ដោយលើកផែនការរយៈពេល ៤ ខែ ពីខែមករាដល់ខែមេសា ១៩៨៨ សំដៅធ្វើអោយសភាពការណ៍មានប្រៀបសំរាប់វា។ ខែកុម្ភៈ ១៩៨៨ មជ្ឈិម ប៉ុល ពត បានចេញការណែនាំថ្មីមួយទៀតដោយបន្ថែមពីការកំចាត់ពីរកសាងបី អោយទៅជា «ការកំចាត់ពីរ កសាងបួន»។ កំចាត់ពីរ គឺកំចាត់កងកម្លាំងប្រដាប់អាវុធរបស់បដិវត្តន៍នៅមូលដ្ឋាន (យោធា នគរបាលសេនាជន) និងកំចាត់រដ្ឋអំណាចបដិវត្តន៍។ កសាង ៤ គឺ កសាងស្នូលតាមគ្រួសារនីមួយៗ កសាងស្នូលតាមក្រុមគ្រួសារ ដែលមានលក្ខណៈជាការចាត់តាំងស្នូលបង្កប់របស់ក្រុមនៃបណ្តាគ្រួសារ កសាងឈ្លប កសាងស្នូលភូមិ ដែលមានលក្ខណៈជាការចាត់តាំងរដ្ឋអំណាចថ្នាក់ភូមិ ដែលខ្មាំងហៅថាជាស្នូលបច្ចេកទេសមានភារៈជាស្នូលនយោបាយ ស្នូលសេដ្ឋកិច្ច ស្នូលខាងនិរសារ ស្នូលស៊ើបការណ៍ស្នូលចលនាទាហានខ្មែរ ស្នូលចលនាភ្នាក់ងាររដ្ឋបាល ស្នូលអប់រំរៀន

*សូត្រ ស្ទូលសង្គមកិច្ចជីវភាព។*

*ខ្មាំងបានបែងចែកជា ៤ ប្រភេទភូមិ ភូមិរំដោះត្រូវកសាងចំហ និងពាក់កណ្ដាលចំហរ ភូមិពាក់កណ្ដាលរំដោះ ត្រូវកសាងចំហរ និងពាក់កណ្ដាលចំហ ភូមិរំដោះពេលយប់ ត្រូវកសាងសម្ងាត់ និងភូមិដែលបដិវត្តន៍កាន់កាប់បណ្ដោះអាសន្ន ត្រូវកសាងសម្ងាត់។ ខ្មាំងចាត់ទុកថាការកំចាត់ពីរ គឺជាការបើកទ្វារដើម្បីកសាងបួន ដែលពួកវាចាត់ទុកថាជាចំណុចគន្លឹះដែលត្រូវអនុវត្ត។*

*ផែនការរបស់ខ្មាំងមានលក្ខណៈធំធេង ប៉ុន្តែលទ្ធភាពរបស់ពួកវាមានកំរិត។ ថែមពីលើនេះ ការរីកចំរើនរបស់កម្លាំងបដិវត្តនៅមូលដ្ឋានក៏បានរុញច្រានអោយថយក្រោយនូវឧបាយកលដ៏ពិសពុលនេះ។ ក្នុងសេចក្ដីណែនាំរបស់ ប៉ុល ពត ផ្ញើអោយបណ្ដាអង្គភាពរបស់វា ដើម្បីត្រួតពិនិត្យការអនុវត្តផែនការ កំចាត់ពីរ កសាងបួន ប៉ុល ពត បានទទួលស្គាល់ ហើយធ្វើការទិទៀនចំពោះអង្គភាពថ្នាក់ក្រោម ដែលអនុវត្តមិនបានសំរេចផែនការ ដោយលើកឡើងថា មានសមរភូមិមួយចំនួននៅ ជញ្ជ្រំជើងនៅឡើយ ទៅមុខមិនរួច មិនទាន់ចូលតាមទិសត្រឹមត្រូវនៅឡើយ។*

*បន្ទាប់ពីពិនិត្យឃើញថា ផែនការរបស់ខ្លួនមិនបានសំរេច ខែឧសភា ១៩៨៨ អគ្គបញ្ជាការដ្ឋានកងទ័ពកម្ពុជាប្រជាធិបតេយ្យ បានចេញនូវផែនការ "គួរអោយភ្ញាក់ផ្អើលមួយ" ដល់អង្គភាពរបស់វាអោយធ្វើសកម្មភាពនៅខេត្តកំពង់ធំ និងកំពង់ចាម ក្នុងគោលដៅឈានទៅក្ដាប់និងកសាងកម្លាំងប្រជាជននៅជនបទ អោយបានពី ៧០ ទៅ ៨០ ភាគរយ ហើយលើកផែនការធ្វើបដិរូបដីស្រែ និងជាតួបនីយកម្មចំការកៅ*

ស្វ៊ូ គឺដណ្ដើមយកដីស្រែ ចែកអោយកសិករក្រ តែកុំចែកច្រើនពេក ហើយអោយកសិករចែកផលដែលធ្វើបានអោយពួកវាខ្វះ ដណ្ដើមយកចំការកៅស៊ូចែកអោយប្រជាជនធ្វើ ហើយចែកផលជាមួយវាពាក់កណ្ដាល ដែលពួកវាហៅថា ត្រៀមទទួលយកសន្លឹកឆ្នោតពីប្រជាជនក្នុងពេលបោះឆ្នោត។ ជាមួយនោះ ពួក ប៉ុល ពត ក៏បានលើកផែនការដ៏ចម្លែកមួយ គឺផែនការ "ប្រមូលប្រជាជនកាប់ឈើបិទផ្លូវ" ដែលពួកវាចាត់ទុកថា មានអត្ថន័យទាំងនយោបាយ យោធា ទាំងសេដ្ឋកិច្ចយ៉ាងធំទូលាយ។ ខ្មាំងមានផែនការបិទផ្លូវទាំងអស់តែក្នុងរយៈមួយអាទិត្យទៅ ២០ ថ្ងៃ ដោយដាក់ផែនការអោយប្រជាជន ១ នាក់កាប់ឈើអោយបាន ១០ ដើម ដើម្បីស្រាស់ផ្លូវ។ ផែនការនេះហាក់ដូចជាចង់បង្កើតនូវដំបន់យុទ្ធសាស្ត្រ ឬភូមិ ឃុំយុទ្ធសាស្ត្រ ដើម្បីចេញពីនោះ ពង្រីកថែមនូវដំបន់កាន់កាប់ដោយពួកវា ឬត្រៀមបង្ហាញអំពីភាពស្របច្បាប់របស់វាក្នុងពេលមានដំណោះស្រាយនយោបាយ។ សូមបញ្ជាក់ថា ពេលនោះ ប៉ុល ពត ក៏បានចេញបញ្ជាអោយកម្លាំងវារំដោះអោយបានខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ ហើយកាត់ផ្លូវជាតិលេខ ៤ លេខ ៥ និងលេខ ៦។ ប៉ុន្តែ ផែនការប្រកបដោយការផ្សងព្រេង និងមហិច្ឆិតានេះ មិនបានអនុវត្តនៅកន្លែងណាមួយឡើយ ហើយខ្មាំងក៏នៅលាក់ខ្លួនគេចចេញពីការបោសសំអាតរបស់បដិវត្តន៍បន្តទៀត។

ក្នុងបញ្ហាចិត្តសាស្ត្រ និងការឃោសនាក្រៅប្រទេស ដើម្បីបន្តភាពស្របច្បាប់នៃកម្លាំងរបស់វា ទប់ស្កាត់នូវការទាមទារសុំអោយកំចាត់ពួក ប៉ុល ពត ចេញពីជីវភាពនយោបាយរបស់សង្គមកម្ពុជា ធ្វើអោយគេនឹកនាដល់តួនាទីរបស់ចិន និងខ្មែរក្រហម ក្នុងដំណោះស្រាយនយោ

បាយនៅកម្ពុជា គំរាមកំហែងស្មារតីប្រជាជន ព្រមទាំងទប់ស្កាត់នូវការដែលកងទ័ពវៀតណាមដកតាមកាលកំណត់។ ពួក ប៉ុល ពត បានលើកឡើងរបស់ដែលហៅថា "ឱកាសយុទ្ធសាស្ត្រឆ្នាំ ១៩៩០" គឺការដណ្តើមរដ្ឋអំណាច ក្រោយពេលវៀតណាមដកអស់ពីកម្ពុជា។ ក្នុងពេលជាមួយគ្នា ពួក ប៉ុល ពត បានបង្កើននូវសកម្មភាពវាយប្រហារទៅលើកម្លាំង សីហនុ និង សឺន សាន ដែលជាសម្ព័ន្ធមិត្ត ដើម្បីគំរាមកំហែង ទប់ស្កាត់នូវការព្រមព្រៀងដោយឡែកណាមួយ ក្នុងដំណោះស្រាយនយោបាយសំរាប់បញ្ហាកម្ពុជា ដោយគ្មានពួកខ្មែរក្រហម។

យើងគួររំលឹកថា តុល្យភាពកម្លាំងនៅលើសមរភូមិ ក្នុងរយៈពេលចុងក្រោយនេះ មានការអនុគ្រោះអោយការតស៊ូរបស់ប្រជាជនកម្ពុជា។ ខ្មាំងសត្រូវ បានសាកល្បងធ្វើអោយកម្លាំងបដិវត្តកម្ពុជាចុះខ្សោយ ក្នុងពេលដែលកងទ័ពវៀតណាមបន្តដកចេញពីកម្ពុជា។ ខែវិច្ឆិកា ១៩៨៧ កងទ័ពវៀតណាម បានដកចេញពីកម្ពុជាចំនួន ២០.០០០ នាក់ ហើយដើមឆ្នាំ ១៩៨៨ បានដកចេញពីព្រំដែនកម្ពុជា-ថៃ ចំនួន ៣០ គីឡូម៉ែត្រ ស្របតាមសុឆន្ទរបស់កម្ពុជា និងវៀតណាម ឆ្លើយតបនឹងសុឆន្ទៈរបស់ឧត្តមសេនិយ ឆាវ៉ាលីត យុងឆៃយុត (*Chavalit Yongchaiyudh*) អគ្គបញ្ជាការកងទ័ពថៃ ដែលគាត់បានប្រកាសបន្ថយចំនួនកងទ័ពថៃដែលបោះប្រចាំតាមព្រំដែនកម្ពុជា ដែលគោលបំណងសំខាន់របស់យើង ចង់ជៀសវាងការប៉ះទង្គិចគ្នា ហើយរៀបចំព្រំដែនប្រទេសទាំងពីរអោយមានស្ថេរភាព និងសន្តិភាព។ ចាប់ពីខែ មិថុនា រហូតខែធ្នូ ១៩៨៨ កងទ័ពវៀតណាមបានដកចេញចំនួន ៥០.០០០ នាក់ទៀត ដោយរាប់ទាំងកងទ័ពនៅក្បែរព្រំដែន និងផ្ទៃក្នុងប្រទេសផង។ ការដក

កងទ័ពវៀតណាមពីរលើក ចំនួន ៧០.០០០ នាក់ ក្នុងពេលដែលខ្មាំងសត្រូវកំពុងខិតខំដណ្តើមយកប្រៀបខ្លាំងត្រឡប់ទៅវិញ បានក្លាយជាអម្រែកដ៏ធ្ងន់ធ្ងរសំរាប់ប្រជាជនកម្ពុជា ក្នុងកិច្ចការពារជាតិ ប៉ុន្តែអាស្រ័យដោយការរីកធំធាត់នៃកម្លាំងផ្ទាល់របស់បដិវត្តន៍កម្ពុជា យើងរក្សាបាននូវប្រៀបខ្លាំងប្រៀបឈ្នះ ទាំងនៅផ្ទៃក្នុង ទាំងនៅព្រំដែន រក្សាបាននូវស្ថិរភាពសំរាប់ ការបង្កបង្កើនផលរបស់ប្រជាជននៅទូទាំងប្រទេស ធ្វើអោយមូលដ្ឋានបន្តរីកចំរើន តាមទិសអំណោយផលអោយយើង។ ការដកកងទ័ពវៀតណាមជាចំណែកៗ ចេញពីកម្ពុជា ហើយរក្សាបាននូវភាពរឹងមាំរបស់កម្ពុជា បានក្លាយទៅជាការគាបសង្កត់ដ៏ធ្ងន់ធ្ងរ សំរាប់ភាគីដែលទាក់ទិនក្នុងជម្លោះនៅកម្ពុជា ដែលគេត្រូវតែប្រញាប់ប្រញាល់ចូលតុចរចា ដើម្បីដោះស្រាយបញ្ហាតាមផ្លូវនយោបាយ ហើយក៏បានផ្ទេរកម្លាំងសង្កត់ពីការអោយដកកងទ័ពវៀតណាម ទៅជាការទាមទារអោយគូបដិបក្ខចូលកាន់តុចរចា និងទាមទារអោយកំចាត់ចោលនូវគ្រោះថ្នាក់នៃការវិលត្រឡប់នៃរបប ប៉ុល ពត។

# ការបែកបាក់
# នៃកម្លាំងប្រឆាំង

*សម្ព័ន្ធភាពនៃកម្លាំងដែលប្រឆាំងគ្នា ពុំមែនជារឿងងាយស្រួលឡើយ។ ក្នុងសម្ព័ន្ធភាពមួយដែលមិនស្មើភាពអំពីសិទ្ធិ និងផលប្រយោជន៍ ហើយខ្វះការស្មោះត្រង់ជាមួយគ្នា ពិតជាមិនអាចនាំមកនូវការបិតបេរយូរអង្វែងបានឡើយ។ គោលបំណង និងគោលដៅចុងក្រោយខុសគ្នា ទោះបីខិតខំសម្រុះសម្រួលអំពីផលប្រយោជន៍ និងសកម្មភាពចំពោះមុខយ៉ាងណាក៏ដោយ ក៏គេមិនអាចបិទបាំងបាននូវការខ្វែងទំនាស់គ្នាបានឡើយ។*

*តាំងពីមុនពេលបង្កើតឡើងនូវសម្ព័ន្ធភាពត្រីភាគី ពួកគេបានបង្ហាញយ៉ាងច្បាស់លាស់អំពីការខុសគ្នាខាងសារជាតិ និងគោលដៅចុងក្រោយរួចទៅហើយ។ គេបានធ្វើការតស៊ូយ៉ាងតឹងតែង ដើម្បីត្រួតត្រាជំរំជនភៀសខ្លួន ដើម្បីពង្រីកឥទ្ធិពលបក្សពួកផ្ទាល់ខ្លួន និងដើម្បីត្រួតត្រារដ្ឋាភិបាលចម្រុះ ដែលគេនឹងបង្កើតឡើង។ ទោះបីសម្ដេច សីហនុ និង សឺន សាន មានជំហរប្រុងប្រយ័ត្នបំផុត មុននឹងឈានជើងចូលរដ្ឋាភិបាលចម្រុះត្រីភាគីជាមួយពួកខ្មែរក្រហម តែគាត់មិនអាចគេចផុតពីចំណាប់ខ្នាំងរបស់ពួក ប៉ុល ពត បានឡើយ។ សឺន សាន បានសុំអោយប្រទេសដែលគាំទ្រគាត់ ផ្ដល់នូវជំបង់យ៉ាងរឹងមាំមួយអោយគាត់ មុននឹងអោយគាត់ចូលទ្រុងខ្លា ប៉ុន្តែ ជាក់ស្ដែងគាត់មិនអាចធ្វើអ្វីខ្លាបានទេ ផ្ទុយទៅវិញ*

គាត់បានក្លាយជាចំណីខ្លា ដែលតម្រូវអោយគាត់អនុវត្តពាក្យស្លោក "ចូលស្ទឹងតាមបត់ ហើយអារសាច់ជូនខ្លា" ដើម្បីរស់។ ការឈ្លោះប្រកែកគ្នាពុំមែនគ្រាន់តែមានរវាងក្រុម និងក្រុមតែប៉ុណ្ណោះទេ គឺមានរហូតរវាងមនុស្ស និងមនុស្ស ក្នុងក្រុមនីមួយៗ ទៀតផង។ ទំនាស់ផ្ទៃក្នុងនៃរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែររបស់ សឺន សាន បានរុញ សឺន សាន អោយស្ថិតក្នុងសភាពការណ៍ដ៏លំបាក ពោលគឺរុញ សឺន សាន ទៅអោយចិន និងខ្មែរក្រហមត្រួតត្រាតែម្តង។ តាំងពីឆ្នាំ ១៩៨៥ មក ក្នុងរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ មានការប្រេះឆាររវាងក្រុម សឺន សាន និងក្រុមឧត្តមសេនិយ សាក់ ស៊ុតសាខន ដែលជាជម្លោះមានចរិតជារដ្ឋប្រហារ ដែលឧត្តមសេនិយ សាក់ ស៊ុតសាខន ធ្វើឡើង ដើម្បីដក សឺន សាន ចេញពីតំណែងប្រធានរណសិរ្ស។ ស្នាមប្រេះឆាររវាងពួកទាំងពីរក្នុងក្រុមតែមួយនេះ បានកើតមានជាយូរយារមកហើយ ដែលត្រូវដល់កំរិតផ្ទុះចេញជាសង្គ្រាមផ្ទៃក្នុង ហើយដែលគន្លឹះផ្ទុះគឺផ្តើមឡើងចាប់ពីការសំរេចរបស់ សឺន សាន បណ្តេញ ហ៊ីង កន្ថុន និង អាប់ឌុល ហ្គាហ្វា ពាង ម៉េត អោយចេញពីតំណែងគណៈកម្មាធិការប្រតិបត្តិ នៅថ្ងៃ ២២ សីហា ១៩៨៥ និងបណ្តេញអោយចេញពីរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ នៅថ្ងៃទី ៤ ធ្នូ ១៩៨៥។ ឆ្លៀតឱកាសនោះ ឧត្តមសេនិយ សាក់ ស៊ុតសាខន ដែលជាអគ្គបញ្ជាការកងទ័ព និងឧត្តមសេនិយ ដៀន ដែលជានាយអគ្គសេនាធិការ បានបង្កើតឡើងនៅថ្ងៃ ១៧ ធ្នូ ១៩៨៥ នូវគណៈកម្មាធិការមួយហៅថា «គណកម្មាធិការមជ្ឈិមបណ្តោះអាសន្នស្រោចស្រង់រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ» ដើម្បីជំនួសអោយគណៈកម្មាធិការប្រតិបត្តិរបស់ សឺន សាន។ ក្រោយការព្យាយាមសម្រុះសម្រួលមិនបានសំរេច ថ្ងៃ

១៦ កុម្ភៈ ១៩៨៦ សឺន សាន បានចុះហត្ថលេខាលើបទបញ្ញត្តិអោយឧត្តមសេនិយ សាក់ សាក់ ស៊ុតសាខន និង ដៀន ដែល ចេញពីតំណែងអគ្គបញ្ជាការ និងអគ្គសេនាធិការកងទ័ព។

សង្គ្រាមផ្ទៃក្នុងបានផ្ទុះឡើង ចេញផុតពីរង្វង់ត្រួតត្រារបស់ សឺន សាន ច្របូកច្របល់ពេញផ្ទៃក្នុងរណសិរ្សនេះ និងរញ្ជួយដល់រដ្ឋធម្មនុញ្ញក្រុងកូឡាឡំពួរ អំពីការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគី។ ក្រុមទាំងពីរបានធ្វើការចោទប្រកាន់គ្នា ដោយបើកកកាយអស់នូវចំណុចខ្សោយរបស់គ្នាទៅវិញទៅមក។ ក្រុមរបស់ សាក់ ស៊ុតសាខន ចោទប្រកាន់ សឺន សាន ថាបក្សពួកគ្រួសារនិយម អត្តនោម័ត្តិ ផ្តាច់ការ កេងប្រវ័ញ្ចយកជំនួយបរទេស ដើម្បីធ្វើមានធ្វើបាន អោយក្រុមគ្រួសារ និងបក្សពួក យកលុយជំនួយបរទេសដើរទេស្សនកិច្ចកំសាន្តទៅប្រទេសក្រៅ។ល។ ឯក្រុម សឺន សាន ក៏បានចោទបកត្រឡប់វិញខ្លាំងក្លាណាស់ដែរ ហើយមិនសូវខុសគ្នាប៉ុន្មានអំពីការចោទប្រកាន់របស់ក្រុម សាក់ ស៊ុតសាខន មកលើខ្លួនដែរ តែមានចំណុចប្លែកត្រង់ "មិនស្តាប់មេកោយ ពុករលួយ និងរំលោភលើសិទ្ធិមនុស្ស ពួកនេះជាពួកទម្លាក់ស្តេច សីហនុ កាលពីថ្ងៃ ១៨ មីនា ១៩៧០ និងជាអ្នកទទួលខុសត្រូវធ្វើអោយសាធារណរដ្ឋខ្មែរធ្លាក់ទៅលើដៃខ្មែរក្រហម កាលពីថ្ងៃ ១៧ មេសា ១៩៧៥"។ ក្រុម សឺន សាន បានធៀតប្រើ ព្រឹត្តិការណ៍នយោបាយកន្លងមក ដើម្បីសង្កត់លើ សាក់ ស៊ុតសាខន ផង និងអូសទាញសម្តេច សីហនុ អោយគាំទ្រខ្លួនក្នុងជម្លោះនេះផង តាមរយៈលើកឡើងអំពីរដ្ឋប្រហារ ១៨ មីនា ១៩៧០ ប៉ុន្តែ សឺន សាន ភ្លេចគិតថា នៅក្បែរខ្លួនគាត់មានឧត្តមសេនិយ និងមនុស្សមួយចំនួនធ្លាប់បានចូលរួមប្រឆាំងសម្តេច សីហនុ ដែរ រួមទាំងខ្លួន

គាត់ផង។ ការលើកឡើង អំពីការទទួលខុសត្រូវក្នុងការធ្វើអោយសាធារណរដ្ឋខ្មែរធ្លាក់ទៅលើដៃខ្មែរក្រហម សឺន សាន ចង់អូសទាញ ឧត្តមសេនិយ សូ ខាមខូយ និងអ្នកឯទៀត អាស្រ័យដោយចាត់ទុកថា សាក់ ស៊ុតសាខន បានធ្វើរដ្ឋប្រហាររំលំឧត្តមសេនិយរូបនេះកាលពីថ្ងៃ ១២ មេសា ១៩៧៥។ សូមរំលឹកថា ក្រោយពេល លន់ នល់ បានចាកចេញពីប្រទេស គេបានចាត់តាំងឧត្តមសេនិយ សូ ខាមខូយ អោយធ្វើជាប្រធានាធិបតីស្តីទីរបស់សាធារណរដ្ឋខ្មែរ។ ក្រោយធ្វើប្រធានាធិបតីស្តីទីបាន ១២ ថ្ងៃ នាថ្ងៃ ១២ មេសា ១៩៧៥ ពេលសហរដ្ឋអាមេរិកបិទស្ថានទូតនៅភ្នំពេញ សូម ខាមខូយ បានចេញដំណើរទៅបាងកក តាមឧទ្ធម្ភាគចក្រ នៃកងទ័ពសហរដ្ឋអាមេរិក ដែលមកដឹកអ្នកការទូតអាមេរិកចេញពីកម្ពុជា។ មុនពេលចេញទៅ សូ ខាមខូយ បានប្រគល់ការងារអោយ ឡុង បូរ៉េត ជារដ្ឋមន្ត្រីទី ១ នៃសាធារណរដ្ឋខ្មែរ។ ក្រោយពេលឧត្តមសេនិយ សូ ខាមខូយ ចេញដំណើរ វរជនមួយចំនួនបានធ្វើការប្រជុំគ្នា ហើយសំរេចបង្កើតគណៈកម្មការមួយមានគ្នា ៧ នាក់ ហៅថា "គណៈកម្មការ ៧ នាក់កំពូល" (*Les 7 suprêmes*)។ គណៈកម្មការនេះ សំរេចធ្វើរដ្ឋប្រហារទម្លាក់ឧត្តមសេនិយ សូ ខាមខូយ ដោយចោទប្រកាន់ថា បានរត់គេចបាត់ពីភ្នំពេញមិនដឹងទៅទីណា ហើយឈប់អោយប្រជាជនទទួលស្គាល់ សូ ខាមខូយ ជាប្រធានាធិបតីស្តីទីតទៅទៀត។ ក្នុងគណៈកម្មការ ៧ នាក់កំពូលនេះ មានឧត្តមសេនិយឯក សាក់ ស៊ុតសាខន ជាប្រធាន ឡុង បូរ៉េត ហង់ ធុនហាក់ ថោង វ៉ាន់ហ្វាន់មឿង វង់ សារិនឌី អ៊ា ឆុងឌីប គីមអាង ជាសមាជិក។ ផ្អែកលើ សាក់ ស៊ុតសាខន ជាប្រធានគណៈកម្មការ ៧ នាក់កំពូលនេះហើយ ទើប ក្រុម សឺន សាន ទម្លាក់កំហុសទៅ

លើ សាក់ ស៊ុតសាខន ថាបានទទួលខុសត្រូវចំពោះបរាជ័យនៃសាធារណរដ្ឋខ្មែរ។ ទំនាស់ផ្ទៃក្នុងរបស់រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ បានធ្វើអោយបណ្តាប្រទេស ដែលគាំទ្រកម្លាំងប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា មានការព្រួយបារម្ភយ៉ាងខ្លាំង និងធ្វើអោយប៉ះពាល់ទៅដល់រដ្ឋាភិបាលចម្រុះត្រីភាគីផងដែរ ព្រោះថាសេចក្តីប្រកាសបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២២ មិថុនា ១៩៨២ មិនបាននិយាយអំពីតួនាទីរបស់រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ ក្នុងរដ្ឋាភិបាលនេះឡើយ គឺនិយាយតែពីនាមរបស់បុគ្គលជាមេដឹកនាំបីរូប មាន នរោត្តម សីហនុ ខៀវ សំផន និងសឺន សាន ប៉ុណ្ណោះ។ ប្រសិនបើ សាក់ ស៊ុតសាខន បណ្តេញ សឺន សាន ចេញពីតំណែង គឺត្រូវលុបបំបាត់ចោលសេចក្តីប្រកាស ក្រុង កូឡាឡាំពួរ។ បើវាមានរឿងយ៉ាងដូច្នេះ វានឹងធ្វើអោយមុខមាត់នៃអ្នកផ្តើមគំនិតបង្កើតរដ្ឋាភិបាលចម្រុះ ត្រូវជួបនឹងការអាម៉ាស់យ៉ាងខ្លាំង ហើយគេក៏បាត់នូវសន្ទឹកបៀរដ៏ល្អសំរាប់កៀបសង្កត់បដិវត្តន៍កម្ពុជា និងវៀតណាម។ មូលហេតុនេះ តម្រូវអោយប្រទេសទាំងនេះចាំបាច់ត្រូវមានសកម្មភាព និងប្រកាន់យកជំហរដាច់ណាត់មួយ ដើម្បីការពាររដ្ឋាភិបាលចម្រុះត្រីភាគី។ វាផ្ទុយពីការវិភាគរបស់មជ្ឈដ្ឋានទូតនៅទីក្រុងបាងកក ដែលបានលើកឡើងថា សហរដ្ឋអាមេរិក ចិន និងអាស៊ាន ពិសេសថៃ "បានសំរេចចិត្តមិនធ្វើសកម្មភាពជ្រៀតជ្រែកនៅក្នុងជម្លោះនេះ ហើយទុកអោយគូបដិបក្ខដោះស្រាយដោយខ្លួនឯង"។ ប្រសិនបើគ្មានអន្តរាគមន៍ និងការគាបសង្កត់ វាប្រាកដណាស់ថា សឺន សាន មិនបានបន្តតំណែងប្រធានរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ ហើយក៏មិនបានធ្វើជានាយករដ្ឋមន្ត្រីនៃរបស់ដែលហៅថា កម្ពុជាប្រជាធិបតេយ្យទៀតដែរ។ ការ

ព្រួយបារម្ភរបស់ប្រទេស ដែលគាំទ្ររដ្ឋាភិបាលចម្រុះ និងសេចក្តីប្រកាស ក្រុង កូឡាឡាំពួរ បានជួយពង្រឹងជំហររបស់ សឺន សាន នៅក្នុងជម្លោះ ជាមួយ សាក់ ស៊ុតសាខន ដៀន ដែល ប៉ុន្តែក៏បានរុញ សឺន សាន អោយ ស្ថិតក្រោមការត្រួតត្រារបស់ ចិន ថៃ និងខ្មែរក្រហមកាន់តែខ្លាំង ដែលមិន អាចអោយគាត់មានការហក់លោតណាមួយ ក្រៅពីរង្វង់ត្រួតពិនិត្យរបស់ គេឡើយ រាប់ទាំងការស្វែងរកដំណោះស្រាយតាមផ្លូវនយោបាយអោយ បញ្ហាកម្ពុជាផង ដែលសម្តេច សីហនុ បានលើកឡើងយ៉ាងច្បាស់នៅថ្ងៃ ២ ធ្នូ ១៩៨៧ ក្នុងឱកាសចរចាជាមួយ ហ៊ុន សែន ថា "សឺន សាន មិនហ៊ាន ចរចាជាមួយឯកឧត្តមឡើយ ព្រោះខ្លាចចិនកាត់ជំនួយ"។ ជំនួយនៅទីនេះ តាមយើងយល់ មានច្រើនបែបច្រើនយ៉ាង ក្នុងនោះមានទាំងជំនួយសំរាប់ ផ្ទាល់ខ្លួន សឺន សាន ដើម្បីជៀសផុតពីការបណ្តេញចេញពីតំណែងផង។ ជម្លោះ សឺន សាន-សាក់ ស៊ុតសាខន បានធ្វើអោយទន់ជ្រាយនូវ ឥរិយាបថរបស់ សឺន សាន ចំពោះសម្តេច សីហនុ មួយកំរិតដែរ ដែល ប៉ុន្មានឆ្នាំមុន ជម្លោះរវាងឥស្សរជនទាំងពីរ មានការតឹងតែងបង្គួរ។ ពេល នេះ សឺន សាន ត្រូវការជំនួយ ឬការគាំទ្ររបស់សម្តេច សីហនុ ដើម្បីរក្សា នូវមុខនាទីប្រធានរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ និងនាយករដ្ឋមន្ត្រីរដ្ឋា ភិបាលចម្រុះ ប៉ុន្តែ តាមរយៈនៃជម្លោះនេះ ក៏បានពាំងនូវសកម្មភាពរួម ផ្នែកយោធារវាងកម្លាំង សឺន សាន និងកម្លាំងសម្តេច សីហនុ។ ក្រុមទាំង ពីរបានឯកភាពគ្នាបង្កើតឡើងនូវ "គណៈកម្មការយោធាអចិន្ត្រៃយ៍ និង អគ្គបញ្ជាការចម្រុះ" ដែល សីហនុ បានយល់ព្រមនៅថ្ងៃ ១២ ធ្នូ ១៩៨៥ នៅប៉េកាំង និងរណសិរ្ស សឺន សាន បានយល់ព្រមនៅថ្ងៃទី ៤ មករា ១៩៨៦។ អាស្រ័យដោយគណៈកម្មការយោធាអចិន្ត្រៃយ៍ និងអគ្គបញ្ជា

ការចម្រុះមានឈ្មោះឧត្តមសេនិយ សាក់ ស៊ុតសាខន ជាអគ្គបញ្ជាការ និង អាប់ឌុល ហ្គាហ្វាពាង់ម៉េត ជានាយអគ្គសេនាធិការរង ដែលវាជាគ្រោះគំរាមកំហែងកាន់តែខ្លាំងសំរាប់ខ្លួននោះ សឺន សាន បានចេញបញ្ញត្តិមួយមានន័យថា "គណៈកម្មការយោធាអចិន្ត្រៃយ៍ និងអគ្គបញ្ជាការចម្រុះ ត្រូវប្រកាសព្យួរមិនអោយមានសកម្មភាពជាបណ្តោះអាសន្ន"។ តាមរយៈនៃបទបញ្ញត្តិនេះ ក្រុម សាក់ ស៊ុតសាខន បានឱកាសដើម្បីឃោសនាប្រឆាំង សឺន សាន ពីបទប្រឆាំងនឹងកិច្ចសហប្រតិបត្តិការ រវាងកងទ័ពរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ ជាមួយកងទ័ពនិយមសីហនុ។

តាមរយៈនៃការគាបសង្កត់ដោយសម្ងាត់ ឬដោយចំហ ទៅលើក្រុម សាក់ ស៊ុតសាខន "កាត់ជំនួយមិនអោយដីជ្រក" "គេមិនអាចទទួលស្គាល់មនុស្សពីរនាក់ ក្នុងរណសិរ្សតែមួយនោះទេ" "ដើម្បីកុំអោយប៉ះពាល់ដល់សន្និសញ្ញាកូឡាឡាំពួរ ដែលអោយកំណើតដល់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ" "ការសម្រុះសម្រួលបញ្ចូលគណៈកម្មការប្រតិបត្តិចាស់ និងគណៈកម្មការស្រោចស្រង់រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ អោយនៅជាមួយគ្នា" បណ្តាប្រទេសមេផ្តើមគំនិតបង្កើតរដ្ឋាភិបាលចម្រុះបានទទួលជោគជ័យក្នុងការរក្សាទុក សឺន សាន ក្នុងតំណែង ប៉ុន្តែគេមិនអាចលុបបំពាត់ចោលនូវស្នាមប្រេះឆាដែលបានកើតឡើងហើយនោះឡើយ។ ភាគីទាំងពីរបន្តបញ្ចេញចង្កូមដាក់គ្នារៀងរហូតមក។ រឿងនេះហើយដែលធ្វើអោយ សឺន សាន ជួបការលំបាកក្នុងការដកខ្លួនពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចម្រុះ។ សម្តេច សីហនុ បានដកខ្លួនចេញរួចជាស្រេច ហើយរដ្ឋាភិបាលចម្រុះគ្មានប្រធានាធិបតី សល់តែនាយករដ្ឋមន្ត្រី។ បើ សឺន សាន សំរេចចិត្តឈប់ធ្វើនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះ សាក់

ស៊ុតសាខន នឹងបានឱកាសដេញគាត់ចេញពីតំណែងប្រធានរណសិរ្ស រំដោះប្រជាពលរដ្ឋខ្មែរ ហើយ ចិន ក៏លែងគាំទ្រគាត់ទៀត ព្រោះលែងមានប្រយោជន៍អោយគេ។ បើនៅបន្តធ្វើជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលចម្រុះ សភាពការណ៍នយោបាយកាន់តែគាបសង្កត់ចំពោះខ្លួនគាត់ ម្យ៉ាងដោយខ្មែរក្រហមត្រូវគេទាមទារអោយកំចាត់ចោល និងម្យ៉ាងទៀត ពួកខ្មែរក្រហមនៅតែបន្តវាយទៅលើកម្លាំងរបស់គាត់។ ដូច្នេះ សឺន សាន កំពុងស្ថិតនៅក្នុងមាត់ដង្កាប់ ដែលពិបាកក្នុងការជ្រើសរើសផ្នែកយុទ្ធសាស្ត្រសំរាប់បញ្ហាផ្ទាល់ខ្លួនគាត់ផង និងបញ្ហារួមផង។

ចំពោះកម្លាំងរបស់សម្តេច សីហនុ វិញ ក៏មានទំនាស់យ៉ាងធ្ងន់ធ្ងរ ហើយក៏ប្រមូលផ្តុំជុំវិញការដណ្តើមអំណាច ការឃ្លោងអំណាច បក្សពួកគ្រួសារនិយម អត្តនោម័តិ ផ្តាច់ការ និងការកេងប្រវ័ញ្ច។ ការសម្លាប់ដោយថ្នាំបំពុល របស់ឈ្មោះ គង់ ស៊ីលាស់ មេចលនា មូលីណាកា គឺស្ថិតក្នុងអាថ៌កំបាំងនៃក្រុមនេះ និងទាក់ទងដល់ក្រុម សឺន សាន។ គេនៅចាំបានថា គង់ ស៊ីលាស់ ជានាយទាហាននៃរបប លន់ នល់ ដែលរត់ទៅជ្រកកោននៅប្រទេសបារាំង។ រួមជាមួយឈ្មោះ ប៊ួ ហ៊ែល គង់ ស៊ីលាស់ បានមកដល់ប្រទេសថៃ ដឹកនាំក្រុមប្រដាប់អាវុធខ្មែរសេរីមួយចំនួន ហើយបានបង្កើតចលនារំដោះជាតិខ្មែរ ហៅកាត់ថា "មូលីណាកា" នៅឆ្នាំ ១៩៧៩។ ក្រោយពី គង់ ស៊ីលាស់ ត្រូវបានគេបំពុលស្លាប់នារដូវក្តៅឆ្នាំ ១៩៨១ អ៊ិន តាំ អតីតនាយករដ្ឋមន្ត្រីសាធារណរដ្ឋខ្មែរបានចូលមកជំនួសពេលនោះ ក្នុងក្របខ័ណ្ឌរណសិរ្សរួបរួមជាតិ ដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត្យ សន្តិភាព និងសហប្រតិបត្តិការ ហៅកាត់ថា "ហ៊្វុនស៊ីនប៉ិច" ដែលដឹកនាំដោយសម្តេច សីហនុ ហើយមានកងទ័ពឈ្មោះហៅ

ថា កងទ័ព សីហនុនិយម។ អ៊ិន តាំ ត្រូវបានទទួលតំណែងជាអគ្គបញ្ជាការ ហើយក៏ទទួលផងដែរនូវនាទីជាអនុប្រធានទី ២ នៃរណសិរ្ស ហ៊ុន ស៊ីនប៉ិច និងជាសមាជិកការិយាល័យសម្របសម្រួលផ្នែកកិច្ចការពារប្រទេសនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ។

ក្រោយមួយរយៈនៃការរកាំរកូសក្នុងរង្វង់រណសិរ្ស និងអនាធិបតេយ្យក្នុងកងទ័ពរបស់គាត់ ព្រមទាំងមានការគាបសង្កត់ និងជ្រៀតជ្រែកពីរដ្ឋាភិបាលថៃ និងសិង្ហបុរី អ៊ិន តាំ បានដាក់ពាក្យសុំលាលែងពីតំណែងនៅថ្ងៃ ២៣ មករា ១៩៨៤ ហើយឈប់ធ្វើសកម្មភាពកាលពីថ្ងៃ ២ កុម្ភៈ ១៩៨៤។ ដើម្បីកុំអោយអ្នកផងផ្សេងទៀតធ្វើអាជីវកម្មយកចំណេញពីឈ្មោះរបស់គាត់ ថ្ងៃ ១៨ កុម្ភៈ ១៩៨៥ អ៊ិន តាំ បានធ្វើសេចក្តីថ្លែងការណ៍មួយបង្ហាញសាធារណមតិអំពីការលាលែងពីតំណែងរបស់ខ្លួន។ ក្នុងសេចក្តីថ្លែងការណ៍ចំនួនពីរទំព័ររបស់គាត់ ដែលផ្ញើមកអោយការិយាល័យ អាអេហ្វប៉េ នៅបាងកក ចុះផ្សាយថ្ងៃ ០១ មីនា ១៩៨៥ អ៊ិន តាំ បានបង្ហាញពីភាពទំនាស់ដ៏ជ្រាលជ្រៅក្នុងរង្វង់រណសិរ្ស និងកងទ័ព សីហនុ។ គាត់បានហៅឧត្តមសេនិយ ទៀប បែន ដែលសម្តេច សីហនុ ចាត់តាំងនៅថ្ងៃ ១៦ មីនា ១៩៨៥ អោយធ្វើអគ្គបញ្ជាការជំនួសគាត់ ថាជា ឧត្តមសេនីយមួយរូបបានទទួលការប្រោះព្រំពីរដ្ឋាភិបាលថៃ និងសិង្ហបូរី គាត់ក៏បានចោទប្រកាន់ផងដែរ ចំពោះរដ្ឋាភិបាលថៃ និងសិង្ហបុរី ដែលបានជ្រៀតជ្រែកក្នុងកិច្ចការរបស់គាត់ជាអគ្គបញ្ជាការ ដែលនាំដល់ការបង្កអនាធិបតេយ្យពេញទីក្នុងចំណោមកងទ័ពដែលគាត់បញ្ជា។ ប្រការដែលសំខាន់ជាងទៀត អ៊ិន តាំ បានលើកបង្ហាញពីនយោបាយដណ្តើមយកទឹកដីរបស់ថៃ ដែលប៉ុនប៉ងដណ្តើមយកទៅវិញនូវខេត្ត បាត់ដំបង សៀមរាប ឧត្តរ

មានជ័យ ថ្មពួក ព្រះវិហារ និងកោះកុង ដែលសៀមបានប្រគល់អោយកម្ពុជាតាមកិច្ចព្រមព្រៀងបារាំង-សៀម ឆ្នាំ ១៩០៧ ហើយបានប្រគល់មកម្តងទៀត បន្ទាប់ពីជប៉ុនចាញ់សង្គ្រាមលោកលើកទី ២ ដែលពេលនោះមានទាំងខេត្តកំពង់ធំផង។ អ៊ិន តាំ បានលើកច្បាស់ថា៖«ក្នុងរយៈពេល ៣ ឆ្នាំ ដែលខ្ញុំនៅក្នុងព្រៃតស៊ូ ខ្ញុំមានជំនឿជាក់ថាថៃឡង់ដ៍ ទោះជាគេសន្យាថា មិនលើកឡើងវិញនូវបញ្ហាព្រះវិហារទេនោះក្តី តែគេមិនបោះបង់ចោលនូវនយោបាយដណ្តើមយកទឹកដីខេត្តបាត់ដំបង សៀមរាប ឧត្តរមានជ័យ ថ្មពួក ព្រះវិហារ និងកោះកុង ដែលមានប្រវត្តិសាស្ត្រអាចប្រៀបប្រដូចទៅនឹងតំបន់ អាល់សាស លរ៉ែន (*Alsace Lorraine*)» គាត់បន្ថែមទៀតថា «ហេតុដូចនេះ យុទ្ធសាស្ត្រនៃការតស៊ូខ្មែរ និងគោលដៅពិតប្រាកដរបស់ពួកអាជ្ញាធរយោធាថៃ សំដៅទៅរកទិសបី គឺ ដកយកពួកថៃក្រហមចេញ បំបែកបំបាក់កម្លាំងវៀតណាម និងរៀបចំផែនការវាយដណ្តើមយកវិញនូវទឹកដីទាំងនោះ។ នេះជាដំណើរការយូរអង្វែង ដែលខ្មែរទាំងឡាយសមនឹងឈ្មោះខ្មែរនោះត្រូវតែមានមនសិការឡើង»។ ចុងក្រោយ គាត់ធ្វើការគូសបញ្ជាក់ថា «តាមមតិរបស់ខ្ញុំ ខ្ញុំយល់ថា បញ្ហាកម្ពុជាមិនអាចដោះស្រាយបានឆាប់ "មុនពេលយូរអង្វែង"។ ពេលណាសង្គ្រាមបន្តយូរទៅទៀត គ្រោះថ្នាក់បាត់បង់ខេត្តភាគខាងលិចរឹតតែធំធេង ខ្ញុំចាកចេញពីរណសិរ្ស ហ៊្វុនស៊ីនប៉ិច និងរដ្ឋាភិបាលចម្រុះនេះ ជាសញ្ញាប្រឆាំងនឹងការជ្រៀតជ្រែកពីបរទេស ក្នុងគោលបំណងធ្វើអោយការតស៊ូខ្មែរទៅជាអាវុធមុខពីរ ប្រឆាំងវៀតណាមផង និងប្រឆាំងមាតុភូមិខ្ញុំផងដែរ»។

ការវាយតម្លៃនយោបាយថៃចំពោះកម្ពុជារបស់ អ៊ិន តាំ ពិតជាត្រឹមត្រូវ ការដកខ្លួនរបស់គាត់ធ្វើឡើងដោយមានសតិសម្បជញ្ញៈ ប៉ុន្តែ គាត់

មិនបានធ្វើសកម្មភាពណាមួយ ដើម្បីទប់ស្កាត់គ្រោះថ្នាក់បាត់ដីនៃបណ្ដាខេត្តភាគខាងលិចនោះទេ គាត់បែរជាខ្វល់ខ្វាយយ៉ាងច្រើនជុំវិញការបែកបាក់នៃក្រុម សឺន សាន និងរដ្ឋាភិបាលចម្រុះ ដែលតម្រូវអោយគាត់សរសេរលិខិតទូន្មាន សឺន សាន ដែលបានលទ្ធផលផ្ទុយពីការដែលគាត់ចង់បានទៅវិញ។

ក្រោយពេល អ៊ិន តាំ ចាកចេញជាផ្លូវការហើយ សម្ដេច សីហនុ បានចាត់តាំងឧត្ដមសេនិយទោ ទៀប បែន ជាអគ្គបញ្ជាការ និងជានាយអគ្គសេនាធិការកងទ័ព សីហនុនិយម ហើយក៏បានតែងតាំងប្រពន្ធរបស់គាត់ អ្នកអង្គម្ចាស់ក្សត្រី នរោត្តម មូនិច សីហនុ ជាអនុប្រធានទី ២ នៃរណសិរ្ស ហ្វ៊ុនស៊ីនប៉ិច ដែលតំណែងនេះ អ៊ិន តាំ ធ្លាប់ទទួលពីមុនមកដែរ។ សូមបញ្ជាក់ថា អនុប្រធានទី ១ នៃរណសិរ្សនេះ គឺ ញឹក ជូឡុង។

ពេញមួយឆ្នាំប្រកបដោយជម្លោះផ្ទៃក្នុង និងវិបត្តិផ្សេងទៀត រួមទាំងការបាត់បង់ទីតាំងចុងក្រោយនៅតាទុំផង ឧត្តមសនិយ ទៀប បែន ត្រូវដកចេញពីតំណែងអគ្គបញ្ជាការ និងនាយអគ្គសេនាធិការ។ តាមពត៌មានថា សម្ដេច សីហនុ បានសំរេចដកឧត្ដមសេនិយ ទៀប បែន ពីថ្ងៃ ៣០ មករា ១៩៨៦ ក្នុងពេលសម្ដេចស្នាក់នៅប្រទេសចិន។ ការដកឧត្ដមសេនិយ ទៀប បែន ចេញពីតំណែង ដោយអាងទៅលើកំហុសរបស់ឧត្ដមសេនិយរូបនេះថា ផឹកស្រាច្រើនពេក ធ្វើអោយបាត់ប្រាក់ពីរម៉ឺនដុល្លារ ធ្វើការមិនចុះសម្រុងជាមួយនរោត្តម រណឫទ្ធិ ជាតំណាងផ្ទាល់សម្ដេច សីហនុ ធ្វើទុក្ខបុកម្នេញអ្នកក្រោមបង្គាប់មានរហូតដល់បាត់ខ្លួន (សម្លាប់ដោយសម្ងាត់)។ នរោត្តម រណឫទ្ធិ កូនប្រុសរបស់សម្ដេច សីហនុ

ដែលបានតែងតាំងជាតំណាងផ្ទាល់របស់សម្តេច សីហនុ រួចមកហើយ នោះ ត្រូវបានតែងតាំងអោយទទួលតំណែងបន្ថែមលើមុខតំណែងទាំងពីរ ដែល ឧត្តមសេនិយ ទៀប បែន ធ្លាប់ទទួលពីមុនៗ ប្រពន្ធនរោត្តម រណឫទ្ធិ ក៏បានទទួលការតែងតាំងពីឆ្នាំ ១៩៨៥ អោយទទួលជាប្រធានសមាគម នារីខ្មែរ។ មានដំណឹងថា តំណែងនាយអគ្គសេនាធិការ ដំបូងបំរុង ប្រគល់អោយនរោត្តម ចក្រពង្ស ប៉ុន្តែ អាស្រ័យដោយមានការជំទាស់ ច្រើនក៏អាក់ខានទៅវិញ ទុក ចក្រពង្ស ត្រឹមប្រធានកងពលតូច ប៉ុណ្ណោះ។ ការផ្លាស់ប្តូរអ្នកដឹកនាំជាច្រើនលើកច្រើនសាក្នុងជួរណាសិរ្ស ហ៊ុនស៊ីនប៉ិច និងកងទ័ព សីហនុនិយម មិនបាននាំមកនូវស្ថិរភាពផ្ទៃក្នុង ឡើយ។ ការឈ្លោះប្រកែកនៅបន្ត ចំណោទដែលធំគឺការកេងប្រវ័ញ្ចរបស់ មេកោយលើថ្នាក់ក្រោមបង្គាប់ បែកចេញជាច្រើននិន្នាការ រហូតដល់សមា ជិករណសិរ្សនេះ ទៅក្រៅប្រទេស ក៏បែកជាច្រើនក្រុមខុសៗ គ្នា។

ឯចំណែកខ្មែរក្រហម ប៉ុល ពត ពិតមែនតែក្រុមនេះល្បីឈ្មោះថា ពូកែរក្សាការសម្ងាត់អំពីផ្ទៃក្នុង ប៉ុន្តែពួកគេមិនអាចបិទបាំងនូវការបែក បាក់នោះបានដែរ បង្ហាញច្បាស់បំផុត គឺអំពើឃោរឃៅរបស់ពួកមេ ក្លោងរឹងរូសមកលើពលទាហាន និងនាយទាហានថ្នាក់ក្រោម។ ថ្វីត្បិត តែបានចាញ់រួចទៅហើយ ពួក ប៉ុល ពត នៅតែបន្តអនុវត្តនូវនយោ បាយសម្រិតសម្រាំងផ្ទៃក្នុងតទៅទៀត ដែលពួកវាមិនអនុញ្ញាតិអោយ អ្នកណាដែលទទួលការសង្ស័យថាក្បត់អង្គការ ឬស្រពិចស្រពិលអំពី មិត្ត និងសត្រូវនៅរស់បានឡើយ។ នៅក្នុងជួរមេដឹកនាំ ថ្វីត្បិតតែអនុវត្ត មាគ៌ាតស៊ូផង សម្រួលផងក៏ដោយ ក៏មានការខ្វែងគំនិតគ្នា ហើយមាន ការសង្ស័យគ្នាទៅវិញទៅមកច្រើនដែរ។ ខៀវ សំផន ទោះបីត្រូវបាន

តែងតាំងជាចំហថា ធ្វើជាប្រធាននៃកម្លាំងខ្មែរក្រហម តែមនុស្សនេះគ្រាន់តែមានឈ្មោះជានិមិត្តរូបតែប៉ុណ្ណោះ មិនអាចសំរេចកិច្ចការអ្វីបានឡើយ។ សម្តេច សីហនុ ធ្លាប់បាននិយាយថា ខៀវ សំផន ធ្វើការក្រោមបង្គាប់ អៀង ធីរិទ្ធ ប្រពន្ធរបស់ អៀង សារី ដែលជាមេឃាតករដ៏កំណាច ដែលបានដកខ្លួនចេញពីតំណែងរដ្ឋមន្ត្រីការបរទេស ហើយបញ្ជាមក ខៀវ សំផន វិញតាមរយៈប្រពន្ធខ្លួន។

កម្លាំងដែលនៅក្រោមបង្គាប់របស់តាម៉ុក គ្មានការទុកចិត្តចំពោះ ខៀវ សំផន ឡើយ ទោះជាត្រូវប្រើឈ្មោះ ខៀវ សំផន ដើម្បីឃោសនាប្រជាភិថុតក៏ដោយ មានពេលខ្លះពួកតាម៉ុក បានចោទប្រកាន់ ខៀវ សំផន ថា បានចាញ់ឧបាយកលរដ្ឋាភិបាលភ្នំពេញ។ តាមពត៌មានសម្ងាត់ថា ចិន ក៏មិនទុកចិត្ត និងមិនចូលចិត្ត ខៀវ សំផន ដែរ។ ប៉ុល ពត អៀង សារី តាម៉ុក នៅតែមានតួនាទីសំខាន់ ក្នុងការដឹកនាំក្រុមខ្មែរក្រហម។ មុនពេលប្រជុំក្រៅផ្លូវការនៅហ្សាការតា ពួកមេខ្មែរក្រហមមានមតិបីខុសៗគ្នា ដែលតាមពត៌មាន មតិទី ១ រួមមាន ប៉ុល ពត អៀង សារី តាម៉ុក មតិទី ២ ជាមតិ សុន សេន មតិទី ៣ ជាមតិ ខៀវ សំផន។ ទោះមានមតិខ្វែងគ្នា តែចុងក្រោយគេត្រូវសំរេចយកមតិរបស់ប៉េកាំង ដែលកំណត់ថាត្រូវរួមប្រជុំដើម្បីម្យ៉ាងជៀសវាងពីភាពឯកោ ព្រោះភាគីដទៃ និងប្រទេសដទៃទៅចូលរួមហើយ ម្យ៉ាងទៀតទៅដើម្បីទប់ស្កាត់ការព្រមព្រៀងរវាងរបបភ្នំពេញ ជាមួយ សីហនុ និង សឺន សាន។ នៅទីក្រុង បូហ្គ័រ ប្រទេសឥណ្ឌូនេស៊ី ពីថ្ងៃទី ២៤-២៨ កក្កដា ខៀវ សំផន បានបង្ហាញរូបរាងច្បាស់ថា ជាមនុស្សគ្មានឯកពជ្យត្រង់ណាសោះ គឺជាប្រធាននិមិត្តរូបមិនហ៊ាននិយាយអ្វីក្រៅពីការណែនាំមុនពេលចេញដំណើរ បើនិយាយ

សុទ្ធតែបានទីប្រឹក្សាដែលជាមនុស្ស ប៉ុល ពត រៀបចំអោយធ្វើជាអ្នកជំនួយការសំរេចសិន រហូតដល់ ខៀវ សំផន មិនហ៊ានឆ្លើយនូវសំណួរអ្នកកាសែតក្នុងពេលដែលខ្លួនបើកធ្វើសន្និសីទកាសែត ដែលអ្នកសារពត៌មានរាប់រយនាក់ហៅថា «ជាការប្រជុំកាសែតដ៏ចម្លែកមួយ»។ ខៀវ សំផន គោរពអង្គការរហូតគ្មានចរិតឯករាជ្យ ក្នុងឋានៈខ្លួនជាប្រធាននៃកម្លាំងខ្មែរក្រហម។ ប៉ុណ្ណឹងហើយ ប៉ុល ពត នៅមិនទុកចិត្ត ចុះតើមនុស្សរបៀបណាទៀត ទើប ប៉ុល ពត ទុកចិត្ត?

ចំពោះទំនាក់ទំនងរវាងក្រុមខ្មែរទាំងបីក្នុងរដ្ឋាភិបាលចម្រុះ ដូចកាសែតបារាំង បានធ្វើការប្រៀបធៀបគួរអោយអស់សំណើចមួយថា "រដ្ឋាភិបាលចម្រុះជាពពុះសាប៊ូមួយ ដែលចាំងផ្លេកៗ គ្រប់ពណ៌នៅពេលគេផ្លុំ ប៉ុន្តែមិនយូរមិនឆាប់ ពពុះនេះនឹងបែកជាមិនខាន"។ វាពិតជាដូច្នេះមែន តាំងពីថ្ងៃចាប់កំណើតមក រដ្ឋាភិបាលនេះមានវិបត្តិជាអចិន្ត្រៃយ៍។ ពួកខ្មែរក្រហម ប៉ុល ពត មិនដែលបានចាត់ទុកក្រុម សីហនុ និង សឺន សាន ថាជាមិត្តម្តងណាឡើយ។ ថ្ងៃ ២២ មិថុនា ១៩៨២ បង្កើត ថ្ងៃ ២៧ មិថុនា ១៩៨២ គឺក្រោយពេលបង្កើត ៥ ថ្ងៃ លេខ ៨៧ ជាលេខសម្ងាត់របស់ ប៉ុល ពត បានចេញការណែនាំទៅថ្នាក់ក្រោម អោយប្រុងប្រយ័ត្នចំពោះ សីហនុ និង សឺន សាន ដោយចាត់ទុកថា ជាសត្រូវវណ្ណៈ ដែលត្រូវតស៊ូ។ គេចាត់ទុក សីហនុ ជាសក្តិភូមិ សឺន សាន ជានាយទុនកុំប្រាឌ័រ ដែលមកដណ្តើមអំណាចពីកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវតែប្រុងប្រយ័ត្នហើយធ្វើការតស៊ូ។ ការសាមគ្គីជាមួយ សីហនុ និង សឺន សាន ពេលនេះ គឺដើម្បីប្រមូលកម្លាំងរណសិរ្សប្រឆាំងវៀតណាមតែប៉ុណ្ណោះ។ ពួក ប៉ុល ពត បានចាត់ទុកថា រណសិរ្ស ជាមួយ សីហនុ សឺន សាន បច្ចុប្បន្នជា

រណសិរ្សមានឯកភាពផង និងមានទំនាស់ផង តែ អនាគត នឹងក្លាយជាទំនាស់បដិបក្ខ ព្រោះសារជាតិវណ្ណៈមិនអាចនៅជាមួយគ្នាបាន ដូច្នេះត្រូវសាមគ្គី សំខាន់សំរាប់រណសិរ្សខាងក្រៅ ឯខាងក្នុងត្រូវរាំងសកម្មភាពពួក សីហនុ និង សឺន សាន កុំអោយពង្រីកឥទ្ធិពលចំពោះប្រជាជន ព្រោះនាំអោយពិបាកទៅថ្ងៃក្រោយៗ តាមរយៈនៃការណែនាំអោយប្រុងប្រយ័ត្នចំពោះកម្លាំង សីហនុ និង សឺន សាន ពួកទាហាន ប៉ុល ពត ជានិច្ចកាលបានវាយប្រហារទៅលើកងទ័ព សីហនុ និង សឺន សាន ដែលបណ្តាលអោយស្លាប់ និងរបួសនាយទាហាន និងពលទាហានជាច្រើនៗ ការវាយប្រហារជាប់មិនដាច់ ពីសំណាក់ពួក ប៉ុល ពត ទៅលើកម្លាំងសីហនុនិយម បានធ្វើអោយសម្តេច សីហនុ ខឹងសម្បាយ៉ាងខ្លាំងរហូតបានគំរាមកំហែងលាលែងពីប្រធានរដ្ឋាភិបាលត្រីភាគី ជាច្រើនលើកច្រើនសា តាំងពីឆ្នាំ ១៩៨២ មកៗ នៅគ្រប់ការលាលែងរបស់គាត់ សម្តេច សីហនុ បានថ្កោលទោសយ៉ាងខ្លាំងចំពោះឧក្រិដ្ឋកម្មរបស់ពួក ប៉ុល ពត ទៅលើអ្នកដែលមានស្វាមីភក្តិចំពោះគាត់ៗ

ចេញពីការប៉ះទង្គិចខាងយោធាជាប្រចាំ ឈានទៅដល់ការខ្វែងទំនាស់ខាងនយោបាយដ៏ស្រួចស្រាល សម្តេច សីហនុ មើលឃើញច្បាស់ថា ក្រោមឆត្រនៃរដ្ឋាភិបាលចម្រុះត្រីភាគី និងក្រោមការគាំពាររបស់ចិន និងអាស៊ាន គាត់មិនអាចធ្វើអ្វីកើតឡើយ ក្នុងការស្វែងរកដំណោះស្រាយនយោបាយសំរាប់បញ្ហាកម្ពុជាៗ ថ្ងៃ ៧ ខែ ឧសភា ១៩៨៧ គួបផ្សំនឹងការដែលពួក ប៉ុល ពត វាយទៅលើកម្លាំងគាត់ខ្លាំងផង គាត់សំរេចធ្វើវិធានការ "ពាក់កណ្តាល" គឺលាលែង ៩០ ភាគរយ ពីប្រធានរដ្ឋាភិបាលចម្រុះត្រីភាគីៗ ចាប់ពីពេលនោះមក សម្តេច សីហនុ បានស្វែងរក

ការចរចាជាមួយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយបានបើកការចរចាពីរលើក នៅប្រទេសបារាំងនាខែ ធ្នូ ១៩៨៧ និងខែ មករា ១៩៨៨។ រយៈកាលនេះ ពួក ប៉ុល ពត បានណែនាំកម្លាំងរបស់វា អោយចាប់ផ្តើមឃោសនាថា ជាសកម្មភាពដោយឡែករបស់ សីហនុ តែក៏នៅតែបន្តអូសទាញសម្តេច សីហនុ។ ថ្ងៃ ៣០ ខែ មករា ១៩៨៨ នៅទីក្រុងប៉េកាំង សម្តេច សីហនុ បានប្រកាសលាលែងជាស្ថាពរពីតំណែងប្រធានកម្ពុជាប្រជាធិបតេយ្យ ដែលពេលនោះគាត់ហៅរដ្ឋាភិបាលត្រីភាគីថា ជាបិសាចគួរអោយព្រឺខ្លាច។ ប៉ុល ពត បានប្រញាប់ប្រញាល់បញ្ជូន ខៀវ សំផន អោយទៅសុំអង្វរសម្តេច សីហនុ ចូលកាន់តំណែងវិញ។ ក្រោយពីការស្ងាត់ស្ងៀមមួយរយៈខ្លី ថ្ងៃ ១១ កក្កដា ១៩៨៨ សម្តេច សីហនុ បានប្រកាសលាលែងជាស្ថាពរលើកទី ២ ហើយដែលមានចរិតដាច់ខាតជាងលើកមុនៗ ហើយប្រឆាំងខ្មែរក្រហម ខ្លាំងជាងពេលមុនៗ ថ្ងៃទី ២៧ កក្កដា ១៩៨៨ ក្នុងពេលប្រជុំក្រៅផ្លូវការ រវាងបក្សពួកខ្មែរដែលមានជម្មោះ ប្រទេសឥណ្ឌូចិន និងប្រទេស អាស៊ាន កំពុងប្រព្រឹត្តិទៅ ប៉ុល ពត បានចេញបទបញ្ជាអោយកម្លាំងរបស់វាធ្វើការវាយប្រហារទាំងនយោបាយ និងយោធា ទៅលើកម្លាំង សីហនុ និង សឺន សាន ដែលមានខ្លឹមសារទាំងស្រុងថា «៨៧ ផ្ញើជូនគ្រប់កន្លែង៖

*I — សភាពការណ៍ក្នុងពេលបច្ចុប្បន្ននេះ ឃើញថាកាន់តែអនុគ្រោះអោយយើង ក្នុងការវាយកំចាត់ពីរ កសាងបួន និងអនុវត្តយុទ្ធវិធីបីយ៉ាង។ ហេតុនេះ ស្នើគ្រប់មុខសញ្ញាខិតខំជំរុញកសាងកម្លាំង ៤ យ៉ាងអោយបានច្រើនកុះករគ្រប់កន្លែងទូទាំងសមរភូមិ ដើម្បីយើងមានលក្ខណាអាចឈានទៅមុខទៀត។ ចំពោះផ្ទៃក្នុង សំណូមពរខិតខំរៀនសូត្រអំពីឯកសារ*

*ខ្លឹមសារ បកស្រាយពន្យល់ អំពីឧបាយកលអាខ្មាំងយួន និងអំពីទស្សនៈរបស់យើងចំពោះពួកខ្មែរផ្សេងៗ ទៀត ជាពិសេសពួក សីហនុ និង ពួកខ្មែរសេរី សឺន សាន។*

*១. ចំពោះការចរចាស្អីគេនោះ នៅក្រុងហ្សាការតា វាមិនអាចដោះស្រាយបញ្ហាយើងបានទេ។ គន្លឹះសំខាន់ គឺ បើយើងវាយខ្លាំង ទើបខ្មាំងវាដកថយ។*

*២. ចំពោះ សីហនុ បច្ចុប្បន្នលាលែងផុតពីរដ្ឋាភិបាលចម្រុះត្រីភាគី ហើយ សីហនុ ចូលថ្លុកផ្តែហើយ វាចាប់ដៃ ឪបជើងធ្វើខ្ញុំកញ្ជះបារាំង រត់ចោលត្រីភាគី រត់ចោលជាតិ រត់ចោលប្រជាជនយើងហើយ វាគ្មានគិតគូរដល់ជាតិ ដែលកំពុងរងគ្រោះ ដោយសារយួនកាប់សម្លាប់ប្រជាជនប្រល័យពូជសាសន៍ទេ សីហនុ គិតតែប្រយោជន៍ផ្ទាល់ខ្លួនវាទេ។*

*II. វិធានការទប់ទល់របស់យើងចំពោះបញ្ហានេះ គឺ៖*

*១. ចំពោះពួក សីហនុ និង សឺន សាន យើងត្រូវតែវាយ ឬផ្ទឹះផ្តៀលនយោបាយរបស់ពួកវា គឺ:*

*ក. ឃោសនាលើកអំពីធាតុពិតនៃការជិះជាន់ កេងប្រវ័ញ្ចចំពោះប្រជាកសិករយើងរាប់សិបឆ្នាំមកហើយ បណ្តាលអោយកសិករយើងងើបក្បាលឡើងមិនរួច ហើយត្រូវរងទុក្ខវេទនាលំបាកក្រីក្ររហេមរហាមរហូតដល់កសិករខ្លះ ត្រូវទៅស៊ីឈ្នួលគេ ដើម្បីយកលុយមកចិញ្ចឹមក្រពះ។*

*ខ. ឃោសនាលើកអំពីធាតុពិត ពុករលួយ ពាលាអាវាសែ មិនគិតគូររឿងជាតិ និងប្រជាជនអ្វីទេ។*

*គ. ឃោសនាលើកអំពីធាតុពិត វាធក់ប្អូន រំលោភកូនក្រមុំប្រជាជនយើង ហើយប្រជាជនបានស្គាល់ច្បាស់ណាស់ ពួកនេះជាមនុស្សព្រៃផ្សៃ គ្មានចិត្តមេត្តាធម៌ស្អីបន្តិចបន្តួច ដូចកងទ័ពជាតិយើងទេ។*

*ឃ. វិភាគតាមប្រវត្តិសាស្ត្រ ពួកខ្មែរសេរីមិនដែលវាយឈ្នះនរណាទេ ក្នុងសម័យណាក៏ពួកវាចាញ់គេទាំងអស់ មូលហេតុដែលនាំអោយចាញ់គេនោះ គឺមកពីមាគ៌ានយោបាយ និងការដឹកនាំរបស់វាមិនត្រឹមត្រូវ ចំណែកការអនុវត្តន៍របស់ពួកវាក៏ដូចគ្នាដែរ ឃើញនយោបាយរបស់វាគ្មានមូលដ្ឋានអ្វីទេ។ ដូចនេះពួកវាមានតែបរាជ័យ ដូចមិត្តយើងទាំងឡាយបានឃើញស្រាប់មកហើយ ក្នុងរយៈ ៩ ឆ្នាំកន្លងមកនេះ ពួកខ្មែរសេរី មានតែចាញ់គេជាប់ វាគ្មានទៅមុខទេ ទោះជាកម្លាំងរបស់វាទៅដល់មុខសញ្ញាខ្លះរបស់យើង តែប្រជាជនដែលស្គាល់ធាតុពិតរបស់វា គេមិនល្មើពកថ្វាសចូលបំរើអោយវាទេ ហើយគេមិនសូវទៅនៅជាមួយពួកវាផង។*

*២. អំពីវិធីដោះស្រាយ ដើម្បីវាយនយោបាយពួកខ្មែរទាំងនោះ កុំអោយប្រជាជនព្រឺលភ្នែកគឺ៖*

*ក. ឃោសនាអប់រំអោយប្រជាជនឃើញច្បាស់ នូវធាតុពិតរបស់ពួកវា។*

*ខ. ឃោសនាអប់រំអោយជួរយើងយល់ជ្រួតជ្រាប បែងចែកច្បាស់លាស់អំពីយើង និងសត្រូវ ហើយបញ្ជាក់ច្បាស់ថា យើងជាអ្វី ត្រូវបំរើអោយអ្នកណា ពួក សីហនុ និងខ្មែរសេរី សឺន សាន ជាអ្វី តើពួកនេះបំរើផលប្រយោជន៍អោយវណ្ណៈណា។*

*គ. ខិតខំពង្រឹងជួរយើង និងអប់រំប្រជាជន ព្រោះបើជួរយើងរឹងមាំ ហើយប្រជាជនគេស្អប់ខ្ពើមវា តើពួកខ្មែរទាំងនោះវានៅកន្លែងណាបាន ហើយបើគេមិនចូលបំរើអោយវា តើវាមានកម្លាំងឯណាមកបង្កើនចំនួនទ័ព។ ដូច្នេះវាមុខជាត្រូវលោយជាមិនខានទេ។ សរុបមកវិញ ត្រូវខិតខំអប់រំប្រជាជន និងផ្ទៃក្នុងយើងអោយយល់ជ្រួតជ្រាប ហើយប្រើកម្លាំងមហាជន ទៅវាយរំលំនយោបាយពួកវា បណ្តាលអោយពួក សីហនុ និង សឺន សាន មុខជាត្រូវបែកខ្ញែកអស់។*

៣. ចាប់ពីថ្ងៃនេះតទៅ បើឃើញពួក សីហនុ និងពួក សឺន សាន ទៅកន្លែងណា យើងត្រូវចាត់ចែងកម្លាំងទៅវាយកម្ទេចពួកវាចោល ហើយយើងប្រើកម្លាំងរបស់យើង និងស្នូល ៤ យ៉ាង ប្រទាក់ក្រឡាសំណាញ់អោយញឹកទៅតាមភូមិ រហូតដល់ក្រុមគ្រួសារតែម្តង។ *ដកការពិសោធន៍កាលពីមុន យើងឈ្នះពួកខ្មាំងសត្រូវគ្រប់ប្រភេទដូចជា សីហនុ បារាំង សឺន សាន អាមេរិក ក៏ដោយសារយើងចេះផ្អែកលើកម្លាំងមហាជន កត្តាកំណត់រាល់ជោគជ័យរបស់យើង គឺត្រូវជឿលើមហាជនដ៏មហិមា ហើយបើប្រជាជនគាំទ្រយើង គឺទោះជាខ្មាំងសត្រូវណាក៏ដោយ ក៏យើងអាចឈ្នះបានទាំងអស់ កុំថាតែចំពោះ សីហនុ។*

*សរុបអោយខ្លីមក គឺខិតខំឃោសនាអប់រំផ្ទៃក្នុងជួរយើង និងប្រជាជនបំផុសអោយគេមានការឈឺចាប់ស្អប់ខ្ពើមចំពោះ សីហនុ និង សឺន សាន រហូតដល់ប្រឆាំងជាមួយពួកខ្មែរទាំងនេះ»។*

*ទូទាំងអត្ថបទនៃបទបញ្ជារបស់លេខ ៨៧ ប្រមូលផ្តុំសំខាន់លើការវាយទៅលើ សីហនុ សឺន សាន។ នេះវាហាក់ដូចជាដំណាក់កាល ធ្វើអត្តឃាតខាងនយោបាយរបស់ពួកខ្មែរក្រហម ប៉ុល ពត តាមរយៈនៃសេចក្តីសំរេចខាងនយោបាយ ដែលមានចរិតជាការផ្លាស់ប្តូរសម្ព័ន្ធភាព សូម្បីតែស្នូល ៤ យ៉ាង ដែលពួកវាធ្លាប់បានកសាង ដើម្បីវាយសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏បានត្រូវបង្វែរទៅវាយ សីហនុ សឺន សាន វិញដែរ។ ក្នុងសេចក្តីណែនាំមួយមិនគ្រប់គ្រាន់ នាថ្ងៃ ០៨ សីហា ១៩៨៨ អគ្គបញ្ជាការដ្ឋានកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ ដែលគេអាចដឹងបានថាជា ប៉ុល ពត បានចេញការណែនាំមួយទៀតដល់កម្លាំងរបស់វា ដែលប្រមូលផ្តុំបកអាក្រាតថ្កោលទោស បំផុសជួរវាអោយចងកំហឹងចំពោះពួក សីហនុ សឺន សាន ហើយជំរុញសកម្មភាពកងកម្លាំង*

ប្រដាប់អាវុធ ដើម្បីវាយកម្លាំងទាំងពីរនេះ។ នេះជាការបែកបាក់ធ្ងន់ធ្ងរបំផុតមិនដែលមានពីមុនមក។ ចាប់តាំងពីមានបទបញ្ហា យើងពិនិត្យឃើញថា ក្នុងមួយខែៗ មានរាប់សិបលើកដែលពួក ប៉ុល ពត វាយពួកសីហនុ និង សឺន សាន ដែលធ្វើអោយពួកនេះស្លាប់ និងរបួសជាច្រើន ហើយក៏បានរត់មកសុំសារភាពជាមួយបដិវត្តន៍ជាច្រើនដែរ។

គួររំលឹកអំពីការបែកបាក់នៃត្រីភាគី ក្នុងឱកាសការចរចាក្រៅផ្លូវការនៅហ្សាការតា។ សឺន សាន ខៀវ សំផន រណប្ញទ្ធិ បានបង្ហាញយ៉ាងច្បាស់អំពីទំនាស់ដែលមិនអាចបិទបាំងបាន ហើយក៏មិនងាយដោះស្រាយបាន នៅពេលដែល រណប្ញទ្ធិ លើកឡើងថា "គេមិនអាចដោះស្រាយបាននូវបញ្ហា អាស្រ័យដោយម្ខាងៗ លើកឡើងតែពាក់កណ្ដាលនៃបញ្ហា"។ ខ្ញុំ (ហ៊ុន សែន) បានសួរ រណប្ញទ្ធិ ភ្លាមថា ពាក់កណ្ដាលទី ១ គឺអ្វី? ហើយពាក់កណ្ដាលទី ២ គឺអ្វី? រណប្ញទ្ធិ ឆ្លើយថា ពាក់កណ្ដាលទី ១ គឺដកកងទ័ពវៀតណាម ពាក់កណ្ដាលមួយទៀតគឺកំចាត់គ្រោះថ្នាក់ខ្មែរក្រហម ប៉ុល ពត កុំអោយត្រឡប់ទៅកាន់អំណាចវិញ។ ចប់ចម្លើយនេះ យើងពិនិត្យឃើញ ខៀវ សំផន និងប្រតិភូរបស់គាត់ មុខដូចចង់ស្រក់ឈាម ពោរពេញទៅដោយកំហឹង។ វាកាន់តែក្ដៅក្រហាយថែមទៀត នៅពេល សឺន សាន បង្ខំអោយ ខៀវ សំផន សន្យាថា "ពេលកងទ័ពវៀតណាមដកចេញ ខ្មែរក្រហមមិនដណ្ដើមអំណាចម្នាក់ឯងនោះទេ" ធ្វើអោយ ខៀវ សំផន លែងនិយាយអ្វីកើតទៀត។ ការបែកបាក់មិនត្រឹមតែបានបង្ហាញនៅពេលប្រជុំដំណាក់កាលទី ១ រវាងបក្សពួកខ្មែរប៉ុណ្ណោះទេ ប៉ុន្តែបានលាតត្រដាងចំពោះមុខបណ្ដាប្រទេសដែលចូលរួមក្នុងដំណាក់កាលទី ២ ផងដែរ។ នៅពេលបណ្ដាប្រទេសអាស៊ាន

បានឈានដល់ការចុះសម្រុងជាមួយបណ្ដាប្រទេសឥណ្ឌូចិន ស្ដីពីភាពចាំបាច់ត្រូវរាំងស្កាត់ការវិលត្រឡប់របស់ពួកខ្មែរក្រហម ប៉ុល ពត ហើយឯកភាពក្នុងការបញ្ឈប់ជំនួយពីខាងក្រៅ ចំពោះកម្លាំងខ្មែរបដិបក្ខ ទាំង សឺន សាន ទាំង រណឫទ្ធិ តំណាងអោយសម្ដេច សីហនុ សុទ្ធតែបានឡើងថ្លែងយោបល់សុំកុំអោយគេបញ្ចូលខ្លួនទៅក្នុង"កន្ត្រក" ជាមួយ ប៉ុល ពត ដែលធ្វើអោយប្រតិភូខ្មែរក្រហម ចូលក្នុងភាពឯកោយ៉ាងខ្លាំង។ តាម សឺន សាន អោយយើងដឹង ខៀវ សំផន បានព្រាងឡើងនូវបទអន្តរាគមន៍មួយសំរាប់ជំទាស់នឹងសេចក្ដីថ្លែងការណ៍ ចុងក្រោយនៃសម័យប្រជុំ និងសំរាប់ថ្លែងក្នុងសន្និសីទសារពត៌មាន ហើយបង្ខំអោយ សឺន សាន អាន ប៉ុន្តែ សឺន សាន មិនព្រមអាន ចុងក្រោយខ្មែរក្រហម ខៀវ សំផន ត្រូវអានដោយខ្លួនឯង។

ក្នុងការចរចាជាមួយសម្ដេច សីហនុ ប៉ុន្មានលើកកន្លងមក យើងសង្កេតឃើញថា សម្ដេច សីហនុ បានប្រើប្រាស់ពេលវេលាចរចាយ៉ាងច្រើន ដើម្បីវាយប្រហារទៅលើដៃគូខ្លួន ក្នុងរដ្ឋាភិបាលចម្រុះត្រីភាគី។ មនុស្សខ្លះ បានចាត់ទុកថា នេះជាយុទ្ធវិធីរបស់សម្ដេច សីហនុ ដើម្បីគេចចេញពីការចោទប្រកាន់ថា បានរួបរួមជាមួយខ្មែរក្រហម ប៉ុន្តែសំរាប់យើង យើងចាត់ទុកថានេះជាទំនាស់មានចរិតជាសារជាតិនៃសម្ព័ន្ធភាពនៃបងប្អូនដែលជាសត្រូវនឹងគ្នា។

ក្រៅពីទំនាក់ទំនងដ៏តឹងតែងរវាងក្រុមសម្ដេច សីហនុ សឺន សាន ជាមួយខ្មែរក្រហម ទំនាក់ទំនងរវាងក្រុមសម្ដេច សីហនុ ជាមួយក្រុម សឺន សាន ដែលហៅថា អ្នកជាតិនិយមដូចគ្នា ក៏មានភាពតានតឹងខ្លាំងដែរ។ គេរកគ្រប់វិធី ដើម្បីរាំងស្កាត់នូវលទ្ធភាពឈានមុខខាងនយោបាយ និង

ទម្លាក់ឥទ្ធិពលគ្នាទៅវិញទៅមក។ ស្ទើរតែគ្រប់លេខនៃព្រឹត្តិប័ត្រសារព័ត៌មាន កាសែត ទស្សនាវដ្តីរបស់ពួកគេ តែងតែលើកឡើងពីការចោទប្រកាន់គ្នា មិនគ្រាន់តែលើបញ្ហាតូចតាចប៉ុណ្ណោះទេ តែថែមទាំង ហែកហួរគ្នាអំពីជាតុពិតខាងនយោបាយទៀតផង ដែលគេត្រូវប្រើពេលវេលា និងកម្លាំងជាច្រើន ដើម្បីទប់ស្កាត់ជាមួយគ្នា។ ជម្លោះបានកើតមានជាប្រចាំ តាំងពីមុនបង្កើតសម្ព័ន្ធភាពត្រីភាគី អាស្រ័យដោយពួកគេដណ្តើមការត្រួតត្រាជំរំអ្នកភៀសខ្លួន ដណ្តើមជំនួយមនុស្សធម៌ និងប្រកួតប្រជែងឥទ្ធិពលគ្នា។ ជម្លោះឈានទៅដល់ការប៉ះទង្គិចគ្នាតាមផ្លូវយោធាផង ដែលធ្វើអោយម្ខាងៗ ខូចខាតរៀងៗ ខ្លួន។ ក្រោយពេលមានវិបត្តិផ្ទៃក្នុង នៃរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែររបស់ សឺន សាន ឥរិយាបថរបស់ សឺន សាន និងក្រុមគាត់មានភាពធូរស្រាលមួយរយៈ អាស្រ័យដោយ សឺន សានត្រូវការការគាំទ្រពីសម្តេច សីហនុ ដើម្បីតស៊ូក្នុងជម្លោះជាមួយ សាក់ ស៊ុតសាខន។ ការបន្តបិតបេរក្នុងតំណែងអាស្រ័យដោយធម្មនុញ្ញកូឡាទ្បំពួរ និងការគាំទ្ររបស់ឪពុកធម៌នៃរដ្ឋាភិបាលត្រីភាគី បានធ្វើអោយ សឺន សាន ពង្រឹងនូវជំហរខ្លួន ហើយបញ្ចេញចង្កូមដាក់សម្តេច សីហនុ ឡើងវិញ។ ក្នុងការចរចារវាងសម្តេច សីហនុ ជាមួយយើង សម្តេច សីហនុ បានឆ្លៀតវាយប្រហារ សឺន សាន យ៉ាងពេញទំហឹង ឯ សឺន សាន ក៏បានឆ្លៀតប្រើប្រាស់ការដែលសម្តេច សីហនុ ចរចាជាមួយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីពង្រឹងការគាំទ្រពីចិន និងខ្មែរក្រហម ហើយវាយប្រហារទៅលើ សម្តេច សីហនុ ថាបាន"ក្បត់ជាតិ" ដោយហុចដៃអោយសត្រូវ។ ក្នុងការចរចា ហ៊ុន សែន-សីហនុ លើកទី ២ ខែមករា ១៩៨៨ នៅប្រទេសបារាំងសម្តេច

សីហនុ បានលើកឡើងពីរូបមន្តបង្កើតរដ្ឋាភិបាលចំរុះទ្វេភាគីរវាងគាត់ជាមួយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគ្មានខ្មែរ សឺន សាន និងខ្មែរក្រហម។ ដោយឃើញថា សីហនុ ប្រានខ្លួនចេញពីដំណោះស្រាយកម្ពុជា សឺន សាន បានវាយប្រហារយ៉ាងខ្លាំងទៅលើ សីហនុ។

ក្រោយពេលទទួលការវាយប្រហារ ជាច្រើនលើកច្រើនសារបស់ សឺន សាន ទៅលើខ្លួនគាត់ និងក្រោយពីបានទទួលសារទូរលេខមួយច្បាប់ពី រណឫទ្ធិ កូនប្រុសរបស់គាត់នៅឯក្រុង បាងកក ថា កងទ័ពរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ ចំនួន ៣០០ នាក់ បានហ៊ុំព័ទ្ធកងទ័ព សីហនុនិយម ដែលបោះប្រចាំនៅខេត្តត្រាត ប្រទេសថៃ តាំងពីថ្ងៃ ២៩ មករា ១៩៨៨ មក ក្នុងបំណងកុំអោយមានកងទ័ពសីហនុនៅទីនេះ និងចង់ដណ្តើមយកទៅវិញនូវកងទ័ពរបស់ សឺន សាន ២០០ នាក់ ដែលបានរត់មកសុំចុះចូលជាមួយទ័ព សីហនុ កាលពីខែធ្នូ ១៩៨៧។ ថ្ងៃ ៣០ ខែមករា ១៩៨៨ នៅទីក្រុងប៉េកាំង សម្តេច សីហនុ បានធ្វើសេចក្តីប្រកាសលាលែងពីតំណែងប្រធានរដ្ឋាភិបាលត្រីភាគីជាស្ថាពរ។ ក្នុងសេចក្តីថ្លែងការណ៍របស់គាត់ និងក្នុងសារទូរលេខ ផ្ញើមកអោយ នរោត្តម រណឫទ្ធិ នាថ្ងៃដដែល សម្តេច សីហនុ បានប្រមូលផ្តុំលើកឡើង អំពីទំនាស់រវាងគាត់ជាមួយ សឺន សាន ដោយបញ្ជាក់ថា "ដុំវិញការសំរេចលាចេញជាស្ថាពររបស់បិតា ពីកម្ពុជាប្រជាធិបតេយ្យ និងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃ ៣០ មករា ១៩៨៨ នេះតទៅ ព្រោះបិតាលែងនៅជាមួយលោក សឺន សាន និងរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែររបស់គាត់បានទៀតហើយ"។ ក្រោយពីការស្ងាត់ស្ងៀមមួយរយៈ ហើយដើម្បីបង្កើតជំហររួមគ្នា ក្នុងការជួបជុំក្រៅផ្លូវការនៅហ្សាការតា ថ្ងៃ ២៩

កក្កដា ១៩៨៨ មុនពេលចាកចេញពី ហ្សាការតា ប្រទេស ឥណ្ឌូនេស៊ី ថ្លែងចំពោះអ្នកយកព័ត៌មានអំពីលទ្ធភាពនៃការធ្វើសម្ព័ន្ធភាពរវាងក្រុមគាត់ជាមួយ រដ្ឋាភិបាលក្រុងភ្នំពេញ ដើម្បីទប់ស្កាត់ខ្មែរក្រហម សម្តេច សីហនុ ក៏បានចោទប្រកាន់ថា ពួក សឺន សាន មានការលំបាកព្រោះពួកគេ "ប្រឆាំងកុម្មុយនិស្តក៏ខ្លាំង ប្រឆាំងរាជានិយមក៏ខ្លាំងណាស់ដែរ"។

ថ្ងៃ ៩ សីហា ១៩៨៨ បន្ទាប់ពីទស្សនកិច្ចនៅប្រទេស ម៉ាឡេស៊ី ប្រុយណេ និងសិង្ហបូរី សឺន សាន បានសរសេរលិខិតមួយថ្វាយសម្តេច សីហនុ ដែលមានចរិតជាការទូន្មានចំពោះ សីហនុ។ ដូចគេឯងបានដឹងរួចហើយថា សម្តេច សីហនុ មិនធ្លាប់ទទួលនូវការទូន្មានពី សឺន សាន ឬជនជាតិខ្មែរណាឡើយ ដូច្នេះលិខិត សឺន សាន ប្រៀបដូចជាគន្ទឹះផ្ទុះនៃគ្រាប់បែកដូច្នេះដែរ ការបកត្រឡប់មកវិញហាក់ដូចជាសង្គ្រាមលើក្រដាសរបស់អ្នកធ្វើនយោបាយ។ ថ្ងៃ ១៥ សីហា ១៩៨៨ ពីទីក្រុងប៉េកាំង សម្តេចបានធ្វើចុតហ្មាយ (លិខិត) មួយឆ្លើយតបចំពោះការទូន្មានរបស់ សឺន សាន ដែលមានខ្លឹមសារយ៉ាងជូរចត់ សូម្បីតែលើលិខិតរបស់ សឺន សាន ដែលហៅសម្តេច សីហនុ ថា ជា "ប្រធានកម្ពុជាប្រជាធិបតេយ្យ" ក៏សម្តេច បានគូសព័ទ្ធជុំវិញពាក្យនេះ ហើយសរសេរថា "ខ្ញុំលែងជាប្រធានកម្ពុជាប្រជាធិបតេយ្យទៀតហើយ"។

សម្ព័ន្ធភាពនៃបក្សពួកបីក្រុម គ្មានក្រុមណាត្រូវគ្នាឡើយ។ គេជាសត្រូវនឹងគ្នាតាំងពីកូនចៅតូចតាចរហូតដល់មេធំៗ ថ្នាក់កំពូល និងរហូតដល់ការមិនចុះសម្រុងគ្នា រវាងបណ្តាប្រទេសដែលគាំទ្ររដ្ឋាភិបាលចម្រុះនេះទៀតផង។ បណ្តាប្រទេសអាស៊ាន អាមេរិក និងប្រទេសប៉ែកខាងលិចខ្លះ គេធ្មៀតប្រើប្រាស់ខ្មែរក្រហមដើម្បីធ្វើអោយវៀតណាម និង

បដិវត្តន៍កម្ពុជាចុះខ្សោយ ប៉ុន្តែគេក៏ប្រឹងទប់ស្កាត់ខ្មែរក្រហមកុំអោយដណ្តើមអំណាចម្នាក់ឯង ហើយពង្រឹងតួនាទី សីហនុ សឺន សាន ដើម្បីត្រួតត្រាកម្ពុជា ដែលនាំដល់ការស្តារឡើងវិញ នូវឥទ្ធិពលប្រទេសប៉ែកខាងលិចនៅកម្ពុជា និងមានប្រទេសខ្លះចង់អោយកម្ពុជា ក្លាយជាតំបន់ទ្រនាប់រវាងវៀតណាម និងថៃផង។ ចិន គាំទ្រយ៉ាងរឹងមាំចំពោះខ្មែរក្រហម ប៉ុល ពត ប៉ុន្តែត្រូវឆ្លៀតប្រើ សីហនុ សឺន សាន ដើម្បីជាគ្រឿងអលង្ការតុបតែងមុខមាត់ខ្លួនប្រាណអោយ ប៉ុល ពត ដើម្បីគេចចេញពីគ្រោះថ្នាក់នៃការបាត់តួនាទីខាងនយោបាយនៅលើឆាកអន្តរជាតិ ប៉ុន្តែក៏គ្មានពេលណាដែលចិនជួយពួក សីហនុ សឺន សាន អោយមានកម្លាំងយោធាអាចត្រួតត្រា ឬប្រណាំងប្រជែងជាមួយពួក ប៉ុល ពត បានឡើយ ឬហោចណាស់ក៏ត្រូវរក្សាអោយពួក ប៉ុល ពត នៅជាភាគីខ្លាំងជាងគេក្នុងការកាន់អំណាចនៅកម្ពុជា។ ការខុសគ្នានេះ ជាការខុសគ្នាផ្នែកយុទ្ធសាស្ត្រចុងក្រោយ ថ្វីត្បិតតែគេខិតខំសម្រុះសម្រួលយុទ្ធវិធី ចំពោះមុខយ៉ាងណា ក៏មិនអាចបិទបាំងបាននូវការខ្វែងទំនាស់គ្នាបានដែរ។

ថៃ ជាសមាជិកសមាគមបណ្តាប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន បានលោតចូលក្នុងនយោបាយចិន ក្នុងការធ្វើសង្គ្រាម ប្រឆាំងកម្ពុជា និងឥណ្ឌូចិន ក្នុងពេលនោះ ប្រទេសផ្សេងទៀត ពិសេស ឥណ្ឌូនេស៊ី បានចាត់ទុកចិនជាគ្រោះគំរាមកំហែងចំពោះឥណ្ឌូនេស៊ី និងអាស៊ីអាគ្នេយ៍។ នេះមិនមែនជាការខុសគ្នា គ្រាន់តែជុំវិញបញ្ហាកម្ពុជាមួយមុខនោះទេ តែជាការខុសគ្នាអំពីបញ្ហាយុទ្ធសាស្ត្រ ក្នុងបញ្ហាសន្តិភាព ស្ថិរភាព នៅអាស៊ីអាគ្នេយ៍ផងដែរ។ នៅពេលថៃ និងចិន ពិភាក្សាគ្នាអំពីការកសាងឃ្លាំងស្តុកអាវុធរបស់ចិន នៅប្រទេសថៃ បណ្តាប្រទេសក្នុងសមា

គមអាស៊ាន សុទ្ធតែមានការព្រួយបារម្ភ ក្នុងកំរិតខុសៗ គ្នា។

ប្រទេសប៉ែកខាងលិចជាច្រើន គាំទ្រ សីហនុ សឺន សាន ប៉ុន្តែមិនអាចទទួលស្គាល់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យបាន ទោះជាសីហនុ ធ្វើជាប្រធានក៏ដោយ ព្រោះរដ្ឋាភិបាលនេះមានខ្មែរក្រហមជាស្នូល។ ប៉ែកខាងលិច អាមេរិក និងអាស៊ាន ដែលតែងតែឡើងសម្លេងគាំទ្រ សីហនុ ក្នុងប៉ុន្មានឆ្នាំនេះ គេធ្លាប់មានអនុស្សាវរីយ៍ដ៏ជូរចត់ជាមួយ សីហនុ ក្នុងដើមទសវត្សឆ្នាំ ៧០ អាស្រ័យដោយគេបានគាំទ្រលន់ នល់ និងអាមេរិក ប្រឆាំង សីហនុ នៅពេលនោះ។ សីហនុ ក៏បានឃើញច្បាស់ខ្លួនឯងថា ការដែលប្រទេសទាំងនេះគាំទ្រខ្លួន អាស្រ័យដោយពេលនេះគ្មានសន្ទឹកបៀរណាអោយល្អជាងនេះ ហើយការគាំទ្រនេះក៏ក្នុងផលប្រយោជន៍យុទ្ធសាស្ត្ររបស់គេដែរ។ ថៃ ស្អប់ សីហនុ យ៉ាងខ្លាំងក្នុងបញ្ហាព្រះវិហារ និងខេត្តមួយចំនួន ដែលថៃបង្ខំប្រគល់អោយកម្ពុជាក្រោយសង្គ្រាមលោកលើកទី២ នាឆ្នាំ ១៩៤៧ ដូច្នេះ ការគាំទ្ររបស់ថៃចំពោះ សីហនុ មានចរិតបណ្តោះអាសន្ន ដើម្បីគាបសង្កត់យកខេត្តទាំងនេះទៅវិញ។ ថៃ មិនអនុញ្ញាតិអោយ សីហនុ មានកម្លាំងគ្រប់គ្រាន់ ដើម្បីត្រួតត្រាអំណាចឡើយ សីហនុ បានទទួលស្គាល់ថា "ប្រៀបធៀបបញ្ជីដែលចិនបានផ្តល់ជំនួយសំរាប់កងទ័ពរបស់ខ្ញុំ ខ្ញុំបានទទួលតែ ១០ ភាគរយគត់ពីថៃ" ទាំងចិន ទាំងថៃ សុទ្ធតែរារាំងមិនអោយកងទ័ព សីហនុ កើនឡើង គាត់បញ្ជាក់ថា "ថៃ មិនចង់អោយសីហនុ ខ្លាំងទេ គេចង់អោយខ្មែរក្រហមគ្របសង្កត់រដ្ឋាភិបាលចម្រុះ ថៃស្អប់ សីហនុ ថៃ មិនចង់បាន សីហនុ ទេ"។ ថ្ងៃ ២៧ កក្កដា ១៩៨៨ នៅទីក្រុង ហ្សាការតា ក្នុងពេលជួបជាមួយភាគីខ្មែរទាំង ៤ ប្រតិភូ សីហនុ

បាននិយាយថា សមាជិករដ្ឋសភាថៃខ្លះ បានទៅទស្សនកិច្ចនៅមូលដ្ឋានរបស់ខ្ញុំនៅជិតព្រំដែន នៅទីនោះគេបានសួរនាយទាហានខ្ញុំថា "ក្រែង សីហនុ ទទួលថានឹងផ្តល់ខេត្តព្រះវិហារ បាត់ដំបង សៀមរាប និងកំពង់ធំ មកអោយថៃវិញ" ចំណុចនេះបញ្ជាក់អំពីអាថ៌កំបាំងរបស់ថៃ ក្នុងការគាំទ្រ សីហនុ និងបក្សពួកខ្មែរផ្សេងទៀត ដែលជាឧបាយកលដណ្តើមដី នេះជាវិធី "វិនិយោគទុន ឬដាក់នុយដើម្បីចាប់ត្រី"។ អ្វីៗទាំងអស់ ក្នុងល្បែងសម្ព័ន្ធភាពប្រឆាំងកម្ពុជា គឺសុទ្ធតែបណ្តោះអាសន្ន ក្នុងផលប្រយោជន៍រៀងៗខ្លួន រាប់តាំងពីបក្សពួកខ្មែរ រហូតដល់ពពួកឪពុកធម៌របស់រដ្ឋាភិបាលចម្រុះ។

ជាជាតុពិត រដ្ឋាភិបាលចម្រុះបានរលាយរួចស្រេចទៅហើយ ដោយរដ្ឋាភិបាលនេះគ្មានការត្រួតត្រាទឹកដី និងប្រជាជន រស់នៅក្រៅប្រទេស តាមការប្រោះព្រំពីបរទេស ប៉ុន្តែ ការស្របច្បាប់ក៏លែងមានន័យអ្វីដែរ ព្រោះភាគីទាំងបី បានឈានដល់ការកំចាត់គ្នាទាំងយោធា និងនយោបាយហើយដែរ ហើយបើតាមធម្មនុញ្ញក្វាឡាឡំពួរ ថ្ងៃ ២២ មិថុនា ១៩៨២ រដ្ឋាភិបាលចម្រុះនេះ បានរលាយរួចទៅហើយ តាំងពីថ្ងៃ ៧ ឧសភា ១៩៨៧ ពេលដែលសម្តេច សីហនុ លាលែងពីតំណែង "ពាក់កណ្តាល"។ ពាក់កណ្តាល ឬស្ថាពរ គឺជាការលាលែង ព្រោះជាទម្លាប់លើសកលលោក មិនដែលមានប្រមុខរដ្ឋ ឬរដ្ឋាភិបាលណា លាលែងពីតំណែងពាក់កណ្តាលនោះឡើយ។ តែ ប៉ុន្មានម៉ោង ឬប៉ុន្មានថ្ងៃក្រោយ គេត្រូវតែតែងតាំងមនុស្សថ្មីចូលជំនួស។ បើគេមិនទទួលយកថ្ងៃ ៧ ឧសភា ១៩៨៧ ក៏គេត្រូវទទួលយកថ្ងៃ ១០ កក្កដា ១៩៨៨ ពេលដែល សីហនុ លាលែងជាស្ថាពរ ពីប្រធានរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

ហើយត្រូវហែកចោលសេចក្តីប្រកាស កូឡាឡាំពួរ ទើបត្រឹមត្រូវ ព្រោះសេចក្តីប្រកាសនេះអត់និយាយពីរណសិរ្សហ៊្វុនស៊ីនប៉ិចឡើយ និយាយតែឈ្មោះ សីហនុ ជាប្រធានតែប៉ុណ្ណោះ។ ពេលហូបបាយថ្ងៃត្រង់រវាងខ្ញុំ សម្តេច សីហនុ សឺន សាន ថ្ងៃទី ៧ វិច្ឆិកា ១៩៨៨ ក្នុងឱកាសចរចាថ្នាក់កំពូល ហ៊ុន សែន-សីហនុ-សឺន សាន នៅ ហ្វែរអង់តាដឺន័រ ខ្ញុំបានចោទសួរសម្តេចថា តើរដ្ឋាភិបាលចម្រុះត្រីភាគីនៅបិតបេរទៀតឬទេ បើសម្តេចបានចាកចេញជាស្ថាពរហើយនោះ។ សម្តេច សីហនុ បានឆ្លើយថា ជាផ្លូវច្បាប់គឺត្រូវចប់ហើយ បានសេចក្តីថា រដ្ឋាភិបាលចម្រុះនេះរលាយបាត់ទៅហើយ ពេលនោះ សឺន សាន និយាយអ្វី ក៏មិនកើតសុខចិត្តនៅស្ងៀមមិនចេញស្តី។ តើវានៅបិតបេរបន្តអាស្រ័យដោយ សឺន សាន នៅក្នុងតំណែងជានាយករដ្ឋមន្ត្រីឬ? បើវាពិតដូច្នេះមែន ការចោទប្រកាន់របស់ក្រុម សាក់ ស៊ុតសាខន ដៀន ដែល គឺជាការត្រឹមត្រូវ។ សឺន សាន ជាមនុស្សអាត្មានិយម ត្រូសារបុណ្យស័ក្តិ សុខចិត្តឱបយកតំណែងនាយករដ្ឋមន្ត្រី ហើយបណ្តោយអោយយុទ្ធជនរបស់គាត់ស្លាប់ដោយការវាយប្រហារពីសំណាក់ពួកខ្មែរក្រហម ប៉ុល ពត។ នៅពេលហូបបាយជាមួយខ្ញុំ (ហ៊ុន សែន) នៅល្ងាចថ្ងៃ ២៨ កក្កដា ១៩៨៨ នៅទីក្រុង បូហ្គ័រ ប្រទេសឥណ្ឌូនេស៊ី សឺន សាន បាននិយាយថា ចិន និងខ្មែរក្រហមខឹងនឹងគាត់ តែគាត់មិនអាចបោះបង់ចិនរៀងរហូតបានទេ ត្រូវរកដោះផ្សេងដើម្បីបោះ ប៉ុន្តែរហូតមកដល់នេះ គាត់នៅតែត្រូវការចិន និងខ្មែរក្រហម ជាងត្រូវការយុទ្ធជនក្រោមការដឹកនាំរបស់គាត់។ ដូចបានជំរាបជូនខាងលើស្រាប់ហើយថា ជម្លោះផ្ទៃក្នុងរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ បានជំរុញ សឺន សាន អោយចិន និងខ្មែរក្រហមត្រួតត្រាតែ

ម្តង។ គាត់ស្ថិតក្នុងមាត់ដង្កាប់ដែលពិបាកក្នុងការរើខ្លួន។ បើគាត់ឈប់ធ្វើនាយករដ្ឋមន្ត្រី សាក់ ស៊ុតសាខន ដេញគាត់ បើគាត់បន្តនៅជានាយករដ្ឋមន្ត្រី ខ្មែរក្រហមសម្លាប់ទាហាន របស់គាត់ "ឥឡូវ សំរាប់ សឺន សាន តំណែងមានសារសំខាន់ជាងជីវិតមនុស្ស ហើយថែមទាំងប្រាក់ទៀតផង" ហ្សាក់ បេគ័រ (*Jacque Bekaert*) ក្នុងពេលចូលធ្វើសម្ភាសន៍ជាមួយខ្ញុំ (ហ៊ុន សែន) ថ្ងៃទី ១០ វិច្ឆិកា ១៩៨៨ នៅប្រទេសបារាំង ពេលនិយាយដល់ សឺន សាន ការពារខ្មែរក្រហមនៅអង្គការសហប្រជាជាតិ គាត់ភ្ញាក់មាត់និយាយថា "សឺន សាន ត្រូវការតែប្រាក់"។

ការបែកបាក់កម្លាំងប្រឆាំង បានដើរទន្ទឹមជាមួយការឯកភាព និងការឈានឡើងដ៏រឹងមាំរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបាននាំដល់ការបង្កើតនូវបរិយាកាសនយោបាយថ្មី សំរាប់ការដោះស្រាយបញ្ហាកម្ពុជា។

## ពីការប្រឈមមុខទៅដល់ការចរចា បដិវត្តន៍ចានផ្លូវដំណាក់កាល ការផ្លាស់ប្តូរសម្ព័ន្ធភាព

*ដំណាក់កាលក្រោយពេល ប៉ុល ពត ដួលរលំ គឺជា ដំណាក់កាលកកើតឡើងនូវសម្ព័ន្ធភាពប្រឈមមុខដាក់គ្នា នៅអាស៊ីអាគ្នេយ៍។ ចិន អាមេរិក បានធ្វើសកម្មភាពយ៉ាងមមាញឹក ដើម្បីបង្កើតឡើងនូវរណសិរ្សប្រឆាំងវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជា។ គេប្រមូលទាំងអស់ ហើយហ៊ានធ្វើសម្បទានផលប្រយោជន៍អ្នកដទៃ ដើម្បីផលប្រយោជន៍ខ្លួន។ ឧទាហរណ៍ ចិន បានយកបក្សកុម្មុយនិស្តថៃដែលខ្លួនធ្លាប់ជួយជាយូរឆ្នាំមកហើយ ធ្វើជាសន្ទឹកបៀរ ដើម្បីប្តូរយកនូវការដែលរដ្ឋាភិបាលរាជាណាចក្រថៃជួយពួក ប៉ុល ពត ហើយអូសទាញថៃ ចូលក្នុងយុទ្ធសាស្ត្ររបស់ចិន។ មិនគ្រាន់តែប្រឆាំងកម្ពុជា វៀតណាមប៉ុណ្ណោះ គេបានធ្វៀតប្រើប្រាស់បញ្ហាកម្ពុជា ដើម្បីប្រឆាំងសហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយម និងធ្វើជាខ្នឹមសារដ៏សំខាន់ ក្នុងការឃុបឃិតចិន អាមេរិក បំរើដល់ការអូសទាញទុន និងបច្ចេកវិទ្យារបស់អាមេរិក និងប៉ែកខាងលិច ដើម្បីទំនើបកាវូបនីយកម្ម ៤ យ៉ាងរបស់ចិន។ គេខិតខំភ្ជាប់បញ្ហាកម្ពុជាទៅក្នុងទំនាក់ទំនងរវាងខាងកើត និងខាងលិច ដែលជាមូលហេតុនៃការបាត់បង់សន្តិភាព ស្ថិរភាព នៅអាស៊ីអាគ្នេយ៍។ សភាពការណ៍សកលលោកពេលនោះ ក៏មានការស្មុគ្រស្មាញ និង*

*តានតឹងយ៉ាងខ្លាំង ពិសេសទំនាក់ទំនងខាងកើត និងខាងលិច។ ក្នុងឆ្នាំ ១៩៧៩ នោះទៀត ក៏បានកើតឡើងនូវបញ្ហាអាហ្វហ្គានីស្ថានមួយទៀត ដែលពួកចក្រពត្តិបានប្រើប្រាស់ ធ្វើជាខ្លឹមសាររួមជាមួយបញ្ហាកម្ពុជា ដើម្បីជំរុញការប្រឈមមុខគ្នា ពិសេសនៅទ្វីបអាស៊ី ក្នុងពេលនៅអឺរ៉ុប និងដំបន់ផ្សេងទៀត មានការតានតឹងរួចស្រេចទៅហើយ។*

*ក្នុងឆ្នាំ ១៩៧៩ នៅអាស៊ីអាគ្នេយ៍ ពុំមានឃើញលេចឡើងនូវនិន្នាការចរចាណា ក្រៅពីការប្រឈមមុខគ្នានោះឡើយ។ សភាពការណ៍វិវត្តពោរពេញដោយភាពតានតឹង ការស្រមើស្រមៃ ស្តីពីការផ្តួលរំលំរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាតាមផ្លូវយោធា នៅតែមានឥទ្ធិពលគ្របដណ្តប់ទៅលើគំនិតរបស់មេដឹកនាំនៃប្រទេសប្រឆាំងកម្ពុជា ដូច្នេះ ពួកគេមិនអើពើអ្វីចំពោះសំណើរបស់យើង ដែលសុំអោយមានការចរចាដោះស្រាយបញ្ហាកម្ពុជា ដោយសន្តិវិធីនោះឡើយ។*

*បន្ទាប់ពីការតស៊ូអស់រយៈពេលប៉ុន្មានឆ្នាំ ពោរពេញទៅដោយពលិកម្មរបស់ប្រជាជនកម្ពុជា ដោយមានការជួយឧបត្ថម្ភរបស់វៀតណាម សហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយម ក៏ដូចជាអង្គការអន្តរជាតិ បានធ្វើអោយប្រជាជនកម្ពុជារស់ឡើងវិញពីគំនរផេះផង់។ ជោគជ័យក្នុងការបំបាត់គ្រោះអត់ឃ្លាន និងការធ្វើអោយមានស្ថិរភាពជីវភាពប្រជាជន ជោគជ័យក្នុងការវាយបំបាក់ការរើបំរះរបស់ខ្មាំង ជោគជ័យក្នុងការកសាងបក្ស កម្មាភិបាល និងរចនាសម្ព័ន្ធគ្រប់ផ្នែក ការដកកងទ័ពវៀតណាមមួយផ្នែកលើកដំបូង នៅឆ្នាំ ១៩៨២ បានពង្រឹងដល់ទ្រឹស្តីអំពី "សភាពការណ៍កម្ពុជាមិនប្រែក្រឡាស់"។ ចេញពីបញ្ហានេះ ក៏បានលេចឡើងនូវនិន្នាការចរចាពីសំណាក់ឥស្សរជនខ្លះ ក្នុងចំណោម*

ប្រទេសអាស៊ាន ដែលធ្វើអោយចិន ថៃ មានការព្រួយបារម្ភ ហើយ ខិតខំធ្វើសកម្មភាពបំផ្លិចបំផ្លាញ ដើម្បីបន្តនយោបាយប្រឈមមុខ។ សភាពការណ៍បន្តមានការប្រែប្រួល ប្រទេសអាស៊ាន មិនចុះសម្រុងគ្នា ថៃតាំងខ្លួនជាសមរភូមិមុខ ហើយបញ្ហានយោបាយអាស៊ាន ក្នុងបញ្ហា កម្ពុជា និងឥណ្ឌូចិន។ ក្នុងពេលដែលឥណ្ឌូនេស៊ី ម៉ាឡេស៊ី ខិតខំស្វែង រកការបង្កើនទំនាក់ទំនងជាមួយវៀតណាម ដើម្បីជំរុញ កិច្ចចរចារវាង ក្រុមប្រទេសទាំងពីរ ឈានទៅរកដំណោះស្រាយមួយរវាងអាស៊ាន និងឥណ្ឌូចិន ស្តីពីបញ្ហាកម្ពុជា ឈរលើមូលដ្ឋានវៀតណាមដកកងទ័ព និងកំចាត់ ប៉ុល ពត។ ចិន បានបើកទូលាយឥទ្ធិពលរបស់ខ្លួននៅថៃ ក៏ ប៉ុន្តែ វាបានក្លាយទៅជាប្រភពគំរាមកំហែងសំរាប់ប្រទេសអាស៊ានផ្សេង ទៀត។ សិង្ហបូរី ជាអ្នកឡើងសម្លេងខ្លាំងបំផុតអំពីរបស់ដែលហៅថា "ដាក់ទណ្ឌកម្មសេដ្ឋកិច្ចចំពោះវៀតណាម និងកម្ពុជា" ប៉ុន្តែ ប្រទេស នេះបែរជាអ្នករកស៊ីច្រើនបំផុតជាមួយកម្ពុជា និងវៀតណាម រហូតដល់ ទំនិញថៃមកដល់កម្ពុជា និងវៀតណាម ឆ្លងតាមដៃសិង្ហបូរី ហើយ ទំនិញកម្ពុជា និងវៀតណាម ទៅដល់ប្រទេសថៃ ក៏ឆ្លងតាមដៃសិង្ហបូរី ដែលធ្វើអោយសិង្ហបូរីរកចំណេញបានយ៉ាងច្រើន។

ការឃុបឃិត ចិន-អាមេរិក ជាចិត្តសាស្ត្របានធ្វើអោយប្រទេស អា ស៊ាន ដែលខ្លាចចិន មានការព្រួយបារម្ភ។ អាស៊ាន ថែមទាំងព្រួយ បារម្ភចំពោះមុខការកែលំអទំនាក់ទំនងរវាងចិន និងសូវៀត បន្ទាប់ពី ប្រទេសទាំងពីរ បានចាប់ផ្តើមចរចាគ្នា ពីខែតុលា ១៩៨២ មក ដែលប្រការ សំខាន់ គឺខ្លាចការឈានដល់ការកែលំអទំនាក់ទំនងរវាងវៀតណាម-ចិន ដែលនាំដល់ភាពមិនអនុគ្រោះនៃតុល្យភាពកម្លាំងក្នុងដំបន់។

ថ្វីត្បិតតែមានការបែកខ្ញែកអំពីនយោបាយ និងចិត្តសាស្ត្រ ពិសេសការខុសគ្នាអំពីយុទ្ធសាស្ត្ររវាងឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងថៃ ជុំវិញឥទ្ធិពលចិន និងទំនាក់ទំនងជាមួយវៀតណាម ក៏ពួកគេបន្តបង្រួបបង្រួមក្នុងវណសិរ្សប្រឆាំងកម្ពុជា ដែលជាវណសិរ្សមានទំនាស់ផង និងឯកភាពផង ដូច្នេះហើយបានជានិន្នាការចរចាបានកើតឡើងមែន ការប្រឈមមុខក៏បានថយចុះមែន ប៉ុន្តែគឺស្ថិតក្នុងល្បឿនយ៉ាងយឺតៗ ចិន នៅតែជំរុញអោយថៃខិតខំដណ្តើមការត្រួតត្រានយោបាយអាស៊ាន ក្នុងបញ្ហាកម្ពុជា ហើយចិនជាបង្អែកថៃក្នុងបញ្ហានេះ។

ពួកសត្រូវនៃបដិវត្តន៍កម្ពុជា មិនទទួលស្គាល់មូលហេតុដែលនាំអោយកើតមានបញ្ហាកម្ពុជា ហើយក៏មិនទទួលស្គាល់ការពិត ដែលនាំអោយបាត់សន្តិភាព និងស្ថិរភាពនៅអាស៊ីអាគ្នេយ៍ដែរ។ ពេលនោះ មានការបកស្រាយខុសៗ គ្នាថា បញ្ហាកម្ពុជា ជាបញ្ហាផ្ទៃក្នុងកម្ពុជា ជាបញ្ហារវាងវៀតណាម និងកម្ពុជា ជាជម្លោះរវាងខាងកើត និងខាងលិច ជាបញ្ហាសូវៀត និងចិន ជាបញ្ហាវៀតណាម និងចិន ជាបញ្ហារវាង ឥណ្ឌូចិន និងចិន ជាបញ្ហារវាងឥណ្ឌូចិន និងអាស៊ាន។ ចំពោះការបាត់បង់សន្តិភាព និងស្ថិរភាពនៅអាស៊ីអាគ្នេយ៍វិញ គេលើកឡើងតែមូលហេតុបណ្តាលមកពីកងទ័ពវៀតណាមនៅកម្ពុជា ឬវត្តមានសូវៀតនៅអាស៊ីអាគ្នេយ៍តែប៉ុណ្ណោះ ពួកគេមិនបានលើកឡើងអំពីចរិតពិតប្រាកដ នៃរឿងហេតុនោះឡើយ។ គេមិនបានគិតថា ការបាត់បង់សន្តិភាព និងស្ថិរភាពនៅអាស៊ីអាគ្នេយ៍មានយូរមកហើយ ហើយកើតមកពីការជ្រៀតជ្រែក ឈ្លានពាន ពីសំណាក់ពួកចក្រពត្តិ អាណានិគមនិយម និងវាតទីនិយមក្រៅដំបន់ឡើយ ដូចជា បារាំង អង់គ្លេស ហុលឡង់ ជប៉ុន អាមេរិក ហើយបន្ទាប់មកទៀតគឺ ចិន

ដែលជាអ្នកបានបញ្ជូនសង្គ្រាមបង្ហូរឈាមចូលអាស៊ីអាគ្នេយ៍។ គេក៏មិនបានគិតថា អ្នករងគ្រោះពិតប្រាកដដោយសារសង្គ្រាមឈ្លានពានពីសំណាក់ប្រទេសក្រៅដំបន់ គឺជាប្រជាជនកម្ពុជា-វៀតណាម-ឡាវ ដែលចេញផុតពីសង្គ្រាមមួយដល់សង្គ្រាមមួយទៀត រហូតដល់ការប្រល័យពូជសាសន៍នៅកម្ពុជា ក្រោមការចាត់ចែង របស់ចិនឡើយ។ គេក៏មិនបានគិតថា ក្នុងការឈ្លានពានមកលើប្រទេសនៅឥណ្ឌូចិន តើប្រទេសក្រៅដំបន់ប្រើប្រាស់ប្រទេសណាខ្លះជាបង្អែក ដូចជាថៃ។ ថៃ ជាសម្ព័ន្ធមិត្តគួរអោយទុកចិត្តរបស់ជប៉ុន ក្នុងសង្គ្រាមលោកលើកទី ២ ជាមូលដ្ឋានរឹងមាំរបស់អាមេរិក ក្នុងការឈ្លានពានឥណ្ឌូចិន ហើយក៏ជាសម្ព័ន្ធមិត្តដ៏គួរអោយទុកចិត្តរបស់ចិន ក្នុងការធ្វើសង្គ្រាមប្រឆាំងកម្ពុជា វៀតណាម និងឡាវ "បើគ្មានថៃ ពួក ប៉ុល ពត មិនអាចរស់បានទេ"។ ហើយគេក៏មិនបានគិតដល់ការអនុវត្តន៍នយោបាយបំបែកបំបាក់ ដើម្បីត្រួតត្រារបស់ពួកចក្រពត្តិ អាណានិគមនិយមវាតទីនិយម ចំពោះប្រជាជាតិនៅអាស៊ីអាគ្នេយ៍ផងទេ។ គេថែមទាំងបំភ្លេចនូវអស្ថិរភាពដែលបណ្តាលមកពីកត្តាផ្ទៃក្នុងរបស់គេ រដ្ឋប្រហារជាបន្តបន្ទាប់នៅថៃ និងវិបត្តិផ្ទៃក្នុងនៅហ្វីលីពីន និងប្រទេសមួយចំនួនទៀត វាពិតជាមិនចេញមកពីវត្តមានកងទ័ពវៀតណាម នៅកម្ពុជានោះឡើយ។

ចុងឆ្នាំ ១៩៨៤ និន្នាការចរចាបានកើតមានឡើងនៅក្នុងចំណោមប្រទេសប៉ែកខាងលិច ពិសេសបារាំង។ គេចង់អោយមានការជួបប្រាស្រ័យដោយស្ទាត់ស្នៀមរវាងសម្តេច សីហនុ ជាមួយតំណាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា។ បារាំងជាអ្នករៀបចំអោយមានការជួបគ្នានេះនៅប៉ារីស ដែលមានគំរោងធ្វើនៅខែវិច្ឆិកា ១៩៨៤។ ប៉ុន្តែ

អាស្រ័យដោយមានការគាបសង្កត់យ៉ាងខ្លាំងពីសំណាក់ចិន និងខ្មែរក្រហមទៅលើសម្ដេច សីហនុ ទើបការជួបនេះមិនអាចធ្វើទៅបាន។

ឆ្នាំ ១៩៨៥ សភាពការណ៍សកលលោកមានការវិវត្តន៍អនុគ្រោះអោយនិន្នាការចរចាឆ្ពោះទៅរកការធូរស្រាល បញ្ចប់ដំណាក់កាលតានតឹងបំផុត ដែលអូសបន្លាយកន្ទងមកអស់រយៈពេល ៧ ឆ្នាំ (១៩៧៨-១៩៨៤)។ ឆ្នាំ ១៩៨៥ បានកត់សម្គាល់នូវការរីកចំរើនថ្មីក្នុងទំនាក់ទំនងរវាងសូវៀត-អាមេរិក-ចិន។ ក្រោយរយៈពេលដ៏វែងនៃនយោបាយវាយបកយ៉ាងប្ដូរផ្ដាច់ប្រឆាំងចរន្តបដិវត្តទាំងបី និងតាមរយៈនៃការរត់ប្រណាំងសព្វាវុធដ៏ខ្លាំងក្លា អាមេរិកក៏មិនអាចជួយអោយខ្លួនដណ្ដើមបានមកវិញនូវឧត្ដមភាពខាងយោធា ដែលអាមេរិកបានបាត់បង់តាំងពីពេលជាប់ផុងនៅវៀតណាមនោះដែរ។ ក្នុងពេលនោះ អាមេរិកកាន់តែមិនអាចទប់ទល់នឹងបដិវត្តន៍ ដែលរីកចំរើនយ៉ាងខ្លាំងក្លានៅមជ្ឈិមបូព៌ា និងអាហ្វ្រិកខាងត្បូង ជាពិសេសនៅអាមេរិកកណ្ដាល ការ៉ាអ៊ីប ទន្ទឹមនឹងពេលនោះដែរ របបដែលស្និទ្ធអាមេរិក នៅតំបន់មួយចំនួនត្រូវចុះខ្សោយ និងមានវិបត្តិ ដូចជានៅអាស៊ីអាគ្នេយ៍ ថៃត្រូវមានរដ្ឋប្រហារជាបន្តបន្ទាប់ ហ្វីលីពីនច្របូកច្របល់ សម្ព័ន្ធមិត្តអាមេរិកនៅអឺរ៉ុប និងជប៉ុន មិនព្រមដើរជាមួយអាមេរិក ក្នុងនយោបាយប្រឈមមុខជាមួយសហភាពសូវៀត ហើយបន្តនយោបាយរួមរស់ជាមួយសូវៀត ក្នុងយុទ្ធសាស្ត្ររួម នៃការធូរស្រាលរវាងខាងកើត និងខាងលិច។ នយោបាយបង្កភាពតានតឹងរត់ប្រណាំងសព្វាវុធរបស់អាមេរិក មិនបានជួយអោយអាមេរិកគាបសង្កត់សម្ព័ន្ធមិត្តបានទេ ផ្ទុយទៅវិញបានធ្វើអោយទំនាស់រវាងអាមេរិក និងសម្ព័ន្ធមិត្ត កាន់តែជ្រាលជ្រៅថែមទៀត។ ម្យ៉ាងទៀត ការដែលចិនបានកែលំអទំនាក់ទំនងជាមួយសូវៀត បន្ទាប់ពីការចរចា

*អស់រយៈពេល ៣ ឆ្នាំ (១៩៨២-១៩៨៥) ចិន ក៏មិនឃុបឃិតជាមួយអាមេរិក ប្រឆាំងសូវៀតដូចពីឆ្នាំ ១៩៧៥-១៩៨០ ទៀតដែរ ធ្វើអោយអាមេរិកមិនអាចដំណើរការនយោបាយបង្កភាពប្រឈមមុខជាមួយសូវៀត តែម្នាក់ឯងបានឡើយ។ ចាប់ពីចុងឆ្នាំ ១៩៨២ មក ទន្ទឹមនឹងការជំរុញទំនាក់ទំនងទ្វេភាគីជាមួយចិន អាមេរិកត្រូវបង្ខំចិត្តឈានចូលចរចាជាមួយសហភាពសូវៀតដែលចំណុចកំពូលគឺ ការជួបចរចាថ្នាក់កំពូលសូវៀត-អាមេរិក នៅទីក្រុង ហ្សឺណែវ នាចុងឆ្នាំ ១៩៨៥។ ការជួបប្រាស្រ័យថ្នាក់កំពូលសូវៀត-អាមេរិក នៅហ្សឺណែវ ថ្វីត្បិតតែពុំទាន់បានដោះស្រាយនូវបញ្ហាធំៗ ក៏មែនពិត ប៉ុន្តែវាមានអត្ថន័យយ៉ាងធំធេងចំពោះទំនាក់ទំនងរវាងប្រទេសទាំងពីរ និងជះឥទ្ធិពលដល់សភាពការណ៍លើសកលលោកទាំងមូលដែរ។ ការជួបប្រាស្រ័យនេះ បានបើកឡើងនូវដំណើរការចរចា និងការកែលំអទំនាក់ទំនងរវាងប្រទេសទាំងពីរ ក្រោយរយៈពេល ៧ ឆ្នាំ ដែលមានការតានតឹងបំផុត។ ការដែលភាគីទាំងពីរសន្យាមិនបង្កសង្គ្រាមនុយក្លេអ៊ែរ និងមិនដណ្តើមឧត្តមភាពខាងយោធា បានជួយរំងាប់នូវការព្រួយបារម្ភរបស់បណ្តាប្រទេស អំពីគ្រោះថ្នាក់នៃសង្គ្រាមនុយក្លេអ៊ែរ។*

*ចំពោះចិន ស្ថិតចំពោះមុខការកែលំអទំនាក់ទំនងរវាងសហភាពសូវៀត និងសហរដ្ឋអាមេរិក ចិនមានការព្រួយបារម្ភចំពោះការដែលសូវៀត-អាមេរិក ពង្រឹងភាពទ្វេប៉ូល ដោះស្រាយបណ្តាបញ្ហាលើសកលលោក ជាពិសេសបណ្តាបញ្ហានៅអាស៊ី ដោយគ្មានតួនាទីរបស់ចិន។ ដូច្នេះហើយ បានជាក្នុងពេលខិតខំអូសទាញទុន និងបច្ចេកទេសរបស់លោកខាងលិច ដើម្បីដំណើរការទំនើបកាវូបនីយកម្ម ៤ យ៉ាង ចិនក៏ត្រូវជំរុញជា*

មួយគ្នាដែរ នូវការកែលំអទំនាក់ទំនងជាមួយសហភាពសូវៀត និងបណ្ដាប្រទេសសង្គមនិយម ម្យ៉ាងគឺដើម្បីពង្រីក និងស្ដារឡើងវិញ នូវសំណង់ឧស្សាហកម្ម ដែលជាជំនួយរបស់ប្រទេសសង្គមនិយម ក្នុងពេលមុន តែម្យ៉ាងទៀត ក៏ដើម្បីធ្វើជាសន្ទឹកបៀតថ្លៃ ក្នុងទំនាក់ទំនងជាមួយអាមេរិកផងដែរ។ ចិន នៅតែឆ្លៀតប្រើប្រាស់ទំនាស់សូវៀត-អាមេរិក ដែលគេហៅថា សន្ទឹកបៀពីរដើម្បីសង្កត់គ្នា "ទៅជាមួយអាមេរិក ដើម្បីសង្កត់សូវៀត ទៅជាមួយសូវៀត ដើម្បីសង្កត់អាមេរិក"។

ចាប់ពីចំណុចដែលចិនឃុបឃិតជាមួយអាមេរិក ប្រឆាំងសូវៀត មកដល់ចំណុចទាំងអាមេរិក ទាំងចិន កែលំអទំនាក់ទំនងជាមួយសូវៀត គឺជាជោគជ័យនៃមាគ៌ាសន្តិភាពរបស់សហភាពសូវៀត ហើយក៏ជាជោគជ័យនៃចលនាតស៊ូ ដើម្បីការធូរស្រាល និងសន្តិភាពផងដែរ។ វាក៏មានឥទ្ធិពលយ៉ាងជ្រាលជ្រៅ ចំពោះសភាពការណ៍អន្តរជាតិ ដែលធ្វើអោយនិន្នាការដោះស្រាយវិវាទ ដោយឆ្លងតាមរយៈនៃការចរចា រីកចំរើននៅគ្រប់ទីកន្លែង ដែលមានជម្លោះ។

ឆ្នាំ ១៩៨៩ នៅអាស៊ីអាគ្នេយ៍ ក៏បានបើកឡើងនូវទិដ្ឋភាពថ្មី ដែលអនុគ្រោះអោយនយោបាយចរចា ហើយរុញច្រានអោយថយក្រោយនូវនយោបាយប្រឈមមុខដាក់គ្នា។ ជ័យជំនះដ៏ធំធេងក្នុងរដូវប្រាំងឆ្នាំ ១៩៨៤-១៩៨៥ បានកំណត់ផ្លូវបត់មួយក្នុងសភាពការណ៍យោធានៅកម្ពុជា ហើយក៏ជាដំណាក់កាលបញ្ចប់ស្ថានភាព ដំបន់ត្រួតពិនិត្យពីរ និងរដ្ឋាភិបាលពីរនៅកម្ពុជា និងជាដំណាក់កាលនៃជំហានថយក្រោយផ្នែកយុទ្ធសាស្ត្ររបស់ពួក ប៉ុល ពត និងកម្លាំងប្រឆាំង។ ជោគជ័យដ៏ធំធេងនៃមហាសន្និបាតបក្សប្រជាជនបដិវត្តកម្ពុជាលើកទី ៥ បន្ទាប់ពី ៦

ឆ្នាំនៃការកសាងឡើងវិញ រួមនឹងជ័យជំនះលើគ្រប់វិស័យ យោធា នយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច បានបង្ហាញអោយឃើញនូវការរីកធំធាត់របស់បដិវត្តន៍កម្ពុជា លើមាគ៌ាឆ្ពោះទៅរកភាពម្ចាស់ការក្នុងកិច្ចការពារ និងកសាងប្រទេស។ ការបំពេញរយៈពេលក្នុងការដកកងទ័ពវៀតណាមមកនៅត្រឹម ៥ ឆ្នាំ គឺដកទាំងស្រុង ក្នុងឆ្នាំ ១៩៩០ ចំពេលដែលចិន មិនអាចអនុវត្តបាននូវមេរៀនទី ២ ប្រឆាំងវៀតណាម ដើម្បីសង្គ្រោះពួកបរិវារ គឺបានដាក់ចេញនូវលទ្ធភាពពីរ ក្នុងការដោះស្រាយបញ្ហាកម្ពុជា គឺ លទ្ធភាព "មាន ឬគ្មានដំណោះស្រាយនយោបាយ" មានន័យថា ប្រសិនបើមិនអាចរកឃើញនូវដំណោះស្រាយនយោបាយមុនឆ្នាំ ១៩៩០ ទេ នោះបដិវត្តន៍កម្ពុជា ចេះតែបន្តរីកចំរើនធំធាត់ ហើយទទួលយកការកិច្ចការពារប្រទេសដោយខ្លួនឯង កងទ័ពស្ម័គ្រចិត្តវៀតណាម នឹងដកទាំងអស់នាឆ្នាំ ១៩៩០ ទោះបីពួក ប៉ុល ពត មិនទាន់ត្រូវបោសសំអាតអស់ទាំងស្រុងនៅឡើយក៏ដោយ ក៏បញ្ហាកម្ពុជា ត្រូវបានដោះស្រាយដោយខ្លួនឯង ដោយមិនចាំបាច់មានដំណោះស្រាយនយោបាយទៀតឡើយ ហើយបើមានការចរចាបន្ត ក៏គ្មានបញ្ហាកងទ័ពវៀតណាម លើកយកទៅដោះស្រាយទៀតឡើយ គឺមានតែបញ្ហាកំចាត់ចោលពួក ប៉ុល ពត និងការបញ្ឈប់ជំនួយពីខាងក្រៅអោយកម្លាំងខ្មែរបដិបក្ខប៉ុណ្ណោះ។ សភាពការណ៍នេះ បានដាក់អោយបដិវត្តន៍កម្ពុជា ក្តាប់បានយ៉ាងណែន នូវកត្តាជាមូលដ្ឋានបំផុតដើម្បីដោះស្រាយបញ្ហាកម្ពុជា។

ក្នុងពេលបដិវត្តន៍កម្ពុជាត្រូវបានពង្រឹង ហើយកាលបរិច្ឆេទដាក់លាក់មួយក្នុងការដកកងទ័ពវៀតណាមជាឯកតោភាគី ត្រូវបានដាក់ចេញនោះ

បណ្តាឧបករណ៍ដែលចិនប្រើប្រាស់សំរាប់ប្រឆាំងប្រទេស ទាំងបីនៅឥណ្ឌូចិន សុទ្ធតែត្រូវចុះខ្សោយ ហើយក៏មិនអាចធ្វើអោយសភាពការណ៍កម្ពុជាប្រែក្រឡាស់បានដែរ។ ពួក ប៉ុល ពត ត្រូវចុះខ្សោយ រដ្ឋាភិបាលចម្រុះត្រីភាគី កំពុងប្រឈមមុខនឹងគ្រោះថ្នាក់នៃការរលំរលាយ ថៃដែលជាឧបករណ៍របស់ចិន ប្រឆាំងបណ្តាប្រទេសនៅឥណ្ឌូចិន ត្រូវជួបនឹងវិបត្តិផ្ទៃក្នុង (រដ្ឋប្រហារមិនបានសំរេចឆ្នាំ ១៩៨៥) ហើយត្រូវឯកោក្នុងបណ្តាប្រទេសអាស៊ាន។ ក្នុងបណ្តាប្រទេសអាស៊ាន និន្នាការឈានចូលចរចា ដើម្បីបង្កើតឡើងនូវសន្តិភាព ស្ថិរភាព នៅអាស៊ីអាគ្នេយ៍ បានកើនឡើងជាងពេលណាៗ ទាំងអស់។ ការដែលចិនមិនអនុវត្តបាននូវមេរៀនទី ២ ប្រឆាំងវៀតណាម ក្នុងពេលដែលពួក ប៉ុល ពត ត្រូវវាយអោយបរាជ័យយ៉ាងដំណំ បង្ហាញអោយឃើញថា ចិន មិនអាចសង្គ្រោះឧបករណ៍ដ៏សំខាន់របស់ខ្លួននៅអាស៊ីអាគ្នេយ៍បានឡើយ ដូច្នេះ ចិនក៏មិនអាចក្លាយទៅជាបង្អែកគួរអោយទុកចិត្តរបស់ប្រទេស អាស៊ាន ក្នុងការប្រឆាំងឥណ្ឌូចិនដែរ។ ការប្រែប្រួលក្នុងយុទ្ធសាស្ត្ររបស់ចិន ដែលបានផ្លាស់ប្តូរពីការឃុបឃិតជាមួយអាមេរិកប្រឆាំងសូវៀត មកជាការកែលំអទំនាក់ទំនងជាមួយសូវៀតវិញ និងការដែលអាមេរិកកែលំអទំនាក់ទំនងជាមួយសូវៀត ព្រមទាំងការចរចាអាមេរិក-វៀតណាម អំពីជនជាតិអាមេរិកបាត់ខ្លួនក្នុងសង្គ្រាមវៀតណាម ក៏បានធ្វើអោយមានការព្រួយបារម្ភសំរាប់បណ្តាប្រទេសអាស៊ានផងដែរ។ ម្យ៉ាងទៀត ដោយមានការព្រួយបារម្ភពីឥទ្ធិពលរបស់ចិន និងដោយមានទំនាស់ជាមួយនយោបាយគាំពារនិយមផ្នែកសេដ្ឋកិច្ច របស់អាមេរិក និងជប៉ុន ដែលបានបង្កឡើងនូវការលំបាកក្នុងការលក់ដូរ ប្រទេសអាស៊ានជាច្រើន បានបើកទូលាយទំនាក់ទំនងខាងសេដ្ឋកិច្ច

ជាមួយសូវៀត និងបណ្តាប្រទេសសង្គមនិយម។ សភាពការណ៍នេះ បានបង្កើតឡើងនូវនិន្នាការរួមរស់ដោយសន្តិសហវិជ្ជមាន ក្នុងចំណោមបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍។ ឥណ្ឌូនេស៊ី និងប្រទេសមួយចំនួនទៀត សុទ្ធតែចង់បង្កើត អោយមានតុល្យភាពថ្មីរវាងបណ្តាប្រទេសធំនៅអាស៊ីអាគ្នេយ៍ កែលំអទំនាក់ទំនងជាមួយវៀតណាម ដើម្បីធ្វើជាមូលដ្ឋានសំរាប់ការបង្កើតតំបន់សន្តិភាព ស្ថិរភាព នៅអាស៊ីអាគ្នេយ៍ និងដោះស្រាយបញ្ហាកម្ពុជា។

ឆ្នាំ ១៩៨៥ បន្ទាប់ពីការចរចាទ្វេភាគី រវាងវៀតណាម ជាមួយប្រទេសអាស៊ាននីមួយៗ រវាងឡាវ ជាមួយប្រទេសអាស៊ាននីមួយៗ ការចរចារវាងវៀតណាម ដែលជាតំណាងអោយក្រុមប្រទេសឥណ្ឌូចិន និងឥណ្ឌូនេស៊ី ដែលតំណាងអោយប្រទេសអាស៊ានបានចាប់ផ្តើម ដែលជាដំណាក់កាលទី ១ ក្នុងការបញ្ចប់ដំណាក់កាលដែលថៃគ្រប់គ្រងនយោបាយអាស៊ាន ក្នុងបញ្ហាកម្ពុជា និងក្នុងទំនាក់ទំនងជាមួយបណ្តាប្រទេសឥណ្ឌូចិន បានបើកឡើងនូវដំណាក់កាលចរចា ឈានទៅរកសន្តិសហវិជ្ជមាន រវាងក្រុមប្រទេសទាំងពីរនៅអាស៊ីអាគ្នេយ៍។ អាស៊ីអាគ្នេយ៍ បានចូលដល់ដំណាក់កាលប្រឈមមុខផង និងចរចាផង ហើយការចរចាមាននិន្នាការវិវត្តរីកចំរើន ដោយបានទទួលនូវការលើកទឹកចិត្ត។ ឆ្នាំ ១៩៨៦ ការចរចារវាងវៀតណាម ឥណ្ឌូនេស៊ី ក្នុងកំរិត និងរូបភាពខុសៗ គ្នា បានបន្តទៅទៀត។ ក្នុងឆ្នាំនោះដែរ សហភាពសូវៀតបានដាក់ចេញនូវផែនការសន្តិភាពសំរាប់អាស៊ីប៉ាស៊ីហ្វិក តាមរយៈសេចក្តីថ្លែងការណ៍វ្ល៉ាឌីវ៉ូស្តុក (Vladivostock) របស់អគ្គលេខាគណៈកម្មាធិការមជ្ឈិម បក្សកុម្មុយនិស្តសហភាពសូវៀត មីខាអ៊ីល ហ្គ័របាឆេវ (Mikhail Gorbatchev) ថ្ងៃ ២៨ ខែ កក្កដា ១៩៨៦ ដែលជាការបង្កើនការយកចិត្តទុកដាក់ ចំពោះសន្តិសុខនៅដំបន់អាស៊ីប៉ា

ស៊ីហ្វិក បន្ទាប់ពីបានខិតខំដោះស្រាយនៅទ្វីបអឺរ៉ុប។ នេះជាកម្មវិធីសន្តិភាពគ្រប់ជ្រុងជ្រោយមួយ ដែលបង្កបរិយាកាសឈានទៅរកដំណោះស្រាយដើម្បីការធូរស្រាល ហើយជំរុញនិន្នាការចរចានៅអាស៊ីអាគ្នេយ៍ ដែលមានកំណើតរួចមកហើយ។

ក្នុងរយៈពេលនោះ មានលេចឡើងនូវគំនិតផ្តួចផ្តើមអោយមានការជួបគ្នាក្រៅផ្លូវការរវាងបក្សពួកខ្មែរដែលមានជម្លោះ និងប្រទេសមានការពាក់ព័ន្ធ ដែលគេអោយឈ្មោះថាជប់លៀងស្រា "កុកតៃប៉ាទី" ដើម្បីលុបចោលនូវសំណាញ់ដែកស្តីពីបញ្ហាពិធីការ ឬការទទួលស្គាល់គ្នាលើការដាក់ស្ពែង ឬលើផ្លូវច្បាប់។ នៅឯប៉ារីស ប្រទេសបារាំង ស៊ីសុវត្ថិ កូមីកូ និងមនុស្សមួយចំនួនទៀត ដែលយកនាមថាជាតំណាងអោយសម្តេច សីហនុ បានខិតខំធ្វើការទាក់ទងជាមួយសមាគមស្នេហាជាតិរបស់អាណិកជនខ្មែរនៅបារាំង ដើម្បីស្ទាបស្ទង់មតិរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា អំពីលទ្ធភាពនៃការជួបប្រជុំក្រៅផ្លូវការដែលគេផ្តើមគំនិតថាអាចធ្វើនៅប្រទេសបារាំង ឬអូទ្រីស្ត។

រាល់ការផ្តើមគំនិត អោយមានការជួបគ្នា សុទ្ធតែត្រូវចិន និងខ្មែរក្រហមបំផ្លាញ។ ពួកគេចង់អោយមានការចរចាផ្ទាល់រវាងរដ្ឋាភិបាលត្រីភាគី ជាមួយវៀតណាម ហើយដាក់លក្ខខណ្ឌអោយកងទ័ពវៀតណាមដកចេញសិន ទើបចាប់ផ្តើមចរចា និងដោះស្រាយបញ្ហាកម្ពុជា តាមសេចក្តីសំរេចចិត្តរបស់អង្គការសហប្រជាជាតិ។

ឆ្នាំ ១៩៨៧ សភាពការណ៍មានការវិវត្តន៍យ៉ាងឆាប់រហ័ស។ មូលហេតុសំខាន់គឺ ចេញមកពីការពង្រឹងខ្លួននៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា រយៈពេលដកកងទ័ពវៀតណាមទាំងអស់ពីកម្ពុជានៅមិន

ឆ្ងាយ បញ្ហាកម្ពុជា អាចនឹងត្រូវដោះស្រាយដោយខ្លួនឯង រដ្ឋាភិបាលចម្រុះត្រីភាគី ត្រូវបែកបាក់យ៉ាងធ្ងន់ធ្ងរ។ សភាពការណ៍រួមនៅលើសកលលោក ក៏ដូចជានៅអាស៊ីអាគ្នេយ៍ កំពុងមានការប្រែប្រួលយ៉ាងសំខាន់។ និន្នាការតស៊ូ ក្នុងសន្តិសហវិជ្ជមាន និងដោះស្រាយការវិវាទតាមការចរចា កំពុងមានការវិវត្តន៍រីកចំរើនយ៉ាងខ្លាំង ពិសេសលេចធ្លោឡើង គឺការស្រុះស្រួលអំពីការបំបាត់ចោលកាំជ្រួចមីស៊ីលរយៈមធ្យម និងការជួបគ្នាជាកំពូលរវាងសូវៀត-អាមេរិក។ សកម្មភាពនយោបាយការទូតដ៏មមាញឹករបស់កម្ពុជា វៀតណាម ឡាវ សូវៀត ឥណ្ឌូនេស៊ី និងរបស់សម្តេច សីហនុ បានបង្កឡើងនូវលទ្ធភាពទម្លាយភាពទាល់ច្រកក្នុងការដោះស្រាយបញ្ហាកម្ពុជា និងអាស៊ីអាគ្នេយ៍។ នៅថៃ ក្រោយពីការឡើងកាន់តំណែងជាអគ្គបញ្ជាការរបស់ឧត្តមសេនិយឯក ឆាវ៉ាលីត យ៉ុងឆៃយុត ជាមួយនឹងការប្រកាសរបស់ឧត្តមសេនិយរូបនេះ ដែលចាត់ទុកបញ្ហាកម្ពុជា ជាកិច្ចការផ្ទៃក្នុងកម្ពុជា និងការបន្ថយភាពតានតឹងនៅព្រំដែន តាមរយៈនៃការបន្ថយកម្លាំងយោធាថៃនៅព្រំដែនថៃ-កម្ពុជា ក៏បានជះឥទ្ធិពលជាផ្នែកនយោបាយ និងចិត្តសាស្ត្រដល់ភាគីពាក់ព័ន្ធក្នុងជម្លោះនៅកម្ពុជា។

វិបត្តិការណ៍ពាក់កណ្តាល តាមរយៈនៃការលាលែងចេញពីតំណែងប្រធានកម្ពុជាប្រជាធិបតេយ្យចំនួន ៥០ ភាគរយរបស់សម្តេច សីហនុ មិនមែនគ្រាន់តែបង្ហាញពីភាពបែកបាក់នៃត្រីភាគី ដែលបណ្តាលពីការវាយប្រហាររបស់កងទ័ព ប៉ុល ពត ទៅលើកងទ័ពដែលមានស្មោះត្រង់ចំពោះគាត់ប៉ុណ្ណោះទេ តែនេះគឺជាចំណុចចាប់ផ្តើមនៃការស្វែងរកច្រកចេញ តាមច្រកមួយផ្សេងទៀត ក្រៅពីច្រកនៃនយោបាយត្រីភាគី ចិន

និងអាស៊ាន។

ចាប់ពីថ្ងៃប្រកាសលាចេញពីតំណែង នាថ្ងៃ ០៧ ឧសភា ១៩៨៧ សម្ដេច សីហនុ បានសំដែងចេញនូវគោលជំហរឯករាជ្យ ថ្មីត្បិតតែ ចិន ថៃ ប៉ុល ពត និង សឺន សាន ជំទាស់។ តាមរយៈអាជ្ញាកណ្ដាលឈ្មោះ លោក សាហ្វារីនី (*Sapharini*) ជាអគ្គរដ្ឋទូតអង្គការរំដោះប៉ាឡេស្ទីន ប្រចាំប្រទេសកូរ៉េខាងជើង ការព្រមព្រៀងមួយអំពីការជួបគ្នារវាង ហ៊ុន សែន និងសម្ដេច សីហនុ នឹងប្រុងធ្វើនៅចន្លោះខែ មិថុនា និងកក្កដា ១៩៨៧ នៅព្យុងយ៉ាង រដ្ឋធានីប្រទេសកូរ៉េខាងជើង ប៉ុន្ដែ ត្រូវអាក់ខាន ទៅវិញ ដោយសារឥទ្ធិពលនៃការបំផ្លាញ ដែលសម្ដេច សីហនុ បកស្រាយថា ខ្លាចឥទ្ធិពលអាក្រក់ដល់ការបោះឆ្នោតនៅអង្គការសហប្រជាជាតិ ដែលធ្វើអោយមនុស្សក្នុងភាគីគាត់ និងឪពុកធម៌របស់កម្ពុជាប្រជាធិបតេយ្យ គេនឹងថ្កោលទោស ហើយទម្លាក់ការទទួលខុសត្រូវមកលើគាត់ ចំពោះការបាត់បង់នូវភាពអនុគ្រោះក្នុងការបោះឆ្នោត អំពីសេចក្ដីសំរេចចិត្តស្ដីពី បញ្ហាកម្ពុជា។ ដូច្នេះ គាត់សុំលើកការជួបទៅក្រោយមហាសន្និបាតអង្គការសហប្រជាជាតិវិញ។

នយោបាយបង្រួបបង្រួមជាតិ និងសំណើសន្តិភាពរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានដាក់ចេញនាខែ សីហា ១៩៨៧ និងខែ តុលា ១៩៨៧ បន្ទាប់ពីការសំរេចចិត្តធ្វើសកម្មភាពឆ្ពោះទៅរកការដោះស្រាយបញ្ហាកម្ពុជាតាមផ្លូវនយោបាយ បានក្លាយជាចំណុចស្របគ្នារវាងយើង ជាមួយសម្ដេច សីហនុ ដែលបានប្ដេជ្ញាស្ថិតក្រៅនយោបាយ ចិន អាស៊ាន និងត្រីភាគី ក្នុងបញ្ហាកម្ពុជា។

ថ្ងៃ ២៩ កក្កដា ១៩៨៧ ក្នុងទស្សនកិច្ចផ្លូវការរបស់បណ្ឌិត ម៉ុកតា គូ

ស៊ូម៉ាអាតម៉ាតហ្សា (*Mochtar Kusumaatmadsa*) រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី នៅវៀតណាម វៀតណាម និងឥណ្ឌូនេស៊ី បានព្រមព្រៀងគ្នាអំពីរូបមន្តនៃការជួបជុំក្រៅផ្លូវការ ដែលចែកចេញជាពីរដំណាក់កាលៈ ដំណាក់កាលទី ១ មានភាគីខ្មែរបដិបក្ខទាំងពីរជួបគ្នា ហើយដំណាក់កាលទី ២ មានបណ្តាភាគីខ្មែរ និងបណ្តាប្រទេសពាក់ព័ន្ធជួបគ្នា ដែលជាការជួបគ្នាគ្មានសញ្ញានយោបាយ។ បន្ទាប់ពីការព្រមព្រៀងរវាងវៀតណាម និងឥណ្ឌូនេស៊ី ដែលមានលក្ខណៈជាតំណាងអោយក្រុមប្រទេសទាំងពីរ ឥណ្ឌូចិន និងអាស៊ាន នោះមក ចិន និងថៃ បានខិតខំបំផ្លិចបំផ្លាញ។ ប៉ុន្មានថ្ងៃក្រោយគេបើកសន្និសីទវិសាមញ្ញមួយនៅទីក្រុងបាងកក ដើម្បីច្រានចោលនូវកិច្ចព្រមព្រៀងក្រុងហូជីមិញស្តីអំពីការជួបគ្នាក្រៅផ្លូវការ ដែលមានចំណែកមួយត្រូវប៉ះពាល់យ៉ាងខ្លាំងដល់កិត្តិយសឥណ្ឌូនេស៊ី ដែលបណ្តាប្រទេស អាស៊ាន បានចាត់អោយធ្វើជាតំណាង ក្នុងការស្វែងរកការព្រមព្រៀងជាមួយវៀតណាម។ អំពើនេះ បាននាំដល់ការប្តេជ្ញាកាន់តែខ្លស់របស់ឥណ្ឌូនេស៊ី ក្នុងការធ្វើសកម្មភាពឆ្ពោះទៅរកការចរចា ថ្វីត្បិតតែបណ្ឌិត ម៉ុកតា គូស៊ូម៉ាអាតម៉ាតហ្សាត្រូវបានជំនួសដោយ អាលី អាឡាតាស (*Ali Alatas*) ក្នុងតំណែងជារដ្ឋមន្ត្រីការបរទេសក៏ដោយ ហើយត្រូវធ្វើការតស៊ូផង និងសម្រុះសម្រួលជាមួយថៃ និងសិង្ហបូរីផង ក៏អ្នកដឹកនាំឥណ្ឌូនេស៊ី នៅតែឯកភាពគ្នាប្តេជ្ញាដើរឆ្ពោះតាមទិសដៅ ដែលគេបានប្រឹងប្រែងកន្លងមកដែរ។

ភាពទាល់ច្រកក្នុងការផ្តួចផ្តើមអោយមានការជួបគ្នា មិនបានធ្វើអោយសម្តេច សីហនុ ដែលបានប្តេជ្ញាស្ថិតនៅក្រៅនយោបាយ អាស៊ាន ចិន និងត្រីភាគី បោះបង់ចោលនូវការប៉ុនប៉ងជួបជាមួយតំណាងរដ្ឋាភិបាលសាធា

រណរដ្ឋប្រជាមានិតកម្ពុជាឡើយ។ ផ្ទុយទៅវិញ គឺបានក្លាយជារំសេវ បញ្ជូនមួយថែមទៀត សំរាប់សម្តេច សីហនុ ក្នុងការឈានទៅមុខខាង នយោបាយ តាមរយៈនៃការសំរេចធ្វើអោយមានការជួបគ្នារវាងគាត់ ជាមួយ ហ៊ុន សែន។ ថ្ងៃ ១៨ កក្កដា សម្តេច សីហនុ បានផ្ញើលិខិតមួយ ផ្ញើជូនឥស្សរជនខ្មែរ ៧ រូប នៅប្រទេសបារាំង មានលោក ញឹក ជូឡុង ឈុំ កុសល ហ៊ុយ កន្ធុល ឈាន វ៉ែម នង គីមនី ថុន អ៊ុក ឌួង សំអុល ដើម្បី ជួយរៀបចំអោយមានការប្រជុំនៃភាគីខ្មែរ ដែលមានជម្លោះជាមួយគ្នា។ បន្ទាប់មកថ្ងៃ ០៤ កញ្ញា ១៩៨៧ ឥស្សរជនទាំង ៧ រូប បានផ្ញើលិខិត មកជូន រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា សុំអំពាវនាវអោយ មានការជួបគ្នា។ ដើម្បីបង្ហាញពីភាពឯករាជ្យ និងដោយមានការលើក ទឹកចិត្តរបស់បារាំងផង សម្តេច សីហនុ បានសំរេចយកប្រទេសបារាំង ធ្វើជាកន្លែងជួបប្រជុំ។ ចំពោះភាគីយើងយល់ឃើញថាពេលវេលាបាន មកដល់ សំរាប់ការជួបគ្នាមួយរវាងយើងជាមួយ សម្តេច សីហនុ ហើយ ក៏បានកំណត់ថាប្រទេសបារាំង គឺកន្លែងដ៏សមស្របមួយសំរាប់ការជួប គ្នារបៀបនេះ។ អាស្រ័យដោយគ្មានតំណាងប្រចាំប្រទេសបារាំង យើង បានស្នើសុំជំនួយឧបត្ថម្ភពីគ្រួសារចិត្តធម៌បារាំងមួយ គឺ លោក ហ្គាឡា ប្រ៊ុយ (*Galabru*) និងភរិយា របស់គាត់ ដែលមានដើមកំណើតជាខ្មែរ ហើយជាកូនលោកស្រី ប៉ុង ប៉េងចេង អតីតរដ្ឋមន្ត្រីក្រសួងសុខាភិបាល ជំនាន់រាជាណាចក្រកម្ពុជា។ លោកហ្គាឡាប្រ៊ុយ ជាអតីតឯកអគ្គរដ្ឋទូត បារាំងប្រចាំប្រទេសអង់ហ្គោឡា បន្ទាប់មកគាត់ធ្វើការនៅក្រុមប្រឹក្សារដ្ឋ បារាំង។ ក្នុងនាទីជា ទីប្រឹក្សាក្រុមប្រឹក្សារដ្ឋ គាត់បានមកធ្វើទស្សនកិច្ច នៅកម្ពុជា ក្នុងឆ្នាំ ១៩៨៧។ ជាមនុស្សម្នាក់ដែលស្រឡាញ់ការពិត និង

យុត្តិធម៌ គាត់ចង់អោយខ្មែរបញ្ចប់នូវជម្លោះ និងមានការបង្រួបបង្រួមជាតិ។ គាត់ និងភរិយាបានទទួលយកនូវសំណើដោយរីករាយ ក្នុងការជួយបញ្ជូនពាក្យពីភាគីសាធារណរដ្ឋប្រជាមានិតកម្ពុជាទៅភាគីសម្តេច សីហនុ និងត្រឡប់មកវិញ ព្រមទាំងជួយឧបត្ថម្ភលើបញ្ហាផ្សេងទៀតដែលទាក់ទងដល់ការចរចា។

គួររំលឹកថា ថ្វីត្បិតតែយើងបានទទួលនូវការជួយឧបត្ថម្ភដោយ អស់ពីចិត្តពីថ្លើម នៃគ្រួសារចិត្តធម៌ ហ្គាឡាប្រុយ ហើយសម្តេច សីហនុ ក៏ទទួលស្គាល់លោក ហ្គាឡាប្រុយ និងភរិយាគាត់ ថាជាអ្នកជួយកិច្ចការនេះ ប៉ុន្តែយើងក៏នៅជួបការលំបាកច្រើន។ ការលំបាកមិនមែនមកពីសម្តេច សីហនុ ផ្ទាល់ទេ ប៉ុន្តែមានមនុស្សដែលធ្វើអោយលំបាក។ យើងនឹកស្មានថា សម្តេច សីហនុ ចេញផុតពីប្រទេសចិនហើយ ចិន មិនអាចបំផ្លាញបាន ប៉ុន្តែ មិនមែនដូច្នេះឡើយ ភ្នាក់ងារចិន តាមបំផ្លាញគ្រប់ជំហាន។ យើងត្រូវប្រើប្រាស់ពេលវេលាយ៉ាងច្រើន ដើម្បីសម្រុះសម្រួលអំពីពេលវេលា និងទីកន្លែងនៃការជួបគ្នា។ លិខិតដែលយើងបានផ្ញើទៅ សម្តេច សីហនុ ហើយដែលទៅដល់ទីក្រុងប៉ារីស មុនពេលសម្តេចចេញពីព្យុង្គយ៉ាង ទៅប៉ារីសផងនោះ មិនបានទៅដល់សម្តេចទេ។ "ពួកអ្នកហែហម និងកងរក្សាព្រះអង្គ" គេបង្កើតលក្ខខណ្ឌច្រើនបែបច្រើនយ៉ាង រហូតហ៊ានសំរេចនូវកិច្ចការជំនួសសម្តេច។ នៅភ្នំពេញ យើងបានរិះរកមធ្យោបាយ ដើម្បីអោយពាក្យពេចន៍ពិតប្រាកដរបស់យើងបានទៅដល់សម្តេច សីហនុ យើងបានជ្រើសរើសផ្លូវភ្នំពេញ-បាងកក-ប៉ារីស វិញ។ នៅបាងកក មានព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ជាកូនប្រុសរបស់ សម្តេច សីហនុ នៅប្រចាំការទីនោះ ដែលយើងបានដឹងតាំងពីមុនមកថា ជា

មនុស្សម្នាក់ចង់ចរចាដោះស្រាយបញ្ហាកម្ពុជាតាមផ្លូវនយោបាយ។ យើងសំរេចវាយទូរលេខទៅសម្តេច សីហនុ តាមអាស័យដ្ឋាន រណឫទ្ធិ នៅបាងកក។ ក្រោយបានទទួលទូរលេខហើយ គាប់ជួន ត្រូវចេញដំណើរទៅបង្រៀននៅសាលាច្បាប់នៅប្រទេសបារាំងផង រណឫទ្ធិ បាននាំទូរលេខនេះទៅថ្វាយសម្តេច សីហនុ ផ្ទាល់តែម្តង ដោយមិនឆ្លងកាត់កងរក្សាព្រះអង្គនៅប្រទេសបារាំងឡើយ។ ប៉ុន្មានម៉ោងក្រោយមក សារទូរលេខមួយពីសម្តេច សីហនុ ផ្ញើមក ហ៊ុន សែន ថ្លែងអំណរគុណ ហើយបញ្ជាក់ពីការយល់ព្រមជួបគ្នា ដោយទុកលទ្ធភាពអោយភាគីយើងជាអ្នកកំណត់ថ្ងៃខែជួបគ្នា។ ខ្លឹមសារនៃលិខិតដែលផ្ញើតាមផ្លូវប៉ារីស តាមអ្នកហែហមសម្តេច និងខ្លឹមសារសារទូរលេខដែលផ្ញើតាម រណឫទ្ធិ នៅក្រុងបាងកក មានន័យដូចគ្នា ប៉ុន្តែចម្លើយបានមកវិញខុសគ្នា។ យើងបានដឹងច្បាស់ថា លិខិតទៅមិនដល់គោលដៅ។ ភាគីយើងបានសំរេចយកថ្ងៃ ០២ ធ្នូ ១៩៨៧ ធ្វើជាថ្ងៃជួបលើកទី ១ រវាងយើងជាមួយ សម្តេច សីហនុ នោះក៏ជាថ្ងៃកំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាលើកទី ៩ ហើយក៏ជាថ្ងៃដែលបដិវត្តន៍កម្ពុជា ចាប់ផ្តើមផ្ទេរដំណាក់កាលដែរ។ ថ្វីត្បិតតែបានកំណត់គ្នារួចស្រេចអំពីពេលវេលា និងទីកន្លែង ប៉ុន្តែពួកអ្នក "បំផ្លាញ" នៅតែធ្វើសកម្មភាពបន្ត។ គេបង្កើតឡើងនូវការមួលបង្កាច់ដើម្បីរារាំងការចូលរួមចរចាពីសំណាក់សមាជិកប្រតិភូយើងខ្លះ រហូតដល់គេបំផ្លោងពាក្យអំពី "ពិធីការដ៏ចម្លែក" សំរាប់ការចរចាររវាងមេដឹកនាំនៃបក្សនយោបាយទាំងពីរដែលកំពុងប្រឆាំងគ្នា។ សម្តេច សីហនុ មិនបានគិតគូរអំពីបញ្ហាពិធីការមានទាបមានខ្ពស់ឡើយ។ អ្វីដែលគាត់គិតគឺខ្លឹមសារការងារសំរាប់ដោះស្រាយបញ្ហា ប៉ុន្តែ ក្រុមអ្នកហែហមគាត់

បែរជាលើកឡើងអំពីអ្វីដែលសារពត៌មានបរទេស លើកមកផ្សាយគួរអោយអស់សំណើចថា "ហ៊ុន សែន ត្រូវចាត់ទុកខ្លួនជាពស្ត្រសាមញ្ញមួយរូបទៅគាល់ស្តេចមួយអង្គ"។ ប្រហែល ជាពួកគេចង់រៀបចំដូចក្នុងប្រាសាទទេវានិទិច្ច័យទេដឹង? ពួកគេភ្លេចគិតថា ដល់សាច់រឿងពិតប្រាកដ ដែលត្រូវតែមានតួឯក គេភ្លេចគិតថា បក្សនយោបាយទាំងពីរកំពុងមានជម្លោះគ្នានៅឡើយ ការប្រើប្រាស់ ពាក្យថា "ទៅសួរសុខទុក្ខ" គ្រាន់តែជាការកាត់សំណាញ់ដែក ដើម្បីទម្លាយភាពទាល់ច្រកអំពីពិធីការតែប៉ុណ្ណោះ ឯពេលសន្ទនា បើសិនមួយចាំតែនិយាយណែនាំ មួយទៀតចាំតែបាទ គឺមិនមែនជាការសន្ទនា នៃកម្លាំងប្រឆាំងគ្នាឡើយ ដូច្នេះខ្លឹមសារពិតប្រាកដនៃការជួបគ្នា គឺ "ស្មើភាព"។ សំរាប់យើងមិនមែនទាមទារស្មើភាពរហូតដល់មិនស្គាល់ចាស់ទុំនោះទេ យើងគោរពចាស់ទុំ តែយើងរក្សាសិទ្ធិ ក្នុងការសន្ទនា ខាងនយោបាយ។ ក្រៅពីពួកហែហមសម្តេចបំផ្លាញនៅខាងក្នុង ពួកខ្មែរក្រហម និងក្រុម សឺន សាន ក៏បានខិតខំបំផ្លាញពីខាងក្រៅខ្លាំងណាស់ដែរ។ ពួកគេខិតខំសរសេរលិខិតទៅថ្វាយសម្តេច សីហនុ រហូតមានក្លែងបន្ទំថា ជាលិខិតចេញពីនិស្សិតសកលវិទ្យាល័យភ្នំពេញ (មុនពេលសកលវិទ្យាល័យភ្នំពេញបង្កើត) ដើម្បីជំទាស់នឹងការដែលសម្តេច សីហនុ ជួបជាមួយតំណាងរដ្ឋាភិបាលភ្នំពេញ។ ជារូបភាពខាងក្រៅ មេខ្មែរក្រហមស្ថិតក្នុងសភាពស្ងាត់ស្ងៀម តែខាងក្នុងគឺឃោសនាប្រឆាំងជាមួយ សីហនុ ព្រមទាំងមានការប៉ុនប៉ងធ្វើឃាត រណប្ញទ្ធិ ហើយទម្លាក់កំហុសអោយរដ្ឋាភិបាលភ្នំពេញ និងវៀតណាមដើម្បីបំផ្លាញការចរចា។ សឺន សាន បានប្រឹងធ្វើសកម្មភាពយកចំណេញ។ មុនពេលចរចា សឺន សាន បានទៅជួបជាមួយសម្តេច សីហនុ ដើម្បីផ្ញើយោបល់អំពី

បញ្ហាត្រូវលើកពិភាក្សា។ អាស្រ័យដោយ គាត់ជាចំណាប់ខ្មាំងរបស់ចិន និងខ្មែរក្រហម អំពីជំនួយសំរាប់ផ្ទាល់ខ្លួនគាត់ និងជាចំណាប់ខ្មាំងរបស់ក្រុម សាក់ ស៊ុតសាខន សឺន សាន ធ្វើសកម្មភាពក្នុងទិសដៅ "រួចខ្លួន ឬចំណេញ" គឺថា បើការចរចា ហ៊ុន សែន-សីហនុ ត្រូវបរាជ័យ សឺន សាន រួចខ្លួនគ្មានខាតបង់អ្វីទាំងអស់ តែបើសំរេចផលវិញ សឺន សាន ក៏បានកំរៃខ្លះដែរ គាត់មុខតែលោតចូលក្នុងដំណោះស្រាយដែល ហ៊ុន សែន-សីហនុ បានរកឃើញនេះ។ ក្នុងសភាពការណ៍នេះ ពួកខ្មែរក្រហម បានយកសកម្មភាព សឺន សាន ធ្វើជាការឃោសនា ដើម្បីបិទបាំងនូវមតិផ្ទាល់របស់ពួកគេ ហើយដែលក្នុងរយៈពេលជិត ៩ ឆ្នាំ វិទ្យុខ្មែរក្រហមមិនដែលបានលើកពីសំដី សឺន សាន ទៅធ្វើការឃោសនាសោះ។

ចំពោះចិន ការជួបគ្នានេះបានគំរាមកំហែងយ៉ាងខ្លាំងចំពោះផលប្រយោជន៍របស់ចិន។ ចិន មិនចង់អោយមានការជួបគ្នាឡើយ ប៉ុន្តែដោយរារាំងសម្តេច សីហនុ មិនបាន ចិនប្រកាសចំហរថា មិនជំទាស់នឹងការសំរេចរបស់សម្តេច សីហនុ ទេ ប៉ុន្តែខាងក្នុងគេខិតខំធ្វើអោយការជួបនេះ មិនបានទទួលលទ្ធផល។ ប្រការដែលធ្វើអោយចិនព្រួយបារម្ភបំផុត គឺខ្លាចបញ្ហាកម្ពុជាត្រូវបានដោះស្រាយដោយភាគីកម្ពុជាទាំងពីរ ហើយបញ្ហាកម្ពុជា ត្រូវរបូតចេញផុតពីដៃរបស់ចិន។

ចំពោះបណ្តាប្រទេសអាស៊ាន សំខាន់ថៃ និងឥណ្ឌូនេស៊ី មានផលប្រយោជន៍ខុសគ្នាអំពីការជួបគ្នានេះ។ ការព្រួយបារម្ភរបស់ថៃ ប្រហាក់ប្រហែលនឹងចិនដែរ គេព្រួយហើយក៏ភ័យខ្លាចចំពោះការបាត់បង់ផលប្រយោជន៍ ប្រសិនជា សីហនុ និងសាធារណរដ្ឋប្រជាមានិតកម្ពុជា រក

ឃើញដំណោះស្រាយមួយ លើមូលដ្ឋានភាគីទាំងពីរសហការជាមួយគ្នា។

ផលប្រយោជន៍ធំបំផុតរបស់ឥណ្ឌូនេស៊ី គឺដោះស្រាយបញ្ហាកម្ពុជាអោយបានឆាប់ ដែលក្នុងដំណោះស្រាយនេះ តួនាទីចិន និងខ្មែរក្រហមមានកំរិតតិច ដើម្បីឈានទៅដោះស្រាយបញ្ហាសន្តិភាព ស្ថិរភាព នៅក្នុងដំបន់។ ទន្ទឹមនឹងការអបអរសាទរចំពោះការជួបគ្នានេះ ឥណ្ឌូនេស៊ី ក៏មានការព្រួយបារម្ភខ្លាចការជួបគ្នានេះ ដោះស្រាយបានទូវបញ្ហាដែលមិននាំដល់ការប្រជុំក្រៅផ្លូវការនៅហ្សាការតា ហើយក៏ព្រួយបារម្ភខ្លាចការជួបគ្នានេះ មានការបែកបាក់កាន់តែធ្ងន់ធ្ងរ ធ្វើអោយលទ្ធភាពដោះស្រាយបញ្ហាកម្ពុជាកាន់តែទាល់ច្រក។

ចំពោះបណ្តាប្រទេសនៅអឺរ៉ុប អាមេរិក ភាគច្រើនគាំទ្រការជួបគ្នានេះ ប៉ុន្តែគេមានការព្រួយបារម្ភខ្លាចមានឥទ្ធិពលអាក្រក់ដល់ទំនាក់ទំនងរបស់គេជាមួយចិនក៏ដោយ។ នៅអឺរ៉ុប មានតែរ៉ូម៉ានី និងយូហ្គោស្លាវីទេ ដែលមិនសប្បាយចិត្តនឹងការជួបគ្នានៅប៉ារីស។ សម្តេច សីហនុ បានទិទៀនចំពោះប្រធានាធិបតី រ៉ូម៉ានី អំពីជំបូន្មានប្រធានាធិបតីរូបនេះ ចំពោះគាត់ ដែលថា "ម្តងអោយជួប ម្តងមិនអោយជួប"។

បន្ទាប់ពីឆ្លងកាត់នូវការលំបាកជាច្រើន ទាំងខាងភាគីយើង ទាំងខាងភាគីសម្តេច សីហនុ ថ្ងៃ ២ ធ្នូ ១៩៨៧ យើងបានសំរេចការជួបគ្នាមួយនៅ ហ្វែរអង់តាដឺន័រ (*Fere-En-Tardenois*) ខាងកើតទីក្រុងប៉ារីស នៃប្រទេសបារាំង ដែលបានប្រព្រឹត្តទៅអស់រយៈពេលបីថ្ងៃ ហើយមានចេញសេចក្តីប្រកាសរួមមួយ ដែលចុះហត្ថលេខាដោយ សីហនុ និង ហ៊ុន សែន នៅថ្ងៃ ៤ ធ្នូ ១៩៨៧។ នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយដែលភាគីខ្មែរមានជម្លោះជាមួយគ្នា បានជួបនិយាយគ្នា ដើម្បីស្វែងរក

ការបញ្ចប់ជម្លោះតាមផ្លូវនយោបាយ។ ពិតមែនតែនៅមានការខ្វែងគំនិតគ្នាជាច្រើនអំពីជំហានត្រូវដើរ និងការរៀបចំដោះស្រាយជាក់ស្តែង ប៉ុន្តែភាគីទាំងពីរបានឯកភាពគ្នាលើចំណុចមួយចំនួន ដែលជាមូលដ្ឋាន អោយការដោះស្រាយជាបន្តនូវបញ្ហាលំអិតជាក់ស្តែង។ សំខាន់យើងឯកភាពគ្នាថា បញ្ហាកម្ពុជាត្រូវដោះស្រាយតាមផ្លូវនយោបាយ ហើយបញ្ហាកម្ពុជា ជាកិច្ចការផ្ទៃក្នុងកម្ពុជា ដែលត្រូវដោះស្រាយដោយប្រជាជនកម្ពុជាខ្លួនឯង និងគ្មានការជ្រៀតជ្រែកពីបរទេស។

ការជួបគ្នានេះ បាននាំទៅដល់ការផ្ទេរដំណាក់កាលបដិវត្ត ពីដំណាក់កាលវាយគ្នាតែតាមផ្លូវយោធា មកកាន់ដំណាក់កាលវាយខាងយោធាផង និងចរចានយោបាយផង គឺ "ដំណាក់កាលវាយផងចរចាផង"។ បើយើងចាប់គិតពីថ្ងៃបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ២ ធ្នូ ១៩៧៨ មកទល់ថ្ងៃចរចាលើកដំបូង ២ ធ្នូ ១៩៨៧ គឺមានរយៈពេល ៩ ឆ្នាំគត់ ដែលបដិវត្តន៍កម្ពុជា បានផ្ទេរដំណាក់កាល។

ការចាប់ផ្តើមចរចា គឺជាដំណាក់កាលប្រែប្រួលនៃកម្លាំងសង្គត់ និងជាដំណាក់កាលនៃការចាប់ផ្តើមប្រែប្រួលនៃសម្ព័ន្ធភាពនៅកម្ពុជា និងអាស៊ីអាគ្នេយ៍។ ការប្រែប្រួលនៃកម្លាំងសង្គត់ គឺផ្ទេរពីការទាមទារអោយវៀតណាមដកកងទ័ពចេញពីកម្ពុជាជាឯកតោភាគី ទៅជាការទាមទារអោយពួកខ្មែរបដិបក្ខចូលកាន់តុចរចា ដើម្បីស្វែងរកដំណោះស្រាយនយោបាយ បង្កលក្ខណៈអោយកងទ័ពវៀតណាមដកចេញដាច់។ ៩ ថ្ងៃក្រោយពេលចុះហត្ថលេខាលើសេចក្តីប្រកាសរួម ហ្វែរអង់តាដឺន័រ ៤ ធ្នូ ១៩៨៧ ដែលក្នុងសេចក្តីប្រកាសរួមនោះ បាននិយាយដល់ការជួបគ្នាជាលើកទី ២ និងទី ៣ បន្តទៀត សម្តេច សីហនុ បានវាយទូរលេខ

មួយមក ហ៊ុន សែន សុំលុបចោលការប្រជុំទាំងពីរលើកនេះ។ ហេតុផលដែលគាត់លុបចោលការប្រជុំ តាមសំដីរបស់គាត់ ក្នុងពេលសន្ទនាជាមួយបណ្ដាអគ្គរដ្ឋទូតបណ្ដាប្រទេសអាស៊ាន នៅហ្វែរអង់តាជីន័រ ប្រទេសបារាំង ថ្ងៃ ១១ ធ្នូ ១៩៨៧ សម្ដេច សីហនុ បានទម្លាក់ការទទួលខុសត្រូវមកលើ ហ៊ុន សែន ដោយលើកឡើងថា ហ៊ុន សែន ត្រូវការ សឺន សាន និង ខៀវ សំផន ជាងត្រូវការ សីហនុ។ សុំរំលឹកថា ក្រោយពេលប្រជុំលើកទី ១ ខ្ញុំ (ហ៊ុន សែន) បានផ្ញើលិខិតមួយថ្លែងអំណរគុណចំពោះឥស្សរជនខ្មែរ ៧ រូប ដែលបានផ្ដើមគំនិតអោយមានការជួបគ្នា ហើយអំពាវនាវអោយឥស្សរជនទាំង ៧ រូបនេះ បន្តការប្រឹងប្រែងតទៅទៀត ហើយខិតខំអញ្ជើញភាគីខ្មែរផ្សេងៗ ទៀត ចូលរួមវេទិកាចរចា ហ៊ុន សែន-សីហនុ។ ភាគីខ្មែរផ្សេងទៀតមានន័យថា សឺន សាន ខៀវ សំផន ដែលសម្ដេច សីហនុ យល់ថា ហ៊ុន សែន ត្រូវការអ្នកទាំងពីរជាងត្រូវការគាត់។ គាត់បានដឹងខ្លឹមសារលិខិត ដែលយើងផ្ញើអោយឥស្សរជនខ្មែរទាំង ៧ រូប តាមរយៈ ញឹក ជូឡុង ដែលជាមនុស្សម្នាក់ក្នុងចំណោមឥស្សរជនខ្មែរ ៧ រូប ហើយដែលគាត់ជាអនុប្រធានទី ១ រណសិរ្ស ហ៊្វុនស៊ីនប៉ិច ផងដែរ។

ការប្រកាសលុបចោលនូវកិច្ចប្រជុំទាំងពីរលើករបស់សម្ដេច សីហនុ បានធ្វើអោយមានប្រតិកម្មពីរប្លែកពីគ្នា "សប្បាយ និងព្រួយ"។ ចិន ខ្មែរក្រហម និងសឺន សាន ហាក់ដូចជាសប្បាយរីករាយពីដំណឹងស្ដីពីការលុបចោលការប្រជុំ ដែលគេចាត់ទុកថា "ជាការបែកបាក់នៃគូស្វាម៉ីភរិយាថ្មី ដែលទើបរៀបការ" ហើយគេបានឆ្លៀតធ្វើអាជីវកម្មពីព្រឹត្តិការណ៍នេះ។ ចំពោះប្រទេសប៉ែកខាងលិច និងភាគច្រើននៃសមាជិកសមាគមអាស៊ាន

ដែលបានតាំងចិត្តគាំទ្រការជួប ហើយបានអបអរសាទរចំពោះលទ្ធផលនៃការជួបគ្នារួចទៅហើយនោះ បានសំដែងនូវការភ្ញាក់ផ្អើល និងសំដែងនូវការសោកស្តាយ។ សន្និសីទកំពូលនៃប្រទេសអាស៊ាន ថ្ងៃ ១៤-១៥ ធ្នូ ១៩៨៧ បានសំដែងនូវការអបអរសាទរចំពោះការជួបគ្នារវាង សីហនុ និងហ៊ុន សែន ហើយសំដែងនូវការសោកស្តាយចំពោះការដែល សីហនុ លុបចោលការប្រជុំ។ ស្តេចនៃប្រទេស ប្រុយណេ បានប្រៀបធៀបការជួបរវាង ហ៊ុន សែន និង សីហនុ ថាជាអំពូលភ្លើងដែលដាច់ទៅវិញ ធ្វើអោយងងឹតទូទាំងអាស៊ីអាគ្នេយ៍។ ពេលនោះ កម្លាំងសង្កត់បានបង្វែរពីការទាមទារអោយវៀតណាមដកកងទ័ព ទៅជាការទាមទារអោយ សម្តេច សីហនុ និងក្រុមខ្មែរផ្សេងទៀត ចូលកាន់តុចរចា។

ប៉ុន្មានថ្ងៃក្រោយ សម្តេច សីហនុ បានយល់ព្រមធ្វើការចរចាឡើងវិញ ហើយក៏បានដំណើរការចរចាវគ្គទី ២ នៅថ្ងៃ ២១ និង ២២ មករា ១៩៨៨ នៅប្រទេសបារាំងដដែល។ ការជួបគ្នាលើកនេះ មិនបានចេញនូវសេចក្តីប្រកាសរួមណាមួយឡើយ។ ភាគីនីមួយៗ ប្រកាសដោយឡែកអំពីលទ្ធផលនៃការចរចា។ ចំណុចសំខាន់នៃវគ្គចរចាលើកទី ២ គឺការលេចឡើងនូវលទ្ធភាពដំណោះស្រាយដោយឡែកមួយរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាមួយសម្តេច សីហនុ ដោយគ្មានការចូលរួមរបស់ សឺន សាន និងខ្មែរក្រហម។ បញ្ហានោះត្រូវបានសម្តេច សីហនុ ជាអ្នកលើកឡើងអំពីរូបមន្តរដ្ឋាភិបាលចម្រុះទ្វេភាគី ហើយដែលប្រការនេះបាននាំដល់ការខឹងសម្បារបស់ សឺន សាន និងខ្មែរក្រហម ដោយចាត់ទុកថាសម្តេច សីហនុ បានទាត់ក្រុមទាំងពីរចេញពីដំណោះស្រាយនយោបាយកម្ពុជា។ ការវាយលុករបស់ សឺន សាន ទៅលើសម្តេច សីហនុ បាន

នាំដល់ការប្រកាសលាលែងជាស្ថាពរ លើកទី ១ ពីតំណែងប្រធានកម្ពុជាប្រជាធិបតេយ្យរបស់សម្ដេច សីហនុ កាលពីថ្ងៃ ៣០ មករា ១៩៨៨ ដែលក្នុងសេចក្ដីប្រកាសលាលែងពីតំណែងរបស់គាត់ សម្ដេច សីហនុ បានប្រកាសប្រមូលផ្ដុំមុខព្រួញវាយទៅលើ សឺន សាន វិញ។

ក្នុងការលាឈប់របស់សម្ដេច សីហនុ គាត់ក៏បានលុបចោលនូវការជួបគ្នាលើកទី ៣ ដែលត្រូវធ្វើនៅព្យុងយ៉ាង ប្រទេសកូរ៉េខាងជើង ខែមេសា ១៩៨៨ លើកទី ៤ ខែវិច្ឆិកា ១៩៨៨ នៅប្រទេសបារាំង និងលើកទី ៥ នៅដើមឆ្នាំ ១៩៨៩ នៅ ញូវដែលី ប្រទេសឥណ្ឌាផងដែរ ដោយលើកការចរចានេះទៅឆ្នាំ ១៩៨៩ ឬ ១៩៩០ វិញ។

ការលុបចោលការប្រជុំរបស់សម្ដេច សីហនុ មិនបានបញ្ឈប់នូវការប្រឹងប្រែងរួមសំដៅអោយមានការចរចានោះទេ។ ការខិតខំដើម្បីសំរេចអោយមានការជួបគ្នាក្រៅផ្លូវការ តាមកិច្ចព្រមព្រៀងក្រុង ហូជីមិញ វិញ រវាង វៀតណាម និងឥណ្ឌូនេស៊ី បានចាប់ផ្ដើមសាជាថ្មី។ បន្ទាប់ពីការដកកងទ័ពវៀតណាម ចំនួន ២០.០០០ នាក់ នាខែ វិច្ឆិកា ១៩៨៧ និងការប្រកាសដកកងទ័ពវៀតណាម ក្នុង ៦ ខែចុងឆ្នាំ ១៩៨៨ ចំនួន ៥០.០០០ នាក់ បានក្លាយទៅជាកម្លាំងសង្កត់ខាងពេលវេលាចំពោះគូបដិបក្ខ និងប្រទេសដែលគាំទ្រកម្លាំងប្រឆាំង។ ពួកគេមានជំនឿថា កងទ័ពវៀតណាមដកពិតប្រាកដ ហើយនឹងដកអស់ឆ្នាំ ១៩៩០ មែន ដូច្នេះភាពចាំបាច់ដែលគេត្រូវគិត និងធ្វើសកម្មភាពនោះ គឺ ត្រូវស្វែងរកដំណោះស្រាយនយោបាយអោយបានមុនឆ្នាំ ១៩៩០ ដូចនេះ ត្រូវរៀបចំអោយមានការចរចា។ ឥណ្ឌូនេស៊ី ឈានមុខក្នុងការធ្វើអោយប្រទេសអាស៊ានមានការប្រែប្រួល។ ឥណ្ឌូនេស៊ី មានផលប្រយោជន៍

ដើម្បីជំរុញអោយមានការជួបគ្នា និងធ្វើអោយមានលទ្ធផល ដើម្បីពង្រីកតួនាទីរបស់ ឥណ្ឌូនេស៊ី នៅអាស៊ីអាគ្នេយ៍ និងចំពោះសន្និសីទកំពូលលើកទី ៩ ដែលឥណ្ឌូនេស៊ី កំពុងឈរឈ្មោះជាបេក្ខជនប្រធានសន្និសីទកំពូល។ ឥណ្ឌូនេស៊ី ពេញចិត្ត នឹងរៀបចំការប្រជុំក្រៅផ្លូវការ ដោយបានចាត់ទុកថា ជាគំនិតផ្តួចផ្តើមរបស់ឥណ្ឌូនេស៊ី និងអាស៊ាន ហើយត្រូវធ្វើនៅប្រទេសឥណ្ឌូនេស៊ីទៀតផង ប៉ុន្តែ ឥណ្ឌូនេស៊ី មិនបោះបង់ចោលនូវការសហការជាមួយវៀតណាម ដែលជាលក្ខខណ្ឌចាំបាច់ក្នុងការធ្វើអោយសំរេចការជួបគ្នានេះ។ ឥណ្ឌូនេស៊ី នៅតែបន្តអនុវត្តនូវកិច្ចព្រមព្រៀងក្រុង ហូជីមិញ អំពីរូបមន្តនៃការជួបគ្នា ដោយចែកជាពីរដំណាក់កាល ទោះបីមានការមិនចុះសម្រុងពីប្រទេសអាស៊ានខ្លះ ដែលចង់អោយការជួបនេះមានតែមួយដំណាក់កាល ដែលជាតុពិតគឺជាការបង្ខំអោយមានការជួបរវាងវៀតណាម ជាមួយបណ្តាភាគីខ្មែរ ប៉ុន្តែ ឥណ្ឌូនេស៊ី ក៏ចង់ប្រើប្រាស់វេទិកានេះ ដើម្បីពិភាក្សាបញ្ហាផ្ទៃក្នុងកម្ពុជាផងដែរ។

ថ្ងៃ ៨-៩ កក្កដា ១៩៨៨ សន្និសីទរដ្ឋមន្ត្រីការបរទេសអាស៊ាន បានចេញសេចក្តីប្រកាសមានលក្ខណៈអាក្រក់ អំពីការប្រជុំក្រៅផ្លូវការ និងអំពីបញ្ហាកម្ពុជា។ ឥណ្ឌូនេស៊ី ស្ថិតក្នុងការគាបសង្កត់នៃកម្លាំងប្រឈមមុខ តម្រូវអោយឥណ្ឌូនេស៊ី មាននយោបាយមុខពីរ គឺសម្រុះសម្រួលជាមួយវៀតណាម ដើម្បីរក្សាកិច្ចព្រមព្រៀងក្រុង ហូជីមិញ ផង និងសម្រុះសម្រួលជាមួយកម្លាំងប្រឈមមុខក្នុងអាស៊ាន និងចិន ផង ដើម្បីរក្សានូវការឯកភាព។

ថ្ងៃ ១១ កក្កដា ១៩៨៨ នៅភ្នំពេញមានសន្និសីទវិសាមញ្ញរវាងរដ្ឋមន្ត្រី

ការបរទេសកម្ពុជា-វៀតណាម-ឡាវ ធ្វើឡើងក្នុងបំណងបញ្ជាក់ឡើងវិញ អំពីជំហររបស់បណ្តាប្រទេសនៅឥណ្ឌូចិន ជុំវិញការប្រជុំក្រៅផ្លូវការនៅហ្សាការតា ដែលយើងបានបញ្ជាក់ច្បាស់ថា សាធារណរដ្ឋប្រជាមានិតកម្ពុជាចូលរួមនៅដំណាក់កាលទី ១ ឯវៀតណាម និងឡាវ ចូលរួមនៅដំណាក់កាលទី ២ ហើយតម្រូវអោយប្រទេសអាស៊ាន គោរពកិច្ចព្រមព្រៀងក្រុង ហូជីមិញ ដែលជាកិច្ចព្រមព្រៀងរវាងបណ្តាប្រទេសឥណ្ឌូចិន និងអាស៊ាន។ ថ្ងៃបន្ទាប់ អាឡាតាស់ រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី បានប្រកាសចំហកែតម្រូវគោលជំហរអាស៊ានថា នឹងធ្វើតាមរូបមន្តកិច្ចព្រមព្រៀងក្រុង ហូជីមិញ។ ឯផ្ទៃក្នុងវិញគេសំដែងនូវការសោកស្តាយដោយសេចក្តីថ្លែងការណ៍របស់ អាស៊ាន បានធ្វើអោយប្រទេសឥណ្ឌូចិនខឹងសម្បារ។ ការកែតម្រូវរបស់ឥណ្ឌូនេស៊ី ដែលជាប្រទេសត្រូវធ្វើម្ចាស់ផ្ទះ ជាលក្ខខណ្ឌចាំបាច់សំរាប់ការចូលរួមរបស់ប្រទេសទាំងបីនៅឥណ្ឌូចិន។

ចំពោះខ្មែរត្រីភាគី ក្រោយពីស្ទាក់ស្ទើរអស់មួយរយៈ នៅថ្ងៃ ២៩ មិថុនា ១៩៨៨ គេប្រកាសថា នឹងចូលរួមកិច្ចប្រជុំ ប៉ុន្តែទាមទារអោយវៀតណាមចរចាជាមួយ សីហនុ និងត្រីភាគី។ ពួកនេះក៏មិនចង់អោយមាន ដំណាក់កាលពីរ នៃការជួបជុំក្រៅផ្លូវការនេះដែរ។ សម្តេច សីហនុ មានអារម្មណ៍បែកខ្ញែក ថ្វីបើគាត់ក៏ជាអ្នកផ្តើមគំនិតម្នាក់ក្នុងការជួបជុំក្រៅផ្លូវការនេះ តែគាត់ហាក់ដូចជាមិនចង់ចូលរួម។ អាស្រ័យដោយគាត់បានប្រកាសលាលែងចេញពី តំណែងប្រធានកម្ពុជាប្រជាធិបតេយ្យត្រីភាគីផងនោះ គាត់បានសំរេចចិត្តទៅ ហ្សាការតា ក្នុងឋានៈជាអ្នកនៅខ្ពស់ជាងភាគីទាំង ៤ ដើម្បីទុកអោយភាគីកម្ពុជាតស៊ូជាមួយគ្នា ហើយ

*គាត់ទៅ ហ្សាការតា ក្នុងបំណងចរចាជាមួយវៀតណាម។ ក្រៅពីវេទិកា នៅហ្សាការតា សម្តេច សីហនុ ក៏នៅតែចង់អោយមានការជួបប្រាស្រ័យ ដែលឧបត្ថម្ភដោយមេដឹកនាំចលនាមិនចូលបក្សសម្ព័ន្ធ ដែលជាគំនិត ផ្តួចផ្តើមរបស់គាត់ដែរ ហើយក៏ចង់បន្តការចរចា ហ៊ុន សែន-សីហនុ នៅ ពេលណាមួយដែលឱកាសហុចអោយ។*

*សឺន សាន បានរួចចាកពីចំណាប់ខ្មាំងនៃការប្រឆាំងការចរចារបស់ ខ្មែរក្រហម ដែលគាត់នៅក្រៅការចរចារវាង ហ៊ុន សែន-សីហនុ អស់ មួយរយៈ។ ហ្សាការតា ជាឱកាសនៃសុធន្នៈរបស់ សឺន សាន គាត់បាន សំអាងហេតុផលថា វៀតណាម ចូលរួមដែរ ទើបគាត់ចូលរួម។*

*ខ្មែរក្រហមមិនអាចនៅស្ងៀមបាន ត្រូវសំរេចចិត្តធ្វើសកម្មភាព "លើ តុដើម្បីបំផ្លាញ"។ ពេលមុន ខ្មែរក្រហមធ្វើសកម្មភាពខាងក្រៅ ដើម្បី បំផ្លាញការចរចា ហ៊ុន សែន-សីហនុ តែពេលនេះ ត្រូវឈានចូលបំផ្លាញ ពីខាងក្នុង។ អស់មួយរយៈពេល ពួកខ្មែរក្រហមមានការខ្វែងទំនាស់ អំពី គោលជំហរជុំវិញការប្រជុំក្រៅផ្លូវការនៅហ្សាការតា តែក្រោយមកគេ ត្រូវសម្រុះសម្រួលតាមគោលជំហររបស់ ចិន។ ពួកគេចាត់ទុកថា បើគេ មិនទៅចូលរួមទេ គេនឹងប្រឈមមុខនឹងគ្រោះថ្នាក់ធំពីរៈ ទី ១ បើមិន ទៅចូលរួមទេ គេនឹងត្រូវឯកោ ព្រោះភាគីផ្សេងទៀត និងបណ្តាប្រ ទេសនៅអាស៊ីអាគ្នេយ៍ក៏ចូលរួមអស់ហើយ, ទី ២ ជាគ្រោះថ្នាក់ដ៏ធំសំ រាប់ខ្មែរក្រហម គឺលទ្ធភាពនៃការព្រមព្រៀង រវាងរដ្ឋាភិបាលសាធារ ណរដ្ឋប្រជាមានិតកម្ពុជា ជាមួយ សីហនុ-សឺន សាន អាចកើតមាន បាន ដោយគ្មានខ្មែរក្រហម ដូច្នេះចាំបាច់ត្រូវចូលរួម ដើម្បីរាំងការ ព្រមព្រៀងរវាងភាគីទាំងបី។ ប៉ុន្តែទោះបីបានប្រកាសនឹងចូលរួមចរចា*

ប៉ុន្តែខ្មែរក្រហមរកវិធីបំផ្លាញតាមរយៈបបួល សីហនុ សឺន សាន ចេញនូវសេចក្តីថ្លែងការណ៍រួមមួយនៅថ្ងៃ ២៩ មិថុនា ១៩៨៨ ដោយលើកឡើងនូវលក្ខខណ្ឌទុកជាមុនសំរាប់ការចរចា គឺទាមទារអោយវៀតណាមចរចាជាមួយ សីហនុ និងត្រីភាគី ទាមទារអោយវៀតណាមដកកងទ័ពជាបីដំណាក់កាល ដោយមានការត្រួតពិនិត្យរបស់អន្តរជាតិទាមទាររំលាយចោលសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយបង្កើតរដ្ឋាភិបាលចម្រុះចតុភាគី ដឹកនាំដោយ សីហនុ និងបោះឆ្នោតដោយសេរី ក្រោមការត្រួតពិនិត្យរបស់អន្តរជាតិ។

បណ្តាប្រទេសដែលមានការពាក់ព័ន្ធ ឬយកចិត្តទុកដាក់ដល់បញ្ហាកម្ពុជា សុទ្ធតែធ្វើសកម្មភាពយ៉ាងមមាញឹក ដើម្បីជះឥទ្ធិពលដល់កិច្ចប្រជុំក្រៅផ្លូវការនៅហ្សាការតា។ ចិន ជាចំហមិនជំទាស់ការប្រជុំក្រៅផ្លូវការ តែក៏ទាមទារអោយវៀតណាមចរចាជាមួយ សីហនុ និងត្រីភាគី។ ថ្ងៃ ០១ កក្កដា ១៩៨៨ ចិនប្រកាសគោលជំហរ ៤ ចំណុច ស្តីពីបញ្ហាកម្ពុជា ដើម្បីជះឥទ្ធិពលដល់គោលជំហរថៃ និងអាស៊ាន ក្នុងបំណងទប់ទល់នឹងមតិសាធារណៈ ដែលទាមទារអោយកំចាត់ចោលពួក ប៉ុល ពត។ ថ្ងៃ ២ កក្កដា ១៩៨៨ ចិនស្នើសូវៀតចរចាជាវិសាមញ្ញ ពីបញ្ហាកម្ពុជា។ អាមេរិក និងបណ្តាប្រទេសប៉ែកខាងលិច គាំទ្រការជួបគ្នានៅហ្សាការតា តែចង់អោយវៀតណាម ចរចាជាមួយ សីហនុ ដោយមានកំរិតខុសៗ គ្នា។ អាមេរិកគាំទ្រគោលជំហររបស់ អាស៊ាន ជំរុញការចរចាជាមួយវៀតណាម ជាមួយគ្នានេះ អាមេរិកបន្តពិភាក្សាជាមួយសូវៀត ចិន ពីបញ្ហាកម្ពុជា។ ថ្ងៃ ១៤-១៥ កក្កដា ១៩៨៨ រដ្ឋមន្ត្រីការបរទេសអាមេរិក ចរចាជាមួយចិនពីបញ្ហាកម្ពុជា។

ថ្ងៃ ១៣ កក្កដា ១៩៨៨ និងថ្ងៃ ១៨ កក្កដា ១៩៨៨ រដ្ឋមន្ត្រីការបរទេសអាមេរិកផ្ញើលិខិតពីរច្បាប់ អោយរដ្ឋមន្ត្រីការបរទេសសហភាពសូវៀត ហើយព្រមព្រៀងគ្នាថា ភាគីទាំងពីរនឹងចរចាពីបញ្ហាកម្ពុជា នាដើមខែ សីហា ១៩៨៨។

អង្គការសហប្រជាជាតិ ក៏បានពង្រីកនូវសកម្មភាពរបស់អគ្គលេខាធិការ ក្នុងការស្វែងរកដំណោះស្រាយនយោបាយ អោយកម្ពុជា អាស្រ័យដោយអង្គការនេះបានទទួលស្គាល់ពួកប្រល័យពូជសាសន៍ ប៉ុលពត និងមានសេចក្តីសំរេចចិត្ត លំអៀងទៅម្ខាង។ ថ្ងៃ ៣០ មិថុនា ១៩៨៨ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានបញ្ជូនបេសកជនពិសេសមកភ្នំពេញ ដែលជាការចាប់ផ្តើមជួបប្រាស្រ័យខាងនយោបាយ រវាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាមួយអង្គការសហប្រជាជាតិ ដែលប៉ុន្មានឆ្នាំមុននេះ មានការជួបប្រាស្រ័យក្នុងកំរិតបញ្ហាមនុស្សធម៌តែប៉ុណ្ណោះ។

មុននឹងដល់ភ្នំពេញ បេសកជនអគ្គលេខាធិការអង្គការសហប្រជាជាតិ បានធ្វើដំណើរទៅបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ និងជួបជាមួយខាងខ្មែរត្រីភាគី ដើម្បីពិភាក្សាលើគំរោងនៃដំណោះស្រាយបញ្ហាកម្ពុជា ដែលរៀបចំឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងអ្នកជំនួយការរបស់គាត់ ក្នុងគោលបំណងយកសេចក្តីព្រាងនេះទៅធ្វើជារបៀបវារៈនៃការប្រជុំក្រៅផ្លូវការនៅហ្សាការតា។ គំរោងនេះត្រូវឈប់ប្រើប្រាស់ក្រោយពេលពិភាក្សានៅក្រុងភ្នំពេញ យើងបានពន្យល់បេសកជនពិសេសអគ្គលេខាធិការ កុំអោយជ្រៀតជ្រែកចូលរឿងផ្ទៃក្នុងកម្ពុជា ហើយអោយខិតខំជៀសវាងនូវការលើកឡើង

លំអៀងទៅរកម្ខាង ដូចដែល អង្គការសហប្រជាជាតិបានធ្វើ ៩ ឆ្នាំមកហើយ និងមិនត្រូវដាក់ប្រជាជនកម្ពុជាដែលជាអ្នករងគ្រោះ អោយស្មើជាមួយពួកឧក្រិដ្ឋជនប្រល័យពូជសាសន៍ ប៉ុល ពត ឡើយ។

ចលនាមិនចូលបក្សសម្ព័ន្ធ បានចាប់ផ្តើមធ្វើសកម្មភាពក្នុងការស្វែងរកដំណោះស្រាយបញ្ហាកម្ពុជា បន្ទាប់ពីមានការផ្តើមគំនិតរបស់សម្តេច សីហនុ និងការយល់ព្រមពីសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ថ្ងៃ ១៥ កក្កដា ១៩៨៨ ក្រុមជំនាញនៃប្រទេសគុយបា ឥណ្ឌា ហ្សីមបាវ៉េ ដែលជាប្រធានសន្និសីទកំពូលលើកទី ៦ ទី ៧ និងទី ៨ នៃចលនាមិនចូលបក្សសម្ព័ន្ធ វៀតណាមតំណាងអោយប្រទេសនៅឥណ្ឌូចិន ឥណ្ឌូនេស៊ីតំណាងអោយប្រទេសអាស៊ាន អង្គការរំដោះប៉ាឡេស្ទីន ដែលជាអ្នកទទួលសំណើពីសម្តេច សីហនុ លើកដំបូង ដើម្បីរៀបចំអោយមានការជួបរវាងភាគីខ្មែរទាំង ៤ ជាមួយបណ្តាមេដឹកនាំប្រទេសមិនចូលបក្សសម្ព័ន្ធ បានធ្វើការប្រជុំនៅញូវដែលី ប្រទេសឥណ្ឌា ដើម្បីធ្វើការពិគ្រោះយោបល់អំពីបញ្ហាកម្ពុជា ហើយក៏បានសំរេចបញ្ជូនបេសកជនពិសេសរបស់ចលនាមិនចូលបក្សសម្ព័ន្ធទៅ ហ្សាការតា ដើម្បីតាមដានការប្រជុំ។

អង្គការឯកជនរបស់ប្រទេសស៊ុយអែដ មានឈ្មោះហៅថា "អង្គការសម្រុះសម្រួលអន្តរជាតិ" ក៏បានស្វះស្វែងធ្វើអោយមានការជួបគ្នារវាងភាគីខ្មែរទាំង ៤ ដោយលើកឡើងនូវរូបមន្តជាច្រើន ដើម្បីរំលាយភាពទាល់ច្រក និងឈានទៅដោះស្រាយជម្លោះតាមការចរចា។

សាធារណមតិភាគច្រើន បានបាញ់មុខព្រួញឆ្ពោះទៅ ហ្សាការតា ថ្វីត្បិតតែពេលនោះ កំពុងមានព្រឹត្តិការណ៍វិបត្តិផ្ទៃក្នុង នៅភូមា ហើយនៅប្រទេសថៃ មានការបោះឆ្នោត និងកំពុងជួបការលំបាកអំពីការ

រៀបចំរដ្ឋាភិបាលចម្រុះក៏ដោយ។

ក្នុងថ្ងៃ ២៣-២៤ កក្កដា ១៩៨៨ ប្រតិភូទាំងអស់បានទៅដល់ ហ្សាការតា ហើយបង្ហួសទៅទីក្រុង បូហ្គ័រ ដែលជាកន្លែងប្រជុំ។ មានតែសម្ដេច សីហនុ ទេ ដែលស្ថិតនៅ ហ្សាការតា ដោយគាត់ចាត់ទុកខ្លួនជាអ្នកនៅក្រៅសៃវៀននៃការប្រកួត ប៉ុន្តែជាអ្នកអោយទឹកនៃភាគី ហ៊្វុនស៊ីនប៉ិច ដែលមានកូនប្រុសគាត់ជាប្រធានប្រតិភូ ហើយក៏ជាអ្នកនៅខ្ពស់ជាងភាគីទាំង ៤ តាមរយៈនៃការទៅសួរសុខទុក្ខគាត់ របស់គណៈប្រតិភូទាំង ៤។

ល្ងាចថ្ងៃ ២៤ កក្កដា ១៩៨៨ ពិធីជប់លៀង "ដើម្បីការស្គាល់គ្នា" មួយបានរៀបចំឡើងសំរាប់អ្នកចូលរួមទាំងអស់។ ព្រឹកថ្ងៃ ២៥ កក្កដា ១៩៨៨ ការប្រជុំដំណាក់កាលទី ១ បានចាប់ផ្តើម បន្ទាប់ពី "ការផឹកតែ និងកាហ្វេដើម្បីស្គាល់គ្នា"។ នេះជាការជួបលើកដំបូងនៃភាគីដែលមានជម្លោះទាំងអស់ បន្ទាប់ពីការជួបរវាង ហ៊ុន សែន–សីហនុ ដែលគេអោយឈ្មោះថា "ការជួបជុំនៃបងប្អូនដែលជាសត្រូវនឹងគ្នា"។ ល្ងាចថ្ងៃ ២៥ កក្កដា ១៩៨៨ ជាការជួបដំណាក់កាលទី ២ ដែលជាការជួបគ្នាដំបូងរវាង ភាគីខ្មែរដែលមានជម្លោះ និងក្រុមប្រទេសពីរ ឥណ្ឌូចិន និងអាស៊ាន ដែលបានប្រឈមមុខគ្នាអស់រយៈពេលជិត ១០ ឆ្នាំកន្លងមក។

ការជួបនេះ បាននាំទៅដល់កិច្ចសហការជាលើកដំបូងរវាងប្រទេសនៅក្នុងដំបន់ ក្នុងការដោះស្រាយបញ្ហាកម្ពុជា និងបញ្ហាសន្តិភាព ស្ថិរភាពនៅអាស៊ីអាគ្នេយ៍។ ការជួបគ្នានេះ មិនគ្រាន់តែបានទម្លាយភាពទាល់ច្រកខាងផ្នែកនយោបាយ និងចិត្តសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែនៅបានបង្កើតឡើងនូវក្របខ័ណ្ឌដំណោះស្រាយនយោបាយមួយដែលបានបែងចែកទិដ្ឋភាពពីរ ផ្ទៃក្នុង និងអន្តរជាតិ នៃបញ្ហាកម្ពុជា ហើយផ្សារភ្ជាប់

បញ្ហាគន្លឹះពីរ គឺការដកកងទ័ពវៀតណាមចេញពីកម្ពុជា និងការទប់ស្កាត់កុំអោយរបបប្រល័យពូជសាសន៍ ប៉ុល ពត វិលត្រឡប់មកវិញ បញ្ឈប់ជំនួយអោយក្រុមខ្មែរបដិបក្ខ បញ្ឈប់ការជ្រៀតជ្រែកពីខាងក្រៅចូលកិច្ចការផ្ទៃក្នុងកម្ពុជា។ ជាលើកដំបូងហើយ ដែលបណ្តាប្រទេសអាស៊ាន ទទួលស្គាល់បញ្ហាគន្លឹះពីរ នៃបញ្ហាកម្ពុជា ដែលប៉ុន្មានឆ្នាំមុន គេនិយាយតែពីការដកកងទ័ពវៀតណាម ដោយមិនបាននិយាយអ្វីសោះពីគ្រោះថ្នាក់នៃរបប ប៉ុល ពត និងការបញ្ឈប់ជំនួយពីខាងក្រៅ ចំពោះពួកខ្មែរបដិបក្ខ។ នេះក៏ជាលើកដំបូងដែរ ដែលគេទទួលស្គាល់ថា បញ្ហាផ្ទៃក្នុងកម្ពុជា អាស្រ័យដោយប្រជាជនកម្ពុជា ជាអ្នកដោះស្រាយតាមរយៈនៃការឯកភាពជាមួយយើង បែងចែកទិដ្ឋភាពពីរ ផ្ទៃក្នុង និងអន្តរជាតិនៃបញ្ហាកម្ពុជា ដែលប៉ុន្មានឆ្នាំមុននោះ គេចង់ចាត់ចែងជោគវាសនាប្រជាជនកម្ពុជា ជំនួសប្រជាជនកម្ពុជា ដូចជាការតម្រូវអោយមានរបបនយោបាយតាមអាស៊ាន ឬការរៀបចំរដ្ឋាភិបាលជំនួសប្រជាជនកម្ពុជា។ល។

ការជួបគ្នាក្រៅផ្លូវការនៅហ្សាការតា បាននាំដល់ការប្រមូលផ្តុំកម្លាំងថ្មីនៅអាស៊ីអាគ្នេយ៍ ដែលមានចរិតជាការផ្លាស់ប្តូរសម្ព័ន្ធភាព ហើយក៏ជាដំណាក់កាលផ្ទេរកម្លាំងសង្កត់ ពីការទាមទារអោយវៀតណាមដកចេញពីកម្ពុជា ទៅជាការទាមទារអោយកំចាត់ចោលគ្រោះថ្នាក់នៃពួកខ្មែរក្រហម ប៉ុល ពត។ អាស្រ័យដោយបញ្ហាខ្មែរក្រហមជាគ្រោះថ្នាក់ និងជាឧបសគ្គសំរាប់ការស្វែងរកដំណោះស្រាយនយោបាយនៅកម្ពុជានោះ ការតស៊ូរវាងសម្ព័ន្ធមិត្តបានចាប់ផ្តើមយ៉ាងតឹងតែងទាំងភាគី សីហនុ និង សឺន សាន ក៏បែរមករកការឯកភាពជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជាដើម្បីប្រឆាំងខ្មែរក្រហម ភាគី សីហនុ បានលើកឡើងត្រង់ៗ អំពីភាពចាំ

បាច់ត្រូវកំចាត់ចោលគ្រោះថ្នាក់នៃខ្មែរក្រហម។ សឺន សាន ថ្វីត្បិតតែខ្លាចខ្មែរក្រហម និងចិនខឹង ប៉ុន្តែក៏ត្រូវបង្ខំអោយ ខៀវ សំផន ធ្វើសេចក្តីថ្លែងការណ៍ថា "ខ្មែរក្រហម នឹងមិនដណ្តើមអំណាចតែម្នាក់ឯងទេ ក្រោយពេលវៀតណាមដកចេញពីកម្ពុជា"។ សឺន សាន បានទាំងឡើងថ្លែងចំពោះមុខនៃការប្រជុំថា កុំអោយបញ្ចូលខ្លួនក្នុង "កន្ត្រក" ជាមួយពួកខ្មែរក្រហម។ ***វាងភាគីទាំង ៤ បានចាប់ផ្តើមពីចំណុច ៣ ប្រឆាំង ១ គឺ ៣ ភាគី ប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា បានក្លាយទៅជា ៣ ប្រឆាំង ១ ដដែល ប៉ុន្តែ គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា សីហនុ សឺន សាន ប្រឆាំងខ្មែរក្រហមវិញ។*** ឆ្លងតាមរយៈការប្រែប្រួលនៃអង្គប្រជុំក្រៅផ្លូវការនេះ ក៏បានកើតមានទូវការផ្លាស់ប្តូរការប្រមូលកម្លាំងនៅអាស៊ីអាគ្នេយ៍ ចាប់ផ្តើមពី ៩ ប្រឆាំង ៣ ទៅជា ១១ ប្រឆាំង ១ វិញ គឺ មុននោះ ប្រទេសអាស៊ាន ៦ រួមជាមួយត្រីភាគី ប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា វៀតណាម និងឡាវ ទៅជាប្រទេសអាស៊ានទាំង ៦ រួមជាមួយវៀតណាម ឡាវ សាធារណរដ្ឋប្រជាមានិតកម្ពុជា សីហនុ សឺន សាន ប្រឆាំងខ្មែរក្រហមវិញ។ ពួកខ្មែរក្រហមត្រូវស្ថិតក្នុងភាពឯកោយ៉ាងខ្លាំង ដែលសារពត៌មានបរទេសកត់សម្គាល់ថា "ខ្មែរក្រហមយកកទៅលអន្ទាក់" ការប្រជុំក្រៅផ្លូវការនៅ ហ្សាការតា ហាក់ដូចជាតុលាការកាត់ទោសពួក ប៉ុល ពត មួយដែរ ហើយពួក ប៉ុល ពត ហាក់ដូចជាបានត្រូវគេកំចាត់ខាងផ្នែកនយោបាយមួយចំណែកហើយដែរ។

អាស្រ័យដោយបញ្ហាខ្មែរក្រហម ប៉ុល ពត ជាបញ្ហាក្តៅបំផុត ដែលគេចាំបាច់ត្រូវលើកឡើងពិភាក្សាដោះស្រាយនោះ កម្លាំងសង្កត់ចំពោះការទាមទារអោយដកកងទ័ពវៀតណាម បានផ្ទេរទៅជាការទាមទារ

កំចាត់គ្រោះថ្នាក់នៃពួកខ្មែរក្រហមវិញ។ ប្រទេសជាច្រើន ថ្វីត្បិតតែប្រកាសជាចំហទាមទារអោយវៀតណាមដក ប៉ុន្តែជាផ្ទៃក្នុងគេខ្លាចវៀតណាមដកចាប់ពេកនាំអោយ ប៉ុល ពត ត្រឡប់មកវិញ ម្យ៉ាងទៀត បើវៀតណាមដកចាប់ពេក គេគ្មានពេលគ្រប់គ្រាន់ដើម្បីកសាងកម្លាំងអោយ សីហនុ និង សឺន សាន ឬហោចណាស់ បើវៀតណាមដកអស់ដោយគ្មានដំណោះស្រាយនយោបាយ គេក៏ត្រូវបាក់មុខបាក់មាត់ខ្លាំងដែរ។ ដូច្នេះ ទាំងប្រទេសអាស៊ាន ទាំងលោកខាងលិចបានបោះបង់នូវការទាមទារអោយវៀតណាមដកជាឯកតោភាគីដោយឥតលក្ខខណ្ឌ ទៅជាការទាមទារអោយវៀតណាមដកក្នុងក្របខ័ណ្ឌ "ដំណោះស្រាយនយោបាយហើយសុខចិត្តផ្សារភ្ជាប់ការកំចាត់របបប្រល័យពូជសាសន៍ ប៉ុល ពត និងការបញ្ឈប់ជំនួយពីខាងក្រៅអោយកម្លាំងខ្មែរបដិបក្ខ"។ នៅក្នុងការប្រជុំក្រៅផ្លូវការ នៅ ហ្សាការតា គ្មានប្រទេសណាមួយទាមទារអោយវៀតណាមដកមុនការបរិច្ឆេទ ដែលកម្ពុជា និងវៀតណាម បានដាក់ចេញ នោះឡើយ។

ចាប់តាំងពីមានការប្រជុំក្រៅផ្លូវការមក គេឃើញមាន "ភាពបែកខ្ញែកនៃសម្ព័ន្ធភាព" ដែលមិនអាចលាក់បាំងបានឡើយ។ ឥស្សរជនសំខាន់ៗខ្លះរបស់ឥណ្ឌូនេស៊ីបានអោយយោបល់ដល់ប្រតិភូយើងថា "**ភាពចាំបាច់ត្រូវតែកំចាត់ខ្មែរក្រហម ដូច្នេះត្រូវបង្កើតសម្ព័ន្ធភាពរវាងរដ្ឋាភិបាលភ្នំពេញ ជាមួយ សីហនុ និង សឺន សាន ដើម្បីប្រឆាំងខ្មែរក្រហម**"។ សម្តេច សីហនុ បានប្រកាសជាញឹកញាប់អំពីលទ្ធភាពនៃការធ្វើសម្ព័ន្ធភាពជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីទប់ស្កាត់ខ្មែរក្រហម។ តេង ស៊ីវពីង បានផ្ញើលិខិតផ្ញើអោយសម្តេច សីហនុ ព្រមានកុំអោយមានការព្រមព្រៀងដោយឡែកណាមួយ ជាមួយសាធារណរដ្ឋប្រជាមា

និតកម្ពុជា នៅក្នុងឱកាសជួបគ្នាលើកទី ៣ ហ៊ុន សែន-សីហនុ ខែ វិច្ឆិកា ១៩៨៨ នៅ ប៉ារីស។ សឺន សាន ចង់អនុវត្តវិធានការអព្យាក្រឹត ចំពោះ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងខ្មែរក្រហម ដើម្បីការពារកម្លាំង តាមរយៈនៃការស្នើសុំកុំអោយសាធារណរដ្ឋប្រជាមានិតកម្ពុជា វាយទៅ លើកម្លាំងគាត់ ទុកអោយគាត់មានដំបន់រំដោះ និងកុំអោយខ្មែរក្រហម ចូលដំបន់របស់គាត់កាន់កាប់ ឬហោចណាស់មិនវាយទៅលើគាត់ដូច ពេលមុនៗ គាត់ស្នើ នៅល្ងាចថ្ងៃ ២៥ កក្កដា ១៩៨៨ នៅទីក្រុង បូហ្គ័រ ប្រទេស ឥណ្ឌូនេស៊ី ក្នុងពេលហូបបាយល្ងាច ជាមួយ ហ៊ុន សែន ហើយត្រូវ បាន ហ៊ុន សែន បញ្ជាក់ត្រឡប់ទៅវិញថា មិនអាចធ្វើបានពេលណា សឺន សាន នៅជាមួយខ្មែរក្រហម ប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ការ បញ្ជាក់នេះ ធ្វើឡើងនៅថ្ងៃទី ២៦ កក្កដា ១៩៨៨ ក្នុងឱកាសនៃការជួប គ្នារវាងប្រតិភូ ហ៊ុន សែន និងប្រតិភូ សឺន សាន នៅទីក្រុង បូហ្គ័រ។

ក្រុមខ្មែរក្រហម ចាប់ផ្តើមកែប្រែនយោបាយនៃសម្ព័ន្ធភាព ពីការរួម ជាមួយ សីហនុ - សឺន សាន ទៅជាការវាយកំទេចកម្លាំង សីហនុ - សឺន សាន ទាំងនយោបាយ និងយោធា ជាមួយនោះ ខ្មែរក្រហមចាប់ផ្តើមអនុ វត្តនយោបាយការទូត "ការពារខ្លួន" ដើម្បីទប់ស្កាត់នូវចលនាទាមទារ អោយកំចាត់ខ្មែរក្រហម ប៉ុល ពត។ ថ្ងៃ ១៦ សីហា ១៩៨៨ ខ្មែរក្រហម ដាក់ចេញនូវសំណើ ១៤ ចំណុច ម្តងនេះគេហ៊ានទទួលយកនូវការចែក អំណាចស្មើគ្នា ទាំងនយោបាយ និងយោធា និងទទួលអោយមានការត្រួត ពិនិត្យអន្តរជាតិ ដែលប៉ុន្មានឆ្នាំមុនគេជំទាស់ អាស្រ័យដោយគេស្រមើ ស្រមៃថា អាចដណ្តើមអំណាចបានម្នាក់ឯង ប៉ុន្តែឥឡូវបែរជាព្រួយចំពោះ មុខនៃការត្រូវកំចាត់ទាំងនយោបាយ និងទាំងយោធាទៀតផង។

ចិន មានការលំបាកក្នុងការជ្រើសរើសផ្នែកយុទ្ធសាស្រ្ត ចំពោះបញ្ហាកម្ពុជា។ ឧបករណ៍ដែលចិនប្រើប្រាស់ សុទ្ធតែត្រូវចុះខ្សោយ ថែមទាំងត្រូវប្រឈមមុខនឹងការរលំរលាយទៀតផង។ ចិន បង្ខំចិត្តគាំទ្រ សីហនុ ជាចំហ តែត្រូវប្រឆាំង សីហនុ អំពីការដែល សីហនុ ចង់ធ្វើសម្ព័ន្ធភាពជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជាចោលខ្មែរក្រហម ជំទាស់នឹងសំណើ សីហនុ បង្កើតរដ្ឋាភិបាលចម្រុះចតុភាគី លើមូលដ្ឋាននៃរចនាសម្ព័ន្ធសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ចិន បានផ្លាស់ប្តូរពីការទាមទារអោយវៀតណាមដកចេញពីកម្ពុជា ជាឯកតោភាគី ដោយឥតលក្ខខណ្ឌ ទៅជាការទាមទារអោយវៀតណាម ដាក់ចេញប្រតិទិនដកកងទ័ព ក្នុងដំណោះស្រាយនយោបាយ។ ក្នុងសេចក្តីថ្លែងការណ៍មួយជាមួយទីភ្នាក់ងារសារពត៌មានជប៉ុន ក្យូដូ ថ្ងៃ ១២ សីហា ១៩៨៨ និងក្នុងកិច្ចសន្ទនាជាមួយនាយករដ្ឋមន្រ្តីជប៉ុន តាកេស៊ីតា (*Takeshita*) ថ្ងៃ ២៦ សីហា ១៩៨៨ ហ្សាវ ហ្សឺយ៉ាង អគ្គលេខាធិការបក្សកុម្មុយនិស្តចិន បានទទួលស្គាល់ជាលើកដំបូងថា ពួកខ្មែរក្រហមជាគ្រោះថ្នាក់ ដែលមិនអោយពួកនេះវិលត្រឡប់ទៅកាន់អំណាចម្នាក់ឯងនៅកម្ពុជា តែគាត់បានប្រឹងប្រែងផ្សារភ្ជាប់នូវគ្រោះថ្នាក់នៃការកាន់អំណាចម្នាក់ឯងរបស់ ហេង សំរិន ហ៊ុន សែន នៅកម្ពុជា គាត់បានសង្កត់ធ្ងន់ថា "ពិនិត្យស្ថានភាពជាក់ស្តែងនៃកម្លាំងប្រដាប់អាវុធរបស់ភាគីកម្ពុជាទាំង ៤ ទោះជាចំនួនទ័ព ឬការបំពាក់អាវុធ គឺកម្លាំង ហេង សំរិន ហ៊ុន សែន នៅតែច្រើនជាងគេ ហើយខ្លាំងជាងគេ។ ទាំងចិន ទាំងសហគមន៍អន្តរជាតិសុទ្ធតែជំទាស់នឹងភាគីខ្មែរក្រហម ក្តាប់អំណាចផ្តាច់មុខ ប៉ុន្តែមិនយល់ស្របចំពោះភាគី ហេង សំរិន ហ៊ុន សែន ក្តាប់ផ្តាច់មុខ"។ ពិតមែនតែព្រួញមួយបាញ់ចំគោលដៅ

ពីរ ប៉ុន្តែលើកដំបូងហើយ ដែលអ្នកដឹកនាំចិនបានបាញ់ចំទៅលើឧបករណ៍ខ្លួន ដោយចាត់ទុកខ្មែរក្រហមជាគ្រោះថ្នាក់។ ថ្វីត្បិតតែ ប្រទេសចិននៅតែបន្តចាត់ទុកបញ្ហាកម្ពុជា បណ្តាលមកពីកងទ័ពវៀតណាមនៅកម្ពុជាក៏ដោយ ការដែលចិនទទួលស្គាល់ថា ពួកខ្មែរក្រហម ប៉ុល ពត ជាគ្រោះថ្នាក់គឺ ជាការទទួលស្គាល់នៃប្រភពដើម ដែលនាំអោយវៀតណាមចូលកម្ពុជាដើម្បីជួយប្រជាជនកម្ពុជា ផ្តួលរំលំរបប ប៉ុល ពត។

ជាទ្រឹស្តី "គ្មានការកាប់សម្លាប់ពីសំណាក់ពួក ប៉ុល ពត ក៏គ្មានការក្រោកឈរឡើងរបស់ប្រជាជនកម្ពុជា ដែលនាំដល់ការជួយឧបត្ថម្ភពីវៀតណាមដើម្បីផ្តួលពួក ប៉ុល ពត ដែរ"។ ហ្សាវ ហ្សឺយ៉ាង ប្រឹងផ្សារភ្ជាប់របប ប៉ុល ពត ជាមួយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាទ្រឹស្តីនិងការជាក់ស្តែង គេមិនអាចយល់ទាល់តែសោះថា "កម្លាំងពីរបដិបក្ខនឹងគ្នា ១៨០ អង្សា អាចនៅក្នុងកន្ត្រកជាមួយគ្នាបានទេ" គេមិននិយាយសោះថា ដោយសារតែពួក ប៉ុល ពត វាឃោរឃៅ ព្រៃផ្សៃហើយ ទើបកម្លាំង ហេង សំរិន វាយរំលំ ដូច្នេះកម្លាំងទាំងពីរ មិនអាចនៅក្នុងទ្រុងជាមួយគ្នាបានទេ។

អគ្គលេខាបក្សកុម្មុយនិស្តចិន នៅបានទទួលយកជាលើកដំបូងនូវកងរក្សាសន្តិសុខសហប្រជាជាតិ និងគណៈកម្មការត្រួតពិនិត្យអន្តរជាតិចូលមកកម្ពុជា។ បញ្ហានេះក៏បានបង្កើតអោយមានការងឿងឆ្ងល់សំរាប់អ្នកវិភាគនយោបាយ។ បញ្ហានៅត្រង់ថា ហេតុអ្វីបានជារយៈពេលជាង ៩ ឆ្នាំ ចិន មិនទទួល ហើយពេលនេះ ចិនទទួលស្គាល់ បញ្ហានេះវាចេញមកពីតុល្យភាពកម្លាំងនៅលើសមរភូមិកម្ពុជា។ ប៉ុន្មានឆ្នាំមុន គេស្រមើស្រមៃថាកម្លាំង ប៉ុល ពត អាចមានលទ្ធភាពដណ្តើមអំណាចបានម្នាក់

ឯង តែពេលនេះ មិនត្រឹមតែចុះខ្សោយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវប្រឈមមុខនឹងគ្រោះថ្នាក់នៃការរលំរលាយទៀតផង។ ដូច្នេះ ត្រូវផ្លាស់ប្តូរយុទ្ធសាស្ត្រ ពីការយកអំណាចម្តាក់ឯងមកត្រឹមកំរិត "រក្សាអោយស្ថិតស្ថេរ" នៃកម្លាំង ប៉ុល ពត ចិនយល់ច្បាស់ណាស់ថា ពួកខ្មែរក្រហម ប៉ុល ពត មិនអាចការពារកម្លាំងបានតាមរយៈនៅក្នុងព្រៃ និងលើទឹកដីថៃជារៀងរហូតនោះទេ។ ជាងនេះទៅទៀត បន្ទាប់ពីនាយករដ្ឋមន្ត្រីថ្មីនៅថៃ ដែលមាននិន្នាការចង់ចូលរួមក្នុងដំណោះស្រាយនយោបាយនៅកម្ពុជា ដើម្បីបង្កើតទីផ្សាររកស៊ីរបស់ថៃ នៅតណ្ឌូចិនផងនោះ កាន់តែធ្វើអោយចិនព្រួយបារម្ភ។ ដូច្នេះ ដើម្បីការពារកម្លាំងពួកខ្មែរក្រហមបាន ត្រូវផ្អែកលើកងរក្សាសន្តិសុខ និងគណៈកម្មការត្រួតពិនិត្យអន្តរជាតិ។ ការទទួលយកកងរក្សាសន្តសុខអន្តរជាតិ និងគណកម្មការត្រួតពិនិត្យអន្តរជាតិ ម្យ៉ាងគឺដើម្បីការពារកម្លាំងអោយ ប៉ុល ពត តែម្យ៉ាងទៀត ក៏ដើម្បីសម្រុះសម្រួលជាមួយ អាមេរិក លោកខាងលិច អាស៊ាន សីហនុ សឺនសាន ដែលចង់អោយមានស្ថាប័នអន្តរជាតិទាំងពីរនេះដែរ។ រាល់ចំណុចនៃការប្រែប្រួល ក្នុងជំហររបស់ចិន ប្រមូលផ្តុំទៅលើវិធានការទប់ស្កាត់ការដែលខ្មែរក្រហម ត្រូវកំចាត់ពីជីវភាពនយោបាយសង្គមកម្ពុជា។

ចាប់ពីការប្រជុំក្រៅផ្លូវការ ហ្សាការតា យុទ្ធនាការទាមទារអោយកំចាត់ចោលនូវពួក ប៉ុល ពត បានកើតមាននៅគ្រប់កន្លែងនៃពិភពលោក ហើយលេចធ្លោឡើងនៅប៉ែកខាងលិច ដូចជា អង់គ្លេស បារាំង អាឡឺម៉ង់ខាងលិច រហូតដល់អ្នកទទួលពានរង្វាន់ណូបែល ១២ រូប ក៏បានចេញមុខទាមទារអោយបណ្តេញពួក ប៉ុល ពត ចេញពីអង្គការសហប្រជាជាតិដែរ។ នៅសហរដ្ឋអាមេរិក យុទ្ធនាការធំៗ ជាច្រើននៅក្នុងប្រជាជន នៅ

ក្នុងរដ្ឋសភា ព្រឹទ្ធសភា បានប្រមូលផ្តុំទៅលើមុខព្រួញទាមទារកំចាត់ខ្មែរក្រហម ប៉ុល ពត។ ថ្ងៃ ៩ តុលា ១៩៨៨ ក្នុងពេលមហាសន្និបាតអង្គការសហប្រជាជាតិ កំពុងពិភាក្សាដេញដោលអំពីសភាពការណ៍កម្ពុជា និងបញ្ហាកម្ពុជា អង្គការមហាជនអាមេរិកចំនួនបីរួមជាមួយលោក ឌិត ប្រន ដែលជាអ្នកដឹកនាំរឿងភាពយន្តដ៏ល្បីល្បាញឈ្មោះ "វាលពិឃាត" បាននាំគ្នាជួបជុំនៅក្បែរអង្គការសហប្រជាជាតិ ដើម្បីទាមទារបណ្តេញពួកខ្មែរក្រហមចេញពីអង្គការពិភពលោកនេះ និងទាមទារផ្តល់ជំនួយអភិវឌ្ឍន៍ដល់កម្ពុជា។ "លោក ឌិត ប្រន ជាជនជាតិខ្មែរ ដែលបានរួចផុតពីការកាប់សម្លាប់របស់ ប៉ុល ពត គាត់បានទៅស្នាក់នៅសហរដ្ឋអាមេរិក ហើយបានដឹកនាំខ្សែភាពយន្តរឿង វាលពិឃាត ដែលនិយាយពីឧក្រិដ្ឋកម្មរបស់ពួកប្រល័យពូជសាសន៍ ប៉ុល ពត"។ នៅក្នុងអង្គការសហប្រជាជាតិ ប្រតិភូភាគច្រើនបានចាត់ទុកការប្រជុំក្រៅផ្លូវការនៅ ហ្សាការតា ថាមានលទ្ធផលដែលត្រូវបន្ត ប្រការនេះបានធ្វើអោយប្រទេស អាស៊ាន មួយចំនួនចង់បំពេញបន្ថែមសេចក្តីសំរេច ស្តីពីកម្ពុជា ដោយបញ្ចូលខ្លឹមសារពីការប្រជុំក្រៅផ្លូវការទៅក្នុងសេចក្តីសំរេចចិត្ត។ ចំណុចនេះបានធ្វើអោយមានទំនាស់យ៉ាងខ្លាំងរវាងប្រតិភូ អាស៊ាន ជាមួយ ខៀវ សំផន ប្រធានប្រតិភូខ្មែរក្រហម ដែលតម្រូវអោយ ខៀវ សំផន ត្រូវធ្វើលិខិតមួយ នៅថ្ងៃ ០២-០៩-១៩៨៨ ផ្ញើទៅប្រតិភូប្រទេសនានា ប្រចាំអង្គការសហប្រជាជាតិ ដើម្បីចលនាអោយរក្សាទុកសេចក្តីសំរេចចិត្ត ១០ ឆ្នាំកន្លងមក។

នៅចលនាមិនចូលបក្សសម្ព័ន្ធ បញ្ហាកម្ពុជា ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង បន្ទាប់ពីការប្រជុំក្រៅផ្លូវការនៅ ហ្សាការតា។ ថ្ងៃ ១៥-១៧

សីហា ១៩៨៨ នៅ ហារ៉ារេ (*Harare*) ប្រទេស ហ្ស៊ីមបាវ៉េ (*Zimbabwe*) មានការប្រជុំក្រុមជំនាញនៃប្រទេស ហ្ស៊ីមបាវ៉េ គុយបា ឥណ្ឌា វៀតណាម ឥណ្ឌូនេស៊ី អង្គការរំដោះជាតិប៉ាឡេស្ទីន បន្ទាប់មករដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំង ៦ បានប្រជុំគ្នានៅថ្ងៃទី ៦ កញ្ញា ១៩៨៨ នៅ នីកូស៊ី ប្រទេសស៊ីប្រ ហើយថ្ងៃ ៨ កញ្ញា ១៩៨៨ អាឡាតាស់ រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី បានរាយការណ៍លទ្ធផលនៃការប្រជុំក្រៅផ្លូវការនៅ ហ្សាការតា ជូនសន្និសីទរដ្ឋមន្ត្រីការបរទេស នៃប្រទេសមិនចូលបក្សសម្ព័ន្ធ។ ថ្វីត្បិតតែមានការបំផ្លិចបំផ្លាញ ពីកម្លាំងនិយមការប្រឈមមុខ ប៉ុន្តែ ស្មារតី និងបរិយាកាសនៃការចរចា នៅតែបន្ត។ លទ្ធផលនៃការសហការរវាងប្រទេសនៅក្នុងដំបន់ ត្រូវបានរក្សា ដែលនាំដល់ការបំព្រួញរយៈពេលនៃការដោះស្រាយបញ្ហាកម្ពុជា ហើយក៏ជាការបើកច្រកអោយការដោះស្រាយបញ្ហាសន្តិភាព ស្ថិរភាពសំរាប់ដំបន់អាស៊ីអាគ្នេយ៍ផងដែរ។

សភាពការណ៍នៅបន្តវិវត្តន៍ស្មុគ្រស្មាញ ប៉ុន្តែបានចេញផុតពីដំណាក់កាលប្រឈមមុខតែមួយមុខ ទៅកាន់ដំណាក់កាលចរចាផង និងប្រឈមមុខផង ហើយការចរចាកំពុងតែមានអានុភាពខ្ពស់ជាងការប្រឈមមុខ។ បដិវត្តន៍កម្ពុជា បានផ្ទេរពីដំណាក់កាលវាយតែខាងយោធា ទៅកាន់ដំណាក់កាលវាយផង និងចរចាផងរង់ចាំការផ្ទេរទៅកាន់ដំណាក់កាលតស៊ូផង និងសម្រុះសម្រួលផង ប្រសិនបើមានដំណោះស្រាយនយោបាយ។ សម្ព័ន្ធភាពនៅកម្ពុជា និងអាស៊ីអាគ្នេយ៍កំពុងមានការផ្លាស់ប្តូរទាំងរូបភាពទាំងខ្លឹមសារ។ ខ្មែរក្រហម ប៉ុល ពត បានក្លាយជាបញ្ហាចម្បង និងបន្ទាន់សំរាប់ការដោះស្រាយ។ កម្លាំងសង្កត់ត្រូវបានផ្ទេរជាបណ្តើរៗពីការទាមទារអោយវៀតណាមដក ទៅជាការទាមទារអោយបំបាត់

គ្រោះថ្នាក់ នៃការវិលត្រឡប់របស់ ប៉ុល ពត។ ការព្រួយបារម្ភ ខ្លាចវៀតណាម ដកធាប់រហ័ស នាំដល់ ប៉ុល ពត ត្រឡប់មកវិញ កំពុងកើតមាននៅគ្រប់ទីកន្លែង។ របស់ដែលគេថាមិនត្រូវការនោះ ប្រែក្លាយទៅជាត្រូវការហើយចាំបាច់ "គេមិនត្រូវការកងទ័ពវៀតណាម តែគេត្រូវការកងទ័ពវៀតណាមដើម្បីទប់ស្កាត់ ប៉ុល ពត"។ ការសង្ឃឹមលើសម្ព័ន្ធភាពរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជាជាមួយ សីហនុ ដើម្បីប្រឆាំងខ្មែរក្រហមបានកើតមានក្នុងមនុស្សជាច្រើន។ ចិន កំពុងពិបាកជ្រើសរើសផ្នែកយុទ្ធសាស្រ្ត ក្នុងបញ្ហាកម្ពុជា និងអាស៊ីអាគ្នេយ៍។ លទ្ធភាពនៃការដកកងទ័ពវៀតណាមចេញពីកម្ពុជា ដោយគ្មានដំណោះស្រាយនយោបាយ កំពុងក្លាយទៅជាកម្លាំងសង្កត់ចំពោះភាគីដែលជាប់ទាក់ទិន។

## ភាពរអាក់រអួល និង ឧបសគ្គ

*ការប្រជុំក្រៅផ្លូវការនៅ ហ្សាការតា ២៥-២៨ កក្កដា ១៩៨៨ បានកកើតឡើងនូវរូបភាពសហការ រវាងបណ្តាប្រទេសក្នុងតំបន់ ដើម្បីដោះស្រាយបញ្ហាកម្ពុជា ហើយបានបង្កើតឡើងនូវក្របខ័ណ្ឌដំណោះស្រាយនយោបាយមួយ ដែលបានបែងចែកទិដ្ឋភាពផ្ទៃក្នុង និងទិដ្ឋភាពអន្តរជាតិ នៃបញ្ហាកម្ពុជា ហើយផ្សារភ្ជាប់បញ្ហាគន្លឹះទាំងពីរគឺ ការដកកងទ័ពវៀតណាមចេញពីកម្ពុជា ជាមួយនឹងការទប់ស្កាត់កុំអោយរបប ប៉ុល ពត វិលត្រឡប់មកវិញ និងការបញ្ឈប់ជំនួយយោធាអោយភាគីខ្មែរបដិបក្ខ និងបញ្ឈប់ការជ្រៀតជ្រែក ពីខាងក្រៅចូលកិច្ចការផ្ទៃក្នុងកម្ពុជា។ នេះជាលើកដំបូង ដែលបញ្ហាកម្ពុជាត្រូវបានលើកគំរោងដោះស្រាយដោយផ្សារភ្ជាប់បញ្ហានានាដែលមានការទាក់ទងគ្នា ហើយបញ្ហាគន្លឹះសំខាន់ គឺបញ្ហា ប៉ុល ពត ត្រូវបានប្រមូលផ្តុំមុខព្រួញដើម្បីទប់ស្កាត់។*

*ក្រោយពេលដែលបញ្ហា ប៉ុល ពត បានលេចឡើងជាបញ្ហាចម្បង ហើយក្តៅបំផុតនោះ យើងពិនិត្យឃើញនូវចលនាការទូតដ៏ទូលំទូលាយរបស់ ចិន-ថៃ-ខ្មែរក្រហម ដើម្បីទប់ស្កាត់ ដែលក្នុងនោះរាប់តាំងពីវិធានការដាក់ការគាបសង្កត់របស់ចិន ទៅលើសម្តេច សីហនុ ផង។ ថ្ងៃ ១៥ សីហា ១៩៨៨ ខ្មែរក្រហម បានដាក់ចេញនូវសំណើសន្តិភាពមួយ ដែលគេហៅថា ដើម្បីដោះស្រាយបញ្ហាកម្ពុជាតាមនយោបាយសព្វមុខ ដែល*

ក្នុងនោះមានចំណុចមួយនិយាយថា "ផ្សះផ្សារជាតិរវាងជនជាតិកម្ពុជាទាំងអស់ គណៈបក្សពួកទាំងអស់ ដោយគ្មាន គិតគូរដល់អតីតកាល និងនិន្នាការនយោបាយរបស់អ្នកណាទាំងអស់"។ យើងដឹងច្បាស់លាស់ថា ការនិយាយនេះ គឺដើម្បីទប់ទល់ចំពោះមតិសាធារណៈ ដែលកំពុងទាមទារអោយកំចាត់មេក្លោង ប៉ុល ពត ព្រមទាំងសហការីជិតស្និទ្ធរបស់គេ។ ថ្ងៃ ២៦ សីហា ១៩៨៨ អគ្គលេខាបក្សកុម្មុយនិស្តចិន ហ្សាវ ហ្សីយ៉ាង បានលើកឡើងនូវទស្សនៈថ្មីមួយ អំពីបញ្ហាស្នូលមួយ គឺការដកកងទ័ពវៀតណាម និងគ្រោះថ្នាក់ពីរគឺ ខ្មែរក្រហមក៏គ្រោះថ្នាក់ របប ហេង សំរិន ក៏គ្រោះថ្នាក់ ដែលគេលើកឡើងថាត្រូវប្រឆាំងការវិលត្រឡប់មកកាន់អំណាចឡើងវិញរបស់ខ្មែរក្រហម និងប្រឆាំងកម្លាំង ហេង សំរិន ក្តាប់អំណាចម្នាក់ឯង ហើយក៏បានលើកផងដែរនូវការទទួលយកកងរក្សាសន្តិសុខអន្តរជាតិចូលមកកម្ពុជា ដែលមកដល់ខែ តុលា ១៩៨៨ ពួកខ្មែរក្រហមក៏ប្រកាសយល់ព្រមទទួលយកដូចគ្នា។ ច្បាស់លាស់ណាស់ ការលើកឡើងរបស់ចិន និងខ្មែរក្រហម គឺ ប៉ុនប៉ង ដើម្បីប្រែក្រឡាស់សភាពការណ៍ ដែលបានកើតមានឡើងតាំងពីខែ ឧសភា ១៩៨៨ ពិសេស ក្រោយការប្រជុំក្រៅផ្លូវការនៅ ហ្សាការតា ដែលបានប្រមូលផ្តុំទៅលើខ្មែរក្រហម ប៉ុល ពត រួចស្រេចទៅហើយ។ ប៉ុន្តែ ពុំគ្រាន់តែបណ្តាប្រទេសលោកខាងលិច និងអាស៊ាន មិនគាំទ្រប៉ុណ្ណោះទេ តែថែមទាំងគេបន្តលើកឡើងនូវបញ្ហាគន្លឹះពីរ និងប្រមូលផ្តុំលើកឡើងអំពីគ្រោះថ្នាក់ ប៉ុល ពត ទៀតផង។

ក្នុងពេលដែលសម្តេច សីហនុ ប្រកាសចាត់ទុកថា ការកំចាត់ខ្មែរក្រហមគឺជាបញ្ហាស្លាប់រស់ ហើយប្តេជ្ញាចិត្តចរចាជាទ្វេភាគីជាមួយ ហ៊ុន

សែន ដោយលើកឡើងអំពីលទ្ធភាពនៃការធ្វើសម្ព័ន្ធភាពទាំងយោធា និងនយោបាយជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីកំចាត់ខ្មែរក្រហម តេង ស៊ីវពីង បានសរសេរលិខិតព្រមានចំពោះសម្តេច សីហនុ កុំអោយមានការព្រមព្រៀង ដោយឡែកណាមួយជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលធ្វើអោយសម្តេច សីហនុ មានជំហានថយក្រោយក្នុងបញ្ហាខ្មែរក្រហម នៅក្នុងឱកាសចរចាលើកទី ៣ ហ៊ុន សែន-សីហនុ និងការប្រជុំកំពូលលើកទី ១ រវាង ហ៊ុន សែន-សីហនុ-សឺន សាន។ សម្តេច សីហនុ បានអោយដឹងថា ចិន បានកាត់ប្រាក់សំរាប់គាត់ធ្វើសកម្មភាព ដែលចិន ធ្លាប់អោយ ១ ឆ្នាំៗ ៣០០.០០០ ដុល្លារអាមេរិក។ អាស្រ័យដោយការបែកបាក់យ៉ាងធ្ងន់ធ្ងរក្នុងជួរត្រីភាគី និងដើម្បីដាក់ការគាបសង្កត់មកលើសម្តេច សីហនុ ឆ្នាំ ១៩៨៨ នេះ ចិនមិនបានកោះប្រជុំត្រីភាគីកម្ពុជាប្រជាធិបតេយ្យ ដើម្បីបែងចែកជំនួយដូចពីឆ្នាំ ១៩៨៣-១៩៨៧ នោះឡើយ ហើយថែមទាំងប្រកាស សំដែងនូវការព្រួយបារម្ភចំពោះមុខការចរចា ហ៊ុន សែន-សីហនុ មុនពេលការចរចានេះបានប្រព្រឹត្តទៅតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ដែលធ្វើអោយសម្តេច សីហនុ មិនអាចធ្វើសកម្មភាពណាមួយក្រៅពីវង្វង់នៃគោលជំហររបស់ចិន បានឡើយ។ សភាពការណ៍វិវត្តមិនអនុគ្រោះអោយចិន ទ្រឹស្តីគន្លឹះមួយ និងគ្រោះថ្នាក់ពីរ គ្មានអ្នកណាគាំទ្រ ចិនបានប្រកាសជួបជាកំពូលជាមួយសហភាពសូវៀត ដែលចិនបានពន្យាពេលនៃការជួបជាកំពូលនេះ អស់រយៈពេលជាច្រើនឆ្នាំ អាស្រ័យដោយចិនបានលើកឡើងនូវឧបសគ្គបី ដែលសំខាន់បំផុតគឺឧបសគ្គអំពីបញ្ហាកម្ពុជា។ បន្ទាប់ពីរដ្ឋមន្ត្រីការបរទេស ចិន និងសហភាពសូវៀតជួបគ្នានៅអង្គការសហប្រជាជាតិ នាខែ តុលា ១៩៨៨

ភាគីទាំងពីរបានប្រកាសថា រដ្ឋមន្ត្រីការបរទេសចិនធ្វើទស្សនកិច្ចនៅសហភាពសូវៀត ដើមខែ ធ្នូ ១៩៨៨ ហើយរដ្ឋមន្ត្រីការបរទេសសហភាពសូវៀត ធ្វើទស្សនកិច្ចនៅចិន នៅខែ មករា ១៩៨៩ ដើម្បីរៀបចំអោយមានការជួបថ្នាក់កំពូលសូវៀត-ចិន នៅមុនរដូវក្តៅ ១៩៨៩។ ចិនត្រូវការអោយមានការជួបជាកំពូលចិន-សូវៀត ក្នុងពេលដែលបញ្ហាកម្ពុជា មិនទាន់បានដោះស្រាយ សភាពការណ៍នោះបាននាំដល់ភាពផ្ទុយនឹងគោលជំហររបស់ចិនរយៈពេល ១០ ឆ្នាំកន្លងមក ដែលចិន បានចាត់ទុកបញ្ហាកម្ពុជា ជាឧបសគ្គសំខាន់បំផុត ក្នុងការកែលំអទំនាក់ទំនងសូវៀត-ចិន។

ច្បាស់លាស់ណាស់ បញ្ហាកម្ពុជា មិនមែនជាមូលហេតុនោះឡើយ ប៉ុន្តែវាជាលេសមួយដែលចិន ប្រើប្រាស់សំរាប់ប្រឆាំងសហភាពសូវៀត រាំងស្កាត់ការកែលំអទំនាក់ទំនងសូវៀត-ចិន និងសំរាប់ទាក់ទាញអាមេរិក ប្រទេសប៉ែកខាងលិច និងអាស៊ាន ដើម្បីបំរើផលប្រយោជន៍យុទ្ធសាស្ត្ររបស់ចិនតែប៉ុណ្ណោះ។ តាំងពីខែតុលា ១៩៨២ សូវៀត ចិន ចាប់ផ្តើមចរចាជាមួយគ្នា ថ្នាក់អនុរដ្ឋមន្ត្រីការបរទេស។ រហូតមកទល់បច្ចុប្បន្ននេះ ទោះបីបញ្ហាកម្ពុជាមិនទាន់បានដោះស្រាយ ក៏ទំនាក់ទំនង ចិន-សូវៀត បានកែលំអយ៉ាងច្រើន ហើយពេលនេះទៀត បញ្ហាកម្ពុជាក៏មិនទាន់បានដោះស្រាយ ក្នុងពេលដែលចិន ប្រកាសជួបជាកំពូល ជាមួយសហភាពសូវៀត ដូច្នេះ វាកាន់តែបញ្ជាក់ច្បាស់ថា បញ្ហាទំនាក់ទនងសូវៀត-ចិន មិនចំណុះជាមួយបញ្ហាកម្ពុជាឡើយ ហើយបញ្ហាទាំងពីរវាបានកើតឡើងមិនចំពេលជាមួយគ្នាដែរ។ ទំនាក់ទំនងសូវៀត-ចិន ចាប់ផ្តើមអាក្រក់ទៅតាំងពីដើមទសវត្ស ឆ្នាំ ៦០ ឯបញ្ហាកម្ពុជា ក៏ទើបកើតឡើងនៅចុងទសវត្សឆ្នាំ ៧០។

ចិនប្រកាសជួបកំពូលជាមួយសូវៀត អាចមកពីការព្រួយបារម្ភរបស់ចិន ចំពោះមុខការរីកចំរើន ក្នុងទំនាក់ទំនង សូវៀត-អាមេរិក ដែលក្លាយទៅជាប៉ូលពីរ ដើម្បីដោះស្រាយបញ្ហានានា នៅលើសកលលោក ក្នុងពេលដែលចិនមិនទាន់ ប្រែក្លាយខ្លួនអោយទៅជាប្រៀបដែលមាន ប៉ូលបី ទាំងនៅអាស៊ីប៉ាស៊ីហ្វិក ទៀតផង។ បញ្ហាមួយនៅអាស៊ី គឺបញ្ហាអាហ្វហ្គានីស្ថាន គេបានដោះស្រាយដោយ អាហ្វហ្គានីស្ថាន ប៉ាគីស្ថាន សហភាពសូវៀត អាមេរិក ដោយគ្មានតួនាទីរបស់ចិន។ បញ្ហាកម្ពុជា កំពុងរបូតផុតពីដៃរបស់ចិន ការប្រជុំក្រៅផ្លូវការនៅ ហ្សាការតា នាខែកក្កដា ១៩៨៨ មិនត្រូវបានស្វាគមន៍ដោយចិន ពួកខ្មែរក្រហមមិនចូលរួមប្រជុំក្រុមការងារនៅ ហ្សាការតា ដែលប្រជុំពីថ្ងៃ ១៧-១៩ តុលា ១៩៨៨ ហើយក៏មិនចូលរួមប្រជុំកំពូលរវាងភាគីខ្មែរនៅប្រទេសបារាំង ពីថ្ងៃ ៧-៨ វិច្ឆិកា ១៩៨៨ ថៃមានការប្រែប្រួលខ្លះ បន្ទាប់ពីមាននាយករដ្ឋមន្ត្រីថ្មី សូវៀត អាមេរិក បារាំង បានចរចាគ្នាអំពីបញ្ហាកម្ពុជា សន្ទឹកបៀពីរដែលចិនក្ដាប់សុទ្ធតែបង្កការលំបាកអោយចិន សន្ទឹកបៀ ប៉ុល ពត លេបលែងចូល ហើយកំពុងស្ទាក់បំពង់ក សន្ទឹកបៀ សីហនុ ចិនក្ដាប់មិនជាប់ រហូតមានពេលបង្វិលមុខព្រួញប្រឆាំងចិន និង ប៉ុល ពតវិញ ហើយបញ្ហាកងទ័ពវៀតណាម ក៏មិននៅជាសន្ទឹកបៀសំរាប់ចិន ប្រើប្រាស់ដូច ១០ ឆ្នាំកន្លងមកទៀតឡើយ។ សិល្បៈការទូត និងព្រនង់ការទូត បានធ្វើដំណើរព្រមៗ គ្នា ទ្រឹស្ដីគន្ទឹះមួយគ្រោះថ្នាក់ពីរ ធ្វើអោយលេចឡើងនូវសញ្ញានៃការប្រេះឆាររវាងចិន និងខ្មែរក្រហម។ ការត្រៀមបោះបង់ចោលខ្មែរក្រហមនៅពេលវៀតណាមដកចេញពីកម្ពុជា ការប្រឆាំងខ្មែរក្រហមវិលមកកាន់អំណាចម្នាក់ឯង ហើយទទួលយកកង

រក្សាសន្តិសុខអន្តរជាតិចូលមកកម្ពុជា ការប្រកាសជួបកំពូលជាមួយសហភាពសូវៀត ការចាត់បញ្ជូន លី ប៉េង នាយករដ្ឋមន្ត្រីចិន មកទស្សនកិច្ចនៅថៃ ដើម្បីបញ្ចុះបញ្ចូល និងគាបសង្កត់ថៃ ការព្រមានចំពោះសម្តេច សីហនុ កុំអោយមានការព្រមព្រៀងដោយឡែកជាមួយភ្នំពេញ ការកាត់ជំនួយហិរញ្ញវត្ថុសំរាប់សកម្មភាពរបស់សម្តេច សីហនុ ដោយមិនប្រជុំត្រីភាគី ដើម្បីចែកចាយជំនួយយោធា និងហិរញ្ញវត្ថុ ការកំណត់គោលជំហរអោយសម្តេច សីហនុ និង សឺន សាន ក្នុងការចរចាជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ល។ ទាំងអស់នេះ ធ្វើឡើងដើម្បីកុំអោយបញ្ហាកម្ពុជារបូតចេញផុតពីដៃរបស់ចិន។

មុនពេលចរចាលើកទី ៣ ហ៊ុន សែន-សីហនុ និងការចរចាថ្នាក់កំពូលលើកទីមួយ ហ៊ុន សែន-សីហនុ-សឺន សាន ក៏មានសកម្មភាពការទូតដ៏មមាញឹក។ សឺន សាន បានប្រឹងផ្សារភ្ជាប់ខ្លួនជាមួយចិន និងខ្មែរក្រហម ហើយការពារខ្មែរក្រហមនៅអង្គការសហប្រជាជាតិ ដើម្បីបង្កើនសទ្ទឹកឆ្នោតមកគាបសង្កត់សាធារណរដ្ឋប្រជាមានិតកម្ពុជា លើតុចរចា។ សម្តេច សីហនុ បានធ្វើដំណើរទៅប្រទេសអាស៊ានមួយចំនួន ជប៉ុន បារាំង អាមេរិក អង់គ្លេស ដើម្បីប្រមូលការគាំទ្រពី អាស៊ាន អាមេរិក ប្រទេសប៉ែកខាងលិច ទាំងនយោបាយ និងយោធា ដើម្បីធ្វើជាបង្អែកមុនការចរចា។ បណ្តាប្រទេសអាស៊ាន មានភាពបែកខ្ញែក ដោយមានប្រទេសមួយចំនួន ចង់រក្សានូវលទ្ធផលដែលសម័យប្រជុំក្រៅផ្លូវការនៅ ហ្សាការតា សំរេចបាន ហើយប្រទេសមួយចំនួនទៀត ខិតខំបំផ្លិចបំផ្លាញតាមរយៈនៃការរក្សាទុកសេចក្តីសំរេចចិត្ត រយៈពេល ៩ ឆ្នាំកន្លងមក ប៉ុន្តែ មានបន្ថែមចំណុចដែលនិយាយពីការមិនវិលត្រឡប់នៃ

របបខ្មែរក្រហម ដើម្បីជាយុទ្ធវិធីប្រមូលបន្ថែមសន្លឹកឆ្នោត ហើយដែលក្រោយពីការបោះឆ្នោត ដើម្បីតម្រូវចិត្តចិន សឺន សាន បានអត្ថាធិប្បាយថា ក៏និយាយយោងដល់របបគ្រប់គ្រងក្រុងភ្នំពេញផងដែរ ដែលបានបង្កើតអោយមានការខឹងសម្បារ ពីប្រទេសដែលបានបោះឆ្នោតអោយសេចក្តីសំរេចចិត្តនេះ។ ដូច្នេះ ឆ្នាំ ១៩៨៨ នេះ គេពិនិត្យ ឃើញមានសិល្បៈការទូតរបស់ប្រទេសអាស៊ានពីរខុសគ្នាមួយនៅ ហ្សាការតា ឯមួយទៀតនៅអង្គការសហប្រជាជាតិ។

ការចរចាលើកទីបី ហ៊ុន សែន-សីហនុ បានគ្រោងធ្វើនៅថ្ងៃ ០៥ វិច្ឆិកា ១៩៨៨ នៅសណ្ឋាគារ គ្រីយ៉ុង (*Crillon*) នៅចំកណ្តាលទីក្រុងប៉ារីស នៃប្រទេសបារាំង ប៉ុន្តែត្រូវលើកទៅថ្ងៃ ៦ វិច្ឆិកា ១៩៨៨ វិញ ហើយនៅ ហ្វែរអង់តាដឺន័រ។ ហេតុផលនៃការផ្លាស់ប្តូរទីកន្លែង និងពេលវេលា នៃការប្រជុំ គឺជាហេតុផលមិនគួរនឹងនិយាយ ព្រោះជាគ្មានសមហេតុសមផលបន្តិចណាសោះ ហើយបញ្ហាទាំងអស់បានបង្កើតឡើងដោយក្រុមជំនួយការរបស់សម្តេច សីហនុ និងពួកមន្ត្រីបារាំងឡេមឡឺមជាមួយសម្តេចសីហនុ ខ្លះ ដែលទៅចាក់រុកសម្តេច សីហនុ ថា ហ៊ុន សែន បានវាយស្មើជាមួយសម្តេច អាស្រ័យដោយ ហ៊ុន សែន បានជួលសណ្ឋាគារគ្រីយ៉ុងស្នាក់នៅជាមួយ ធ្វើអោយសម្តេច សីហនុ ខឹងសម្បា ហើយលុបចោលការប្រជុំនៅសណ្ឋាគារគ្រីយ៉ុង។ តាមទូរលេខថ្ងៃ ១៣ សីហា ១៩៨៨ ពីទីក្រុងតូក្យូរបស់សម្តេច សីហនុ ផ្ញើមកអោយ ហ៊ុន សែន សម្តេចបានកំណត់ថា ការប្រជុំនឹងធ្វើនៅសណ្ឋាគារគ្រីយ៉ុង ថ្ងៃ ៥ វិច្ឆិកា ១៩៨៨ វេលាម៉ោង ១០ ព្រឹក។ ដើម្បីងាយស្រួលអនុវត្តការងារ និងបន្ថយការលំបាកអំពីការធ្វើដំណើរ និងកិច្ចការពារសន្តិសុខ យើងបានសំរេច

ជួលសណ្ឋាគារគ្រីយ៉ុងដើម្បីស្នាក់នៅ អាស្រ័យដោយសណ្ឋាគារនេះធំមានរាប់រយបន្ទប់ ហើយក៏មិនមែនជាផ្ទះសំណាក់ដាច់មុខរបស់សម្តេច សីហនុ ហើយសម្តេច សីហនុ ក៏គ្មានលទ្ធភាពដើម្បីជួលសណ្ឋាគារនេះនៅតែឯងបានដែរ។ អ្នកណាក៏ដោយចុះ អោយតែមានប្រាក់ ក៏អាចជួលសណ្ឋាគារនេះនៅតែម្នាក់ឯងបានដែរ ហើយក៏មិនថាជនជាតិណាឬឋានៈនាទីណាឡើយ។ ចម្ងៃកត្រង់តែសម្តេច សីហនុ ដែលគាត់គ្មានលទ្ធភាពជួលផ្តាច់សណ្ឋាគារនេះ បែរជាមកជំទាស់នឹងការស្នាក់នៅរបស់ប្រតិភូយើង ក្នុងសណ្ឋាគារនេះ ដែលហេតុផលសំខាន់ គឺការបែងចែកដាច់ស្រឡះ រវាងស្តេច និងរាស្ត្រ ហើយបែងចែកដាច់ស្រឡះរវាងខ្មែរ និងខ្មែរដូចគ្នា។ អំពើនេះ បានបង្កើតអោយមានការសង្ស័យពីសំណាក់ជនជាតិខ្មែរនៅបរទេស ក៏ដូចជា ជនជាតិបរទេសដែលបានដឹងឮក្នុងរឿងនេះ អំពីប្រជាធិបតេយ្យសេរីនិយម ដែលសម្តេច សីហនុ ធ្លាប់តែបានលើកឡើងដើម្បីប្រឆាំងជាមួយភាគីបដិបក្ខ តើវាអាចមានប្រជាធិបតេយ្យ មានសេរីភាព និងសមភាពយ៉ាងដូចម្តេចបាន បើគ្រាន់តែប្រមុខនៃកម្លាំងពីរ ដែលកំពុងបដិបក្ខជាមួយគ្នា ដែលភាពពិតប្រាកដកំពុងតែស្មើភាពជាមួយគ្នាក្នុងការចរចា ហើយត្រូវបែងចែកដាច់ស្រឡះពីគ្នាយ៉ាងនេះ ប្រកាន់ឋានៈ វណ្ណៈខ្ពស់ទាបយ៉ាងនេះទៅហើយ ទំរាំមានដំណោះស្រាយនយោបាយ ហើយម្នាក់មាននាទីខ្ពស់ម្នាក់មាននាទីទាប តើនឹងត្រូវមានការគោរពសង្កត់យ៉ាងណាទៀត។ ការសង្ស័យនេះ មានភាពត្រឹមត្រូវ ហើយបានក្លាយជាការប្រុងប្រយ័ត្នរបស់យើង ចំពោះពាក្យប្រជាធិបតេយ្យសេរីនិយមនេះដែរ។ ការលុបចោលការប្រជុំនៅសណ្ឋាគារគ្រីយ៉ុង បានបង្កើតឡើងនូវការលំបាក

យ៉ាងខ្លាំងសំរាប់យើង ព្រមពេលជាមួយគ្នាតាមរយៈមន្ត្រីបារាំងគេបាន ដាក់នូវលក្ខខណ្ឌពីរអោយយើង ដែលយើងមិនអាចទទួលយកបាន ទីមួយ គេស្នើអោយយើងទៅប្រជុំនៅអតីតលំនៅដ្ឋានឯកអគ្គរដ្ឋទូតខ្មែរ ដែលបារាំងបានប្រគល់អោយសម្តេច សីហនុ ដោយខុសច្បាប់ (ផ្ទះនេះជាសម្បត្តិរបស់រដ្ឋកម្ពុជា ដែលសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបង់ពន្ធអោយបារាំងអស់រយៈពេល ១០ ឆ្នាំមកហើយ)។ បារាំងចង់អោយយើងប្រជុំនៅទីនោះ ដើម្បីផ្តល់ភាពស្របច្បាប់អោយសម្តេច សីហនុ ក្នុងការកាន់កាប់ផ្ទះនេះ។ មន្ត្រីក្រសួងការបរទេសបារាំង បាននិយាយថា បើ ហ៊ុន សែន ទៅជួប សីហនុ នៅផ្ទះនេះ សម្តេច សីហនុ នឹងវាយតម្លៃខ្ពស់ចំពោះ ហ៊ុន សែន។ យើងបានឆ្លើយតបទៅវិញថា បើ ហ៊ុន សែន ទៅប្រជុំនៅផ្ទះនេះ ហ៊ុន សែន នឹងបានការវាយតម្លៃយ៉ាងទាបពី ប្រជាជនកម្ពុជា ៨ លាននាក់ នៅក្នុងប្រទេស។ លក្ខខណ្ឌទីពីរ ដែលគេលើកគឺ អោយយើងចាកចេញពីសណ្ឋាគារគ្រីយ៉ុង ទៅនៅសណ្ឋាគារផ្សេង ហើយយកសម្តេច សីហនុ មកនៅសណ្ឋាគារគ្រីយ៉ុងវិញនិងប្រជុំនៅសណ្ឋាគារគ្រីយ៉ុង។ គ្រប់លក្ខខណ្ឌ យើងមិនអាចទទួលយកបានឡើយ ប៉ុន្តែ ដើម្បីកុំអោយមានឥទ្ធិពលដល់ការប្រជុំ យើងបានដាក់ចេញនូវរូបមន្តមួយ គឺស្នើអោយជ្រើសរើសកន្លែងទីបី ដើម្បីបើកការប្រជុំ មានន័យថា មិនប្រជុំនៅសណ្ឋាគារគ្រីយ៉ុង ហើយក៏មិនប្រជុំនៅអតីតផ្ទះឯកអគ្គរដ្ឋទូតខ្មែរដែរ។ ចុងក្រោយបំផុត បានដើរដល់ការឯកភាពយក ហ្វែរអង់តាដឺន័រ ដែលជាកន្លែងប្រជុំលើកទី ១ ហ៊ុន សែន-សីហនុ កាលពីខែធ្នូ ១៩៨៧ ធ្វើជាកន្លែងប្រជុំលើកទីបី ហ៊ុន សែន-សីហនុ និងជាកន្លែងប្រជុំកំពូលត្រីភាគីទីមួយផងដែរ។

ចំពោះរូបភាពនៃការប្រជុំវិញ សម្តេច សីហនុ មានបំណងអោយការប្រជុំនេះ ជាការប្រជុំប្រាំភាគីតែម្តង ដោយមិនមានការប្រជុំទ្វេភាគី ហ៊ុន សែន–សីហនុ ដូចដែលបានព្រមព្រៀងគ្នា តាំងពីខែកក្កដា ១៩៨៨ នោះមកទេ។ យើងបានទាមទារអោយមានការជួបទ្វេភាគីជាមុនសិន ដើម្បីពិភាក្សាអំពីរូបភាពប្រជុំបន្តទៀត។ ការជួបទ្វេភាគី ហ៊ុន សែន-សីហនុ បានប្រព្រឹត្តទៅ នៅថ្ងៃ ៦ វិច្ឆិកា ១៩៨៨។ ពេលបើកការប្រជុំភ្លាម ខ្ញុំ (ហ៊ុន សែន) បានសួរសម្តេច សីហនុ ថាតើការប្រជុំនេះរបៀបណា ព្រោះតាមការព្រមព្រៀងរវាងសម្តេច និងទូលបង្គំ គឺជាការប្រជុំលើកទីបី រវាងសម្តេច និងទូលបង្គំ ប៉ុន្តែឥឡូវនេះ សម្តេចបានហៅខ្មែរក្រហម និង សឺន សាន ចូលរួមដែរ។ សម្តេច សីហនុ បានឆ្លើយថា ខ្ញុំបានដឹងថា ឯកឧត្តម ហ៊ុន សែន មិនមែនត្រូវការចរចាតែជាមួយ សីហនុ មួយទេ គឺ ឯកឧត្តម ត្រូវការចរចាជាមួយ ខៀវ សំផន និង សឺន សាន ដែរ ប្រពន្ធខ្ញុំ ម៉ូនិក ជាសាក្សីស្រាប់ ដូច្នេះទើបខ្ញុំហៅខ្មែរក្រហម និង សឺន សាន ចូលរួម។ ការប្រជុំថ្ងៃស្អែក មានឯកឧត្តម ហ៊ុន សែន ឯកឧត្តម សឺន សាន អោក សាគុណ តំណាងអោយ ខៀវ សំផន រណឫទ្ធិ តំណាងអោយហ៊្វុនស៊ីនប៉ិច ឯខ្ញុំ (សីហនុ) ជាភាគីមួយនៅកណ្តាល ឬនៅពីលើគេ។ ខ្ញុំ (ហ៊ុន សែន) បានចោទសួរថា តើនេះជាការប្រជុំបញ្ចភាគី (ប្រាំភាគី) ឬ? សម្តេច សីហនុ ឆ្លើយថា ទេមិនមែនទេ ជាប្រជុំចតុភាគី បើឯកឧត្តមមិនអោយខ្ញុំចូល ខ្ញុំដកខ្លួនចេញ។ ខ្ញុំ (ហ៊ុន សែន) ឆ្លើយវិញថា បើសម្តេចដកខ្លួនថយ ទូលបង្គំក៏ដកខ្លួនថយដែរ ហើយចាត់តាំងតំណាងទូលបង្គំអោយចូលរួមប្រជុំដូចសម្តេចចាត់ រណឫទ្ធិ និងខៀវ សំផន ចាត់ អោក សាគុណ អោយចូលប្រជុំដែរ។

ចុងក្រោយយើងបានលើកឡើងនូវរូបមន្តបី ទីមួយៈ សំរេចការប្រជុំហ៊ុន សែន-សីហនុ លើកទីបីជាមុនសិន ទីពីរៈ បើកការប្រជុំចតុភាគីថ្នាក់បច្ចេកទេសនៃតំណាងរបស់ភាគីទាំង ៤ ព្រោះ អោក សាគុណ តំណាង ខៀវ សំផន មិនអាចចូលរួមថ្នាក់កំពូលបានឡើយ ទីបីៈ បើកប្រជុំកំពូលចតុភាគី ប្រសិនខៀវ សំផន ចូលរួម ហើយប្រជុំកំពូលត្រីភាគី ប្រសិន ខៀវ សំផន មិនចូលរួម។ សម្តេច សីហនុ បានយល់ព្រមតាមរូបមន្តទាំងបីនេះ ហើយចាត់ចែងអោយប្រាប់ទៅតំណាងខ្មែរក្រហមនៅអគ្គការអ៊ុយណេស្កូ នៅប៉ារីស។ ក្រោយបន្តិច យើងបានទទួលពត៌មានថា តំណាងខ្មែរក្រហមគ្មានបទបញ្ជាអោយចូលរួមប្រជុំថ្នាក់បច្ចេកទេសនៃតំណាងភាគីទាំង ៤ ទេ ហើយក៏គ្មានដំណឹងពី ខៀវ សំផន ដែរ ដូច្នេះ យើងឯកភាពជាមួយសម្តេច សីហនុ ថា ត្រូវប្រជុំកំពូលត្រីភាគី ហ៊ុន សែន-សីហនុ-សឺន សាន នៅថ្ងៃទី ០៧ វិច្ឆិកា ១៩៨៨។ គ្រាន់តែបញ្ហាទីកន្លែងប្រជុំ និងរូបភាពនៃការប្រជុំ ក៏មានការតស៊ូយ៉ាងតឹងតែងរួចស្រេចទៅហើយ អ្វីៗ កើតឡើងដោយសារខ្វះការគោរពនូវការព្រមព្រៀង ហើយខ្វះសមភាពរវាងដៃគូចរចាដែលវាបានបង្កើតទៅជាការរអាក់រអួលនៃដំណើរការចរចា ហើយបង្កើតនូវភាពអាម៉ាស់សំរាប់ជាតិខ្មែរទៀតផង។

ការចរចាកំពូលត្រីភាគីបានចាប់ផ្តើម ហើយបញ្ចប់ទៅវិញក្នុងបរិយាកាសស្និទ្ធស្នាលខាងរូបភាព និងតឹងតែងខាងខ្លឹមសារ ប៉ុន្តែក៏បានឯកភាពគ្នាចុះហត្ថលេខា ចេញនូវសេចក្តីប្រកាសរួមដែលចំណុចសំខាន់គឺការបង្កើតឡើងនូវគណៈកម្មការការងារមួយ ដើម្បីសិក្សារកលទ្ធភាពនៃដំណោះស្រាយសំរាប់បញ្ហាកម្ពុជា ដែលជាការបង្កើតឡើង

នូវវេទិកាសំរាប់ដោះស្រាយបញ្ហាផ្ទៃក្នុងកម្ពុជា ដែលបញ្ហានេះគ្មានវេទិកាអន្តរជាតិណាមួយអាចដោះស្រាយជំនួសបាន នោះគឺជាការបើកឡើងនូវដំណាក់កាលចរចារវាងភាគីខ្មែរជាមួយគ្នា ហើយដែលបានពង្រីកក្របខ័ណ្ឌពីវេទិកា ហ៊ុន សែន-សីហនុ មកកាន់វេទិកា ហ៊ុន សែន-សីហនុ-សឺន សាន និងទុកទ្វារអោយនៅចំហសំរាប់ការចូលរួមរបស់ខ្មែរក្រហម ប្រសិនបើគេចង់ចូលរួមៗ

ក្រៅពីការបង្កើតបាននូវគណៈកម្មការការងារ ដែលជាតុពិតគឺការបង្កើតនូវវេទិកាផ្ទៃក្នុងកម្ពុជា ដែលចាត់ទុកថា ជាជំហានជឿនលឿនទៅមុខនោះ យើងពិនិត្យឃើញថាមានជំហានថយក្រោយខាងខ្លឹមសារបើប្រៀបធៀបជាមួយខ្លឹមសារ ដែលសំរេចបានតាមរយៈនៃការប្រជុំក្រៅផ្លូវការនៅ ហ្សាការតា ដែលពេលនោះមានលើកឡើងពីទំនាក់ទំនងនៃបញ្ហាជាច្រើន ក្នុងក្របខ័ណ្ឌដំណោះស្រាយនយោបាយមួយៗ ទាំងសម្តេច សីហនុ ទាំង សឺន សាន សុទ្ធតែបានខិតខំកាត់ផ្តាច់នូវទំនាក់ទំនងរវាងការដកកងទ័ពវៀតណាម ជាមួយនឹងការទប់ស្កាត់មិនអោយរបបប្រល័យពូជសាសន៍ ប៉ុល ពត វិលត្រឡប់មកវិញ កាត់ផ្តាច់ប្រតិទិននៃការដកកងទ័ពវៀតណាម ជាមួយនឹងការបញ្ឈប់ជំនួយយោធាអោយបណ្តាភាគីខ្មែរបដិបក្ខ ហើយខិតខំទទូចទាមទារអោយមានតួនាទីខាងនយោបាយ និងយោធារបស់ខ្មែរក្រហម ក្នុងដំណោះស្រាយនយោបាយ ព្រមពេលដែលទាមទារអោយរំលាយចោលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលជាកម្លាំងទប់ដ៏សំខាន់បំផុត និងជាកម្លាំងប្រឆាំងតែមួយគត់ ចំពោះការវិលត្រឡប់របស់ ពួក ប៉ុល ពត ហើយការទាមទារនេះគ្មានអ្វីក្រៅពីការបើកទ្វារសំរាប់ អោយ ប៉ុល ពត

ធ្វើការកាប់សម្លាប់ប្រជាជនសាជាថ្មី និងជាអំពើនាំទៅរកការរំលោភលើសិទ្ធិសំរេចរបស់ប្រជាជនកម្ពុជា។ តាមការសង្កេត ចំពោះជំហររបស់សម្តេច សីហនុ មានការថយក្រោយបើប្រៀបធៀបជាមួយជំហរគាត់កាលពីខែ កក្កដា និងសីហា ១៩៨៨ ដែលពេលនោះ គាត់ប្រឆាំង និងទាមទារយ៉ាងខ្លាំងអោយកំចាត់ចោលពួកខ្មែរក្រហម ប៉ុល ពត រហូតដល់លើកពីលទ្ធភាពនៃការធ្វើសម្ព័ន្ធភាពជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជា ទាំងនយោបាយ និងយោធា ដើម្បីកំចាត់ខ្មែរក្រហម។ ជំហរនេះ ត្រូវបានដកថយតាំងពី តេង ស៊ីវពីង សរសេរលិខិតព្រមានចំពោះគាត់ ប្រហែលជាចុងខែកញ្ញា ឬដើមខែតុលា ១៩៨៨ ដែលធ្វើអោយគាត់គិតគូរយ៉ាងខ្លាំង ហើយមិនអាចរកការស្រុះស្រួលណាមួយអោយចេញផុតពីគោលជំហររបស់ចិនឡើយ ហើយដែលប្រការនោះ បាននាំទៅដល់ការផ្សងព្រេងជាមួយខ្មែរក្រហម ប៉ុល ពត ដែលគាត់ខិតខំការពាររក្សាអោយបាននូវតួនាទីខាងយោធារបស់ពួក ប៉ុល ពត ក្នុងដំណោះស្រាយនយោបាយ រហូតដល់ទីបំផុត គាត់មិនហ៊ាននិយាយចំឈ្មោះរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅក្នុងសេចក្តីប្រកាសរួមនៃសម័យប្រជុំផង។

អាស្រ័យដោយស្រវឹងនឹងការគាំទ្ររបស់អាស៊ាន និងបណ្តាប្រទេសប៉ែកខាងលិច ពិសេសចំពោះជំនួយយោធារបស់អាមេរិក គាត់ខិតខំនិងប្រើប្រាស់កម្លាំង ប៉ុល ពត ធ្វើជាកម្លាំងទប់ ហើយទាញពេលដើម្បីកសាងកម្លាំងយោធាអោយខ្លួនគាត់ ដូច្នេះគាត់ព្យាយាមនឹងកាត់ផ្តាច់ការដកកងទ័ពវៀតណាម ជាមួយនឹងការបញ្ឈប់ជំនួយយោធាពីខាងក្រៅអោយបណ្តាភាគីខ្មែរបដិបក្ខ ទោះបីភាគីយើងសំរេចចិត្តថា យើងក៏យល់ព្រមឈប់ទទួលជំនួយយោធាពីបរទេសដែរ គាត់បែរជាបើក

លទ្ធភាពអោយសាធារណរដ្ឋប្រជាមានិតកម្ពុជាទទួលជំនួយយោធា ពីបរទេសទៀតចុះ ដែលជាអំពើនាំទៅដល់ការបន្ថែមនូវលទ្ធភាពនៃការផ្ទុះសង្គ្រាមកាន់តែធំ ហើយដែលវាផ្ទុយពីបំណងផ្សះផ្សារជាតិអោយបានឆាប់ បញ្ចប់ទុក្ខវេទនារបស់ប្រជាជនកម្ពុជាអោយបានឆាប់។

ក្រោយការប្រជុំមិនបានសំរេចជោគជ័យ ទាំងសម្តេច សីហនុ ទាំង សឺន សាន សុទ្ធតែបានទម្លាក់កំហុសអោយ ហ៊ុន សែន ថាមិនបានគិតដល់ផលប្រយោជន៍របស់ប្រជាជនកម្ពុជា ហើយគិតតែពីប្រយោជន៍របស់វៀតណាម និងសូវៀត ក្នុងពេលដែលគាត់រំលោភយ៉ាងកម្រោល ទៅលើផលប្រយោជន៍ប្រជាជនកម្ពុជា តាមរយៈនៃការទាមទារបើកច្រកសំរាប់ការវិលត្រឡប់នៃរបប ប៉ុល ពត ដើម្បីសម្លាប់ប្រជាជន សាជាថ្មី ហើយដែលក្រុមទាំងពីរគ្មានក្រុមណាមួយ ហ៊ានប្រឆាំងជាមួយ ប៉ុល ពត ហើយថែមទាំងគាំទ្រនូវពួក ប៉ុល ពត ទៀតផង។ ពាក្យសំដីដែលគាត់លើកឡើងនៅពេលប្រជុំថា "**បើគ្មានការចូលរួមពីកងទ័ពខ្មែរក្រហមទេ ចិននឹងមិនយល់ព្រមទេ**" តើពាក្យនេះដើម្បីចិន ឬដើម្បីប្រជាជនកម្ពុជា? ឯពាក្យរបស់ ហ៊ុន សែន ថាវិញគឺ "**តើដោះស្រាយបញ្ហាកម្ពុជា ត្រូវគិតផលប្រយោជន៍ប្រជាជនកម្ពុជា ឬគិតផលប្រយោជន៍ចិន បើអោយកងទ័ពខ្មែរក្រហមចូលរួមដើម្បីតម្រូវចិត្តចិន និងខ្មែរក្រហម វាអន្តរាយដល់អាយុជីវិតប្រជាជនកម្ពុជា**" តើពាក្យនេះដើម្បីវៀតណាម និងសូវៀត ឬដើម្បីផលប្រយោជន៍ប្រជាជនកម្ពុជា?

បញ្ហាឧបសគ្គសំខាន់សំរាប់ការដោះស្រាយបញ្ហាកម្ពុជា គឺ ចិន និងខ្មែរក្រហម ពិតមែនតែគេមិនមែនជាកូនសោតែមួយគត់ក្នុងការដោះស្រាយបញ្ហាកម្ពុជា តែគេនៅតែមានលទ្ធភាពធ្វើជាឧបសគ្គសំរាប់កិច្ច

ដំណើរការស្វែងរកសន្តិភាពអោយកម្ពុជា។ ក្រៅពីខ្មែរក្រហមមិនចូលរួមចរចាអស់ពីរលើករួចមកហើយ ចិនក៏មានលទ្ធភាពនឹងដាក់ការគាបសង្កត់ទៅលើសម្តេច សីហនុ និង សឺន សាន តាមរយៈគំរាមកំហែង កាត់ជំនួយ ដើម្បីកំរិតសកម្មភាពក្រុមទាំងពីរក្នុងរង្វង់ត្រួតត្រារបស់ចិន។ ពេលខាងមុខ ការចូលរួមក្នុងគណៈកម្មការការងារ និងការចូលរួមប្រជុំកំពូលលើកក្រោយ ក៏ដូចជាការចូលរួមរបស់ខ្មែរក្រហម ក្នុងការប្រជុំក្រៅផ្លូវការនៅ ហ្សាការតា លើកទី ២ បានក្លាយជាបច្ចុប្បន្នភាពមួយដែលលើកយកទៅពិភាក្សា ហើយក៏ជាការព្រួយបារម្ភរបស់ ឥណ្ឌូនេស៊ីដែលជាប្រទេសត្រូវរៀបចំការប្រជុំក្រៅផ្លូវការលើកទី ២ផងដែរ ដូច្នេះ ចិន និងខ្មែរក្រហម នៅតែជាឧបសគ្គសំខាន់ ក្នុងដំណើរការសន្តិភាពនៅកម្ពុជា។ ថ្ងៃ ២៥ វិច្ឆិកា ១៩៨៨ ខៀវ សំផន បានផ្ញើទូរលេខទៅសម្តេច សីហនុ ថា គេនឹងចូលប្រជុំលើកក្រោយ ហើយចាត់អោយ អោក សាគុណ ចូលរួមក្នុងគណៈកម្មការការងារ ប៉ុន្តែគេនៅតែមានការសង្ស័យព្រោះគេធ្លាប់ធ្វើរបៀបនេះ នៅហ្សាការតា កន្លងមកដែរ។

**ផ្នែកទី ២**

# ការអភិវឌ្ឍន៍ លើវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ រយៈពេល ១០ ឆ្នាំ ភាពចាំបាច់ និងកិច្ចការត្រូវដោះស្រាយ

## សមិទ្ធិផល ១០ ឆ្នាំ ខាងវិស័យ
## សេដ្ឋកិច្ច និងកិច្ចការត្រួវបន្ត

*ឥឡូវនេះ យើងពិនិត្យឡើងវិញនូវសមិទ្ធិផល ១០ ឆ្នាំ ក្នុងវិស័យសេដ្ឋកិច្ច និងជីវភាពប្រជាជន។*

*ប្រជាជនកម្ពុជា ទោះជាសព្វថ្ងៃកំពុងរស់នៅក្នុងប្រទេសក្តី ឬកំពុងរស់នៅឯបរទេសក្តី សុទ្ធតែបានដឹងថា របប ប៉ុល ពត បានអនុវត្តនយោបាយទុរគតភាវូបនីយកម្មនៅទូទាំងប្រទេស។ ប្រជាជនត្រូវបានជម្លៀសពីទីក្រុង ទីប្រជុំជនទៅកាន់ជនបទចុងកាត់មាត់ញក ហើយពីកន្លែងមួយទៅកាន់កន្លែងមួយទៀត ប្រជាជនជាទូទៅត្រូវបានគេដាក់អោយស្ថិតនៅក្នុងបរិវេណប្រមូលផ្តុំ ធ្វើរួមស៊ីរួម។ ដូច្នេះ ប្រជាជនកម្ពុជាគ្មាននៅសេសសល់កម្មសិទ្ធិអ្វីទេ តាំងពីមធ្យោបាយ និងឧបករណ៍ផលិតកម្ម រហូតដល់ផ្ទះសម្បែង និងសម្ភារៈប្រើប្រាស់ សូម្បីតែចាន ស្លាបព្រា ឆ្នាំង ។ល។ ក៏គ្មានផង។ ប្រជាជនមានសិទ្ធិត្រឹមតែបញ្ចេញកម្លាំងពលកម្មដ៏សែនវេទនា ដើម្បីប្តូរមកវិញនូវការហូបចុកដ៏សែនខ្វះខាត និងស្រេកឃ្លាន។ ឯផលដែលបានមកពីកម្លាំងពលកម្មរបស់យើងគ្រប់ៗ គ្នា គឺអាស្រ័យលើអង្គការជាអ្នកចាត់ចែង។*

*បណ្តារោងចក្រ សហគ្រាស នៅតាមទីក្រុងត្រូវបិទទ្វារ ឬបំផ្លាញ។ រូបិយវត្ថុត្រូវបោះបង់ចោលលែងប្រើការ ហើយប្រទេសជាតិគ្មានចរាចរទំនិញ គ្មានទីផ្សារ គ្មានការផ្លាស់ប្តូរទំនិញ ដែលយើងអាចនិយាយ*

សង្ខេបថា ការទាក់ទងផលិតកម្មនាពេលនោះ គឺជាការទាក់ទងផលិតកម្មរវាងម្ចាស់ទាសករ និងទាសករ ពោលគឺ អង្គការជាម្ចាស់ទាសករ ឯប្រជាជនកម្ពុជា តាំងពីកុមារដល់មនុស្សចាស់ជរា គឺជាទាសករទាំងអស់។

ប្រការគួរអោយព្រឺខ្លាចបំផុត ដែលយើងបានជួបប្រទះ ក្រោយពេលរំដោះថ្ងៃ ៧ មករា ១៩៧៩ ដែលពួក ប៉ុល ពត បានបន្សល់ទុក គឺការអត់ឃ្លានដែលបានគំរាមកំហែងជីវិតប្រជាជន មិនមែនតែក្នុងគ្រួសារមួយ ឬភូមិ ឃុំ ស្រុក ខេត្តមួយនោះទេ តែគឺទូទាំងប្រទេសទាំងមូល។

ក្រៅពីអ្នកបានស្លាប់រួចទៅហើយ អ្នកនៅសេសសល់ត្រូវស្ថិតក្នុងស្ថានភាពបាក់កម្លាំងជាទូទៅ។ ក្រោយពេលរំដោះរួច ប្រជាជនបាននាំគ្នាបំផ្លាញចោលនូវរបបធ្វើការប្រមូលផ្តុំ ធ្វើរួមស៊ីរួម គេនាំគ្នាចែកមធ្យោបាយផលិតកម្ម ចែកសម្ភារៈប្រើប្រាស់ ចែកស្បៀង ដែលនៅសេសសល់បន្តិចបន្តួច ក្នុងជង្រុករួមដែល ប៉ុល ពត បានប្រមូលទុក។ កន្លែងជាច្រើន គ្មានទាំងស្រូវនៅសេសសល់ផង ដោយពួកវាបំផ្លាញចោលអស់មុនពេលវារត់ មានទាំងការដុតស្រូវចោលរាប់ពាន់ហិកតា ដែលកំពុងទុំនៅក្នុងស្រែផង (ស្រូវទាំងនេះងាយឆេះ ព្រោះជារដូវប្រាំង)។ ប្រជាជនរាប់ម៉ឺននាក់ទៀត ដែលត្រូវពួក ប៉ុល ពត ជម្លៀសចូលព្រៃ ឡើងភ្នំ ឬទៅព្រំដែនកម្ពុជា ថៃ គ្មានទាំងបានចែកសម្ភារៈ ឬស្បៀងអ្វីនឹងគេផង។ ឯអ្នកដែលបានចំណែកសម្ភារៈ និងស្បៀងពីសហករណ៍របស់ ប៉ុល ពត ក៏គ្មានបានអ្វីជាធំដុំដែរ គ្រួសារខ្លះបានគោខ្លះរទេះ បាននង្គ័ល ឬនាស់ខ្លះគោក្របី បានចានខ្លះឆ្នាំង។ល។

បានរំដោះហើយតើត្រូវទៅណា ហើយត្រូវធ្វើអ្វី ក្នុងស្ថានភាពសល់

តែបាតដៃទទេ ហើយស្ថិតក្នុងការអត់ឃ្លានយ៉ាងនេះ? ចង់បង្កបង្កើនផលកសិកម្ម ជំហានដំបូងនេះ ក៏ធ្វើមិនបានផង ព្រោះចំខែប្រាំងគ្មានទឹក។ កន្លែងដែលមានទឹកអាចធ្វើស្រែប្រាំងបាន បែរជាខ្វះមធ្យោបាយ ខ្វះពូជធារ។ ជាងនេះទៅទៀត ជំហានដំបូងនេះ ការចាំបាច់របស់គ្រួសារនិមួយៗ គឺត្រូវវិលត្រឡប់មកកាន់ភូមិកំនើត មកជួបជុំគ្រួសារ បន្ទាប់ពីពួក ប៉ុល ពត បានជម្លៀសក្នុងពេលដែលពួកវាកាន់អំណាច។ ដូច្នេះ ទូទាំងប្រទេសស្ទុសឹងជាអ្នកភៀសខ្លួនលើទឹកដីរបស់ខ្លួន មានតែគ្រួសារមួយចំនួនទេ ដែលមិនត្រូវជម្លៀស ហើយគេមិនចាំបាច់ធ្វើដំណើរទៅទីណាផ្សេងទៀត តែក្នុងនេះក៏មានគ្រួសារមួយចំនួន ត្រូវធ្វើដំណើរស្វែងរកញាតិមិត្ត កូនចៅ ឪពុកម្តាយ។ល។ ដែលត្រូវព្រាត់ប្រាសដែរ។

នៅតាមផ្លូវតូច ផ្លូវធំ តាមទីក្រុង ទីប្រជុំជន និងជនបទ ទូទាំងប្រទេស យើងបានជួបទិដ្ឋភាពប្រហាក់ប្រហែលគ្នា គឺមនុស្សដើរទាំងហ្វូងៗ ក្នុងភាពហេវហត់ ស្គមស្គាំងស្លេកស្លាំង សម្លៀកបំពាក់រហែករយ៉ៃ អ្នកខ្លះដើរដោយគ្មានស្បែកជើងផង នាំកូនចៅធ្វើដំណើរតម្រង់ទៅស្រុកកំណើត។

ប៉ុន្មានខែដំបូងនេះ ប្រហែលជា ៨០ ភាគរយនៃចំនួនប្រជាជន គ្មានបានបង្កបង្កើនផលអ្វីទេ។ ដំណាក់កាលនេះ អង្ករមានតម្លៃជាងមាសពេជ្រទៅទៀត។ គ្រួសារខ្លះ ដែលបានខិតខំលួចលាក់ទុកមាស ពេជ្រខ្លះពីសម័យ ប៉ុល ពត ក៏បានយករបស់នេះ ដូរជាមួយអង្ករ ឬពោតជាមួយគ្រួសារខ្លះ ដែលមានស្បៀងបន្តិចបន្តួច។ គ្រួសារខ្លះក៏គ្មានអ្វីសោះតែម្តង។

*បញ្ហាដ៏ធ្ងន់ធ្ងរនេះ ត្រូវធ្លាក់មកលើរដ្ឋាភិបាលថ្មីជាអ្នកដោះស្រាយ។ តើយើងបានដោះស្រាយយ៉ាងណា? ហើយពីពេលនោះមកដល់ពេលនេះ តើមានជំហានរីកចំរើនយ៉ាងណា?*

*រយៈពេលដំបូងនេះ រដ្ឋាភិបាលយើងក៏គ្មានអ្វីដែរ។ ខុសប្លែកពី លន់ នល់ ដែលទទួលតំណពីសម្តេច សីហនុ ខុសប្លែកពី ប៉ុល ពត ដែលទទួលដំណពី លន់ នល់ រដ្ឋាភិបាលយើងបានទទួលតំណពីរបបមួយដែលគ្មានបានបន្សល់ទុកអ្វីក្រៅពីផលវិបាករាប់មិនអស់ ដែលយើងត្រូវដោះស្រាយ។ ដោយឡែក ស្បៀង ពេលវាយរំលំរបប ប៉ុល ពត កងទ័ពយើងដណ្តើមយកបាននូវស្បៀងខ្លះ ដែលពួកវាបំផ្លាញមិនទាន់ ប៉ុន្តែ ចំនួននេះតិចតួចណាស់ បើប្រៀបធៀបនឹងចំនួនប្រជាជនរាប់លាននាក់ ដែលកំពុងជួបប្រទះនឹងការអត់ឃ្លាន។*

*គោលការណ៍ ១១ ខ របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងគោលការណ៍ផ្សេងៗ ទៀត ដែលក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាបានដាក់ចេញនៅគ្រាដំបូង មានភាពត្រឹមត្រូវណាស់ សំរាប់ការរស់រានរបស់ប្រជាជនយើង។ ការជួយគ្នាក្នុងគ្រាក្រ គឺជាទម្លាប់របស់ប្រជាជនយើង ហើយដែលយើងបានអនុវត្តយ៉ាងល្អ ក្នុងដំណាក់កាលដ៏លំបាកនេះ។ ពិតមែនតែមានគ្រួសារខ្លះ បានឆ្លៀតយកចំណេញតាមរយៈនៃការយកស្បៀងដើម្បីដូរយកមាស ឬត្បូងមានតម្លៃក៏ដោយចុះ ក៏នេះនៅតែជាវិធីដ៏ល្អដែលគេត្រូវជ្រើសរើស ដោយឈរលើការព្រមព្រៀងរវាងគ្នាដើម្បីរស់ ហើយនេះក៏ជាជំហានដំបូងនៃការចាប់ផ្តើមការផ្លាស់ប្តូរទំនិញ ដែលមិនធ្លាប់មានក្នុងរបបប្រល័យពូជសាសន៍។ ប៉ុន្តែ ជាមូលដ្ឋាន និងជាទូទៅ ប្រជាជនបានជួយគ្នា មិនមែនគ្រាន់តែស្បៀងប៉ុណ្ណោះទេ*

*គឺថែមទាំងបានជួយផ្តល់ផ្ទះសំណាក់ ជួយព្យាបាលជំងឺ ចំពោះអ្នកធ្វើដំណើរឆ្លងកាត់ទៅរកភូមិកំណើត ជួយគ្នាក្នុងផលិតកម្ម ជំហានដំបូង និងរហូតដល់ជួយចិញ្ចឹមថែទាំ ចំពោះជនចាស់ជរា ពិការ និងកុមារកំព្រាទៀតផង។ល។*

*រដ្ឋយើងក៏បានប្រើប្រាស់អស់នូវលទ្ធភាព និងវិធានការសរុប ដើម្បីដោះស្រាយការលំបាកទាំងនេះ ប៉ុន្តែដូចយើងបានដឹងរួចមកហើយថា រដ្ឋយើងគ្មានមូលដ្ឋានសម្ភារៈ ថវិកា ក្រៅពីស្បៀងដែលជណ្តើមបានបន្តិចបន្តួចពី ប៉ុល ពត ហើយដែលមួយផ្នែកត្រូវចិញ្ចឹមកងទ័ព និងអង្គភាពរដ្ឋ និងមួយផ្នែកទៀត ត្រូវយកទៅជួយប្រជាជន។*

*ក្នុងសភាពការណ៍តានតឹងនេះ ការជួយឧបត្ថម្ភពីប្រជាជនវៀតណាមមានសារៈសំខាន់ណាស់។ បក្ស និងរដ្ឋាភិបាលវៀតណាម បានផ្តល់ជាបន្ទាន់នូវជំនួយជាស្បៀងអាហារ ថ្នាំពេទ្យ សម្ភារៈប្រើប្រាស់ផ្សេងៗទៀតទៅចែកជូនប្រជាជនកម្ពុជា ដែលកំពុងខ្វះខាត។ ក្រៅពីជំនួយរបស់រដ្ឋាភិបាល យើងនៅបានឃើញជំនួយរបស់ប្រជាជនវៀតណាមតាមគ្រួសារនីមួយៗ រាប់សិបម៉ឺនកញ្ចប់ ផ្ញើតាមរយៈខេត្តវៀតណាមដែលជាសម្ព័ន្ធមេត្រីជាមួយខេត្តកម្ពុជា។ ជំនួយនេះ យើងឃើញកញ្ចប់ខ្លះមានអង្ករប្រហែល ១ គីឡូក្រាម អំបិលប្រហែល ១ ខាំ កញ្ចប់ខ្លះមានច្រើនជាងនេះ រហូតមានសម្លៀកបំពាក់ទៀតផង ដែលអាចអោយយើងសម្គាល់បានថា នេះជាជំនួយផ្ទាល់របស់គ្រួសារប្រជាជនវៀតណាមនីមួយៗ ផ្ញើជូនគ្រួសារកម្ពុជា។ រីឯកងទ័ពស្ម័គ្រចិត្តវៀតណាមនៅកម្ពុជា ក៏បានរួមចំណែកយ៉ាងច្រើន ក្នុងការដោះស្រាយការអត់ឃ្លាននៅកម្ពុជា។ បណ្តាអង្គភាពកងទ័ពវៀតណាម ទោះជាមានបទ*

បញ្ហា ឬគ្មានបទបញ្ជាពីថ្នាក់លើ ក៏សុទ្ធតែបានចែករំលែកស្បៀង អាហារ ថ្នាំសង្កូវជូនប្រជាជនកម្ពុជា រហូតដល់គេត្រូវទទួលចិញ្ចឹមទាំង ស្រុងអស់មួយរយៈពេល ចំពោះប្រជាជនដែលទើបរត់ចេញពី ប៉ុល ពត មុនពេលត្រឡប់ទៅភូមិកំណើត ត្រូវទទួលចិញ្ចឹមមនុស្សចាស់ជរា ដែលមិនអាចធ្វើដំណើរទៅណាបាន និងត្រូវចិញ្ចឹមថែទាំកុមារកំព្រា អស់ពេលដ៏យូរ ទម្រាំយើងបង្កើតបានមណ្ឌលកុមារកំព្រា។

ក្រៅពីជួយដោះស្រាយការហូបចុកជាបន្ទាន់ វៀតណាមនៅបាន ជួយជាបន្ទាន់ទៀត ចាប់តាំងពីឧបករណ៍ផលិតកម្ម រហូតដល់ពូជស្រូវ និងកសិផលផ្សេងទៀត ដើម្បីប្រជាកសិករអាចចាប់ផ្តើមបង្កើនផល ក្នុងរដូវវស្សាឆ្នាំ ១៩៧៩ និងបានបញ្ជូនជាបន្ទាន់ដែរ តាំងពីវិស្វករ អ្នក បច្ចេកទេស រហូតដល់កម្មករ ដើម្បីជួយស្តារឡើងវិញ នូវបណ្តារោង ចក្រ សហគ្រាសផលិតកម្ម។

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក៏បានជួយជាបន្ទាន់ ផងដែរដល់ប្រជាជននៅតាមខេត្តជាប់ព្រំដែនឡាវ និងក៏បានផ្តល់ជំនួយ បន្ទាន់មួយទៀត ដែលមានចំនួនយ៉ាងច្រើនជាស្បៀងអាហារ សម្ភារៈ ប្រើប្រាស់ ដែលសមមិត្ត សុផានុវង្ស សមាជិកការិយាល័យនយោបាយ មជ្ឈិមបក្សប្រជាជនបដិវត្តឡាវ ប្រធានរដ្ឋឡាវ នាំមកជូន ក្នុងឱកាស ទស្សនកិច្ចជាមិត្តភាព និងជាផ្លូវការនៅសាធារណរដ្ឋប្រជាមានិតកម្ពុជា នាខែ មីនា ឆ្នាំ ១៩៧៩។

សហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយមជាបងប្អូន ក៏ចាប់ផ្តើម ផ្តល់មកជាបន្ទាន់នូវស្បៀងអាហារ ថ្នាំសង្កូវ សម្ភារៈប្រើប្រាស់ ឧបករណ៍ និងមធ្យោបាយផលិតកម្ម រហូតដល់វត្ថុធាតុដើម ដែលជាជំនួយអាចអោយ

យើងចាប់ផ្តើមបាននូវសកម្មភាពផលិតកម្ម ផ្នែកឧស្សាហកម្ម សិប្បកម្ម។

ចូលដល់ឆ្នាំ ១៩៨០ ប្រទេសមួយចំនួនទៀត ក្នុងនោះមានទាំងឥណ្ឌាផង ព្រមទាំងអង្គការអន្តរជាតិ ជាអង្គការរបស់អង្គការសហប្រជាជាតិ ជាអង្គការមិនមែនរដ្ឋាភិបាល ក៏បានចាប់ផ្តើមផ្តល់ជំនួយជាបន្ទាន់អោយយើងដែរ។

ឆ្លងតាមរយៈនៃការប្រឹងប្រែងផ្ទាល់របស់ប្រជាជនកម្ពុជា គួបផ្សំនឹងការជួយឧបត្ថម្ភពីអន្តរជាតិ យើងបានជំនះជាបណ្តើរៗ នូវការអត់ឃ្លាន ហើយផលិតកម្មស្បៀងក្នុងឆ្នាំ ១៩៧៩-១៩៨០ ពិតមែនតែជួបប្រទះគ្រោះធម្មជាតិក៏ដោយ ក៏ជាលទ្ធផលគួរអោយកត់សម្គាល់ ដែលធ្វើអោយយើងសំរេចភារកិច្ចជាប្រវត្តិសាស្ត្រ ក្នុងការបញ្ចប់ការអត់ឃ្លាន ដែលបន្សល់ទុកពីរបប ប៉ុល ពត ក្នុងឆ្នាំ ១៩៨១ ហើយក៏ជាមូលដ្ឋានអោយយើងឈានឡើងដល់សព្វថ្ងៃនេះ។

ការបញ្ចប់ការអត់ឃ្លាន ចាំបាច់ត្រូវរាប់បញ្ចូលទៅក្នុងសមិទ្ធិផលបដិវត្ត ដែលយើងទទួលបាន ពិតមែនតែវាគ្មានបានបន្សល់ទុកនូវសំណង់អ្វីអោយយើងឃើញរហូតដល់សព្វថ្ងៃនេះមែន ប៉ុន្តែវាបានបន្សល់ទុកនូវជីវិតមនុស្ស ដែលបំរុងនឹងស្លាប់ដោយសារការអត់ឃ្លាន វាបានធ្វើអោយមនុស្សរាប់លាននាក់ដែលស្គមស្គាំង មានសុខភាពបរិបូណ៌ ដើម្បីបន្តជីវិតរស់នៅ ដើម្បីកសាងជីវិតថ្មី និងបង្កបានជាមូលដ្ឋានដ៏សំខាន់ ដើម្បីការរស់ឡើងវិញរបស់ទឹកដី និងប្រជាជនយើង។ នេះគឺជាជោគជ័យនៃមាគ៌ាសាមគ្គីជាតិ និងសាមគ្គីអន្តរជាតិ របស់បក្ស និងរដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ជោគជ័យដំបូងនេះបង្ហាញយ៉ាងច្បាស់នូវសមត្ថភាពនិងកម្លាំងរស់ដ៏អស្ចារ្យរបស់ប្រជាជន

យើង ដែលកម្លាំងនេះផុសចេញពីមនុស្សម្នាក់ៗ គ្រួសារនីមួយៗ ភូមិ ឃុំ ស្រុក ខេត្តនីមួយៗ រហូតដល់ទូទាំងប្រទេស ហើយក៏បានផ្តល់នូវបទពិសោធន៍យ៉ាងច្រើនសំរាប់យើងបន្តដំណើរទៅមុខទៀត។

ឥឡូវនេះ ខ្ញុំសូមលើកឡើងវិញអំពីទិដ្ឋភាពទូទៅ និងតាមផ្នែកនីមួយៗ ក្នុងវិស័យសេដ្ឋកិច្ច ដើម្បីកត់ត្រាទុកនូវគុណសម្បត្តិ និងចំណុចខ្វះខាត ដែលយើងបានឆ្លងកាត់ ក្នុងការស្តារ និងកសាងសេដ្ឋកិច្ចរយៈពេល ១០ ឆ្នាំកន្លងទៅ។

បញ្ហាគ្រប់គ្រងសេដ្ឋកិច្ច គឺជាបញ្ហាមួយដ៏ថ្មីថ្មោង សំរាប់បក្ស និងរដ្ឋយើង ដែលទើបបានកាន់អំណាច។ ជាងនេះទៅទៀត យើងបានចាប់ផ្តើមពីសង្គមមួយ ដែលគ្មានរចនាសម្ព័ន្ធខាងសេដ្ឋកិច្ច និងគ្មានរចនាសម្ព័ន្ធផ្សេងទៀត ពីភាពច្របូកច្របល់ ពីបាតដៃទទេ ព្រមពេលដែលយើងខ្វះកម្មាភិបាលខាងសេដ្ឋកិច្ច ហើយប្រជាជនកំពុងអត់ឃ្លានថែមទៀត។

ជាជំហានដំបូងនេះ ទស្សនៈអំពីការកសាងសេដ្ឋកិច្ច ស្ថិតក្នុងភាពខុសៗគ្នា។ មានមតិលើកឡើងថា យើងបានសំរេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យរួចទៅហើយ ដូច្នេះយើងអាចកសាងសេដ្ឋកិច្ចសង្គមនិយមតែម្តង ដោយអនុញ្ញាតិអោយមានតែសមាសភាពសេដ្ឋកិច្ចរដ្ឋ និងសេដ្ឋកិច្ចសមូហភាពបានហើយ ឯសេដ្ឋកិច្ចគ្រួសារ គឺស្ថិតក្នុងសមាសភាពបន្ទាប់បន្សំតូចតាចតែប៉ុណ្ណោះ ហើយមិនចាំបាច់អោយមានសេដ្ឋកិច្ចឯកជនទេ ព្រោះសមាសភាពសេដ្ឋកិច្ចឯកជន បានស្លាប់តាំងពីក្នុងរបប ប៉ុល ពត ទៅហើយ មិនត្រូវអោយវារស់ឡើងវិញទេ។ ការជំទាស់មិនអោយមានសេដ្ឋកិច្ចឯកជន បានអូសបន្លាយអស់រយៈពេលយ៉ាងយូរ ទោះជាលើ

ការដាក់ស្តែង សេដ្ឋកិច្ចឯកជនបានកើតមានឡើងតាំងពីជំហានដំបូង ហើយបានរីកដុះដាលជាបណ្តើរៗ នៅក្នុងវិស័យកសិកម្មៗ វិស័យសិប្បកម្ម វិស័យសេវាកម្មលក់ដូរ ដឹកជញ្ជូនៗលៗ ក៏យើងនៅតែមិនទទួលស្គាល់វាដែរ យើងអូសបន្ទាយរហូតដល់ចុងឆ្នាំ ១៩៨៤ ទើបអោយសច្ចាប័នទទួលស្គាល់សមាសភាពសេដ្ឋកិច្ចឯកជន នៅក្នុងឱកាសសន្និបាតកម្មាភិបាលទូទាំងប្រទេសរបស់បក្ស ពីថ្ងៃ ២ ដល់ថ្ងៃ ៩ វិច្ឆិកា ១៩៨៤ៗ ប៉ុន្តែយើងក៏គួរកត់សំគាល់ដែរថា ក្រៅពីទស្សនៈខាងលើនេះ ក៏មានទស្សនៈចង់បើកអោយសេដ្ឋកិច្ចឯកជនធ្វើសកម្មភាព ដោយចាត់ទុកសេដ្ឋកិច្ចឯកជនជាចំណែកដ៏សំខាន់មួយ ក្នុងការជំរុញផលិតកម្មបំរើសេចក្តីត្រូវការរបស់សង្គម ហើយមានបំណងប្រើប្រាស់អោយអស់នូវប្រេកពទុនបច្ចេកទេស និងពលកម្មរបស់ប្រជាជនយើងក្នុងការកសាងប្រទេសៗ ជុំវិញទស្សនៈស្តីពីការកសាងសេដ្ឋកិច្ច គឺបានលើកមកពិភាក្សាជាប្រចាំនៅក្នុងឱកាសប្រជុំធំៗ របស់បក្ស និងរដ្ឋៗ ឯការដឹកនាំចាត់ចែង គ្រប់គ្រងសេដ្ឋកិច្ច ក៏ស្ថិតក្នុងភាពលំបាក ដោយយើងមិនទាន់កំណត់អោយបានច្បាស់លាស់ៗ បើនិយាយពីរោងចក្រ ឬមូលដ្ឋានសេដ្ឋកិច្ចរដ្ឋផ្សេងទៀត គឺសុទ្ធតែចូលទៅក្នុងរបៀបគ្រប់គ្រងចំណាយគ្រប់ ចំណូលគ្រប់ ចំណេញខាតគឺជារឿងរបស់រដ្ឋទទួលខុសត្រូវៗ ក្នុងកសិកម្ម ក៏រៀបចំ មានចំណុចខុសៗ គ្នាដែរៗ

ចំពោះវិស័យកសិកម្ម ការងារនេះយើងត្រូវចាប់ផ្តើមពីការរៀបចំគោលការណ៍ខាងកសិកម្មផង ការរៀបចំចាត់តាំងផលិតកម្ម ដោយប្រមូលប្រជាជនអោយចេះជួយគ្នា ក្នុងផលិតកម្មផង និងដំណើរការដោះស្រាយមធ្យោបាយសម្ភារៈសំរាប់កសិកម្មផងៗ បើនិយាយពីការងារចលនាប្រជាកសិករអោយធ្វើស្រែចំការ គឺមិនមែនជាការពិបាកទេ

ព្រោះនេះជាការងារកសិករស្រាប់ទៅហើយ ប៉ុន្តែការពិបាកជាដំបូងនេះ គឺប្រជាជនអត់ឃ្លាន ឬខ្វះខាតស្បៀង ប្រជាជនកំពុងធ្វើដំណើរត្រឡប់ទៅភូមិកំណើត ឬស្វែងរកក្រុមគ្រួសារញាតិមិត្ត។ ការពិបាកមួយទៀត គឺការចាប់ផ្តើមធ្វើស្រែចំការដោយខ្វះកម្លាំងអូសទាញ ខ្វះឧបករណ៍ ខ្វះពូជជារ។ល។ គោ ក្របី មុនសង្គ្រាមមានជាង ៣ លានក្បាល ក្រោយរបប ប៉ុល ពត នៅសល់តែជាង ១ លានក្បាលប៉ុណ្ណោះ។ ក្រោយពេលរំដោះ គ្រួសារខ្លះបានយកគោ ឬក្របី ១ ក្បាល ឬ ១ នឹម ប៉ុន្តែគ្រួសារជាច្រើនគ្មានគោ ក្របី ហើយចាប់ផ្តើមបង្កើនផលដំបូង គឺត្រូវប្រើប្រាស់កម្លាំងមនុស្សកាប់ដីនឹងចប។ គ្រួសារខ្លះ ដែលប្តី ឬកូនប្រុស បានត្រូវ ប៉ុល ពត សម្លាប់ គឺនៅសល់តែកម្លាំងនារី ដែលត្រូវបំពេញតួនាទីជាបុរស ក្នុងការបង្កបង្កើនផល។ បន្ថែមលើនេះទៀត យើងត្រូវដោះស្រាយនូវបញ្ហាដីធ្លី។ ពួក ប៉ុល ពត បានប្រមូលដីស្រែចំការ ធ្វើជារបស់រួម តាមវិធីធ្វើប្រព័ន្ធភ្លឺស្រែ និងប្រឡាយ ហើយដែលខុសនឹងបច្ចេកទេស។ ឧទាហរណ៍ ដីមួយហិកតា ធ្វើស្រែតែមួយ ដីមួយគីឡូម៉ែត្របួនជ្រុង ធ្វើប្រឡាយព័ទ្ធជុំវិញ។ ដូច្នេះដីទាប និងដីខ្ពស់ នៅជាប់ជាមួយគ្នា មានភ្លឺស្រែតែមួយ ដែលតម្រូវអោយប្រជាជន ត្រូវលើកភ្លឺស្រែតូចៗ ឡើងវិញ ស្របទៅតាមស្ថានភាពដីទាប ឬខ្ពស់ ហើយត្រូវបិទ ឬទម្លាយចោលនូវព្រែកដែលពួក ប៉ុល ពត ជីក ឬបិទ ដែលនាំអោយលិចដំណាំ ឬខ្វះទឹក។ គ្រាន់តែការងារកែស្ថានភាពដីធ្លីនេះ ក៏យើងត្រូវប្រើប្រាស់ពលកម្មប្រជាជនអស់យ៉ាងច្រើន ដែលជាហេតុបង្អាក់ដល់ដំណើររីកចំរើន នៃការបង្កបង្កើនផល។

បក្ស និងរដ្ឋយើងបានយកចិត្តទុកដាក់ជាពិសេសដល់ផលិតកម្ម

*ស្បៀង សំខាន់ជាងគេគឺស្រូវ ហើយយើងក៏យល់បានអំពីស្ថានភាពពិតប្រាកដរបស់ប្រជាជន និងខឿនផលិតកម្ម ដែលចាំបាច់ត្រូវមានគោលការណ៍បំផុសចលនាប្រជាជនអោយចេះសាមគ្គីជួយគ្នា ក្នុងជីវភាពរស់នៅ និងក្នុងផលិតកម្ម។ ដូច្នេះហើយ បានជាយើងត្រូវដោះស្រាយនូវឧបករណ៍ សម្ភារៈកសិកម្មជូនប្រជាជនផង ហើយត្រូវដំណើរការរៀបចំឡើងនូវក្រុមសាមគ្គីបង្កបង្កើនផលកសិកម្មផង។ ន័យពិតប្រាកដដែលយើងចង់ធ្វើក្រុមសាមគ្គីបង្កបង្កើនផល គឺចង់ចលនាប្រជាជនអោយចេះជួយគ្នា អាចរស់បានទាំងអស់គ្នា ទាំងអ្នកមានពលកម្ម ទាំងអ្នកខ្វះខាតពលកម្ម ទាំងអ្នកមានគោក្របី និងមធ្យោបាយ ទាំងអ្នកគ្មានគោក្របី និងមធ្យោបាយ ដែលសភាពការណ៍តម្រូវអោយយើង ត្រូវតែធ្វើដូច្នេះ។ ប៉ុន្តែជាការគួរអោយស្តាយ មានកន្លែងមួយចំនួន អាស្រ័យដោយការយល់ដឹងពុំទាន់បានត្រឹមត្រូវ និងដោយសមត្ថភាពនៅខ្សោយរបស់កម្មាភិបាលនៅមូលដ្ឋាន ព្រមទាំងថ្នាក់លើណែនាំទៅថ្នាក់ក្រោមមិនបានគ្រប់គ្រាន់ផង ក៏ធ្វើអោយការចាត់តាំងរៀបចំក្រុមសាមគ្គីដំណើរការមិនបានល្អ ទាំងរូបភាព ទាំងខ្លឹមសារ។ ឧទាហរណ៍ក្រុមសាមគ្គីរៀបចំច្រើនគ្រួសារពេក ចាប់ពី ៣០, ៤០, ៥០ រហូតដល់ ៧៥ គ្រួសារក្នុងមួយក្រុម ដែលនាំអោយពិបាកគ្រប់គ្រង។ ឯខ្លឹមសារវិញ កន្លែងមួយចំនួនប្រទាញទៅរកខ្លឹមសារសហករណ៍កសិកម្ម ធ្វើរួមហើយចែកផលតាមពលកម្ម ដែលនាំដល់ការភ័យខ្លាចរបស់ប្រជាជន ហើយមិនបានជំរុញស្មារតីរបស់ប្រជាជនក្នុងការធ្វើម្ចាស់ ក្នុងផលិតកម្មបានទៀត។ កន្លែងមួយចំនួន អនុវត្តការចែកដីធ្លីតាមរបៀបចល័តផ្លាស់ប្តូរគ្រួសារ ឬក្រុមណាអោយធ្វើកន្លែងនេះនៅឆ្នាំនេះ ដល់ឆ្នាំក្រោយត្រូវ*

ទៅធ្វើកន្លែងផ្សេង ដែលជាហេតុធ្វើអោយប្រជាជនលែងគិតគូរដល់ការថែទាំភ្លឺស្រែ ទំនប់ ប្រឡាយ រហូតមិនទាំងដាក់ដីថែទាំដីស្រែទៀតផង។

យើងក៏បានកែសម្រួលជាបន្ទាន់នូវរូបភាពចាត់តាំង ដោយបន្ថយពីចំនួនរាប់សិបគ្រួសារមកនៅត្រឹមពី ១០ ទៅ ១៥ ឬខ្ពស់បំផុត ២០ គ្រួសារ ប៉ុណ្ណោះក្នុង ១ ក្រុម។ ឯខ្ទឹមសារវិញក៏នៅដំណើរការតាមការយល់ដឹងដោយឡែកៗ របស់មូលដ្ឋាន និងតាមការជាក់ស្តែងនៃកម្លាំងផលិតកម្មរបស់កន្លែងនីមួយៗ ដូច្នេះហើយបានជា ប៉ុន្មានឆ្នាំក្រោយនេះ យើងសង្កេតឃើញថា ក្រុមសាមគ្គីបានកើតជាច្រើនប្រភេទ ប្រភេទទី ១ ទី ២ ទី ៣ រហូតដល់ប្រជាកសិករមួយចំនួន មិនស្ថិតនៅក្នុងក្រុមសាមគ្គីណាមួយឡើយ គឺធ្វើការរកស៊ីតាមកម្លាំងគ្រួសារផ្ទាល់តែម្តង។ អាចនិយាយបានថា នោះជាដំណាក់កាលរាវរករបៀបរកស៊ីដែលជឿនលឿន ហើយដែលទីបំផុតគឺរបៀបធ្វើក្រុមសាមគ្គីមានចរិតជាវេរប្រវាស់ដៃ ជារបៀបដែលប្រជាជនចូលចិត្ត ជំរុញបានផលិតកម្មផង ហើយជួយគ្នាបានផង និងស្របតាមទំនៀមទំលាប់របស់ប្រជាជនយើងផង។ របៀបនេះ គឺចាប់ផ្តើមដំណើរការពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីកសិកម្ម ដែលគេត្រូវចែកដីអោយប្រជាកសិករតាមពលកម្មច្រើន ឬតិច និងស្របតាមបរិមាណដីមានច្រើន ឬតិច រួចហើយគេជួយផលិតគ្នាតាមរបៀបផ្លាស់ប្តូរ ពលកម្មជួយគ្នាទៅវិញទៅមកៗ គេមានការសម្រុះសម្រួលគ្នាយ៉ាងសមស្រប និងយោគយល់គ្នាពីកម្លាំងអូសទាញ។ ឧទាហរណ៍ អ្នកមានគោក្របី ទៅជួយភ្ជួររាស់អោយអ្នកគ្មានគោក្របី ១ ថ្ងៃ ដោយទៅទាំង ពលកម្មផ្ទាល់របស់គេ ទៅទាំងគោក្របី ទៅទាំងនង្គ័លរនាស់ រួចហើយអ្នកដែលត្រូវបានគេជួយនោះ

*ត្រូវមកសង់អ្នកទៅជួយនោះវិញ។ គេសម្រុះសម្រួលជួយគ្នាចំពោះចាស់ជរា គ្រួសារយុទ្ធជនពលី មរណៈ គ្រួសារយុទ្ធជននៅសមរភូមិមុខ។ល។ រហូតដល់គេប្រមូលធ្វើការរួម ដូចជាធ្វើជាពសាស្ត្រ ធ្វើផ្លូវ ស្ពាន សាលារៀន។ល។ គេបានទទួលផលនៅលើផ្ទៃដីដែលគ្រួសារគេបានធ្វើអាជីវកម្ម។ នេះជារបៀបធ្វើការដោយសាមញ្ញរបស់ប្រជាជន ក្នុងស្មារតីសាមគ្គីជួយឧបត្ថម្ភគ្នា និងក្នុងស្មារតី ធ្វើម្ចាស់លើការងារផលិតកម្ម។*

*សន្និបាតគណៈកម្មាធិការមជ្ឈិមបក្សលើកទី ៧ អាណត្តិទី ៤ ពីថ្ងៃទី ៩ ដល់ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៨៣ បានដាក់ចេញនូវសេចក្តីសំរេចចិត្តអំពីក្រុមសាមគ្គីបង្កបង្កើនផល ដែលស្មារតីរួមគឺជំរុញ និងពង្រីករបៀបរកស៊ីតាមរបៀបខាងលើ ដែលប្រជាជនយើងនិយមហៅថា ក្រុមសាមគ្គីប្រភេទទី ២។ ជាមួយនោះ មជ្ឈិមបក្សក៏បានកំណត់ថា ទោះជាក្រុមសាមគ្គីប្រភេទណាក៏ដោយ ក៏ត្រូវអនុវត្តភារកិច្ច ៣ គឺ ភារកិច្ចបង្កបង្កើនផល ភារកិច្ចការពារ និងភារកិច្ចអប់រំនយោបាយសតិអារម្មណ៍។ ចាប់ពីនោះមក សន្ទុះនៃផលិតកម្មស្បៀងមានការរីកចំរើនយ៉ាងខ្លាំង ហើយចលនាធ្វើជាពសាស្ត្រ ធ្វើប្រពលវប្បកម្មលើដំណាំស្រូវ ការប្រើប្រាស់ពូជថ្មី ការប្រើប្រាស់បច្ចេកទេស ការបង្កើនរដូវដាំដុះ ក៏រីកចំរើនគួរអោយកត់សម្គាល់។ បក្ស និងរដ្ឋយើង ក៏បានខិតខំដោះស្រាយទំនាស់អំពីការបាត់តុល្យភាពរវាងដីធ្លី និងចំនួនប្រជាជន ដោយបានផ្តល់ទុនយ៉ាងច្រើនក្នុងមួយឆ្នាំៗ ដើម្បីរុករាន និងស្តារដីថ្មី ប៉ុន្តែក៏នៅតែដោះស្រាយមិនទាន់រួច។ កន្លែងមានដីច្រើន តែមានប្រជាជនតិច ឯកន្លែងមានដីតិច តែប្រជាជនច្រើន។ កត្តាសន្តិសុខ និងគមនាគមន៍ ក៏ជាចំណោទមួយ ដែលធ្វើអោយយើងបែងចែកពលកម្មសង្គមឡើងវិញ*

មិនបានឆាប់ៗ

ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ បើយើងពិនិត្យមើលអំពីការរីកចំរើនក្នុងវិស័យកសិកម្ម ក៏អាចចាត់ទុកជាសមិទ្ធិផលគួរអោយកត់សម្គាល់ពិសេសវិស័យស្បៀង ដែលយើងបានបញ្ចប់ជាស្ថាពរនូវការអត់ឃ្លាន ហើយបំព្រួញបាននូវការបាត់តុល្យភាពរវាងសេចក្តីត្រូវការ និងការផ្គត់ផ្គង់ អោយមកនៅត្រឹមកំរិតតូច ដែលអាចទ្រាំទ្របានៗ

ខាងក្រោមនេះ គឺជាតួលេខប្រចាំឆ្នាំ នៃផ្ទៃដី និងផលប្រចាំឆ្នាំ៖

| ឆ្នាំ | ផ្ទៃដីស្រូវជាហិកតា | បរិមាណផល |
|---|---|---|
| ឆ្នាំ ១៩៧៩ | ៧៧០.៥១០ | ២៦៥.២២០ តោន |
| ឆ្នាំ ១៩៨០ | ១.៤៤១.៤៧០ | ១.៧១៥.៣១០ តោន |
| ឆ្នាំ ១៩៨១ | ១.៤៩១.៦៥០ | ១.៤៨៩.៦១០ តោន |
| ឆ្នាំ ១៩៨២ | ១.៦៨០.៣៥០ | ១.៩៨៩.២០០ តោន |
| ឆ្នាំ ១៩៨៣ | ១.៧៣៩.៨៦០ | ២.០៣៩.១៩០ តោន |
| ឆ្នាំ ១៩៨៤ | ១.៤១៦.៧៨០ | ១.២៥៨.២៥០ តោន |
| ឆ្នាំ ១៩៨៥ | ១.៥១៦.០០០ | ១.៧៨៩.៤៩០ តោន |
| ឆ្នាំ ១៩៨៦ | ១.៦១៨.១៩០ | ២.០៨៦.០៨០ តោន |
| ឆ្នាំ ១៩៨៧ | ១.៤២៧.២១០ | ១.៨១៣.៣៥០ តោន |

ចំពោះឆ្នាំ ១៩៨៨ ប៉ាន់ស្មានផ្ទៃដី និងទិន្នផលមានការកើនឡើងលើសពីឆ្នាំ ១៩៨៧ៗ ប្រៀបធៀបនឹងឆ្នាំនីមួយៗ មានការកើនឡើងទាប ឬខ្ពស់ អាស្រ័យដោយធាតុអាកាស ព្រោះថា កសិកម្មនៅប្រទេសយើងចំណុះស្ទើរទាំងស្រុងទៅនឹងធាតុអាកាស (ធម្មជាតិ) គឺជារឿង

រាល់ឆ្នាំយើងតែងជួបប្រទះនូវគ្រោះធម្មជាតិ បើមិនច្រើនក៏តិច បើមិនទូទៅក៏តាមដំបន់ដែរ ប៉ុន្តែធ្ងន់ធ្ងរជាងគេ គឺនៅឆ្នាំ ១៩៨០ និងឆ្នាំ ១៩៨៤។

កំណើនស្បៀងកើនឡើងជារៀងរាល់ឆ្នាំ ប៉ុន្តែក៏នៅដើរមិនទាន់កំណើនរបស់ប្រជាជន ដែលកើនឡើងក្នុងអត្រាប្រចាំឆ្នាំ ជិត ៣ ភាគរយ។ វិធានការសរុប ៣ យ៉ាង បាន និងកំពុងអនុវត្តជាទូទៅ ដើម្បីបង្កើនផលិតកម្មស្បៀង គឺវិធានការពង្រីកផ្ទៃដី បង្កើនរដូវដាំដុះ និងប្រពលវប្បកម្ម។ ស្បៀងជាមុខព្រួញសេដ្ឋកិច្ចសំខាន់ជាងគេដែលមហាសន្និបាតបក្សលើកទី ៥ បានកំណត់ ដែលត្រូវប្រើប្រាស់កម្លាំងសរុបដើម្បីសំរេចអោយបាន ៣ លានតោនក្នុងឆ្នាំ ១៩៩០ ហើយប្រជាជនមួយនាក់ គិតជាមធ្យមត្រូវទទួលបាន ៣៥០ គីឡូក្រាម។ នេះជាការតស៊ូពោរពេញទៅដោយការលំបាក ប៉ុន្តែប្រកបដោយក្តីរីករាយ ព្រោះគោលការណ៍ដែលបក្ស និងរដ្ឋបានដាក់ចុះ គឺសមស្របតាមចំណូលចិត្តរបស់ប្រជាជនយើងហើយ។

ក្រៅពីស្រូវ ដំណាំផ្សេងៗ ទៀត ដូចជា ដំណាំកសិផល និងដំណាំឧស្សាហកម្ម ក៏មានការរីកចំរើនគួរអោយកត់សំគាល់ ដែលធ្វើអោយរដ្ឋយើងមានប្រភពទំនិញ មិនគ្រាន់តែផ្គត់ផ្គង់ទីផ្សារក្នុងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមុខទំនិញនាំចេញ និងផ្គត់ផ្គង់ជាវត្ថុធាតុដើមអោយឧស្សាហកម្ម សិប្បកម្មទៀតផង។

ជាទូទៅ យើងពិនិត្យឃើញថាប្រជាជនដែលរស់នៅក្នុងដំបន់ផលិតកសិផល និងដំណាំឧស្សាហកម្ម មានការចាត់តាំងរកស៊ីស្រួលជាងដំបន់ផលិតស្រូវ ព្រោះនៅទីនោះ ការរៀបចំក្រុមសាមគ្គីបានធ្វើឡើងត្រឹមត្រូវជាងដំបន់ធ្វើស្រូវ ដោយជាទូទៅគេរៀបចំក្រុមសាមគ្គី ដែល

មានចរិតជួយគ្នា ដែលគេនិយមហៅថា ក្រុមប្រភេទទី ២។ ក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ យើងសង្កេតឃើញថា ពិតមែនតែរដ្ឋបានមានផែនការផលិតមុខកសិផលនេះប៉ុណ្ណេះ កសិផលនោះប៉ុណ្ណោះ ប៉ុន្តែជាការជាក់ស្តែង ប្រជាជនមិនផលិតតាមផែនការរដ្ឋទេ គឺគេផលិតទៅតាមសេចក្តីត្រូវការរបស់ទីផ្សារ និងទៅតាមថ្លៃ។ មុខកសិផលណា ដែលមានសេចក្តីត្រូវការច្រើន ហើយបានតម្លៃខ្ពស់ គឺគេនាំគ្នាផលិតកសិផលនោះ។ ដូច្នេះនេះក៏ជាទម្លាប់របស់ប្រជាជនដែលស្ថិតក្នុងដំណាក់កាលផលិតទំនិញ ជាទម្លាប់ដែលបានកើតមានតាំងពីយូរមកហើយ ហើយដែលគេមានលទ្ធភាពដើម្បីធ្វើ ព្រោះដីធ្លីដែលប្រជាកសិករផលិតកសិផល និងដំណាំឧស្សាហកម្មទាំងនោះ អាចផ្លាស់ប្តូរបានពីការផលិតមុខទំនិញមួយទៅកាន់ការផលិតមុខទំនិញមួយទៀត តាមគេចង់បាន ដែលខុសពីផ្ទៃដីធ្វើដំណាំស្រូវ។ ប៉ុន្តែ រដ្ឋ ដោយក្តាប់សភាពការណ៍ និងសំណូមពរនៃការផលិតមិនបានក៏ដាក់ផែនការផលិត តែគោលនយោបាយថ្លៃលើផលិតផលមួយចំនួនដែលរដ្ឋចង់បាន មិនបានលើកទឹកចិត្តដល់អ្នកផលិតទេ។ បន្ថែមលើនេះ ការប្រមូលទិញរបស់រដ្ឋក៏ធ្វើឡើងមិនបានល្អ នាំអោយឈ្មួញឆ្លៀតឱកាសដណ្តើមទិញប្រជែងជាមួយរដ្ឋបាន។ យើងបានអូសបន្លាយសភាពការណ៍នេះអស់រយៈពេលយ៉ាងយូរ ទើបយើងកែតម្រូវបាន ហើយផ្តើមចេញពីនេះបានជំរុញអោយការផលិតកសិផលនិងដំណាំឧស្សាហកម្មរីកឡូតមួយជំហានទៀត។

ប៉ុន្តែ ទន្ទឹមនេះ យើងគួរកត់សម្គាល់នូវការលំបាករបស់ប្រជាជនដែលរស់នៅក្នុងតំបន់ផលិតកសិផល និងដំណាំឧស្សាហកម្ម។ តំបន់នេះជាទូទៅ ស្ថិតក្នុងការបាត់តុល្យភាពរវាងផ្ទៃដី និងចំនួនប្រជាជន គឺ

ប្រជាជនចេះតែកើន ហើយផ្ទៃដីនៅដដែល ឬត្រូវបាត់បង់ ថែមដោយការកសាងផ្ទះសម្បែង ឬសំណង់ផ្សេងៗ។ ម្យ៉ាងទៀត តំបន់នេះស្ទើរតែជាទូទៅគ្មានការផលិតស្រូវទេ គេត្រូវធ្វើការផ្លាស់ប្តូរជាមួយតំបន់ផលិតស្រូវ។ ក្នុងពេលដែលរដ្ឋយើងមានវិធានការតឹងរ៉ឹងក្នុងការចរាចរស្រូវអង្ករ នាំដល់ការអនុវត្តន៍ជ្រុលហួសហេតុរបស់កម្មាភិបាលមូលដ្ឋានមួយចំនួន ដែលបង្កការលំបាកសំរាប់ប្រជាជនទាំងតំបន់ផលិតកសិផល ទាំងតំបន់ផលិតស្រូវ ព្រោះវាផ្ទុយនឹងគោលការណ៍ចរាចរ ផ្លាស់ប្តូរទំនិញរវាងតំបន់ផលិតមុខទំនិញខុសៗ គ្នា។ យើងសូមលើកឧទាហរណ៍ តំបន់ផលិតកសិផល និងដំណាំឧស្សាហកម្ម ត្រូវការស្រូវឯតំបន់ផលិតស្រូវត្រូវការត្រីប្រហុក ផ្អក មុង ភួយ ក្រមា និងសម្ភារៈប្រើប្រាស់ផ្សេងៗ ទៀត ដែលតំបន់ផលិតកសិផលមាន ហើយតាមទំនៀមទម្លាប់ គេធ្លាប់ផ្លាស់ប្តូរគ្នា លើកលែងតែក្នុងរបប ប៉ុល ពត ដែលគេមិនបានធ្វើ។ រដ្ឋគ្មានលទ្ធភាពដោះស្រាយស្រូវអង្ករអោយប្រជាជនក្នុងតំបន់ផលិតកសិផលទេ ហើយក៏គ្មានលទ្ធភាពដោះស្រាយដូចជាប្រហុក ផ្អក។ល។ អោយប្រជាជនតំបន់ផលិតស្រូវដែរ។ ដូច្នេះ ពេលកម្មាភិបាលនៅមូលដ្ឋានមួយចំនួន អនុវត្តវិធានការគ្រប់គ្រងទីផ្សារនៅមូលដ្ឋានហួសហេតុ ក៏បានបង្កឡើងនូវការលំបាកសំរាប់ តំបន់ទាំងពីរ ហើយក៏ជះឥទ្ធិពលមិនល្អដល់ផលិតកម្មនៃតំបន់ទាំងពីរទៀត។

ខ្ញុំចង់និយាយបន្ថែមអំពីជោគជ័យនៃការពង្រីកដំណាំក្រចៅ ដើម្បីបង្ហាញអំពីសារសំខាន់ នៃគោលនយោបាយគំនាស់ខាងសេដ្ឋកិច្ច គួបផ្សំនឹងការចាត់តាំងផលិតកម្ម។ នៅខេត្តបាត់ដំបង មានរោងចក្រផលិតសំបកបាវមួយយ៉ាងធំ ដែលបានកសាងឡើងមុនពេលសង្គ្រាម ហើយ

ដែលការផលិតរបស់រោងចក្រនេះ ផ្អែកលើវត្ថុធាតុដើមក្រចៅដាំនៅខេត្តបាត់ដំបងតែម្តង។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ រោងចក្រនេះ ត្រូវបានស្តារ ប៉ុន្តែខ្វះវត្ថុធាតុដើម។ រោងចក្របានដំណើរការប្រមូលគ្រាប់ពូជក្រចៅបានតែប៉ុន្មានគីឡូក្រាមប៉ុណ្ណោះ ដើម្បីចែកជូនប្រជាជនដាំ តែចលនាក្នុងជំហានដំបូងនេះ ស្ថិតក្នុងសភាពខ្សោយ។ ប៉ុន្មានឆ្នាំក្រោយមក រោងចក្រក៏ចាប់ផ្តើមម្ចាស់ការលើកឡើងនូវគោលនយោបាយខាងសេដ្ឋកិច្ច ដោយកំណត់ថ្លៃខ្ពស់ ផ្តល់សម្ភារៈមធ្យោបាយអោយប្រជាជន ផ្តល់ទុនអោយប្រជាជនខ្ចី ដោយមានការប្រាក់ទាប រហូតដល់លក់ស្បៀងជូនប្រជាជនថ្លៃទាប ព្រមទាំងចាត់តាំងប្រមូលទិញបានល្អពីប្រជាជនទៀត។ តាំងពីពេលនោះមក យើងឃើញល្បឿននៃដំណាំក្រចៅមានការរីកលូតលាស់យ៉ាងខ្លាំង ដែលមានលទ្ធភាពផ្គត់ផ្គង់ទាំងស្រុងនូវវត្ថុធាតុដើមដល់រោងចក្រ ដើម្បីផលិតបាវធានាបានការប្រើប្រាស់ក្នុងប្រទេស និងអាចនាំចេញបានមួយចំនួនទៀតផង ហើយដែលបញ្ហានេះ ពីឆ្នាំ ១៩៨១ ដល់ឆ្នាំ ១៩៨៥ រដ្ឋយើងត្រូវចំណាយពី ២ លាន ទៅ ២,៥ លានដុល្លារជារៀងរាល់ឆ្នាំ ដើម្បីនាំចូលសំបកបាវសំរាប់សេចក្តីត្រូវការក្នុងប្រទេស។

ចំពោះកៅស៊ូ ដែលជាដំណាំឧស្សាហកម្មដ៏សំខាន់របស់កម្ពុជា យើងបានចាប់ផ្តើមស្តារឡើងវិញចាប់ពីឆ្នាំ ១៩៨០ ដោយប្រើប្រាស់កម្លាំងផ្ទាល់ខ្លួនយើងផង និងដោយសហប្រតិបត្តិការជាមួយប្រទេសជាមិត្តផង ពិសេសសហភាពសូវៀត។

ចំការកៅស៊ូ និងបណ្តារោងចក្រកែច្នៃកៅស៊ូ ត្រូវទទួលការខូចខាតយ៉ាងធ្ងន់ធ្ងរពីការទម្លាក់គ្រាប់បែក គ្រាប់កាំភ្លើងធំរបស់ចក្រពត្តិអាមេរិក។

ពេល ប៉ុល ពត កាន់អំណាច ពួកវាក៏បានធ្វើអាជីវកម្មលើផ្ទៃដីមួយចំនួន ប៉ុន្តែអ្នកបច្ចេកទេសកៅស៊ូត្រូវបានពួកវាសម្លាប់អស់យ៉ាងច្រើន។ ក្រោយពេលរំដោះ យើងហាក់ដូចជាគ្មាននៅសល់អ្វីក្រៅពីដើមកៅស៊ូ ហើយតំបន់មួយចំនួនពោរពេញទៅដោយគ្រាប់មីន ដែលពួក ប៉ុល ពត បានដាក់មុនពេលពួកវាចាញ់សង្គ្រាមទៀតផង។ គ្រាដំបូង ដោយខ្វះការថែទាំ អ្នកខ្លះក៏បានទៅកាប់ដើមកៅស៊ូធ្វើជាអុសដុតចំអិនអាហារ។ អ្នកបច្ចេកទេស និងកម្មករដែលសល់ពីស្លាប់ ត្រូវស្ថិតក្នុងភាពបែកខ្ញែក កម្មាភិបាលគ្រប់គ្រងក៏មានតិច ហើយពេលវេលាក៏តម្រូវអោយយើងដំណើរការស្តារជាបន្ទាន់នូវអាជីវកម្មកៅស៊ូនេះ។

យើងត្រូវដំណើរការព្រមគ្នា នូវការរៀបចំក្បាលម៉ាស៊ីន ដឹកនាំគ្រប់គ្រង ជ្រើសរើសកម្មករ សង់លំនៅដ្ឋានជូនកម្មករ រៀបចំបំពាក់សម្ភារៈមធ្យោបាយសំរាប់ដំណើរការផលិត។ គ្រាដំបូងនេះ យើងជួបការលំបាកច្រើន ប៉ុន្តែយើងបានទទួលយ៉ាងពេញចិត្តនូវការឧបត្ថម្ភរបស់អ្នកបច្ចេកទេសវៀតណាម ដែលធ្លាប់មានបទពិសោធន៍អំពីអាជីវកម្មកៅស៊ូ ក្នុងចំណោមអ្នកបច្ចេកទេសទាំងនេះ មានមួយចំនួនធ្លាប់ធ្វើការជាមួយបារាំងក្នុងពេលបារាំងធ្វើអាជីវកម្មកៅស៊ូនៅកម្ពុជា ហើយដែលបានរត់គៀសខ្លួនទៅវៀតណាមក្នុងសម័យសង្គ្រាម និងសម័យ ប៉ុល ពត។ សមមិត្តទាំងនេះបានផ្តល់អោយយើង នូវបទពិសោធន៍អំពីការចាត់តាំងគ្រប់គ្រងអំពីបច្ចេកទេសអាជីវកម្ម។ គួបផ្សំនឹងកម្មាភិបាលបច្ចេកទេសយើងដែលនៅសេសសល់ យើងបានចាប់ផ្តើមជាជំហានដំបូង ក្នុងឆ្នាំ ១៩៨០ ហើយក៏នៅក្នុងឆ្នាំ ១៩៨០ នេះដែរ យើងបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការលើវិស័យកៅស៊ូ ជាមួយសហភាពសូវៀត ដែលជាជំណាក់កាលបើក

ផ្លូវ អោយយើងពង្រីកមូលដ្ឋានសម្ភារៈបច្ចេកទេសសំរាប់វិស័យកៅស៊ូរបស់យើង។

ចំការកៅស៊ូ ជាមូលដ្ឋានផលិតកម្មសំខាន់បំផុតរបស់រដ្ឋ សំរាប់ការនាំចេញ និងផ្គត់ផ្គង់វត្ថុធាតុដើមអោយឧស្សាហកម្ម និងសិប្បកម្មក្នុងប្រទេស។ យើងបានស្តារឡើងវិញនូវចំការកៅស៊ូចាស់ ក្នុងល្បឿនយ៉ាងលឿន ហើយក៏បានដំណើរការដាំថ្មីបន្ថែមទៀត ចាប់តាំងពីឆ្នាំ ១៩៨៥ មក។ ក្នុងប៉ុន្មានឆ្នាំដំបូង យើងបានធ្វើអាជីវកម្មកៅស៊ូ តែក្នុងកំរិតកសិដ្ឋានរដ្ឋរបស់មជ្ឈិម តែប៉ុណ្ណោះ។ ឯចំការកៅស៊ូនៅខេត្តរតនគិរី កំពង់សោម និងចំការកៅស៊ូរាយប៉ាយក្រៅកសិដ្ឋានរដ្ឋ នៅខេត្តកំពង់ចាម ក្រចេះ ក៏មិនទាន់បានប្រគល់អោយខេត្ត ឬក្រុមសាមគ្គីរបស់ប្រជាជនធ្វើនៅឡើយ។ សភាពការណ៍នេះ យើងបានទុកអោយដើមកៅស៊ូរាប់ពាន់ហិកតា ស្ថិតក្នុងស្ថានភាពខ្វះការថែទាំ ដែលមិនត្រឹមមិនបានទាញយកផលប៉ុណ្ណោះទេ តែនៅត្រូវខូចខាតដោយភ្លើងឆេះ ដោយការកាប់ធ្វើអុសដុត និងខូចដោយបញ្ហាបច្ចេកទេសទៀត។ ចាប់តាំងពីឆ្នាំ ១៩៨៥ មក មជ្ឈិមបានប្រគល់ចំការកៅស៊ូទាំងនោះអោយខេត្តគ្រប់គ្រង ធ្វើអាជីវកម្មផ្ទាល់ ហើយដែលកន្លែងមួយចំនួន ដូចជាខេត្តកំពង់ចាម បានប្រគល់អោយប្រជាជនធ្វើអាជីវកម្ម ធ្វើអោយផលិតកម្មមានការកើនឡើងមួយកំរិតថែមទៀត។

យើងសូមលើកយកតួលេខប្រចាំឆ្នាំនៃផលិតកម្មកៅស៊ូ មកពិនិត្យដូចខាងក្រោមៈ

| ឆ្នាំ | អាជីវកម្មលើផ្ទៃដី | បរិមាណផល |
|---|---|---|
| ឆ្នាំ ១៩៨០ | ៥.០០០ ហិកតា | ១.៣០០ តោន |
| ឆ្នាំ ១៩៨១ | ៨.៨០០ ហិកតា | ៤.០០០ តោន |
| ឆ្នាំ ១៩៨២ | ១១.៨០០ ហិកតា | ៧.០០០ តោន |
| ឆ្នាំ ១៩៨៣ | ១៤.៥០០ ហិកតា | ៩.០០០ តោន |
| ឆ្នាំ ១៩៨៤ | ១៩.៥០០ ហិកតា | ១៣.៤០០ តោន |
| ឆ្នាំ ១៩៨៥ | ២៦.២០០ ហិកតា | ១៧.៦៤០ តោន |
| ឆ្នាំ ១៩៨៦ | ៣៦.០០០ ហិកតា | ២៤.៥០០ តោន |
| ឆ្នាំ ១៩៨៧ | ៤០.០០០ ហិកតា | ២៥.០០០ តោន |
| ឆ្នាំ ១៩៨៨ | ផែនការអាជីវកម្មលើផ្ទៃដី ៤៣.០០០ ហិកតា | ផែនការបរិមាណផល ៣២.០០០ តោន |

*ការកើនឡើងនូវបរិមាណកៅស៊ូធម្មជាតិនេះ អនុញ្ញាតអោយយើងបាននាំចេញទៅបរទេស ហើយបានបំពេញនូវចន្លោះនៃការបាត់តុល្យភាពរវាងការនាំចេញ និងការនាំចូល បានមួយកំរិត។*

*ក្នុងប៉ុន្មានឆ្នាំនៃការស្តារឡើងវិញនូវអាជីវកម្មកៅស៊ូ បញ្ហាដែលចោទឡើងសំរាប់យើង គឺបញ្ហាលំនៅដ្ឋានកម្មករ បញ្ហាការដោះស្រាយរបបគោលនយោបាយចំពោះកម្មករ និងការថែទាំសុខភាពជូនកម្មករ។ ឯបញ្ហាគមនាគមន៍ដឹកជញ្ជូន និងមូលដ្ឋានកែច្នៃជ័រ បញ្ហាកម្មាភិបាល និងបច្ចេកទេស គឺនៅតែជាបញ្ហាចោទឡើងជាប្រចាំ។*

*ចំពោះវិស័យរុក្ខកម្ម អាជីវកម្មឈើ គឺជាផ្នែកមួយដែលមានការរីកចំរើន ហើយឈើក៏ក្លាយទៅជាមុខព្រួញដ៏សំខាន់មួយ ក្នុងចំណោមមុខព្រួញទាំង ៤ នៃសេដ្ឋកិច្ចជាតិ។ វាបានបំរើដល់សេចក្តីត្រូវការរបស់*

ប្រជាជននៅក្នុងប្រទេស និងបំរើដល់ការនាំចេញទៀតផង។ ពីមួយឆ្នាំទៅមួយឆ្នាំ អាជីវកម្មឈើបានរីកចំរើនឡើងគួរអោយកត់សម្គាល់។ ប៉ុន្តែនៅទីនេះ យើងត្រូវការហ៊ាននិយាយការពិត អំពីគុណវិបត្តិរបស់យើងក្នុងការងារគ្រប់គ្រង និងក្នុងអាជីវកម្មឈើ។ សម្បត្តិធម្មជាតិដែលជាមរតកដ៏មានតម្លៃនេះ យើងគ្រាន់តែបានធ្វើអាជីវកម្មយកផលតែប៉ុណ្ណោះ រីឯការថែទាំការពារ ការដាំថ្មី យើងធ្វើបានតិចតួចណាស់ រហូតដល់កន្លែងមួយចំនួន យើងមិនបានធ្វើសោះតែម្តង។ ប៉ុន្មានឆ្នាំកន្លងមក មានកើតឡើងនូវការបាត់តុល្យភាពរវាងតំបន់ងាយស្រួល និងតំបន់ជួបការលំបាកខាងសន្តិសុខ និងដឹកជញ្ជូន គឺកន្លែងពិបាកខាងសន្តិសុខ និងដឹកជញ្ជូន យើងមិនបានធ្វើអាជីវកម្ម ឈើមានអាយុហួសកំណត់។ ឯដំបន់ងាយស្រួលខាងសន្តិសុខ និងដឹកជញ្ជូនវិញ យើងបានធ្វើអាជីវកម្មរហូតចូលដល់កំរិតបំផ្លិចបំផ្លាញ កាប់ទាំងធំកាប់ទាំងតូច កាប់ទាំងកូនឈើតូចតាចយកមកធ្វើអុសធ្យូង កាប់ទាំងដើមឈើ ដែលប្រជាជនចោះយកជ័រ។ល។ ម៉ាស៊ីនអារឈើ បានរីកដុះដាលដូចផ្សិតនៅគ្រប់ទីកន្លែង ខ្វះការគ្រប់គ្រង។ ការដឹកជញ្ជូនចរាចរឈើធ្វើឡើងដោយអនាធិបតេយ្យ ឯកជនក៏ធ្វើ អង្គភាពរដ្ឋក៏ធ្វើ។ ការប្រើប្រាស់ឈើ ក៏ខ្វះភាពសន្សំសំចៃ ឡឥដ្ឋ ឡក្បឿងដែលត្រូវការអុស មិនបានប្រើប្រាស់អោយអស់នូវមែកឈើដែលបានកាប់ តែបែរជាកាប់កូនឈើ ឬយកឈើល្អមកដុតវិញ។ មុខសញ្ញាត្រូវមានអាទិភាពក្នុងការផ្តល់ឈើបែរជាទទួលបានតិច ដូចជាធារាសាស្ត្រ ឧបករណ៍សិប្បកម្ម មន្ទីរពេទ្យ សាលារៀន ស្ពាន មធ្យោបាយដឹកជញ្ជូន ទូក កាណូត រទេះ។ល។ ការគ្រប់គ្រងចំពោះជនធ្វើអាជីវកម្មកាប់ឈើ ក៏មិនទាន់បានល្អ ទុកអោយ

ពួកឈ្មួញធ្មៀតក្តាប់អ្នកទាំងនេះ នាំដល់ការប្រជែងរវាងឈ្មួញជាមួយរដ្ឋ ក្នុងការធ្វើអាជីវកម្មឈើ។ ការដាំឈើឡើងវិញ ធ្វើបានតិចតួច ក្នុងខេត្តព្រៃវែង ស្វាយរៀង តាកែវ ហើយខ្វះការថែទាំទៀតផង។

ក្នុងការនាំឈើទៅបរទេស យើងធ្វើបានត្រឹមនាំឈើមូលចេញ មិនទាន់បានជំរុញនូវការងារកែច្នៃឈើដើម្បីនាំចេញឡើយ ហើយការនាំឈើមូលចេញទៀតសោត មានពេលខ្លះឈើត្រូវបាត់គុណភាពបណ្តាលមកពីការដឹកជញ្ជូនយឺត ឬមកពីទម្រង់បែបបទរដ្ឋបាលច្រើនពេក។ នាចុងក្រោយនេះ ឃើញថាមានល្បឿនលឿនជាង អាស្រ័យដោយយើងបានប្រគល់ភារៈអោយក្រសួងកសិកម្មនាំចេញផ្ទាល់តែម្តង។

សរុបមក ចំពោះសេចក្តីសំរេចរបស់មហាសន្និបាតបក្សលើកទី ៥ យើងអនុវត្តបានត្រឹមកំរិតធ្វើអាជីវកម្មឈើប៉ុណ្ណោះ ប៉ុន្តែការការពារព្រៃឈើ ការដាំដើមឈើឡើងវិញ ការកែច្នៃឈើដើម្បីនាំចេញ ការគ្រប់គ្រងអាជីវកម្មកាប់ឈើ ដឹកជញ្ជូនឈើ អារឈើ គឺយើងធ្វើបានតិចតួចណាស់ ស្ទើរតែពុំមានផង។

ចំពោះវិស័យជលផល ជិត ២ ទសវត្សនៃសង្គ្រាម គេគ្មានលទ្ធភាពនឹងការពារបឹងបួ ទន្លេកុំអោយរាក់បានទេ។ រដូវទឹកទន្លេមេគង្គឡើងបាននាំដីល្បាប់ចូលទៅក្នុងទន្លេសាប ព្រែក បឹងបួ បូកបន្ថែមស្លឹកឈើជ្រុះធ្លាក់ចុះទៅទៀត ធ្វើអោយទន្លេសាប និងបឹងបួមួយចំនួនកាន់តែរាក់ទៅៗ រហូតដល់ព្រែក និងបឹងបួមួយចំនួន ត្រូវរីងស្ងួត ហើយប្រភពត្រីក៏កាន់តែតិចទៅជាលំដាប់។

ប៉ុន្មានឆ្នាំក្រោយរំដោះ ការនេសាទត្រីទាំងទឹកសាប ទាំងសមុទ្រ រីកចំរើនគួរអោយកត់សម្គាល់ ដែលអាចដោះស្រាយបាននូវអាហារជូន

ប្រជាជន និងបំរើដល់ការនាំចេញបានមួយចំនួនទៀតផង។ ឯការចិញ្ចឹមត្រីក៏មានដំហានរីកចំរើនល្អ។ ប៉ុន្តែក្នុងវិស័យនេះ ក៏មានបញ្ហាដែលគួរអោយព្រួយបារម្ភ ភាពអនាធិបតេយ្យក្នុងការចាប់ត្រីបានកើតមានស្ទើរគ្រប់ទីកន្លែង ដោយការប្រើប្រាស់ឧបករណ៍ចាប់ត្រីទំនើប នាំអោយពាយប្រកពត្រី។ ការចាប់ត្រីក្នុងរដូវត្រីពង(រដូវហាមឃាត់) ការធ្វើនេសាទក្នុងដែនបំរុងទុក ការកាប់ព្រៃលិចទឹកក៏ជាមូលហេតុនាំអោយអស់ប្រភពត្រីដែរ។ ការគ្រប់គ្រងឡូត៍នេសាទ ក៏ធ្វើពុំទាន់បានល្អ ការគ្រប់គ្រងប្រើប្រាស់ផលនេសាទ ក៏ធ្វើបានតិច វិធានការណ៍សេដ្ឋកិច្ច និងគោលនយោបាយចំពោះអ្នកនេសាទក៏ពុំទាន់ជាក់ស្តែង និងពុំទាន់លើកទឹកចិត្តដល់អ្នកនេសាទ ជម្លោះអំពីឡូត៍នេសាទក៏បានកើតឡើងជាប្រចាំ ដែលរកច្រកដោះស្រាយមិនទាន់រួច។ ការគ្រប់គ្រងនេសាទសមុទ្រធ្វើបានតិចតួច ដែលបញ្ហាសំខាន់យើងមិនទាន់បានចេញដំណើរ ពីវិធានការសេដ្ឋកិច្ច ដើម្បីគ្រប់គ្រងអាជីវកម្មនេសាទនៅឡើយ។

ជារួមក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ យើងសង្កត់ធ្ងន់តែទៅលើការធ្វើអាជីវកម្មចាប់ត្រី ប៉ុន្តែវិធានការការពារ និងបង្កើនប្រភពត្រី ការចាត់តាំងគ្រប់គ្រងផលនេសាទ និងការធ្វើអាជីវកម្មនេសាទ គឺយើងធ្វើបានតិចតួចណាស់។

ប៉ុន្តែ ទោះជាមានចំណុចខ្វះខាតដូចបានរៀបរាប់ខាងលើក៏ដោយ ក៏ការងារនេះបានបំរើដល់ការរីកចំរើនរបស់ប្រជាជនយើង ក្នុងរយៈពេលកន្លងមក ហើយបក្ស និងរដ្ឋ ក៏បានដាក់ចេញជាបន្តបន្ទាប់នូវបទដ្ឋានផ្សេងៗ ដើម្បីកែលំអនូវការខ្វះខាតទាំងនេះ។ ពិនិត្យតួលេខនៃផលនេសាទប្រចាំឆ្នាំអាចអោយយើងដឹងបានពីដំហានរីកចំរើន និង

សមត្ថភាពរបស់ប្រជាជនយើង ក្នុងវិស័យនេសាទកម្ម ហើយវាបាន ជួយយើងក្នុងការដោះស្រាយអាហារជូនប្រជាជន និងរក្សាស្ថិរភាព តម្លៃនៅលើទីផ្សារ។

ខាងក្រោមនេះ ជាតួលេខប្រចាំឆ្នាំ នៃផលនេសាទទាំងទឹកសាប និងសមុទ្រ៖

| | |
|---|---|
| ឆ្នាំ ១៩៨០ | ២០.០០០ តោន |
| ឆ្នាំ ១៩៨១ | ៥១.៦០០ តោន |
| ឆ្នាំ ១៩៨២ | ៦៨.៧១៤ តោន |
| ឆ្នាំ ១៩៨៣ | ៦៨.២៦១ តោន |
| ឆ្នាំ ១៩៨៤ | ៦៥.១២៦ តោន |
| ឆ្នាំ ១៩៨៥ | ៦៧.៥៧៧ តោន |
| ឆ្នាំ ១៩៨៦ | ៧៣.៦២១ តោន |
| ឆ្នាំ ១៩៨៧ | ៧៤.១៥៤ តោន |
| ឆ្នាំ ១៩៨៨ | ៧៧.៣៩៣ តោន |

ពិនិត្យអំពីលទ្ធផលដែលយើងទទួលបាន ក្នុងវិស័យកសិកម្មទាំងមូល យើងអាចនិយាយបានថា នេះជាសមិទ្ធិផលដ៏ធំធេងណាស់បើប្រៀបធៀបទៅនឹងការលំបាកដែលយើងបានជួបប្រទះ ដោយត្រូវចេញដំណើរពីបាតដៃទទេ ពីការអត់ឃ្លាន និងពីភាពច្របូកច្របល់។ យើងអាចនិយាយដោយពេញចិត្តថា នយោបាយកសិកម្មរបស់បក្ស និងរដ្ឋ ពិតជាត្រឹមត្រូវ ដែលមិនគ្រាន់តែជំរុញអាជីវកម្មប៉ុណ្ណោះទេ តែនៅបានរៀបចំព្រមគ្នានូវការទាក់ទងផលិតកម្មនៅជនបទ បំផុសលើក

ទឹកចិត្តជំរុញផលិតកម្មផង និងបំផុសស្មារតីជួយឧបត្ថម្ភគ្នាបានផង ដែលធ្វើអោយយើងបានឆ្លងផុតនូវដំណាក់កាលដ៏សែនលំបាកបំផុត។ ជាងនេះទៅទៀត ការម្ចាស់ការកែសំរួលនូវចំណុចដែលមិនទាន់សមស្រប ក៏បានបង្ហាញនូវជាតុបដិវត្តរបស់បក្ស និងប្រជាជនយើង ដែលជានិច្ចកាលស្វែងរកនូវភាពជឿនលឿនបញ្ចូលក្នុងផលិតកម្ម។ កត្តានេះបានកែលំអយ៉ាងច្រើនដល់សភាពការណ៍ផលិតកម្ម និងជីវភាពរស់នៅរបស់ប្រជាជន។

បន្ទាប់ទៅនេះ ខ្ញុំសូមលើកមកពិនិត្យ អំពីវិស័យឧស្សាហកម្ម សិប្បកម្ម ដែលជាវិស័យមួយបានរួមចំណែកយ៉ាងច្រើនដល់ការរីកចំរើនរបស់សង្គមជាតិ ហើយដែលបានបង្ហាញយ៉ាងច្បាស់អំពីសមត្ថភាពរបស់កម្មករកម្ពុជា ក្រោមការដឹកនាំរបស់បក្ស។

រោងចក្រ សហគ្រាស ទាំងនៅមជ្ឈិម ទាំងនៅតាមខេត្តក្រុងសុទ្ធតែស្ថិតក្នុងការបោះបង់ចោល ខ្វះការថែទាំ រហូតដល់ត្រូវបំផ្លិចបំផ្លាញផង។ មានរោងចក្រតិចតួចទេ ដែលពួក ប៉ុល ពត បានដំណើរការផលិត ហើយក្នុងចំនួននេះ មានរោងចក្រមួយចំនួនត្រូវពួកវាបំផ្លាញ ក្នុងពេលពួកវារត់ចេញទៅ។ វិស្វករ អ្នកបច្ចេកទេស និងកម្មករ ត្រូវពួក ប៉ុល ពត សម្លាប់អស់យ៉ាងច្រើន អ្នកដែលនៅសេសសល់ស្ថិតក្នុងភាពបែកខ្ញែក ហើយមួយចំនួនក៏រត់ទៅប្រទេសក្រៅ តាមរយៈពួក ប៉ុល ពត កៀរទៅភាគខាងលិចកម្ពុជា ឬកៀរចូលទៅប្រទេសថៃ។

ពិតជាអស្ចារ្យមែន ចំពោះស្មារតីស្រឡាញ់រោងចក្ររបស់កម្មករកម្ពុជា។ កម្មករដែលនៅសេសសល់ពីការស្លាប់ ហើយដែលត្រូវបានជម្លៀសទៅកាន់កន្លែងឆ្ងាយៗ បានវិលត្រឡប់មកភូមិកំណើតវិញ

ហើយដែលភូមិកំណើតពិតប្រាកដរបស់គេ គឺរោងចក្រ ដែលគេធ្លាប់បានធ្វើការមុនពេលពួក ប៉ុល ពត ជម្លៀសគេចេញទៅ។ ថ្វីត្បិតតែរោងចក្រមិនទាន់ដំណើរការផលិត ប៉ុន្តែអ្នកទាំងនេះបានមករស់នៅក្បែរៗរោងចក្រ ហើយចូលរួមការពាររោងចក្រ។ នៅកន្លែងជាច្រើន កម្មករបានដើរប្រមែប្រមូលគ្រឿងបន្លាស់ ហើយរហូតដល់ដំណើរការជួសជុលរោងចក្រទៀត ទោះជាមិនទាន់មានការចាត់តាំងពីរដ្ឋអំណាចក៏ដោយ។ យើងអាចនិយាយបានថា កម្មករបានដើរតួនាទីយ៉ាងសំខាន់ក្នុងការការពាររោងចក្រ ក្នុងពេលសភាពការណ៍នៅច្របូកច្របល់ ហើយដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើអោយរោងចក្រចាប់ផ្តើមដំណើរការឡើងវិញ។ គ្មានអ្នកណាស្គាល់រោងចក្រ ជាងកម្មករដែលធ្លាប់ធ្វើការនៅក្នុងរោងចក្រនេះទេ។ វិស្វករ និងអ្នកបច្ចេកទេសជាន់ខ្ពស់បានស្លាប់ទៅ មានតែកម្មករដែលធ្លាប់ធ្វើការក្នុងរោងចក្រតាំងពីមុនមកទេ ដែលដឹងប្រវត្តិ និងបច្ចេកទេសរោងចក្រនេះ គេក្លាយជាអ្នកឯកទេសដ៏សំខាន់សំរាប់រោងចក្រ ជាស្នូលក្នុងការអូសទាញអោយកម្មករថ្មីៗ ចូលធ្វើការ និងជាអ្នកជួយបណ្តុះបណ្តាលបច្ចេកទេសអោយកម្មករថ្មីៗ ទៀត។ យើងនៅមានសេសសល់ខ្លះៗ ដែរ នូវវិស្វករ និងអ្នកបច្ចេកទេសជាន់ខ្ពស់ ប៉ុន្តែក្នុងរយៈពេលនេះ យើងត្រូវការអ្នកចេះដឹងទាំងនេះអោយធ្វើជាអ្នកដឹកនាំគ្រប់គ្រង ដូច្នេះមានមួយចំនួនក៏គេឃ្លាតឆ្ងាយពីរោងចក្រ មួយចំនួនទៀតក៏ចូលធ្វើការនៅស្ថាប័នផ្សេងទៀត ដែលមិនចំនឹងមុខជំនាញរបស់គេ។

រយៈពេលដំបូងនេះ វៀតណាមក៏មានតួនាទីយ៉ាងសំខាន់ក្នុងការស្តារវិស័យឧស្សាហកម្មនៅកម្ពុជា ដោយបានបញ្ជូនមកនូវវិស្វករ កម្ម

ករឯកទេស ព្រមទាំងគ្រឿងបន្លាស់ រហូតដល់វត្ថុធាតុដើមមួយចំនួន ដើម្បីដំណើរការផលិត។ សមមិត្តទាំងនេះ បានរួមជាមួយកម្មករកម្ពុជា ធ្វើអោយរោងចក្រអគ្គិសនី និងម៉ាស៊ីនបូមទឹកនៅភ្នំពេញដំណើរការ ឡើងវិញជាដំបូង ហើយជាបន្តបន្ទាប់ធ្វើអោយរោងចក្រដ៏ទៃទៀត បានចាប់ផ្តើមដំណើរការ។

ពេលចាប់ផ្តើមដំណើរការ ឧស្សាហកម្មនៅកម្ពុជាត្រូវជួបការលំបាក យ៉ាងច្រើន រចនាសម្ព័ន្ធក្នុងឧស្សាហកម្មមិនទាន់រៀបចំអោយបានល្អ នៅឡើយ យើងទើបតែមានក្រសួងឧស្សាហកម្មដែលមានកម្មាភិបាល តែប៉ុន្មាននាក់ប៉ុណ្ណោះ។ កង្វះកម្មាភិបាលដឹកនាំគ្រប់គ្រង កង្វះអ្នក បច្ចេកទេស កង្វះថាមពលអគ្គិសនី គឺជាចំណោទដ៏ធំ ដែលធ្វើអោយ រោងចក្រដំណើរការក្នុងភាពអាក់រអួល។ ជាងនេះទៅទៀត បញ្ហា គ្រឿងបន្លាស់ និងវត្ថុធាតុដើម ក៏បានចោទឡើងយ៉ាងធ្ងន់ធ្ងរ។ រោង ចក្រនៅកម្ពុជាភាគច្រើនគឺជារបស់ចិន ជប៉ុន និងប្រទេសប៉ែកខាងលិច ផ្សេងទៀត ហើយតាំងពីគ្រាដំបូងរហូតមកដល់សព្វថ្ងៃនេះ ប្រទេស ទាំងនេះបានអនុវត្តនូវរបស់ដែលហៅថា "ហ៊ុំព័ទ្ធខាងសេដ្ឋកិច្ច និងឯ កោកម្ពុជាខាងនយោបាយ"។ ដូច្នេះ យើងមិនអាចរកគ្រឿងបន្លាស់ និង វត្ថុធាតុដើមពីប្រទេសទាំងនេះបានទេ។ ការដោះស្រាយគ្រឿងបន្លាស់ មួយផ្នែកត្រូវពឹងផ្អែកលើការច្នៃប្រឌិតរបស់កម្មករយើង មួយផ្នែកត្រូវ ពឹងពាក់មិត្តវៀតណាម មួយផ្នែកត្រូវពឹងពាក់ប្រទេសសង្គមនិយម និង មួយផ្នែកទៀត ត្រូវពឹងពាក់អង្គការអន្តរជាតិមួយចំនួន។ ឯវត្ថុធាតុដើម ត្រូវពឹងពាក់ជាសំខាន់លើវៀតណាម សហភាពសូវៀត និងប្រទេស សង្គមនិយមផ្សេងទៀត។

*ឯការចាត់តាំងគ្រប់គ្រងអាជីវកម្ម ក៏ស្ថិតនៅក្នុងដំហានពារក។ ចេញដំណើរដំបូង យើងក៏បានបែងចែកពេងចក្រមួយចំនួន អោយក្រសួងឧស្សាហកម្មគ្រប់គ្រងផ្ទាល់ មួយចំនួនទៀតខេត្ត ក្រុង ជាអ្នកគ្រប់គ្រង ប៉ុន្តែដំណើរការអាជីវកម្មដូចៗ គ្នា គឺជាអង្គភាពចំណូលបំពេញ អោយចំណាយ ឬហៅថាចំណូលគ្រប់ចំណាយគ្រប់ ដែលជារបៀបគ្រប់គ្រងបែបនាម៉ឺននិយម រដ្ឋប៉ាវផ្តាច់តែម្តង ខាតក៏រដ្ឋបំពេញអោយ ចំណេញក៏រដ្ឋយកទាំងអស់ ធ្វើអោយមូលដ្ឋានខ្វះស្មារតីច្នៃប្រឌិត ខ្វះស្មារតីប្រឡងប្រណាំង ជំរុញការផលិត។ ស្ទើរជាទូទៅ ពេងចក្រ ធ្វើអាជីវកម្មខាត មានពេងចក្រតិចតួចទេដែលរួចខ្លួន មិនខាតហើយមិនចំណេញ និងពេងចក្រមួយចំនួនតូច ដែលមានចំណេញតិចតួច។*

*បញ្ហារបៀបគ្រប់គ្រង និងធ្វើអាជីវកម្មរបស់ពេងចក្រសហគ្រាស បានក្លាយជាបច្ចុប្បន្នភាពមួយ ដែលបក្ស និងរដ្ឋត្រូវលើកមកពិភាក្សាជាប្រចាំ ហើយបញ្ហានេះស្ថិតក្នុងភាពបដិវត្ត និងការតស៊ូលើទស្សនៈ នៅក្នុងបក្ស និងក្នុងជួរកម្មាភិបាល។ ត្រង់នេះអាចនិយាយបានថា និន្នាការកែទម្រង់ទទួលបានជោគជ័យជាជំហានៗ ហើយក៏មិនបង្កអោយមានការបែកបាក់ក្នុងជួរបក្ស និងកម្មាភិបាលដែរ ដែលទីបំផុតយើងបានបញ្ចូលពេងចក្រស្ទើរតែទាំងអស់ អោយចូលទៅកាន់អាជីវកម្មម្ចាស់ការហិរញ្ញវត្ថុ និងបន្ថែមទៅដោយគោលនយោបាយប្រឡងប្រណាំង ក្នុងការផលិតសំរាប់កម្មករម្នាក់ៗ ដោយអនុវត្តការទទួលបៀវត្សតាមបរិមាណផល។ តាំងពីពេលនោះមក យើងសង្កេតឃើញពេងចក្រភាគច្រើនធ្វើអាជីវកម្មបានចំណេញ គុណភាពផលិតផលក៏ល្អ ហើយមានទាំងការកែច្នៃបាននូវមុខទំនិញថ្មីៗ បន្ថយបានយ៉ាងច្រើននូវការ*

បាត់បង់វត្ថុធាតុដើម ដោយការអនុវត្តន៍ល្អនូវការសន្សំសំចៃ។ ចំពោះបទដ្ឋានស្រុកស្រុតបាត់បង់វត្ថុធាតុដើម ដែលរដ្ឋកំណត់ ៤ ឬ ៥ ភាគរយ បានបន្ថយការបាត់បង់មកនៅត្រឹម ២ ឬ ៣ ភាគរយ ហើយបង្កើនបានផលិតផលលើសផែនការកំណត់។ រោងចក្រជាច្រើនបានបើកបៀវត្សបន្ថែមអោយកម្មករពី ២ ដល់ ៤ ខែក្នុងមួយឆ្នាំ ហើយ នៅសល់ប្រាក់ជាបេឡាអត្ថប្រយោជន៍របស់រោងចក្រ និងសមូហភាព ផ្សេងទៀតផង។

ត្រង់នេះ យើងសូមកត់សម្គាល់ថា បើនិយាយពីសមត្ថភាពរបស់រោងចក្រសហគ្រាស និយាយពីសមត្ថភាពរបស់កម្មករ យើងនៅមានលទ្ធភាពច្រើនទៀតក្នុងការច្នៃប្រឌិត ដើម្បីពង្រីកផលិតកម្ម ប៉ុន្តែគោលការណ៍របស់យើងមួយចំនួន ក៏ពុំទាន់បង្កលក្ខណៈអោយរោងចក្រពង្រីកបានអស់នូវលទ្ធភាពរបស់ខ្លួននៅឡើយ។ ផ្នែកចរាចរបែងចែក ក៏មិនទាន់ដើរតួនាទីជាអ្នកជំរុញផលិតកម្មនៅឡើយដែរ ហើយមានកន្លែងខ្លះ និងពេលខ្លះ ថែមទាំងធ្វើអោយរាំងស្ទះដល់ផលិតកម្មទៀតផង ដូចជាផលិតផលដែលរោងចក្រផលិតបាននៅកកស្ទះពេញឃ្លាំង គុណភាពទំនិញថយចុះ ធ្វើអោយរោងចក្រកប់ទុន ខ្លះទុនធ្វើអាជីវកម្ម ហើយត្រូវរត់រកចងការប្រាក់ធនាគារ ឬការផ្តល់វត្ថុធាតុដើមអោយរោងចក្រមិនទាន់ពេលវេលា។ ចំណុចនេះ បានធ្វើអោយរដ្ឋាភិបាល មានការគិតគូរឡើងវិញ តើចាំបាច់ត្រូវផ្តល់អោយរោងចក្រមានសិទ្ធិផលិត ហើយមានសិទ្ធិធ្វើចរាចរ ដោយមិនចាំបាច់ឆ្លងផ្នែកពាណិជ្ជកម្ម ឬទេ? ក្រុមប្រឹក្សារដ្ឋមន្ត្រីក៏បានសាកល្បងប្រគល់សិទ្ធិអោយរោងចក្រមួយចំនួន មានសិទ្ធិលក់នូវមុខទំនិញដែលរោងចក្រផលិតបាន ដោយមិនចាំបាច់ឆ្លងផ្នែកពាណិជ្ជកម្ម ហើយក៏កំពុងពិនិត្យបន្តទៅទៀត។

ប៉ុន្តែ យើងក៏ត្រូវមើលឃើញនូវចំណុចខ្វះខាតជាអត្តនោម័តិ ក្នុងវិស័យឧស្សាហកម្មខ្លួនឯងដែរ ដូចជា ការផលិតនូវមុខទំនិញខ្វះគុណភាព ផាលនង្គ័លផលិតតាមគំរូតែមួយ ដែលនៅតំបន់ជាច្រើនមិនអាចប្រើបាន សំបកកង់រថយន្ត សំបកកង់ទោចក្រយានប្រើមិនកើត បារីធាប់ដុះផ្សិត ។ល។ ឬមានគុណភាពហើយ ប៉ុន្តែខ្វះសោភ័ណភាព ដែលធ្វើអោយអ្នកប្រើប្រាស់មិនចូលចិត្ត។

ចំពោះសិប្បកម្ម ផ្នែកនេះមានការរីកចំរើនលឿន បើប្រៀបធៀបជាមួយឧស្សាហកម្ម។ មានមូលដ្ឋានសិប្បកម្មតិចតួចទេ ដែលរដ្ឋធ្វើដោយផ្ទាល់ ឯភាគច្រើននៃសិប្បកម្ម គឺស្ថិតក្នុងសមាសភាពសេដ្ឋកិច្ចឯកជន ហើយវារីកចំរើនដោយគ្មានការដឹកនាំជាគោលការណ៍ ព្រោះមុនឆ្នាំ ១៩៨៩ សមាសភាពសេដ្ឋកិច្ចឯកជនមិនទាន់មានចែងក្នុងរដ្ឋធម្មនុញ្ញនៅឡើយ។ ទោះជាមានការដឹកនាំ ឬគ្មានការដឹកនាំក៏ដោយ ក៏សភាពការណ៍សត្យានុម័តិរបស់សង្គម វាទាមទារអោយមានមូលដ្ឋានផលិតកម្មរបៀបនេះ។ សភាពការណ៍នេះ បានបង្កើតឡើងនូវបញ្ហាដែលត្រូវពិភាក្សាថា តើត្រូវទទួលស្គាល់ការជាក់ស្តែងនេះយ៉ាងណា? ឬមួយក៏ត្រូវលុបបំបាត់វាចោល? ដូចបានលើកឡើងខាងលើហើយថា ផ្នែកក្នុងយើងមាននិន្នាការមិនអោយមានសេដ្ឋកិច្ចឯកជនទេ គឺអោយមានត្រឹមកំរិតសេដ្ឋកិច្ចគ្រួសារប៉ុណ្ណោះ ដូច្នេះបានជារដ្ឋធម្មនុញ្ញមិនបានចែងពីសមាសភាពសេដ្ឋកិច្ចឯកជនឡើយ។ ប៉ុន្តែជាក់ស្តែង សិប្បកម្មបានកកើតឡើង ដោយចេញដំណើរពីសេដ្ឋកិច្ចឯកជន ទោះបីមូលដ្ឋានសិប្បកម្មខ្លះបានខិតខំយកផ្លាកជាក្រុមសាមគ្គី ឬជាសេដ្ឋកិច្ចសមូហភាពក៏ដោយចុះ ក៏ជាតុពិតគឺជាសេដ្ឋកិច្ចឯកជន។ ហើយសិប្បកម្មឯក

*ជននេះទៀតសោត ក៏បានរួមចំណែកយ៉ាងច្រើនដល់ការផលិតទំនិញបំរើសេចក្តីត្រូវការរបស់សង្គម បន្ថយបានការនាំចូលពីបរទេស ឯគុណភាពទំនិញទៀតសោតក៏ល្អ រហូតមានមុខទំនិញមួយចំនួនល្អជាងរោងចក្ររដ្ឋផលិតទៀតផង។*

*យើងកំពុងខ្វះទុន ខ្វះបច្ចេកទេស និងពលកម្ម ហេតុអ្វីក៏យើងមិនធ្មៀតប្រើទុន បច្ចេកទេស ពលកម្មរបស់ប្រជាជនយើង បែរជាទៅចងការប្រាក់ពីបរទេស ហើយជួលអ្នកបច្ចេកទេសបរទេសមកធ្វើការ។ ជាងនេះទៀត ក្នុងពេលដែលយើងកំពុងខ្វះទំនិញ សិប្បកម្មបានជួយផលិតទំនិញបំរើសេចក្តីត្រូវការរបស់ប្រជាជន ធ្វើអោយតម្លៃទំនិញនៅលើទីផ្សារមានស្ថិរភាព ដោះស្រាយបាននូវការងារអោយមនុស្សក្នុងទីក្រុង ទៅប្រជុំជនដែលខ្វះការងារធ្វើ បង្កើនបានចំណូលគ្រួសារ រដ្ឋក៏បានចំណេញដោយការគ្រប់គ្រងពន្ធដារ និងការធ្វើចរាចរទំនិញរបស់សិប្បកម្ម ហើយវាថែមទាំងជួយដល់ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់សង្គមក្នុងទីក្រុង ដែលតែងតែកើតញឹកញាប់បណ្តាលមកពីប្រភេទមនុស្សគ្មានការងារធ្វើទៀតផង។*

*ទីចុងបំផុត យើងបានដើរដល់ការសំរេចថា ចាំបាច់ត្រូវទទួលស្គាល់អត្ថិភាពនៃសិប្បកម្មឯកជន ហើយការិយាល័យនយោបាយក៏បានចេញសេចក្តីសំរេចលេខ ២៤៧ ចុះថ្ងៃទី ២៧ ខែកក្កដា ១៩៨៤ ស្តីពីការពង្រីកសិប្បកម្មនៅរដ្ឋធានីភ្នំពេញ ដើម្បីជាជំហានបទពិសោធន៍សំរាប់ទូទាំងប្រទេស។ យើងមានគោលដៅគ្រប់គ្រង និងពង្រីកផ្នែកនេះអោយលឿនជាងនេះទៀត ដោយចលនាប្រជាជន រាប់ទាំងអ្នកលក់ដូរផង អោយបង្វែរទុនទៅពង្រីកផលិតកម្មសិប្បកម្ម។ តាមយើងចាំបាន*

ពេលនោះយើងប្រើពាក្យថា សិប្បករចង់អោយរដ្ឋគ្រប់គ្រងគេ តែបើរដ្ឋមិនគ្រប់គ្រងគេទេ គេក៏មិននៅក្រោមការគ្រប់គ្រងរបស់រដ្ឋដែរ ហើយគេនៅតែធ្វើ ព្រោះជាការទាមទាររបស់សង្គម ដូច្នេះ ត្រង់នេះគួរតែទទួលស្គាល់ថា យើងបានដើរក្រោយការវិវឌ្ឍន៍របស់ផលិតកម្មសិប្បកម្ម ដែលជាសត្យានុម័តិបង្ខំអោយយើងត្រូវតែទទួលស្គាល់។ ការទទួលស្គាល់នេះមិនមែនជាជំហានចុះចាញ់ ឬថយក្រោយទេ ប៉ុន្តែជាជំហានមួយយ៉ាងលឿនទៅមុខរបស់បក្សយើង ដោយយើងបានទទួលស្គាល់នូវការពិត ហើយអនុវត្តនយោបាយសេដ្ឋកិច្ចបើកទូលាយ ដោយគួបផ្សំប្រើប្រាស់អោយអស់ នូវបណ្តាសមាសភាពសេដ្ឋកិច្ចក្នុងសង្គម ដើម្បីបំរើការស្តារនិងកសាងសេដ្ឋកិច្ចជាតិ។

បន្ទាប់ពីការទទួលស្គាល់ និងការជំរុញសិប្បកម្មឯកជន អោយមានការវិវឌ្ឍន៍ សន្និបាតកម្មាភិបាលទូទាំងប្រទេសរបស់បក្ស ពីថ្ងៃទី ២ ដល់ទី ៩ វិច្ឆិកា ឆ្នាំ ១៩៨៤ បានដាក់ចេញនូវសមាសភាពសេដ្ឋកិច្ចមួយទៀត គឺសមាសភាពសេដ្ឋកិច្ចឯកជន។ មហាសន្និបាតបក្សលើកទី ៥ ក៏បានអោយសច្ចាប័នទទួលស្គាល់សមាសភាពសេដ្ឋកិច្ចនេះ ហើយរដ្ឋសភាក៏បានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ ក្នុងសម័យប្រជុំលើកទី ១០ នីតិកាលទី ១ ពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៩៨៦។

ដូច្នេះ សិប្បកម្ម ដែលក្នុងនោះសិប្បកម្មឯកជនជាអ្នកដើរតួដ៏សំខាន់ បានធ្វើដំណើរក្នុងភាពស្របច្បាប់។ ពីមួយថ្ងៃទៅមួយថ្ងៃផលិតកម្មកាន់តែរីកចំរើន មុខទំនិញថ្មីៗ បានដាក់លក់នៅទីផ្សារ គុណភាពទំនិញកាន់តែខ្ពស់ មូលដ្ឋានសិប្បកម្មចាស់ៗ ក៏បានពង្រីកផលិតកម្មថែមមូលដ្ឋានថ្មីៗ ក៏បានកើតមានឡើងជាបន្តបន្ទាប់។ ប្រជាជនកាន់តែ

*សប្បាយរីករាយ និងហ៊ានបោះទុនចេញ ដើម្បីពង្រីកផលិតកម្ម។ បច្ចេកទេសថ្មីៗ ក៏កើតមាន រហូតសិប្បកម្មខ្លះ ឈានទៅបង្កើនមុខទំនិញ ជំនួសអោយការនាំចូលពីបរទេស ដែលធ្វើអោយរដ្ឋចំណេញរូបិយប័ណ្ណយ៉ាងច្រើន។*

*យើងនៅចាំបានថា ក្នុងសម័យប្រជុំមួយរបស់គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រី នាពាក់កណ្តាលឆ្នាំ ១៩៨៦ ដើម្បីពិភាក្សាអំពីវិស័យឧស្សាហកម្ម សិប្បកម្ម ដោយឃើញមុខទំនិញរបស់សិប្បកម្មប្រកួតប្រជែងជាមួយមុខទំនិញរបស់ឧស្សាហកម្មរដ្ឋ មតិរបស់ថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម បានស្នើក្រុមប្រឹក្សារដ្ឋមន្ត្រីសុំបិទមូលដ្ឋានសិប្បកម្មឯកជនមួយចំនួនដែលផលិតមុខទំនិញប្រជែងជាមួយរដ្ឋ ពិសេសសំបកកង់ទោចក្រយាន។ ពេលនោះគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សារដ្ឋមន្ត្រីបានសំរេចថា ចាំបាច់ត្រូវរក្សា និងពង្រីកសិប្បកម្មប្រភេទនេះតទៅទៀត។ អ្នកកាត់សេចក្តីក្នុងរឿងនេះ គឺប្រជាជនដែលជាអ្នកទិញ។ សព្វថ្ងៃប្រជាជនចូលចិត្តទិញសំបកកង់របស់សិប្បកម្ម ព្រោះវាមានគុណភាពផង មានសោភ័ណភាពផង ហើយមានតម្លៃថោកល្មមទៀត។ ឯរបស់ឧស្សាហកម្ម គឺខ្វះគុណភាពផង ហើយខ្វះសោភ័ណភាពផង ពិតមែនតែតម្លៃថោកជាងសិប្បកម្មបន្តិចបន្តួចក៏ដោយ ក៏ប្រជាជនមិនចូលចិត្តប្រើ។ ដូចនេះត្រូវទុកអោយសិប្បកម្មរត់ប្រណាំងជាមួយឧស្សាហកម្ម អំពីគុណភាព។ ពេលណាប្រជាជនឈប់ទិញរបស់សិប្បកម្ម យើងមិនចាំបាច់ប្រកាសបិទមូលដ្ឋានសិប្បកម្មនេះទេ គេនឹងបិទដោយខ្លួនឯង ហើយទៅរកការផលិតមុខទំនិញថ្មីផ្សេងទៀតវិញជាមិនខាន។*

*ក្រៅពីសិប្បកម្មផលិតនូវគ្រឿងឧបភោគបរិភោគ មុខទំនិញប្រើ*

ប្រាស់ ឧបករណ៍កសិកម្ម និងសម្ភារៈសំណង់ យើងក៏នៅឃើញសិប្បកម្មជួសជុលគ្រឿងយន្ត ជួសជុលសម្ភារៈប្រើប្រាស់ ជួសជុលមធ្យោបាយដឹកជញ្ជូន សិប្បកម្មកែច្នៃតុ ទូ កៅអី គ្រែ ធ្វើទូក កាណូត រទេះ រហាត់ទឹក។ល។ មានការរីកចំរើនយ៉ាងល្អ។ សិប្បកម្មដែលមានលក្ខណៈជាការសាងសង់ស៊ីវិល ក៏បានកើតឡើងយ៉ាងច្រើនក្នុងទូទាំងប្រទេស សម្រួលដល់ការសាងសង់ផ្ទះសម្បែង អគារសាធារណៈរបស់ប្រជាជន បណ្ដុះបណ្ដាលបាននូវអ្នកបច្ចេកទេស ក្នុងការសាងសង់ ដោះស្រាយបានមួយផ្នែកនូវការងារធ្វើសំរាប់ប្រជាជន ហើយក្រុមសំណង់របស់ប្រជាជននេះឯង ក៏បានជួយដល់រដ្ឋ ក្នុងការសាងសង់សំណង់របស់រដ្ឋ ដូចជាផ្ទះកម្មករចំការកៅស៊ូ អគារធ្វើការរបស់រដ្ឋ។ល។

ឆ្លងតាមរយៈគោលនយោបាយរបស់បក្ស និងរដ្ឋ ក្នុងការពង្រីកសិប្បកម្ម ប្រជាជនកាន់តែមានជំនឿទុកចិត្ត ហ៊ានបញ្ចេញទុនមកកសាងមូលដ្ឋានផលិតកម្ម ហើយពីមួយឆ្នាំទៅមួយឆ្នាំ ផលិតផលកាន់តែកើនឡើង រួមជាមួយផលិតផលឧស្សាហកម្មរដ្ឋផង យើងបំពេញបានមួយផ្នែកជំនួវសេចក្ដីត្រូវការរបស់សង្គម បន្ថយបានមួយកំរិតនូវការនាំចូលពីបរទេស និងបន្ថយបានមួយកំរិតនូវ ចន្លោះនៃការបាត់តុល្យភាពរវាងសេចក្ដីត្រូវការ និងការផ្គត់ផ្គង់។

ប៉ុន្តែយើងក៏ត្រូវទទួលស្គាល់នូវចំណុចសេសសល់ ដែលត្រូវបន្តដោះស្រាយ គឺការអនុវត្តន៍គោលការណ៍អំពីការពង្រីកសិប្បកម្មមិនទាន់បានព្រមគ្នា និងមិនទាន់មានចលនាស្មើគ្នានៅឡើយ មានតែរដ្ឋធានីភ្នំពេញ និងខេត្តមួយចំនួនប៉ុណ្ណោះទេ ដែលមានសន្ទុះលឿន ឯខេត្តក្រុងមួយចំនួនទៀត ចលនានៅយឺត ធ្វើក្នុងភាពស្ទាក់ស្ទើរ សតិ

*អារម្មណ៍ខ្វាចសេដ្ឋកិច្ចឯកជន នៅតែជាជំងឺដ៏ពុំរ៉ែសំរាប់កម្មាភិបាលមួយចំនួន។ ទម្រង់បែបបទនៅសាំញ៉ាំពេក ធ្វើអោយប្រជាជនរារែកមិនហ៊ានបញ្ចេញទុន និងបច្ចេកទេសពង្រីកផលិតកម្ម។ ការផ្គត់ផ្គង់វត្ថុធាតុដើមអោយសិប្បកម្មផលិតមុខទំនិញដែលរដ្ឋត្រូវការ ក៏ធ្វើពុំទាន់បានល្អ។ អង្គការសហជីព ក៏ពុំទាន់បានចូលធ្វើសកម្មភាព ដើម្បីធានាផលប្រយោជន៍កម្មករនៅមូលដ្ឋានសិប្បកម្មឯកជន ដែលមានជួលពលករ។ល។*

ចំពោះវិស័យគមនាគមន៍ដឹកជញ្ជូន

*បើនិយាយពីផ្នែកគមនាគមន៍ យើងអាចនិយាយបានថា ផ្នែកនេះត្រូវទ្រុឌទ្រោមយ៉ាងខ្លាំង។ ចាប់តាំងពីឆ្នាំ ១៩៧០ មក ស្ពាន ថ្នល់ ផ្លូវដែក ខ្វះការជួសជុល និងថែទាំ មិនត្រឹមតែប៉ុណ្ណោះ គឺត្រូវបំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែក គ្រាប់កាំភ្លើងធំ គ្រាប់មីន ឬត្រូវខូចខាតដោយសារការប្រយុទ្ធគ្នា។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ រដ្ឋយើងក៏បានយកចិត្តទុកដាក់ធ្វើការងារនេះ ប៉ុន្តែទុនរបស់យើងតិច យើងធ្វើបានត្រឹមកំរិតថែទាំ និងជួសជុលតូចតែប៉ុណ្ណោះ។ ឯការពង្រីកគមនាគមន៍នៅជនបទក៏ធ្វើបានក្នុងកំរិតតិចតួច ចរាចរនៅជួបការលំបាកច្រើន។ ក្រៅពីនេះ ខ្មាំងសត្រូវក៏នៅបន្តបំផ្លិចបំផ្លាញទៅលើស្ពាន លើផ្លូវដែកដែលទាមទារអោយយើងត្រូវចំណាយថវិកា សម្ភារៈ និងពលកម្ម ដ៏ច្រើនដើម្បីជួសជុល។*

*មធ្យោបាយដឹកជញ្ជូន ដូចជា រថយន្ត រថភ្លើង កាណូត កប៉ាល់ដែលនៅសេសសល់ ក៏ត្រូវតែធ្ងន់កាត់ការជួសជុលទើបអាចដំណើរការបាន។ រថយន្តតូចធំរាប់រយគ្រឿងត្រូវពួក ប៉ុល ពត បំផ្លាញទុកចោល*

គរលើគ្នាដូចភ្នំ ឯកប៉ាល់ កាណូតយ៉ាងច្រើន ត្រូវពន្លិចចោលក្នុងទន្លេ។ មធ្យោបាយដឹកជញ្ជូនសាមញ្ញដូចជា រទេះគោ រទេះសេះ ទូក ទោចក្រយាន ទោចក្រយានយន្ត។ល។ មាននៅសេសសល់តិចតួច ដែលប្រជាជនប្រមូលបានពីសហករណ៍របស់ពួក ប៉ុល ពត មកវិញ។

ប៉ុន្តែ ទោះបីស្ថិតក្នុងស្ថានភាពបែបនេះក៏ដោយ ក៏វិស័យគមនាគមន៍ដឹកជញ្ជូនបានចាប់ដំណើរការភ្លាមតាំងពីក្រោយថ្ងៃរំដោះ។ មធ្យោបាយដឹកជញ្ជូនជារថយន្ត រថភ្លើង កាណូត កប៉ាល់ សាឡាងសម្រាប់កំពង់ចម្លង។ល។ ត្រូវបានជួសជុល ហើយដាក់អោយដំណើរការ។ មធ្យោបាយថ្មីៗ ក៏ត្រូវបានបំពាក់ថែមទៀត ដោយការនាំចូលរបស់រដ្ឋ ដោយជំនួយ របស់ប្រទេសសង្គមនិយម និងរបស់អង្គការអន្តរជាតិនានា។ ស្ពានដែលខូចត្រូវបានធ្វើឡើងវិញ ផ្លូវថ្នល់មួយចំនួនត្រូវបានជួសជុល ផ្លូវថ្មីមួយចំនួនទៅកាន់ព្រំដែនកម្ពុជា-ថៃ ដើម្បីបំរើដល់ការផ្គត់ផ្គង់ចំពោះកម្លាំងការពារព្រំដែនត្រូវបានកសាងឡើង។ មធ្យោបាយដឹកជញ្ជូនអ្នកដំណើរ រាប់តាំងពីរថយន្ត រថភ្លើង កាណូត រហូតដល់ទោចក្រយាន ទោចក្រយានយន្ត រ៉ឺម៉កសណ្តោង ត្រីចក្រយាន។ល។ បានកើតមានឡើងនៅទូទាំងប្រទេស។ កំពង់ផែទាំងតូចទាំងធំ ត្រូវបានស្តារ និងដាក់ អោយដំណើរការជាប្រក្រតី។ វិស័យគមនាគមន៍ដឹកជញ្ជូន បានក្លាយទៅជាសរសៃឈាមតភ្ជាប់នៅទូទាំងប្រទេស បំរើអោយការងារចរាចរ បែងចែកទំនិញ បំរើដល់ការធ្វើដំណើររបស់ប្រជាជន ដោះស្រាយបានល្អនូវការបាត់តុល្យភាពរវាងដំបន់មានទំនិញ និងតំបន់ខ្វះទំនិញ បំរើយ៉ាងល្អនូវការដឹកជញ្ជូនទំនិញនាំចេញ និងនាំចូល។ ការដឹកជញ្ជូនតាមផ្លូវទឹក និងផ្លូវដែកមានការរីកចំរើន បន្ថយបាននូវ

ការចំណាយក្នុងការដឹកជញ្ជូន។

ក្នុងផ្នែកនេះ យើងគួរតែលើកឡើងមកនិយាយអំពីវីរភាព និងការច្នៃប្រឌិតរបស់កម្មករ កម្មាភិបាល និងយុទ្ធជនយើង។ ក្នុងគ្រាដំបូង បើនិយាយពីការដាក់អោយប្រើប្រាស់នូវមធ្យោបាយដឹកជញ្ជូន និងកំពង់ផែ គឺសុទ្ធតែលេចចេញពីស្មារតីច្នៃប្រឌិតរបស់កម្មករយើងទាំងអស់។ គេបានខិតខំប្រមែប្រមូលគ្រឿងបន្លាស់ ដើម្បីជួសជុលក្បាលរថភ្លើង ទូររថភ្លើង រថយន្ត កាណូត កប៉ាល់ មធ្យោបាយលើកដាក់នៅកំពង់ផែ រហូតឈានទៅកែច្នៃបាននូវគ្រឿងបន្លាស់ដ៏សំខាន់ៗ ជំនួសអោយការប្រើប្រាស់រូបិយប័ណ្ណដើម្បីនាំចូល។

រថយន្តមួយចំនួនដែលខូចនៅតាមចិញ្ចើមថ្នល់ ឬនៅតាមកន្ទេងកៀនកោះ តាំងពីជំនាន់ លន់ នល់ ឬ ប៉ុល ពត នាវាមួយចំនួនដែលលិចតាំងពីយូរមកហើយ ត្រូវបានកម្មករយើងស្តារ និងជួសជុល ដាក់អោយដំណើរការ ហើយដែលកំពុងរួមចំណែកក្នុងការដឹកជញ្ជូនសព្វថ្ងៃនេះ។ ការផលិតមធ្យោបាយដឹកជញ្ជូនថ្មីៗ ក៏មានការរីកចំរើនយ៉ាងច្រើន ដូចជាកប៉ាល់ កាណូត ទូក សាឡាង រទេះគោ រទេះសេះ រ៉ឺម៉កសណ្តោង។ ខាងផ្នែកធ្វើផ្លូវធ្វើស្ពាន ក៏មានការច្នៃប្រឌិតយ៉ាងខ្ពស់ ដោយប្រើប្រាស់អស់លទ្ធភាពនូវកម្លាំងប្រាជ្ញា ស្មារតី និងមធ្យោបាយ ដើម្បីកសាង ឬជួសជុលថ្នល់ស្ពាន។ គមនាគមន៍ជនបទ ក៏ត្រូវបានពង្រីក។ គេបានខិតខំធ្វើផ្លូវធ្វើស្ពានថែមថ្មីៗ ទៀត ដើម្បីសម្រួលដល់ការធ្វើដំណើររបស់ប្រជាជន ហើយកន្ទេងមួយចំនួនបានគួបផ្សំយ៉ាងល្អ រវាងការធ្វើជាធារាសាស្ត្រជាមួយគមនាគមន៍ ដូចជាការធ្វើចរាចរតាមកូនព្រែកដែលបានជីក ឬចរាចរលើខ្នងទំនប់ដែលបានលើកទប់ទឹក។ ការ

កសាងផ្លូវថ្មីៗ ទៅកាន់ព្រំដែនកម្ពុជា-ថៃ មិនគ្រាន់តែបំរើដល់វិស័យការពារជាតិប៉ុណ្ណោះទេ ប៉ុន្តែនៅបានបំរើដល់ការបែងចែកពលកម្មសង្គមឡើងវិញ និងបំរើដល់ចរាចរផលិតផលរបស់ប្រជាជនទៀតផង។

កម្មករបើកបររថភ្លើង បើកបររថយន្ត កម្មករជួសជុលផ្លូវ ស្ពាន បានបញ្ចេញនូវវីរភាពដ៏ខ្ពង់ខ្ពស់របស់ខ្លួន ដោយបានធ្វើដំណើរដឹកជញ្ជូនតាមផ្លូវប្រកបដោយគ្រោះថ្នាក់ ដែលមានការស្ទាក់បាញ់ ដាក់មីនរបស់ខ្មាំងសត្រូវ ត្រូវជួសជុលផ្លូវស្ពាននៅកន្លែងដាច់ស្រយាល ដែលសមមិត្តទាំងនេះ ចាំបាច់ត្រូវធ្វើការងារដឹកជញ្ជូន ឬជួសជុលផ្លូវស្ពានផង ត្រូវបំពេញភារកិច្ចប្រយុទ្ធការពារទំនិញ ការពារមធ្យោបាយផង។

ខាងប្រៃសណីយ៍ និងទូរគមនាគមន៍ ក៏មានការរីកចំរើនគួរអោយកាត់សម្គាល់ដែរ។ ទូរស័ព្ទទាក់ទងក្នុងទីក្រុងភ្នំពេញ និងពីទីក្រុងភ្នំពេញទៅបណ្តាខេត្ត បានដាក់អោយដំណើរការបានយ៉ាងឆាប់។ ជំនួយជាផ្កាយរណបរបស់សហភាពសូវៀត បានសម្រួលអោយយើងទាក់ទងទូរស័ព្ទជាមួយប្រទេសក្រៅ។ ទូរលេខរវាងក្រុងភ្នំពេញ ជាមួយបណ្តាខេត្ត រវាងភ្នំពេញជាមួយប្រទេសក្រៅ ក៏មានដំណើរការជាប្រក្រតី។ សំបុត្រកញ្ចប់បញ្ញើទាំងក្នុង និងក្រៅប្រទេស បានបញ្ជូនទៅមកយ៉ាងឆាប់រហ័ស បង្កលក្ខណៈងាយស្រួលអោយការទាក់ទងរវាងមជ្ឈិម និងមូលដ្ឋាន រវាងអង្គភាពរដ្ឋ ជាមួយអង្គភាពរដ្ឋ រវាងប្រជាជន និងប្រជាជន រវាងក្នុងប្រទេស និងក្រៅប្រទេស។

ក្នុងវិស័យគមនាគមន៍ ដឹកជញ្ជូន និងប្រៃសណីយ៍ ក៏មានបញ្ហាសេសសល់ជាច្រើន។ ភាពទ្រុឌទ្រោម និងការខូចខាតថ្នល់ ស្ពាន រាប់ទាំងផ្លូវដែកផង ទាមទារជាបន្ទាន់នូវការជួសជុលធំ ប៉ុន្តែយើងខ្វះថវិកា

និងសម្ភារៈ ដើម្បីធ្វើការងារនេះ។ បន្ថែមលើនេះ ការដឹកជញ្ជូនទំនិញ ពិសេសការដឹកជញ្ជូនឈើមានទម្ងន់លើសពីការទទួលបានរបស់ស្ពាន ថ្នល់ ធ្វើអោយខូចផ្លូវ និងបាក់ស្ពានថែមទៀត។ មធ្យោបាយដឹកជញ្ជូនអ្នកដំណើរ មានមិនគ្រប់សំណូមពរនៃការធ្វើដំណើររបស់ប្រជាជន។ រថយន្ត ឬកាណូតនីមួយៗ ផ្ទុកអ្នកធ្វើដំណើរ និងទំនិញហួសចំណុះ នាំអោយគ្រោះថ្នាក់ដល់អាយុជីវិតប្រជាជន។ ការរៀបចំផែ ជាចំណតកាណូតចូលចត ធ្វើបានតិច ទុកអោយកាណូតកប៉ាល់បុកច្រាំង នាំដល់គ្រោះថ្នាក់ចំពោះប្រជាជន។ ទាំងអស់នេះ ធ្វើអោយប្រជាជនជួបការលំបាកក្នុងការធ្វើដំណើរ ខាតពេលវេលា ហើយរហូតគ្រោះថ្នាក់ដល់អាយុជីវិតទៀត។ បន្ថែមលើនេះ ប៉ុន្មានឆ្នាំមុននេះ ស្នាក់ការត្រួតពិនិត្យតាមផ្លូវទាំងស្របច្បាប់ ទាំងមិនស្របច្បាប់មានច្រើនពេក នាវាឬរថយន្តត្រូវឈប់រង់ចាំការត្រួតពិនិត្យមួយកន្លែងៗ មិនតិចជាងកន្លះម៉ោងទេ រហូតមានដល់ទៅពីរឬបីម៉ោងផង ដែលកាន់តែធ្វើអោយប្រជាជនជួបការលំបាក បាត់ពេលវេលាយ៉ាងច្រើនក្នុងការធ្វើដំណើរ ហើយតម្លៃឈ្នួលរថយន្ត ឬកាណូតក៏កើនឡើងទៀត។ នៅចុងឆ្នាំ ១៩៨៧ ក្រុមប្រឹក្សារដ្ឋមន្ត្រី បានចេញបញ្ជាបិទស្នាក់ការត្រួតពិនិត្យមួយចំនួនធំ នាំអោយការធ្វើដំណើរបានឆាប់ជាងមុន ប៉ុន្តែក៏នៅតែជួបដំណើរអេសកម្ម បណ្តាលមកពីការត្រួតពិនិត្យយូរពេករបស់ស្នាក់ការដែលនៅសល់ ឬមកពីជនអាក្រក់ស្ទាក់រថយន្ត ឬកាណូតម្តងម្កាលដើម្បីរកកម្រៃ។

ការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនអ្នកដំណើររបស់ឯកជន ដូចជារថយន្ត កាណូត ធ្វើមិនទាន់បានល្អ ហើយក៏មិនទាន់មានគោល

នយោបាយច្បាស់លាស់អំពីការដឹកជញ្ជូនឯកជននេះនៅឡើយ។ បញ្ហានៅត្រង់ថា ក្នុងពេលដែលរដ្ឋមិនទាន់មានមធ្យោបាយដឹកជញ្ជូន អ្នកដំណើរអោយបានគ្រប់គ្រាន់តាមសំណូមពរ នៃការធ្វើដំណើររបស់ប្រជាជន ដែលចេះតែកើនឡើងនោះ តើយើងគួរប្រើប្រាស់ទុន និងមធ្យោបាយរបស់ឯកជន ក្រោមការដឹកនាំគ្រប់គ្រងរបស់រដ្ឋ បំរើដល់ការដឹកជញ្ជូន ពិសេសក្នុងផ្នែកដឹកជញ្ជូនអ្នកដំណើរនេះឬទេ? ឯកជន មានសិទ្ធិប្រើប្រាស់រថយន្តផ្ទាល់ខ្លួនហើយ ប៉ុន្តែយើងគួរលើកទឹកចិត្តដល់ការនាំចូលរថយន្តដឹកជញ្ជូនអ្នកដំណើរ ទាំងតូចទាំងធំ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាជន។ ម្យ៉ាងទៀត ជាការជាក់ស្តែងក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ឯកជនមួយចំនួនក៏បានធ្វើអាជីវកម្មរួចស្រេចទៅហើយ ជារថយន្តឈ្នួល ជាកាណូតតូច និងមធ្យម ដែលពេលនេះ គ្រាន់តែទាមទារអោយមានគោលការណ៍ពង្រីក និងការគ្រប់គ្រងអោយបានល្អតែប៉ុណ្ណោះ។ ចុងក្រោយនេះ រដ្ឋយើងបានដើរដល់ការសំរេច អនុញ្ញាតអោយឯកជនធ្វើអាជីវកម្មក្នុងផ្នែកដឹកជញ្ជូនអ្នកដំណើរ ហើយលើកទឹកចិត្តដល់ការនាំចូលនូវមធ្យោបាយដឹកជញ្ជូនតាមរយៈនៃការបន្ថយពន្ធនាំចូល។

បញ្ហាគួរអោយកត់សំគាល់មួយទៀត គឺគ្រោះថ្នាក់ដោយការធ្វើចរាចរក្នុងទីក្រុង តាមផ្លូវនានានៅក្រៅក្រុង មានអត្រាខ្ពស់ បណ្តាលមកពីការដឹកជញ្ជូនហួសចំណុះ និងការបើកបរលឿន ហើយគ្មានសណ្តាប់ធ្នាប់ ដែលធ្វើអោយរបួសពិការ និងបាត់បង់ជីវិតមនុស្ស និងខូចខាតទ្រព្យសម្បត្តិអស់ជាច្រើន។

ក្នុងផ្នែកចរាចរបែងចែក ខ្ញុំចង់លើកឡើងជាសំខាន់អំពី ពាណិជ្ជកម្ម

ហិរញ្ញវត្ថុ និងធនាគារ។

យើងចាំបាច់ត្រូវពិនិត្យឡើងវិញ នូវសភាពការណ៍ក្នុងគ្រាដំបូង ដើម្បីពិនិត្យពីចំណុចចេញដំណើរនៃការរៀបចំ និងការវិវឌ្ឍន៍នៃផ្នែកចរាចរបែងចែករយៈពេល ១០ ឆ្នាំកន្លងមក។ ជនបរទេស និងជនកម្ពុជានៅបរទេសមួយចំនួន ដែលមិនបានស្គាល់របប ប៉ុល ពត ពេលមកដល់កម្ពុជា គេហាក់ដូចជាមានការភ្ញាក់ផ្អើលចំពោះមុខមាត់ទីផ្សាររបស់កម្ពុជា ដែលមានសកម្មភាពជាធម្មតា ទីផ្សារសំបូរដោយទំនិញ និងមានប្រាក់កាសចាយវាយ ហើយមានមួយចំនួនហាក់ដូចជាពុំបានជឿថា ប៉ុល ពត បានបំផ្លាញចោលរូបិយវត្ថុ និងទីផ្សារនៅកម្ពុជាទេ ...។

យើងនៅចាំបានថា ក្នុងឆ្នាំ ១៩៧៤ មានគណៈប្រតិភូសេដ្ឋកិច្ចហិរញ្ញវត្ថុមួយរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដឹកនាំដោយ អៀង សារី និង ចាន់ សេងហុង ដែលពេលនោះជាសមាជិកភូមិភាគបូព៌ាទិស និងជាលេខាបក្សដំបន់ ២១ របស់ភូមិភាគបូព៌ាទិស បានធ្វើទស្សនកិច្ចនៅប្រទេសមួយចំនួន ដែលជាសំខាន់មានសាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។ គេអាចដឹងបានថា បំណងសំខាន់គឺ ស្នើអោយចិនជួយបោះក្រដាសប្រាក់ថ្មី ដើម្បីប្តូរជាមួយក្រដាសប្រាក់របស់ លន់ នល់ នៃសាធារណរដ្ឋខ្មែរ។ ក្រដាសប្រាក់នេះត្រូវបានយកមកតាំងពិព័រណ៌បង្ហាញប្រជាជន នៅក្នុងតំបន់រំដោះ នាចុងឆ្នាំ ១៩៧៤ និងដើមឆ្នាំ ១៩៧៥។ ដើមឆ្នាំ ១៩៧៥ តាមវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា គេបានប្រកាសផ្សាយអំពីការឈប់ចាយក្រដាសប្រាក់របស់ លន់ នល់។ ការឈប់ចាយប្រាក់ បានធ្វើឡើងភ្លាមនៅក្នុងដំបន់រំដោះ ប៉ុន្តែនៅបន្តចាយក្នុងតំបន់ដែល លន់ នល់ កាន់

*កាប់ ហើយក៏ត្រូវឈប់ចាយជាស្ថាពរនៅថ្ងៃទី ១៧ មេសា ១៩៧៥ ពេលដែលរបប លន់ នល់ ដួលរលំ។ យើងនៅចាំបានថា ប្រជាជននៅក្រុងភ្នំពេញ និងទីក្រុងនានាទូទាំងប្រទេស ដែលត្រូវពួក ប៉ុល ពត ជម្លៀសចេញ គេគ្មានបានដឹងអំពីការមិនចាយប្រាក់នេះទេ គួបផ្សំនឹងពេលដេញប្រជាជនពីទីក្រុង ពួក ប៉ុល ពត បានបញ្ឆោតប្រជាជនថា ទៅតែ ២ ទៅ ៥ ថ្ងៃ ឬក្នុងរយៈពេលខ្លីប៉ុណ្ណោះ ដើម្បីជៀសអោយផុតពីការទម្លាក់គ្រាប់បែករបស់អាមេរិក។ ដូច្នេះ ប្រជាជន ភាគច្រើនត្រូវចេញពីផ្ទះដោយនាំទៅជាមួយនូវរបស់ស្រាលៗ សំខាន់ ប្រាក់ មាស ពេជ្រ ប៉ុន្តែចេញផុតពីផ្ទះ ពីទីក្រុង របស់ទាំងនេះលែងមានតម្លៃអ្វីទាំងអស់ ដោយហេតុថា ទូទាំងប្រទេសលែងមានការចាយប្រាក់ លែងមានទីផ្សារដើម្បីផ្លាស់ប្តូរទំនិញហើយ ហើយគេក៏មិនអាចវិលត្រឡប់មកផ្ទះសម្បែង ភូមិកំណើតវិញបានដែរ។*

*យើងនៅចាំសំដីរបស់ពួក ប៉ុល ពត បកស្រាយអំពីខ្លឹមសារនៃជ័យជំនះ ១៧ មេសា ១៩៧៥ ថាៈ យើងបានសំរេចទាំងស្រុង និងជាស្ថាពរនូវការបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យហើយ បដិវត្តន៍កម្ពុជាបានឈានចូលដំណាក់កាលធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ ត្រង់នេះ តាមការបកស្រាយរបស់គេ ការសំរេចបដិវត្តន៍ប្រជាជាតិ គឺការវាយបណ្តេញចក្រពត្តិអាមេរិកចេញពីកម្ពុជា ហើយគ្មានរបបអាយ៉ងនៅកម្ពុជា ឯការសំរេចបដិវត្តន៍ប្រជាធិបតេយ្យ គឺការគាស់រំលើងរបបសក្តិភូមិ នាយទុន តាមរយៈការជម្លៀសប្រជាជនចេញពីទីក្រុង តាមការឈប់ចាយវាយប្រាក់កាស។ ពេលប្រជាជនចេញពីទីក្រុង គឺគេមិនអាចស្ពាយមកជាមួយនូវរោងចក្រ ផ្ទះសម្បែង មធ្យោបាយ*

ផលិតកម្មផ្សេងទៀតទេ ហើយបើយករថយន្តចេញមក ពេលអស់សាំង គេក៏ត្រូវចោលរថយន្ត បើយកប្រាក់រៀលចេញមក គេក៏មិនអាចទិញអ្វីបាន មាស ពេជ្រ ក៏លែងមានតម្លៃ ដូច្នេះកម្មសិទ្ធិនៃរបបសក្តិភូមិ នាយទុន គឺត្រូវរលាយទាំងស្រុង។ ឯនៅជនបទ គ្មានម្ចាស់ដីទៀតទេ ហើយក៏គ្មានការរកស៊ីជាឯកជនដែរ ប្រជាជនទាំងចាស់ទាំងថ្មី (ប្រជាជនថ្មី គឺប្រជាជនដែលត្រូវជម្លៀសចេញពីទីក្រុង) សុទ្ធតែនៅក្នុងសហករណ៍ដូចគ្នា។ ទូទាំងប្រទេស គ្មានអ្នកមាន គ្មានអ្នកក្រដូចមុនទៀតទេ។ ដូចពួក ប៉ុល ពត និយាយមែន ទូទាំងប្រទេស ប្រជាជនត្រូវស្ថិតក្នុងសហករណ៍ប្រមូលផ្តុំ ធ្វើរួមស៊ីរួម គ្មានទំនាក់ទំនងផ្លាស់ប្តូរទំនិញទេ ទោះជាតាមរូបភាពណាក៏គ្មានដែរ។

ដូច្នេះ ក្រោយការដួលរលំទៅនៃរបប ប៉ុល ពត ទំនាក់ទំនងផលិតកម្មតាមបែបទាសភាពនេះ ត្រូវបំផ្លាញចោលភ្លាមជាមួយដែរ ហើយទំនាក់ទំនងផលិតកម្មថ្មីត្រូវចាប់ផ្តើមឡើងភ្លាម ក្នុងសភាពការណ៍ដែលគ្មានទីផ្សារ និងគ្មានរូបិយវត្ថុ ធ្វើជាតំណាងអោយការផ្លាស់ប្តូរទំនិញ។

ពិតជារឿងដ៏ចម្លែកហើយ បើប្រៀបធៀបជាមួយប្រទេសដទៃលើសកលលោកនេះ ពេលដែលរបបថ្មីត្រូវទទួលតំណពីរបបចាស់។ ប្រទេសនានា ពេលរបបថ្មីឡើងជំនួសរបបចាស់ គឺឈរលើមូលដ្ឋានដែលមានស្រាប់ ដោយគ្រាន់តែត្រូវកែលំអតាមនយោបាយថ្មីតែប៉ុណ្ណោះ។ គេបោះផ្សាយរូបិយវត្ថុថ្មីផ្លាស់ប្តូរជំនួសអោយរូបិយវត្ថុចាស់ ដោយប្រជាជនរក្សាបាននូវតម្លៃនៃទ្រព្យសម្បត្តិរបស់គេ ហើយមានប្រទេសជាច្រើនមិនទាំងប្តូរប្រភេទរូបិយវត្ថុផង ដោយគេបន្តប្រើប្រាស់រូបិយវត្ថុពីរបបចាស់ គេបន្តទំនាក់ទំនងផ្លាស់ប្តូរទំនិញក្នុងទីផ្សារដែល

មានស្រាប់។ ឯនៅកម្ពុជា គឺត្រូវចាប់ផ្ដើមពីការរៀបចំថ្មី ទាំងទីផ្សារ ទាំងរូបិយវត្ថុ ហើយអ្វីៗ ទាំងអស់ក៏ត្រូវរៀបចំឡើងវិញជាថ្មីដែរ ចាប់តាំងពីកម្មសិទ្ធិលើដីធ្លី ផ្ទះសម្បែងក្នុងទីក្រុង រហូតដល់មធ្យោបាយផលិតកម្ម។

ជាក្រឹត្យក្រម បន្ទាប់ពីការលោយទៅនូវបែបផែនផលិតកម្មមួយបែនផែនផលិតកម្មថ្មីមួយទៀត ត្រូវតែឡើងមកជំនួស។ នៅកម្ពុជា គឺដូចនេះឯង បន្ទាប់ពីកំទេចចោលនូវសហករណ៍ប្រមូលផ្ដុំ ផ្ញើរួមស៊ីរួមរបស់ពួក ប៉ុល ពត ប្រជាជនចាប់ផ្ដើមចែកចាយគ្នានូវស្បៀងអាហារ មធ្យោបាយ និងឧបករណ៍ផលិតកម្ម ហើយក៏ចាប់ផ្ដើមបង្កើតឡើងភ្លាមដែរ នូវរូបភាពផ្លាស់ប្ដូរទំនិញតាមរយៈទីផ្សារ ដែលវាចាប់កកើតជាដំបូងរវាងបុគ្គល និងបុគ្គល រវាងគ្រួសារ និងគ្រួសារ ឬរវាងសមូហភាព និងសមូហភាព។ ពិតមែនហើយ ការចាប់ផ្ដើមដំបូងនូវទំនាក់ទំនងផ្លាស់ប្ដូរទំនិញ គឺវាកើតឡើងដោយឯកឯង គ្មានការចាត់តាំងដឹកនាំពីរដ្ឋអំណាចទេ តែវាជាសំណូមពរនៃសង្គម ជាភាពចាំបាច់ដែលប្រជាជនត្រូវធ្វើដោយខានមិនបាន ហើយដែលរដ្ឋាភិបាលបានចាត់ទុកថា ជាចំណុចរីកចំរើនតាមក្រឹត្យក្រម ដែលត្រូវតែជំរុញអោយវារីកចំរើនថែមទៀត។ ន័យពិតប្រាកដ គឺជំរុញអោយផលិតកម្មមានការរីកចំរើន តាមទិសផលិតទំនិញបំរើសេចក្ដីត្រូវការរបស់សង្គម ហើយដែលរដ្ឋាភិបាលត្រូវគិតជាបន្ទាន់ ដល់ការបោះផ្សាយក្រដាសប្រាក់ដើម្បីជាតំណាងអោយការផ្លាស់ប្ដូរទំនិញលើទីផ្សារ។

គ្រាដំបូងនៃការចាប់ផ្ដើមទំនាក់ទំនងផ្លាស់ប្ដូរទំនិញ ក្នុងសភាពការណ៍មិនទាន់មានក្រដាសប្រាក់ យើងពិនិត្យឃើញការផ្លាស់ប្ដូរសំខាន់ហើយជាដំបូង គឺរវាងបុគ្គល និងបុគ្គល រវាងគ្រួសារ និងគ្រួសារ

ដោយប្រើប្រាស់របស់ និងរបស់ ទំនិញ និងទំនិញ ដើម្បីផ្លាស់ប្តូរជាមួយគ្នា ដូចជាការយកអង្ករ ឬស្រូវ ដូរយកក្រមា ឬក្អម យកស្រូវអង្ករ ដូរមាន់ ទា ជ្រូក ត្រី។ល។ រហូតយកមាស ឬត្បូងមានតម្លៃ ដូរជាមួយស្បៀង ឬវត្ថុផ្សេងទៀត។ ដូច្នេះ មាស និងត្បូងមានតម្លៃ ចាប់ផ្តើមមានតម្លៃឡើងវិញ។ សូមបញ្ជាក់ថា បញ្ហាមាស ពេជ្រ ឬត្បូងមានតម្លៃ មិនមែនជារបស់ដែលចែកបានពីសហករណ៍ ប៉ុល ពត មកទេ តែជារបស់បុគ្គល ឬគ្រួសារខ្លះ ដែលបានខិតខំលាក់ទុកដោយលួចលាក់ពីពេល ប៉ុល ពត កាន់អំណាច ហើយដែលបានក្លាយជាទុនដ៏សំខាន់មួយ សំរាប់ការរស់នាគ្រាដំបូងផង និងសំរាប់ការពង្រីកផលិតកម្មនាពេលក្រោយៗ នេះផង។ ជាជំហានៗ យើងសង្កេតឃើញនូវការកកើតឡើងជាទីផ្សារតូចៗ នៅតាមទីក្រុង ទីប្រជុំជន និងមានផ្ទះលក់ទំនិញរបស់គ្រួសារ ហើយដែលក្នុងដំណាក់កាលមុនមានការចាយប្រាក់រៀល មាសបានដើរតួនាទីយ៉ាងសំខាន់ តំណាងអោយរូបិយវត្ថុ ធ្វើជាអាជ្ញាកណ្តាលក្នុងការផ្លាស់ប្តូររវាងទំនិញមួយ ជាមួយនឹងទំនិញមួយទៀត។ ក្នុងរយៈពេលដំបូងនេះ មាសនេះឯងបានបង្កើនឡើងនូវប្រភពទំនិញសំរាប់ទីផ្សារ ដែលមួយផ្នែក មាសប្តូរបាននូវមធ្យោបាយ និងឧបករណ៍ផលិតកម្មសម្រាប់ផលិតមុខទំនិញ និងមួយផ្នែកទៀត បានប្រើប្រាស់មាសដើម្បីនាំទំនិញពីថៃឡង់ដ៍ តាមរយៈខេត្តកោះកុង បាត់ដំបង សៀមរាប និងពីវៀតណាម តែសំខាន់ ពីថៃឡង់ដ៍។ បញ្ហានាំមាសចេញទៅប្រទេសថៃឡង់ដ៍ ដើម្បីប្តូរមកវិញនូវមុខទំនិញប្រើប្រាស់ រហូតដល់មធ្យោបាយផលិតកម្ម បានក្លាយទៅជាបញ្ហាមួយ ដែលយើងធ្លាប់និយាយថា ជំងឺហូរឈាមមាស។ ពិតណាស់ ការហូរមាសចេញពី

ប្រទេសមួយ ទោះជាប្រទេសណាក៏ដោយ ក៏សុទ្ធតែជាការមិនល្អសំរាប់សេដ្ឋកិច្ចជាតិនោះទេ ប៉ុន្តែសំរាប់ប្រទេសកម្ពុជា ការហូរចេញមាសសំរាប់នាំចូលមកវិញនូវទំនិញ និងមធ្យោបាយផលិតកម្មក្នុងពេលដែលប្រជាជនកំពុងជួបប្រទះការខ្វះខាត ហើយរដ្ឋគ្មានលទ្ធភាពដោះស្រាយនោះ សភាពការណ៍នេះហាក់ដូចជាមិនអាក្រក់ ពេកទេ។ បើគ្មានមាសទៅ ក៏ទំនិញមិនបានមកដែរ។ បើចង់បានទំនិញ ឬមធ្យោបាយផលិតកម្មពីប្រទេសក្រៅមក គឺចាំបាច់ត្រូវប្រើប្រាស់រូបិយប័ណ្ណបរទេស ឬត្រូវប្រើទំនិញដូចជាកៅស៊ូ ឈើ កសិផល។ល។ ដើម្បី ប្តូរជាមួយបរទេស ហើយនោះក៏ជាមាសដែរ។ ហេតុនេះហើយបានជាមានមតិមួយចំនួនលើកឡើងថា ការហៅថាជំងឺហូរឈាមមាស ហាក់ដូចជាពុំត្រឹមត្រូវ ព្រោះមាសជាប្រភេទទំនិញមួយ ដើម្បីប្តូរយកប្រភេទទំនិញផ្សេងទៀត។ បើមិនអោយវាធ្វើចរាចរទេ វាក៏ត្រូវតែស្លាប់ដូចជាខ្លួនប្រាណមនុស្ស គឺបើឈាមមិនធ្វើចរាចរទេ មនុស្សមិនអាចរស់បានទេ។ មាសក៏ដូចគ្នា បើកប់ទុកចោលទៅក៏គ្មានតម្លៃប្រើប្រាស់ ហើយយើងក៏មិនអាចពង្រីកបាននូវមធ្យោបាយផលិតកម្ម មិនអាចនាំមកនូវមុខទំនិញដែលយើងកំពុងខ្វះខាតនេះដែរ។ រួមមក ក្នុងរយៈពេលដំបូងនេះ មាសមានតួនាទីសំខាន់ណាស់ វាផ្តល់លទ្ធភាពអោយយើងនាំមកនូវទំនិញផ្គត់ផ្គង់ទីផ្សារ ពង្រីកបានមូលដ្ឋានផលិតកម្មផង ហើយមានតួនាទីជាអាជ្ញាកណ្តាលសំរាប់ការផ្លាស់ប្តូររវាងទំនិញ ជាមួយទំនិញផ្សេងទៀតផង។

ប្រការដែលយើងគួរសិក្សាដកពិសោធន៍ក្នុងគ្រាដំបូងនេះ គឺបញ្ហាតម្លៃ និងថ្លៃ។ ទីផ្សារត្រូវបានកើតឡើងដោយប្រជាជន ក្នុងសភាពការណ៍មិនទាន់មានរូបិយវត្ថុ ដូច្នេះរដ្ឋគ្មានការកំណត់អំពីតម្លៃ និងថ្លៃ

លើមុខទំនិញណាមួយទេ រាប់ទាំងមាសពេជ្រ ត្បូងមានតម្លៃផង។ ប៉ុន្តែ ប្រជាជនគេចេះគិត ហើយសម្រុះសម្រួលគ្នាបានយ៉ាងស្រួល អំពីថ្លៃ ដូចជា ក្រមាមួយដូរបានស្រូវប៉ុន្មានគីឡូក្រាម ឬមាសមួយជីដូរបាន អង្ករប៉ុន្មានគីឡូក្រាម រហូតគេអាចសម្រុះសម្រួលធ្វើការផ្លាស់ប្តូរទំនិញ ជាមួយប្រជាជននៃប្រទេសជិតខាង ដូចជា វៀតណាម ឡាវ ថៃ ដែល មានចរិតជាពាណិជ្ជកម្មក្រៅប្រទេសទៀតផង។ ប្រជាជនយើងចេះគិត គូរយ៉ាងច្បាស់លាស់អំពីក្បាលចូល និងក្បាលចេញ នៃផលិតផល ដែលនាំដល់ការដាក់ចេញនូវថ្លៃ សំរាប់ផលិតផលរបស់គេបានយ៉ាង សមស្រប និងនាំដល់ការរីកចំរើននៃផលិតកម្ម និងស្ថិរភាពទីផ្សារ ក្នុង គ្រាដំបូងផង។

ក្នុងពេលដែលទីផ្សារបានកកើត និងរីកចំរើនឡើងនោះ ពិតមែនតែ វាកើតឡើងដោយឯកឯង តាមរយៈនៃសកម្មភាពមនុស្សក្នុងសង្គម ប៉ុន្តែ រដ្ឋយើងក៏បានជំរុញលើកទឹកចិត្តអោយផ្នែកនេះវិវឌ្ឍចំទិស និង មានស្ថិរភាព។ រដ្ឋយើងបានដំណើរការ រៀបចំឡើងវិញភ្លាមដែរនូវ ក្បាលម៉ាស៊ីនដឹកនាំផ្នែកពាណិជ្ជកម្ម ដោយបង្កើតឡើងនូវគណៈកម្មាធិ ការពាណិជ្ជកម្មមួយ ដែលបច្ចុប្បន្នជាក្រសួងពាណិជ្ជកម្មក្នុង និងក្រៅ ប្រទេស ព្រមទាំងបង្កើតឡើងនូវគណៈកម្មាធិការហិរញ្ញវត្ថុ ធនាគារមួយ ដែលបច្ចុប្បន្នមានស្ថាប័នពីរ គឺក្រសួងហិរញ្ញវត្ថុ និងធនាគារជាតិនៃប្រ ជាជនកម្ពុជា។ យើងក៏គួររំលឹកផងដែរថា ក្នុងគ្រាដំបូងស្ថាប័នទាំងបីនេះ ពុំទាន់មានសកម្មភាពជាអាជីវកម្មភ្លាមទេ បញ្ហាសំខាន់គឺមានរៀបចំជ្រើស រើសកម្មាភិបាល បុគ្គលិក និងបណ្តុះបណ្តាលបច្ចេកទេសជំនាញ។ ការងាររបស់ផ្នែកពាណិជ្ជកម្មពេលដំបូងនេះ សំខាន់គឺធ្វើការងារផ្គត់

ផ្គត់ផ្គង់ជីវភាពអោយកម្មាភិបាលបុគ្គលិក កងកម្លាំងប្រដាប់អាវុធតាមរបៀបបើកផ្តល់អោយដោយគ្មានការទូទាត់ អត់គិតពីការចំណេញខាត។ គ្រប ខ័ណ្ឌដែលចូលបំរើការងាររដ្ឋ ដំបូងក៏គ្មានប្រាក់បៀវត្ស ដូច្នេះគេរស់នៅដោយការផ្គត់ផ្គង់ទាំងស្រុងពីរដ្ឋ។ ការងាររបស់ហិរញ្ញវត្ថុ ធានាគារនាគ្រាដំបូង សំខាន់បំផុតគឺការរៀបចំបោះផ្សាយក្រដាសប្រាក់ថ្មី។

ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៨០ ក្រដាសប្រាក់រៀលត្រូវបានដាក់អោយប្រើប្រាស់ ព្រមពេលជាមួយនឹងការដាក់អោយប្រើប្រាស់ថ្លៃលើទំនិញមួយចំនួនដែលសំខាន់ៗ ដូចជាស្បៀង គ្រឿងឧបភោគបរិភោគ និងការរៀបចំឡើងនូវប្រាក់បៀវត្ស ដែលពេលនោះ យើងហៅថា ប្រាក់ឧបត្ថម្ភសំរាប់កម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ។

ការដាក់អោយប្រើប្រាស់នូវប្រាក់រៀលថ្មី បានអនុញ្ញាតអោយផ្នែកពាណិជ្ជកម្មរដ្ឋ ចាប់ផ្តើមធ្វើសកម្មភាពមានលក្ខណៈជាអាជីវកម្មចំណេញខាត ធ្វើអោយពាណិជ្ជកម្មឯកជន និងទីផ្សារមានសកម្មភាពជាប្រក្រតី ធ្វើអោយផលិតកម្មមានសន្ទុះរីកចំរើនគួរអោយកត់សម្គាល់។ ប្រាក់រៀលបានពង្រីកតួនាទីជាបណ្តើរៗ ហើយឈានទៅធ្វើជាអាជ្ញាកណ្តាលជំនួសអោយមាស ក្នុងការផ្លាស់ប្តូរផលិតផលនៅក្នុងប្រទេស។ នេះជាជោគជ័យដ៏សំខាន់មួយរបស់បក្ស និងរដ្ឋយើង ក្នុងនយោបាយសេដ្ឋកិច្ច ព្រោះថាខ្មាំងសត្រូវក៏ខិតខំបំផ្លាញយើង តាមរយៈនៃការបំផ្លាញក្រដាសប្រាក់ឃោសនាមិនអោយប្រជាជនទទួលស្គាល់ និងចាយវាយប្រាក់រៀលរបស់យើង តែទីបំផុត ប្រជាជនអបអរសាទរហើយជឿទុកចិត្តលើក្រដាសប្រាក់របស់យើង ដែលនាំដល់ការជំរុញផលិតកម្មយ៉ាងខ្លាំងក្លា។

យើងគួររំលឹកឡើងវិញបន្តិច អំពីចរាចរសាច់ប្រាក់របស់យើងក្នុង

គ្រាដំបូងៗ ពិតមែនហើយ ក្នុងការបោះផ្សាយក្រដាសប្រាក់រៀលនាគ្រាដំបូង ប្រជាជនមានការសប្បាយរីករាយណាស់ ប៉ុន្តែមិនមានអ្នកណាក៏សុទ្ធតែទទួលបានក្រដាសប្រាក់ភ្លាមនោះទេ។ អ្នកដែលទទួលបានក្រដាសប្រាក់មុនគេ គឺកម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធនៅក្រុងភ្នំពេញ និងទីក្រុងធំៗ ផ្សេងទៀត តាមរយៈនៃការបើកប្រាក់ឧបត្ថម្ភជាលើកដំបូង បន្ទាប់មកប្រាក់នេះ បានចេញពីដៃអ្នកទាំងនេះ ទៅកាន់អ្នកលក់ទំនិញនៅតាមទីក្រុងធំៗ។

ចំពោះប្រជាជនមួយភាគធំ មិនទាន់បានទទួលប្រាក់ ហើយក៏មិនទាន់ស្គាល់ប្រាក់រៀលពិតប្រាកដនៅឡើយ វៀរលែងតែអ្នកដែលមានទំនិញលក់ៗ បើនិយាយពីកសិករវិញ កសិករនៅតំបន់ផលិតកសិផលបានប្រើប្រាស់មុនគេ អាស្រ័យដោយគេមានផលិតផលលក់មុន ឯតំបន់ផលិតស្រូវភាគច្រើន គឺរហូតដល់ពេលបញ្ចប់ការច្រូតកាត់រដូវវស្សា ឆ្នាំ ១៩៨០ ទើបមានប្រាក់រៀលប្រើប្រាស់។

នៅតំបន់ដាច់ស្រយាល ចរាចរប្រាក់រៀលក៏កាន់តែមានសភាពយឺតដែលត្រូវទាញបន្ទាយអស់រយៈពេលយ៉ាងយូរ ទើបប្រជាជនបានស្គាល់ និងបានប្រើប្រាស់ប្រាក់រៀល។ យើងអាចនិយាយបានថាប្រហែលជាចុងឆ្នាំ ១៩៨១ ជាទូទៅ ប្រជាជនបានស្គាល់ និងបានប្រើប្រាស់ប្រាក់រៀល ទោះជាតិចក្តីច្រើនក្តី ប៉ុន្តែតាមការពិនិត្យ ប្រាក់រៀលបោះផ្សាយក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូង មិនជាច្រើនប៉ុន្មានទេ ហើយចំនួននោះបានប្រមូលផ្តុំតែនៅភ្នំពេញ កណ្តាល បាត់ដំបង កំពង់ចាម កំពង់សោម កោះកុង ដែលមានសមាមាត្រជិត ៦០ ភាគរយ នៃចំនួនសរុបសាច់ប្រាក់ដែលបានបោះផ្សាយ ដូច្នេះ នៅបណ្តាខេត្តផ្សេងទៀត

មានមិនច្រើនទេ។ តាមរយៈនេះ យើងអាចដឹងបានថា ប្រជាជននៅតាមខេត្តទាំងនេះ ពុំមានប្រាក់រៀលច្រើនទេ ហើយបើមាន ក៏ប្រមូលផ្តុំសំខាន់នៅតាមទីក្រុង ទីប្រជុំជនដែរ។

បើពិនិត្យពីល្បឿននៃការធ្វើដំណើររបស់ប្រាក់រៀល ហាក់ដូចជាយឺត ប៉ុន្តែ បើប្រៀបធៀបទៅនឹងល្បឿនរីកចំរើនរបស់ទីផ្សារ របស់ផលិតកម្ម ហើយប្រជាជនមិនទាន់ស្គាល់នូវក្រដាសប្រាក់ គួបផ្សំជាមួយ ការឃោសនាបំផ្លាញរបស់ខ្មាំងមិនអោយប្រជាជនទទួលស្គាល់និងចាយវាយប្រាក់រៀលផងនោះ យើងសន្និដ្ឋានបានថា ប្រាក់រៀលបានធ្វើដំណើរយ៉ាងលឿន ស្របតាមចង្វាក់ផលិតកម្ម ទាំងនៅទីក្រុង ទាំងនៅជនបទ ហើយមានឥទ្ធិពលយ៉ាងធំធេង ចំពោះផលិតកម្ម និងចំពោះជីវភាពរស់នៅរបស់ប្រជាជន។

មកដល់ពេលនេះ ទំនាក់ទំនងរវាងរូបិយវត្ថុ និងទំនិញ បានក្លាយទៅជាសកម្មភាពប្រក្រតី បង្កឡើងនូវភាពងាយស្រួលដល់ការចរាចរបែងចែក ដល់ទំនាក់ទំនងរវាងមនុស្ស និងមនុស្ស រវាងរដ្ឋ និងប្រជាជន។ តែយើងក៏មិនភ្លេចនឹងលើកយកមកនិយាយ អំពីចំណុចខ្វះខាតរបស់យើង ដែលទាក់ទងដល់ការរក្សាតម្លៃរូបិយវត្ថុ និងសកម្មភាពរបស់ធនាគារ។ ពេលដំបូង យើងបានបោះផ្សាយប្រាក់រៀលមិនច្រើនមែនប៉ុន្តែជាបណ្តើរៗ យើងបានបោះផ្សាយបន្ថែម ហើយដែលរហូតមកដល់ពេលនេះ ចំនួនប្រាក់រៀល ដែលចរាចរនៅទូទាំងប្រទេស មានទំហំយ៉ាងធំ ដែលគួរអោយព្រួយបារម្ភ។ បញ្ហានេះ បណ្តាលមកពីកត្តាសត្យានុម័តិ ដែលតម្រូវអោយយើងធ្វើ ដូចជាតម្លើងបៀវត្សអោយបុគ្គលិក កម្មករ កម្មាភិបាល និងកងកម្លាំងប្រដាប់អាវុធ ការបញ្ចេញ

ប្រាក់ទៅទិញកសិផល និងស្បៀងពីប្រជាជន និងការបញ្ចេញទៅប្រើប្រាស់ផ្សេងៗ ទៀតៗលៗ ដែលជាកត្តាអត្តនោម័តិ ការបញ្ចេញទំនិញលក់ដើម្បីប្រមូលសាច់ប្រាក់មកវិញ ធ្វើក្នុងសភាពយឺត ការរិះរកវិធានការ ដើម្បីប្រមូលសាច់ប្រាក់ចូលធនាគារក៏នៅយឺត បន្ថែមពីលើនេះទៀត ស្ថាប័ន និងខេត្ត ក្រុងមួយចំនួនរក្សាសាច់ប្រាក់ទុកយ៉ាងច្រើនមិនបញ្ចូលក្នុងធនាគារៗ សភាពការណ៍នេះតម្រូវអោយរដ្ឋបោះផ្សាយនូវសាច់ប្រាក់សំរាប់ចំណាយបន្ថែមទៀត ដែលធ្វើអោយសាច់ប្រាក់មានចំនួនកាន់តែច្រើនលើទីផ្សារ ដែលនាំដល់ការបាត់តុល្យភាពរវាងរូបិយវត្ថុ និងទំនិញ (អតិផរណា) កាន់តែច្រើន ធ្វើអោយជីវភាពកម្មាភិបាល បុគ្គលិក កម្មករ និងកងកម្លាំងប្រដាប់អាវុធ ដែលទទួលបៀវត្សពីរដ្ឋ កាន់តែជួបការលំបាកៗ

សកម្មភាពអាជីវកម្មរបស់ធនាគារទៀតសោត ក៏ធ្វើពុំបានល្អ និងខ្លាំងក្លាៗ បណ្តាញធនាគារ ក្នុងពេលដំបូងមានត្រឹមថ្នាក់ខេត្ត ដែលធ្វើអោយសកម្មភាពអាជីវកម្មមានកំរិតចង្អៀត ហើយក្រោយមក ទោះជាត្រូវបានពង្រីកដល់ស្រុកមួយចំនួនក៏ដោយ ក៏សកម្មភាពធនាគារនៅពុំទាន់បានដើរតួនាទី ជាកម្លាំងជំរុញផលិតកម្មនៅឡើយដែរៗ គោលនយោបាយចំពោះមុខសញ្ញាត្រូវអោយខ្ចីប្រាក់នៅចង្អៀត ចំនួនប្រាក់ដែលប្រជាកសិករត្រូវខ្ចីសំរាប់ទិញឧបករណ៍ផលិតកម្ម ទិញកម្លាំងអូសទាញ ជាគោ-ក្របី កំណត់ដោយស្ទាប់ក្រឡា ហើយកែប្រែយឺតៗ ចំនួនប្រាក់ដែលប្រជាជនខ្ចីបាន មិនអាចទិញបានគ្រប់គ្រាន់ អាស្រ័យដោយការឡើងថ្លៃនៃឧបករណ៍ និងមធ្យោបាយទាំងនេះៗ ឧទាហរណ៍ការកំណត់ដំបូង គោមួយនឹមថ្លៃ ២០០០ រៀល តែប៉ុន្មានឆ្នាំក្រោយមក

គោមួយនឹមឡើងថ្លៃដល់ ៥០០០ រៀល ហើយយើងមិនបានកែប្រែអោយទាន់ពេលវេលាឡើយ។ ទំនាក់ទំនងរវាងប្រជាជន ដែលត្រូវការចងការប្រាក់ ពីធនាគារ ជួបការលំបាកច្រើន អាស្រ័យដោយត្រូវទាមទារបែបបទច្រើនពេក។ សភាពការណ៍នេះ បានធ្វើអោយប្រជាជនត្រូវរត់ទៅចងការប្រាក់ឈ្មួញដែលមានតម្លៃការប្រាក់យ៉ាងខ្ពស់ ហើយមានកន្លែងខ្លះការប្រាក់ស្មើដើមទៀតផង ស្របតាមពាក្យថា "វស្សាមួយកន្តាំង ប្រាំងមួយតៅ" ព្រមជាមួយនោះ ឈ្មួញបានឆ្លៀតឱកាសប្រមូលពីកូនបំណុលនូវផលិតផលសំរេច ដែលធ្វើអោយរដ្ឋយើងគ្រប់គ្រងទំនិញមិនបានល្អ ពាប់ទាំងស្បៀងផង។ ការចលនាប្រជាជនអោយយកប្រាក់មកចងការអោយធនាគារ ដែលយើងធ្លាប់ហៅថា បេឡាសំចៃ នោះក៏ធ្វើបានតិច។ ប្រជាជនទុកសាច់ប្រាក់យ៉ាងច្រើននៅក្នុងគ្រួសារ ដែលជាហេតុធ្វើអោយកប់ទុនហើយក៏កើតមាននូវឱនភាពសាច់ប្រាក់។ ការធ្វើអាជីវកម្មរបស់ធនាគារដើម្បីប្រមូលរូបិយប័ណ្ណបរទេស មិនទាន់បានល្អ។ អត្រាប្តូរប្រាក់មិនទាន់បានលើកទឹកចិត្តអោយជនបរទេសយករូបិយប័ណ្ណមកប្តូរ មិនទាន់បានលើកទឹកចិត្តអាណិកជន កម្ពុជានៅបរទេស ផ្ញើប្រាក់មកតាមរយៈធនាគារ ដើម្បីឧបត្ថម្ភគ្រួសារគេនៅក្នុងប្រទេស ដែលជាហេតុធ្វើអោយគេលួចផ្ញើតាមរយៈប្រៃសណីយ៍ និងផ្ញើតាមរយៈមនុស្សចេញចូលកម្ពុជា ដែលនាំដល់មនុស្សខិលខូចមួយចំនួនអាចកេងបន្ទំយក ឬយកកំរៃរហូតដល់ ៣០ ភាគរយ។ រូបិយប័ណ្ណដែលចូលក្នុងប្រទេសហើយ ត្រូវចេញទៅបរទេសវិញតាមផ្លូវមិនស្របច្បាប់ អាស្រ័យដោយអត្រាប្តូរប្រាក់របស់រដ្ឋទាប និងដោយមិនទាន់មានការចាត់តាំងអាជីវកម្មលក់ដូរ ដើម្បីប្រមូលរូបិយប័ណ្ណៈ អង្គការមនុស្សធម៌អន្តរជាតិដែល

មានប្រាក់មកជួយកម្ពុជា ក៏បានបង្វែររូបិយប័ណ្ណទាំងនោះ ទៅទិញរបស់ពីប្រទេសផ្សេងយកមកអោយកម្ពុជា ទោះជារបស់ទាំងនោះមានស្រាប់នៅកម្ពុជា ក៏ដោយ។

អំពីហិរញ្ញវត្ថុឆ្នាំ ១៩៧៩ យើងមិនទាន់មានការគិតគូរអំពីថវិកាទេ។ ឆ្នាំ ១៩៨០ ទោះបីបានបោះផ្សាយប្រាក់ហើយក៏ដោយ ក៏យើងមិនទាន់បានគ្រោងគិតអោយបានច្បាស់លាស់នៅឡើយ អំពីចំណូលចំណាយថវិការដ្ឋ ប៉ុន្តែ ឆ្នាំ ១៩៨០ ក៏ជាឆ្នាំផ្តល់នូវមូលដ្ឋានដ៏សំខាន់មួយសំរាប់យើងរៀបចំថវិកាជាតិដែរ។ ខែ មិថុនា ១៩៨១ ថវិការដ្ឋត្រូវបានធ្វើងនិងអនុម័តជាលើកដំបូង ក្នុងឱកាសសម័យប្រជុំលើកទី ១ នីតិកាលទី ១ របស់រដ្ឋសភា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ក្នុងរយៈពេលដំបូងនេះ អាស្រ័យដោយមូលដ្ឋានសេដ្ឋកិច្ចនៅទន់ខ្សោយ បណ្តាមូលដ្ឋានផលិតកម្មរបស់រដ្ឋ អនុវត្តនូវរបបចំនូលគ្រប់ចំណាយគ្រប់ចំណូលបំពេញអោយចំណាយ អង្គភាពផលិតកម្មជាច្រើនធ្វើអាជីវកម្មខាត ចំណាយយោធា សន្តិសុខ ចំណាយបុព្វហេតុរដ្ឋបាល អប់រំវប្បធម៌ សុខាភិបាល មានចំនួនច្រើន ថវិការដ្ឋត្រូវបាត់តុល្យភាពយ៉ាងធំ ដែលតម្រូវអោយរដ្ឋាភិបាល ត្រូវបោះផ្សាយថវិកាសាច់ប្រាក់យ៉ាងច្រើន ដើម្បីបំពេញអោយចំណាយ។ ប៉ុន្មានឆ្នាំកន្លងមក យើងពិនិត្យឃើញថា ចន្លោះនៃការបាត់តុល្យភាពមានការថយចុះ អាស្រ័យដោយការកើនឡើងនៃចំណូល ដែលបានមកពីផលិតកម្មក្នុងប្រទេស សំខាន់គោលការណ៍អំពីការផ្តល់សិទ្ធិអោយពេងចក្រ សហគ្រាសធ្វើអាជីវកម្មស្វយ័តខាងហិរញ្ញវត្ថុ។ ការផ្តល់បៀវត្សតាមបរិមាណផល បានធ្វើអោយមានចលនាប្រឡងប្រណាំងបង្កើនទិន្នផល និងទិន្នផលពលកម្ម ចលនា

ប្រឡងប្រណាំងបង្កើនចំណូល សន្សំសំចៃចំណាយ បានរួមចំណែកយ៉ាងច្រើន ក្នុងការរក្សាលំនឹងថវិការដ្ឋ។ ម្យ៉ាងទៀត អាស្រ័យដោយទីផ្សារក៏មានទំនិញកើនឡើងផងនោះ ចំណូលពន្ធដារគ្រប់ប្រភេទក៏បានកើនឡើងដែរ។ គោលនយោបាយផ្នែកហិរញ្ញវត្ថុ ក៏មានជំហានកែលំអ ដែលនាំអោយយើងចេញផុតពីការគ្រប់គ្រងមូលដ្ឋានផលិតកម្ម ឬអង្គភាពអាជីវកម្មតាមរបៀបរដ្ឋបាល ទៅកាន់ការគ្រប់គ្រងមានលក្ខណជាការគិតគូរចំណេញខាត ហើយពង្រីកបាននូវប្រជាធិបតេយ្យក្នុងជីវភាពសេដ្ឋកិច្ចរបស់សង្គម។ រចនាសម្ព័ន្ធវិនិយោគទុន ក៏បានកែសំរួលទៅតាមគោលការណ៍របស់បក្ស និងរដ្ឋ សំខាន់ផ្តល់មុខព្រួញសេដ្ឋកិច្ចទាំងបួន ស្បៀង កៅស៊ូ ឈើ ជលផល និងចំពោះសំណង់បំរើអោយផលិតកម្ម និងគមនាគមន៍ដឹកជញ្ជូន។ ការបែងចែកថ្នាក់គ្រប់គ្រងថវិកាបានរៀបចំជាបន្ទាន់ដល់ខេត្ត ហើយពិតមែនតែថ្នាក់ស្រុកមិនទាន់មានថវិកា ប៉ុន្តែ ដើម្បីបំរើអោយការពង្រឹងមូលដ្ឋាន និងសំដៅលុបបំបាត់ការរែអង្គាសពីប្រជាជនរបស់រដ្ឋអំណាច និងកម្មាភិបាលនៅមូលដ្ឋាន យើងបានរៀបចំឡើងនូវថវិការបស់ថ្នាក់ឃុំ និងសង្កាត់ ដាក់អោយប្រើប្រាស់តាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ១០០ សសរ កាលពីថ្ងៃទី ២១ សីហា ឆ្នាំ ១៩៨៨។

ប្រសិនបើពិនិត្យអំពីការលំបាកដ៏ធំធេង ដែលយើងបានឆ្លងកាត់ ហើយយើងរក្សាបាននូវលំនឹងខាងថវិកាត្រឹមប៉ុណ្ណោះ នោះក៏ជាជោគជ័យមួយដំណាក់ទៅហើយ។ យើងចេញដំណើរពីបាតដៃទទេ ហើយឈានទៅកសាងថវិការដ្ឋបាន មិនមែនជារឿងងាយស្រួលទេ។ សំខាន់ជាងនេះទៅទៀត សង្គ្រាមបំផ្លិចបំផ្លាញ និងគ្រោះគំរាមកំហែងពីខាង

ក្រៅនៅតែបន្ត តម្រូវអោយយើងត្រូវចំណាយថវិកាយ៉ាងច្រើន សំរាប់ការកសាង និងពង្រឹងសមត្ថភាពយោធា សន្តិសុខ ដើម្បីការពារជាតិ ព្រោះវាគ្មានការជ្រើសរើសណាអោយល្អជាងនេះទៀតទេ។ បើយើងមិនចំណាយសំរាប់ការងារនេះទេ ប្រជាជនពិតជាត្រូវទទួលការកាប់សម្លាប់ម្តងទៀត។ ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធសង្គម ស្តារឡើងវិញនូវមូលដ្ឋានបំរើអោយវិស័យសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច ក៏ទាមទារការចំណាយយ៉ាងធំ ក្នុងពេលដែលការរកចំណូលនៅក្នុងប្រទេសបានតិច ដែលតម្រូវអោយយើងបោះផ្សាយសាច់ប្រាក់បន្ថែម និងត្រូវទៅខ្ចីពីបរទេស ដើម្បីបំពេញអោយចំណាយ ដែលជាហេតុធ្វើអោយមានឱនភាពថវិកា នាំដល់ឱនភាពសាច់ប្រាក់ទៀត ហើយបំណុលបរទេសក៏បានកើនឡើងដែរ ពិតមែនតែបំណុលនេះ ស្ទើរតែទាំងអស់មិនមានការប្រាក់ ពិសេសគឺបំណុលដែលយើងជំពាក់សហភាពសូវៀត និងប្រទេសសង្គមនិយមមួយចំនួន។ តែយើងគួរពិនិត្យអំពីការខ្វះខាតរបស់យើងផ្ទាល់ដែរ ក្នុងការងារហិរញ្ញវត្ថុ ថវិកា ដែលមានចំណុចមួយធ្វើអោយបាត់តុល្យភាពថវិកាថែមទៀតផង។ ក្បាលម៉ាស៊ីនរដ្ឋបាលរបស់យើងពីលើដល់ក្រោមមានទំហំធំ ដែលរដ្ឋត្រូវទទួលបន្ទុកចិញ្ចឹមទាំងស្រុង ទាំងអ្នកធ្វើការផ្ទាល់ទាំងអ្នកនៅក្នុងបន្ទុក (កូនប្រពន្ធ ឪពុកម្តាយ) ហើយដែលគ្រាន់តែថវិកា និងសាច់ប្រាក់សំរាប់បំពេញអោយវិសមភាពថ្លៃលើមុខទំនិញផ្គត់ផ្គង់ ក៏មានចំនួនយ៉ាងច្រើនទៅហើយ។ នៅតាមអង្គភាពអាជីវកម្មទៀតសោត ផ្នែកបំរើការរដ្ឋបាលក៏មានចំនួនច្រើន ដែលធ្វើអោយប៉ះពាល់ដល់ចំណូលថវិការដ្ឋ និងចំណូលសំរាប់កម្មករ បុគ្គលិក ដែលផលិតផ្ទាល់។ ចំណាយរដ្ឋបាល បុព្វហេតុ

*ចំណាយប្រើប្រាស់មានទំហំធំ ហើយកន្ទ្រង់មួយចំនួនមានភាពខ្វះខ្វាយផង ការសន្សំសំចៃមិនទាន់មានចលនាស្មើគ្នាជាទូទៅ។ លទ្ធភាពនៃចំណូលមាន ក៏ប៉ុន្តែប្រមូលបានតិច ពិសេសពីពន្ធដារគ្រប់ប្រភេទ។ កម្មាភិបាលពន្ធដារមួយចំនួន ក៏នៅឃុបឃិតជាមួយអាជីវករបន្លំប្រាក់ពន្ធ។ វិភាគទានអំពីកសិកម្ម មុនឆ្នាំ ១៩៨៨ មិនបានលើកទឹកចិត្តដល់ការផលិត ហើយទាំងបង្កអោយមានការថ្នាំងថ្នាក់ពីប្រជាជនទៀតផង។*

*ស្ថាប័ន និងមូលដ្ឋានមួយចំនួន ប្រមូលបានថវិកាហើយ តែមិនបង់ចូលរដ្ឋ ហើយថែមទាំងធ្វើនិយតភាពថវិកាពីមុខសញ្ញាមួយទៅកាន់មុខសញ្ញាមួយ ខុសពីផែនការរបស់រដ្ឋទៀតផង។ ប្រសិនបើមានគោលនយោបាយត្រឹមត្រូវផងហើយមានការគ្រប់គ្រងបានល្អ ប្រភពចំណូលអាចនឹងកើនខ្ពស់ ដែលអាចមានលទ្ធភាពបំពេញអោយការចំណាយនាំដល់ការលុបបំបាត់ចោលនូវការបាត់តុល្យភាពថវិកា ក្នុងរយៈពេលមួយដ៏ខ្លី យ៉ាងហោចណាស់ក៏បំព្រួញបាននូវចន្លោះឃ្លាតគ្នា រវាងចំណូល និងចំណាយថវិការដ្ឋដែរ។ ទោះបីយ៉ាងណាក៏ដោយ ក៏យើងបានប្រឹងប្រែងបន្ថយបានមួយចំនួន នូវការបាត់តុល្យភាពរវាងចំណូល និងចំណាយ ក្នុងថវិការដ្ឋ ហើយឆ្នាំដែលបាត់តុល្យភាពច្រើន ក៏មិនជាអាក្រក់ពេកនោះទេ ព្រោះថាឆ្នាំនោះ យើងត្រូវជំរុញការវិនិយោគទុនសំរាប់ជាមូលដ្ឋានបំរើអោយវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ច្រើន ដែលយើងសុខចិត្តទទួលយកការបាត់តុល្យភាព ដើម្បីប្តូរយកនូវមូលដ្ឋានសម្ភារៈបច្ចេកទេស និងសុខុមាលភាពជូនប្រជាជន។*

*ចំពោះផ្នែកពាណិជ្ជកម្ម ដូចបានលើកឡើងខាងលើហើយថា បន្ទាប់ពីការដួលរលំទៅនៃរបប ប៉ុល ពត សកម្មភាពផ្លាស់ប្តូរទំនិញ*

របស់ប្រជាជន បានចាប់ផ្ដើមមានឡើងភ្លាមដែរ ហើយសកម្មភាពនេះត្រូវបានបើកពង្រីកជាជំហានៗ រហូតដល់កកើតឡើងនូវទីផ្សារ នូវអាគារលក់ដូរ និងរហូតឈានដល់ការផ្លាស់ប្ដូរពាណិជ្ជកម្មជាមួយបរទេស។ ទីផ្សាររីកធំជាត់ តាមរយៈនៃការរីកចំរើនខាងផលិតកម្មក្នុងប្រទេស និងការផ្លាស់ប្ដូរទំនិញជាមួយបរទេស ហើយវាកាន់តែងាយស្រួលថែមទៀតនៅពេលប្រាក់រៀលបានធ្វើចរាចរជាធរមាន។

ក្នុងជីវភាពសេដ្ឋកិច្ចនៃប្រទេសយើង ១០ ឆ្នាំកន្លងទៅ ពិតមែនតែនិយាយអំពីសេដ្ឋកិច្ចមានផែនការ ប៉ុន្តែជាក់ស្ដែងសកម្មភាពស្ទើរជាទូទៅ គឺរត់តាមសេដ្ឋកិច្ចទីផ្សារ។ ផលិតកម្មគ្រប់ផ្នែក រីកចំរើនតាមសេចក្ដីត្រូវការរបស់ទីផ្សារ ហើយថ្លៃទំនិញទៀតសោត ក៏មានការវិវត្តន៍តាមសេចក្ដីត្រូវការរបស់ទីផ្សារ មានន័យថា ទំនិញណាមានច្រើន ហើយសេចក្ដីត្រូវការតិច មានថ្លៃទាប ហើយទំនិញណាមានតិច តែសេចក្ដីត្រូវការច្រើន ថ្លៃខ្ពស់។

ក្នុងស្ថានភាពផលិតកម្មកំពុងស្ដារឡើងវិញ ហើយពុំទាន់មានស្ថិរភាព តម្លៃក៏មានការវិវត្តន៍ប្រែប្រួល ជាមួយនោះ រដ្ឋចាំបាច់ត្រូវធានាអោយបុគ្គលិក កម្មកររដ្ឋ មានស្ថិរភាព ដែលទាមទារចាំបាច់ត្រូវមានការលក់របបផ្គត់ផ្គង់តាមថ្លៃស្ថិរភាព។ ទីផ្សាររបស់យើង ក៏បានកកើតឡើងនូវប្រព័ន្ធពីរ គឺផ្សាររដ្ឋ និងផ្សារសេរី ព្រមទាំងមានតម្លៃបី គឺតម្លៃផ្គត់ផ្គង់ តម្លៃជានាអាជីវកម្មពាណិជ្ជកម្ម តម្លៃសេរី ដែលធ្វើអោយយើងជួបការលំបាកយ៉ាងខ្លាំង ក្នុងការគ្រប់គ្រងទីផ្សារ និងសកម្មភាពអាជីវកម្ម ទិញ លក់ របស់ពាណិជ្ជកម្មរដ្ឋ។ ទំនិញរបស់រដ្ឋ ទោះជាថ្លៃជានាអាជីវកម្ម ក៏មានថ្លៃទាប ដែលវិសមភាពយ៉ាងច្រើនជាមួយថ្លៃទីផ្សារ

សេរី ក្នុងពេលនោះក៏មានបុគ្គលិករដ្ឋមួយចំនួន ឆ្លៀតឱកាសកិបកេង យកទំនិញទៅលក់នៅទីផ្សារសេរី ធ្វើអោយទំនិញផ្គត់ផ្គង់ និងទំនិញសំរាប់លក់ជូនប្រជាជនមិនបានដល់ដៃកម្មាភិបាល បុគ្គលិក កម្មករ កងកម្លាំងប្រដាប់អាវុធ និងប្រជាកសិករ។ ឯថ្លៃទិញផលិតផលពីប្រជាជនទៀតសោត ក៏ទាបជាងទីផ្សារ ដែលជាហេតុធ្វើអោយរដ្ឋជួបការលំបាកក្នុងការប្រមូលទិញ។ មុខទំនិញសំរាប់នាំចេញមួយចំនួន យើងកំណត់ថ្លៃស្លាប់ក្រឡា ដែលមិនបានលើកទឹកចិត្តដល់ការផលិត ហើយឈ្មួញក៏ឆ្លៀតឱកាសនេះ ដើម្បីប្រមូលទិញ និងនាំចេញ។ សភាពការណ៍នេះ បានអូសបន្លាយអស់រយៈពេលដ៏យូរ រហូតដល់ឆ្នាំ ១៩៨៦ ទើបរដ្ឋមានការកែប្រែ ដោយកំណត់តាមថ្លៃអណ្ដែតមួយ សំរាប់អោយផ្នែកពាណិជ្ជកម្ម មានលទ្ធភាពប្រមូលទិញ គឺរដ្ឋគ្រាន់តែកំណត់ថាប្រមូលទិញតាមថ្លៃស្រុះស្រួល លើមូលដ្ឋាននាំចេញបានរូបិយប័ណ្ណ និងមានចំណេញ។ តាំងពីពេលនោះមក មុខទំនិញមួយចំនួន យើងប្រមូលទិញបានលើសផែនការ ដូចជា ម្រេច ម្រ័ក្សណ៍ ខ្ទឹមច័ន្ទក្រស្នា។ល។

សកម្មភាពនៃបណ្ដាអង្គភាពអាជីវកម្ម ពាណិជ្ជកម្មក្នុងប្រទេស ថ្វីត្បិតតែចាប់តាំងពីការបោះផ្សាយប្រាក់ អង្គភាពទាំងនោះបានធ្វើអាជីវកម្មមានលក្ខណៈជាការចំណេញខាត តែចំណេញខាតនៅទីនេះ ត្រឹមកំរិតក្របខ័ណ្ឌរដ្ឋប៉ុណ្ណោះ។ ការចំណេញ គឺបានមកពីលំអៀងថ្លៃលើមុខទំនិញមួយចំនួន ដែលរដ្ឋផ្ដល់អោយផ្នែកពាណិជ្ជកម្មលក់ជូនប្រជាជន ចំពោះការចំណេញបានមកពីការធ្វើអាជីវកម្មទិញ លក់ មានតិចតួចណាស់។ ផ្នែកពាណិជ្ជកម្មនៅកន្លែងមួយចំនួន ធ្វើសកម្មភាពក្នុង

ឋានៈជាអង្គភាពផ្គត់ផ្គង់ ដែលគ្រាន់តែទទួលទំនិញពីលើទៅបែងចែក ហើយទទួលទំនិញបញ្ជូនអោយថ្នាក់លើវិញ ហើយទទួលយកកំរៃអប្បហារតែប៉ុណ្ណោះ។

ថ្វីត្បិតតែមិនទាន់បង្កើនបានតួនាទីជាអង្គភាព អាជីវកម្មពិតប្រាដកតែផ្នែកពាណិជ្ជកម្មរដ្ឋយើងទទួលរ៉ាប់រងភារកិច្ចយ៉ាងសំខាន់ ក្នុងការចរាចរបែងចែកទំនិញក្នុងក្របខ័ណ្ឌរដ្ឋ ប្រមូលទិញបាននូវស្បៀង និងផលិតផលសំខាន់ៗ ដើម្បីផ្គត់ផ្គង់អង្គភាពរដ្ឋ និងបំរើដល់ការនាំចេញ ហើយក៏បានដើរតួនាទីដ៏សំខាន់ ក្នុងការទំនាក់ទំនងផ្លាស់ប្តូរទំនិញជាមួយប្រជាជន ពិតមែនតែថាមិនទាន់ល្អពេកទេ តែក៏ជាមូលដ្ឋានមួយបង្កជំនឿទុកចិត្តពីសំណាក់ប្រជាជនចំពោះរដ្ឋ ហើយធានាបាននូវផលប្រយោជន៍នៃផលិតករ។ គោលនយោបាយចំពោះផ្នែកពាណិជ្ជកម្មត្រូវបានកែសម្រួលជាបន្តបន្ទាប់ ដែលមានខ្លឹមសារ និងរូបភាព កាន់តែរស់រវើក ហើយកាន់តែជះឥទ្ធិពលល្អដល់ផលិតកម្ម។ គួរកត់សំគាល់ថា នៅក្នុងពេលដែលរដ្ឋមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ ក្នុងការធ្វើចរាចរបែងចែកទំនិញ ពិសេសក្នុងទំនាក់ទំនងទិញលក់ជាមួយប្រជាជន រដ្ឋយើងក៏មានវិធានការសមស្របមួយចំនួន ចំពោះពាណិជ្ជកម្មឯកជន ឬការផ្លាស់ប្តូរទំនិញរបស់ប្រជាជន ដែលបង្កឡើងនូវភាពងាយស្រួលមួយ ក្នុងការងារចរាចរបែងចែក និងស្ថិរភាពទីផ្សារ។ ក្នុងពាណិជ្ជកម្មក្រៅប្រទេស ក៏បក្ស និងរដ្ឋយើង មានគោលការណ៍សមស្របបង្គួរ ថ្វីត្បិតតែរដ្ឋធម្មនុញ្ញបានចែងពីភាពផ្តាច់មុខរបស់រដ្ឋលើពាណិជ្ជកម្មក្រៅប្រទេស ប៉ុន្តែ ក្នុងស្ថានភាពដែលរដ្ឋមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ដើម្បីធ្វើអាជីវកម្មផ្តាច់មុខ រដ្ឋយើងក៏បានរក្សាទុកអោយ

ឯកជនមានលទ្ធភាពនាំចេញនាំចូល។ ហើយក្នុងនោះដែរ រដ្ឋក៏មានគោលការណ៍កែលំអអំពីការនាំចេញ នាំចូល របស់រដ្ឋ ដោយផ្តល់សិទ្ធិអោយខេត្តក្រុងនាំចេញនូវមុខទំនិញណាដែលលើសផែនការ និងក្រៅផែនការរបស់រដ្ឋ ដែលមុនឆ្នាំ ១៩៨៨ អ្វីៗ ទាំងអស់ ទាក់ទងដល់ការនាំចេញនាំចូល គឺមជ្ឈិមជាអ្នកធ្វើ។ ពេលដែលមជ្ឈិមឱបមិនជុំ ដែលជាចន្លោះប្រហោងមួយយ៉ាងធំ មជ្ឈិមក៏មិនបានលើកទឹកចិត្តដល់ខេត្តក្រុងអោយប្រមូលមុខទំនិញសំរាប់នាំចេញដែរ។ ដើម្បីសំរួលដល់ការងារនាំចេញចូល ទាំងរដ្ឋ និងឯកជន ការប្រជុំរដ្ឋសភាលើកទី ៥ អាណត្តិទី ៧ ដល់ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ១៩៨៨ បានកែមាត្រា ១៩ នៃរដ្ឋធម្មនុញ្ញ ដែលមុននោះបានចែងថា រដ្ឋផ្តាច់មុខលើពាណិជ្ជកម្មក្រៅប្រទេសមកដាក់ថា ពាណិជ្ជកម្មក្រៅប្រទេសស្ថិតក្នុងការគ្រប់គ្រង និងចាត់តាំងរបស់រដ្ឋ ដែលគោលដៅសំខាន់ក្នុងការកែប្រែនេះ គឺដើម្បី អោយរដ្ឋាភិបាលមានលទ្ធភាពចាត់ចែងគ្រប់គ្រង ការនាំចេញនាំចូល បានងាយស្រួលរាប់ទាំងការប្រើប្រាស់ឯកជនផង ក្នុងពេលរដ្ឋមិនទាន់មានលទ្ធភាពធ្វើខ្លួនឯងទាំងស្រុង។ ចាប់តាំងពីការកែសម្រួលមក យើងពិនិត្យឃើញថាចំណូលដែលបានមកពីការនាំចេញមានការកើនឡើង អាស្រ័យដោយមូលដ្ឋានមើលឃើញពីផលប្រយោជន៍ដែលខ្លួនត្រូវធ្វើ ដើម្បីការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន។ ជាមួយនោះ យើងក៏បានបន្ថយនូវការនាំមាសចេញទៅប្តូរយកទំនិញពីបរទេសដែរ។

ក្នុងផ្នែកចរាចរបែងចែក ក៏នៅមានបញ្ហាចោទធ្ងន់ធ្ងរនៅឡើយ ដែលទាមទារត្រូវធ្វើការកែលំអបន្តទៀត គឺធ្វើយ៉ាងណា អោយការងារនេះក្លាយជាគន្លឹះជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ តើយើងនឹងត្រូវដាក់

ចេញគោលនយោបាយផ្នែកហិរញ្ញវត្ថុ ថវិកាយ៉ាងណា តើធនាគារ ត្រូវធ្វើអាជីវកម្មយ៉ាងណា ត្រូវមានវិធានការយ៉ាងណា ដើម្បីទប់ស្កាត់ឱនភាពថវិកា និងឱនភាពសាច់ប្រាក់ ហើយឈានទៅអោយមានតុល្យភាពរវាងចំណូល និងចំណាយទាំងថវិកា និងសាច់ប្រាក់ ត្រូវកែសម្រួលប្រព័ន្ធថ្លៃ និងបៀវត្សយ៉ាងណា ដើម្បីអោយទីផ្សារមានថ្លៃឯកភាព និងស្ថិរភាពផង និងមិនអោយមានភាពច្របូកច្របល់ដល់ទីផ្សារ និងដល់ជីវភាពប្រជាជនផង ហើយតើពាណិជ្ជកម្មរដ្ឋត្រូវមានសកម្មភាពយ៉ាងណា ដើម្បីមានចំណេញដល់ផលិតកម្ម និងជីកនាំទីផ្សារបាន។ល។

ជាមួយនោះដែរ យើងត្រូវកែប្រែរចនាសម្ព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចយ៉ាងណា ដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលកន្លងមកនេះយើងធ្វើមិនទាន់ត្រូវនៅឡើយ ហើយថែមទាំងបង្កអោយមានការយឺតយ៉ាវនិងរាំងស្ទះដល់ដំណើរការផងក៏សឹងមាន។ ទាំងអស់នេះសុទ្ធតែជាបញ្ហាធំៗ និងស្មុគស្មាញ ដែលទាមទារការពិចារណាអោយបានហ្មត់ចត់មុននឹងធ្វើសកម្មភាព ព្រោះថា ប្រសិនបើធ្វើមិនបានល្អទេ វានឹងនាំទៅដល់ភាពស្មុគស្មាញយ៉ាងច្រើន។

ជាទូទៅ ក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ យើងមានចំណុចល្អជាច្រើន ទាំងគោលការណ៍ ទាំងការចាត់តាំងអនុវត្ត ដែលអាចនាំអោយប្រទេសចាកចេញពីសភាពការណ៍លំបាកបំផុត ហើយមកស្ថិតក្នុងដំណាក់កាលស្តារ និងអភិវឌ្ឍ។ ពិតមែនហើយ ការងារនេះជាការងារដ៏លំបាក ហើយលំបាកជាងនេះទៅទៀត គឺយើងបានទទួលតំណពីភាពខ្ទេចខ្ទាំ ដែលរបបប្រល័យពូជសាសន៍ ប៉ុល ពត បានបន្សល់ឡើងជាមរតកដ៏ធ្ងន់ធ្ងរ ដែល បក្ស រដ្ឋាភិបាល និងប្រជាជនយើងត្រូវតែ

ប្រឈមមុខដោះស្រាយ ព្រមពេលដែលសង្គ្រាមបំផ្លិចបំផ្លាញពីខ្មាំងសត្រូវនៅតែបន្ត ដែលតម្រូវអោយយើងត្រូវតែចំណាយកម្លាំងមនុស្ស កម្លាំងទ្រព្យសម្បត្តិ ថវិកា ដើម្បីបំពេញភារកិច្ចការពារជាតិ និងការពារអាយុជីវិតរបស់ប្រជាជន។ វាជាការពិបាកណាស់ នៅពេលដែលយើងត្រូវធ្វើការងារជាច្រើនក្នុងពេលជាមួយគ្នា ប៉ុន្តែយើងគ្មានការជ្រើសរើសណាផ្សេងក្រៅពីនេះទៀតទេ ព្រោះនេះជាសង្គ្រាមដែលខ្មាំងសត្រូវបង្ខំអោយយើងត្រូវធ្វើ បើមិនដូច្នេះទេ គ្រោះថ្នាក់នៃរបបប្រល័យពូជសាសន៍ ប៉ុល ពត នឹងវិលមករកប្រជាជនយើងជាថ្មី ដែលជាប្រការមិនអាចទទួលយកបានឡើយ។ ការប្រើប្រាស់កម្លាំងមនុស្ស ទ្រព្យសម្បត្តិ និងថវិកាដ៏ច្រើន ដើម្បីការពារជាតិ គឺវាពិតជាមានឥទ្ធិពលមិនល្អទេ សំរាប់ការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច វប្បធម៌ និងការលើកកំពស់ជីវភាពប្រជាជន។ យើងបានដឹងយ៉ាងដូច្នេះ ប៉ុន្តែយើងក៏នៅតែធ្វើ ព្រោះជៀសមិនរួច។ តែ ទោះបីយើងជួបប្រទះនូវការលំបាកយ៉ាងនេះក៏ដោយ ក៏យើងបានធ្វើអោយសេដ្ឋកិច្ចជាតិមានជំហានរីកចំរើនជាលំដាប់។ ការបញ្ចប់ជាស្ថាពរនូវការអត់ឃ្លាន ដែលបន្សល់ទុកពីរបប ប៉ុល ពត គឺជាព្រឹត្តិការណ៍នយោបាយដ៏មានអត្ថន័យ ក្នុងជីវភាពនយោបាយនៃរបបថ្មីនៃយើង ហើយជាបណ្តើរៗ យើងបានធ្វើអោយវិស័យដទៃទៀត ចាប់ផ្តើមមានសកម្មភាព និងរីកចំរើន ទោះបីស្ថិតក្នុងសភាពយឺតយ៉ាវក៏ដោយ តែនេះក៏ជាមោទនភាពធំណាស់របស់ប្រជាជនកម្ពុជា និងប្រទេសជាមិត្តភក្តិ ដែលបានជួយយើង។

យើងសូមរំលឹកថា យើងបានចេញដំណើរពីបាតដៃទទេ ខ្វះសព្វខ្វះគ្រប់ ក្នុងកាលៈទេសៈ និងស្ថានការណ៍ប្រទេសជាតិមានសន្តិភាព

ផង និងមានសង្គ្រាមផងៗ ទោះបីសន្តិភាពបានកើតមានលើចំណែកភាគច្រើននៃដែនដី និងពេលវេលា ហើយសង្គ្រាមបានកើតមានដាច់ដោយដុំ និងពេលវេលាខ្លះក៏ពិតមែន តែសង្គ្រាមនោះវាក៏បានបង្កនូវការឈឺចាប់ ភាពវិនាសដល់អាយុជីវិត និងទ្រព្យសម្បត្តិយ៉ាងច្រើនដែរ។ ចាប់តាំងពីចេញដំណើរមក ក្នុងវិស័យសេដ្ឋកិច្ច យើងត្រូវបាត់តុល្យភាពលើបញ្ហាជាច្រើន ប៉ុន្តែសំខាន់ យើងបាត់តុល្យភាពលើបញ្ហាធំៗ ៤ យ៉ាងគឺៈ

ទីមួយ: ការបាត់តុល្យភាពរវាងសេចក្តីត្រូវការ និងការផ្គត់ផ្គង់។

ទីពីរ: ការបាត់តុល្យភាពរវាងចំណូល និងចំណាយ។

ទីបី: ការបាត់តុល្យភាពរវាងការនាំចេញ និងការនាំចូល។

ទីបួន: ការបាត់តុល្យភាពរវាងរូបិយវត្ថុ និងទំនិញ។

ការបាត់តុល្យភាពទាំង ៤ គឺជាទំនាស់ ៤ យ៉ាង ដែលមានទំនាក់ទំនងជាមួយគ្នាបេះមិនដាច់ គឺជាចុងខ្សែបួននៃចំណងមួយ ហើយដែលចាំបាច់ត្រូវមានដំណោះស្រាយសមហេតុសមផល ហើយដំណោះស្រាយសំខាន់បំផុត និងតែមួយគត់ដែលត្រូវប្រកាន់យកនោះគឺការជំរុញផលិតកម្មផ្ទៃក្នុងប្រទេស អោយមានការកើនឡើង។ បញ្ហានេះមិនមែនជារឿងងាយស្រួលទេ វាជាបញ្ហាដ៏ពិបាក ហើយប្រកបដោយការតស៊ូ។ ការតស៊ូនោះ ម្យ៉ាង គឺតស៊ូជាមួយកត្តាសត្យានុម័តិដែលជាផលវិបាកបន្សល់ទុកពីរបប ប៉ុល ពត ជាមួយសង្គ្រាមដែលចេះតែញាំញីយើង ជាមួយធម្មជាតិដែលគ្មានភាពអនុគ្រោះ ក៏ដូចជាការលំបាកផ្សេងទៀត។ល។ តែម្យ៉ាងទៀត ក៏ត្រូវធ្វើការតស៊ូជាមួយកត្តាអត្តនោម័តិ នៅក្នុងផ្ទៃក្នុងយើងដែរ នោះគឺជាការតស៊ូស្វែងរកផ្លូវ

ដែលនាំប្រទេសជាតិអោយអភិវឌ្ឍបានឆាប់រហ័ស។

១០ ឆ្នាំកន្លងមក យើងបាននាំប្រទេសអោយចេញផុតពីដំណាក់កាលដែលលំបាកបំផុតរួចទៅហើយ ហើយកំពុងស្ថិតក្នុងដំណាក់កាលស្តារ និងអភិវឌ្ឍលើគ្រប់វិស័យ។ យើងបានបំពេញនូវការបាត់តុល្យភាពលើវិស័យទាំង ៤ អោយមកមានចន្លោះកាន់តែតូចទៅៗ ប៉ុន្តែក៏នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ សំណូមពរនៃការអភិវឌ្ឍន៍របស់ប្រទេសជាតិ គឺមិនត្រូវទុកអោយមានការបាត់តុល្យភាពយ៉ាងដូច្នេះឡើយ ដូច្នេះ ត្រូវរកគ្រប់វិធានការ ដើម្បីស្រាយនូវចំណងដែលកំពុងតែជំពាក់នេះ។ ទំនាស់ដែលសំខាន់ ដែលចាំបាច់ដោះស្រាយមុនគេ គឺដោះស្រាយការបាត់តុល្យភាពរវាងសេចក្តីត្រូវការ និងការផ្គត់ផ្គង់។ បើដោះស្រាយបានទំនាស់ទី ១ នេះ ទំនាស់បីផ្សេងទៀត ក៏នឹងត្រូវបានដោះស្រាយ ហោចណាស់ក៏បានបន្ថយខ្លះដែរ។ សេចក្តីត្រូវការរបស់ប្រទេសជាតិ និងរបស់ប្រជាជនចេះតែកើនឡើងអំពីបរិមាណ ព្រមទាំងគុណភាពថែមទៀត ក្នុងពេលដែលល្បឿន ផលិតកម្មរីកចំរើនយឺត ហើយខ្វះគុណភាពផង។ យើងគ្រាន់តែលើកយកមកនិយាយអំពីបញ្ហាស្បៀង និងម្ហូបអាហារ។ តាមពិតផលិតកម្មស្បៀង និងម្ហូបអាហារ មានការកើនឡើងជាប្រចាំ ប៉ុន្តែនៅតែរត់មិនទាន់សេចក្តីត្រូវការ អាស្រ័យដោយក្នុងពេលនោះដែរកំណើនប្រជាជន ក៏បានកើនខ្ពស់ ដែលយើងអាចប៉ាន់ស្មានបានថា មិនទាបជាង ២,៨ ភាគរយទេ។ តាមការគិតគូររបស់យើង បើប្រជាជនកើន ១ ភាគរយ ស្បៀងត្រូវកើន ៣ ភាគរយ ទើបអាចចិញ្ចឹមប្រជាជនបានគ្រប់គ្រាន់ ដូច្នេះ ទាមទារអោយស្បៀងកើនឡើង ១០ ភាគរយ ជារៀងរាល់ឆ្នាំ។ ក្នុងពេលដែល

សេចក្តីត្រូវការមានកំរិតខ្ពស់យ៉ាងដូច្នេះ ផលិតកម្មកសិកម្មរបស់យើង គ្មានភាពនឹងនទេ អាស្រ័យដោយកសិកម្មយើងចំណុះស្ទើរទាំងស្រុង ទៅលើធម្មជាតិ។ ដីស្រែចំការទៀតសោត ក៏ខ្សោះ ជីជាតិ ចំពេលដែល យើងខ្វះជី ចំណែកឯគោលការណ៍រដ្ឋវិញក៏ពុំទាន់បានលើកទឹកចិត្ត ប្រជាកសិករនៅឡើយដែរ ដូចជាបញ្ហាការរៀបចំក្រុមសាមគ្គី បញ្ហា ការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីកសិកម្ម និងគោលនយោបាយថ្លៃ ចំពោះដំណាំស្បៀង។

ខ្ញុំបាននិយាយបន្តិចអំពីអត្រាកំណើនប្រជាជនដែលកើនខ្ពស់ មិន មែនមានន័យថា ចង់បន្ថយអត្រាកំណើននោះទេ គ្រាន់តែចង់បង្ហាញ អំពីសភាពការណ៍សត្យានុម័តិតែប៉ុណ្ណោះ។ តើនៅពេលខាងមុខនេះ យើងត្រូវដោះស្រាយទំនាស់រវាងសេចក្តីត្រូវការ និងការផ្គត់ផ្គង់ គឺក្នុង បញ្ហាស្បៀង និងម្ហូបអាហារយ៉ាងណា? មិនមែនបញ្ហាបន្ថយអត្រា កំណើនប្រជាជននោះទេ តែគឺជាបញ្ហាជំរុញផលិតកម្មស្បៀង ដែលជា រណសិរ្សជួរមុខរបស់យើង។ បញ្ហានៅទីនេះ គឺត្រូវពិនិត្យឡើងវិញនូវ គោលការណ៍ខ្វះ ដែលយើងដាក់ចេញមិនទាន់បានសមស្រប ហើយ កែសម្រួលវាអោយស្របនឹងការជាក់ស្តែង ព្រមទាំងចាត់វិធានការអនុ វត្តអោយកាន់តែមានប្រសិទ្ធិភាព។ ដំបូង ខ្ញុំចង់និយាយដល់ការរៀបចំ ទំនាក់ទំនងផលិតកម្មនៅជនបទ ដែលតាមទ្រឹស្តីយើងធ្លាប់និយាយថា កម្លាំងផលិតកម្មកំណត់ទំនាក់ទំនងផលិតកម្ម មានន័យថាការរៀបចំទំ នាក់ទំនងផលិតកម្ម ត្រូវតែស្របជាមួយនឹងសមត្ថភាព នៃកម្លាំងផលិត កម្ម។ ជាទ្រឹស្តីវាយ៉ាងដូច្នេះមែន ប៉ុន្តែយើងធ្វើមិនបានទេ។ សមត្ថភាព មធ្យោបាយ និងឧបករណ៍ផលិតកម្មរបស់យើង តម្រូវអោយធ្វើត្រឹម

លក្ខណៈជាគ្រួសារ ឬជាក្រុមសាមគ្គី ដែលមានចរិតជាវេរប្រវាស់ដៃរវាងគ្រួសារ និងគ្រួសារតែប៉ុណ្ណោះ ប៉ុន្តែ យើងបែរជាចលនាប្រជាជនអោយធ្វើក្រុមសាមគ្គី របៀបធ្វើរួមទទួលផលតាមពលកម្មទៅវិញ ដែលជាហេតុធ្វើអោយរាំងស្ទះដំណើររីកចំរើននៃផលិតកម្ម មិនបានលើកទឹកចិត្តដល់ប្រជាកសិករ ហើយក៏បានធ្វើអោយរាំងស្ទះដល់ការធ្វើម្ចាស់ការងាររបស់កសិករទៀតផង។ ខ្ញុំសូមលើកឧទាហរណ៍មួយបង្ហាញពីភាពមិនបានធ្វើម្ចាស់លើការងាររបស់កសិករ។ នៅខែ កក្កដា ឆ្នាំ ១៩៨៣ ខ្ញុំរួមជាមួយកម្មាភិបាលក្រសួងការបរទេស ប្រមាណជាង ១០០ នាក់ បានទៅរួមធ្វើពលកម្មជាមួយប្រជាជននៅសង្កាត់អូរបែកក្អម នៅជាយក្រុងភ្នំពេញ។ ពេលនោះខ្ញុំបានទៅស្ទូងជាមួយប្រជាជនប្រមាណជាង ២០ នាក់។ ទាំងអស់គ្នាមិនទាន់ដឹងថា ខ្ញុំជាអ្នកណានៅឡើយទេ ព្រោះយើងមានគ្នាច្រើន ហើយទើបទៅដល់ភ្លាមក៏ចុះស្ទូងតែម្តង។ ក្រោយបន្តិចមក ខ្ញុំបានឆ្លៀតសំណេះសំណាលជាមួយប្រជាជន។ ចាប់ផ្តើមដំបូង ខ្ញុំសួរបងប្អូនប្រជាជនទាំងនេះថា តើនេះជាក្រុមសាមគ្គីប្រភេទណា? ចម្លើយបានមកគឺ នេះជាក្រុមសាមគ្គីប្រភេទទី ១។ ខ្ញុំបានសួរទៀតថា តើមានប៉ុន្មានគ្រួសារ? ចម្លើយមកវិញទាំងមិនច្បាស់លាស់ថា ប្រហែល ២៥ គ្រួសារ។ ខ្ញុំសួរថែមមួយសំណួរទៀតថា ក្នុង ២៥ គ្រួសារនេះមានដីប៉ុន្មានហិកតា? លើកនេះគ្មានចម្លើយទេ។ មួយសន្ទុះទើបបងស្រីម្នាក់ ដែលសំដីបានជាងគេឆ្លើយថា អត់ដឹងទេ ស្រេចនឹងគេហៅទៅធ្វើឯណា គឺទៅធ្វើឯនោះឯង។ ខ្ញុំមានអារម្មណ៍ថា កសិករមិនទាន់បានធ្វើម្ចាស់លើដីធ្លី ឬការងារនៅឡើយទេ។

ផ្តើមពីនេះ ខ្ញុំចាប់ដំណើរការស្រាវជ្រាវអំពីបញ្ហាការរៀបចំក្រុមសាមគ្គី

បង្កបង្កើនផលនៅជនបទ ព្រមពេលដែលថ្នាក់ដឹកនាំជាន់ខ្ពស់ បក្ស និងរដ្ឋជាច្រើន ក៏បានដំណើរការស្រាវជ្រាវបញ្ហានេះដែរ។ ខ្ញុំបានធ្វើដំណើរទៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។ នៅទីនោះ ខ្ញុំបានជួបអ៊ំស្រី ២ នាក់ ដែលធ្លាប់ស្គាល់គ្នាមុនឆ្នាំ ១៩៧៥។ ក្នុងពេលសំណេះសំណាលខ្ញុំបានសួរថា តើមានបានទិញដីពីរដ្ឋទេ ព្រោះរដ្ឋបានបញ្ជូនចុះមកដល់ខេត្តស្រុកយើង។ អ៊ំស្រីម្នាក់បានឆ្លើយថា បានមកដល់មែន ប៉ុន្តែរដ្ឋមិនលក់អោយក្រុមសាមគ្គីប្រភេទទី ២ ទេ គឺទុកលក់អោយក្រុមសាមគ្គីប្រភេទទី ១។ ខ្ញុំចាប់ផ្តើមមានអារម្មណ៍ថា ការបែងចែកក្រុមសាមគ្គីមានប្រភេទខុសគ្នា ជាចិត្តសាស្ត្រ គឺយើងបានបែងចែកប្រជាជនអោយនៅដាច់ពីគ្នា តាមប្រភេទនៃក្រុមសាមគ្គី។

គួររំលឹកថា ក្រុមសាមគ្គីប្រភេទទី ១ នេះ មិនមែនធ្វើនៅទូទាំងប្រទេសទេ គឺមានធ្វើនៅកន្លែងខ្លះៗ តែប៉ុណ្ណោះ។ ប៉ុន្តែ ទោះបីយ៉ាងនេះក្តី ជាចិត្តសាស្ត្រ ក៏ជះឥទ្ធិពលដល់ប្រជាជននៅកន្លែងផ្សេងទៀតដែរ ហើយបើនិយាយពីកម្មាភិបាលនៅមូលដ្ឋានវិញ ពេលរាយការណ៍ឡើងថ្នាក់លើ ក៏ហាក់ដូចជាមានមោទនភាពណាស់អំពីក្រុមសាមគ្គីប្រភេទទី ១ ដែលខ្លួនរៀបចំបាន ទោះជាក្រុមសាមគ្គីប្រភេទនេះមានកន្លែងខ្លះ ប្រជាជនខ្លះហូបក៏ដោយ។

នោះគឺជាមោទនភាពដោយយោងទៅលើរូបភាព ដោយសំអាងថាខ្លួនបានរៀបចំទំនាក់ទំនងផលិតកម្មសង្គមនិយមនៅជនបទ។ ជាងនេះទៀត មានកន្លែងខ្លះ គ្មានក្រុមសាមគ្គីប្រភេទទី ១ ទេ ប៉ុន្តែក៏រាយការណ៍ជូនថ្នាក់លើថាមានដែរ ដើម្បីជៀសវាងការរិះគន់ថា មិនដឹកនាំប្រជាជនឈានទៅសង្គមនិយម ហើយបញ្ហានេះក្លាយទៅជាការ

ប្រកួតប្រជែងរាយការណ៍អំពី ការរៀបចំទំនាក់ទំនងផលិតកម្មសង្គមនិយម ឬហោចណាស់ក៏បានសំដែងពីបំណងអនាគតដែរ ដោយមិនបានគិតដល់កម្លាំងផលិតកម្ម តើវាមានលទ្ធភាពអោយយើងរៀបចំទំនាក់ទំនងផលិតកម្មត្រឹមកំរិតណា។ ចេញពីបញ្ហានេះ មានកន្លែងមួយចំនួន ហើយប្រហែលជាមិនតិចទេ មានការភ័យខ្លាចចំពោះរបបកម្មសិទ្ធិឯកជនអំពីបញ្ហាដីធ្លី និងមធ្យោបាយផលិតកម្ម នាំដល់ការបែងចែក និងការប្រើប្រាស់មិនបានលើកទឹកចិត្តដល់ប្រជាកសិករ ហើយក៏មិនបានធ្វើអោយកសិករនឹងនចិត្ត ក្នុងការធ្វើអាជីវកម្មលើដីធ្លីផងដែរ។ កន្លែងខ្លះ ដោយចង់បានសមភាពហួសហេតុ គេចែកដីអោយកសិករមានចរិតចល័ត ឆ្នាំនេះគ្រួសារ ឬក្រុមគ្រួសារនេះធ្វើនៅកន្លែងនេះ ឆ្នាំក្រោយត្រូវទៅធ្វើនៅកន្លែងផ្សេង ដែលជាហេតុធ្វើអោយគ្រួសារ ឬក្រុមសាមគ្គីមិនយកចិត្តទុកដាក់ដល់ការថែទាំ ដូចជាមិនដាក់ដី មិនពង្រឹងភ្លឺស្រែ មិនធ្វើប្រឡាយទឹកហើយក៏មិនបានរុករានពង្រីកដីធ្លីថែមទៀត ។ល។ ចំពោះការរុករានដីថ្មី ក៏មិនអាចធ្វើបានលឿន អាស្រ័យដោយប្រជាជនមិនមានលំនឹងក្នុងចិត្តថា តើគេមានសិទ្ធិធ្វើអាជីវកម្មរយៈពេលប៉ុន្មានឆ្នាំ ព្រោះរដ្ឋគ្រាន់តែបានប្រាប់គេថា ដីសល់ទំនេរអោយប្រជាជនខ្ចីធ្វើ មិនដឹងថ្ងៃណារដ្ឋដកយកវិញ ម្យ៉ាងទៀត ដីដែលថាអោយប្រជាជនខ្ចីធ្វើក៏មានទំហំតូច ដែលជាប្រការមិនបានលើកទឹកចិត្តដល់ការពង្រីកដីថ្មី។ បញ្ហានេះក៏ធ្វើអោយមានការយឺតយ៉ាវដល់ដំណើរការបែងចែកពលកម្មសង្គមឡើងវិញ ហើយចំពោះមុខគឺយឺតយ៉ាវក្នុងការដោះស្រាយ ការបាត់តុល្យភាពរវាងកន្លែងមានដីតិចប្រជាជនច្រើន និងកន្លែងមានដីច្រើនប្រជាជនតិច។ ក្នុងបញ្ហានេះដែរ យើងបានទុក

ដីស្រែអំបិលរាប់រយហិកតានៅខេត្តកំពត ទុកចំការកៅស៊ូដែលនៅរាយប៉ាយក្នុងខេត្តកំពង់ចាម ក្រចេះ កំពង់សោម រាប់ពាន់ហិកតា អោយនៅចោលទំនេរ ដោយចាត់ទុកទាំងអស់នេះថាជារបស់រដ្ឋ ហើយទោះជារដ្ឋគ្មានលទ្ធភាពធ្វើអាជីវកម្ម ក៏រដ្ឋមិនបានប្រគល់អោយប្រជាកសិករធ្វើអាជីវកម្មទាញយកផលដែរ នេះក៏ជាការខាតបង់មួយដែលអូសបន្លាយអស់រយៈពេលយ៉ាងយូរ រហូតដល់ឆ្នាំ ១៩៨៦-១៩៨៧ នេះ ទើបរដ្ឋប្រគល់ដីស្រែអំបិល និងចំការកៅស៊ូអោយប្រជាជនធ្វើអាជីវកម្ម។

យើងគួររំលឹកដែរថា មិនមែនអ្វីក៏ជាកំហុសនោះទេ ហើយមិនមែនជាកំហុសមានជាទូទៅគ្រប់ទីកន្លែងនោះដែរ។ មានកន្លែងជាច្រើនក៏បានអនុវត្តល្អ ហើយបានលើកទឹកចិត្តដល់ប្រជាកសិករ ក្នុងការថែទាំដីស្រែ ចំការ និងស្តារដីថ្មី ហើយថែមទាំងបានលើកទឹកចិត្ត ដល់ការតាំងទីលំនៅថ្មី និងការដាំដំណាំឧស្សាហកម្មរយៈពេលយូរផង។ ពិសោធន៍ល្អរបស់ខេត្តតាកែវ គឺបក្ស និងរដ្ឋអំណាចខេត្ត ស្រុក បានធ្វើអោយប្រជាជនមានលំនឹងក្នុងចិត្ត ហើយក្លាយជាម្ចាស់ពិតប្រាកដលើដីធ្លី។ តាមរយៈនៃការចែកដីអោយកសិករ ហើយដោយមានលិខិតបញ្ជាក់អំពីសិទ្ធិកាន់កាប់ដី ធ្វើអោយប្រជាកសិករមានការរីករាយ ហើយថែទាំដីធ្លីរបស់គេបានល្អ។ ជាមួយនឹងការរៀបចំក្រុមសាមគ្គីបានសមស្របទៅនឹងសមត្ថភាពនៃកម្លាំងផលិតកម្ម និងស្របទៅនឹងចំណូលចិត្តរបស់ប្រជាជន កសិកម្មរបស់ខេត្តតាកែវ ទោះបីធម្មជាតិមិនសូវអនុគ្រោះដូចខេត្តផ្សេងទៀត តែទូទៅគឺរីកចំរើនខ្ពស់ ការប្រើប្រាស់ពូជថ្មី និងការធ្វើប្រពលវប្បកម្មក៏បានច្រើន។ ជារៀងរាល់ឆ្នាំ ខេត្តនេះទិញស្រូវបានគ្រប់ឬលើសផែនការ រាប់ទាំងស្រូវពូជផង ឯវិភាគទានស្នេហាជាតិក៏ប្រមូល

បាន មានអត្រាខ្ពស់ជាងខេត្តដទៃ អាស្រ័យដោយប្រជាជនគ្មានការលាក់លៀមអំពីផ្ទៃដីដែលគាត់ធ្វើបាន។ ចំពោះការស្តារដីថ្មី និងការតាំងទីលំនៅថ្មី ខេត្តតាកែវសំរេចជោគជ័យដ៏ធំធេង តាមរយៈការលើកទឹកចិត្តដល់ប្រជាកសិករ គឺរដ្ឋប្រគល់ដីទៅតាមលទ្ធភាពនៃកម្លាំងរបស់គ្រួសារនីមួយៗ ដូច្នេះមានគ្រួសារជាច្រើនធ្វើបាន ២-៣ ហិកតា ឬច្រើនជាងនេះទៀត។ មិនយូរប៉ុន្មាន តំបន់ដែលសល់ដីទំនេររាប់ពាន់ហិកតានេះ បានក្លាយទៅជាស្រែចំការ ជាសួនដំណាំ និងជាភូមិករបស់ប្រជាជន ដែលខេត្តស្នើឡើងបង្កើតជាស្រុកថ្មី ហៅថា បូរីជលសា។ ក្រៅពីខេត្តតាកែវ នៅកន្លែងផ្សេងទៀតដូចជា កំពត កោះកុង កំពង់សោម កំពង់ចាមៗលៗ បានលើកទឹកចិត្តប្រជាជនអោយរុករានដីថ្មី ដើម្បីដាំនូវដំណាំរយៈពេលវែង ដូចជាម្រេច កាហ្វេ ហើយក៏បានស្តារឡើងវិញនូវចំការកៅស៊ូ ចំការដូង ដែលធ្លាប់តែទុកចោលពីពេលមុនៗ

ភ្ជាប់ជាមួយបញ្ហាដីធ្លី ខ្ញុំសូមលើកបន្តិចអំពីមធ្យោបាយ និងឧបករណ៍ផលិតកម្ម។ ពិតមែនតែយើងបានយកចិត្តទុកដាក់ដោះស្រាយយ៉ាងច្រើន ប៉ុន្តែក៏នៅមានចំណុចដែលត្រូវកែសម្រួលជាច្រើនទៀត។ បើនិយាយអំពីកម្លាំងអូសទាញ ជាគោក្របី ប្រៀបធៀបទៅនឹងដីធ្លីដែលយើងត្រូវធ្វើ ឃើញថាមិនជាខ្វះប៉ុន្មានទេ ប៉ុន្តែ ការលំបាកនៅត្រង់ថា មានកន្លែងដែលសល់គោក្របី និងកន្លែងដែលខ្វះគោក្របី ដោយប្រៀបធៀបទៅនឹងចំនួនដីដែលត្រូវធ្វើ។ បញ្ហានេះយើងដោះស្រាយមិនទាន់បាននៅឡើយ។ ត្រាក់ទ័រ ដែលនាំចូលមកក៏ភ្លរាស់មិនទាន់អស់សមត្ថភាពនៅឡើយ មានការយឺតយ៉ាវជាច្រើនដែលបណ្តាលមកពីបែបបទរដ្ឋបាល និងការទូទាត់ ឬឧបសគ្គផ្សេងទៀត រួមទាំងបច្ចេក

ទេសផង ហើយក្នុងពេលនោះ រដ្ឋមិនទាន់ហ៊ានលក់ត្រាក់ទ័រអោយគ្រួសារ ឬក្រុមសាមគ្គីនៅឡើយ ប្រការនេះក៏នាំដល់ការយឺតយ៉ាវក្នុងអាជីវកម្មៗ ប្រសិនបើយើងហ៊ានលក់ត្រាក់ទ័រអោយកសិករ ហើយកុំខ្លាចដល់ការកើតមាននូវរបបកម្មសិទ្ធិឯកជននោះ យើងអាចដោះស្រាយបានបញ្ហាជាច្រើន ហើយជំរុញបាននូវផលិតកម្មៗ ប៉ុន្តែរហូតដល់ឆ្នាំ ១៩៨៧ ទើបក្រុមប្រឹក្សារដ្ឋមន្ត្រី បានលើកឡើងនូវគោលការណ៍លក់ត្រាក់ទ័រអោយប្រជាជន ដូច្នេះឃើញថា យើងទាញបន្ទាយអស់រយៈពេលយូរដែរៗ ម៉ាស៊ីនបូមទឹកក៏ដូចគ្នា មុនឆ្នាំ ១៩៨៦ ម៉ាស៊ីនបូមទឹកប្រមូលផ្ដុំតែនៅមជ្ឈិម ខេត្ត ស្រុកប៉ុណ្ណោះ ទំរាំដោះស្រាយបាននូវទម្រង់បែបបទ លិខិតស្នាម ស្រូវត្រូវងាប់អស់ទៅហើយក៏មានៗ ក្រោយពេលលក់អោយប្រជាជនឃើញថា ម៉ាស៊ីនបូមទឹក គឺនៅជាប់នឹងប្រឡាយទឹក ហើយហាក់ដូចជាមិនសូវឮស្រែកថា ខូចឬខ្វះប្រេងដូចជាពេលរដ្ឋគ្រប់គ្រងនោះឡើយៗ ការផ្គត់ផ្គង់ឈើ និងសម្ភារៈសំណង់សំរាប់ប្រជាជនកសាងទំនប់ ប្រឡាយ ទ្វារទឹក ឧបករណ៍កសិកម្មផ្សេងទៀត ក៏ធ្វើអោយផលិតកម្មមានល្បឿនយឺតដែរៗ

ឆ្លងតាមការលើកឡើងនូវចំណុចខ្វះៗ ខាងលើនេះ យើងគួរតែសើរើពិនិត្យឡើងវិញនូវចំណុចខ្វះដែលជាគោលការណ៍ និងលើកឡើងនូវវិធានការណ៍មួយចំនួនបន្ថែម ដែលខ្ញុំសូមលើកយកជាគំនិតផ្ទាល់ ដើម្បីសាកល្បងជំរុញដោះស្រាយទំនាស់រវាងសេចក្ដីត្រូវការ និងការផ្គត់ផ្គង់អំពីបញ្ហាស្បៀងៗ

ទី ១៖ គួរកែសម្រួលអំពីការរៀបចំក្រុមសាមគ្គីបង្កបង្កើនផល នៅទីនោះ ខ្ញុំមិនចង់និយាយពីការរំលាយចោលក្រុមសាមគ្គីនោះទេ ប៉ុន្តែអ្វី

ដែលត្រូវកែ គឺរបៀបធ្វើអាជីវកម្មរបស់ក្រុមសាមគ្គី។ យើងរក្សាទុកនូវរូបភាពក្រុមសាមគ្គី ដែលមានពី ១០ ទៅ ១៥ គ្រួសារ ដើម្បីជួយគ្នា ហើយបំពេញភារកិច្ចបី គឺ ភារកិច្ចបង្កបង្កើនផល ភារកិច្ចវាយខ្មាំងការពារមូលដ្ឋាន និងភារកិច្ចឃោសនាអប់រំនយោបាយសតិអារម្មណ៍។ ឯការធ្វើអាជីវកម្មវិញ គឺគួររៀបចំអោយស្របទៅនឹងលទ្ធភាពនៃមធ្យោបាយ និងឧបករណ៍ផលិតកម្ម។ ជាទូទៅ យើងពិនិត្យឃើញថា លទ្ធភាពជាក់ស្តែង គឺអនុញ្ញាតអោយយើងធ្វើបានត្រឹមកំរិតក្រុមសាមគ្គី ជាវេរប្រវាស់ដៃ ដែលយើងធ្លាប់ហៅថា ក្រុមសាមគ្គីប្រភេទទី ២ តែប៉ុណ្ណោះ មិនអាចឈានទៅធ្វើរួមហើយចែកផលតាមពលកម្មបានទេ។

បញ្ហានេះគេអាចចោទសួរថា តើក្រុមសាមគ្គីរបៀបនេះ អាចជួយដល់អ្នកខ្វះពលកម្ម ដូចជាគ្រួសារយុទ្ធជនពលី ពិការ គ្រួសារយុទ្ធជនកំពុងនៅក្នុងជួរកងទ័ពបានទេ? គេអាចធ្វើបានតាមរយៈនៃស្មារតីសាមគ្គីយោគយល់គ្នា ដែលគេអាចជួយជាពលកម្មម្តងម្កាលក្នុងរដូវបង្កបង្កើនផល ហើយគ្រួសារនោះថែទាំដោយខ្លួនឯង រហូតដល់គេអាចជួយគ្នាបានអំពីសម្ភារៈទៀតផង។ មិនត្រឹមតែប៉ុណ្ណោះ គេក៏អាចមានលទ្ធភាពរួមកម្លាំងគ្នា ដើម្បីធ្វើការងាររួមដូចជា ធ្វើកូនប្រឡាយ ទំនប់ ។ល។ ទៀតផង។

បញ្ហាសំខាន់នៅទីនេះ គឺយើងត្រូវបែងចែកដីធ្លីអោយបានសមស្រប ហើយគួរបែងចែកទៅតាមតំបន់ពីរខុសគ្នា។ នៅតំបន់ដែលមានដីតិច ហើយប្រជាជនច្រើន គួរបែងចែកទៅតាមពលកម្ម ឬចំនួនមនុស្សនៅតាមគ្រួសារ ឯនៅតំបន់ដែលមានដីច្រើន ហើយប្រជាជនតិច ក្រៅពីការបែងចែកទៅតាមពលកម្ម ឬចំនួនមនុស្សក្នុងគ្រួសារ គឺត្រូវទុកលទ្ធ

ភាពអោយគ្រួសារនីមួយៗ ធ្វើនៅលើដីសល់ទំនេរ ឬរុករានដីថ្មីទៅតាមលទ្ធភាពនៃពលកម្មរបស់គ្រួសារ ហើយមិនគួរកំណត់ពីទំហំឡើយ។ ពេលធ្វើ ឬពេលប្រមូលផល គេអាចផ្លាស់ប្តូរពលកម្មគ្នា "គឺប្រវាស់ដៃ" រួចគ្រួសារនីមួយៗ ម្ចាស់ការថែទាំ និងធ្វើប្រពលវប្បកម្ម ហើយទទួលផលទៅតាមទិន្នផល ដែលចំណែកដីរបស់ខ្លួនបានផ្តល់អោយ។ និយាយអោយចំ នេះជារបៀបធ្វើអាជីវកម្មមានលក្ខណៈគ្រួសារ ក្រោមរូបភាពជួយគ្នា នៃក្រុមសាមគ្គីបង្កបង្កើនផល។ រូបភាពនេះអាចលើកទឹកចិត្ត ដល់ប្រជាកសិករក្នុងការធ្វើម្ចាស់លើដីធ្លី លើអាជីវកម្ម លើភោគផលដែលគេទទួលបាន ហើយក៏មិនបណ្តោយអោយគ្រួសារណាមួយ ធ្លាក់ក្នុងភាពក្រីក្រហួតគ្មានដីបង្កបង្កើនផលដែរ ហើយក៏អាចជួយដល់គ្រួសារដែលជួបការលំបាកបានដែរ។

ដូច្នេះ ក្រុមសាមគ្គីបង្កបង្កើនផល គឺនៅសល់តែរូបភាពមួយទេ គ្មានប្រភេទជាច្រើន ដូចពេលមុនៗ ប៉ុន្តែ មតិខាងលើនេះ ក៏មិនមែនមានន័យថា យើងចង់អោយគ្រប់កន្លែងធ្វើតាមគំរូតែមួយនោះទេ សំណូមពរជាមូលដ្ឋាន គឺត្រូវតែពិនិត្យនូវលទ្ធភាពជាក់ស្តែងនៃឧបករណ៍ និងមធ្យោបាយផលិតកម្ម តើអាចមានលទ្ធភាពអោយយើងរៀបចំរបៀបធ្វើអាជីវកម្មក្នុងក្រុមសាមគ្គីយ៉ាងណា។ មានកន្លែងខ្លះ ក៏មានចំណែកដីមួយចំនួន ដែលតម្រូវអោយប្រជាជនសហការធ្វើ ហើយចែកផលតាមការស្រុះស្រួលគ្នា ដូចជាប្រព័ន្ធប្រឡាយទឹកត្រូវប្រើរួម ត្រូវមានម៉ាស៊ីនបូមទឹក ហើយត្រូវប្រើប្រេងយ៉ាងច្រើន ដូច្នេះគ្រួសារមួយ មិនអាចធ្វើទៅកើតទេ ទាល់តែក្នុងក្រុមទាំងមូល ឬភូមិទាំងមូល រួមគ្នាទាំងពលកម្ម ទាំងសម្ភារៈ ទើបអាចធ្វើទៅកើត។ ដូច្នេះ ក៏គួរទុកលទ្ធភាពអោយ

ប្រជាជនសម្រុះសម្រួលគ្នា តើត្រូវធ្វើរបៀបណា។ ធ្វើយ៉ាងនេះ ទើបការរៀបចំទំនាក់ទំនងផលិតកម្ម សមស្របទៅនឹងកំរិតសមត្ថភាពនៃកម្លាំងផលិតកម្ម។ និយាយយ៉ាងដូច្នេះ មិនមែនបានសេចក្ដីថា បក្ស និងរដ្ឋបោះបង់ចោលតួនាទីដឹកនាំនោះទេ គឺត្រូវតែដឹកនាំ តែការដឹកនាំយ៉ាងណាក៏ត្រូវពិនិត្យដល់ការជាក់ស្ដែង និងលទ្ធភាពពិតប្រាកដរបស់ប្រជាជនយើង។ យើងត្រូវដឹងថា បំណងមិនអាចរំលងនូវលទ្ធភាពពិតប្រាកដបានទេ។

ទី ២៖ គួរកែសម្រួលនូវគោលនយោបាយ ស្ដីពីការប្រើប្រាស់ដីធ្លីកសិកម្ម។ ប៉ុន្មានឆ្នាំកន្លងមក មានកន្លែងមួយចំនួន ប្រជាកសិករមិនទាន់មានលំនឹងក្នុងចិត្តនៅឡើយ មិនទាន់ដឹងថា តើដីដែលគេធ្វើអាជីវកម្មសព្វថ្ងៃនេះ ជាដីរបស់គេរហូតទៅឬយ៉ាងណា ព្រោះរដ្ឋបានកំណត់ថា ដីធ្លីជាកម្មសិទ្ធិរបស់រដ្ឋ។ ក្នុងមាត្រា ១៥ នៃរដ្ឋធម្មនុញ្ញ គឺមានតែដីភូមិ សំរាប់សង់ផ្ទះ សួនច្បារ សួនបន្លែទេ ដែលពលរដ្ឋមានសិទ្ធិពេញទីក្នុងការប្រើប្រាស់ និងមានសិទ្ធិតំណមរតក លើដីដែលរដ្ឋប្រគល់អោយគ្រួសារនីមួយៗ តាមការកំណត់នៃច្បាប់។ ឯ មាត្រា ១៦ បានចែងថា ក្រៅពីដីសំរាប់សង់ផ្ទះនៅ និងធ្វើជាសួនច្បារ សួនបន្លែ ដែលមានកំណត់ក្នុងច្បាប់ និងក្រៅពីចំណែកដីដែលក្រុមសាមគ្គីបង្កបង្កើនផលបានប្រគល់អោយ ដើម្បីបំពេញផលិតកម្មរបស់ក្រុម ពលករកសិកម្មមួយរូបៗ អាចបានរដ្ឋអោយខ្ចីដីជាបន្ថែម ដើម្បីដាំដំណាំរដូវតាមលទ្ធភាពពលកម្ម ហើយមានសិទ្ធិទទួលផលនៃការងារនេះ។

បើនិយាយពីច្បាប់ដែលបានកំណត់ឃើញថា មិនមានអ្វីរាំងស្ទះឡើយ ប៉ុន្តែពេលផ្សព្វផ្សាយ និងចាត់តាំងអនុវត្តន៍ យើងមិនទាន់បាន

លើកទឹកចិត្តប្រជាកសិករ ហើយមិនទាន់ធ្វើអោយប្រជាកសិករនឹងន ចិត្តឡើយ។ ប្រការសំខាន់ គឺសិទ្ធិក្នុងការបង្កបង្កើនផល លើដីដែលច្បាប់បានចែងថា រដ្ឋអោយខ្ចីដី។ ពាក្យថាអោយខ្ចី ប្រជាកសិករភាគច្រើនយល់ថា នឹងត្រូវសងនៅពេលណាមួយ ដូច្នេះគេមិនហ៊ានដាំដំណាំរយៈពេលវែង មិនហ៊ានទៅរុករានដីថ្មីបន្ថែមទៀត ជាងនេះទៅទៀតមិនបានលើកទឹកចិត្តដល់ការតាំងលំនៅថ្មី នៅកន្លែងសល់ដីទំនេរច្រើន។ ដូច្នេះ វារាំងស្ទះដល់ការពង្រីកដីថ្មី និងការបែងចែកពលកម្មសង្គមឡើងវិញដែរ។ ចំណុចសំខាន់នៅទីនេះ យើងមិនកែមាត្រាទី ១៤ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា "ទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់រដ្ឋមានដីធ្លី ព្រៃឈើ សមុទ្រ ទន្លេ បឹង ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស និងសំណង់ផ្សេងៗ ទៀតរបស់រដ្ឋ" ទេ ហើយក៏មិនកែមាត្រា ១៧ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា "ជនណាក៏ដោយគ្មានសិទ្ធិទិញ លក់ បញ្ចាំ ឬប្រវាស់ដីធ្លីបានឡើយ ជនណាក៏ដោយមិនអាចប្រើប្រាស់ដីធ្លីកសិកម្ម ដីព្រៃដោយចិត្តឯង ក្នុងគោលបំណងផ្សេងទៀតបាន បើគ្មានការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ច"។ ការដោះស្រាយនៅទីនេះ សំខាន់គឺបញ្ជាក់អំពីសិទ្ធិកាន់កាប់ និងធ្វើអាជីវកម្មលើដីធ្លី ដែលរដ្ឋបានផ្តល់អោយគ្រួសារនីមួយៗ គឺត្រូវអោយគេមានសិទ្ធិតំណមរតកតកូនតចៅ ប្រសិនបើដីធ្លីនេះ រដ្ឋមិនត្រូវការយកទៅធ្វើអ្វីផ្សេងទៀត។ ក្នុងករណីអគ្គការរដ្ឋ ឬអគ្គការសង្គមត្រូវការ ក៏ត្រូវតែពិភាក្សាសម្រុះសម្រួលជាមួយគ្រួសារ ដែលកំពុងកាន់កាប់ដីធ្លីនេះ អោយបានសមហេតុសមផល ដោយធានាដល់ផលប្រយោជន៍ស្របច្បាប់របស់គ្រួសារនេះ ហើយបង្កលក្ខណៈអោយគ្រួសារនេះមាន

ដីធ្លីសំរាប់លំនៅដ្ឋាន និងបង្កបង្កើនផលនៅកន្លែងផ្សេងទៀត។ ករណីនេះអាចកើតមានតិចតួចទេ ប៉ុន្តែក៏មិនអាចជៀសផុតដែរ អាស្រ័យដោយភាពចាំបាច់នៃការរីកចំរើនរបស់ប្រទេសជាតិ។ បច្ចុប្បន្ន ការបែងចែកដីធ្លីអោយគ្រួសារកសិករនីមួយៗ មានស្ថិរភាពបង្គួរហើយ ដូច្នេះគួរចេញការបញ្ជាក់អោយគ្រួសារកសិករនីមួយៗ កាន់កាប់តែម្តង ដើម្បីអោយប្រជាកសិករមានការនឹងនចិត្ត។ ចំណែកដីដែលគ្រួសារមួយចំនួនបានទៅរុករានថ្មី ក៏ត្រូវមានការបញ្ជាក់ទទួលស្គាល់ ហើយនិងបន្តទទួលស្គាល់ ចំពោះដីណាដែលគ្រួសារនឹងទៅរុករាន ឬស្តារថ្មីបន្តទៀត។ រដ្ឋយើងហាមឃាត់តែការទិញ លក់ បញ្ចាំ ឬប្រវាស់ដី ហាមឃាត់ការទៅរុករាន ដីថ្មីមិនបានសុំការអនុញ្ញាត ដែលវាអាចប៉ះពាល់ដល់ព្រៃលិចទឹក ព្រៃបំរុងទុក ឬពីលើតំបន់មានរ៉ែ តំបន់ដែលនឹងត្រូវកសាងពេងចក្រ ឬមូលដ្ឋានបំរើអោយការការពារប្រទេស។ល។ រដ្ឋក៏ហាមឃាត់ផងដែរ ចំពោះការទៅចាប់ដីព្រៃទុកមិនធ្វើអាជីវកម្ម ហើយទុកលក់ ឬជួលអោយអ្នកដទៃ។ ចំពោះបញ្ហានេះ យើងក៏ត្រូវពិនិត្យឡើងវិញនូវគោលនយោបាយស្តីពីការឧបត្ថម្ភចំពោះការស្តារដីថ្មី និងការតាំងទីលំនៅថ្មី ធ្វើយ៉ាងណាបង្កលក្ខណសម្បត្តិងាយស្រួលអោយការងារនេះ ដើម្បីដោះស្រាយការបាត់តុល្យភាពរវាងផ្ទៃដី និងចំនួនប្រជាជនចំពោះមុខផង និងដោះស្រាយការបែងចែកពលកម្មសង្គមឡើងវិញ ទៅអនាគតផង។

ទី ៣៖ អំពីការវិនិយោគទុនកសាងមូលដ្ឋាន សម្ភារៈឧបករណ៍ មធ្យោបាយបច្ចេកទេស បំរើអោយការផលិតស្បៀង។

ចំណុចនេះ គួរពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធវិនិយោគរបស់យើង

ចំពោះវិស័យកសិកម្ម ព្រមទាំងត្រូវត្រួតពិនិត្យប្រសិទ្ធិភាពរបស់វា តើមានអ្វីដែលត្រូវកែសម្រួលឬទេ។ អាទិភាពសំខាន់របស់យើង គឺប្រមូលផ្តុំចំពោះការកសាងសំណង់ធារាសាស្ត្រ ដើម្បីដោះស្រាយទឹកអោយប្រជាជនធ្វើស្រែ។ ក្នុងពេលដែលរដ្ឋខ្វះទុន យើងគ្រាន់តែបានប្រមូលផ្តុំទៅលើសំណង់ធំៗ តែប៉ុណ្ណោះ ហើយមិនទាំងបានគ្រប់គ្រាន់ផង ឯសំណង់តូចៗ ដែលជាសេចក្តីត្រូវការនៅគ្រប់ទីកន្លែង ហើយដែលប្រជាជនមានលទ្ធភាពចូលរួមជាពលកម្ម ជាសម្ភារៈនោះ យើងធ្វើក៏បានតិចៗ ការគួបផ្សំរវាងរដ្ឋ និងប្រជាជន ក្នុងការកសាងសំណង់បំរើអោយកសិកម្ម ពិតមែនតែមានចលនាហើយ ប៉ុន្តែនៅមិនទាន់អស់ប្រភពនៃកម្លាំងដែលយើងមាននៅឡើយ។ មានកន្លែងខ្លះ ប្រជាជនធ្វើដោយខ្លួនឯង ជាពលកម្ម ជាថវិកា ដោយគ្រាន់តែសុំអោយរដ្ឋជួយលក់ឈើ ដែក ស៊ីម៉ង់ ប្រេងៗលៗ តែប៉ុណ្ណោះ ក៏យើងដោះស្រាយមិនទាន់ពេលវេលា ឬក៏មិនបានតែម្តងទៀតផង។ ក្នុងការដោះស្រាយទឹកយើងត្រូវការហើយនូវសំណង់ធារាសាស្ត្រធំ និងមធ្យម ប៉ុន្តែ យើងខ្វះទុន និងសម្ភារៈ។ ក្នុងពេលនោះ សំណង់ធារាសាស្ត្រតូចៗ គឺជាការចាំបាច់នៅគ្រប់ទីកន្លែងទាំងអស់ ទោះជាទីនោះមានធារាសាស្ត្រធំ ឬមធ្យមហើយក៏ដោយ ក៏គេត្រូវការកូនប្រឡាយ ដើម្បីបង្ហូរទឹកបញ្ចូលស្រែគេដែរ។ ដូច្នេះ ធារាសាស្ត្រតូចៗ នៅតែជាទិសដៅត្រូវជំរុញធ្វើហើយត្រូវដាក់ក្នុងយុទ្ធសាស្ត្រយូរអង្វែង។ បើយើងដឹកនាំបានល្អ ការងារនេះនឹងវិវឌ្ឍឆាប់រហ័ស ព្រោះជាផលប្រយោជន៍ផ្ទាល់របស់គ្រួសារ ឬភូមិឃុំតែម្តង ប្រជាកសិករពិតជាពេញចិត្តក្នុងការចូលរួម ហើយការងារនេះ ក៏មិនទាមទារបច្ចេកទេសខ្ពស់ដែរ ចាស់ស្រុក ចាស់ភូមិ ដែលធ្លាប់

ស្គាល់ស្ថានភាពភូមិសាស្រ្តក៏អាចធ្វើបាន រដ្ឋជួយតែសម្ភារៈខ្វះ ដូចជា ដែក ស៊ីម៉ង់ ឈើ ប្រេងឥន្ធនៈ ឬក៏ជួយបច្ចេកទេសខ្វះ ដែលមានភាព ស្មុគស្មាញប៉ុណ្ណោះ។ ចំពោះសំណង់ធំ ឬមធ្យម ដែលរដ្ឋធ្វើ ឬរដ្ឋរួម ជាមួយ ប្រជាជនធ្វើ ក៏ត្រូវពិនិត្យអោយច្បាស់លាស់ តើត្រូវធ្វើកន្លែង ណាមុន កន្លែងណាក្រោយ ព្រោះបើធ្វើក្នុងពេលជាមួយគ្នា ក៏យើង គ្មានទុន និងសម្ភារៈដែរ។ ម្យ៉ាងទៀតក៏ត្រូវចេះធៀតគួបផ្សំ ការកសាង ផ្លូវគមនាគមន៍ជាមួយធារាសាស្រ្តដែរ ដូចជាការជីកព្រែកធ្វើផ្លូវទឹក ដោយគួបផ្សំនឹងការយកទឹកធ្វើស្រែ ឬលើកទំនប់យកទឹកធ្វើស្រែ ដោយគួបផ្សំនឹងការធ្វើចរាចរដឹកជញ្ជូនលើខ្នងទំនប់តែម្តង។ល។ ការ ងារនេះ មានបទពិសោធន៍នៅកន្លែងមួយចំនួនហើយ ដូចជា ខេត្ត តាកែវ និងខេត្តព្រៃវែង។ ចំពោះទុនវិនិយោគសំរាប់កសាងធារាសាស្រ្ត ក៏គួរតែពិនិត្យបន្ថែម អោយបានខ្ពស់ជាងមុនទៀតដែរ បញ្ហានេះ គឺមិន ត្រឹមតែចែករំលែកទុនពីផ្នែកកសិកម្មទាំងមូលប៉ុណ្ណោះទេ ប៉ុន្តែត្រូវចែក រំលែកទុនពីផ្នែកផ្សេងៗ ទៀត ក្នុងសង្គម មកបន្ថែម ដើម្បីអោយផ្នែក ធារាសាស្រ្តបានដើរមុខមួយជំហាន។

ចំពោះឧបករណ៍ មធ្យោបាយ រដ្ឋយើងគួរតែហ៊ានក្នុងការលក់ជូន ប្រជាជន ដូចជា ត្រាក់ទ័រ ម៉ាស៊ីនបូមទឹក ឬក៏មធ្យោបាយសម្ភារៈផ្សេងៗ ទៀត ប៉ុន្តែសំខាន់គឺ ត្រាក់ទ័រ និងម៉ាស៊ីនបូមទឹក។ ការពង្រីកថែមដីថ្មី ឬ ការបង្កបង្កើនផលលើដីមានស្រាប់ ត្រូវការអោយមានមធ្យោបាយភ្ជួរ រាស់បានគ្រប់គ្រាន់។ ប្រសិនបើរដ្ឋយើងផ្តល់អោយទៅប្រជាជនប្រើ ប្រាស់តែម្តង គឺវាងាយស្រួលក្នុងការគ្រប់គ្រង និងធ្វើអាជីវកម្មបានទាន់ ពេលវេលា មិនចាំបាច់ឆ្លងកាត់លិខិតស្នាម ឬការទូទាត់ដ៏សាំញ៉ាំដូចរយៈ

ពេលកន្លងមក ហើយការប្រើប្រាស់ ក៏បានពេញសមត្ថភាពនៃគ្រឿងម៉ាស៊ីនផង ដោយសារនៅនឹងមូលដ្ឋានស្រាប់។ ក្រៅពីការភ្ជួររាស់ គេអាចច្នៃទៅជាមធ្យោបាយដឹកជញ្ជូន សណ្តោងរ៉ឺម៉ក បូមទឹក កិនពោត ឬបែនស្រូវៗល។ ហើយនេះ ក៏ជាការបណ្តុះបណ្តាលបច្ចេកទេសនៅនឹងកន្លែងស្រាប់ផង ព្រោះពេលគេប្រើ គេត្រូវតែចេះថែទាំ ឬជួសជុលបានខ្លះដែរ។ ម៉ាស៊ីនបូមទឹកក៏ដូចគ្នា គេប្រើប្រាស់វា ជួសជុលថែទាំវាក្រៅពីការបូមទឹកបញ្ចូលស្រែ បើគេកែច្នៃធ្វើជាម៉ាស៊ីនកាណូត សំរាប់ដឹកជញ្ជូន ឬក៏ទាញឌីណាម៉ូ សំរាប់យកភ្លើងបំភ្លឺ ក៏វាកាន់តែចំណេញថែមទៀត។ ម្យ៉ាងទៀត អាស្រ័យដោយត្រាក់ទ័រ ឬម៉ាស៊ីនបូមទឹកជាមធ្យោបាយផលិតកម្មដែលមានតម្លៃខ្ពស់ គ្រួសារកសិករពិតជានឹងខិតខំរួមគ្នាដើម្បីទិញ។ ដូច្នេះ វាក៏ជាមធ្យោបាយមួយ ដើម្បីអូសទាញអោយកសិករសហការផ្សារភ្ជាប់ នៅជុំវិញមធ្យោបាយផលិតកម្មនេះ ហើយប្រសិនបើក្រុមសាមគ្គី ឬភូមិនេះប្រើមិនអស់សមត្ថភាពនៃគ្រឿងម៉ាស៊ីននេះទេ គេក៏អាចយកវាទៅស៊ីឈ្នួល ភ្ជួររាស់ ឬបូមទឹក អោយក្រុម ឬភូមិដទៃបានដែរ។ រដ្ឋយើងក៏គួរហ៊ានផងដែរ ក្នុងការលក់បណ្តាក់អោយគ្រួសារកសិករ ក្រុម ឬភូមិ ឃុំ ក្នុងករណីដែលគេខ្វះប្រាក់ទិញត្រាក់ទ័រ ឬម៉ាស៊ីនបូមទឹក។

ចំពោះបញ្ហាបច្ចេកទេសកសិកម្ម ការងារនេះក៏ត្រូវជំរុញបន្ថែម។ ក្រៅពីការបណ្តុះបណ្តាលបច្ចេកទេសជាន់ខ្ពស់ ដែលធ្វើនៅមជ្ឈិម ឬបញ្ជូនទៅសិក្សានៅបរទេស គួរយកចិត្តទុកដាក់បណ្តុះបណ្តាលនៅនឹងកន្លែងនៅតាមខេត្តក្រុង ហើយក៏គួរបញ្ចូលបច្ចេកទេសកសិកម្មនេះទៅក្នុងកម្មវិធីសិក្សា នៅតាមសាលារៀនអោយបានកាន់តែច្រើន។ ធ្វើ

យ៉ាងនេះ យើងអាចបង្កើនចំនួនអ្នកបច្ចេកទេសបានឆាប់រហ័សផង ហើយធ្វើអោយគ្រួសារប្រជាកសិករមានការចេះដឹងអំពីបច្ចេកទេសដាំដុះ ការធ្វើប្រពលវប្បកម្ម បានឆាប់រហ័សផង ហើយជាងនេះទៅទៀត សិស្សសាលា ក្រោយបញ្ចប់ការសិក្សា ទោះជាមិនអាចចូលធ្វើការងាររដ្ឋបាន ក៏គេអាចយកការចេះដឹងខ្លះៗ ខាងកសិកម្ម ដែលបានទទួលពីសាលារៀន ទៅបង្កបង្កើនផលតាមគ្រួសារបានដែរ។ បច្ចេកទេសដែលត្រូវដោះស្រាយជាបឋម គឺការធ្វើប្រពលវប្បកម្ម ដែលទាក់ទងសំខាន់ដល់ការប្រើប្រាស់ពូជ ការធ្វើជី ការដាំដុះ ការថែទាំ ការប្រើប្រាស់ជី ។ល។ ដើម្បីធ្វើអោយទិន្នផលបានកើនឡើង រួចចាកពីកំរិតក្រោម ១ តោន ឬលើស ១ តោនបន្តិចបន្តួចក្នុងមួយហិកតា ដែលស្ទើរតែមិនអាចសងរួចថ្លៃដើមនៃការផលិតផងនោះ។

ទី ៤ៈ ដើម្បីបង្កើនបរិមាណផលស្បៀងអោយបានឆាប់ ក្រៅពីបញ្ហាបីដែលបានលើកឡើងខាងលើ គប្បីមានវិធានការសរុបបីយ៉ាង គឺការពង្រីកផ្ទៃដី ការធ្វើប្រពលវប្បកម្ម និងការបង្កើនរដូវ។ វិធានការសរុបបីយ៉ាងនេះ ជាវិធានការរួមរបស់រដ្ឋ ប៉ុន្តែការធ្វើនៅតាមតំបន់មានលក្ខណៈប្លែកៗគ្នា យោងទៅតាមលក្ខណៈដោយឡែករបស់មូលដ្ឋាន។

ចំពោះការពង្រីកផ្ទៃដី តើយើងគួរអោយអាទិភាពពង្រីកនៅកន្លែងណា? ប៉ុន្មានឆ្នាំកន្លងមក យើងពិនិត្យឃើញថា ផ្ទៃដីស្រូវឡើងទឹកនៅក្នុងខេត្តមួយចំនួន ដូចជា បាត់ដំបង សៀមរាប កំពង់ធំ។ល។ នៅបោះបង់ចោលយ៉ាងច្រើន មិនទាន់បានស្តារនៅឡើយ។ ដូច្នេះ យើងគួរជួយប្រជាជនក្នុងបណ្តាខេត្តនេះ អោយស្តារឡើងវិញ ដោយហ៊ានធ្វើវិនិយោគទុនចូលដំបន់នេះ ដោយប្រមូលផ្តុំត្រាក់ទ័ររបស់រដ្ឋចុះជួយ

ក្ខរ ហើយផ្ដល់អាទិភាពក្នុងការលក់ត្រាក់ទ័រជូនប្រជាជននៅតំបន់នេះ ធ្វើយ៉ាងណាអោយប្រជាជន មានកម្លាំងគ្រប់គ្រាន់ក្នុងការស្ដារដីស្រូវឡើងទឹក ដែលបោះបង់ចោលទំនេរ។ ក្រៅពីនោះ ក៏ត្រូវយកចិត្តទុកដាក់ជួយឧបត្ថម្ភដល់ប្រជាជន នៅតំបន់ដែលមានមនុស្សច្រើន ហើយមានដីតិច ដើម្បីបានស្ដារ ឬរុករកដីថ្មីនៅក្នុងមូលដ្ឋានផ្ទាល់ ឬនៅដំបន់ផ្សេងទៀត ដែលមានដីច្រើន។ ការងារនេះ ត្រូវម្ចាស់ការធ្វើក្នុងក្របខ័ណ្ឌភូមិ ឃុំ ស្រុក ឬខេត្ត ហើយត្រូវមានផែនការច្បាស់លាស់ល្អ។ ក្នុងករណីខេត្តមិនមានដីអាចពង្រីកបានថែមទៀត មជ្ឈិមត្រូវទទួលបន្ទុក។

ចំពោះការធ្វើប្រពលវប្បកម្ម ការងារនេះត្រូវធ្វើនៅគ្រប់ទីកន្លែង ទាំងកន្លែងមានដីច្រើន ទាំងកន្លែងមានដីតិច ពិសេសកន្លែងមានដីតិច។ ការធ្វើប្រពលវប្បកម្ម វាមានប្រយោជន៍ច្រើនជាងការពង្រីកផ្ទៃដី។ ឧទាហរណ៍ បើពង្រីកផ្ទៃដីបានពីរហិកតា ហើយធ្វើបានក្នុងមួយហិកតាតែមួយតោននោះ ឯការធ្វើប្រពលវប្បកម្មមួយហិកតា បានរហូតពីរឬបីតោននោះ យើងគួរធ្វើប្រពលវប្បកម្មវិញ ប្រសើរជាងការពង្រីកផ្ទៃដី ព្រោះថាយើងត្រូវចំណេញពលកម្មយ៉ាងច្រើន។ ជាទូទៅ យើងពិនិត្យឃើញថា ការធ្វើប្រពលវប្បកម្មមានចលនាខ្លាំង តែនៅតំបន់ដែលមានដីតិច ប្រជាជនច្រើន ព្រោះវាចាំបាច់ត្រូវតែធ្វើ ឯតំបន់ដែលមានដីច្រើន ហើយប្រជាជនតិច មិនទាន់មានចលនានៅឡើយ។ ពិតហើយ ការធ្វើប្រពលវប្បកម្មលើដំណាំស្រូវ ត្រូវមានការជួយឧបត្ថម្ភពីរដ្ឋខ្លះដែរ ដូចជា ជី ថ្នាំសម្លាប់សត្វល្អិត បច្ចេកទេស ប៉ុន្តែគ្រួសារកសិករនីមួយៗ មានតួនាទីសំរេចកំណត់ ក្នុងការបង្កើនទិន្នផល សូម្បីតែជីធម្មជាតិដែលគ្រួសារនីមួយៗ ប្រមូល ក៏បានរួមចំណែកដោះស្រាយបញ្ហា

ដីខ្ទះហើយដែរ។

ឯការបង្កើនរដូវ ការងារនេះថ្មី ហើយទើបតែធ្វើក្នុងរបបថ្មីរបស់យើងនេះទេ តែជាចលនាដែលគួរអោយមានការទុកចិត្ត។ តំបន់មួយចំនួនធ្វើបានដោយជោគជ័យ គឺធ្វើស្រូវពីរដងក្នុងមួយរដូវ ដែលពីមុននោះធ្លាប់បានធ្វើតែមួយដង ក្នុងមួយរដូវ ឬក្នុងមួយឆ្នាំ។ ពិតមែនហើយ ការងារនេះមានការលំបាក ព្រោះវាទាក់ទងដល់កត្តាជាច្រើន ដូចជាបញ្ហាធាតុអាកាស បញ្ហាទឹក ដី កម្លាំងពលកម្ម។ល។ ប៉ុន្តែ យើងគួរជំរុញតទៅទៀត ព្រោះវានឹងនាំដល់ការបង្កើនទិន្នផល បង្កើនចំណូលអោយប្រជាជន ហើយដីធ្លីយើងទៀតសោត ក៏ផ្តល់លទ្ធភាពអោយយើងធ្វើនៅច្រើនកន្លែងដែរ។

ប្រសិនបើដោះស្រាយបានបញ្ហាមួយចំនួនខាងលើនេះ យើងពិតជាឈានទៅដោះស្រាយទំនាស់ រវាងសេចក្តីត្រូវការ និងការផ្គត់ផ្គង់អំពីបញ្ហាស្បៀងបាន ហើយចេញពីនោះ យើងនឹងដោះស្រាយបាននូវបញ្ហាផ្សេងទៀត។

ដូចបានដឹងរួចមកហើយថា ការបាត់តុល្យភាពរវាងសេចក្តីត្រូវការ និងការផ្គត់ផ្គង់ មិនមែនតែលើបញ្ហាស្បៀងមួយមុខនោះទេ គឺនៅមានបញ្ហាច្រើនផ្នែកផ្សេងទៀត ប៉ុន្តែសំខាន់ គឺសំណូមពរអំពីមុខទំនិញប្រើប្រាស់សំរាប់បំរើជីវភាព សំរាប់ហូបចុក សំរាប់ការធ្វើដំណើរ សំរាប់ការសិក្សា សំរាប់បំរើដល់ផលិតកម្ម។ល។ សំណូមពរនៅទីនេះ មិនគ្រាន់តែអំពីបរិមាណប៉ុណ្ណោះទេ ប៉ុន្តែនៅជាបញ្ហាគុណភាពទៀតផង។ ផលិតផលរបស់រោងចក្រយើងមួយចំនួន វាលែងស្របទៅនឹងសំណូមពររបស់ប្រជាជនយើងហើយ។

បញ្ហានេះ វាទាមទារអោយមានការពិនិត្យកែលំអថែមទៀត នូវគោលការណ៍របស់យើង ដែលបានដាក់ចេញសំរាប់វិស័យឧស្សាហកម្ម និងសិប្បកម្ម ពិសេសពិនិត្យអំពីរចនាសម្ព័ន្ធវិនិយោគទុនចំពោះផ្នែកឧស្សាហកម្ម ព្រមទាំងត្រូវកែសម្រួលប្រព័ន្ធបច្ចេកទេសរបស់រោងចក្រខ្លះ ដើម្បីបង្កើនគុណភាពនៃផលិតផល។ ប្រការសំខាន់នៅទីនេះ គឺត្រូវជំរុញអោយបានខ្លាំងជាងនេះទៀត នូវសិប្បកម្ម ទាំងសមូហភាព ទាំងឯកជន ដើម្បីរួមចំណែក ផលិតនូវមុខទំនិញសំរាប់ផ្គត់ផ្គង់សេចក្តីត្រូវការរបស់សង្គម ដែលចេះតែកើនឡើង ជាមួយនោះក៏ត្រូវផ្ទៀតយកការរួមចំណែករបស់ឯកជន ដើម្បីកសាងឡើងនូវរោងចក្រថ្មី ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចឯកជន ឬក្របខ័ណ្ឌនៃសមាសភាពសេដ្ឋកិច្ចរដ្ឋចម្រុះជាមួយឯកជន។

ប្រសិនបើយើងដោះស្រាយបាននូវទំនាស់រវាងសេចក្តីត្រូវការ និងការផ្គត់ផ្គង់តាមរយៈនៃការបង្កើនផលិតកម្មក្នុងប្រទេស វាពិតជានឹងបានរួមចំណែកដល់ការដោះស្រាយ ការបាត់តុល្យភាពរវាងចំណូល និងចំណាយ ការបាត់តុល្យភាពរវាងការនាំចេញ និងការនាំចូល និងការបាត់តុល្យភាពរវាងរូបិយវត្ថុ និងទំនិញ ដែលនាំដល់ការមានលំនឹងនៃថវិការដ្ឋ បំបាត់ ឬបន្ថយបាននូវឱនភាពថវិកា និងសាច់ប្រាក់ រក្សាបាននូវស្ថិរភាពតម្លៃនៅលើទីផ្សារ បន្ថយបាននូវការជំពាក់បំណុលបរទេស ដែលបណ្តាលមកពីការនាំចូលមានទំហំច្រើនជាងការនាំចេញ។

# សមិទ្ធិផល ១០ ឆ្នាំ ខាងវិស័យ សង្គមកិច្ច វប្បធម៌ និង កិច្ចការត្រួបត្ត

*ក្នុងសភាពការណ៍ដែលគ្រប់វិស័យត្រូវបំផ្លិចបំផ្លាញដល់ឫសគល់ ហើយត្រូវរង្គោះរង្គើរហូតដល់បញ្ញាញាណរបស់ជាតិ ការកសាងឡើងវិញនូវខឿនវប្បធម៌ សង្គមកិច្ចមួយ ដែលមានភាពជឿនលឿន ចាំបាច់ត្រូវមានពេលគ្រប់គ្រាន់ ប៉ុន្តែសភាពការណ៍ប្រទេស មិនអនុញ្ញាតអោយយើងរង់ចាំឡើយ ហើយត្រូវតែចាប់ផ្តើមចេញដំណើរព្រមពេលគ្នាជាមួយនឹងវិស័យផ្សេងទៀតដែរ។ បើយើងពិនិត្យមើលឡើងវិញ ក្នុងរយៈពេល ១០ ឆ្នាំកន្លងមក គឺយើងទទួលបានជោគជ័យធំធេងណាស់ លើវិស័យវប្បធម៌ សង្គមកិច្ច ដែលបានផ្តល់អោយប្រជាជនយើងនូវមោទនភាពដ៏ជ្រាលជ្រៅ ហើយក៏ជាបទពិសោធន៍ដ៏ថ្លៃថ្លា សំរាប់ការឈានឡើងជាបន្តរបស់យើងដែរ។*

១. អំពីវិស័យអប់រំ និងបណ្តុះបណ្តាល

*យើងបានដឹងរួចមកហើយ ប្រទេសជាតិយើងត្រូវធ្លាក់ក្នុងសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក តាំងពីឆ្នាំ ១៩៧០ មក។ ពេលសង្គ្រាមកើតមានភ្លាម ប្រទេសក៏ត្រូវបែងចែកជាតំបន់កាន់កាប់ពីរ មួយគឺដំបន់រំដោះនៃអ្នកតស៊ូប្រឆាំងការឈ្លានពានរបស់អាមេរិក មួយទៀតគឺតំបន់*

ដែលកាន់កាប់ដោយរបប លន់ នល់ ស្និទ្ធិនឹងអាមេរិក។ នៅតំបន់រំដោះ សាលារៀនទាំងអស់ត្រូវបិទទ្វារ ម្យ៉ាងដោយខ្លាចសង្គ្រាម ខ្លាចការទម្លាក់គ្រាប់បែករបស់អាមេរិក តែម្យ៉ាងទៀត ក៏ចេញមកពីអំពើល្ងង់ខ្លៅរបស់អ្នកកាន់អំណាចក្នុងដំបន់រំដោះនាពេលនោះដែរ។ ក្នុងពេលដែលនៅតំបន់រំដោះនាប្រទេសវៀតណាម ប្រទេសឡាវ គេខិតខំបង្រៀនកូនចៅរបស់គេទាំងនៅក្នុងលេណដ្ឋាន ទាំងនៅក្នុងកន្លែងលាក់ខ្លួន ក្នុងព្រៃដ៏ស្ងាត់ជ្រងំ ឯតំបន់រំដោះកម្ពុជាដែលមានភាពអនុគ្រោះច្រើនជាង បែរជាបិទអស់នូវសាលារៀន។ សិស្ស សាស្ត្រាចារ្យ គ្រូបង្រៀនមួយចំនួនរត់មកទីក្រុងនាតំបន់ដែល លន់ នល់ កាន់កាប់ដែលក្នុងនោះមួយចំនួនក៏បានចូលរៀនបន្ត មួយចំនួនក៏អត់ ហើយបង្ខំចិត្តត្រូវចូលធ្វើទាហាន ឬក៏រកការធ្វើ។ ឯគ្រូបង្រៀនសាស្ត្រាចារ្យ ក៏ដូចគ្នាមានចំនួនតិចទេ ដែលបានចូលមកបង្រៀន ឯមួយចំនួនធំគ្មានសាលារៀន គ្មានថ្នាក់បង្រៀន។ ដើម្បីរស់ គេត្រូវបង្ខំចិត្តចូលធ្វើទាហាន ដែលជាឱកាសដ៏ល្អសំរាប់ពួក លន់ នល់ ប្រមូលកម្លាំង។ ចំណែកឯសិស្ស និងបុគ្គលិកសិក្សា ដែលសុខចិត្តរស់នៅដំបន់រំដោះ ក៏ត្រូវបោះបង់ចោលការរៀន និងការបង្រៀនតែម្តង។ កុមារកុមារី ដែលដល់អាយុត្រូវចូលរៀនហើយមិនបានរៀន ចេះតែកើនឡើង បន្ថែមពីលើអនក្ខរជនបន្សល់ទុកពីពេលមុនទៀតនោះ ក៏កាន់តែធ្វើអោយចំនួនអ្នកមិនចេះអក្សរកើនច្រើនឡើងៗ។

យើងមិនបដិសេធនូវភាពក្លាហានរបស់ប្រធានភូមិ ឬគ្រូបង្រៀននៅកន្លែងខ្លះ នាតំបន់រំដោះពេលនោះ ដែលចង់អោយកូនចៅចេះដឹងបានឆ្លៀតបង្រៀនកូនចៅនាពេលយប់ ក្រោមគ្រោះថ្នាក់នៃគ្រាប់បែក

របស់អាមេរិក ហើយឪពុក និងបងៗ ខ្លះ បានបង្រៀនកូន ប្អូន នៅតាមផ្ទះ តាមវាលស្រែ ប៉ុន្តែចំនួននេះក៏មានតិចតួច ហើយគុណភាពក៏ទាបដែរ។

សង្គ្រាមអូសបន្លាយជាង ៥ ឆ្នាំ បានបន្សល់ទុកនូវអនក្ខរជន ទាំងចាស់ទាំងថ្មី នៅតំបន់រំដោះយ៉ាងច្រើន។ នៅឯទីក្រុង ថ្វីត្បិតតែមានសាលារៀន ប៉ុន្តែក៏មិនអាចស្រូបយកអស់នូវចំនួនក្មេង ដែលស្ថិតក្នុងវ័យសិក្សាដែរទេ។ នេះ គឺជាទំនោរឈានទៅរកការចុះខ្សោយនៃប្រទេសជាតិមួយរួចស្រេចទៅហើយ ប៉ុន្តែធ្ងន់ធ្ងរជាងនេះទៀត ក្រោយថ្ងៃដែលពួក ប៉ុល ពត ដណ្តើមបានអំណាច ទូទាំងកម្ពុជា គឺគ្មានការសិក្សាទេ ពោលគឺសាលារៀនក្នុងគ្រប់កំរិតសិក្សា ទាំងឧត្តមសិក្សា ទាំងសិក្សាឯកទេសត្រូវបិទទ្វារ ហើយបានក្លាយជាបណ្តើរៗ ទៅជាមន្ទីឃុំឃាំង ជាឃ្លាំង ជាកន្លែងបាយរួម ឬក៏ត្រូវរុះរើចោល។ សិស្ស និស្សិត បុគ្គលិកសិក្សា មិនត្រឹមតែត្រូវបង្ខំអោយបោះបង់ចោលសាលាប៉ុណ្ណោះទេ តែគេត្រូវស្ថិតជាមុខសញ្ញា ដែលអង្គការ ប៉ុល ពត ត្រូវកំទេចចោលទៀតផង។

រយៈពេលជិត ៤ ឆ្នាំនៃ គ្មានការរៀនសូត្រទូទាំងប្រទេស និងជាង ៥ ឆ្នាំ នៃ គ្មានការរៀនសូត្រនៅដំបន់រំដោះ បានធ្វើអោយអនក្ខរជនទាំងចាស់ទាំងក្មេង កើនឡើងយ៉ាងច្រើន។ បន្ថែមពីលើការកាប់សម្លាប់ចំពោះអ្នកចេះដឹងអស់យ៉ាងច្រើនទៀតនោះ ថ្វីត្បិតតែប្រទេសយើងបានរំដោះ ប៉ុន្តែនាគ្រាដំបូង គឺប្រៀបដូចជាមនុស្សហូរឈាមជិតអស់ពីខ្លួន ហើយបញ្ញាញាណរបស់ជាតិ ក៏ត្រូវបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដែរ។

ក្រោយពេលរំដោះ មូលដ្ឋានសម្ភារៈសំរាប់បំរើអោយការសិក្សាដូចជាសាលារៀន គឺនៅសេសសល់មួយចំនួនធំ ប៉ុន្តែត្រូវធ្វើការជួសជុល

ទើបអាចដំណើរការបាន ឯចំណែកក្បួនខ្នាត និងសម្ភារៈសំរាប់រៀន និងបង្រៀន ក៏ដូចជាសាលារៀនដែរ គឺត្រូវបំផ្លិចបំផ្លាញស្ទើរទាំងស្រុង។ ក្នុងសភាពការណ៍បែបនេះ ពេលមើលឃើញពីការរីកចំរើននៃប្រទេសជាតិយើងកាន់តែមានមោទនភាពចំពោះកម្លាំងរស់របស់ជាតិ ចំពោះទឹកចិត្តស្នេហាជាតិរបស់បញ្ញាវ័ន្តយើង ដែលនៅសេសសល់ពីការស្លាប់។

ការរៀនសូត្របានចាប់ផ្តើមភ្លាម ដោយមិនរង់ចាំបវេសនកាល។ នេះគឺការប្រមែប្រមូលគ្រូ និងសិស្ស ដើម្បីចាត់តាំងបើកថ្នាក់រៀនរំលឹកឡើងវិញ។ រហូតដល់បវេសនកាលឆ្នាំសិក្សា ១៩៧៩-១៩៨០ ដែលជាបវេសនកាលលើកទី ១ ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា យើងមានសិស្សចូលរៀននៅផ្នែកបឋមសិក្សារហូត ៩៤៧.៣០៧ នាក់ មានថ្នាក់រៀនចំនួន ១៧.៧៦១ និងបុគ្គលិកសិក្សាចំនួន ២៥.៥២៦ នាក់។ យើងគួររំលឹកថា ពេលនោះនៅតាមជនបទ ភាគច្រើនត្រូវរៀនក្រោមផ្ទះប្រជាជន រៀនក្រោមដំបូលផ្ទះធ្លាយ។ កុមារកុមារីយើង ត្រូវអង្គុយផ្ទាល់ដី ហើយប្រើប្រាស់ធ្យូងដើម្បីសរសេរ។ ឯជួរគ្រូបង្រៀនទៀតសោតភាគច្រើនខ្វះការចាត់តាំង គេមិនមែនជាគ្រូ តែក្នុងបំណងអោយកូនចៅចេះដឹង គេត្រូវបង្ខំចិត្តធ្វើគ្រូដោយគ្មានយកកម្រៃអ្វីពីរដ្ឋ ឬពីប្រជាជនឡើយ។ នៅឯទីក្រុង ជួរគ្រូបង្រៀន សាស្ត្រាចារ្យ បានប្រមូលផ្តុំជាបន្ទាន់ ហើយដែលភារកិច្ចជាបន្ទាន់នោះដែរ គឺការរៀបចំក្បួនខ្នាតដើម្បីបង្រៀន និងរៀន ព្រមពេលដែលក្បាលម៉ាស៊ីនផ្នែកអប់រំទើបរៀបចំឡើង ហើយពុំទាន់មានស្ថិរភាពផង។ ពីក្រោយថ្ងៃរំដោះ រហូតដល់ពេលបើកបវេសនកាលនាឆ្នាំដំបូង ជួរកម្មាភិបាល បុគ្គលិកក្នុងផ្នែកអប់រំ ត្រូវធ្វើការងារជាច្រើនដូចជា ការរៀបចំឡើងនូវរចនាសម្ព័ន្ធ

*វិស័យអប់រំនៅគ្រប់ថ្នាក់ ការរៀបចំនូវក្បួនខ្នាតដើម្បីអោយគ្រូបង្រៀន និងអោយសិស្សរៀន ការប្រមូលជួរគ្រូបង្រៀន ដើម្បីធ្វើវិក្រឹតការ ផ្នែកគរុកោសល្យ ការរៀបចំជួសជុលឡើងវិញនូវសាលារៀន និងមូលដ្ឋានសម្ភារៈផ្សេងទៀត។ល។ ក្នុងពេលដែលសភាពការណ៍របស់ប្រទេសជាតិកំពុងប្រឈមមុខទល់នឹងការលំបាកយ៉ាងខ្លាំង ហើយធំៗ ទៀតផង។ យើងអាចកំណត់បានថា ក្នុងអាជីពរបស់សាស្ត្រាចារ្យ និងគ្រូបង្រៀន គេមិនដែលជួបប្រទះនូវកិច្ចការដ៏លំបាកបែបនេះទេ ប៉ុន្តែ នេះជាមោទនភាពដ៏ឧត្តុង្គឧត្តមសំរាប់អ្នកទាំងឡាយ ដែលបានចូលរួមក្នុងការងារនាគ្រាដំបូងនេះ។ គេបានប្រើប្រាស់ការចេះដឹង ដែលគេមានព្រមទាំងកម្លាំងកាយ កម្លាំងចិត្ត ដើម្បីបង្កើតឡើងនូវមូលដ្ឋានដ៏រឹងមាំមួយ សំរាប់ការរីកចំរើននៃវិស័យអប់រំរយៈពេល ១០ ឆ្នាំកន្លងមក និងទៅពេលអនាគត។*

*ផ្អែកលើការបូកសរុប ១០ ឆ្នាំ របស់ក្រសួងអប់រំ យើងសូមដកស្រង់នូវតួលេខខ្លះ ដើម្បីបង្ហាញពីការរីកចំរើននៃវិស័យអប់រំ៖*

*ក. ផ្នែកមត្តេយ្យសិក្សា*

- *ឆ្នាំ ១៩៧៩-១៩៨០ មានសាលា ៩៦ ថ្នាក់ ២៣០ សិស្ស ៨.២២៩ នាក់ គ្រូ ២៦៧ នាក់។*
- *ឆ្នាំ ១៩៨០-១៩៨១ មានសាលា ១៤៩ ថ្នាក់ ៤៤៦ សិស្ស ១៥.០៧៧ នាក់ គ្រូ ៦៣០ នាក់។*
- *ឆ្នាំ ១៩៨១-១៩៨២ មានសាលា ២៣៣ ថ្នាក់ ៤៤៨ សិស្ស ១៦.៥៧៩ នាក់ គ្រូ ៨១៨ នាក់។*
- *ឆ្នាំ ១៩៨២-១៩៨៣ មានសាលា ៣៧១ ថ្នាក់ ៨២៣ សិស្ស*

២៣.៧៩៧ នាក់ គ្រូ ៩៥៦ នាក់។

- ឆ្នាំ ១៩៨៣-១៩៨៤ មានសាលា ៥០០ ថ្នាក់ ១.១២៨ សិស្ស ៣៥.៤៦៦ នាក់ គ្រូ ១.៤៩៣ នាក់។
- ឆ្នាំ ១៩៨៤-១៩៨៥ មានសាលា ៥៤១ ថ្នាក់ ១៤២០ សិស្ស ៣៩.៩២០ នាក់ គ្រូ ១.៨៣៥ នាក់។
- ឆ្នាំ ១៩៨៥-១៩៨៦ មានសាលា ៥៤១ ថ្នាក់ ១.៥៥៧ សិស្ស ៥៦.១៦៥ នាក់ គ្រូ ២.៣៩៨ នាក់។
- ឆ្នាំ ១៩៨៦-១៩៨៧ មានសាលា ៥៥១ ថ្នាក់ ១.៨៦៤ សិស្ស ៥៥.៧៦០ នាក់ គ្រូ ២.៦២៥ នាក់។
- ឆ្នាំ ១៩៨៧-១៩៨៨ មានសាលា ៥៦០ ថ្នាក់ ២.០៥៩ សិស្ស ៥៩.៦៧៩ នាក់ គ្រូ ២.៨៩៧ នាក់។

ចំនួនសាលា ចំនួនថ្នាក់ សិស្ស និងគ្រូ ដែលមានការកើនឡើងជាលំដាប់ បានបង្ហាញអោយឃើញថា អង្គការបក្ស រដ្ឋ និងអង្គការសង្គមនៅគ្រប់លំដាប់ថ្នាក់ បានយកចិត្តទុកដាក់ពង្រីក និងពង្រឹងនូវការងារមត្តេយ្យសិក្សា ថ្វីត្បិតតែចំនួនកុមារដែលចូលមត្តេយសាលា នៅមានចំនួនតិចនៅឡើយ បើប្រៀបធៀបជាមួយចំនួនកុមារ ដែលមានក្នុងទូទាំងប្រទេស ប៉ុន្តែ នេះគឺជាលើកដំបូងហើយក្នុងប្រវត្តិសាស្ត្រប្រទេសយើង ដែលមានសាលាមត្តេយ្យ និងកុមារចូលមត្តេយ្យសាលាយ៉ាងច្រើននេះ។ ឆ្លងតាមសកម្មភាពរបស់មត្តេយសិក្សា យើងបានរំដោះការលំបាករបស់មាតាបិតា ក្នុងការថែទាំកូនក្នុងពេលម៉ោងធ្វើការ ហើយប្រការសំខាន់ជាងនេះទៀត គឺមត្តេយ្យសិក្សាជាកន្លែងប្រមូលផ្តុំអប់រំចរិត មារយាទកុមារ ព្រមទាំងចំណេះដឹងខ្លះនាគ្រាដំបូង ដើម្បីឈានទៅចូលរៀននៅ

*សាលាបឋមសិក្សា។*

*ខ. ផ្នែកបឋមសិក្សា*

- *ឆ្នាំ ១៩៧៩-១៩៨០ សាលារៀនមាន ៥.២៩០ ថ្នាក់ ១៧.៧៦១ សិស្ស ៩៤៧.៣០៧ នាក់ គ្រូ ២៥.៥២៦ នាក់ សិស្ស បានប្រឡងជាប់វិញ្ញាបនប័ត្របឋមសិក្សាមានចំនួន ៦.៤៨១ នាក់។*
- *ឆ្នាំ ១៩៨០-១៩៨១ សាលាមាន ៤.៤៨៤ ថ្នាក់ ២៥.៥២៦ សិស្ស ១.៣២៨.០៥៣ នាក់ គ្រូ ៣០.៣១៦ នាក់ សិស្សប្រឡងជាប់ ១៩.៨៨៥ នាក់។*
- *ឆ្នាំ ១៩៨១-១៩៨២ សាលាមាន ៣.៥២១ ថ្នាក់ ៣១.៨០៤ សិស្ស ១.៥៣៨.៨៣៨ នាក់ គ្រូ ៣១.៨៨៤ នាក់ សិស្សប្រឡងជាប់ ៥០.៨០១ នាក់។*
- *ឆ្នាំ ១៩៨២-១៩៨៣ សាលាមាន ៣.១១៤ ថ្នាក់ ៣៣.៧៤០ សិស្ស ១.៥៩៧.០៨១ នាក់ គ្រូ ៣២.៨៥៩ នាក់ សិស្សប្រឡងជាប់ ៩៦.២២៧ នាក់។*
- *ឆ្នាំ ១៩៨៣-១៩៨៤ សាលាមាន ៣.០០៥ ថ្នាក់ ៣៣.២៨៧ សិស្ស ១.៥០៤.៨៣៩ នាក់ គ្រូ ៣៦.៥២០ នាក់ សិស្សប្រឡងជាប់ ១២១.៤៨៤ នាក់។*
- *ឆ្នាំ ១៩៨៤-១៩៨៥ សាលាមាន ៣.១៣៣ ថ្នាក់ ៣៣.៣៤៥ សិស្ស ១.៣៦៧.០៨៩ នាក់ គ្រូ ៣៥.៦៦៥ នាក់ សិស្សប្រឡងជាប់ ១២៩.៩០៨ នាក់។*
- *ឆ្នាំ ១៩៨៥-១៩៨៦ សាលាមាន ៤.២៩៤ ថ្នាក់ ៣១.០៦២ សិស្ស ១.៣១៥.៥៣១ នាក់ គ្រូ ៣៥.០៨០ នាក់ សិស្សប្រឡងជាប់*

១១៦.០៣២ នាក់។

- ឆ្នាំ ១៩៨៦-១៩៨៧ សាលាមាន ៤.២៨២ ថ្នាក់ ៣០.៩៤៦ សិស្ស ១.២៩៤.២២៧ នាក់ គ្រូ ៣៦.៧៥៤ នាក់ សិស្សប្រឡងជាប់ ១០៩.៦១០ នាក់។
- ឆ្នាំ ១៩៨៧-១៩៨៨ សាលាមាន ៤.៧៨០ ថ្នាក់ ៣០.៨៩០ សិស្ស ១.២៧៩.០៥៣ នាក់ គ្រូ ៣៧.២៩២ នាក់ សិស្សប្រឡងជាប់ ៩៦.៦០០ នាក់។

ប្រសិនបើពិនិត្យអំពី ការថយចុះនៃចំនួនសាលាបឋមសិក្សានាប៉ុន្មានឆ្នាំដំបូងនេះ គឺអាចនឹងមានការយល់ច្រឡំខុះពីសំណាក់ជនបរទេសនិងជនកម្ពុជានៅបរទេស។ យើងសូមបញ្ជាក់ថា ចំនួនសាលាបឋមសិក្សា មានការថយចុះក្នុងចន្លោះឆ្នាំសិក្សា ១៩៨០-១៩៨១ និងតមកបើប្រៀបធៀបនឹងចំនួនសាលា ក្នុងឆ្នាំ ១៩៧៩-១៩៨០ ប៉ុន្តែចំនួនថ្នាក់រៀនពុំមានការថយចុះទេ ផ្ទុយទៅវិញគឺថែមទាំងកើនចំនួនទៀតផងរៀរលែងតែ ២ ឆ្នាំចុងក្រោយនេះ ដែលចំនួនសិស្សបឋមសិក្សាមានការថយចុះដែរ។ ការថយចុះនៃចំនួនសាលាបឋមសិក្សានេះ គឺបណ្តាលមកពីបញ្ហាមួយចំនួនដូចជា ការបើកបង្រៀនថ្នាក់បឋមសិក្សាលើកដំបូងចំទៅលើទីតាំងសាលាមធ្យមសិក្សា ដែលប៉ុន្មានឆ្នាំក្រោយមកសាលាមួយចំនួននេះត្រូវក្លាយទៅជាសាលាមធ្យមសិក្សាវិញ និងការបើកបង្រៀនក្រោមផ្ទះប្រជាជន ក្នុងកុដិព្រះសង្ឃ ក្នុងពេលរង់ចាំកសាង ឬជួសជុលសាលារៀនហើយ ហើយការប្រមូលផ្តុំសាលាតូចៗមកដាក់នៅសាលារៀបរយវិញ ជាកត្តាធ្វើអោយចំនួនសាលាថយចុះក៏ប៉ុន្តែ ចំនួនថ្នាក់រៀនគឺកើនឡើងទៅវិញ។ ម្យ៉ាងទៀត ការថយចុះនៃ

*ចំនួនសិស្សបឋមសិក្សា ចាប់តាំងពីឆ្នាំសិក្សា ១៩៨៣-១៩៨៤ តរៀងមក មិនមែនមកពីបញ្ហានយោបាយនោះឡើយ នោះគឺការថយចុះដើម្បីមកបង្កើននៅមធ្យមសិក្សាវិញ ហើយហេតុផលសំខាន់មួយទៀតគឺក្មេងចូលរៀនបានត្រឹមត្រូវតាមអាយុដែលខុសនឹងគ្រាមុនៗ ក្មេងដែលមិនបានរៀននៅក្នុងពេលមានសង្គ្រាម និងក្នុងរបប ប៉ុល ពត ទោះបីលើសអាយុក៏ដោយ ក៏ត្រូវចូលរៀននៅបឋមសិក្សា ដែលជាហេតុធ្វើអោយនៅសាលាបឋមសិក្សា មានចំនួនសិស្សយ៉ាងច្រើនៗ*

*តាមតួលេខដែលបញ្ជាក់ខាងលើ យើងអាចប៉ាន់ស្មានបានថា កុមារដែលដល់វ័យសិក្សា បានចូលរៀនចំនួន ៨០ ភាគរយហើយ ហើយតួលេខនេះ ត្រូវបានបែងចែកជាពីរតំបន់ គឺនៅតំបន់វាលរាប កុមារដល់វ័យសិក្សាបានចូលរៀនចំនួន ៨៥ ភាគរយ ឯនៅតំបន់ព្រៃភ្នំ គឺមាន ៥៥ ទៅ ៦៥ ភាគរយៗ*

*តាមការស្រាវជ្រាវរបស់ក្រសួងអប់រំ ការប្រៀបធៀបចំនួនសិស្សបឋមសិក្សាដែលមានក្នុងពេលបច្ចុប្បន្ន ឃើញថាមានចំនួនលើសសិស្សនៃឆ្នាំសិក្សា ១៩៦៩-១៩៧០ រហូតដល់ទៅ ៤៥២.៨៦៨ នាក់ៗ*

*គ. ផ្នែកមធ្យមសិក្សាកំរិត ១*

- *ឆ្នាំ ១៩៧៩-១៩៨០ សាលាមាន ១៤ ថ្នាក់រៀនមាន ១០១ សិស្ស ៤.៨០៣ នាក់ គ្រូ ២០៦ នាក់ សិស្សប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ចំនួន ៣១៥ នាក់ៗ*
- *ឆ្នាំ ១៩៨០-១៩៨១ សាលាមាន ៦៦ ថ្នាក់ ៣៨២ សិស្ស ១៧.៣៣១ នាក់ គ្រូ ៦៧១ នាក់ សិស្សប្រឡងជាប់សញ្ញាប័ត្រ ១.១៦៦ នាក់ៗ*

- ឆ្នាំ ១៩៨១-១៩៨២ សាលាមាន ១០៨ ថ្នាក់ ៩៣០ សិស្ស ៣៩.៥១៥ នាក់ គ្រូ ១.៥៨៦ នាក់ សិស្សប្រឡងជាប់សញ្ញាប័ត្រ ២.៧២៤ នាក់។
- ឆ្នាំ ១៩៨២-១៩៨៣ សាលាមាន ១៧៣ ថ្នាក់ ១.៩៤៩ សិស្ស ៨៧.០០៣ នាក់ គ្រូ ៣.៣០០ នាក់ សិស្សប្រឡងជាប់សញ្ញាប័ត្រ ៨.៣០៣ នាក់។
- ឆ្នាំ ១៩៨៣-១៩៨៤ សាលាមាន ២០០ ថ្នាក់ ៣.០៥២ សិស្ស ១៤៥.៧២៦ នាក់ គ្រូ ៤.៤៩៤ នាក់ សិស្សប្រឡងជាប់សញ្ញាប័ត្រ ១៦.៧១៥ នាក់។
- ឆ្នាំ ១៩៨៤-១៩៨៥ សាលាមាន ២២២ ថ្នាក់ ៤.៦៩៨ សិស្ស ២៣៤.៩២៧ នាក់ គ្រូ ៦.១១៦ នាក់ សិស្សប្រឡងជាប់សញ្ញាប័ត្រ ៣១.១៧៥ នាក់។
- ឆ្នាំ ១៩៨៥-១៩៨៦ សាលាមាន ២៧៨ ថ្នាក់ ៥.៧៣០ សិស្ស ២៩៧.៧៨៨ នាក់ គ្រូ ៧.៤១៦ នាក់ សិស្សប្រឡងជាប់សញ្ញាប័ត្រ ៤៧.៣៨២ នាក់។
- ឆ្នាំ ១៩៨៦-១៩៨៧ សាលាមាន ៣០៤ ថ្នាក់ ៦.២៦២ សិស្ស ៣២៧.០៤៩ នាក់ គ្រូ ៨.៩៦៧ នាក់ សិស្សប្រឡងជាប់សញ្ញាប័ត្រ ៥៧.៥៥៣ នាក់។
- ឆ្នាំ ១៩៨៧-១៩៨៨ សាលាមាន ៣៣៧ ថ្នាក់ ៦.៥៣៨ សិស្ស ៣២៦.៤០៣ នាក់ គ្រូ ១០.៨៨២ នាក់ សិស្សប្រឡងជាប់សញ្ញាប័ត្រ ៦៣.៥២២ នាក់។

ពិនិត្យលើអត្រាកំណើន ដែលវាជាកម្លាំងសង្កត់ពីបឋមសិក្សាមក គឺ

តម្រូវអោយយើងរៀបចំលក្ខខណ្ឌចាំបាច់ សំរាប់ទទួលចូលរៀននៅសាលាមធ្យមសិក្សាកំរិត ១។ ពីឆ្នាំសិក្សាមួយទៅឆ្នាំសិក្សាមួយទៀត សិស្សត្រូវកើនស្មើរទ្វេមួយជាពីរ ដែលត្រូវទាមទារនូវទុនដ៏ធំសំរាប់ការកសាងសាលារៀន បង្កើនថ្នាក់រៀន បណ្តុះបណ្តាលគ្រូ និងសម្ភារៈចាំបាច់ផ្សេងទៀត សំរាប់ការបង្រៀន និងរៀន។ ម្យ៉ាងទៀតយើងក៏ត្រូវដាក់សិស្ស តាមថ្នាក់រៀននីមួយៗ ច្រើនហួសកំរិត ទើបស្រូបយកអស់សិស្ស ដែលបានបញ្ចាប់បឋមសិក្សា។ បើប្រៀបធៀបចំនួនសិស្ស និងចំនួនសាលា ដែលមានក្នុងឆ្នាំសិក្សា ១៩៨៧-១៩៨៨ ទៅនឹងចំនួនសិស្ស និងចំនួនសាលា នាឆ្នាំសិក្សា ១៩៦៩-១៩៧០ ដែលមានសាលាចំនួន ៩៦ សិស្សចំនួន ៩១.១៤៤ នាក់ ឃើញថាខុសគ្នាឆ្ងាយណាស់។ បើយើងសរុបចំនួនសិស្សប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ដែលមានរហូតដល់ទៅ ២២៨.៨៥៥ នាក់ ដែលវានឹងក្លាយទៅជាកម្លាំងសង្កត់ដ៏ធំចំពោះមធ្យមសិក្សាកំរិត ២ បណ្តាសាលាឯកទេសវិជ្ជាជីវៈ និងបញ្ហាសង្គមផ្សេងទៀតផង ដោយទាមទារត្រូវដោះស្រាយអោយបានសមហេតុសមផលនៅពេលខាងមុខ។

ឃ. មធ្យមសិក្សាកំរិត ២

- ឆ្នាំ ១៩៧៩-១៩៨០ សាលាមាន ១ ថ្នាក់រៀនមាន ៧ សិស្ស ២៨១ នាក់ គ្រូ ២០ នាក់ សិស្សជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ចំនួន ៧២ នាក់។
- ឆ្នាំ ១៩៨០-១៩៨១ សាលាមាន ១ ថ្នាក់ ១៣ សិស្ស ៥៥៥ នាក់ គ្រូ ២៨ នាក់ សិស្សជាប់សញ្ញាប័ត្រ ១០៤ នាក់។
- ឆ្នាំ ១៩៨១-១៩៨២ សាលាមាន ៥ ថ្នាក់ ២៧ សិស្ស ១.៥១៧

នាក់ គ្រូ ៦៥ នាក់ សិស្សជាប់សញ្ញាប័ត្រ ១៥៦ នាក់។

- ឆ្នាំ ១៩៨២-១៩៨៣ សាលាមាន ៧ ថ្នាក់ ៧៣ សិស្ស ៣.៤៩៣ នាក់ គ្រូ ១៥៨ នាក់ សិស្សជាប់សញ្ញាប័ត្រ ១៣៥ នាក់។
- ឆ្នាំ ១៩៨៣-១៩៨៤ សាលាមាន ១៣ ថ្នាក់ ១៤៣ សិស្ស ៦.៧៦៩ នាក់ គ្រូ ២៧១ នាក់ សិស្សជាប់សញ្ញាប័ត្រ ៧៤៩ នាក់។
- ឆ្នាំ ១៩៨៤-១៩៨៥ សាលាមាន ១៩ ថ្នាក់ ២១១ សិស្ស ១០.៨៨៨ នាក់ គ្រូ ៤៦៨ នាក់ សិស្សជាប់សញ្ញាប័ត្រ ១.១៣៣ នាក់។
- ឆ្នាំ ១៩៨៥-១៩៨៦ សាលាមាន ២៨ ថ្នាក់ ២៦៦ សិស្ស ១៤.០២០ នាក់ គ្រូ ៦១៧ នាក់ សិស្សជាប់សញ្ញាប័ត្រ ២.៣៣៧ នាក់។
- ឆ្នាំ ១៩៨៦-១៩៨៧ សាលាមាន ៣៣ ថ្នាក់ ៣៦៤ សិស្ស ១៨.៧៩៩ នាក់ គ្រូ ៨៥៨ នាក់ សិស្សជាប់សញ្ញាប័ត្រ ៣.៥៦៧ នាក់។
- ឆ្នាំ ១៩៨៧-១៩៨៨ សាលាមាន ៤០ ថ្នាក់ ៥២៧ សិស្ស ២៦.១៧៦ នាក់ គ្រូ ១.០៦៤ នាក់ សិស្សជាប់សញ្ញាប័ត្រ ៤.៧៧០ នាក់។

ប្រៀបធៀបរយៈពេលដំបូង ទៅនឹងរយៈពេលចុងក្រោយនេះ ចំនួនសាលា ថ្នាក់ គ្រូ និងសិស្ស មានការកើនឡើងយ៉ាងច្រើន ហើយវាកើនខ្ពស់ជាងឆ្នាំសិក្សា ១៩៦៩-១៩៧០ ទៅទៀត ដែលពេលនោះចំនួនសិស្សមានតែ ១៨.៨៣៨ នាក់ប៉ុណ្ណោះ។ ការពង្រីក មធ្យមសិក្សាកំរិត ២ ត្រូវជួបនឹងចំណោទដ៏ធ្ងន់ធ្ងរ ដែលមុនបង្អស់ គឺខ្វះប្រភពគ្រូ ខ្វះ

មធ្យោបាយចាំបាច់ផ្សេងទៀត ក្នុងពេលដែលសាលាមធ្យមសិក្សាកំរិត ១ បានក្លាយទៅជាកម្លាំងសង្កត់យ៉ាងខ្លាំង។ ដោយឡែក សាលាមធ្យមសិក្សាកំរិត ២ ក៏បានក្លាយទៅជាកម្លាំងសង្កត់សំរាប់ឧត្តមសិក្សា ព្រោះសិស្សប្រឡងជាប់មធ្យមសិក្សាកំរិត ២ កាន់តែច្រើន ក្នុងពេលដែលគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេសទទួលយកមិនអស់។ ហើយនេះ គឺជាទំនាស់ដ៏ស្រួចស្រាលនាពេលខាងមុខ។

ក្រៅពីបណ្ដាភូមិសិក្សា ដែលបានរៀបរាប់ខាងលើ ពិតមែនតែលទ្ធភាពយើងមានកំរិត ប៉ុន្តែបក្ស និងរដ្ឋយើងនៅបានជំរុញការបណ្ដុះបណ្ដាលថ្នាក់ឧត្តមសិក្សា និងសិក្សាឯកទេស ទាំងនៅក្នុង និងក្រៅប្រទេស ដែលបានផ្ដល់អោយយើងនូវជួរកម្មាភិបាល និងអ្នកឯកទេស ដើម្បីការងារកន្លងមក និងទៅអនាគត ដែលជាមូលដ្ឋានដ៏ល្អ សំរាប់ការឈានឡើង។

តាមតួលេខឆ្នាំ ១៩៨៨ អ្នកជាប់សញ្ញាប័ត្រគ្រប់ប្រភេទ ដែលបានបណ្ដុះបណ្ដាលទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស មាន៖

- អ្នកជាប់សញ្ញាប័ត្រកម្មករជំនាញ និងអ្នកឯកទេសកំរិតបឋម ចំនួន ១៣.៣៦៤ នាក់
- អ្នកបច្ចេកទេសក្របខ័ណ្ឌមធ្យម ចំនួន ២២.៩១០ នាក់
- អ្នកជាប់សញ្ញាប័ត្រឧត្តមសិក្សា ចំនួន ៣.៦៩២ នាក់
- អ្នកមានកំរិតក្រោយមហាវិទ្យាល័យ ចំនួន ៣២ នាក់

ព្រមពេលជាមួយគ្នានេះ យើងនៅមានសិស្ស និស្សិត ដែលកំពុងបន្តការសិក្សានៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈចំនួន ២៩ ដែលមាន ៣៧ មុខជំនាញ គ្រឹះស្ថានមធ្យមសិក្សាឯកទេសចំនួន ២៥ ដែលមាន ៥៧ មុខជំនាញ គ្រឹះស្ថានឧត្តមសិក្សាចំនួន ៦ ដែលមាន ៣០

មុខជំនាញ និស្សិតចំនួនសរុប ២២.៧៣៦ នាក់ នៅឆ្នាំសិក្សា ១៩៨៧-១៩៨៨ ព្រមទាំងនិស្សិតរាប់ពាន់នាក់ទៀត ដែលកំពុងសិក្សានៅបរទេស ហើយអ្នកទាំងនេះនឹងបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ និងត្រៀមទទួលយកនូវភារកិច្ចក្នុងការកសាង និងការពារមាតុភូមិនាពេលខាងមុខ។

យើងក៏គួររំលឹកផងដែរថា ក្នុងដំណើរលើកំណាត់ផ្លូវដ៏លំបាកនៃរយៈកាល ១០ ឆ្នាំនេះ ដើម្បីបំពេញសំណូមពរចំពោះមុខ គ្រប់ស្ថាប័ន គ្រប់ខេត្ត ក្រុង សុទ្ធតែបានបើកវគ្គបណ្តុះបណ្តាលនៅនឹងកន្លែងរយៈពេលខ្លី បំប៉នអោយដល់កម្មាភិបាល បុគ្គលិក កម្មករ ដើម្បីផ្តល់នូវចំណេះដឹងចាំបាច់តាមមុខជំនាញដែលត្រូវធ្វើ ហើយដែលការងារនោះបានរួមចំណែកយ៉ាងសំខាន់ដល់ភាពជឿនលឿនរយៈពេលកន្លងមក។

កិច្ចការដ៏ធ្ងន់ធ្ងរមួយទៀតដែលយើងបានធ្វើ ហើយទទួលបានជោគជ័យដ៏ត្រចះត្រចង់ដែរនោះ គឺការលុបបំបាត់គ្រោះមិនចេះអក្សរ និងបំពេញវិជ្ជា។

អនក្ខរភាព គឺជាផលវិបាកដែលសង្គមមុនៗ បានបន្សល់ទុក ហើយដែលបានក្លាយជាកង្វល់របស់បក្ស និងរដ្ឋយើង ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩។ ដូច្នេះហើយបានជាបក្ស និងរដ្ឋយើង យកចិត្តទុកដាក់ យ៉ាងខ្លាំងចំពោះការងារនេះ ដោយបានបើកយុទ្ធនាការធំៗ ព្រមទាំងចេញបទដ្ឋានជាច្រើន ទាក់ទងដល់ការងារលុបបំបាត់គ្រោះមិនចេះអក្សរ។ នាយកដ្ឋានអប់រំមនុស្សចាស់ ចំណុះក្រសួងអប់រំ ក៏ត្រូវបានបង្កើតឡើងជាបន្ទាន់ បំពេញភារកិច្ចជាសេនាធិការ ក្នុងការងារលុបបំបាត់គ្រោះមិនចេះអក្សរ និងការងារបំពេញវិជ្ជា។ ខ្សែរយៈចាត់តាំងផ្នែកអប់រំ

មនុស្សចាស់ ត្រូវបានរៀបចំឡើងតាំងពីមជ្ឈិមរហូតដល់មូលដ្ឋាន។ យើងគួររំលឹកថា បក្ស និងរដ្ឋយើង បានកំណត់យកថ្ងៃ ១៩ មិថុនា ជាទិវាជាតិបំផុសចលនាប្រយុទ្ធនឹងគ្រោះមិនចេះអក្សរ ហើយថ្ងៃ ១៥ ខែវិច្ឆិកា ឆ្នាំ ១៩៧៩ សមមិត្តប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្ត បានចេញនូវសេចក្ដីអំពាវនាវមួយ ស្ដីពីការងារអប់រំមនុស្សចាស់។ ដើម្បីដឹកនាំការងារនេះ យើងបានបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធ នឹងគ្រោះមិនចេះអក្សរ និងបំពេញវិជ្ជា ដែលមានសមមិត្ត ហេង សំរិន ធ្វើជាប្រធាន ហើយគ្រប់ផ្នែក គ្រប់ថ្នាក់ ក៏សុទ្ធតែមានគណៈកម្មាធិការទទួលបន្ទុកការងារនេះដែរ។

ឆ្លងតាមផែនការ ៣ ឆ្នាំ ពីរ លើក ១៩៨០-១៩៨៣ និង ១៩៨៣-១៩៨៦ យើងបានរំដោះផុតពីគ្រោះមិនចេះអក្សរចំនួន ១.០០២.២២៨ នាក់ ត្រូវជា ៩៣,២២ ភាគរយ ហើយមកដល់ថ្ងៃ ១៣ កុម្ភៈ ១៩៨៨ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងគ្រោះមិនចេះអក្សរ និងបំពេញវិជ្ជាបានប្រកាសភាពឆ្លងផុតពីគ្រោះមិនចេះអក្សរនៅទូទាំងប្រទេស។

ដូច្នេះ យើងបានសំរេចកិច្ចការនេះ ក្នុងរយៈពេល ៩ ឆ្នាំ ក្នុងសកម្មភាពបដិវត្តន៍ទូលំទូលាយនៃសង្គមជាតិ ហើយការដែលគួរកត់សំគាល់គឺយុទ្ធនាការពន្លឺវប្បធម៌បដិវត្តក្នុងជួរយុវជន យុទ្ធនាការពន្លឺវប្បធម៌នារីបដិវត្តកម្ពុជា យុទ្ធនាការពន្លឺវប្បធម៌កម្មករបដិវត្តកម្ពុជា និងយុទ្ធនាការពន្លឺវប្បធម៌កងទ័ពបដិវត្តកម្ពុជា បន្ថែមទៅដោយចលនាដ៏សកម្មរបស់បណ្ដាផ្នែក បណ្ដាថ្នាក់ និងប្រជាជនក្នុងទូទាំងប្រទេស។ ឆ្លងតាមយុទ្ធនាការ និងចលនាទាំងនេះ មនុស្សមិនចេះអក្សរទាំងអស់ ត្រូវជាប់ក្នុងកាតព្វកិច្ចរៀនសូត្រ ហាក់ដូចជាជាប់បំណុលមួយ ដែលគេត្រូវតែ

សង់ដោយខានមិនបាន។

មនុស្សមួយចំនួនអាចលើកឡើងថា នេះជាការបង្ខិតបង្ខំ។ និយាយយ៉ាងនេះ ក៏ជាការត្រឹមត្រូវម្យ៉ាងដែរ ប៉ុន្តែ ការបង្ខិតបង្ខំនេះ វាជាការចាំបាច់ដើម្បីភាពរឹងមាំរបស់ប្រទេសជាតិ សុភមង្គលក្នុងគ្រួសារនីមួយៗ ហើយយើងក៏មិនអាចអូសបន្លាយភាពងងឹតងងល់របស់ប្រជាជនយើងបានតទៅទៀតឡើយ។

ដើរទន្ទឹមជាមួយនឹងការងារលុបបំបាត់គ្រោះមិនចេះអក្សរ ការងារបំពេញវិជ្ជា ក៏ជាការកិច្ចចាំបាច់ និងបន្ទាន់ដែរ។ បើមិនដូច្នេះទេ យើងមិនគ្រាន់តែមិនបានលើកកំពស់សមត្ថភាពកម្មាភិបាល ដែលកំពុងធ្វើការសព្វថ្ងៃបានប៉ុណ្ណោះទេ ប៉ុន្តែយើងនឹងធ្លាក់ទៅក្នុងគ្រោះថ្នាក់មួយទៀត ដែលហៅថា គ្រោះភ្លេចអក្សរសំរាប់អ្នកដែលទើបបានធ្វងផុតពីគ្រោះមិនចេះអក្សរហើយ។ ដូចនេះហើយបានជាភាគច្រើននៃបទដ្ឋានទាក់ទងដល់ការបំបាត់គ្រោះមិនចេះអក្សរ គឺសុទ្ធតែបាននិយាយដល់ការបំពេញវិជ្ជា។ យើងបានចាត់តាំងសាលា និងថ្នាក់រៀនតាមច្រើនរូបភាព អាស្រ័យតាមលក្ខណសម្បត្តិនៃកន្លែងនីមួយៗ ហើយជាបណ្តើរៗ យើងបានពង្រីកគ្រប់កំរិតសិក្សា ដែលកាលពីឆ្នាំសិក្សា ១៩៨០-១៩៨១ យើងមានត្រឹមកំរិតសិក្សាទី ១ ប៉ុណ្ណោះ។

តាមស្ថិតិ ១៩៨៨ ដែលបានផ្តល់ដោយក្រសួងអប់រំ យើងមានសាលារៀនបំពេញវិជ្ជារៀបរយមួយនៅមជ្ឈិម (ភ្នំពេញ) មួយនៅស្ទឹងត្រែង ដែលជាសាលាបំពេញវិជ្ជារៀបរយភូមិភាគឥសាន សំរាប់ខេត្តស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រះវិហារ ព្រមទាំងសាលាបំពេញវិជ្ជារៀបរយខេត្ត ក្រុង ចំនួន ១៧ និងនៅក្រសួងការពារប្រទេសចំនួន ២៥

ទៀត។ ដោយឡែកខេត្តពោធិសាត់ បានបើកសាលាបំពេញវិជ្ជារៀបរយនៅតាមស្រុកទាំង ៤ ក្នុងខេត្ត។ ក្រៅពីនេះ យើងមានសាលារៀនបំពេញវិជ្ជាពាក់កណ្ដាលរៀបរយចំនួន ៤៥ និងសាលាបំពេញវិជ្ជាក្រៅម៉ោងធ្វើការចំនួន ១១៣ ថែមទៀត។

សិស្សបំពេញវិជ្ជា ដែលបានប្រឡងជាប់រយៈពេល ៨ ឆ្នាំកន្លងមកមាន៖

- ជាប់វិញ្ញាបនប័ត្របំពេញវិជ្ជាកំរិតសិក្សាទី ១ ចំនួន ១៦.០០៦ នាក់
- ជាប់សញ្ញាប័ត្របំពេញវិជ្ជាកំរិតសិក្សាទី ២ ចំនួន ១៣.៧៧៦ នាក់
- ជាប់សញ្ញាប័ត្របំពេញវិជ្ជាកំរិតសិក្សាទី ៣ ចំនួន ១.៧៣៥ នាក់

ទន្ទឹមនេះ យើងមានសិស្សដែលកំពុងបន្តរៀនក្នុងសាលាបំពេញវិជ្ជានៅកំរិតសិក្សាទាំង ៣ ចំនួន ១៨៣.៩៩៤ នាក់ (តួលេខឆ្នាំសិក្សា ១៩៨៧-១៩៨៨) ដែលអាចមានការផ្លាស់ប្ដូរទៀត ក្នុងឆ្នាំសិក្សា ១៩៨៨-១៩៨៩។ ការងារបំពេញវិជ្ជា បានជួយអោយយើងដោះស្រាយបាននូវការងារលើកកំពស់សមត្ថភាពកម្មាភិបាល ព្រោះថាម្យ៉ាងកម្មាភិបាលយើងមួយចំនួន អាស្រ័យដោយត្រូវធ្វើការតស៊ូប្រឆាំងខ្មាំងសត្រូវអស់រយៈពេលដ៏យូរ គឺរៀនសូត្រផ្នែកវប្បធម៌បានតិច ដែលចាំបាច់ត្រូវបំពេញបន្ថែម ម្យ៉ាងទៀត ក្នុងជួរកងទ័ព ដែលភាគច្រើនជាកូនកសិករ ហើយដែលបានឆ្លងកាត់សង្គ្រាមច្រើនជាងការរៀនសូត្រនោះ ក៏ត្រូវបង្កើនចំណេះដឹង ដើម្បីបន្តការងារដែរ។

ពិនិត្យលើលទ្ធផលនៃការងារអប់រំបណ្ដុះបណ្ដាលរយៈពេល ១០ ឆ្នាំកន្លងមក យើងអាចសន្និដ្ឋានបានថា វិស័យនេះបានឈានទៅជួរទី ១ ក្នុងជំហានឈានឡើងរបស់ខ្លួន ហើយជាផ្នែកដែលស្រូបបានការយក

ចិត្តទុកដាក់ និងការចូលរួមពីគ្រប់មជ្ឈដ្ឋាន គ្រប់ស្រទាប់ប្រជាជនក្នុងសង្គមជាតិ ពោលគឺវាបានក្លាយទៅជាចលនាបដិវត្តរបស់មហាជនដ៏ទូលំទូលាយ ហើយខ្លាំងក្លាទៀតផង។

ក្នុងពេលឃើញការរីកចំរើននេះ យើងមិនភ្លេចនឹងលើកឡើងនូវការលំបាក និងបញ្ហាសេសសល់ ដែលយើងត្រូវដោះស្រាយនោះទេ។ គុណភាពនៃការសិក្សា គឺជាចំណោទដ៏ធំមួយរបស់យើង ហើយបញ្ហាជួរគ្រូបង្រៀន វាទាក់ទងសំខាន់ទៅនឹងបញ្ហានេះ។ ក្រោយពេលរំដោះបុគ្គលិកសិក្សាដែលនៅសេសសល់ពីការកាប់សម្លាប់របស់ ប៉ុល ពត ពុំមានតុល្យភាពជាមួយនឹងចំនួនសិស្សដែលត្រូវរៀនទេ គឺចំនួនសិស្សមានសន្ទឹកសន្ទាប់ អាស្រ័យដោយក្មេងមិនបានរៀនពេលសង្គ្រាម និងក្នុងរបប ប៉ុល ពត ក៏ត្រូវចូលរៀនដែរ ក្នុងពេលដែលជួរគ្រូបង្រៀន និងថ្នាក់រៀនមានតិច។ ដើម្បីស្រូបយកអោយអស់នូវសិស្សដែលត្រូវរៀនថ្នាក់ទីមួយ។ ត្រូវដាក់សិស្សលើសពីការកំណត់របស់ផ្នែកគរុកោសល្យ។ ឯជួរគ្រូបង្រៀនទៀតសោត ក៏ត្រូវជ្រើសរើសពីចំណោមអ្នកមិនមែនគ្រូបង្រៀន។ នៅទីក្រុង បញ្ហានេះមិនចោទធំដុំទេ ប៉ុន្តែនៅជនបទបានកើតមានជាទូទៅ ដូច្នេះគ្រូជាច្រើនមិនទាន់ធ្លាប់មានបទពិសោធន៍ ក្នុងការបង្រៀន ហើយមានកន្លែងខ្លះ គ្រូមានចំណេះលើសសិស្សតែ ២ ឬ ៣ ថ្នាក់ប៉ុណ្ណោះ។ យើងគួរធ្វើការប្រៀបធៀបពីភាពខុសគ្នា រវាងរបបយើងជាមួយរបប សីហនុ មុនពេលមានសង្គ្រាម។ មុនឆ្នាំ ១៩៧០ ពេលនោះជួរគ្រូបង្រៀន សាស្ត្រាចារ្យមានចំនួនច្រើន ហើយសាលារៀនក៏មានចំនួនច្រើនបង្គួរដែរ ប៉ុន្តែសិស្ស និស្សិត ពេលនោះមានមិនដល់ ១ លាននាក់ទេ។ មកដល់របបយើង ជួរគ្រូបង្រៀន សាស្ត្រាចារ្យ

នៅសល់តិច ហើយមួយចំនួនក៏ត្រូវចូលបំរើការងារនៅតាមស្ថាប័នផ្សេងខុសមុខជំនាញទៀត ឯសាលាទៀតសោត ក៏ត្រូវខូចខាតអស់យ៉ាងច្រើន ប៉ុន្តែសិស្ស និស្សិត បានកើនយ៉ាងច្រើន ដូចមានបញ្ជាក់ក្នុងតួលេខខាងលើស្រាប់។

ការងារដោះស្រាយជួរគ្រូបង្រៀន នៅតែជាចំណោទនៅឡើយ។ ពិតមែនតែរដ្ឋបានខិតខំលើកទឹកចិត្តចំពោះជួរគ្រូបង្រៀន ប៉ុន្តែជាទូទៅយុវជនមួយចំនួនធំហាក់ដូចជាមិនសូវចូលចិត្តធ្វើគ្រូ គួបផ្សំនឹងគោលនយោបាយជានាជីវភាពគ្រូបង្រៀនមិនទាន់បានល្អផងនោះ ធ្វើអោយចំនួនគ្រូមានការកើនឡើងយឺត រត់មិនទាន់ការកើនឡើងនៃចំនួនសិស្ស។ ឯគ្រូដែលបណ្តុះបណ្តាលបានហើយ ក៏មិនសូវចូលចិត្តទៅបង្រៀននៅមូលដ្ឋាន ហើយនៅឯមូលដ្ឋានទៀត ក៏ត្រូវការយកគ្រូបង្រៀនទៅកាន់ការងារដឹកនាំផ្នែករដ្ឋអំណាច ឬមុខជំនាញផ្សេងទៀត ដែលកាន់តែធ្វើអោយខ្វះខាតជួរគ្រូបង្រៀន និងអ្នកដឹកនាំផ្នែកអប់រំនៅមូលដ្ឋានថែមទៀត។

ចំពោះការដោះស្រាយសាលារៀន ប៉ុន្មានឆ្នាំកន្លងមកនេះ មានចលនាដ៏ទូលំទូលាយ ទាំងប្រជាជននៅក្នុងប្រទេស ទាំងជនកម្ពុជានៅឯបរទេស។ តាមរយៈនៃកម្លាំងផ្ទាល់របស់ប្រជាជន ឬការរួមចំណែករបស់ប្រជាជន សាលារៀន ពិសេសបឋមសិក្សា និងមធ្យមសិក្សាកំរិតទី ១ មានការរីកចំរើនយ៉ាងច្រើន។ យើងមិនភ្លេចនឹងលើកឡើង អំពីតួនាទីរបស់ព្រះសង្ឃ អាចារ្យវត្ត ចាស់ព្រឹទ្ធាចារ្យនៅតាមភូមិ ឃុំ ដែលបានដើរតួយ៉ាងសំខាន់ ក្នុងចលនាប្រជាជនចូលរួមវិភាគទានកសាងឡើងនូវសាលារៀន សំរាប់កូនចៅជំនាន់ក្រោយនៃយើង។ បុណ្យផ្កា

កឋិនទាន ឬពិធីបុណ្យផ្សេងទៀត ភាគច្រើនសំដៅប្រមូលបច្ច័យកសាងសាលារៀន នេះគឺជាការសម្រាលនូវបន្ទុករបស់រដ្ឋ ក្នុងការដោះស្រាយសាលារៀន។ ការបង្កើតបានសាលាមធ្យមសិក្សាកំរិតទី ១ នៅតាមឃុំ ឬទីប្រជុំជន ទីរួមស្រុក បានជួយយ៉ាងច្រើនដល់ការបណ្តុះបណ្តាលវប្បធម៌ សំរាប់កូនចៅប្រជាកសិករ ដែលខ្វះមធ្យោបាយ និងប្រាក់កាសសំរាប់មករៀននៅទីក្រុង ឬកន្លែងឆ្ងាយៗ ហើយក៏បានដោះស្រាយនូវការខុសគ្នាអំពីចំណេះដឹងរវាងទីក្រុង និងជនបទ ដែលជាមូលដ្ឋានដ៏សំខាន់មួយ ក្នុងការធ្វើអោយជនបទ និងទីក្រុងរីកចំរើនព្រមគ្នា។ ប៉ុន្តែយើងត្រូវឃើញថា សាលារៀនដែលយើងកសាងបានប៉ុណ្ណោះ មិនទាន់ឆ្លើយតបនឹងសំណូមពរនៅឡើយទេ គិតទាំងគ្រប់កំរិតសិក្សា។ នៅតាមបណ្តាខេត្តភូមិភាគឥសាន ត្រូវបន្តជំរុញការកសាង សាលាបឋមសិក្សានៅតាមភូមិ ឃុំ ត្រូវខិតខំធ្វើអោយមានសាលាមធ្យមសិក្សាកំរិត ១ នៅតាមស្រុក ហើយត្រូវឈានទៅរៀបចំសាលាមធ្យមសិក្សាកំរិត ២ នៅតាមបណ្តាខេត្តទាំងនោះតែម្តង ធ្វើយ៉ាងនេះ ទើបធានាបណ្តុះបណ្តាលកូនចៅ ពិសេសជនជាតិភាគតិចនៅទីនោះតែម្តង។ ការកសាងសាលា ពិសេសសាលាមធ្យមសិក្សាកំរិត ១ និងកំរិត ២ នៅភូមិភាគឥសាន ត្រូវតែគិតទៅដល់អន្តេវាសិកដ្ឋានសំរាប់សិស្ស និងផ្ទះសំណាក់សំរាប់គ្រូបង្រៀនស្នាក់នៅ ធ្វើយ៉ាងនេះទើបមានសិស្ស និងគ្រូនៅក្នុងថ្នាក់រៀន។ ចំពោះដំបន់វាលរាប ក៏ត្រូវតែខិតខំបន្តជំរុញការកសាងសាលាមធ្យមសិក្សាកំរិត ១ និងកំរិត ២ បន្ថែមទៀត ដើម្បីម្យ៉ាងបន្ថយការលំបាករបស់សិស្ស ដែលត្រូវធ្វើដំណើរឆ្ងាយ ឬក្នុងការលំបាករកផ្ទះសំណាក់ក្នុងការសិក្សា ម្យ៉ាងទៀតគឺដើម្បីស្រូបយកសិស្ស

ដែលចប់បឋមសិក្សាចូលមធ្យមសិក្សាកំរិត ១ ហើយស្រូបយកសិស្ស ចប់មធ្យមសិក្សាកំរិត ១ ចូលមធ្យមសិក្សាកំរិត ២ អោយបានកាន់តែច្រើន។ ប៉ុន្មានឆ្នាំខាងមុខ ត្រូវខិតខំស្រូបយកអោយអស់ ពីបឋមសិក្សាចូលមធ្យមសិក្សាកំរិត ១។

តាមរបាយការណ៍ក្រសួងអប់រំឆ្នាំ ១៩៨៨ នេះ មធ្យមសិក្សាកំរិត ១ បានស្រូបយកអស់សិស្សប្រឡងជាប់វិញ្ញាបនប័ត្រ តែនេះគ្រាន់តែគិតទៅលើចំនួនសិស្សត្រូវឡើងថ្នាក់ ទៅនឹងថ្នាក់រៀនដែលអាចទទួលបានតែប៉ុណ្ណោះ។ ប៉ុន្តែ បើគិតតាមភូមិសាស្ត្រសិក្សា គឺពិតជាមិនអាចស្រូបយកសិស្សដែលប្រឡងជាប់អស់ឡើយ អាស្រ័យដោយសាលានៅឆ្ងាយ ហើយខ្វះមធ្យោបាយ ខ្វះផ្ទះសំរាប់ស្នាក់នៅ ដូចនេះ ពិតជាមានកុមារជាច្រើនមិនបានចូលរៀននៅមធ្យមសិក្សាកំរិត ១ ហើយបញ្ហានេះ គឺពិតជាកើតមាននៅជនបទ។ ដូច្នេះ ត្រូវតែជំរុញកសាងសាលារៀនបន្តទៀត ហើយទីតាំងសាលាក៏ត្រូវគិតពីផែនទីសិក្សាអោយបានច្បាស់លាស់ គឺត្រូវកសាងសាលាអោយរត់រកសិស្ស កូនប្រជាជននៅ ទីណាច្រើន គឺកសាងកន្លែងនោះ ហើយដែលស្របនឹងភូមិសាស្ត្រផងដែរ។ ជៀសវាងកសាងសាលារៀនសម្រួលអោយគ្រូធ្វើដំណើរជិត ហើយសិស្សជាច្រើនធ្វើដំណើរឆ្ងាយ ឬកសាងតាមចំណង់របស់កម្មាភិបាលដឹកនាំ ដែលចង់អោយភូមិ ឃុំខ្លួនមានសាលារៀន ដូចកន្លងមកធ្លាប់មានការប្តឹងផ្តល់ពីប្រជាជនរួចមកហើយ។

ឯនៅទីក្រុងភ្នំពេញ ទីរួមខេត្តមួយចំនួន បញ្ហាសាលារៀននៅជាចំណោទនៅឡើយដែរ ដោយយើងស្រូបយកសិស្សបានតិច និងដាក់សិស្សក្នុងថ្នាក់នីមួយៗ លើសការកំណត់ ដែលបង្ខំអោយយើងត្រូវតែ

*បើកការរៀនសូត្រក្រៅម៉ោងធ្វើការ សំរាប់សិស្សដែលប្រឡងធ្លាក់កៅអី។ បញ្ហាខ្វះសាលាក្នុងទីក្រុង មួយផ្នែកបណ្តាលមកពីកត្តាសត្យានុម័តិ តែមួយផ្នែកទៀត ក៏មកពីកត្តាអត្តនោម័តិរបស់យើងដែរ ដូចជាសាលារៀនមួយចំនួន យើងមិនបានដោះស្រាយអោយសិស្សរៀនទេ បែរជាយកទៅធ្វើជាទីតាំងស្ថាប័នរដ្ឋបាល ឬទីតាំងយោធាទៅវិញ។ ការដែលសាលារៀនមិនបានបើកទ្វារសំរាប់អោយសិស្សរៀន មិនគ្រាន់តែធ្វើអោយរាំងស្ទះដល់ការស្រូបយកសិស្សចូលរៀនប៉ុណ្ណោះទេ ប៉ុន្តែ នៅបានបង្កឡើងនូវបញ្ហាសង្គមថែមទៀតផង ពោលគឺសិស្សដែលនៅវ័យក្មេងក្រោម ១៨ ឆ្នាំ ហើយមិនបានរៀនបន្ត តើអាចធ្វើអ្វីបាន? ម្យ៉ាងទៀតសណ្តាប់ធ្នាប់ចរាចរក្នុងទីក្រុង និងការបាត់ពេលវេលាសំរាប់សិស្សធ្វើដំណើរឆ្ងាយដើម្បីទៅរៀន ក៏ជាបញ្ហាធ្ងន់ធ្ងរមួយដែរ ឧទាហរណ៍អតីតសាលាឥន្ទ្រទេវី ដែលមិនបានបើកអោយសិស្សចូលរៀន សិស្សទាំងនៅទួលគោក ទាំងនៅទឹកល្អក់ ត្រូវប្រមូលផ្តុំរៀននៅសាលាសន្ធរម៉ុក និងបាក់ទូក ដូច្នេះគ្រោះថ្នាក់ចរាចរតាមផ្លូវទៅសាលាទាំងពីរ បានកើនឡើងជាប្រចាំ សិស្សបាត់ពេលវេលាក្នុងការធ្វើដំណើរផង ហើយវាកាន់តែលំបាកថែមទៀតសំរាប់គ្រួសារក្រីក្រ ដែលគ្មានប្រាក់ទិញកង់អោយកូនទៅរៀន។ ដូច្នេះ បញ្ហាសាលារៀន គឺជាការងារដែលយើងត្រូវបន្តដោះស្រាយ ហើយដែលវិធីសំខាន់ គឺបន្តចលនាប្រជាជនចូលរួមចំណែកដោយរដ្ឋផ្តល់អាទិភាព ក្នុងការលក់សម្ភារៈសំណង់ជូន ដូចជា ស៊ីម៉ង់ត៍ ដែក ឈើ។ល។*

*ដើរទន្ទឹមនឹងការកសាងសាលារៀន ការបណ្តុះបណ្តាលជួរគ្រូបង្រៀន នៅតែជាបញ្ហាសំខាន់ ដែលត្រូវយកចិត្តទុកដាក់។ តើយើងនឹងត្រូវមានវិធីយ៉ាងណា ដើម្បីកសាងជួរគ្រូបង្រៀនអោយជនបទ និងបណ្តាខេត្តនៃភូមិ*

ភាគឥសាន? ១០ ឆ្នាំកន្លងមក យើងមានពិសោធន៍ហើយ យើងបានជួប នឹងការលំបាកក្នុងការបញ្ជូនគ្រូពីទីក្រុង ទីប្រជុំជនទៅកាន់ជនបទ ទៅកាន់បណ្តាខេត្តភូមិភាគឥសាន ដូច្នេះយើងគួរ អោយអាទិភាពបណ្តុះបណ្តាលសិស្ស ដែលមកពីជនបទអោយក្លាយទៅជាគ្រូបង្រៀន រួចហើយបញ្ជូនអោយទៅបង្រៀននៅមូលដ្ឋានរបស់គេវិញ។ ពិតមែនហើយ គុណភាពបង្រៀនគ្រាដំបូងនៅខ្សោយ ប៉ុន្តែវា ក៏គ្រាន់បើជាងគ្មានគ្រូបង្រៀនដែរ ម្យ៉ាងទៀតក៏សម្រួលអោយរដ្ឋ និងប្រជាជនក្នុងការដោះស្រាយជីវភាពរស់នៅអោយ គ្រូបង្រៀនមួយកំរិតដែរ ពិសេសផ្ទះសម្បែង អាស្រ័យដោយគេមានផ្ទះសម្បែងនៅមូលដ្ឋាននោះរួចហើយ។ ក្នុងលទ្ធភាពដែលមិនទាន់ដោះស្រាយបានតាមវិធីខាងលើនេះ ត្រូវខិតខំចលនាអោយគ្រូពីកន្លែងផ្សេងទៅបង្រៀន ដោយមានគោលនយោបាយលើកទឹកចិត្តសមស្រប ហើយមូលដ្ឋានដែលត្រូវទទួលគ្រូ ក៏ត្រូវជួយបង្កលក្ខណៈអោយគ្រូមានលំនឹង ដូចជាការស្នាក់នៅ និងជីវភាព។ល។

ក្នុងការដោះស្រាយសៀវភៅ ក្បួនខ្នាតអោយសិស្សរៀន យើងបានខិតខំដោះស្រាយបានច្រើនបង្គួរហើយ ប៉ុន្តែចំណោទដែលត្រូវដោះស្រាយ គឺត្រូវធ្វើយ៉ាងណាអោយបានដល់សិស្សរៀន។ នៅទីក្រុង ទីប្រជុំជនមិនជាចោទធំដុំទេ ប៉ុន្តែនៅជនបទសៀវភៅសំរាប់សិស្សរៀនមានតិច។ ក្នុងពេលសិស្សខ្វះសៀវភៅរៀន សៀវភៅមួយចំនួនស្ថិតនៅក្នុងឃ្លាំងរបស់មន្ទីរអប់រំខេត្ត ក្រុងទៅវិញ ដោយយកហេតុផលថាមានការលំបាកក្នុងការទូទាត់ផ្នែកថវិកា។ ដូច្នេះខាងមុខនេះ យើងមិនគួរអូសបន្លាយស្ថានភាពនេះអោយវែងឆ្ងាយតទៅទៀតទេ យើងត្រូវតែហ៊ានវិនិយោគទុនអោយធំជាងនេះទៀត សំរាប់បោះពុម្ពបន្ថែមនូវ

សៀវភៅសំរាប់សិស្ស។ សៀវភៅដែលបោះពុម្ពបាន ត្រូវលក់អោយសិស្សតែម្តង ដោយគិតគូរតម្លៃសមស្រប ប៉ុន្តែគ្រប់សាលារៀនក៏ត្រូវរៀបចំអោយមានបណ្ណាល័យ រក្សាទុកសៀវភៅសំរាប់អោយសិស្សខ្ចីចំពោះសិស្សដែលគ្មានប្រាក់គ្រប់គ្រាន់ទិញសៀវភៅ។ បញ្ហាសម្ភារៈទំនើបៗ សំរាប់បម្រើការសិក្សា ជារឿងលំបាកព្រោះត្រូវនាំចូលពីបរទេស ប៉ុន្តែ សៀវភៅក្បួនខ្នាតសំរាប់សិស្សរៀន ដែលយើងធ្វើបានដោយខ្លួនឯង វាមិនត្រូវលំបាកទេ។ នៅមជ្ឈិម ខេត្ត ក្រុង ស្រុក បើយើងធ្វើការសន្សំសំចៃក្នុងរយៈតែមួយឆ្នាំ ដូចជាការបញ្ឈប់ការជប់លៀងនៅពេលប្រជុំសន្និបាត ពន្ធត់អគ្គិសនីនៅតាមខេត្ត ស្រុក ក្នុងមួយយប់មួយម៉ោង ឬកន្លះម៉ោង ឬបន្ថយសាំងសំរាប់រថយន្តកម្មាភិបាល ១ នាក់ពីរ ឬបីលីត្រក្នុងមួយខែៗលៗ និងៗលៗ ក៏អាចរកប្រាក់បោះពុម្ពសៀវភៅទៅអោយសិស្សរៀនបានមួយចំនួនធំដែរ។ ការដោះស្រាយបង្កើនថែមនូវសៀវភៅសំរាប់សិស្ស គឺជាវិធានការសំខាន់មួយ ដើម្បីបង្កើននូវគុណភាពសិក្សារបស់សិស្ស ព្រោះថា សិស្សរបស់យើងជាទូទៅរៀនតែមួយពេលក្នុងមួយថ្ងៃ ដូច្នេះសល់មួយពេលទៀតសិស្សត្រូវស្រាវជ្រាវខ្លួនឯងហើយវាក៏សម្រួលដល់ការរំលឹកឡើងវិញនូវមេរៀនរបស់សិស្សផងដែរ។

ទាក់ទងដល់ការដែលសិស្សត្រូវរៀនតែមួយពេលក្នុងមួយថ្ងៃ បានចោទឡើងនូវបញ្ហារៀនបន្ថែម (រៀនគួរ) ដែលបញ្ហានេះបានក្លាយទៅជាកម្មវត្ថុនៃការជជែកគ្នា ទោះបីជាមិនផ្លូវការក៏ដោយ។ មានមតិលើកឡើងថា ការរៀនបន្ថែមគឺសំរាប់បំរើតែកូនអ្នកមានប្រាក់ ឯកូនអ្នកក្រីក្រគ្មានប្រាក់សំរាប់ជួលគ្រូបង្រៀន ត្រូវជួបការលំបាក ហើយរៀនចាញ់កូនអ្នកមានប្រាក់។ បញ្ហានេះ យើងគ្មានវិធីណាអាចបញ្ចប់បានទេ

ព្រោះជាសំណូមពររបស់សិស្សក្នុងការបង្កើនចំណេះដឹងផង និងជាសំណូមពររបស់គ្រូ ក្នុងការលើកកំពស់ជីវភាពផង។ វិធីដោះស្រាយ គឺត្រូវគ្រប់គ្រងអោយបានល្អ ហើយចលនាលោកគ្រូ អ្នកគ្រូអោយជួយទទួលយកសិស្សដែលគ្មានប្រាក់បានចូលរៀន ដោយមិនបាច់បង់ប្រាក់។ ឧទាហរណ៍ គ្រូបង្រៀនម្នាក់បើកបង្រៀនបន្ថែមនៅផ្ទះខ្លួនមានសិស្ស ១០ នាក់ ដែលត្រូវបង់ប្រាក់ យើងគួរចលនាគ្រូនោះអោយទទួលសិស្សបន្ថែម ១ ឬ ២ នាក់ទៀត ដោយមិនបាច់បង់ប្រាក់ ហើយដែលសិស្សនោះ ស្ថិតក្នុងចំណោមកូនចៅនៃគ្រួសារក្រីក្រ។ ធ្វើយ៉ាងនេះ យើងជួយលើកកំពស់គុណភាពសិស្សបានផង និងជួយសំរាលជីវភាពគ្រូបង្រៀនយើងបានមួយកំរិតទៀតផង។

នៅមានបញ្ហាធំៗ ជាច្រើនទៀត ដែលយើងត្រូវបន្តដោះស្រាយ ហើយដែលសំខាន់នោះ គឺដោះស្រាយទំនាស់រវាងលទ្ធភាពនៃទុនវិនិយោគដ៏តិចតួច ជាមួយនឹងគោលនយោបាយពង្រីកអោយបានខ្លាំងវិស័យអប់រំ រវាងការពង្រីកខ្លាំងផ្នែកបរិមាណ ជាមួយលទ្ធភាពអនុវត្តផ្នែកគុណភាព និងការដោះស្រាយចំពោះសិស្ស និស្សិត ដែលមិនអាចបន្តរៀនទៅមុខទៀតបាន។ល។

នយោបាយរបស់បក្ស និងរដ្ឋយើង គឺត្រូវពង្រីកខ្លាំងវិស័យអប់រំ ហើយដែលជាក់ស្តែងកន្លងមក វាបានក្លាយជាចលនាបដិវត្តដ៏ទូលំទូលាយរួចទៅហើយ ប៉ុន្តែក្នុងពេលនោះដែរ លទ្ធភាពនៃទុនវិនិយោគរបស់យើងចំពោះវិស័យអប់រំនៅតិចតួចនៅឡើយ។ ប្រសិនបើយើងពិនិត្យអំពីទុនរបស់យើង គឺមានតិចតួចមែន ប៉ុន្តែយើងក៏នៅមានលទ្ធភាពបង្កើនថែមអោយវិស័យនេះដែរ។

បញ្ហាទុនវិនិយោគ គឺទាមទារនូវការឯកភាពគ្នាអំពីទស្សនៈរបស់គ្រប់ផ្នែក គ្រប់ថ្នាក់ និងប្រជាជនយើង បើមិនដូច្នេះទេ យើងមិនអាចរកទុនបន្ថែមសំរាប់វិស័យនេះបានទេ។ យើងគួរចាត់ទុកថា អប់រំជាទុនវិនិយោគ ឬជាអង្គភាពផលិតមួយយ៉ាងសំខាន់ ក្នុងការកសាងប្រទេសជាតិ ពិតមែនហើយថាមិនអាចទាញយកប្រាក់ដើម និងប្រាក់ចំណេញមកវិញបានភ្លាមៗ នោះទេ ហើយបើបានមកវិញ ក៏មិនមែនតាមគណនេយ្យរបស់ក្រសួងអប់រំ ឬសាលារៀនដែរ។ យើងបញ្ចូលប្រាក់ទុនវិនិយោគទៅតាមរយៈក្រសួងអប់រំ តាមសាលារៀន ហើយវានឹងបានមកវិញតាមរយៈមូលដ្ឋានផលិតកម្មទូទាំងប្រទេស វានឹងបានទៅជាកម្លាំងការពារជាតិដ៏ខ្លាំងក្លា និងជាកម្លាំងការងារដ៏មានប្រសិទ្ធិភាពនៃស្ថាប័នគ្រប់ផ្នែកគ្រប់ជាន់ថ្នាក់ វានឹងបានមកវិញនូវសង្គមជាតិដ៏មានគុណធម៌ និងអារ្យធម៌ ព្រោះថាអប់រំជាផ្នែកដែលផលិតពលករ ហើយពលករនេះឯង ជាអ្នកផលិតនូវសម្ភារៈគ្រប់បែបយ៉ាង ដើម្បីការស្ថិតស្ថេរ និងរីកចំរើនរបស់សង្គម។ សព្វថ្ងៃនេះ កម្លាំងសង្កត់មានតៗគ្នា គឺកំណើនកុមារសង្កត់បឋមសិក្សា បឋមសិក្សាសង្កត់មធ្យមសិក្សាកំរិត ១ មធ្យមសិក្សាកំរិត ១ សង្កត់មធ្យមសិក្សាកំរិត ២ ផង សង្កត់សង្គមផង ចំពោះសិស្សដែលមិនអាចចូលរៀនបន្តបាន ហើយមធ្យមសិក្សាកំរិត ២ សង្កត់ឧត្តមសិក្សាផង និងសង្កត់សង្គមផង ចំពោះសិស្សដែលមិនអាចចូលរៀនបន្តបាន។ បញ្ហាគុណភាព វាក៏បានចោទធ្ងន់ធ្ងរជាមួយគ្នាដែរ។ យើងមិនទាន់ធ្វើការប្រៀបធៀបជាមួយប្រទេសក្រៅទេ គ្រាន់តែនៅក្នុងប្រទេសយើង ប្រសិនបើយើងធ្វើការប្រៀបធៀបអំពីគុណភាពសិក្សា ឃើញថាមានការខុសគ្នារវាងទីក្រុង ជាមួយតំបន់វាលរាប រវាងទីក្រុង

តំបន់វាលរាប ជាមួយតំបន់ព្រៃភ្នំ ហើយដែលបញ្ហានេះទាក់ទងដល់កត្តាជាច្រើន តែជាសំខាន់គឺកត្តាគ្រូ កត្តាមូលដ្ឋានសម្ភារៈបច្ចេកទេស។ល។

ដើម្បីបញ្ចៀសកម្លាំងសង្កត់អំពីបរិមាណ ព្រមទាំងដោះស្រាយបញ្ហាគុណភាព រដ្ឋត្រូវតែហ៊ានពុះពារបោះទុនវិនិយោគសំរាប់វិស័យអប់រំអោយបានខ្លាំងក្លាថែមទៀត។ ជាមួយនោះ ក៏ត្រូវចលនានូវការចូលរួមចំណែករបស់ប្រជាជន ព្រះសង្ឃ អាណិកជនខ្មែរនៅបរទេស ដើម្បីបង្កើនឡើងនូវប្រភពទុនក្នុងការកសាងនូវមូលដ្ឋានសម្ភារៈបច្ចេកទេស បំរើអោយវិស័យអប់រំ។ ទន្ទឹមនេះ ក៏ត្រូវចលនាលោកគ្រូ អ្នកគ្រូ និងប្រជាជនអោយចូលរួមកសាងសម្ភារៈឧបទេសរបស់សាលា ដើម្បីបំរើដល់ការបង្រៀន និងរៀន និងចលនាមូលដ្ឋានផលិតកម្មរបស់រដ្ឋ របស់សមូហភាព របស់ឯកជន ឬគ្រួសារអោយជួយទទួលយកសិស្សទៅធ្វើកម្មសិក្សា ឬធ្វើទស្សនកិច្ចដកពិសោធន៍។ នេះជាវិធីគួបផ្សំរវាងរដ្ឋ និងប្រជាជន ក្នុងការដោះស្រាយទុនសំរាប់ការពង្រីកវិស័យអប់រំ។

បញ្ហាចោទឡើងធ្ងន់ធ្ងរសំរាប់យើងមួយទៀត គឺការដោះស្រាយគ្រោះអត់ការងារធ្វើសំរាប់សិស្សចេញពីសាលា។

សិស្សជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ មានច្រើន ហើយសាលាមធ្យមសិក្សាកំរិត ២ ស្រូបបានតិច។ គ្រាន់តែតួលេខនៅរដ្ឋធានីភ្នំពេញមួយប៉ុណ្ណោះ គឺនៅឆ្នាំសិក្សា ១៩៨៧-១៩៨៨ សិស្សចំណោះទូទៅបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ មាន ១១.១២៩ នាក់ ដោយមិនគិតសិស្សសល់ពីឆ្នាំមុនៗ ផងទេ ហើយសិស្សដែលបានចូលរៀននៅមធ្យមសិក្សាកំរិត ២ បានដល់ទៅ ៤.៥១៥ នាក់ លើផែនការ ៤.០០០ នាក់។ ដោយការប្រឹងប្រែងរបស់រដ្ឋធានី គឺបានបើកការរៀនសូត្រនៅ

ពេលយប់ចំពោះសិស្សដែលមានអាយុ ១៤ ឆ្នាំ និង ១៥ ឆ្នាំ បានចំនួន ៤.៦៦៥ នាក់ទៀត ដោយដាក់សិស្ស ៨០ នាក់ក្នុងមួយថ្នាក់ ក្រៅពីនេះគឺមិនបានចូលរៀនទេ ហើយភាគច្រើនមានអាយុទើប ១៦ ឆ្នាំ។ តាមការសរុបទូទាំងប្រទេស ក្រៅពីជាប់ចូលរៀនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងវគ្គមធ្យមសិក្សាឯកទេស ការចូលបំរើក្នុងក្របខ័ណ្ឌរដ្ឋផ្សេងៗ និងបានចូលរៀនសាលាបំពេញវិជ្ជាក្រៅម៉ោង នៅមានសិស្សជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ប្រហែល ១ ភាគ ៣ ទៀត ដែលមិនបានចូលរៀន ហើយពុំទាន់ទទួលមុខសញ្ញាអ្វីច្បាស់លាស់។ ការទុកអោយយុវជនមិនគ្រប់អាយុមិនបានចូលរៀន គឺជាបញ្ហាធ្ងន់ធ្ងរចំពោះរបបគ្រប់គ្រងថ្មីរបស់យើង។ តើក្មេងទាំងនេះអាចធ្វើអ្វីបាន ហើយតើអនាគតរបស់គេនឹងទៅជាយ៉ាងណា? ជាធម្មតាសិស្សគ្មានការរៀនសូត្រ ហើយគ្មានការងារផងនោះ អាចងាយនឹងបង្កឡើងនូវបញ្ហាអសកម្ម ហើយមានមួយចំនួនអាចនឹងឈានទៅរកភាពកាចសាហាវទៀតផង។

ចំពោះសិស្សជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ មួយចំនួន ដែលពុំបានបន្តការសិក្សានៅឧត្តមសិក្សា ឬទទួលអាហារូបករណ៍ទៅបរទេស ក៏ជាបញ្ហាធ្ងន់ធ្ងរមួយដែរសំរាប់សង្គមយើង ថ្វីត្បិតតែមួយចំនួនមានអាយុលើ ១៨ ឆ្នាំហើយក៏ដោយ។

ចង់ដោះស្រាយបញ្ហានេះ យើងគប្បីងាកទៅក្រោយទៅមើលគោលការណ៍របស់បក្ស និងរដ្ឋយើង ស្តីពីការអប់រំពលកម្មតម្រង់ទិសវិជ្ជាជីវៈ ហើយយើងក៏ត្រូវកំណត់អោយបានច្បាស់នូវទស្សនៈ "តើរៀនដើម្បីអ្វី" ដែលការយល់ដឹងនិងសកម្មភាពប្រតិបត្តិកន្លងមក នៅមានការខុសឆ្គងក្នុងមជ្ឈដ្ឋានកម្មាភិបាល បុគ្គលិក សិស្ស និស្សិតខ្លះ រហូតដល់អ្នក

ដឹកនាំផ្នែកអប់រំនៅមូលដ្ឋាន និងលោកគ្រូអ្នកគ្រូខ្លួនឯង ក៏មានការខុសឆ្គងដែរ។ គោលការណ៍ជាមូលដ្ឋានរបស់បក្ស និងរដ្ឋ គឺត្រូវផ្សារភ្ជាប់ការអប់រំវប្បធម៌ វិទ្យាសាស្រ្តបច្ចេកទេស ទៅនឹងពលកម្មបង្កបង្កើនផល យកចំនេះដឹងវិទ្យាសាស្រ្តបច្ចេកទេសទៅអនុវត្តក្នុងផលិតកម្ម បង្កើនសមត្ថភាពពលកម្ម ក្នុងមុខរបរវិជ្ជាជីវៈ និងបញ្ចូលបច្ចេកទេសកសិកម្ម ឧស្សាហកម្ម សិប្បកម្ម ទៅក្នុងកម្មវិធីសិក្សានៃសាលាចំណេះទូទៅ ជំរុញអោយពង្រឹងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេសលើគ្រប់វិស័យ ជំរុញអោយខិតខំបើកអោយបានច្រើន និងច្រើនរូបភាព នូវសាលា និងថ្នាក់បណ្ដុះបណ្ដាលវិជ្ជាជីវៈទាំងមធ្យម ទាំងបឋម សំរាប់បណ្ដុះបណ្ដាលសិប្បករជំនាញ កម្មករជំនាញតាមសំណូមពររបស់ក្រុមសាមគ្គីបង្កបង្កើនផល ពេងចក្រ សហគ្រាស អង្គភាព និងផ្នែកនានា។

បក្ស និងរដ្ឋយើងចង់អោយសាលាមធ្យមសិក្សាកំរិត ១ បណ្ដុះបណ្ដាលសិស្សានុសិស្សអោយមានសមត្ថភាពបំពេញមុខរបរណាមួយ សំដៅធ្វើអោយសិស្សានុសិស្ស ដែលរៀនចប់មធ្យមសិក្សាកំរិត ១ អាចចេញទៅបំពេញការងារបង្កបង្កើនផល ការពារមាតុភូមិ និងអាចបន្តការសិក្សានៅមធ្យមសិក្សាកំរិត ២ សាលាមធ្យមសិក្សាឯកទេស សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈបានល្អ។

ជាទូទៅ បទដ្ឋានរបស់បក្ស និងរដ្ឋ ស្ដីពីការអប់រំពលកម្មតម្រង់ទិសវិជ្ជាជីវៈមានគ្រប់គ្រាន់បង្គួរ ប៉ុន្ដែយើងធ្វើបានតិច។ ចង់សំរេចនូវបញ្ហានេះ ទាមទារនូវការចូលរួមពីគ្រប់មជ្ឈដ្ឋាននៃសង្គម គឺមិនអាចពឹងផ្អែកតែលើផ្នែកអប់រំធ្វើម្នាក់ឯងបានទេ។ លុះត្រាតែយើងបណ្ដុះនិស្ស័យក្មេង អោយចេះស្រឡាញ់ពលកម្ម មានចំណេះដឹងអំពីផលិតកម្ម ទើប

ក្រោយចេញពីសាលា គេមានការងារធ្វើគ្រប់ៗ គ្នាៗ ដូច្នេះ ភាពចាំបាច់ខានមិនបាន គឺសាលារៀនត្រូវតែផ្សារភ្ជាប់នឹងមូលដ្ឋានផលិតកម្ម ពោលគឺសាលារៀនទាំងអស់ត្រូវមានមូលដ្ឋានផលិតកម្ម ដូចជា ស្រែចំការ រោងជាងឈើ-ដែក ដេរប៉ាក់ ត្បាញ ជួសជុលៗលៗ ហើយសាលាក៏ត្រូវធ្វើទំនាក់ទំនងជាមួយមូលដ្ឋានផលិតកម្ម កសិកម្ម សិប្បកម្ម រោងចក្រ សហគ្រាស រុក្ខដ្ឋានៗលៗ ដើម្បីធ្វើកម្មសិក្សា ទស្សនកិច្ចដកពិសោធន៍ដោយផ្ទាល់ នឹងងាយស្រួលពន្យល់សិស្សៗ ជាមួយនោះ អាស្រ័យដោយលក្ខណៈនៃតំបន់នីមួយៗ ខុសគ្នា មូលដ្ឋាន និងសាលារៀន ក៏ត្រូវម្ចាស់ការជ្រើសរើសនូវមុខរបរសិប្បកម្មប្រពៃណីនៅមូលដ្ឋាន ដើម្បីបង្រៀនសិស្សផងដែរៗ កន្លងមក សាលាមួយចំនួនក៏មានមូលដ្ឋាន និងសម្ភារៈសំរាប់បង្រៀនសិស្សខ្លះដែរ តែ ទុកគ្រាន់តែឧទ្ទេសនាមជូនគណៈប្រតិភូ ដែលទៅទស្សនកិច្ចសាលាតែប៉ុណ្ណោះ សាលារៀនខ្លះមានស្រែចំការដែរ តែមិនមែនក្នុងគោលដៅបង្រៀនសិស្សទេ គឺគោលដៅនាំក្មេងធ្វើស្រែចំការយកផលដាក់ជាបេឡារបស់សាលាតែប៉ុណ្ណោះៗ ពិតហើយ ការងារនេះជួបការលំបាក វាទាមទារនូវជួរគ្រូតាមឯកទេស ទាមទារនូវសម្ភារៈថវិកាសំរាប់ដំណើរការដែរៗ

ដើម្បីជំរុញអោយការតម្រង់ទិសវិជ្ជាជីវៈទទួលបានផល ហើយកសាងបាននូវពលករល្អសំរាប់សង្គម សាលារៀនក៏ត្រូវយកចិត្តទុកដាក់ចំបងលើការងារអប់រំមនោគមវិជ្ជា សីលធម៌នយោបាយ ក្នុងនោះត្រូវតែធ្វើអោយសិស្សានុសិស្សយល់ដឹងច្បាស់លាស់ថា តើត្រូវចេញពីទីណា តម្រង់ទិសទៅកាន់គោលដៅណា ហើយរៀនដើម្បីអ្វីៗ គោលដៅសំខាន់របស់បក្ស និងរដ្ឋយើង គឺបណ្ដុះបណ្ដាលយុវវ័យអោយក្លាយជាពលករថ្មី មានសមត្ថ

ភាពគ្រប់គ្រាន់ រួមចំណែកក្នុងបុព្វហេតុការពារនិងកសាងមាតុភូមិប្រកបដោយជោគជ័យ។ ដើម្បីសំរេចគោលដៅនេះ ការអប់រំពលកម្មនិងតម្រង់ទិសវិជ្ជាជីវៈ ក៏ជាសកម្មភាពអប់រំមួយ មិនអាចខ្វះបាន ក្នុងចំណោមសកម្មភាពជាមូលដ្ឋានរបស់សាលារៀន។ អនុវត្តសកម្មភាពនេះបានល្អ គឺមានន័យថាចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងនិងប្រើប្រាស់កម្លាំងយុវជនដ៏ច្រើនកុះករ ដែលបានបញ្ចប់ការសិក្សានៅសាលារៀនចំណេះទូទៅ ហើយយើងប្រាកដជាមិនជួបនឹងភាពឥតការងារធ្វើរបស់យុវជន ដែលជាមូលហេតុនៃវិបត្តិរបស់សង្គម។

បញ្ហាឧត្តមសិក្សា និងការបញ្ជូនសិស្សទៅរៀននៅបរទេស ក៏ត្រូវដោះស្រាយដែរ។ ចំណោទនៅទីនេះ មានបញ្ហាច្រើន តែខ្ញុំចង់និយាយបញ្ហាពីរ មួយបញ្ហាគ្រូ មួយទៀតគឺការបញ្ចូលភាសាបរទេសទៅក្នុងសាលារៀនចំណេះទូទៅ ដើម្បីរៀននៅឧត្តមសិក្សា និងទៅរៀននៅបរទេស។ ប៉ុន្មានឆ្នាំកន្លងមក យើងបានអញ្ជើញសាស្ត្រាចារ្យពីប្រទេសជាមិត្តមកជួយបង្រៀន។ ប៉ុន្មានឆ្នាំចុងក្រោយនេះ និស្សិតយើងបានបញ្ចប់ការសិក្សានៅក្នុងប្រទេស និងក្រៅប្រទេសមានចំនួនច្រើនដែរ តែយើងមិនទាន់បានផ្តល់អាទិភាព ដល់ការជ្រើសរើសអ្នកពូកែអោយបន្តរៀនដើម្បីយកវិជ្ជាមកបង្រៀនបន្ត។ ចំពោះកម្មាភិបាលដែលកំពុង ធ្វើការសព្វថ្ងៃ ដែលមានលទ្ធភាពទៅបង្រៀនបាន ក៏យើងមិនទាន់មានគោលការណ៍លើកទឹកចិត្តអោយសមស្រប ដើម្បីអោយគេទៅជួយបង្រៀន។ បញ្ហានេះត្រូវគិតឡើងវិញ ព្រោះការប្រើប្រាស់គ្រូរបស់យើងចំណេញច្រើនណាស់ ហើយមានន័យនយោបាយផង។ យើងត្រូវតែហ៊ានយកអ្នកពូកែបញ្ចូលទៅសាលាដើម្បីបង្រៀន ទើបយើងមានសិស្សពូកែ

ហ៊ានមានគោលនយោបាយលើកទឹកចិត្តចំពោះអ្នកចេះដឹង ដើម្បីអោយគេទៅបង្រៀន។ ការប្រើប្រាស់គ្រូបស់យើងចំណោញច្រើន តាំងពីថវិកាកន្ទ្វែងស្នាក់នៅ ពេលវេលារៀនសូត្រ គឺយើងរៀនជាភាសាជាតិយើងផ្ទាល់ ដោយមិនចាំបាច់បកប្រែភាសា។ និយាយយ៉ាងនេះមិនមែនមានន័យថា យើងបដិសេធសាស្ត្រាចារ្យបរទេសដែលជួយយើងនោះទេ តែយើងគួរពឹងពាក់លើឯកទេសណាដែលខ្មែរយើងមិនចេះ ឬដោយសាស្ត្រាចារ្យយើងមានមិនគ្រប់ចំនួនថ្នាក់រៀនតែប៉ុណ្ណោះ។

ចំពោះការបញ្ចូលភាសាបរទេសទៅក្នុងសាលារៀន បញ្ហានេះយើងមានបទពិសោធន៍ហើយ គឺវាត្រូវការទាំងសិស្សរៀននៅក្នុងប្រទេស ទាំងសិស្សត្រូវទៅរៀននៅបរទេស។ ពេលចូលឧត្តមសិក្សា ពិសេសផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងបច្ចេកទេស យើងចាប់ផ្តើមត្រូវការភាសាបរទេស ក្នុងពេលដែលសិស្សមិនចេះ។ ក្នុងរោងចក្រ ម៉ាស៊ីន សម្ភារៈបរិក្ខារ ក៏គ្មានដាក់ផ្លាកអក្សរខ្មែរ ក្នុងពេលដែលកម្មករយើងមើលមិនបាន។ សិស្សនិស្សិតចេញទៅរៀននៅបរទេស មានចំណោះទូទៅពូកែ មិនចាញ់បរទេសទេ ប៉ុន្តែគេគ្មានមូលដ្ឋានភាសាបរទេសណាមួយ ដែលជាហេតុធ្វើអោយគេរៀនចុះខ្សោយ។

ដូច្នេះ យើងគួរតែរៀបចំបញ្ចូលភាសាបរទេស ទៅក្នុងសាលារៀនចំណោះទូទៅជាមុន។ ក្នុងពេលខ្វះគ្រូ យើងគួរបញ្ចូលក្នុងមធ្យមសិក្សាកំរិត ២ សិន លុះដល់ពេលមានជួរគ្រូបង្រៀនហើយ ទើបយើងបញ្ចុះទៅថ្នាក់ក្រោមទៀត។

បញ្ហាចុងក្រោយ គឺបញ្ហាបំពេញវិជ្ជា។ យើងបានលុបបំបាត់ជាស្ថាពរនូវគ្រោះមិនចេះអក្សររួចហើយ តែយើងមិនគួរភ្លេចដល់គ្រោះថ្នាក់នៃ

*ការក្មេចអក្សរនោះទេ។ ដូច្នេះ ការបំពេញវិជ្ជា ទោះជានៅតាមសាលារៀនបរយក្តី ពាក់កណ្តាលរៀបរយក្តី ឬក្រៅម៉ោងធ្វើការក្តី ក៏ត្រូវបន្តជំរុញ ដោយត្រូវខិតខំស្រូបយកកម្មាភិបាល បុគ្គលិក កម្មករ យុទ្ធជនក្នុងកងកម្លាំងប្រដាប់អាវុធ រៀនអោយបានច្រើន ដើម្បីលើកកំពស់សមត្ថភាព។ នៅមូលដ្ឋាន ត្រូវមានជាចលនាមហាជនអោយបានទូលំទូលាយ គឺមិនមែនជាចលនាបំបាត់គ្រោះមិនចេះអក្សរដូចពេលមុនទៀតទេ តែជាចលនាបំពេញវិជ្ជាទប់ស្កាត់គ្រោះថ្នាក់ក្មេចអក្សរ។ យើងត្រូវខិតខំបញ្ជូនចុះទៅមូលដ្ឋាននូវកាសែត ទស្សនាវដ្តី សៀវភៅអានដើម្បីរួមចំណែកដល់ការបំពេញវិជ្ជាផង និងលើកកំពស់ការយល់ដឹងរបស់ប្រជាជនផង។*

*ចំពោះសាលារៀបរយ និងពាក់កណ្តាលរៀបរយ យើងក៏ត្រូវពិនិត្យឡើងវិញអោយបានសមស្របអំពីចំនួនសិស្ស និងទំហំសាលា។ អាស្រ័យដោយក្មេងខ្វះសាលារៀនយ៉ាងច្រើននោះ ឆ្នាំ ១៩៨៨ នេះ បានកើតឡើងនូវមតិមហាជនថា "អ្នកដែលមិនចង់រៀន យើងបង្ខំអោយរៀនដូចជាអោយមនុស្សចាស់ទៅរៀនបំពេញវិជ្ជា តែអ្នកចង់រៀនយើងមិនអោយគេបានរៀន ដូចជាសិស្សដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ ហើយ"។ នេះជាមតិដែលត្រូវយកមកពិនិត្យ ហើយដោះស្រាយអោយបានសមហេតុសមផល។ បើសាលាធំ ហើយសិស្សបំពេញវិជ្ជាមានតិច យើងក៏គួរជួយទទួលយកសិស្សដែលគ្មានថ្នាក់រៀនខ្វះផង។ បញ្ហានេះ ខេត្ត ក្រុងអាចដោះស្រាយបាន។*

*រួមមក ក្នុងវិស័យអប់រំយើងទទួលបានជ័យជំនះក៏ច្រើន ហើយបញ្ហាដែលនៅសេសសល់ត្រូវដោះស្រាយក៏ច្រើនដែរ ប៉ុន្តែយើងជឿជាក់ថា*

យើងពិតជាដោះស្រាយបាននូវបញ្ហាទាំងអស់នេះ។

២.វិស័យវប្បធម៌

ភាពវិនាសដែល ប៉ុល ពត បានបង្កឡើង គឺបានធ្វើអោយអន្តរាយយ៉ាងធ្ងន់ធ្ងរដល់របនាសម្ព័ន្ធរបស់ជាតិ។ សញ្ញាសម្គាល់ជាតិខ្មែរ ដែលធ្លាប់បានបង្ហាញតាមរយៈវប្បធម៌ ស្ទើរតែបានកប់បាត់ទៅក្នុងប្រវត្តិសាស្ត្រនៃរបបស្រេកឈាម ប៉ុល ពត ហើយដែលពីមុនពេល ប៉ុល ពត ឡើងកាន់អំណាច គ្មានអ្នកណាមួយគិតនឹកស្មានដល់សោះ ព្រោះទាំងអស់គ្នាយល់ថា ពួកនេះជាមនុស្ស ហើយជាខ្មែរដែរ។ គ្រប់ៗ គ្នាសុទ្ធតែបានដឹង បានឃើញនូវអំពើដ៏ថោកទាបរបស់ពួក ប៉ុល ពត ទៅលើសម្បត្តិវប្បធម៌សិល្បៈ ទៅលើទំនៀមទំលាប់ប្រពៃណីដ៏ល្អប្រពៃរបស់ជាតិខ្មែរ និងជនជាតិភាគតិចនៅកម្ពុជា ទៅលើជំនឿ និងសេរីភាពខាងស្មារតីរបស់ប្រជាជន ទៅលើអ្វីៗ ដែលហៅថាភាពថ្លៃថ្នូរ ក្នុងឋានៈជាមនុស្ស។

ផលវិបាកនៃរបប ប៉ុល ពត គឺជារឿងរន្ធត់ញាប់ញ័រ ជាមរតកដ៏ធ្ងន់ធ្ងរដែលកូនចៅខ្មែរ ក្រោមរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាយើង ត្រូវតែព្យាបាលនូវស្នាមរបួសដ៏ពិសពុលនេះ។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ព្រលឹងជាតិរបស់យើងបានត្រូវរស់ឡើងវិញ ជាមួយនឹងជោគជ័យដ៏ធំធេងដែលទទួលបានលើវិស័យផ្សេងទៀត។ ពួក ប៉ុល ពត អាចសម្លាប់មនុស្សបានរាប់លាននាក់ក្នុងពេលកាន់អំណាច តែពួកវាមិនអាចសម្លាប់នូវកម្លាំងរស់របស់ជាតិបានឡើយ យើងបានធ្វើអោយវប្បធម៌សិល្បៈរបស់ជាតិរស់ឡើងវិញ ហើយរស់ក្នុងសភាពជឿនលឿនទៅមុខ។

យើងគួររំលឹកឡើងវិញនូវចំណុចខ្វះៗ ដែលយើងបានធ្វើក្នុងសកម្ម

ភាពវប្បធម៌៖

- អំពីបញ្ហាសិល្បៈ និយាយដល់សិល្បៈនៅទីនេះ យើងចង់និយាយសំខាន់អំពីសិល្បៈបុរាណខ្មែរ ដែលមានចរិតជាប្រពៃណីខ្មែរ ហើយយើងគួរតែរំលឹកឡើងវិញបន្តិចអំពីសម័យមុនសង្គ្រាម។ ក្នុងទសវត្សរ៍ ៦០ ដល់ពាក់កណ្តាលទសវត្សរ៍ ៧០ យើងសង្កេតឃើញថា អាស្រ័យដោយសិល្បៈបស្ចឹមប្រទេសបានចូលមកចំកណ្តាលទីក្រុងធំៗ នៅប្រទេសយើង វាបានធ្វើអោយសិល្បៈប្រពៃណីជាតិរួញតូចទៅៗ បន្តិចម្តងៗ ហើយទីចុងបំផុតបានរត់ទៅនៅជនបទ ឯនៅទីក្រុង មួយផ្នែកស្ថិតនៅក្នុងវាំងស្តេច សំខាន់គឺរបាំព្រះរាជទ្រព្យ មួយផ្នែកក៏សេសសល់នៅតាមពេងមហោស្រពសិល្បៈបុរាណខ្មែរ ដូចជាល្ខោនបាសាក់ យីកេ ហើយជាទូទៅ សិល្បៈបុរាណខ្មែរបានប្រមូលផ្តុំ សំខាន់នៅក្នុងសកលវិទ្យាល័យវិចិត្រសិល្បៈ ប៉ុន្តែកម្លាំងក្នុងសកលវិទ្យាល័យនេះ ក៏មិនអាចទប់ឈ្នះដែរត្រូវឥទ្ធិពលនៃសិល្បៈបស្ចឹមប្រទេស ដែលហូរចូលយ៉ាងខ្លាំងមកប្រទេសយើងតាមទីក្រុង ហើយហូរចូលទៅជនបទបន្តទៀត ដូច្នេះផ្នែកសិល្បៈជាតិត្រូវស្ថិតក្នុងកំរិតការពារខ្លួន ហើយនឹងដកថយតែប៉ុណ្ណោះ។ ឧបករណ៍ភ្លេងមួយចំនួន ត្រូវផ្អែកលើព្រះសង្ឃ ជាអ្នកថែទាំក្នុងវត្តអារាម។

ពេលប្រទេសធ្លាក់ក្នុងសង្គ្រាមឆ្នាំ ១៩៧០ នៅទីក្រុងមានសកម្មភាពច្រើនបន្តិច បើប្រៀបធៀបជាមួយនឹងជនបទដែលហៅថា តំបន់រំដោះនាពេលនោះ។ នៅក្នុងតំបន់រំដោះ ក្នុងចន្លោះ ១៩៧០-១៩៧៥ អាចនិយាយបានថាគ្មានរបាំបុរាណ ឧបករណ៍ភ្លេងពិណពាទ្យ (ភ្លេងព្រះរាជទ្រព្យ) ត្រូវបំផ្លាញជាបន្តបន្ទាប់ ព្រោះត្រូវបានចោទប្រកាន់ថា ជាភ្លេង ជារបាំ សំរាប់ពួកសក្តិភូមិ ហើយក្រុមភ្លេងសម័យក៏ត្រូវរលាយជា

បន្តបន្ទាប់ដែរ មានដោតល្អតែវង់ភ្លេងប្រពៃណី ដែលហៅថាភ្លេងការនៅសេសសល់បានគ្រាន់បើ។ ក្រុមសិល្បៈរបស់អង្គការមានខ្លះៗ ដែរ ដោយសំដែងតាមរបៀបថ្មី ប្រកបដោយសម្លៀកបំពាក់ខ្មៅ ឯសិល្បៈមហាជន គឺស្ទើរគ្មានតែម្តង។ ដូច្នេះសិល្បៈបុរាណខ្មែរ ខំរត់ពីទីក្រុងទៅជនបទ ដើម្បីគេចអោយផុតពីភាពរលំរលាយ តែបែរជារលំរលាយឆាប់រហ័សជាងនៅទីក្រុងទៅទៀត ហើយក្រុមតន្ត្រីសម័យដែលខំរាំងទីទៅជនបទ ក៏ត្រូវផុតជីវិតនឹងគេដែរ។

នៅទីក្រុង ទោះបីជួបការលំបាក ប៉ុន្តែអាចរក្សាបានមួយផ្នែកសំខាន់បំផុត សកលវិទ្យាល័យវិចិត្រសិល្បៈ បានរក្សា និងបណ្តុះបណ្តាលទុកនូវជួរសិល្បៈករ ដែលជាទុនមួយសំរាប់យើងនាក្រោយថ្ងៃរំដោះ។ ក្រោយថ្ងៃ ១៧ មេសា ១៩៧៥ គឺជាដំណាក់កាលរលំរលាយវប្បធម៌ខ្មែរ។ ទូទាំងប្រទេស ពេលនោះ យើងគ្មានឮសម្លេងរាំច្រៀង សម្រែកសើចសប្បាយអ្វីទាំងអស់ ក្រៅពីសម្រែកដ៏រន្ធត់នៃអ្នកជិតស្លាប់ សម្រែកក្មេងយំគួរអោយអាណិត។ ប្រសិនបើយើងបានឮតាមវិទ្យុភ្នំពេញរបស់អង្គការ ប៉ុល ពត វិញ គឺសុទ្ធតែមហាលោតផ្លោះ មហាអស្ចារ្យ ដាំៗ កុំអោយសល់ដីមួយចំអាម វាយសំរុកទាំងយប់ទាំងថ្ងៃ បន្ថែមទៅដោយការជេរប្រទេចពួកសក្តិភូមិនាយទុន ពួកប្រតិកិរិយា គិញបង្កប់ស៊ីរូងផ្ទៃក្នុង។ល។ បន្ថែមលើការបំផ្លាញមូលដ្ឋានសម្ភារៈសិល្បៈ កម្មាភិបាល និងសិល្បៈករ សិល្បៈការិនី ជាច្រើនក៏ត្រូវបានសម្លាប់ ដែលធ្វើអោយយើងបាត់នូវប្រភពទុនរបស់ជាតិផ្នែកសិល្បៈ។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ក្រោមការដឹកនាំរបស់បក្ស និងរដ្ឋយើង បានផ្តល់លទ្ធភាពអោយកម្លាំងរស់របស់ជាតិមានកម្លាំងស្ទុះទៅ

មុខយ៉ាងលឿន ធ្វើអោយវិស័យសិល្បៈរីកដុះដាល តាំងពីមជ្ឈិមរហូតដល់ជនបទ។ យើងគួររំលឹកថា រយៈពេលដំបូង យើងត្រូវជួបនឹងការលំបាកយ៉ាងខ្លាំង អាស្រ័យដោយសភាពការណ៍ប្រទេសជាតិខ្វះស្ថិរភាព ជីវភាពប្រជាជនជួបការលំបាក ខ្វះមូលដ្ឋានសម្ភារៈ ខ្វះជួរកម្មាភិបាល ដែលមានការចេះដឹងខាងសិល្បៈ។ តួលេខដែលយើងបានកត់ត្រាទុកឆ្នាំ ១៩៧៩ យើងមានសិល្បៈករ សិល្បៈការិនី ថ្នាក់ឧត្តមត្រឹមចំនួន ២០ នាក់ និងថ្នាក់មធ្យមចំនួន ៣៤២ នាក់ប៉ុណ្ណោះ ដែលបានស្ម័គ្រចិត្តចូលធ្វើការ។ ឆ្លងតាមសកម្មភាពដ៏មមាញឹក យើងបានសំរេចនូវដំណាក់កាលប្រមូលផ្តុំទុននៃសិល្បជាតិ ដែលត្រូវបាត់បង់ក្នុងរបបប៉ុល ពត។ សាលាវិចិត្រសិល្បៈ បានបើកទ្វានៅថ្ងៃ ២៧ មករា ១៩៨១ ដើម្បីចម្លងចំណេះដឹងពីសិល្បករវ័យចាស់ ទៅក្មេងជំនាន់ក្រោយ។ ពលិកម្មដ៏ធំធេងរបស់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ ផ្នែកសិល្បៈ បានបន្សល់ទុកអោយយើងនូវទុនជាតិដ៏ធំ ដែលមិនអាចកាត់ថ្លៃបាន។ ការស្រាវជ្រាវនូវអ្វីដែលបានបាត់ ឬការបង្កើតស្នាដៃថ្មីទុកអោយក្មេងជំនាន់ក្រោយ គឺសុទ្ធតែជាមរតកដ៏មានតម្លៃ ដែលយើងត្រូវថែរក្សា អោយគង់វង្ស។

ដើរព្រមនឹងការប្រមូលមកវិញនូវទុនវប្បធម៌ សិល្បជាតិ ចលនាសិល្បៈបានក្លាយទៅជាចលនាដ៏ធំទូលំទូលាយរបស់មហាជន ដែលរហូតមកដល់ពេលនេះ យើងមានសិល្បអាជីពចំនួន ៤១ ក្រុម សិល្បមហាជន ២.៩៥០ ក្រុម រួមទៅដោយក្រុមភាពយន្តចល័ត ៦០ ក្រុម និងរោងភាពយន្តចំនួន ២៩ ដែលកំពុងមានសកម្មភាពដ៏សស្រាក់សស្រាំ ក្នុងការបំរើប្រជាជននៅគ្រប់ច្រកល្ហកនៃមាតុប្រទេស។

យើងគួររំលឹកដែរថា សិល្បៈផ្នែកសូនរូប ចម្លាក់ សិប្បកម្ម សិល្បៈក៏

មានការរីកចំរើនយ៉ាងខ្លាំងដែរ។

ជាមួយនឹងការរីកចំរើនដែលយើងទទួលបានកន្លងមក យើងក៏ត្រូវគិតពីសកម្មភាពដែលត្រូវបន្ត។ យើងបានបញ្ចប់ដំណាក់កាលប្រមូលមកវិញនូវទុនដែលបានបាត់បង់ហើយ តែនៅពេលខាងមុខ តើគួរតម្រង់ទិសយ៉ាងណា ក្នុងបញ្ហាសិល្បៈ ព្រោះវាពាក់ព័ន្ធដល់ចិត្តសាស្ត្រដល់ការអប់រំមនោគមវិជ្ជា និងសីលធម៌ដែរ។ និយាយមួយបែបទៀតសិល្បៈមានចរិតសរុប វាឆ្លុះបញ្ចាំងអំពីទិដ្ឋភាពសង្គមលើគ្រប់ផ្នែក។ សភាពការណ៍បានផ្ទេរចូលដំណាក់កាលត្រូវតម្រង់ទិសហើយ ត្រូវពង្រឹងគុណភាពហើយ ព្រោះវប្បធម៌អន់ថយ ពុករលួយក៏បានកើតមានហើយដែរតាមរយៈរូបភាពចម្រៀង ហ្វីលអាសអាភាសនៃវីដេអូកាសែ្សត។ គ្មានវិធីណាផ្សេង ក្រៅពីយកសិល្បៈទប់ទល់នឹងសិល្បៈទេ។ គេមិនអាចលើកអំពីសេរីភាពនៃការកំសាន្តសប្បាយ មកធ្វើអោយប៉ះពាល់ទំនៀមទម្លាប់ វប្បធម៌ សិល្បៈដ៏ល្អប្រពៃរបស់ជាតិ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមយើងបានទេ យើងត្រូវតែមានវិធានការទប់ទល់។ ដូច្នេះ ទាមទារនូវការគ្រប់គ្រង ដឹកនាំអោយបានល្អចំពោះ ក្រុមសិល្បៈដែលមានស្រាប់ ពង្រឹងក្រុមនេះអោយក្លាយជាស្នូលសិល្បវប្បធម៌របស់ជាតិ។ ចង់បានដូច្នេះ យើងក៏ត្រូវប្រញាប់ប្រញាល់ដោះស្រាយនូវជួរកម្មាភិបាលដែលមានការចេះដឹងអំពីសិល្បៈ បញ្ជូនទៅមូលដ្ឋានហើយយើងត្រូវប្តេជ្ញា ក្រោយពីការបើកសកលវិទ្យាល័យវិចិត្រសិល្បៈបណ្តុះបណ្តាលអោយបានល្អជួរកម្មាភិបាល និងជួរសិល្បករ សិល្បការិនី។ ចំពោះសកម្មភាពភាពយន្ត វីដេអូកាសែ្សត ក៏ត្រូវមានសកម្មភាពអោយបានខ្លាំង ប្រសិនបើរដ្ឋគ្មានលទ្ធភាពផលិតទេ ត្រូវអនុញ្ញាតអោយ

ក្រុមហ៊ុន សមាគមឯកជន ផលិតក្រោមការដឹកនាំខាងខ្លឹមសាររបស់រដ្ឋ។

– បញ្ហាជំនឿ និងប្រពៃណី

ជំនឿ និងប្រពៃណី ត្រូវបានលុបបំបាត់ក្នុងរបប ប៉ុល ពត ក្នុងពេលរបបនេះកាន់អំណាច។ សាសនាទាំងអស់នៅកម្ពុជា ត្រូវលុបបំបាត់ ព្រះសង្ឃត្រូវផ្សឹក ឬត្រូវសម្លាប់ ហាក់មទូននៃឥស្លាមសាសនា ក៏ដូចគ្នា ហើយវត្តអារាម នៃសាសនាទាំងពីរត្រូវបោះបង់ចោល បំផ្លាញ ឬធ្វើជាមន្ទីឃុំឃាំង។ល។

ក្រោយពេលរំដោះ ជំនឿក៏ត្រូវបានកើតឡើងវិញ ព្រមពេលដែលវត្តអារាមត្រូវបានជួសជុល ឬធ្វើថ្មីក្រោយមកទៀត។ មកដល់ពេលនេះ ទូទាំងប្រទេសមានវត្តចំនួន ២.៣៩៧ ព្រះសង្ឃចំនួន ៦.០៨០ អង្គ វិហារឥស្លាមសាសនាចំនួន ២០ ដែលផ្តល់លទ្ធភាពអោយប្រជាជនរាប់លាននាក់ បានធ្វើបុណ្យទាន តាមលទ្ធភាព និងបំណងរបស់គេ។ រដ្ឋយើងក៏បានផ្តល់ភាពងាយស្រួលចំពោះពុទ្ធបរិស័ទ ដោយបានចាក់ផ្សាយវិទ្យុ និងទូរទស្សន៍ជាតិ នូវធម្មទេសនា និងឧបោសថសីល ដែលបានបង្កើនឡើងនូវជំនឿទុកចិត្ត និងការអបអរសាទរយ៉ាងខ្លាំងពីប្រជាជន។

ចំពោះប្រពៃណីទំនៀមទម្លាប់ ក៏ត្រូវបានគោរពយ៉ាងជាប់លាប់ចំពោះគ្រប់ជនជាតិនៅកម្ពុជា។ អាពាហ៍ពិពាហ៍ដោយបង្ខំ រាប់សិបគូក្នុងរបប ប៉ុល ពត ក៏ត្រូវលុបបំបាត់ជាស្ថាពរ គឺនារីបុរសមានសិទ្ធិពេញទីក្នុងការរើសគូស្រករ ហើយរៀបការតាមប្រពៃណី។

បញ្ហាត្រង់នេះ យើងគួរធ្វើការអប់រំប្រជាជនយើងអោយបានល្អ ព្រោះថាកន្លងមកនេះ មានទំនាស់លែងលះគ្នា ប្រពន្ធពីរបី សាហាយស្មន់ ស្រីញី ប្រុសឈ្មោល ក៏បានកើតមានយ៉ាងច្រើនណាស់ដែរ

ហើយដែលវាបង្កនូវការស្មុគស្មាញយ៉ាងច្រើន សំរាប់សង្គមផង និងគ្រួសារផង។

ក្នុងសកម្មភាពសារព័ត៌មាន ការបោះពុម្ពផ្សាយក៏បានពង្រីកសកម្មភាពដ៏ទូលំទូលាយ។ ការការពារវត្ថុបុរាណ ការពារ និងជួសជុលសម្បត្តិវប្បធម៌ ថ្វីត្បិតតែជួបការលំបាកអំពីទុន និងបច្ចេកទេស តែបក្ស និងរដ្ឋយើង បានយកចិត្តទុកដាក់យ៉ាងខ្លាំង។ សកម្មភាពកីឡា អប់រំកាយសម្ព័ន្ធ បានក្លាយទៅជាចលនាមហាជនដ៏ទូលំទូលាយ។

ពិតមែនហើយ យើងនៅមានការងារច្រើនទៀត ដែលត្រូវធ្វើ ក្នុងវិស័យវប្បធម៌ ដែលតម្រូវអោយយើងមានការប្រឹងប្រែងយ៉ាងខ្លាំង ក្នុងរយៈពេលខាងមុខនេះ។

៣. វិស័យសង្គមកិច្ច

បញ្ហាធ្ងន់ធ្ងរបំផុតដែលយើងជួបប្រទះ និងដោះស្រាយ ក្នុងការងារសង្គមកិច្ច គឺបញ្ហាកុមារកំព្រា ជនជរាពិការ ជនគ្មានទីពំនាក់ ស្ត្រីមេម៉ាយដែលមានកូនច្រើន ហើយខ្វះពលកម្ម។

របប ប៉ុល ពត គ្មានបានបន្សល់ទុកអ្វីក្រៅពីផលវិបាករាប់មិនអស់ភាពព្រាត់ប្រាស ដែលប្រទេសនានាលើសកលលោកមិនដែលបានជួបប្រទះ។ ក្រោយរបបព្រៃផ្សៃនេះដួលរលំទៅ របបថ្មីនៃយើងត្រូវដោះស្រាយនូវកិច្ចការយ៉ាងច្រើន ហើយធំៗ ដែលក្នុងនោះបញ្ហាសង្គម ក៏ចោទយ៉ាងធ្ងន់ធ្ងរ ក្នុងពេលរដ្ឋពុំមានមូលដ្ឋានសម្ភារៈ ថវិកា ដើម្បីដោះស្រាយ។ តាមស្ថិតិនាឆ្នាំ ១៩៨១ នៅទូទាំងប្រទេស មានកុមារកំព្រាសរុបចំនួន ២០៧.១០៥ នាក់ ដែលរស់នៅក្នុងមជ្ឈមណ្ឌលចិញ្ចឹមកុមារកំព្រាចំនួន ៣៤ មាន ៦.២៤២ នាក់ និងរស់នៅតាមគ្រួសារ បង

ប្អូនមីងមា មិត្តភក្តិរបស់ឪពុកម្តាយ និងគ្រួសារមានចិត្តសប្បុរសជម់ចំនួន ២០០.៨៦៣ នាក់។ នេះមិនគិតពីកុមារកំព្រា ដែលស្លាប់ឪពុកសល់ម្តាយ ឬស្លាប់ម្តាយសល់ឪពុកផងទេ។

តើយើងបានដោះស្រាយបញ្ហានេះរបៀបណា ហើយសំរេចបានលទ្ធផលយ៉ាងណា? ក្នុងសភាពការណ៍ដ៏តឹងតែងនេះ បក្ស និងរដ្ឋយើងបានចេញសេចក្តីអំពាវនាវ និងគោលនយោបាយជាបន្តបន្ទាប់ ដោយបំផុសនូវទឹកចិត្តសាមគ្គី ជួយឧបត្ថម្ភគ្នាក្នុងប្រជាជនយើង ហើយមានវិធានការជាបន្ទាន់ ក្នុងការរៀបចំឡើងនូវមណ្ឌលចិញ្ចឹមកុមារកំព្រា។ រយពេលដំបូងមានការលំបាកយ៉ាងច្រើន ព្រោះសូម្បីតែស្ថាប័នបក្ស និងរដ្ឋាភិបាល ក៏ទើបរៀបចំឡើង ហើយក្រុមគ្រួសារនៅទូទាំងប្រទេស ក៏មិនទាន់មានស្ថិរភាពដែរ។ ក្នុងគ្រាដំបូងនេះ កងទ័ពស្ម័គ្រចិត្តវៀតណាម មានតួនាទីយ៉ាងសំខាន់ ក្នុងការជួយដល់កុមារកំព្រា។ យើងនៅចាំបានថា ពួក ប៉ុល ពត បានអនុវត្តគោលនយោបាយជីកស្មៅជីកទាំងឫស ដូច្នេះ មានកុមារច្រើនណាស់ ដែលបានស្លាប់ជាមួយឪពុកម្តាយ។ ចំពោះកុមារកំព្រា ដែលមានភ័ព្វវាសនានៅរស់បាន ភាគច្រើន គេបានរស់នៅក្នុងបរិវេណប្រមូលផ្តុំនៃក្រុមកុមារ ឬកងចល័តរបស់កុមារ និងយុវជន ដែលពួក ប៉ុល ពត មិនអាចដឹងបានថា ជាកូនរបស់អ្នកណាក្នុងពេលសភាពការណ៍ផ្ទៃក្នុងរបស់ពួកវាត្រូវច្របូកច្របល់ និងមួយផ្នែកទៀត ពេលឪពុកម្តាយកុមារស្លាប់ ឬព្រាត់ប្រាស ក៏មានអ្នកចិត្តធម៌ជួយថែទាំ ក្នុងនោះមានមួយចំនួនត្រូវព្រាត់ឪពុកម្តាយតាំងពីពួក ប៉ុល ពត ជម្លៀសចេញពីទីក្រុង ហើយក៏មានមួយផ្នែកទៀត ដែលរស់នៅបាន អាស្រ័យដោយពួក ប៉ុល ពត សម្លាប់មិនទាន់ ក្នុងពេលដែលកង

ទ័ពបដិវត្ត និងកងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមករំដោះ។

ក្នុងរយៈពេលដំបូង កុមារកំព្រាមួយចំនួនត្រូវបានក្រុមគ្រួសារមានចិត្តសប្បុរសជួយយកអាសារ ហើយមួយផ្នែកទៀតត្រូវបានកងទ័ពបដិវត្ត និងកងទ័ពស្ម័គ្រចិត្តវៀតណាម ជួយចិញ្ចឹមបីបាច់ ហើយដែលចំនួននេះស្ទើរទាំងអស់ បានបញ្ជូនចូលក្នុងមជ្ឈមណ្ឌលកុមារកំព្រា នាពេលក្រោយនេះ។ កងទ័ពវៀតណាម ថ្វីត្បិតតែភារកិច្ចសំខាន់របស់គេគឺវាយខ្មាំង ប៉ុល ពត រំដោះប្រជាជនកម្ពុជា ប៉ុន្តែនៅក្បែរនោះ គេមានភារកិច្ចច្រើនទៀត ក្នុងការជួយដោះស្រាយជីវភាពប្រជាជន។ គេទាំងអស់បានចែករំលែកស្បៀងអាហារ ថ្នាំសង្កូវជូនប្រជាជន ជួយព្យាបាលជំងឺ ជួយធ្វើផ្ទះសម្បែងជូនប្រជាជន។ល។ ហើយបន្ទុកដ៏ធ្ងន់ធ្ងរមួយទៀតគឺជួយដល់កុមារកំព្រា។ ការជួយកុមារកំព្រា វាមានការខុសគ្នាជាមួយការជួយសំរាប់គ្រួសារនានា ព្រោះថាគេមិនអាចចែកអង្ករ ឬថ្នាំពេទ្យអោយហើយ ហើយអោយកុមារទាំងនោះធ្វើដំណើរដោយគ្មានគោលដៅនោះបានទេ។ ជាងនេះទៀត មានកុមារខ្លះ មិនទាំងទាន់ចេះដើរចេះនិយាយផង ដូច្នេះ គ្រប់អង្គភាពដែលបានជួបប្រទះកុមារកំព្រាសុទ្ធតែត្រូវថែទាំនៅអង្គភាពសិន ដែលតម្រូវអោយអង្គភាពទាំងនេះចែករំលែកកម្លាំងយុទ្ធជន កម្មាភិបាល សម្ភារៈ ស្បៀងអាហារ ដើម្បីចិញ្ចឹម និងថែទាំកុមារ ក្នុងគ្រាដំបូង។ យើងបានដឹងថា កម្មាភិបាលយុទ្ធជន កងទ័ពវៀតណាមមួយចំនួន សុខចិត្តដេកផ្ទាល់នឹងដី ដើម្បីយកអង្រឹងអោយកុមារកំព្រាដេក សុខចិត្តដេកខ្លួនទទេ ដើម្បីយកភួយដណ្ដប់អោយកុមារកំព្រា។ ដូច្នេះហើយបានជាមានកុមារកំព្រាជាច្រើន បានចាត់ទុកកម្មាភិបាលយុទ្ធជនវៀតណាមថា ជាឪពុកម្ដាយ

របស់គេ។ វាជាការលំបាកសំរាប់អង្គភាពដែលត្រូវប្រយុទ្ធ ឬត្រៀមប្រយុទ្ធ ហើយមានក្មេងនៅជាមួយ វាពិបាកសំរាប់ការទាក់ទងរវាងអ្នកថែទាំជាមួយកុមារ ព្រោះវៀតណាមមិនចេះភាសាខ្មែរ កុមារខ្មែរមិនចេះភាសាវៀតណាម ហើយកុមារមួយចំនួនមិនទាន់ចេះនិយាយទៀតផង។ ដូច្នេះ គេមិនអាចដឹងបានថាកុមារឈ្មោះអ្វី ឪពុកម្តាយឈ្មោះអ្វី ស្រុកកំណើតនៅឯណា ប៉ុន្តែគេអាចរស់នៅជាមួយគ្នាបាន ដូចឪពុកនិងកូន។ មានអង្គភាពកងទ័ពវៀតណាមមួយចំនួន ក៏បានជួយកសាងឡើងនូវមណ្ឌលចិញ្ចឹមកុមារកំព្រា ដូចជាមណ្ឌលកុលាប គីរឡង់ សព្វថ្ងៃនេះជាដើម។

បន្ទាប់ពីបានកសាងឡើងនូវមជ្ឈមណ្ឌលចិញ្ចឹមកុមារ យើងបានប្រមូលផ្តុំជាបន្តបន្ទាប់នូវកុមារកំព្រា។ ទាំងកងទ័ពវៀតណាម ទាំងកងទ័ពកម្ពុជា និងគ្រួសារសប្បុរសមួយចំនួន ក៏បានយកក្មេងមកទុកក្នុងមណ្ឌលទាំងនេះ ដែលតាមស្ថិតិឆ្នាំ ១៩៨០ មណ្ឌលចំនួន ៣៤ បានទទួលកុមារចំនួន ៥.៧៤០ នាក់ ក្នុងនោះកុមារីចំនួន ១.៨២៥ នាក់ ហើយដល់ឆ្នាំ ១៩៨១ មាន ៦.២៤២ នាក់ ក្នុងនោះមានកុមារីចំនួន ២.៣២៧ នាក់។ ចំពោះកុមារកំព្រាជាង ២០ ម៉ឺននាក់ទៀត ត្រូវបានញាតិមិត្ត និងគ្រួសារមានចិត្តសប្បុរសយកទៅចិញ្ចឹម។ យើងមិនអាចភ្លេចបានចំពោះគុណបំណាច់ដ៏ធំធេងរបស់គ្រួសារទាំងនោះឡើយ។ នេះជាការរួមចំណែកក្នុងការដោះស្រាយបញ្ហាសង្គមផង និងជួយអោយកុមារបានក្លាយទៅជាពលរដ្ឋដ៏ល្អរបស់សង្គមទៅថ្ងៃមុខផង។

ឆ្លងតាមសកម្មភាពរួម រវាងរដ្ឋ និងប្រជាជន ហើយមានការជួយឧបត្ថម្ភពីវៀតណាម បណ្តាប្រទេសសង្គមនិយម និងអង្គការមនុស្ស

ធម៌អន្តរជាតិនានា យើងបានដោះស្រាយបញ្ហាធំៗ និងស្មុគ្រស្មាញនេះ ប្រកបដោយជោគជ័យ។ ក្នុងសង្គមថ្មីរបស់យើង មានកុមារកំព្រាច្រើនបំផុត បើប្រៀបធៀបជាមួយសង្គមមុនៗ ប៉ុន្តែជាទូទៅ យើងគ្មានកុមារកំព្រាដេកតាមចិញ្ចើមថ្នល់ ឬធក់ប្ញន់នោះទេ។ ផ្ទុយទៅវិញ មិនត្រឹមតែយើងប្រមូលផ្តុំកុមារក្នុងមណ្ឌលកុមារកំព្រាប៉ុណ្ណោះទេ តែ បក្ស និងរដ្ឋយើងបានខិតខំយ៉ាងខ្លាំង ក្នុងការបណ្តុះបណ្តាលកុមារទាំងនេះ។ យើងមានរបបឧបត្ថម្ភ និងរបបរៀនសូត្របានយ៉ាងល្អ ដោយផ្តល់អាទិភាពយ៉ាងច្រើន ដើម្បីបង្កលក្ខណៈអោយកុមារកំព្រា បានចូលរៀននៅសាលាចំណេះទូទៅ ចូលរៀននៅឧត្តមសិក្សា មធ្យមសិក្សាឯកទេស សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងទៅរៀននៅបរទេស។ ដោយមានការជួយឧបត្ថម្ភ ពីរដ្ឋអំណាច និងប្រទេសជាមិត្ត ព្រមទាំងអង្គការអន្តរជាតិនានា គ្រប់មណ្ឌលកុមារកំព្រាសុទ្ធតែមានការបង្ហាត់បង្រៀនផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជាផ្នែកកាត់ដេរ ប៉ាក់ ត្បាញ ជាងឈើ ជាងដែក។ល។ និងការបង្កបង្កើនផល។ យើងអាចអះអាងបានថា កុមារដែលនៅក្នុងមជ្ឈមណ្ឌលកុមារកំព្រា គ្មានកុមារណាមួយមិនចេះអក្សរនោះទេ លើកលែងតែកុមារវិកលចរិក ហើយស្ទើរតែទូទៅ កុមារមានកំរិតវប្បធម៌ចាប់ពីមធ្យមសិក្សាកំរិត ១ ឡើង ហើយថែមទាំងបានចេះដឹងនូវវិជ្ជាជីវៈខ្លះផង។ ឯកុមារ ដែលរស់នៅតាមគ្រួសារ ភាគច្រើនបានរៀនសូត្រ ហើយភាគច្រើនជាកុមារមានការអប់រំល្អ។

យើងសូមលើកតួលេខនៃកុមារក្នុងមណ្ឌលកុមារកំព្រា ដែលមានការរៀនសូត្រ និងបានបណ្តុះបណ្តាល ពីឆ្នាំ ១៩៨០ មកបច្ចុប្បន្ន គឺមានសិស្សទៅបន្តការសិក្សានៅបរទេសចំនួន ១៧៧ នាក់ រៀននៅថ្នាក់

ឧត្តមសិក្សាក្នុងប្រទេស ១០២ នាក់ រៀនផ្នែកជំនាញថ្នាក់មធ្យម និង បឋម ក្នុងប្រទេសចំនួន ១.១៩១ នាក់ ចេញបំរើការងារតាមស្ថាប័នរដ្ឋ និងកងកម្លាំងប្រដាប់អាវុធចំនួន ៩១៣ នាក់ និងចេញទៅបង្កបង្កើន ផលតាមមូលដ្ឋាន ក្នុងនោះមានចំការកៅស៊ូផង ចំនួន ១.៧៣១ នាក់ ក្រៅពីនោះ នៅកំពុងបន្តរៀនសាលាចំណេះទូទៅ និងមួយចំនួនក៏ បានគូស្រករួចទៅហើយ។ ដូច្នេះចំនួនកុមារកំព្រានៅតាមមណ្ឌល មានការថយចុះ មណ្ឌលនៅសល់ត្រឹម ២៣ មណ្ឌលប៉ុណ្ណោះ។

ក្នុងបញ្ហាកុមារកំព្រា យើងក៏នៅសល់បញ្ហាដែលត្រូវដោះស្រាយ ព្រោះថា ក្រៅពីកុមារកំព្រាដែលបន្សល់ទុកពីរបប ប៉ុល ពត ក៏នៅមាន កុមារកំព្រាមួយចំនួនទៀត ដែលមានក្នុងរបបយើងដែរ ដូចជា កុមារ ត្រូវពួក ប៉ុល ពត ខ្មែរប្រតិកិរិយាសម្លាប់ឪពុកម្តាយ ក្នុងប៉ុន្មានឆ្នាំកន្លង មកនេះ កុមារកំព្រាជាកូនកម្មាភិបាល យុទ្ធជន និងប្រជាជនយើង ដែល បានចូលរួមក្នុងភារកិច្ចការពារជាតិ កុមារកំព្រាដោយឪពុកម្តាយស្លាប់ ដោយប្រការផ្សេងៗ បន្ថែមទៅដោយទារក និងកុមារកំព្រា ដែលបាន កើតឡើងដោយបញ្ហាសង្គម ដូចជាការមានកូនហើយយកទៅទុកនៅ មជ្ឈមណ្ឌលចិញ្ចឹមទារក និងកុមារ បណ្តាលមកពីកត្តាផ្សេងៗ ខុសៗ គ្នា ដែលទាំងអស់នេះតម្រូវអោយយើងត្រូវដោះស្រាយបន្តទៀត។ ចំពោះកុមារកំព្រាដែលរដ្ឋ និងប្រជាជនយើងបានជួយចិញ្ចឹមកន្លងមក ក៏ត្រូវមានដំណោះស្រាយបន្តទៀត គឺកុមារដែលរស់តាមគ្រួសារមិន ចោទបញ្ហាធំដុំទេ ព្រោះមានគ្រួសារជាអ្នករ៉ាប់រងហើយ ប៉ុន្តែចំពោះ កុមារដែលរដ្ឋចិញ្ចឹម ទោះបីគេបានធំពេញរូបពេញរាងហើយ រហូត ដល់មានគូស្រករ ក៏ដូចជាចេញបំរើការងារហើយ ក៏នៅចោទឡើង

បញ្ហាលំនៅដ្ឋាន រាប់ទាំងអ្នកនៅរៀននៅបរទេស ដែលត្រូវត្រឡប់មកវិញផង។ យើងបានឃើញនៅកន្លែងមួយចំនួន ជនកំព្រាបានចេញធ្វើការតាមស្ថាប័នរដ្ឋមែន ប៉ុន្តែត្រូវមកស្នាក់នៅក្នុងមជ្ឈមណ្ឌលកុមារកំព្រាវិញ យុវជនចូលបំពេញកងកម្លាំងប្រដាប់អាវុធ ពេលបានច្បាប់សំរាកប្រចាំឆ្នាំ អាស្រ័យដោយគេគ្មានផ្ទះសម្បែង គ្មានញាតិមិត្ត ក៏ត្រូវមកសម្រាកក្នុងមណ្ឌលកុមារកំព្រា ដែលគេធ្លាប់រស់នៅពីមុន រហូតមានគូស្រករ ហើយក៏នៅសំរាកក្នុងមណ្ឌលនោះដែរ។ ចំពោះអ្នកមានគូស្រករហើយ ប្រសិនបើជនកំព្រាទៅយកប្តី ឬប្រពន្ធដែលមានគ្រួសារមានផ្ទះសម្បែង មិនជាចោទបញ្ហាទេ ប៉ុន្តែនៅពេលដែលគេរៀបការហើយកំព្រាដូចគ្នា គឺគេគ្មានកន្លែងណាស្នាក់នៅក្រៅពីមណ្ឌលកុមារកំព្រា ដែលគេធ្លាប់រស់នៅនោះឡើយ។ ដូច្នេះ ខាងមុខនេះទាមទារអោយគ្រប់ថ្នាក់ គ្រប់ផ្នែក ត្រូវគិត ហើយដោះស្រាយ ពិសេសចំពោះរដ្ឋអំណាចមូលដ្ឋាន និងផ្នែកដែលទទួលកុមារកំព្រាអោយចូលធ្វើការ។ ពិសោធន៍នៅខេត្តកោះកុងធ្វើបានល្អ។ ខេត្តកោះកុងបានទទួលយកកុមារកំព្រាពីខេត្តកណ្តាល ទៅចូលបំរើការងារនៅស្ថាប័នជុំវិញខេត្ត។ ខេត្តបានកសាងផ្ទះសំរាប់ស្នាក់នៅជាគ្រួសារតែម្តង ព្រោះយុវជនយុវនារី ត្រូវរៀបអាពាហ៍ពិពាហ៍ដោយស្ថាប័នដែលទទួលយកយុវជនយុវនារីនោះ ជាអ្នកផ្សំផ្គុំអោយតែម្តង។ នៅចំការកៅស៊ូក៏ដោះស្រាយបានល្អបង្គួរ។ ប្រការដែលសំខាន់មួយទៀតក្នុងបញ្ហានេះ គឺត្រូវជំរុញការបណ្តុះបណ្តាលកុមារកំព្រាដែលសព្វថ្ងៃកំពុងបន្តរៀន ដោយផ្តល់អាទិភាពអោយបានកាន់តែច្រើនសំរាប់គេចូលរៀន នៅគ្រប់ភូមិសិក្សា និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាទិភាពក្នុងការជ្រើសរើស ចូលបំរើការងារក្នុងស្ថាប័នបក្ស និង

រដ្ឋ ក៏ដូចជាមូលដ្ឋានផលិតកម្ម។ យើងត្រូវតែប្តេជ្ញាមិនទុកអោយកុមារកំព្រាពីមុននេះក្លាយជាជនអនាថា ខ្វះទីបង្អែកនៅពេលដែលគេធំឡើងនោះឡើយ។

យើងគួររំលឹកដែរថា ក្នុងចំណោមកុមារកំព្រាដែលរស់នៅក្នុងមជ្ឈមណ្ឌល និងរស់តាមគ្រួសារ ក៏មានមួយចំនួនមានឪពុក ឬម្តាយនៅបរទេស អាស្រ័យដោយត្រូវព្រាត់ប្រាសក្នុងពេលសង្គ្រាម ឬក្នុងរបប ប៉ុល ពត តែ បក្ស និងរដ្ឋយើង តែងតែបានបង្កលក្ខណៈអោយទៅរួមរស់ជាមួយឪពុកម្តាយតាមការស្នើសុំ ហើយក៏បានអនុញ្ញាតអោយជនបរទេសមួយចំនួន បានយកកុមារកំព្រាទៅជួយចិញ្ចឹមនៅឯបរទេសដែរ។

ក្រៅពីកុមារកំព្រា ក៏នៅមានជនជរាពិការ ជនអនាថាផ្សេងទៀតដែលតម្រូវអោយបក្ស និងរដ្ឋយើង ដោះស្រាយដែរ ដែលក្នុងនោះទាមទារអោយយើងរៀបចំនូវ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអោយគេរៀនសូត្រឈានទៅមានលំនឹងក្នុងជីវិត ហើយដែលការងារនេះតម្រូវអោយយើងចំណាយថវិកាអស់ច្រើនដែរ។ ចំពោះស្ត្រីមេម៉ាយដែលមានកូនច្រើន គ្រួសារខ្វះកម្លាំងពលកម្ម គ្រួសារយុទ្ធជនពលី ពិការ ដែលនៅតាមមូលដ្ឋានក៏មានចំនួនយ៉ាងច្រើន ដែលដំណោះស្រាយនេះ ទាមទារនូវស្មារតីជួយឧបត្ថម្ភទំនុកបំរុងពីប្រជាជន។ ហើយការរៀបចំឡើងនូវក្រុមសាមគ្គីបង្កបង្កើនផល បានរួមចំណែកដល់ការដោះស្រាយបញ្ហានេះ។ បន្ថែមលើនេះ បក្ស និងរដ្ឋយើង ក៏នៅមានការកិច្ចដោះស្រាយគោលនយោបាយសមរភូមិក្រោយ ចំពោះគ្រួសារយុទ្ធជន ដែលកំពុងនៅក្នុងជួរកងកម្លាំងប្រដាប់អាវុធ គ្រួសារពលករការពារដែលទៅចូលរួមការពារមាតុភូមិ នៅឯព្រំដែន ហើយដែល ការងារនេះថ្វីត្បិតតែមានការប្រឹងប្រែងច្រើន ប៉ុន្តែក៏នៅមិនទាន់បានល្អជាទូទៅនៅ

ឡើយ ដែលទាមទារអោយខិតខំដោះស្រាយជាបន្តទៀត។

ចំពោះយុទ្ធជនពិការ បញ្ហានេះរមែងកើតមាននៅប្រទេសដែលមានសង្គ្រាមដូចយើង។ រយៈពេល ១០ ឆ្នាំនៃសង្គ្រាម ដែលពោរពេញទៅដោយពលិកម្មរបស់ប្រជាជនយើង ដើម្បីការពារជាតិ ការពារសមិទ្ធិផលបដិវត្ត ការពារភាពសុខសាន្តរបស់ប្រជាជន ប្រឆាំងការវិលត្រឡប់នៃរបប ប៉ុល ពត ក៏បានបន្សល់ទុកអោយយើង នូវជនពិការរាប់ពាន់នាក់។ បក្ស និងរដ្ឋយើង បានខិតខំដោះស្រាយចំពោះបញ្ហានេះ ប៉ុន្តែអាចនិយាយបានថា យើងធ្វើមិនទាន់បានល្អនៅឡើយ ហើយដែលវាជះឥទ្ធិពលអាក្រក់ដល់សង្គម ដល់ស្មារតីប្រយុទ្ធរបស់កងទ័ព និងការស្ម័គ្រចិត្តចូលបំរើកងទ័ពរបស់យុទ្ធជនយើង។ ការអប់រំបណ្តុះបណ្តាលការគ្រប់គ្រងចំពោះយុទ្ធជនពិការធ្វើមិនបានល្អ ហើយដែលមានកន្លែងខ្លះនិងពេលខ្លះ ធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមទៀតផង។ ខាងមុខនេះ ទាមទារនូវការពិនិត្យឡើងវិញ ហើយខិតខំដោះស្រាយអោយបានល្អ សំខាន់គឺបណ្តុះបណ្តាលវប្បធម៌ និងមុខជំនាញវិជ្ជាជីវៈអោយដល់យុទ្ធជនពិការ ដែលនៅសេសសល់សមត្ថភាពពលកម្ម ហើយស្ថាប័នបក្ស និងរដ្ឋបាល ត្រូវខិតខំទទួលយកចូលបំរើការងារស្របតាមលទ្ធភាពនៃជនពិការ ដូចជាការងាររដ្ឋបាលនៅតាមមន្ទីរក្រសួង ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ចំពោះអ្នកមានសមត្ថភាព ហើយមានសីលធម៌ល្អដែលអាចធ្វើការបានដូចជា ដាច់ដៃម្ខាងខ្វាក់ភ្នែកម្ខាង។ល។ យើងគួររៀបចំតម្លើងថ្នាក់ជាកម្មាភិបាលអោយកាន់ការងារសំខាន់ៗ ផង។ យើងមិនគួរប្រមូលផ្តុំយុទ្ធជនពិការ នៅតាមជំរំចិញ្ចឹមយុទ្ធជនពិការរយៈពេលយូរ ដោយគ្មានការរៀនសូត្រ គ្មានការងារធ្វើនោះទេ លើកលែង

តែអ្នកបាត់សមត្ថភាពពលកម្មទាំងស្រុង ឬជិតទាំងស្រុង ដែលរដ្ឋត្រូវទទួលបន្ទុកថែទាំជារៀងរហូតទៅ។ ចំពោះអ្នកនៅធ្វើការបានខ្លះ គួររៀបចំអោយគេធ្វើការ ហើយមានករណីខ្លះ នៅតំបន់ដែលជានាសន្តិសុខ យើងគួរបញ្ជូនទៅអោយគ្រួសារជួយថែទាំ ដោយរដ្ឋយើងផ្តល់បៀវត្សតាមការកំណត់។ ធ្វើយ៉ាងនេះ យុទ្ធជនពិការអាចកសាងគ្រួសារបាន ប្រសិនបើយើងបន្តប្រមូលផ្តុំក្នុងជំរំយុទ្ធជនពិការ គឺពិបាកក្នុងការកសាងគ្រួសារ ជាងនៅមូលដ្ឋាន។

៤.វិស័យសុខាភិបាល

វិស័យសុខាភិបាល ក៏ដូចជាវិស័យផ្សេងទៀតដែរ គឺត្រូវបំផ្លិចបំផ្លាញរហូតដល់ឫសគល់។ មន្ទីរពេទ្យ មូលដ្ឋានសម្ភារៈបំរើអោយការពិនិត្យ និងព្យាបាលជំងឺ បំរើអោយការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ គឺត្រូវបំផ្លាញខ្ទេចខ្ទី ហើយវេជ្ជបណ្ឌិត ឱសថការី និងគ្រូពេទ្យគ្រប់ផ្នែកគ្រប់ថ្នាក់ ព្រមទាំងនិស្សិតពេទ្យរាប់ពាន់នាក់ ត្រូវបានសម្លាប់យ៉ាងសែនព្រៃផ្សៃ។ សុខភាពប្រជាជនដែលសេសសល់ពីការស្លាប់ត្រូវទ្រុឌទ្រោមយ៉ាងខ្លាំង។

ក្រោយពេលរំដោះ ថ្ងៃ ៧ មករា ១៩៧៩ បក្ស និងរដ្ឋយើង បានប្រមូលផ្តុំជាបន្ទាន់នូវជួរគ្រូពេទ្យ ដែលនៅសេសសល់ពីការស្លាប់ ហើយដំណើរការរៀបចំភ្លាមនូវមន្ទីរពេទ្យនៅមជ្ឈិម ៣ កន្លែង និងប៉ុស្តិ៍សង្គ្រោះចំនួន ១០០ កន្លែង។ ជាមួយនោះក៏បានដំណើរការស្តារ និងរៀបចំឡើងវិញជាបន្តបន្ទាប់នូវមូលដ្ឋានព្យាបាលជំងឺ ដែលត្រូវខូចខាតពីជំនាន់របប ប៉ុល ពត។ ដល់ចុងឆ្នាំ ១៩៧៩ យើងសំរេចស្តារ និងរៀបចំឡើងវិញនូវមូលដ្ឋានព្យាបាលជំងឺ បានចំនួន ៦០៥ កន្លែង ក្នុង

នោះមានមន្ទីរពេទ្យនៅមជ្ឈិម ៣ មន្ទីរពេទ្យខេត្តក្រុង ១១ មន្ទីរពេទ្យស្រុក ១០៧ និងគិលានដ្ឋានឃុំ ៤៨៤ ដែលមានគ្រែសរុបចំនួន ៧.៥៧៥ គ្រែ ជាមួយនឹងការប្រមូលបុគ្គលិក អោយចូលធ្វើការបានចំនួន ៦.៤៧៥ នាក់ ក្នុងនោះមានវេជ្ជបណ្ឌិត ៣៣ នាក់ ឱសថការី ២៦ នាក់ គ្រូពេទ្យមធ្យម ១២ នាក់ ទន្តពេទ្យ ៣០ នាក់ គិលានុប្បដ្ឋាកចំនួន ៣.២៣៩ នាក់ និងឆ្មបចំនួន ៣៤២ នាក់។

ក្នុងគ្រាដំបូងនេះ យើងត្រូវជួបនឹងការលំបាកច្រើនយ៉ាងណាស់ ក្នុងការរៀបចំឡើងវិញនូវបណ្តាញសុខាភិបាល។ ពិតមែនតែយើងបានរៀបចំឡើងនូវមន្ទីរពេទ្យ ប៉ុន្តែយើងខ្វះសម្ភារៈបរិក្ខា ខ្វះថ្នាំសង្កូវ ខ្វះនូវជួរកម្មាភិបាលដឹកនាំគ្រប់គ្រង និងជួរគ្រូពេទ្យៗល។ ព្រមពេលជាមួយគ្នានោះ អ្នកជំងឺមានចំនួនយ៉ាងច្រើន និងមានច្រើនប្រភេទ ហើយដែលធ្ងន់ធ្ងរបំផុតនោះ គឺជំងឺគ្រុនចាញ់ និងខ្វះជីវជាតិ។ ដើម្បីដោះស្រាយនូវការងារដ៏បន្ទាន់ និងធ្ងន់ធ្ងរនេះ វៀតណាមបានចាត់បញ្ជូនមកកម្ពុជានូវវិជ្ជបណ្ឌិត ឱសថការី និងជួរគ្រូពេទ្យយ៉ាងច្រើន ព្រមទាំងសម្ភារៈបរិក្ខា ថ្នាំសង្កូវ និងមធ្យោបាយផ្សេងទៀត ដើម្បីអោយបណ្តាមន្ទីរពេទ្យ ក៏ដូចជាប៉ុស្តិ៍សង្គ្រោះចាប់ដំណើរការ។ នៅទីក្រុងមួយចំនួន ពិសេសនៅមូលដ្ឋាន មន្ទីរពេទ្យ និងពេទ្យតាមអង្គភាពកងទ័ពវៀតណាម បានជួយយ៉ាងច្រើនក្នុងការពិនិត្យ និងព្យាបាលជំងឺជូនប្រជាជនយើង។ ហើយជាបន្តបន្ទាប់ ពិសេសចាប់តាំងពីឆ្នាំ ១៩៨០ មក យើងបានទទួលជំនួយខាងវិស័យសុខាភិបាលពីសហភាពសូវៀត បណ្តាប្រទេសសង្គមនិយម និងឥណ្ឌា ហើយចាប់ពីឆ្នាំ ១៩៨០ មកដែរ យើងក៏បានទទួលជំនួយដ៏ច្រើនបន្ថែរពីអង្គការអន្តរជាតិនានា ក្នុងនោះមានការជួយរបស់

កាកបាទក្រហមអន្តរជាតិ និងអ៊ុយនីសេហ្វ ដែលឧបត្ថម្ភទុនពីអង្គការសហប្រជាជាតិ និងប្រទេសប៉ែកខាងលិចមួយចំនួន ក្នុងកម្មវិធីជំនួយជាបន្ទាន់អោយកម្ពុជា ដែលក្នុងជំនួយនោះមានក្រុមគ្រូពេទ្យសំរាប់ធ្វើការនៅមន្ទីរពេទ្យខេត្តមួយចំនួនផង។ នៅមានអង្គការអន្តរជាតិ និងប្រទេសមួយចំនួន បានជួយដោយផ្ទាល់ក្នុងការកសាង និងជួយដល់ដំណើរការមន្ទីរពេទ្យមួយចំនួន ដូចជាអង្គការជំនួយប្រជាជនបារាំង អង្គការទស្សនពិភពលោក កាកបាទក្រហមស៊ុីស ស៊ុយអែដ បារាំង។ល។ សហភាពសូវៀត ក៏បានជួយស្តារឡើងវិញ និងជួយដល់ដំណើរការមន្ទីរពេទ្យដ៏ធំនៅទីក្រុងភ្នំពេញ។ គុយបា ប៊ុលការី សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ឥណ្ឌា និងប្រទេសមួយចំនួនទៀតក៏បានជួយជាសម្ភារៈ បរិក្ខា ថ្នាំពេទ្យ និងបុគ្គលិកពេទ្យ សំរាប់ដំណើរការនៅមន្ទីរពេទ្យមួយចំនួនដែរ។ ជារួម ក្នុងវិស័យសុខាភិបាល យើងបានទទួលជំនួយពីច្រើនប្រភព ដែលអនុញ្ញាតអោយយើងបានចេញផុតពីដំណាក់កាលដែលលំបាកបំផុត ហើយឈានទៅស្ថិរភាពជាជំហានៗ។

ឆ្លងតាមរយៈនៃការប្រឹងប្រែងផ្ទាល់របស់ប្រជាជនយើង និងការជួយឧបត្ថម្ភពីសំណាក់បរទេស រហូតដល់ឆ្នាំ ១៩៨៨ នេះ យើងពង្រីកបាននូវមូលដ្ឋានព្យាបាលជំងឺឡើងរហូតដល់ ១.៧២៥ កន្លែង ខេត្ត ក្រុង ២៩ កន្លែង ស្រុក ១៥៧ កន្លែង និងគិលានដ្ឋានឃុំចំនួន ១.៥៣១ កន្លែង ដែលមានគ្រែសរុបចំនួន ១៨.៦៤២ គ្រែ ឯមូលដ្ឋានសម្ភារៈបច្ចេកទេសក៏បានប្រសើរឡើងជាងឆ្នាំកន្លងដែរ។

ដើម្បីឆ្លើយតបនឹងកង្វះខាតធ្ងរកម្មាភិបាល បុគ្គលិកសុខាភិបាល មហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រ បានត្រូវបើក

ទ្វារ តាំងពីថ្ងៃ ១០ ខែ មករា ១៩៨០ គឺមួយឆ្នាំក្រោយពេលប្រទេសបានរំដោះ ហើយសាលាសុខាភិបាលនៅមជ្ឈិម និងខេត្ត ក្រុង មួយចំនួនក៏បានបើកទ្វារជាបន្តបន្ទាប់ដើម្បីទទួលសិស្ស និស្សិតអោយចូលរៀនដែរ។ គិតមកដល់ឆ្នាំ ១៩៨៨ នេះ យើងបណ្តុះបណ្តាលកម្មាភិបាល បុគ្គលិកសុខាភិបាលគ្រប់ថ្នាក់គ្រប់ផ្នែក បានសរុបចំនួន ១២.៨៨០ នាក់ ក្នុងនោះមានវេជ្ជបណ្ឌិតចំនួន ៥២៧ នាក់ ឱសថការីចំនួន ២៤០ នាក់ ទន្តបណ្ឌិតចំនួន ៣៤ នាក់ផង ហើយសាលាកំពុងបន្តបណ្តុះបណ្តាលនូវសិស្ស និស្សិតប្រមាណជាង ២ ពាន់នាក់ជាប្រចាំទៀតផង ដែលនឹងត្រូវចេញធ្វើការជាបន្តបន្ទាប់នាបណ្តាឆ្នាំខាងមុខ។ ជាមួយនឹងការរីកចំរើនរយៈពេលកន្លងមកនេះ យើងនៅមានបញ្ហាសេសសល់ជាច្រើនដែលត្រូវបន្តដោះស្រាយ។ យើងគ្រាន់តែបានឆ្លងផុតនូវដំណាក់កាលដែលលំបាកបំផុតតែប៉ុណ្ណោះ គឺមិនមានន័យថា គ្មានការលំបាកដែលត្រូវពុះពារតទៅទៀតនោះឡើយ។ មូលដ្ឋានព្យាបាលជំងឺមានការកើនឡើង ប៉ុន្តែមានមូលដ្ឋានជាច្រើនមិនទាន់សមរម្យជាមន្ទីរពេទ្យនៅឡើយ។ នៅមជ្ឈិម និងខេត្តក្រុង មានការជានាល្អបង្គួរ ប៉ុន្តែមន្ទីរពេទ្យនៅថ្នាក់ស្រុក និងគិលានដ្ឋានឃុំ នៅយ៉ាប់យ៉ឺនមែនទែន។ យើងមានមន្ទីរពេទ្យមានបុគ្គលិកពេទ្យច្រើនបង្គួរ ប៉ុន្តែសម្ភារៈបរិក្ខា ថ្នាំសង្កូវ សំរាប់ការពិនិត្យនិងព្យាបាលជំងឺនៅខ្វះខាតធ្ងន់ធ្ងរ ដែលពេលខាងមុខនេះ យើងត្រូវខិតខំពង្រីកនូវមូលដ្ឋានពិនិត្យ និងព្យាបាលជំងឺដែលមានរួចហើយព្រមទាំងខិតខំបំពាក់នូវឧបករណ៍ សម្ភារៈ សំរាប់មូលដ្ឋានទាំងនេះដំណើរការផង។

ចំពោះជួរគ្រូពេទ្យ ថ្វីត្បិតតែមានការកើនឡើង ប៉ុន្តែជាទូទៅមិនទាន់

ឆ្លើយតបតាមសំណូមពរនៅឡើយ ពិសេសថ្នាក់វេជ្ជបណ្ឌិត ឱសថការី គ្រូពេទ្យថ្នាក់មធ្យម។ ប្រៀបធៀបនឹងចំនួនដែលមានសព្វថ្ងៃ ជាមួយចំនួនប្រជាជន ឃើញថានៅតិចពេកណាស់។ បន្ថែមពីលើនេះ ចំនួននេះក៏រាយមិនស្មើផង គឺខេត្តខ្លះទើបមានវិជ្ជបណ្ឌិតតែ ២ ឬ ៣ នាក់ប៉ុណ្ណោះ។ ការបញ្ជូនវិជ្ជបណ្ឌិតដែលបានបញ្ចប់ការសិក្សាថ្មី ទៅធ្វើការនៅបណ្ដាខេត្ត ក្រុង ត្រូវជួបនឹងការលំបាក ដែលតម្រូវអោយយើងត្រូវតែកែប្រែនូវរបៀបជ្រើសរើសសិស្ស និស្សិត តាមរបៀបផ្ដល់អាទិភាពអោយខេត្ត ក្រុងបញ្ជូនសិស្ស និស្សិត មករៀនអោយបានច្រើន ហើយក្រោយពេលបញ្ចប់ការសិក្សា យកត្រឡប់ទៅធ្វើការនៅមូលដ្ឋាននោះវិញ។ ចំពោះការជឿនលឿនក្នុងផ្នែកបច្ចេកទេស វិទ្យាសាស្ត្ររបស់យើងក៏នៅទាប បើប្រៀបធៀបជាមួយប្រទេស ដែលមានការជឿនលឿន ដូច្នេះក៏ចាំបាច់ត្រូវគិត និងដោះស្រាយបញ្ហានេះ ដោយត្រូវធ្មៀតទទួលយកការជួយឧបត្ថម្ភពីបរទេស តាមរយៈនៃការបញ្ជូននិស្សិត ឬវេជ្ជបណ្ឌិត ឱសថការី យើងទៅរៀនសូត្រយកចំណេះថ្មីៗមកបណ្ដុះបណ្ដាលបន្តអោយសិស្ស និស្សិតយើងនៅក្នុងប្រទេស។

កង្វះថ្នាំសង្កូវជាបញ្ហាដ៏ធ្ងន់ធ្ងររបស់យើង រយៈពេលកន្លងមក ក៏ដូចជាពេលខាងមុខ។ ក្នុងមន្ទីរពេទ្យរបស់រដ្ឋ អ្នកជំងឺមួយចំនួន ពេទ្យយើងគ្រាន់តែបានជួយពិនិត្យប៉ុណ្ណោះ ឯថ្នាំព្យាបាល អ្នកជំងឺដោះស្រាយខ្លួនឯង លើមុខថ្នាំមួយចំនួនដែលរដ្ឋគ្មាន។ រដ្ឋយើងផលិតបាននូវថ្នាំពេទ្យមួយចំនួនដែរ និងបានប្រើប្រាស់រូបិយប័ណ្ណនាំចូលមកមួយចំនួន ព្រមទាំងទទួលជំនួយអន្តរជាតិបន្ថែមមួយចំនួនផង ប៉ុន្តែនៅតែមិនអាចឆ្លើយតបបានជាមួយសេចក្ដីត្រូវការដ៏ធំធេងនោះបានឡើយ។ ជា

មួយនោះ ការគ្រប់គ្រងរបស់យើង ក៏មិនទាន់បានល្អដែរ ដែលកាន់តែធ្វើអោយមន្ទីពេទ្យរដ្ឋខ្វះថ្នាំព្យាបាលជំងឺ។ ឱសថបុរាណ ថ្វីត្បិតតែមានការផលិត និងប្រើប្រាស់ ប៉ុន្តែក៏មិនទាន់បើកទូលាយនៅឡើយ ការព្យាបាលជំងឺទូទៅ ត្រូវផ្អែកស្ទើរទាំងស្រុងលើថ្នាំសម័យ។ ការគ្រប់គ្រងចំពោះឯកជនធ្វើអាជីវកម្មលក់ថ្នាំពេទ្យ ក៏ធ្វើមិនទាន់បានល្អ គឺការលក់ថ្នាំពេទ្យតាមចិញ្ចើមថ្នល់ តាមផ្សារ តាមតូប នៅមានជាទូទៅ ហើយប្រការគ្រោះថ្នាក់ជាងនេះទៀត គឺការផលិត និងលក់ថ្នាំក្លែងក្លាយ ដែលធ្វើអោយប៉ះពាល់សុខភាព និងគ្រោះថ្នាក់ដល់អាយុជីវិតប្រជាជន។ រដ្ឋាភិបាលមានគោលការណ៍បើកឱសថស្ថាន ឱសថស្ថានរង ដើម្បីបំព្រួញរហូតទៅបញ្ចប់នូវការលក់ថ្នាំតាមចិញ្ចើមថ្នល់ តាមផ្សារ តែការអនុវត្តរបស់មូលដ្ឋានធ្វើដោយយឺតយ៉ាវ មិនត្រឹមតែប៉ុណ្ណោះ ទុកអោយឱសថស្ថានរង ដែលបានបើករួចហើយមានលទ្ធភាពផ្តាច់មុខតម្លើងថ្លៃថ្នាំពេទ្យតាមទំនើងចិត្ត។ ទស្សនៈខុសឆ្គងមួយរបស់ផ្នែកសុខាភិបាល និងមូលដ្ឋាន គឺក្នុងពេលមិនព្រមអនុញ្ញាតិអោយបើកបន្ថែមនូវឱសថស្ថាននោះ បែរជានាំគ្នាចង់លុបបំបាត់នូវការលក់ថ្នាំតាមផ្សារ តាមតូប ដែលជាប្រការមិនអាចធ្វើទៅបាន ហើយដែលនាំទៅដល់ការកើតឡើងនូវផ្សារងងឹត ក្នុងការលក់ថ្នាំពេទ្យ ហើយឱសថស្ថានដែលបានបើករួចហើយ កាន់តែបានដៃក្នុងការតម្លើងថ្លៃថ្នាំពេទ្យ ដែលធ្វើអោយប្រជាជនកាន់តែជួបការលំបាក។ ដើម្បីបំព្រួញ ឬលុបបំបាត់ការលក់ថ្នាំពេទ្យមិនត្រឹមត្រូវ ចាំបាច់ត្រូវបើកឱសថស្ថាន ឱសថស្ថានរងអោយបានច្រើន។ គេមានលទ្ធភាពប្រមូលបងប្អូនដែលកំពុងលក់តាមតូប តាមផ្សារអោយចូលដើមទុនជាមួយគ្នា ដើម្បីបើកឱសថស្ថាន ដូច្នេះយើងអាចកាត់

បន្ថយបាននូវអ្នកលក់មិនត្រឹមត្រូវ ហើយងាយស្រួលត្រួតពិនិត្យជាង។ យើងត្រូវផ្តល់លទ្ធភាពងាយស្រួលអោយអាជីវកម្ម ដែលនាំចូលថ្នាំពេទ្យ ហើយត្រូវគ្រប់គ្រងអោយបានល្អ ទាំងបច្ចេកទេស ទាំងពន្ធដារ និងត្រូវសម្រួលអោយការផ្ញើថ្នាំពេទ្យតាមរយៈប្រៃសណីយ៍រដ្ឋយើង ពីសំណាក់ជនកម្ពុជានៅបរទេស មកបងប្អូនគេនៅក្នុងប្រទេស។ លុះត្រាតែមានការគួបផ្សំរវាងលទ្ធភាពរបស់រដ្ឋ ជាមួយលទ្ធភាពរបស់ប្រជាជន ទើបយើងអាចដោះស្រាយបាននូវកង្វះឱសថដ៏ធ្ងន់ធ្ងរនេះ។ ជាមួយនោះដែរ ត្រូវបំផុសចលនាផលិត និងការប្រើប្រាស់ឱសថបូរាណអោយបានកាន់តែច្រើន ដើម្បីកាត់បន្ថយនូវការលំបាកអំពីកង្វះថ្នាំពេទ្យ។

ការប្រឆាំងនឹងជំងឺគ្រុនចាញ់ ជំងឺរាតត្បាត ជំងឺកូនក្មេង នៅជាបញ្ហាបច្ចុប្បន្នភាពមួយ ដែលត្រូវប្រយុទ្ធដោះស្រាយ។ អត្រាស្លាប់ដោយជំងឺគ្រុនចាញ់នៅខ្ពស់នៅឡើយ ពិសេសនៅតំបន់ព្រៃភ្នំ តំបន់ព្រំដែនកម្ពុជា-ថៃ។ អត្រាស្លាប់នៃកុមារ ថ្វីត្បិតតែបានកាត់បន្ថយ ប៉ុន្តែក៏នៅខ្ពស់នៅឡើយ។ ចលនាចាក់ថ្នាំការពារកុមារ ថ្វីត្បិតតែមានយុទ្ធនាការធំៗ ជាច្រើន ដែលបំផុសដោយរដ្ឋាភិបាល និងក្រសួងសុខាភិបាល ហើយដោយមានការជួយឧបត្ថម្ភពីអង្គការអ៊ុយនីសេហ្វផងក៏ដោយ ក៏ចលនានេះទើបតែមានការផុលផុសនៅទីក្រុងតែប៉ុណ្ណោះ។ ឯនៅជនបទធ្វើបានតិចតួចណាស់ ម្យ៉ាងដោយរដ្ឋខ្វះមធ្យោបាយ ខ្វះបុគ្គលិក ម្យ៉ាងទៀតដោយការអប់រំចំពោះប្រជាជនមិនបានល្អ ដែលជាហេតុធ្វើអោយគេមិនយកកុមារមកចាក់ថ្នាំការពារ។ កិច្ចការចាក់ថ្នាំការពារកុមារ យើងមានទុនជាបន្ទុរ សំខាន់គឺថ្នាំ អាស្រ័យដោយមានការជួយឧបត្ថម្ភ ពីអន្តរជាតិ ដូច្នេះត្រូវបន្តការងារនេះអោយបានខ្លាំងជាងនេះទៀត ដែលក្នុងនោះត្រូវយកចិត្តទុកដាក់ដល់ការ

*ផ្សារឃោសនាអប់រំក្នុងប្រជាជន ដោយដើរទន្ទឹមនឹងការចាត់តាំងអនុវត្ត។*

*ក្នុងវិធានការការពារជំងឺជាទូទៅ ក៏ត្រូវតែបានយកចិត្តទុកដាក់ ដែលក្នុងនោះគឺចលនាអនាម័យ ប្រឆាំងនឹងជំងឺគ្រប់ប្រភេទ។ ការងារនេះយើងធ្វើបានតិច មិនទាន់ក្លាយជាចលនាមហាជននៅឡើយ។ ចលនាអនាម័យតាមបុគ្គល តាមគ្រួសារ វាជាការចាំបាច់ហើយ តែលុះត្រាតែមានចលនាមហាជន ទើបអនាម័យជាសាធារណៈអាចធ្វើទៅបាន។ ដូច្នេះក៏ទាមទារនូវការឃោសនា អប់រំអោយបានកាន់តែច្រើន តាមគ្រប់លទ្ធភាព និងមធ្យោបាយ។*

**ផ្នែកទី ៣**

# ការកសាងកម្លាំង

# ការកសាងកម្លាំង

*យើងសែនមានមោទនភាពអំពីការរីកចំរើននៃកម្លាំងបដិវត្តកម្ពុជា ដែលជាកម្លាំងកំណត់សំរេចនូវជ័យជំនះរបស់បដិវត្ត ក្នុងការផ្តួលរំលំរបប ប៉ុល ពត និងក្នុងការការពារ និងកសាងប្រទេសរយៈពេល ១០ ឆ្នាំកន្លងទៅ។*

*យើងគួររំលឹកឡើងវិញអំពីប្រវត្តិដើម និងដំណើរវិវត្តនៃការកសាងកម្លាំងរបស់យើង ដែលជាដំណើរប្រកបដោយការលំបាក ប៉ុន្តែពោរពេញទៅដោយមោទនភាព។*

*ក្រោមរបបប្រល័យពូជសាសន៍ ប៉ុល ពត ជនបដិវត្ត និងអ្នកស្នេហាជាតិជាច្រើន បានត្រូវកាប់សម្លាប់។ ជនបដិវត្ត និងអ្នកស្នេហាជាតិមួយចំនួន បានបង្កើតឡើងនូវចលនាតស៊ូ មានដោយដាច់ដោយដុំ និងកន្លែងខុសៗគ្នា ដើម្បីប្រឆាំងនឹងរបប ប៉ុល ពត ហើយចលនាតស៊ូ បានរីកដុះដាលកាន់តែច្រើនឡើង។ ក្រោយព្រឹត្តិការណ៍បះបោរទូទាំងភូមិភាគបូព៌ាទិស នាខែ ឧសភា ១៩៧៨ កម្លាំងតស៊ូបានកើនឡើងយ៉ាងច្រើន ហើយបានឈានទៅដល់ការប្រមែប្រមូលគ្នា ដើម្បីរៀបចំចាត់តាំងឡើងនូវអង្គការដឹកនាំការតស៊ូមានឈ្មោះហៅថា «រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា» ដែលជារណសិរ្សឯកភាពកម្លាំងប្រឆាំងរបប ប៉ុល ពត ហើយក៏ជាកត្តាជ័យជំនះថ្ងៃ ៧ មករា ១៩៧៩ និងក៏ជាប្រភពកម្លាំងដើម្បីកសាង និងការពារមាតុភូមិ ១០ ឆ្នាំកន្លងមក។ គួររំលឹកថាក្នុងចំណោមអ្នកស្នេហាជាតិ ដែលបានចូលរួមក្នុងដំណើរការរំដោះ*

ជាតិ គឺមានបក្ខជនល្អបរិសុទ្ធរបស់បក្សមួយចំនួន បានចូលរួមដឹកនាំចលនានេះ។ បក្ខជនទាំងនេះ ថ្វីត្បិតតែបានចាកចេញពីជួរបក្ស ដែលត្រូវ ប៉ុល ពត បំផ្លិចបំផ្លាញក៏ដោយ ក៏គេមិនបានបោះបង់ចោលនូវឧត្តមគតិដើមរបស់បក្ស ដែលជាបក្សម៉ាក្សឡេនីនដ៏បរិសុទ្ធត្រឹមត្រូវនោះដែរ។ បណ្តាសមមិត្តទាំងនេះ នៅស្វះស្វែងរិះរកវិធី ដើម្បីកសាងបក្សឡើងវិញ ដើម្បីដឹកនាំចលនារំដោះប្រជាជាតិ។ គេអាចដឹងបានហើយថា បក្សប្រជាជនបដិវត្តកម្ពុជា មានដើមកំណើតពីបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលលោកប្រធាន ហូ ជីមិញ បានបង្កើតឡើង។ ព្រមពេលដែលរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា អំពាវនាវសុំការជួយឧបត្ថម្ភពីកងទ័ពវៀតណាម ដើម្បីរំដោះប្រជាជនកម្ពុជា ក្រុមបក្ខជនរបស់បក្ស ក៏បានលើកសំណូមពរផងដែរ នូវការជួយឧបត្ថម្ភក្នុងការកសាងកម្លាំងលើគ្រប់ផ្នែក។ មហាសន្និបាតបក្សលើកទី ៣ ដែលមានឈ្មោះហៅថា «មហាសន្និបាតដើម្បីកសាងបក្សឡើងវិញ» ត្រូវបានធ្វើឡើង ដោយមានការចូលរួមពីបក្ខជនចំនួន ៦២ នាក់ តំណាងអោយបក្ខជនប្រមាណជាង ២០០ នាក់ ដែលកំពុងធ្វើសកម្មភាព នៅច្រើនទីកន្លែងខុសៗគ្នា។ មហាសន្និបាតបានដំណើរការពីថ្ងៃទី ៥ ដល់ថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៧៩ ក្នុងពេលដែលយុទ្ធនាការរំដោះប្រទេសកំពុងប្រព្រឹត្តទៅ។ ឆ្លងតាមមហាសន្និបាតនេះ មាគ៌ានយោបាយក្នុង និងក្រៅប្រទេស ព្រមទាំងមាគ៌ាកសាងបក្សឡើងវិញ ត្រូវបានដាក់ចេញ ហើយគណៈកសាងបក្សមួយ ដែលក្រោយនេះជាគណៈកម្មាធិការមជ្ឈិមបក្ស ត្រូវបានជ្រើសតាំងឡើង។ ចប់មហាសន្និបាត មាតុភូមិកម្ពុជាត្រូវបានរំដោះទាំងស្រុងពីក្រញាំដៃពួកស្រេកឈាម ប៉ុល ពត។ ភារកិច្ច

ដឹកនាំប្រទេសត្រូវធ្លាក់មកលើបក្សប្រជាជនបដិវត្តកម្ពុជា ក្នុងពេលដែលរបបនាសម័្ពន្ធសង្គម ជាទូទៅត្រូវបំផ្លិចបំផ្លាញគ្មានសល់ ឯជួរកម្មាភិបាលក៏មានតិចតួច សភាពការណ៍ពោរពេញទៅដោយភាពច្របូកច្របល់ គ្រោះអត់ឃ្លានកំរាមកំហែងទូទាំងប្រទេស ហើយការប៉ុនប៉ងដណ្តើមអំណាចវិញ របស់ពួក ប៉ុល ពត ក៏នៅតែជាគ្រោះថ្នាក់ដ៏សំខាន់នៅឡើយ។ នេះជាអំរែកដ៏ធ្ងន់ធ្ងរ តែឧត្តុងឧត្តមរបស់បក្ស ដែលត្រូវតែទទួលរែកពន់នូវភារកិច្ចជាប្រវត្តិសាស្រ្តនេះ។

បណ្តាអ្នកដឹកនាំបក្សយើង និងបណ្តាអ្នកដឹកនាំបក្សកុម្មុយនិស្តវៀតណាម តែងបានផ្លាស់ប្តូរយោបល់គ្នា ហើយសុទ្ធតែបានសន្និដ្ឋានដូចៗគ្នាថា «បដិវត្តន៍កម្ពុជា គឺអាស្រ័យដោយប្រជាជនកម្ពុជា ជាអ្នកធ្វើ គ្មានអ្នកណាធ្វើជំនួសប្រជាជនកម្ពុជាបានឡើយ»។ ពិតមែនបដិវត្តន៍កម្ពុជាបាននិងកំពុងប្រើប្រាស់កម្លាំងពីរគួបផ្សំគ្នា ប៉ុន្តែវៀតណាមអាចជួយបានសំខាន់លើការងារការពារប្រឆាំងការវិលត្រឡប់របស់ ប៉ុល ពត ប្រឆាំងការគំរាមកំហែងពីខាងក្រៅ ដើម្បីការពារឯករាជភាពរបស់កម្ពុជា និងការសុខសាន្តរបស់ប្រជាជន ជួយបានលើការបណ្តុះបណ្តាលកម្មាភិបាល ផ្តល់អ្នកបច្ចេកទេស និងជំនួយផ្សេងៗទៀត តាមសំណូមពរកម្ពុជា។ ប៉ុន្តែលើការដឹកនាំគ្រប់គ្រងរដ្ឋអំណាច ការសំរេចលើបញ្ហាទាំងអស់ ដែលទាក់ទងដល់ជោគវាសនា និងការឈានទៅមុខរបស់កម្ពុជា គឺអាស្រ័យដោយប្រជាជនកម្ពុជាជាអ្នកសំរេច វៀតណាម ឬបរទេសផ្សេងទៀតមិនអាចធ្វើការងារនេះបានឡើយ។ វាពិតយ៉ាងដូច្នេះមែន បើប្រជាជនកម្ពុជា មិនក្រោកឈរឡើងធ្វើភារកិច្ចការពារ និងកសាងប្រទេសរបស់ខ្លួនទេ គឺគ្មាននរណាធ្វើជំនួសបានឡើយ ព្រោះការជួយរបស់វៀតណាម និង

ប្រទេសផ្សេងទៀតគឺជាកត្តាសំខាន់មិនអាចខ្វះបាន តែកត្តាកំណត់ជោគជ័យ ឬបរាជ័យ គឺអាស្រ័យលើកត្តាផ្ទៃក្នុងដែលជាប្រជាជនកម្ពុជានេះឯង។

ការតស៊ូដើម្បីរំដោះប្រជាជន រំដោះប្រជាជាតិ វាជាបញ្ហាលំបាកណាស់ទៅហើយ ប៉ុន្តែការការពាររដ្ឋអំណាច និងការធ្វើអោយប្រទេសឈានទៀង វាកាន់តែលំបាកជាង ហើយសំខាន់ទៅទៀត គឺការត្រូវគ្រប់គ្រងរដ្ឋអំណាច ក្នុងសភាពការណ៍សង្គមទាំងមូលច្របូកច្របល់ ជួរកម្មាភិបាលមានតិច ហើយខ្មាំងសត្រូវចិញ្ចឹមចិត្តវាយបក ដណ្តើមរដ្ឋអំណាចទៅវិញ។ ការលំបាកនេះ វាមានច្រើនលើសលប់ បើប្រៀបធៀបនឹងការងាយស្រួល។ ការងាយស្រួលរបស់យើង គឺទឹកចិត្តស្នេហាជាតិ និងស្នេហាសេរីភាពរបស់ប្រជាជន និងការចងកំហឹងរបស់ប្រជាជន ចំពោះរបប ប៉ុល ពត បានបង្កើតឡើងនូវចលនាតស៊ូដ៏ខ្លាំងសំបើមនៅជុំវិញរដ្ឋអំណាចថ្មី ហើយដែលជាកម្លាំងការពាររដ្ឋអំណាចថ្មី។ ម៉្យាងទៀត ប្រពៃណីរបស់ប្រជាជនកម្ពុជា គឺជាប្រពៃណីសាមគ្គីជួយគ្នា ចេះប្រមូលផ្តុំជួយគ្រប់គ្រងថែរក្សាគ្នា រហូតដល់កន្លែងជាច្រើន គេចេះរៀបចំជ្រើសតាំងឡើង នូវអ្នកដឹកនាំថ្នាក់ក្រុម ភូមិ មុនពេលរដ្ឋអំណាចខាងលើណែនាំទៀតផង ជាហេតុសម្រួលអោយរដ្ឋអំណាច ក្នុងការគ្រប់គ្រងប្រជាជន។

ជួរកម្មាភិបាលមានតិច តែត្រូវគ្រប់គ្រងប្រទេសទាំងមូល ហើយម្តងនេះ មិនមែនធ្វើតែនយោបាយ យោធា ដូចពេលតស៊ូ រំដោះជាតិឡើយ គឺត្រូវធ្វើការងារគ្រប់វិស័យ តាំងពីកិច្ចការគ្រប់យ៉ាង នៅក្នុងប្រទេស រហូតដល់ការទាក់ទងអន្តរជាតិទៀតផង។

តើយើងបានធ្វើដំណើររបៀបណា ហើយមានជំហានរីកចំរើនយ៉ាង

ណា ក្នុងការកសាងកម្លាំងរយៈពេល ១០ ឆ្នាំ កន្លងមកនេះ។ ការលើកឡើងនៅក្នុងផ្នែកទី ១ និងផ្នែកទី ២ នៃសៀវភៅនេះ ក៏បានបង្ហាញពីការរីកចំរើន ក្នុងការកសាងកម្លាំងមួយផ្នែកធំរួចទៅហើយ ឯការលើកឡើងនៅទីនេះ សំខាន់បំផុត គឺសំដៅទៅលើការកសាងបក្ស ដែលជាកត្តាកំណត់បំផុតក្នុងជោគជ័យនៃបដិវត្តន៍ និងការកសាងជួរកម្មាភិបាល និងរដ្ឋអំណាចបដិវត្ត។

បក្សយើងចូលគ្រប់គ្រងអំណាច មានសភាពខុសប្លែកពី លន់ នល់ ចូលកាន់អំណាច ដោយគេបានទទួលបន្តលើរចនាសម្ព័ន្ធមានស្រាប់ ជួរអ្នករដ្ឋការមានស្រាប់ ហើយក៏ប្លែកពី ប៉ុល ពត ចូលត្រួតត្រាអំណាច ដោយគេបានកសាងរដ្ឋអំណាចនៅតំបន់រំដោះ លើចំណែកភាគច្រើននៃដែនដីនៅជនបទអស់រយៈពេល ៥ ឆ្នាំកន្លងមកហើយ ហើយ ប៉ុល ពត ក៏មិនពិបាកដល់ការគ្រប់គ្រង ឬកសាងទីក្រុងឡើយ ព្រោះការអនុវត្តន៍នយោបាយបំផ្លាញ វាងាយស្រួលជាងការអនុវត្តន៍នយោបាយកសាង។ បក្សយើងចូលកាន់រដ្ឋអំណាច ក្នុងសភាពការណ៍ដែលរចនាសម្ព័ន្ធសង្គមត្រូវខ្ទេចខ្ទី ខ្វះជួរកម្មាភិបាល និងក្នុងសភាពការណ៍ច្របូកច្របល់។ យើងត្រូវវាយរំដោះប្រទេសក្នុងពេលដ៏ខ្លី រដ្ឋអំណាចនៅជនបទក៏មានតិចតួចណាស់ ហើយមានរយៈពេលខ្លីផង ដូច្នេះយើងត្រូវធ្វើនូវការងារជាច្រើនក្នុងពេលជាមួយគ្នា គឺត្រូវគ្រប់គ្រងរដ្ឋអំណាច តាំងពីមូលដ្ឋានរហូតដល់មជ្ឈិម និងទូទាំងប្រទេស ក្នុងពេលជាមួយគ្នា។ នេះជាចំណុចពិសេសដោយឡែករបស់បក្សយើង ក្នុងដំណាក់កាលដំបូងនៃការគ្រប់គ្រងរដ្ឋអំណាច ដែលវាខុសពីប្រទេសនានា ប៉ុន្តែយើងបានឆ្លងរួចផុតនូវការលំបាកនេះ។ ចំណុចលេចធ្លោឡើង ក្នុងការកសាង

និងពង្រឹងរដ្ឋអំណាចគឺវិធីចាស់ដើងនៃកម្លាំងពីរគួបផ្សំគ្នា គឺវៀតណាម ធ្វើការកិច្ចជាកម្លាំងទប់កុំអោយ ប៉ុល ពត ដណ្ដើមអំណាចវិញ និង វាយកំទេចពួក ប៉ុល ពត ជាបន្ត ឯកម្លាំងបដិវត្តន៍កម្ពុជាធ្វើការកិច្ច កសាង និងពង្រឹងរដ្ឋអំណាច ក៏ដូចជាការងារផ្សេងទៀត។

**ចំណុចពិសេសនៃប្រទេសយើង គឺត្រូវកសាងបក្ស និងរដ្ឋអំណាចពី លើចុះក្រោម** អាស្រ័យដោយយើងមានជួរកម្មាភិបាលតិចពេក បក្ខជន មានតែជាង ២០០ នាក់ ប៉ុណ្ណោះ ដែលយើងរៀបចំបានតែនៅមជ្ឈិម និងថ្នាក់ខេត្ត ក្រុង ពោលគឺស្ថាប័ននៅមជ្ឈិមនីមួយៗ មានកម្មាភិបាល តិចតួច ពីរ ឬបីនាក់ ជាបង្គោល ហើយ ខេត្ត ក្រុង មានកម្លាំងច្រើន បន្ថែរបន្ថែមទៅដោយកងទ័ពមួយ ឬពីរកងវរសេនាតូច ឯថ្នាក់ស្រុក និងឃុំ នៅចន្លោះប្រហោងស្ទើរទាំងស្រុង។ ពេលនោះបក្សយើងបាន រៀបចំនូវក្រុមប្រតិបត្តិការនៅថ្នាក់ស្រុក ដោយរួមមានទាំងស៊ីវិល និង កងទ័ព ធ្វើការកិច្ចវាយខ្មាំងផង ចលនាចាត់តាំងប្រជាជនផង និងដើរតួ នាទីជារដ្ឋអំណាចថ្នាក់ស្រុកផង។ ក្រុមប្រតិបត្តិការនេះ បានដំណើរ ការរៀបចំឡើងនូវរដ្ឋអំណាចថ្នាក់ឃុំ។ ឯនៅថ្នាក់ភូមិ មានកន្លែងមួយ ចំនួន ត្រូវក្រុមប្រតិបត្តិការ រៀបចំ ឬឃុំរៀបចំបន្ត ឯកន្លែងមួយចំនួន ទៀត គឺប្រជាជនជ្រើសរើសដោយខ្លួនគេ ដែលបង្កនូវភាពងាយស្រួល ជាច្រើនដល់រដ្ឋអំណាចខាងលើ។ ក្នុងសភាពការណ៍នេះ ពួក ប៉ុល ពត ក៏បានខិតខំយ៉ាងខ្លាំង ដើម្បីប្រែក្លាយរដ្ឋអំណាចមូលដ្ឋានរបស់ យើងអោយទៅជារដ្ឋអំណាចមុខពីរ។

ក្នុងរយៈមិនយូរប៉ុន្មាន ខ្សែរយៈ និងរចនាសម្ព័ន្ធរដ្ឋអំណាច បានកើត ឡើងជារូបរាងនៅទូទាំងប្រទេស ប៉ុន្តែជួរកម្មាភិបាលនៅមានចំនួនតិច

តូច ហើយគុណភាព និងរបៀបរបបដឹកនាំធ្វើការងារនៅខ្សោយនៅឡើយ។

បក្សយើងបានដាក់ចេញនូវគោលការណ៍ដែលចាត់ទុកថា ជាគន្លឹះចាំបាច់ និងបន្ទាន់បំផុត **គឺការកសាងបក្ស និងជួរកម្មាភិបាលគ្រប់ផ្នែក។** កិច្ចការនេះ ជួបការលំបាកច្រើនក៏ពិតមែន ប៉ុន្តែក៏មានកត្តាងាយស្រួលជាមូលដ្ឋានដែរ។ កត្តាងាយស្រួលជាមូលដ្ឋាននេះ គឺទឹកចិត្តស្នេហាជាតិរបស់ប្រជាជនកម្ពុជា និងការចង់កំហឹងរបស់ប្រជាជនទៅលើរបបប្រល័យពូជសាសន៍របស់ ប៉ុល ពត បានប្រែក្លាយជាចលនាដ៏ធំធេងប្រមូលផ្តុំជុំវិញបក្ស និងរដ្ឋអំណាចថ្មី ដើម្បីការពារ និងកសាងប្រទេស។ ឆ្លងតាមចលនាមហាជនក្នុងបដិវត្តន៍ បានលេចចេញឡើងនូវកម្មាភិបាលល្អៗសកម្ម មានសមត្ថភាព ដែលជាប្រភពងាយស្រួលអោយយើងធ្វើការជ្រើសរើសកសាងជួរកម្មាភិបាល។ តាំងពីក្រោយថ្ងៃរំដោះ បញ្ញវន្តសិស្ស និស្សិត សាស្ត្រាចារ្យ គ្រូបង្រៀន និងអ្នកមានសមត្ថភាពផ្សេងទៀតដែលសេសសល់ពីការស្លាប់ សេសសល់ពីការជម្លៀសចូលទៅប្រទេសថៃ ហើយដែលមិនព្រមរត់ចោលស្រុក បានស្ម័គ្រចិត្តចូលរួមធ្វើការនៅតាមស្ថាប័ននានា និងថ្នាក់នានា ដែលជាភាពងាយស្រួលអោយបក្ស និងរដ្ឋយើងដែលកំពុងត្រូវការអ្នកចេះដឹង ដើម្បីកសាងប្រទេសឡើងវិញ។

បញ្ហាចោទឡើងនៅពេលបន្ទាប់ គឺការបណ្តុះបណ្តាល បំពាក់បំប៉នខាងនយោបាយបច្ចេកទេស និងរបៀបដឹកនាំធ្វើការងារ។ យើងបានចាប់ផ្តើមភ្លាមនូវការបើកសាលានយោបាយទ្រឹស្តី និងមុខជំនាញផ្សេងៗ នៅមជ្ឈិម និងខេត្ត ក្រុង ប៉ុន្តែសាលាទាំងនេះ ក៏មិនអាចឆ្លើយតបបានគ្រប់

គ្រាន់ឡើយ។ បក្សយើងក៏បានលើកសំណូមពរជាមួយវៀតណាម សហភាពសូវៀត និងប្រទេសសង្គមនិយមនានា ដើម្បីជួយក្នុងការងារបណ្តុះបណ្តាលជួរកម្មាភិបាល។ ការជួយឧបត្ថម្ភរបស់វៀតណាម សហភាពសូវៀត និងប្រទេសនានា ក៏បានរួមចំណែកយ៉ាងច្រើនដល់ការកសាងជួរកម្មាភិបាលកម្ពុជាក្នុងគ្រាដំបូងនេះ ទោះបីជារត់មិនទាន់សេចក្តីត្រូវការនៅឡើយក៏ដោយ ប៉ុន្តែក៏បានកសាងគ្រឹះសំរាប់ការឈានឡើងជាបន្តទៀតដែរ។

ក្នុងរយៈពេលដំបូងនេះ ការពង្រីកបក្ខជនធ្វើបានតិចតួចណាស់ កន្លែងខ្លះនៅមជ្ឈិម និងខេត្ត ក្រុង ស្ទើរតែគ្មានផង។ ឯចាប់ពីថ្នាក់ស្រុកចុះ គឺគ្មានតែម្តង ព្រោះនៅទីនោះគ្មានបក្ខជន។ នៅមជ្ឈិម ស្ថាប័នខ្លះគ្មានបក្ខជន ហើយស្ថាប័នជាច្រើនគ្មានសាខាបក្ស ដែលតម្រូវអោយរៀបចំឡើងនូវសហព័ន្ធសាខាបក្ស ដើម្បីអោយបក្ខជនមានជីវភាពបក្សផង និងកសាងបក្សផង។

ដើម្បីធ្វើជាមូលដ្ឋានអោយការកសាងបក្ស ធានាបានទាំងបរិមាណទាំងគុណភាព បក្សយើងបានអនុវត្តវិធីតក្ជាប់ គឺផ្តើមចេញពីការកសាងជួរកម្មាភិបាល ឈានទៅកសាងបក្សដោយឆ្លងតាមរយៈនៃក្រុមស្នូល។ ខែមេសា ឆ្នាំ ១៩៧៩ មជ្ឈិមបក្ស បានចេញសេចក្តីសំរេចរៀបចំឡើងនូវអង្គការចាត់តាំងក្រុមស្នូល ដែលជាអង្គការចាត់តាំងមួយរបស់បក្សហើយនាគ្រាដំបូងនេះ ក្រុមស្នូលទទួលភារៈដឹកនាំនៅកន្លែង ដែលគ្មានសាខាបក្ស។ ក្រុមស្នូលក៏ជាកន្លែងអប់រំនូវទ្រឹស្តីមនោគមវិជ្ជា របស់បក្ស ជាថ្នាលដើម្បីបណ្តុះបណ្តាលមនុស្ស សំរាប់ចូលទៅក្នុងជួរបក្ស។ នៅខេត្ត ក្រុងមួយចំនួន ដែលមិនមានបក្ខជនគ្រប់គ្រាន់ ដើម្បីបង្កើត

ឡើងនូវគណៈអភិបាលកិច្ចការបក្ស គឺបានជ្រើសរើសជនស្នូលល្អ បំពេញបន្ថែមជាសមាជិក ដូច្នេះគណៈអភិបាលកិច្ចការបក្ស នាពេលនោះ មានទាំងបក្ខជន និងមានទាំងសមាជិកក្រុមស្នូលផង។ កន្លែងមួយចំនួនដោយបក្ខជនតិច មិនអាចចាត់តាំងជាសាខាបក្ស ឬ សហព័ន្ធសាខាបក្សបាន យើងបានបញ្ចូលបក្ខជនចូលទៅធ្វើជីវភាព នៅក្នុងក្រុមស្នូល ម្យ៉ាងដើម្បីរក្សានូវជីវភាពរបស់បក្ខជនផង ម្យ៉ាងទៀតដើម្បីជួយដឹកនាំក្រុមស្នូលផង។ វិធីនេះ គឺជាវិធីដ៏ល្អដើម្បីកសាងបក្សបានឆាប់ផង ហើយធានាបាននូវលក្ខណសម្បត្តិផង។

ស្ថានភាពរបស់បក្សយើង បានចែកចេញជាបីដំណាក់កាល។ ដំណាក់កាលទីមួយ ពី ១៩៧៩ ដល់ ១៩៨១ ដែលក្នុងដំណាក់កាលនេះ បក្សមានចំនួនតិចតួចណាស់ ហាក់ដូចជាគ្រាន់តែជាក្រុមមនុស្សជឿនលឿនមួយក្រុមប៉ុណ្ណោះ។ ប៉ុន្តែទោះបីយ៉ាងនេះក្តី ភាពត្រឹមត្រូវអំពីមាគ៌ានយោបាយ បានបង្ហាញពីតួនាទីរបស់បក្សក្នុងការដឹកនាំប្រទេសជាតិ និងជាបក្សនយោបាយពិតប្រាកដ ដែលជាកត្តាកំណត់សំរេចក្នុងជ័យជំនះរបស់បដិវត្តន៍។ ក្នុងរយៈពេលនេះ ដោយមានការកើនឡើងនៃបរិមាណបក្ខជន គឺកើនពីចំនួនជាង ២០០ នាក់ មកជាង ៩០០ នាក់ បក្សយើងក៏បាន បើកមហាសន្និបាតតំណាងទូទាំងប្រទេសរបស់បក្សលើកទី ៤។ មហាសន្និបាតបានវាយតម្លៃឡើងវិញ នូវសភាពការណ៍ និងដាក់ចេញនូវមាគ៌ា ក្នុងប្រទេស ក្រៅប្រទេស ព្រមទាំងទិសដៅកសាងបក្ស។ បក្សយើងនៅតែចាត់ទុកបញ្ហាកសាងបក្ស និងជួរកម្មាភិបាល ជាភារកិច្ចគន្លឹះសំខាន់តទៅទៀត។

ដំណាក់កាលទី ២ គឺចន្លោះពីមហាសន្និបាតបក្សលើកទី ៤ (១៩៨១)

ដល់មហាសន្និបាតបក្សលើកទី ៥ (១៩៨៥) ដែលក្នុងដំណាក់កាលនេះ បក្ខជនបានកើនឡើងយ៉ាងច្រើនអំពីបរិមាណ គឺឡើងដល់ទៅ ៧.៥០០ នាក់ ប៉ុន្តែមិនទាន់បានចុះទៅក្នុងមូលដ្ឋាន និងមហាជននៅឡើយ។ រយៈពេលនេះ បក្សហាក់ដូចជាបក្សរបស់កម្មាភិបាល ព្រោះបក្ខជនភាគច្រើននៅពេលនោះ សុទ្ធសឹងជាកម្មាភិបាលសំខាន់ៗ នៅជុំវិញមជ្ឈិម ក៏ដូចជានៅជុំវិញខេត្ត ក្រុង ហើយបើនៅថ្នាក់ស្រុក ភាគច្រើនគឺជាកម្មាភិបាលស្រុក តែបើមាននៅថ្នាក់ឃុំ ក៏ភាគច្រើនជាប្រធានអនុប្រធានឃុំតែប៉ុណ្ណោះ។ មានកន្លែងមួយចំនួន កសាងបក្សដោយមានរបង ពោលគឺបើកម្មាភិបាលថ្នាក់លើ ឬប្រធាន អនុប្រធាន ចូលបក្សមិនទាន់បានទេនោះ ថ្នាក់ក្រោម ឬសមាជិក ទោះជាល្អយ៉ាងណាក៏ដោយ ក៏ចូលបក្សមិនទាន់បានដែរ គឺត្រូវរង់ចាំអោយកម្មាភិបាលខាងលើចូលបក្សសិន។ នេះជាកំហុសនៅកន្លែងមួយចំនួន ក្នុងការកសាងបក្ស។ ក្នុងដំណាក់កាលនេះ នៅមជ្ឈិមគ្រប់ស្ថាប័នមានសាខាបក្សដឹកនាំ ហើយស្ទើរគ្រប់ខេត្តមានគណៈកម្មាធិការបក្សបណ្តោះអាសន្ន។ ស្រុកមួយចំនួនក៏មានសាខាបក្ស ឃុំមួយចំនួនមានបក្ខជន ហើយឃុំមួយចំនួនតូចមានសាខាបក្ស ឬសហព័ន្ធសាខាបក្ស។

ដំណាក់កាលទីបី ពី ១៩៨៥ រហូតបច្ចុប្បន្ន គឺជាដំណាក់កាលបក្សបានពង្រឹង និងពង្រីកខ្លួន ដោយបានចុះមូលដ្ឋាន និងក្នុងមហាជន។ មហាសន្និបាតបក្សលើកទី ៥ ក៏នៅតែបន្តកំណត់ថា ការកសាងបក្ស និងជួរកម្មាភិបាល នៅតែជាភារកិច្ចមានអត្ថន័យ សំរេចកំណត់ក្នុងជ័យជំនះរបស់បដិវត្តន៍។ ដើម្បីធ្វើអោយមូលដ្ឋានមានបក្ខជន មជ្ឈិមបានបន្តការចាត់តាំងក្រុមប្រតិបត្តិការកសាងបក្ស ចុះទៅជួយកសាង

បក្សនៅមូលដ្ឋាន ហើយដែលការងារនេះ បានដំណើរការខ្លះហើយ ពីឆ្នាំ ១៩៨៣-១៩៨៤។ គួបផ្សំរវាងបក្ស សាខាបក្សមានស្រាប់ និងក្រុមប្រតិបត្តិការកសាងបក្ស ប៉ុន្មានឆ្នាំក្រោយមក បក្សយើងមានឫសចុះដល់មូលដ្ឋាន ក្នុងរោងចក្រ សហគ្រាស មន្ទីរពេទ្យ សាលារៀន កសិដ្ឋាន និងដល់ថ្នាក់ឃុំ ហើយក្នុងកម្លាំងប្រដាប់អាវុធ កងវរសេនាតូចទាំងអស់មានសាខាបក្ស ឬគណបក្ស កងអនុសេនាធំមានបក្ខជន ឬសាខាបក្សឯនៅថ្នាក់វរសេនាធំ កងពលតូច កងពលធំ យោធភូមិភាគ យោធាខេត្តសុទ្ធតែមានគណបក្សនៅតាមថ្នាក់រៀងៗខ្លួន។ ការកសាងបក្សនៅក្នុងរយៈពេលនេះ មានភាពងាយស្រួលច្រើន ដោយបក្ខជន និងអង្គការចាត់តាំងរបស់បក្សបានពង្រាយនៅគ្រប់ទីកន្លែង ងាយស្រួលដល់ការពិនិត្យសំរេចបញ្ចូលបក្ស ម្យ៉ាងដោយជួរកម្មាភិបាល ក្រុមស្នូល សម្ព័ន្ធយុវជន ដែលជាថ្នាលបណ្តុះបណ្តាលបក្ស បានលត់ដំច្រើនឆ្នាំហើយដែរ និងម្យ៉ាងទៀត ដោយចលនាបដិវត្តទាំងបីរបស់មហាជននៅតែជាស្នូល និងជាម៉ែត្រវាស់អំពីលក្ខណសម្បត្តិសំរាប់វិនិច្ឆ័យ ក្នុងការកសាងបក្ស (ចលនាបដិវត្តទាំងបីរបស់មហាជន ដែលបក្សបានដាក់ចេញតាំងពីគ្រាដំបូង គឺចលនាវាយខ្មាំង និងអូសទាញខ្មាំង ចលនាបង្កបង្កើនផល ធ្វើអោយមានស្ថិរភាពក្នុងជីវភាពប្រជាជន និងចលនាកសាងកម្លាំងពិតបដិវត្ត)។ បក្សជាបក្សរបស់ប្រជាជន ដូច្នេះប្រជាជនដើរតួនាទីដ៏សកម្ម ក្នុងការកសាងបក្ស។ ការស្តាប់សួរយោបល់របស់មហាជនក្នុងការសំរេចបញ្ចូលបក្ស ការដាក់អោយមហាជនទិតៀនកសាងបក្ស គឺបានធានាអោយបក្ខជន និងអង្គការចាត់តាំងបក្ស មានគ្រប់លក្ខណសម្បត្តិ ធានាគុណភាព និងផ្សារភ្ជាប់បក្សជាមួយប្រជាជន រាំងបាន

នូវដំណើរខុសឆ្គងរបស់បក្សចំពោះប្រជាជន។ នេះជាគោលការណ៍យកប្រជាជន មហាជន ធ្វើជាគ្រឹះ ដែលបក្សយើងបានប្រកាន់យ៉ាងខ្ជាប់ខ្ជួន។

តាមតួលេខបញ្ចប់នៅត្រីមាសទី ៣ ឆ្នាំ ១៩៨៨ នេះ បក្ខជនយើងបានកើនឡើងរហូតជាង ២២.០០០ នាក់ ដែលមានជីវភាពនៅសាខាបក្សជិត ៣.០០០ ដែលក្នុងនោះមានសាខាបក្សនៅឃុំជាង ១.០០០ សាខា និងស្រុកខណ្ឌស្ទើរទាំងអស់ មានគណបក្ស។ ពិនិត្យតួលេខនេះបើប្រៀបធៀបទៅនឹងចំនួនប្រជាជន ឃើញថា នៅមានសមាមាត្រទាបនៅឡើយ ប៉ុន្តែបើប្រៀបធៀបទៅនឹងឆ្នាំ ១៩៧៩ ដែលពេលនោះយើងមានបក្ខជនតែជាង ២០០ នាក់នោះ ឃើញថា ចំនួននេះបានកើនឡើងខ្ពស់ណាស់។ នៅក្បែរនេះ ថ្នាលសំរាប់បណ្តុះបណ្តាលបក្ស គឺក្រុមស្នូល និងសម្ព័ន្ធយុវជន ក៏មានរាប់ម៉ឺននាក់ទៀត ទាំងអស់នេះ គឺជាភាពងាយស្រួល សំរាប់ការកសាងបក្សនៅពេលខាងមុខ។ ប្រៀបធៀបនឹងឆ្នាំ ១៩៧៩ បើពេលនោះ បក្ខជនមួយនាក់ក្នុងមួយឆ្នាំ កសាងបានបក្ខជនបីនាក់ សរុបមួយឆ្នាំ គឺកសាងបានតែ ៦០០ នាក់ប៉ុណ្ណោះ ប៉ុន្តែក្នុងពេលនេះ បើបក្ខជនមួយនាក់ ក្នុងមួយឆ្នាំ កសាងបានតែមួយនាក់ ក៏មួយឆ្នាំយើងនឹងកសាងបានរហូតដល់ទៅជាង ២២.០០០ នាក់ ដែលនឹងធ្វើអោយជួរបក្ខជនកើនឡើងរហូតដល់ជាង ៤៤.០០០ នាក់ ភ្លាមដែរ។

មិនមែនគ្រាន់តែបរិមាណទេ ដែលបក្សបានយកចិត្តទុកដាក់ បញ្ហាសំខាន់គឺគុណភាពបក្ស ដូច្នេះការអប់រំបំពាក់បំប៉ននូវទ្រឹស្តីនយោបាយគឺជាការងារដែលត្រូវដើរមុខមួយជំហាន។ បក្សយើងបានខិតខំយ៉ាងខ្លាំងចំពោះការងារនេះ ហើយត្រូវធ្វើជាទូទៅក្នុងប្រជាជន និងជួរកម្មាភិបាល ដូច្នេះបក្ខជនដែលបានចូលបក្ស ក៏សុទ្ធតែបានទទួលការអប់រំ

ស្រាប់ហើយដែរ។ ចូលក្នុងជួរបក្ស កំរិតទ្រឹស្តីនយោបាយកាន់តែខ្ពស់ បក្ខជនក៏កាន់តែមានការយល់ដឹង និងភ្ញាក់រលឹកច្រើន ដូច្នេះហើយបាន ជាបទល្មើសវិន័យរបស់អង្គការចាត់តាំងបក្ស និងបក្ខជនបានត្រូវរារាំង។ ប៉ុន្មានឆ្នាំមកនេះ បក្ខជនត្រូវវិន័យ ឬត្រូវបណ្តេញពីជួរបក្សមានកំរិត យ៉ាងទាប។

ទោះជាស្ថិតក្នុងដំណាក់កាល មានបក្ខជនតិចតួច ហើយមាននៅតែ ខាងលើក៏ដោយ ហើយរហូតដល់ដំណាក់កាលបក្ស បានពង្រីក និង ពង្រឹងខ្លួនទៅក្នុងមូលដ្ឋាន និងក្នុងមហាជន ក៏ជានិច្ចកាល បក្សនៅតែ មានភាពរឹងប៉ឹង និងមានភាពត្រឹមត្រូវអំពីមាគ៌ា ដែលសមស្របតាម ផលប្រយោជន៍របស់ប្រជាជន តំណាងផលប្រយោជន៍ពិតប្រាកដ របស់ប្រជាជន។ បក្សហ៊ានទទួលស្គាល់នូវកំហុសចំពោះមុខប្រជាជន អំពីគោលការណ៍ខ្លះ ដែលមិនសមស្រប ហើយអាចធ្វើការកែលំអ ដូច្នេះហើយ បានជាបក្សអាចពង្រីកពង្រឹងខ្លួនបាន ហើយដឹកនាំការ បដិវត្តន៍ឆ្លងកាត់នូវដំណាក់កាលដែលលំបាកបំផុត។ គ្មានមហាជនគាំ ទ្រ បក្សមិនអាចពង្រីកខ្លួនបានឡើយ ហើយរដ្ឋអំណាចក៏មិនអាចស្ថិត ស្ថេរ ឬរីកចំរើនបានដែរ។

និយាយអំពីការរីកចំរើនក្នុងការកសាងបក្ស គេអាចដឹងបានច្បាស់ នូវការរីកចំរើននៃជួរកម្មាភិបាល និងរចនាសម្ព័ន្ធរដ្ឋអំណាចបដិវត្ត។ វិធីតភ្ជាប់ពីការងារកសាងជួរកម្មាភិបាល ដើម្បីកសាងបក្ស ឬទ្រឹស្តី «មានបរិមាណទើបអាចរកឃើញគុណភាព» អាចអោយយើងឃើញនូវ ការរីកចំរើននៃជួរកម្មាភិបាល ទាំងបរិមាណ និងគុណភាព។ ប៉ុន្មានឆ្នាំ ក្រោយបដិវត្តន៍ទទួលបានជ័យជំនះ ជួរកម្មាភិបាលបានរីកចំរើនយ៉ាង

ឆាប់រហ័ស ហើយរដ្ឋអំណាចបដិវត្តត្រូវបានរៀបចំឡើងជាខ្សែចង្វាក់ គឺនៅថ្នាក់ស្រុក បានប្រែក្លាយពីក្រុមប្រតិបត្តិការទៅជាគណៈកម្មាធិការស្រុក នៅមជ្ឈិមស្ថាប័ននានាបានកើតជារូបរាង មានកម្មាភិបាលចំនួនច្រើនបង្គរធ្វើការ ឯខេត្តក្រុងក៏បានរៀបចំឡើងនូវស្ថាប័នជំនួយការអោយថ្នាក់ខ្លួនៗ យើងគួររំលឹកដែរថា យើងបានធ្វើដំណើរពីក្បាលម៉ាស៊ីនរដ្ឋអំណាច និងក្បាលម៉ាស៊ីនជំនួយការតូចពេក រហូតដល់ធំជ្រុល ដែលចុងក្រោយនេះ មជ្ឈិមបក្ស និងរដ្ឋាភិបាល បានពិនិត្យឃើញថា យើងកំពុងស្ថិតក្នុងស្ថានភាព «ក្បាលធំ ខ្លួនធំ ជើងតូច» គឺមានន័យថាក្បាលម៉ាស៊ីននៅមជ្ឈិម ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ធំសំពីងសំពោង ប៉ុន្តែនៅថ្នាក់មូលដ្ឋាន ភូមិ ឃុំ បែរជាស្តើងទៅវិញ ក្នុងពេលដែលមូលដ្ឋាននៅជាចំណុចក្តៅបំផុតនៅឡើយ។

សមិទ្ធផលទាំងអស់ ត្រូវសំរេចឡើងនៅមូលដ្ឋាន ព្រោះមូលដ្ឋានជាសមរភូមិប្រយុទ្ធ ដើម្បីការពារប្រជាជន ការពារសមិទ្ធផលបដិវត្ត ជាកន្លែងប្រមូលផ្តុំប្រជាជន ដែលខ្មាំងសត្រូវកំពុងធ្វើសកម្មភាពនៅទីនោះ ដើម្បីដណ្តើមប្រជាជន ដណ្តើមមូលដ្ឋាន ភូមិ ឃុំពីបដិវត្តន៍។ ការមើលស្រាលចំពោះការកសាងកម្លាំងនៅមូលដ្ឋាន បានអូសបន្លាយអស់រយៈពេលយ៉ាងយូរ ដែលជាកំហុសមួយដ៏ធំរបស់យើង។ ក្រោយការពង្រឹងមូលដ្ឋាន យើងបានពិនិត្យឃើញនូវសភាពការណ៍មានការប្រែប្រួលយ៉ាងល្អ ទាំងជីវភាពរស់នៅរបស់ប្រជាជន ទាំងការវាយខ្មាំងធ្វើអោយឧបាយកលចង់ដណ្តើមប្រជាជន ដណ្តើមមូលដ្ឋានរបស់ខ្មាំងត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរ។ យើងក៏គួររំលឹកឡើងបន្តិចអំពីការកសាងកម្លាំងប្រដាប់អាវុធ និងការកសាងអង្គការមហាជនរបស់បក្ស។ គ្រា

ដំបូងយើងមានកម្លាំងប្រដាប់អាវុធ ដែលមានសាច់ទ័ពមិនច្រើនឡើយ ប៉ុន្តែឆ្លងតាមរយៈនៃការប្រយុទ្ធផង កសាងផង កម្លាំងប្រដាប់អាវុធយើង បានរីកចំរើនឡើង ក្លាយទៅជាឧបករណ៍ដ៏សំខាន់ ដើម្បីការពារបក្ស ការពាររដ្ឋអំណាច និងប្រជាជន។ ការរីកចំរើននេះ បានបង្កលក្ខណៈអោយកងទ័ពស្ម័គ្រចិត្តវៀតណាម បានដកត្រឡប់ទៅប្រទេសវិញជាបណ្តើរៗ ហើយនឹងឈានទៅដកទាំងស្រុងនាឆ្នាំ ១៩៩០។ មាគ៌ាយោធារបស់បក្សបាន ដាក់ចេញស្របនឹងសភាពការណ៍ ស្របនឹងចរិតសង្គ្រាម ដែលខ្មាំងសត្រូវកំពុងធ្វើមកលើយើង ដូច្នេះហើយ វាក៏បានកើតឡើងនូវកងទ័ពបីប្រភេទ ស្រួច តំបន់ ឈ្លប និងប្រភេទទ័ពស្របតាមកំរិតនៃសង្គ្រាម ដូចជា ទ័ពជើងគោក ជើងទឹក ជើងអាកាស ព្រមទាំងមានសមាមាត្រសមស្របរវាងកងទ័ពស្រួច និងតំបន់។ មាគ៌ាសង្គ្រាមប្រជាជនរបស់បក្ស បានកកើតឡើងនូវចលនាកសាងខឿនការពារជាតិរបស់ប្រជាជន។ កងសេនាជនស្វ័យការពារកើតមាននៅគ្រប់ទីកន្លែង តាំងពីក្រសួង មន្ទីររហូតដល់រោងចក្រ សហគ្រាស ហើយពិសេសនៅភូមិ ឃុំ។ ការកសាងប្រព័ន្ធការពារព្រំដែន ត្រូវបានចូលរួមពីសំណាក់ប្រជាជនយ៉ាងច្រើនកុះករ។ ចលនាមហាជនក្នុងកិច្ចការពារជាតិ បានបង្កឡើងនូវប្រៀបកាត់ផ្តាច់ខ្មាំងជាកំណាត់ៗ និងធ្វើអោយខ្មាំងចុះខ្សោយជាបន្តបន្ទាប់ ហើយយើងការពារបានព្រំដែនការពារបានភូមិ ឃុំ រក្សាបានយ៉ាងរឹងមាំនូវសមិទ្ធផលបដិវត្ត។

អង្គការមហាជនរបស់បក្ស ដូចជា សហជីព យុវជន នារី ត្រូវបានកសាងឡើងជាខ្សែចង្វាក់ តាំងពីមជ្ឈិមរហូតដល់មូលដ្ឋានក្លាយទៅជាស្ពានតភ្ជាប់រវាងបក្សជាមួយមហាជន ហើយប្រមូលផ្តុំបានមហាជននៅជុំវិញបក្ស និង

រដ្ឋអំណាច។

នៅពេលលើកឡើង អំពីការងារដែលសំរេចបាន យើងក៏មិនភ្លេចនិយាយដល់កិច្ចការដែលនៅសេសសល់ ដែលត្រូវបន្តដោះស្រាយនោះឡើយ។ បញ្ហាគុណភាពរបស់បក្ខជន អង្គការចាត់តាំងរបស់បក្សនិងជួរកម្មាភិបាល នៅតែជាបញ្ហាត្រូវយកចិត្តទុកដាក់ជាបន្ត ទើបអាចឆ្លើយតបទៅនឹងសភាពការណ៍ដែលរីកចំរើនមិនឈប់ឈរបាន។ រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការ ក៏ត្រូវទាមទារកែលំអ ធ្វើអោយស្រាល តែមានប្រសិទ្ធភាព។ ការពង្រឹង និងកសាងមូលដ្ឋាន នៅតែជាគន្លឹះស្លាប់រស់របស់បដិវត្តន៍ ដែលទាមទារត្រូវតែប្រឹងប្រែងជាបន្ត។

ចំពោះអង្គការមហាជន តើចាំបាច់ត្រូវរៀបចំសមាគមកសិករឬទេ? យើងមានរួចហើយនូវអង្គការយុវជន នារី សហជីព ប៉ុន្តែកសិករនៅមិនទាន់មានអង្គការចាត់តាំងនៅឡើយ អាស្រ័យដោយពេលមុន យើងចាត់ទុកក្រុមសាមគ្គីថា ជាអង្គការចាត់តាំងរបស់កសិករ តែការជាក់ស្តែងក្រុមសាមគ្គីបង្កបង្កើនផល គឺជាអង្គការផលិតកម្មតែប៉ុណ្ណោះ គ្រាន់តែបានធ្វើថែមការកិច្ចគ្រប់គ្រង និងអប់រំនយោបាយ សតិអារម្មណ៍ខ្លះប៉ុណ្ណោះ ហើយដែលក្នុងពេលនោះ ក៏មានកសិករមួយចំនួន មិនស្ថិតនៅក្នុងក្រុមសាមគ្គីដែរ។

និយាយពីការកសាងកម្លាំង យើងមានមោទនភាពជាខ្លាំង អំពីការរីកចំរើនរបស់យើង ប៉ុន្តែយើងមិនអាចបញ្ចប់ត្រឹមកន្លែងនេះឡើយ ព្រោះការតស៊ូជាមួយសត្រូវ នៅតែបន្តស្តែងឡើង យ៉ាងតានតឹង និងស្មុគស្មាញ ឯការកសាងប្រទេស ក៏ទាមទារអោយកម្លាំងរបស់យើងវិវត្តរីកចំរើន ឆាប់រហ័សផងដែរ។

## ផ្នែកទី ៤

# ផ្លូវទៅមុខ

ដប់ឆ្នាំនៃដំណើរលើផ្លូវវែង សុទ្ធសឹងតែបានសាកល្បងរួចស្រេចទៅហើយអំពីសមត្ថភាព និងលទ្ធភាពពិតប្រាកដរបស់ប្រជាជនកម្ពុជា។ ដប់ឆ្នាំនៃអត្ថិភាព សាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើដំណើរឆ្លងកាត់នូវការលំបាកយ៉ាងច្រើនអនេក ធ្វើដំណើរក្នុងស្ថានភាពមានសន្តិភាពផង និងមានសង្គ្រាមផង ហើយបានធ្វើដំណើរពីខ្សោយទៅខ្លាំង។ សមិទ្ធផលរយៈពេលដប់ឆ្នាំ គឺជាឈ្នាន់សំរាប់ការឈានទៅមុខ ហើយក៏បានផ្តល់អោយយើងនូវបទពិសោធន៍ជាច្រើន ក្នុងជីវភាពនយោបាយសង្គមដែរ។ នេះគឺជាមេរៀនពិសោធន៍នៃប្រវត្តិសាស្ត្ររបស់ជាតិយើងទាំងមូល ដែលបានធ្វើដំណើរចេញពីបាតដៃទទេ ដោយត្រូវប្រយុទ្ធផងកសាងផង ហើយទីបំផុតបាននាំប្រទេសដែលត្រូវខ្ទេចខ្ទាំអោយរស់រានមានជីវិតឡើងវិញ។ បទពិសោធន៍ធំបំផុតគឺមាគ៌ាដឹកនាំត្រឹមត្រូវ ដែលរាប់តាំងពីកម្មវិធីនយោបាយ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រហូតដល់សេចក្តីសំរេចចិត្តនៃមហាសន្និបាតបក្សលើកទី ៣ ទី ៤ ទី ៥ គឺសុទ្ធតែបានដាក់ចេញសមស្របតាមសភាពការណ៍ និងគោលបំណងរបស់ប្រជាជន ប្រមែប្រមូលបានប្រជាជនគ្រប់ជនជាតិគ្រប់ស្រទាប់វណ្ណៈទូទាំងប្រទេសយ៉ាងច្រើនកុះករ ក្រោកឡើងតស៊ូផ្តួលរំលំរបបស្រេកឈាម ប៉ុល ពត ហើយបន្តកសាង និងការពារមាតុភូមិ។ បដិវត្តន៍ទទួលបានជោគជ័យ ក៏អាស្រ័យដោយកម្លាំងពីរគួបផ្សំគ្នា គឺកម្លាំងជាតិ និងកម្លាំងសាមគ្គីអន្តរជាតិ ពិសេសការជួយឧបត្ថម្ភរបស់

វៀតណាមៗ លើភាពជាក់ស្តែង គ្មានអ្នកណាមួយបដិសេធ នូវតួនាទីដ៏សំខាន់របស់វៀតណាម ក្នុងការជួយប្រជាជនកម្ពុជា ដើម្បីបញ្ចប់របបប្រល័យពូជសាសន៍ ការពារកុំអោយរបបប្រល័យពូជសាសន៍ត្រឡប់មកវិញ និងក្នុងការជួយអោយប្រជាជនកម្ពុជា រស់រានមានជីវិតឡើងវិញនោះឡើយ។ ឡាវ សហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយមផ្សេងៗទៀត សុទ្ធតែបានរួមចំណែក ក្នុងជ័យជំនះរបស់បដិវត្តន៍កម្ពុជា ហើយកាន់តែធ្វើអោយយើងធូរជាមួយកំរិតទៀត តាមរយៈនៃការជួយឧបត្ថម្ភរបស់បណ្តាប្រទេស និងអង្គការអន្តរជាតិនានា។

បដិវត្តន៍បានឆ្លងផុត នូវដំណាក់កាលដែលលំបាកបំផុត ហើយកំពុងស្ថិតក្នុងដំណាក់កាលពង្រីក និងពង្រឹងខ្លួន។ ពិតមែនតែបានផ្ទេរពីដំណាក់កាលវាយតែខាងយោធា មកកាន់ដំណាក់កាលវាយផង និងចរចាផង ប៉ុន្តែការតស៊ូរវាងយើង និងខ្មាំង នៅតែស្តែងឡើងយ៉ាងតានតឹង ស្មុគស្មាញលើច្រើនវិស័យៈ យោធា នយោបាយ ការទូត សតិអារម្មណ៍ សេដ្ឋកិច្ចៗលៗ សត្រូវមិនទាន់បោះបង់ចោលនូវឧបាយកលផ្តួលរំលំយើងនៅឡើយ ទោះតាមយោធាក្តី នយោបាយក្តី ឬលើតុចរចាក្តី។ ក្នុងសភាពការណ៍នេះ ស្ថានការណ៍ប្រទេស ត្រូវបន្តស្ថិតនៅក្នុងកាលៈទេសៈ មានសន្តិភាពផង និងមានសង្គ្រាមផង។ សន្តិភាពបានកើតមានលើចំណែកភាគច្រើន នៃដែនដី និងពេលវេលា ឯសង្គ្រាមកើតមានដោចដាច់ដោយដុំ និងពេលវេលាខ្លះៗ តែប៉ុណ្ណោះ តែទោះជាយ៉ាងណា សង្គ្រាមនេះក៏មានឥទ្ធិពលអាក្រក់ដល់ការកសាងប្រទេស ហើយក៏បានបង្កអោយមានការឈឺចាប់ច្រើនណាស់ដែរ សំរាប់ប្រជាជនកម្ពុជា។ ប៉ុន្តែយើងត្រូវធ្វើសង្គ្រាមបន្តទៀត ព្រោះជាសង្គ្រាមដែលសត្រូវបង្ខំអោយ

*យើងត្រូវធ្វើ។ សភាពការណ៍នេះ យើងកំពុងស្ថិតនៅដំណាក់កាលមាន សន្តិភាព តែខ្វះស្ថិរភាព អាស្រ័យដោយមានការបំផ្លាញពីសត្រូវគឺ យើងមានឯករាជ្យ តែនៅមានការគំរាមកំហែង អាស្រ័យដោយប្រទេស ក្រៅនៅប្រើប្រាស់ពួកក្រុមខ្មែរបដិបក្ខដើម្បីផ្តួលរំលំ យើងមានការរីកចំ រើនតែមិនទាន់រឹងមាំ អាស្រ័យដោយផលិតកម្មមិនទាន់មានស្ថិរភាព។*

# សង្គ្រាម និងសន្តិភាព

*បញ្ហាសង្គ្រាម និងសន្តិភាពបានក្លាយជាប្រធានបទសំខាន់ ដែលជានិច្ចកាលតម្រូវអោយយើងរកទិសដោះស្រាយ តើនឹងត្រូវបញ្ចប់សង្គ្រាមដើម្បីរកសន្តិភាពដោយវិធីណា? សភាពការណ៍អន្តរជាតិ និងតំបន់មានការប្រែប្រួល អំណោយផលដល់និន្នាការដោះស្រាយការវិវាទតាមការចរចាក៏មែនពិត ប៉ុន្តែវិធីដោះស្រាយក៏នៅជាបញ្ហាចំរូងចំរាសរវាងភាគីទាក់ទិនក្នុងជម្លោះ ហើយបញ្ហា ប៉ុល ពត គឺជាចំណុចក្តៅ និងជាឧបសគ្គក្នុងការដោះស្រាយនេះ។*

*ឆ្លងតាមការវិវត្តន៍នៃសភាពការណ៍ គេអាចប៉ាន់ស្មានបានថា បញ្ហាកម្ពុជា អាចលេចឡើងនូវលទ្ធភាពបីៈ*

*ទីមួយ មានដំណោះស្រាយទាំងស្រុង គឺដោះស្រាយក្នុងពេលជាមួយគ្នា នូវទិដ្ឋភាពផ្ទៃក្នុង និងទិដ្ឋភាពអន្តរជាតិ។*

*ទីពីរ មានដំណោះស្រាយតាមផ្នែក គឺការដោះស្រាយទិដ្ឋភាពអន្តរជាតិមុន ហើយទិដ្ឋភាពផ្ទៃក្នុងដោះស្រាយក្រោយ។*

*ទីបី គ្មានដំណោះស្រាយនយោបាយ គឺឆ្នាំ ១៩៩០ វៀតណាមដកកងទ័ពអស់ពីកម្ពុជា នោះបញ្ហាកម្ពុជាត្រូវបានដោះស្រាយ ហោចណាស់ក៏បញ្ហាកងទ័ពវៀតណាម ត្រូវបានដោះស្រាយដោយខ្លួនឯងដែរ ហើយបើមានការចរចាបន្តទៀត ក៏គ្រាន់តែដោះស្រាយនូវបញ្ហា ប៉ុល ពត និងការបញ្ឈប់ជំនួយអោយក្រុមខ្មែរបដិបក្ខប៉ុណ្ណោះ។*

លទ្ធភាពទីមួយ គឺដំណោះស្រាយគ្រប់ជ្រុងជ្រោយ ឬដំណោះស្រាយទាំងស្រុង ដែលជាលទ្ធភាពល្អបំផុត ប្រសិនបើពួក ប៉ុល ពត ត្រូវបានដកអាវុធ ប៉ុន្តែក៏ជាលទ្ធភាពងាយផ្ទុះឡើងវិញនូវសង្គ្រាមផ្ទៃក្នុងដែរ ប្រសិនបើផ្តល់លទ្ធភាពអោយពួកខ្មែរក្រហម ចូលរួមទាំងនយោបាយ និងយោធា ហើយសង្គ្រាមផ្ទៃក្នុងពេលនោះ នឹងមិនអាចត្រួតត្រាបានឡើយ ព្រោះគេឈានទៅវាយគ្នានៅកណ្តាលទីក្រុង ទីប្រជុំជនតែម្តង។ «ទស្សនៈដែលលើកឡើងថា ត្រូវធ្វើសម្បទានទាំងនយោបាយ និងយោធាអោយពួកខ្មែរក្រហម ដើម្បីអោយចិន និងខ្មែរក្រហមយល់ព្រមចូលរួមដំណោះស្រាយនយោបាយ ដើម្បីបញ្ចប់សង្គ្រាមផ្ទៃក្នុង គឺជាទស្សនៈខុសឆ្គង និងគ្រោះថ្នាក់ ជាទស្សនៈដែលនាំទៅរកការបង្កើតសង្គ្រាមផ្ទៃក្នុងថ្មី ដែលគេមិនអាចកំរិត និងត្រួតពិនិត្យបាន»។

ការប្តូរយកការចូលរួមរបស់ចិន និងខ្មែរក្រហមក្នុងដំណោះស្រាយនយោបាយ តាមរយៈនៃការធ្វើសម្បទានទាំងនយោបាយ និងយោធាអោយពួកខ្មែរក្រហម គឺជា «គន្លឹះផ្ទុះនៃសង្គ្រាមផ្ទៃក្នុង»។ គ្រោះថ្នាក់នៃការប្រល័យពូជសាសន៍នឹងត្រូវឈានមកជិត ប្រជាជនកម្ពុជាម្តងទៀត ហើយវានឹងកើតមានជាបន្ទាន់នៅតាមតំបន់ ដែលពួកខ្មែរក្រហមបោះទីតាំង និងត្រួតត្រា។ តើគេអាចជឿបានទេថា ខ្មែរក្រហមមានការកែប្រែនយោបាយ? វាមិនអាចកើតមានរឿងកែប្រែនយោបាយរបស់ពួកខ្មែរក្រហមឡើយ។ ផ្ទៃក្នុងរបស់ពួកខ្មែរក្រហមនៅតែបន្តកាប់សម្លាប់គ្នា ហើយកម្លាំង សីហនុ សឺន សាន ដែលខ្មែរក្រហមចាត់ទុកជាសម្ព័ន្ធមិត្ត ដើម្បីប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវពួក ប៉ុល ពត កាប់សម្លាប់គ្មានត្រាប្រណី។ ជនភៀសខ្លួនខ្មែរនៅប្រទេសថៃ ដែលពួក ប៉ុល

ពត កាន់កាប់ ហើយដែលជាប្រភពផ្តល់កម្លាំងមនុស្ស សំរាប់បំពេញកងទ័ពអោយពួក ប៉ុល ពត ផងនោះ ក៏គង់ពួក ប៉ុល ពត កាប់សម្លាប់និងរំលោភយ៉ាងកំរោល ចុះទំរាំប្រជាជនកម្ពុជានៅក្នុងប្រទេស ដែលតិច ឬច្រើន សុទ្ធតែបានរួមចំណែកក្នុងការផ្តួលរំលំ ឬប្រឆាំង ប៉ុល ពត ក្នុង ១០ ឆ្នាំកន្លងទៅ តើពួក ប៉ុល ពត វានឹងប្រព្រឹត្តយ៉ាងណាចំពោះគេ ប្រសិនបើពួក ប៉ុល ពត ត្រឡប់មកវិញ ដោយស្របច្បាប់ តាមរយៈដំណោះស្រាយនយោបាយនោះ? ពិសោធន៍ក្នុងអតីតកាលបញ្ជាក់ច្បាស់ថាពួក ប៉ុល ពត កាប់សម្លាប់មនុស្សគ្មានរើសមុខឡើយ។ ក្នុងពេលកាន់អំណាច គេសម្លាប់តាំងពីអនុប្រធានរដ្ឋ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី និងកម្មាភិបាលខ្ពស់ៗ ដែលធ្លាប់រួមរស់ជាមួយគ្នារហូតដល់ប្រជាជនធម្មតា និងកូនក្មេងមិនទាន់ដឹងក្តីផង។ ១០ ឆ្នាំមកនេះ ពួក ប៉ុល ពត នៅបន្តនយោបាយព្រៃផ្សៃគ្មានការកែប្រែត្រង់ណាឡើយ ទោះបីពួកវាបានប្រកាសចំហថារំលាយចោលបក្សកុម្មុយនិស្ត ឬកែប្រែមុខមាត់អ្នកដឹកនាំក៏ដោយ។ ក្នុងឯកសារថ្ងៃទី ២ ធ្នូ ១៩៨៦ ពួក ប៉ុល ពត គ្មានបាននិយាយអ្វីដល់កំហុសរបស់វាបន្តិចណាឡើយ។ ផ្ទុយទៅវិញ វាចាត់ទុកអ្នកដឹកនាំរបស់វា និងរបបកម្ពុជាប្រជាធិបតេយ្យថា ជារបស់ដែលស្អាតបរិសុទ្ធលើសគេក្នុងប្រវត្តិសាស្ត្រ គឺលើសទាំងណាប៉ូឡេអុង របស់បារាំង លើសទាំងពោរកំបោរ អាចារ្យស្វា ក្រឡាហោមគង់ ស៊ីវត្ថា នៅកម្ពុជាទៅទៀត។

គេមិនគួរយកជីវិតប្រជាជនទៅសាកល្បងនឹងការស្លាប់ជាថ្មី តាមរយៈនៃកាផ្តល់លទ្ធភាពអោយពួក ប៉ុល ពត មានអាវុធសំរាប់ស្តារឡើងវិញនូវរបបរបស់វានោះឡើយ។ បើពួក ប៉ុល ពត មិនអាចដណ្តើមបានអំណាចទាំងស្រុង អាស្រ័យដោយមានកម្លាំងទប់ពីគណបក្សដទៃនៅ

កម្ពុជា ក៏គេត្រូវគិតដល់តំបន់ដែលពួក ប៉ុល ពត ត្រួតត្រាដែរ។ ប្រសិនបើពួកខ្មែរក្រហមនៅមានកងទ័ពនោះ «ការមិនដោះស្រាយ ល្អជាងដោះស្រាយ» ព្រោះបើមិនដោះស្រាយទេ សង្គ្រាមវាបន្តកើតនៅព្រំដែនកម្ពុជា-ថៃ នៅត្រង់តំបន់ចុងកាត់មាត់ញក តែបើដោះស្រាយដោយមានការចូលរួមពីកងទ័ពខ្មែរក្រហមនោះ សង្គ្រាមនឹងផ្ទុះឡើងនៅក្នុងរដ្ឋធានី កណ្តាលទីក្រុង ទីប្រជុំជនក្នុងផ្ទៃប្រទេសតែម្តង ហើយម្តងនេះ គឺគ្មានអ្នកណាអាចត្រួតត្រាបានឡើយ កុំថាឡើយតែកងរក្សាសន្តិសុខអន្តរជាតិ ឬក៏ប្រមុខរដ្ឋាភិបាលចំរុះ។

ក្នុងឋានៈជាអ្នកទទួលខុសត្រូវ ការពារជិវិតរបស់ប្រជាជនរាប់លាននាក់ យើងមិនត្រូវទទួលយកនូវដំណោះស្រាយនយោបាយមួយ ដែលមានខ្មែរក្រហម ទាំងនយោបាយ និងយោធាឡើយ គឺយើងត្រូវតែហ៊ានទទួលយកសង្គ្រាមបន្តទៀត ព្រោះវាមានគ្រោះថ្នាក់ដល់ប្រជាជនតិចជាង។

វាជាការមិនសមស្របទាល់តែសោះតាមផ្លូវច្បាប់ និងសីលធម៌ ដែលគេបណ្តោយអោយពួកឧក្រិដ្ឋជន ប៉ុល ពត ស្មើមុខស្មើមាត់ ជាមួយប្រជាជនកម្ពុជា ដែលជាអ្នករងគ្រោះ។ ទោសកំហុសរបស់ពួក ប៉ុល ពត អំពីការប្រល័យពូជសាសន៍ មិនទាន់ទាំងបានធ្វើអ្វីចំពោះពួកវាផង ហើយយើងបែរជានាំគ្នាប្រគល់តួនាទី ទាំងនយោបាយ និង យោធាអោយពួកវាក្នុងពេលដែលពួកវាមិនទាន់កែប្រែនយោបាយផងនេះ។ ការគិតគូរដល់ផលប្រយោជន៍ចិន និងខ្មែរក្រហម ជាងផលប្រយោជន៍ប្រជាជនកម្ពុជា ដើម្បីបានឈ្មោះថា ជាដំណោះស្រាយតុល្យភាព និងស្មើភាព ឬជាដំណោះស្រាយដោយរក្សាបានផលប្រយោជន៍នៃភាគីទាំងអស់ រាប់ទាំងពួក ប៉ុល ពត ផងនោះ មិនមែនជាដំណោះស្រាយនយោបាយ

ដើម្បីនាំមកនូវសន្តិភាពឡើយ ប៉ុន្តែគឺជាការបន្ថែមនូវគ្រោះថ្នាក់ថ្មីអោយប្រជាជនកម្ពុជា ហើយជាការរៀបចំនូវគន្ទឹះផ្ទុះនៃសង្គ្រាមស៊ីវិលថ្មី ដែលគ្មាននរណាត្រួតពិនិត្យបាន។

យើងអាចប៉ាន់ស្មានបានថា ចិន និងខ្មែរក្រហម ពិតជានឹងមិនព្រមរំលាយចោលកងទ័ពខ្មែរក្រហម ដើម្បីចូលរួមដំណោះស្រាយនយោបាយបានឡើយ ។ ដូច្នេះ ពួក ប៉ុល ពត នឹងធ្វើសង្គ្រាមបំផ្លិចបំផ្លាញបន្តទៀត។ គេមិនគួរខ្វាចសង្គ្រាមរបៀបនេះឡើយ ប្រសិនបើភាគីដទៃនិងប្រទេសផ្សេងទៀត ឈប់ផ្តល់ជំនួយអោយពួក ប៉ុល ពត ហើយអង្គការសហប្រជាជាតិឈប់ទទួលស្គាល់វា។ ការខ្លាចសង្គ្រាមឧទ្ទាម ហើយហ៊ានទទួលយកសង្គ្រាមស៊ីវិល ដែលមិនអាចត្រួតត្រាបាន គឺជាអំពើផ្ទុយនឹងបំណងដែលចង់បញ្ចប់សង្គ្រាម។ ផ្លូវជ្រើសរើសមានតែពីរទេះ ទីមួយ អោយ ប៉ុល ពត ចូលរួមទាំងនយោបាយ និងយោធា រួចហើយត្រូវទទួលយកសង្គ្រាមស៊ីវិល ទីពីរ ទ្រាំទ្រធ្វើសង្គ្រាមប្រឆាំងការបំផ្លាញរបស់ពួក ប៉ុល ពត បន្តទៅទៀត។ ផ្លូវទាំងពីរមានសង្គ្រាមបន្តដូចគ្នា ខុសគ្នាត្រង់តូច និងធំតែប៉ុណ្ណោះ។ ការធ្វើសម្បទានអោយពួកខ្មែរក្រហមចូលរួមខាងនយោបាយ ក្នុងដំណោះស្រាយនយោបាយ វាជាការរំលោភរួចស្រេចទៅហើយលើផ្លូវច្បាប់ និងសីលធម៌ ព្រមទាំងលើបំណងរបស់ប្រជាជន ដូចនេះ គេមិនត្រូវឈានមួយជំហ៊ានទៀតទៅតាមផ្លូវគ្រោះថ្នាក់នៃការធ្វើសម្បទានខាងយោធា ដើម្បីលួងលោមពួកខ្មែរក្រហម និងចិនឡើយ។

នៅក្នុងលទ្ធភាពនៃដំណោះស្រាយទាំងស្រុង វាអាចកើតមានបាន ឬមិនបាន គឺស៊ីសងទៅលើឥរិយាបថរបស់ចិន និងខ្មែរក្រហម ហើយ

ស្ថិតនៅត្រង់ចំណុចដែលខ្មែរក្រហមសុខចិត្តទម្លាក់អាវុធឬទេ? មានសំណួរជាច្រើនចោទសួរថា «អ្នកណាជាអ្នកដកអាវុធពីខ្មែរក្រហម?» យើងយល់ច្បាស់ថា មានតែខ្មែរក្រហមខ្លួនឯងទេ ដែលមានលទ្ធភាពដកអាវុធពីខ្លួនគេបាន ដើម្បីប្តូរយកតួនាទីខាងនយោបាយក្នុងដំណោះស្រាយ។ បើមិនដូច្នេះទេ ពួកខ្មែរក្រហមត្រូវស្ថិតនៅក្រៅដំណោះស្រាយនយោបាយ ហើយគេត្រូវប្រើវិធានការសរុប ដើម្បីដកអាវុធពីពួកនេះ។

ដំណោះស្រាយទាំងស្រុង គឺជាដំណោះស្រាយល្អបំផុត ពោលគឺគេអាចដោះស្រាយ ទាំងទិដ្ឋភាពផ្ទៃក្នុង និងទិដ្ឋភាពអន្តរជាតិ ព្រមពេលជាមួយគ្នា ដោយផ្ទៃក្នុងមានការចូលរួមពីភាគីកម្ពុជាទាំង ៤ លើមូលដ្ឋានពួកខ្មែរក្រហមរំលាយចោលកងទ័ព និងទិដ្ឋភាពអន្តរជាតិមានការចូលរួមពីបណ្តាប្រទេសមានការពាក់ព័ន្ធ គឺការដកកងទ័ពវៀតណាមព្រមគ្នាទៅនឹងប្រទេសខាងក្រៅបញ្ឈប់ជំនួយយោធាអោយកម្លាំងបដិបក្ខ។ ដំណោះស្រាយទាំងស្រុង មានលទ្ធភាពតិចតួចណាស់ ម្យ៉ាងដោយបញ្ហាផ្ទៃក្នុងមានភាពស្មុគស្មាញ ហើយខ្មែរក្រហមជាឧបស័គ្គដ៏សំខាន់ ដូច្នេះគេអាចឈានទៅដោះស្រាយ ផ្នែកអន្តរជាតិ មុនទិដ្ឋភាពផ្ទៃក្នុង។

លទ្ធភាពទីពីរ គឺដំណោះស្រាយតាមផ្នែក ដែលដំបូងបំផុត គឺដោះស្រាយផ្នែកអន្តរជាតិមុន ដើម្បីបង្កភាពងាយស្រួលអោយការដោះស្រាយផ្នែកផ្ទៃក្នុង។ ផ្នែកអន្តរជាតិអាចដោះស្រាយរួម និងដោះស្រាយតាមផ្នែករបស់វា ប៉ុន្តែប្រការនេះចិន មិនទាន់បង្ហាញនូវភាពទន់ភ្លន់ចង់ដោះស្រាយនៅឡើយ។

ប្រសិនបើចិនយល់ព្រមចូលរួមក្នុងដំណោះស្រាយ វាជាការល្អ វាអាចដោះស្រាយបានផ្នែកអន្តរជាតិទាំងស្រុង វាមានលក្ខណស្មើភាពសំរាប់

ទាំងសងខាង គឺវៀតណាមដកកងទ័ព ឯប្រទេសផ្សេងទៀតរាប់ទាំងចិនផង បញ្ឈប់ជំនួយអោយខ្មែរបដិបក្ខ។ ប៉ុន្តែប្រសិនបើចិនមិនចូលរួមទេនោះ គេក៏អាចឈានទៅដោះស្រាយតាមផ្នែកបានដែរ។ ថៃជាកត្តាសំខាន់បំផុត ដើម្បីបង្កើតឡើងនូវកិច្ចព្រមព្រៀងអំពីផ្នែកអន្តរជាតិនៃបញ្ហាកម្ពុជា អាស្រ័យដោយថៃជាប្រទេសផ្តល់ជំរកអោយខ្មែរបដិបក្ខ ជាកន្លែងប្រមូលផ្តុំជំនួយពីចិន និងប្រទេសផ្សេងទៀតអោយកម្លាំងប្រឆាំង ដូច្នេះគេអាចចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ជាមួយវៀតណាម និងប្រទេសផ្សេងទៀត និងបណ្តាភាគីកម្ពុជា ដែលចូលរួមក្នុងដំណោះស្រាយនយោបាយ ដោយមិនបាច់មានការចូលរួមរបស់ចិន។ ប្រទេសមួយចំនួនមានការព្រួយបារម្ភហើយសំដែងការសង្ស័យថា បើចិនមិនចូលរួមក្នុងដំណោះស្រាយនយោបាយទេ សង្គ្រាមនឹងមិនបានចប់ឡើយ។ ការព្រួយបារម្ភនេះ ជាការត្រឹមត្រូវម្យ៉ាងដែរ ប៉ុន្តែបើគេហ៊ានធ្វើសម្បទានដល់កំរិតមិនអាចទទួលយកបាន គឺការផ្តល់អោយពួកខ្មែរក្រហមចូលរួមដោយមានកងទ័ពនោះ វានឹងបង្កើតអោយមានការព្រួយបារម្ភ និងគ្រោះថ្នាក់កាន់តែធំ។ ពិនិត្យលើការជាក់ស្តែង គេមិនគួរភ័យខ្លាច ចំពោះការមិនចូលរួមរបស់ចិនទេ ប្រសិនបើថៃសុខចិត្តចូលរួម ក្នុងដំណោះស្រាយនយោបាយហើយនោះ។ យើងមិនបដិសេធនូវការបន្តលួចផ្តល់អាវុធពីចិនអោយពួកខ្មែរក្រហមនោះឡើយ គេពិតជារកវិធីជួយពួកខ្មែរក្រហមបន្តទៀត។ ប៉ុន្តែបើថៃចូលរួមក្នុងដំណោះស្រាយនយោបាយ ប្រទេសថៃខ្លួនឯង ត្រូវចូលរួមក្នុងការរារាំងការផ្តល់ជំនួយអោយខ្មែរក្រហម ដូច្នេះជំនួយពីចិនអោយខ្មែរក្រហម ត្រូវផ្លាស់រូបភាពពីចំហកាត់តាមទឹកដីថៃដោយស្របច្បាប់ ទៅជាសម្ងាត់កាត់តាមទឹកដីថៃ

ដោយមិនស្របច្បាប់។ ចំពោះផ្ទៃក្នុង គឺជាបញ្ហាស្មុគស្មាញ មិនអាចដោះស្រាយបានដាច់ឡើយ ហើយនៅទីនេះ ក៏ពិបាកនឹងរកដំណោះស្រាយរួមផង ប្រសិនបើខ្មែរក្រហមនៅតែចង់មានចំណែកអំពីយោធា។ ហេតុដូចនេះ បញ្ហាចោទឡើងតើគេត្រូវរង់ចាំការយល់ព្រមរបស់ខ្មែរក្រហម ឬប្តេជ្ញាដើរចោលខ្មែរក្រហម? ក្នុងបញ្ហានេះ បានកើតឡើងនូវច្រកបីនៃ «សង្គ្រាម»។ ច្រកទីមួយ គឺរង់ចាំខ្មែរក្រហម ហើយបន្តសង្គ្រាមដូច ១០ ឆ្នាំកន្លងមក ដែលជាសង្គ្រាមមានចំណេញអោយចិន និងខ្មែរក្រហម តែក៏ជាផលវិបាក សំរាប់ប្រជាជនកម្ពុជា និងភាគីផ្សេងទៀត ក្នុងនោះ មានភាគី សីហនុ សឺន សាន ផងដែរ។ ច្រកទីពីរ គឺធ្វើសម្បទានអោយខ្មែរក្រហម ទាំងនយោបាយ និងយោធា ដើម្បីអោយចិន និងខ្មែរក្រហមចូលរួមដំណោះស្រាយនយោបាយ ហើយបន្ទាប់មក សង្គ្រាមស៊ីវិលនឹងផ្ទុះឡើង ដែលគេមិនអាចត្រួតពិនិត្យបាន។ ច្រកទីបី គឺប្តេជ្ញាដើរចោលពួកខ្មែរក្រហម ហើយបង្កើតក្របខ័ណ្ឌដំណោះស្រាយតាមផ្នែក ចំពោះភាគីដែលចង់ចូលរួម រួចហើយបន្តប្រយុទ្ធជាមួយខ្មែរក្រហមតទៅទៀត ដែលជាការប្រយុទ្ធ រវាងប្រជាជនកម្ពុជាជាមួយកម្លាំងឧទ្ទាម ប៉ុល ពត ដែលចិនគាំទ្រ។ ច្រកសង្គ្រាមមានរហូតដល់បី ឯច្រកសន្តិភាពមានតែមួយប៉ុណ្ណោះ គឺ «ដំណោះស្រាយនយោបាយមួយ ដែលមានភាគីទាំងអស់ចូលរួម លើមូលដ្ឋានពួកខ្មែរក្រហមត្រូវរំលាយចោលនូវអង្គការចាត់តាំងខាងយោធា»។ នេះជាច្រកតែមួយគត់សំរាប់នាំមកនូវសន្តិភាពអោយកម្ពុជា។

ដំណោះស្រាយតាមផ្នែកនៃទិដ្ឋភាពអន្តរជាតិ ប្រសិនបើចិនមិនចូលរួម និងដំណោះស្រាយតាមផ្នែកនៃទិដ្ឋភាពផ្ទៃក្នុង ប្រសិនបើខ្មែរ

ក្រហមមិនចូលរួម មិនមែនជាដំណោះស្រាយបញ្ឈប់សង្គ្រាមទាំងស្រុងនោះឡើយ។ នេះជា «ដំណោះស្រាយពាក់កណ្តាល» ដើម្បីឈានទៅរកដំណោះស្រាយទាំងស្រុង ដូច្នេះគេត្រូវហ៊ានទទួលយកការបន្តសង្គ្រាមមួយរយៈទៀត ជាមួយពួកក្បាលរឹង ប៉ុល ពត។ គេមិនគួរខ្លាចចំពោះសង្គ្រាមឧទ្ទាមឡើយ ហើយប្រការដែលគួរអោយខ្លាច គឺសង្គ្រាមស៊ីវិល ដែលបង្កឡើងដោយពួកប្រដាប់អាវុធខ្មែរក្រហម បន្ទាប់ពីមានដំណោះស្រាយនយោបាយ។ សង្គ្រាមឧទ្ទាមរបស់ពួក ប៉ុល ពត មិនអាចឈានទៅរកគោលដៅចុងក្រោយ នៃការដណ្តើមអំណាចបានឡើយ ហើយក៏មិនអាចពង្រីកក្របខណ្ឌសង្គ្រាមបានដែរ ប្រសិនបើដំណោះស្រាយតាមផ្នែកមួយអាចលេចចេញជារូបរាង ទាំងទិដ្ឋភាពផ្ទៃក្នុង ទាំងទិដ្ឋភាពអន្តរជាតិ។ ផ្ទុយទៅវិញ សង្គ្រាមនេះនឹងត្រូវរួញតូចទៅៗ ហើយទីបំផុត នឹងត្រូវបញ្ចប់ក្នុងរយៈពេលមួយជាកំណត់ ។ បទពិសោធន៍ ១០ ឆ្នាំ នៃការបន្តសង្គ្រាមនៅកម្ពុជា គឺពួក ប៉ុល ពត មិនអាចសំរេចគោលដៅរបស់វាបានឡើយ ក្នុងពេលដែលពួកនេះបានការជួយឧបត្ថម្ភពីក្រុម សីហនុ សឺន សាន ពីប្រទេសថៃ អាស៊ាន អាមេរិក ចិន ហើយស្ថិតនៅក្នុងអង្គការសហប្រជាជាតិផង។ ក្នុងពេលនោះដែរ សាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើដំណើរតាំងពីបាតដៃទទេ មកកាន់លំនឹងមួយទាំងស្មារតី និងសម្ភារៈ ហើយកងទ័ពវៀតណាមបានដកចេញពីកម្ពុជាប្រមាណ ២ ភាគ ៣ រួចស្រេចទៅហើយ ក៏ពួកនេះពុំមានលទ្ធភាពធ្វើអោយប្រែក្រឡាស់សភាពការណ៍បានឡើយ។ ប្រសិនបើមានដំណោះស្រាយតាមផ្នែករវាងភាគីខ្មែរឯទៀត ហើយ ថៃ អាស៊ាន និងប្រទេសផ្សេងទៀតចូលរួមក្នុងដំណោះស្រាយដែរនោះ ពួកខ្មែរក្រហម

នឹងស្ថិតឯកោ ហើយបើចង់ធ្វើសង្គ្រាមបន្ត ក៏មិនអាចពង្រីកក្របខ័ណ្ឌសង្គ្រាមបានដែរ។ ចិនក៏មិនអាចធ្វើអ្វីអោយលើសពីនេះបានឡើយ។ សង្គ្រាមទ័ពព្រៃ វាស្ទើរតែក្លាយជារឿងធម្មតា សំរាប់ប្រទេសនៅអាស៊ីទៅហើយ ដោយមានប្រទេសច្រើនបង្គួរ ដែលមានកម្លាំងទ័ពព្រៃប្រឆាំងរដ្ឋាភិបាល ដូចជានៅហ្វីលីពីន ថៃ ភូមា សិរីលង្កា។ល។ ហើយប្រទេសមួយចំនួនទៀត ក៏មានក្រុមឧទ្ទាម ឬក្រុមភេរវកម្មផ្សេងៗ ប្រឆាំងរដ្ឋាភិបាលដែរ។ ឯនៅកម្ពុជា រឿងសង្គ្រាមផ្ទៃក្នុង ក៏មិនមែនជារឿងថ្មី ហើយចម្លែកនោះដែរ គឺវាបានកើតមានជាហូរហែ តាំងពីក្នុងទសវត្ស ឆ្នាំ ៦០ មកម៉្លេះ ហើយ ១០ ឆ្នាំកន្លងមកនេះ (១៩៧៩-១៩៨៩) សង្គ្រាមទ័ពព្រៃ បានកើតមានជាប់រហូត ដោយមានការជួយឧបត្ថម្ភពីប្រទេសនានា ដែលគាំទ្រពួកទ័ពព្រៃនេះផង។ ការលើកឡើងអំពីសង្គ្រាមផ្ទៃក្នុង បណ្តាលមកពីពួកខ្មែរក្រហម និងចិន មិនបានចូលរួមក្នុងដំណោះស្រាយ គឺវាគ្រាន់តែជាការគាបសង្កត់ដោយកម្លាំងកម្រោល ដើម្បីអោយគេទទួលយកតួនាទី ខ្មែរក្រហមខាងយោធា ហើយបង្កើតនូវសង្គ្រាមតាមរូបភាពថ្មីមួយទៀតតែប៉ុណ្ណោះ។ នៅក្នុងលទ្ធភាពនៃដំណោះស្រាយតាមផ្នែក ក៏មានមនុស្សខ្លះ នៃប្រទេសខ្លះ បានគិត ឬបានព្រួយបារម្ភអំពី «ដំណោះស្រាយក្រហម ឬដំណោះស្រាយកុម្មុយនិស្ត» ដែលអ្នកទាំងនោះ បានចាត់ទុកថាជាលទ្ធភាពមួយដែរ ដែលបង្កើតអោយមានការព្រួយបារម្ភពីឥស្សរជននៃប្រទេសខ្លះ។ ដំណោះស្រាយក្រហម ឬដំណោះស្រាយកុម្មុយនិស្ត គឺជាដំណោះស្រាយដោយមានការចូលរួម រវាងរដ្ឋាភិបាល សាធារណរដ្ឋប្រជាមានិតកម្ពុជា ជាមួយពួកខ្មែរក្រហម ហើយទាត់ចោលក្រុមសីហនុ សឺន សាន ដែលជាការទាត់ចោលតួនាទីរបស់អាស៊ាន អាមេរិក និងបណ្តាប្រទេសប៉ែកខាងលិច។

ដំណោះស្រាយក្រហម ជាលទ្ធភាពមួយរបស់ពួកខ្មែរក្រហម បើមិនចំពោះមុខ ក៏ជាទិសដៅយូរអង្វែងដែរ តាមការរៀបរាប់នៃឯកសាររបស់ ប៉ុល ពត ថ្ងៃ ២ ធ្នូ ១៩៨៦ ដែលមានចំណងជើងថា «តើគុណធម៌ គុណភាព ជាតុពិត និងតួនាទីរបស់កម្ពុជាប្រជាធិបតេយ្យយើងយ៉ាងណា ពេលមុន ពេលបច្ចុប្បន្ន និងតទៅអនាគត?»។ ពួក ប៉ុល ពត បានចាត់ទុក សីហនុ សឺន សាន ថាជា «គេ» គឺជាសត្រូវអនាគត ហើយនាខែមេសា ១៩៨៧ ឯកសារ ប៉ុល ពត បានលើកឡើងថា សីហនុ សឺន សាន ជាសត្រូវទៅអនាគតបន្តទៀត តែហាក់ដូចជាចង់ចាត់ទុកកម្លាំងបដិវត្តកម្ពុជា ជាសម្ព័ន្ធភាពអនាគតរបស់វា ដើម្បីប្រឆាំងសក្តិភូមិ សីហនុ នាយទុនកុំប្រាឌ័រ សឺន សាន ទៅវិញ។ ក្នុងពេលពួក ប៉ុល ពត កាន់តែប្រមូលមុខព្រួញទៅលើ សីហនុ និង សឺន សាន យើងក៏បានមើលឃើញសញ្ញាភ្លើងពីចម្ងាយ ប៉ុន្តែជិតអំពីលទ្ធភាពនៃដំណោះស្រាយក្រហមនោះដែរ ហាក់ដូចជាចិនបានគិតគូររឿងនេះដែរ។ ប៉ុល ពត បានដឹងច្បាស់ណាស់ថា ដើម្បីប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជាចំពោះមុខត្រូវប្រើ សីហនុ សឺន សាន ហើយដើម្បីប្រឆាំង សីហនុ សឺន សាន ទៅអនាគតត្រូវប្រើកម្លាំងបដិវត្តន៍កម្ពុជា។ ប្រការនេះ ប្រហែលជា ប៉ុល ពត យល់ច្រឡំថា កម្លាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា មានមនោគមវិជ្ជាឆ្វេងជ្រុលដូចពួកវាដែរ។ ការព្រួយបារម្ភរបស់ប្រទេសខ្លះគឺជាការត្រឹមត្រូវហើយ អាស្រ័យដោយគេមិនដឹងថាកម្លាំងទាំងពីរផ្ទុយគ្នា ១៨០ អង្សានោះឡើយ។ យើងសូមទូន្មានគេថា ប្រការដែលព្រួយបារម្ភ គឺកម្លាំងឆ្វេងបំផុត «ខ្មែរក្រហម» ស្តាំបំផុត «ខ្មែរសេរី» រួមគ្នាប្រឆាំងរបបភ្នំពេញ ដែលបង្កលក្ខណៈអោយពួក ប៉ុល ពត ឡើងកាន់

អំណាចទៅវិញទេ។ គេត្រូវតែដឹងថា របបភ្នំពេញគឺជាកម្លាំងតែមួយគត់ដែលប្រឆាំងខ្មែរក្រហមពិតប្រាកដទាំងយោធា និងនយោបាយ ហើយកម្លាំងនេះមានការចូលរួមពីគ្រប់និន្នាការនយោបាយ ដែលប្រឆាំង ប៉ុល ពត។ វាខុសពីកម្លាំង សីហនុ សឺន សាន ដែលអួតក្អេងក្អាងថាប្រឆាំង ប៉ុល ពត ជាពាក្យសំដី តែជួយពួក ប៉ុល ពត ជាសកម្មភាពនយោបាយ និងយោធា។ យើងមិនដែលបានគិត ហើយក៏មិនដែលបានធ្វើអ្វីក្រៅពីការធ្វើអោយពួក ប៉ុល ពត ចុះខ្សោយ សំដៅទប់ស្កាត់នូវការវិលត្រឡប់នៃរបបរបស់វានោះឡើយ។ សកម្មភាពមនុស្សធម៌ក្នុងគោលនយោបាយសន្តោសប្រណីចំពោះជនវង្វេងផ្លូវ ដែលមាននាយទាហាន និងពលទាហាន ប៉ុល ពត ចុះចូលរាប់ម៉ឺននាក់ មានបំណងតែមួយគត់គឺ សង្គ្រោះជនរួមជាតិ ដែលចាញ់ឧបាយកល ប៉ុល ពត តែប៉ុណ្ណោះ មិនមែនជាការត្រៀមរៀបចំដើម្បីដំណោះស្រាយក្រហមនោះឡើយ។ ១០ ឆ្នាំ កន្លងមក បច្ចុប្បន្ន និងអនាគត គឺពួកប្រទេសដែលភ័យខ្លាចនឹងដំណោះស្រាយក្រហមវិញទេ ដែលចង់បង្កើតដំណោះស្រាយ «ក្រហមឯក» តាមជំហាននៃដំណើរការ «ក្រហមខៀវចូលគ្នា» ហើយចុងក្រោយ «ក្រហមសុទ្ធ» ពោលគឺ ប៉ុល ពត ត្រួតត្រាអំណាចម្នាក់ឯង ហើយទូទាត់កម្លាំង សីហនុ សឺន សាន ចោល។ រឿងជាក់ស្តែងនៃដំណើរការក្រហមខៀវចូលគ្នានោះ គឺការបង្កើត «សម្ព័ន្ធភាពនៃបងប្អូន ដែលជាសត្រូវនឹងគ្នា» «រដ្ឋាភិបាលចំរុះត្រីភាគី» ដើម្បីរំលំរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ដំណោះស្រាយក្រហមជា «ផ្លូវគ្រោះថ្នាក់» ដ៏ធំសំរាប់ប្រជាជនកម្ពុជា ហើយវាមិនអាចកើតមានបានឡើយ ព្រោះយើងមិនមែនជាក្រហមដូចគេយល់ថា អាច

ចូលជាមួយក្រហម ប៉ុល ពត បាននោះឡើយ។

ក្នុងបញ្ហាដំណោះស្រាយចំពោះពួកខ្មែរក្រហម ជាទូទៅហាក់ដូចជាបានឯកភាពគ្នា អំពីគោលដៅត្រូវលុបបំបាត់ មិនអោយរបបខ្មែរក្រហមវិលមកកាន់អំណាចនៅកម្ពុជាវិញ ទាំងប្រជាជនកម្ពុជានៅក្នុងប្រទេស និងក្រៅប្រទេស។ បណ្តាភាគីកម្ពុជា (លើកលែងតែខ្មែរក្រហម) អាស៊ាន អាមេរិក លោកខាងលិច រហូតដល់សេចក្តីសំរេចចិត្តអង្គការសហប្រជាជាតិ ក៏បានបញ្ចូលពាក្យ «ការមិនវិលត្រឡប់មកវិញនៃនយោបាយ និងការអនុវត្តន៍នាអតីតកាលកន្លងទៅថ្មីៗ ដែលត្រូវគេថ្កោលទោសជាសកល» ដែលន័យសំខាន់និយាយដល់ការមិនវិលត្រឡប់នៃរបប ប៉ុល ពត។ ប៉ុន្តែគេមិនទាន់ឯកភាពអំពីវិធានការដែលនាំដល់ការលុបបំបាត់នូវគ្រោះថ្នាក់នេះទេ។ វិធានការរបស់ភាគី និងប្រទេសដែលប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺគេចង់បំបាត់គ្រោះថ្នាក់ ប៉ុល ពត តាមរបៀបផ្តល់តួនាទីទាំងនយោបាយ និងយោធា អោយពួក ប៉ុល ពត ក្នុងដំណោះស្រាយនយោបាយ រួចកំចាត់ ប៉ុល ពត តាមការបោះឆ្នោត ក្នុងពេល ប៉ុល ពត មិនទាន់ទម្លាក់អាវុធ។ ហើយគ្រោះថ្នាក់ជាងនេះទៀត គឺកំចាត់ ប៉ុល ពត តាមរយៈទាមទារអោយរំលាយចោលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលជាការបើកច្រកអោយពួក ប៉ុល ពត មកកាន់អំណាចបានងាយស្រួល។ អ្នកណាក៏ដឹងដែរថា ក្រៅពីសាធារណរដ្ឋប្រជាមានិតកម្ពុជា និងប្រទេសដែលឧបត្ថម្ភគាំទ្រសាធារណរដ្ឋប្រជាមានិតកម្ពុជា គ្មានអ្នកណាប្រឆាំង ប៉ុល ពត ពិតប្រាកដ ហើយមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីទប់ស្កាត់ ប៉ុល ពត ឡើយ។ ប៉ុន្តែបែរជាគេចង់កំចាត់ ប៉ុល ពត តាមវិធានការ «ចងដៃ» អ្នកប្រឆាំង ប៉ុល

ពត ទៅវិញ។ «នេះក៏ជាផ្លូវប្រកបដោយគ្រោះថ្នាក់ នៃអ្នកផ្សងព្រេងខាងនយោបាយ ហើយនេះក៏ជារបៀបលេងល្បែងភ្នាល់ ដោយដាក់ប្រទេស និងជីវិតរបស់ប្រជាជន»។ វិធីតែមួយគត់ ដើម្បីលុបបំបាត់ជាស្ថាពរនូវលទ្ធភាពបង្កើតឡើងវិញនៃរបប ប៉ុល ពត គឺត្រូវបំបាត់ចោលកម្លាំងប្រដាប់អាវុធ ដែលជាឧបករណ៍ដណ្តើម អំណាចបង្កើតរបបរបស់ពួក ប៉ុល ពត ដើម្បីប្តូរយកនូវការចូលរួមខាងនយោបាយរបស់ពួកខ្មែរក្រហម ដែលនេះក៏ជាការរំលោភដ៏ធំមួយរួចទៅហើយ ទៅលើសីលធម៌ និងផ្លូវច្បាប់។ គេមិនត្រូវធ្វើសម្បទានអ្វីរហូតដល់អោយពួកខ្មែរក្រហមមានលទ្ធភាពបង្កវិនាសកម្មជាថ្មី មកលើប្រជាជនកម្ពុជានោះឡើយ។ បើពួក ប៉ុល ពត មិនយល់ព្រម ត្រូវប្តេជ្ញាដើរចោលពួក ប៉ុល ពត ហើយបន្តការប្រយុទ្ធដើម្បីរារាំងការវិលត្រឡប់របស់វា ប្រសើរជាងទុកអោយវាវិលត្រឡប់មកដោយស្របច្បាប់។ ពួកអ្នកអោយឈ្មោះខ្លួនថា ជាអ្នកអាណិតស្រឡាញ់ប្រជាជនកម្ពុជា ចង់អោយប្រជាជនកម្ពុជាបានសន្តិភាព រួចចាកពីការគំរាមកំហែងរបស់ពួក ប៉ុល ពត កំពុងធ្វើសកម្មភាពផ្ទុយពីការនិយាយ គឺគេកំពុងធ្វើនូវអ្វី ដែលអ្នកមានសុឆន្ទៈពិតប្រាកដមិនអាចធ្វើទៅកើត។ ការទទួលស្គាល់នូវគ្រោះថ្នាក់ ប៉ុល ពត វាហាក់ដូចជាគ្រាន់តែ ដើម្បីគេចចេញពីភាពអាម៉ាសខាងផ្នែកសីលធម៌ ហើយការទទួលយក ក៏គ្រាន់តែជារបៀបប្តូរយុទ្ធវិធី ចាត់ទុកដូចជាការធ្វើសម្បទាន ដើម្បីឆ្លៀតយកចំណេញនូវអ្វីដែលគេមិនអាចយកបានតាមការគាំទ្រពួកខ្មែរក្រហម អោយធ្វើសង្គ្រាមតាមផ្លូវយោធាប៉ុណ្ណោះ។ នោះគឺការសុខចិត្តទទួលយកនូវការប្រើពាក្យ «រាំងស្កាត់ការវិលត្រឡប់របស់ពួកខ្មែរក្រហម ប៉ុល ពត ដើម្បីប្តូរយកកាលផ្តួលរំលំ

សាធារណរដ្ឋប្រជាមានិតកម្ពុជាតាមផ្លូវនយោបាយ»។ ប្រទេសខ្លះ ពិសេស សិង្ហបូរី បានលើកឡើងនូវយោបល់គួរអោយភ្ញាក់ផ្អើលថា «ក្រោយពេលកងទ័ពវៀតណាមដកចេញ ត្រូវដកអាវុធពីភាគីខ្មែរទាំងអស់»។ នេះជាការមួយពិបាកយល់ ចំពោះចៅក្រមតុលាការ ដែលបានកាត់ទោសអោយជនរងគ្រោះ និងអ្នកបង្កអោយគេរងគ្រោះជាប់ពន្ធនាគារជាមួយគ្នា។ ប្រទេសដែលផ្តើមគំនិតលើកវិធានការនេះ កំពុងតែខិតខំបង្កើតនូវទម្លាប់ដ៏មានគ្រោះថ្នាក់ គឺការបង្កើតអោយមានភាពស្របច្បាប់ចំពោះអំពើប្រល័យពូជសាសន៍ ដែលសកលលោកកំពុងតែខិតខំលុបបំបាត់។ ពួក សីហនុ ពិសេស ពួក សឺន សាន ម្យ៉ាងដោយចង់រក្សាទុកខ្មែរក្រហម ម្យ៉ាងដោយកម្លាំងយោធាខ្លួនខ្សោយជាង គេក៏ប្រញាប់ប្រញាល់ឯកភាពដោយមិនបាច់គិតពីយុទ្ធសាស្ត្រភ្ជាប់ពី ប៉ុល ពត មកលើខ្លួនឡើយ «នេះពិតជាពួកឱកាសនិយម ធ្មិនក្បាលស៊ីក្បាល ធ្មិនកន្ទុយស៊ីកន្ទុយ ធ្វើយ៉ាងណាអោយតែមានអំណាច»។ វិធីស៊ីមិនបាច់សងវិញ យកទំនិញមិនបាច់សងប្រាក់ គេអាចធ្វើបានតែចំពោះក្រុម សីហនុ សឺន សាន តែប៉ុណ្ណោះ ហើយមិនអាចធ្វើបានចំពោះប្រជាជនកម្ពុជាឡើយ។

របៀបទិញទំនិញមិនបាច់សងប្រាក់ បាននិងកំពុងដំណើរការយ៉ាងមមាញឹក តាមរបស់ដែលហៅថា «រំលាយចោលរបបសាធារណរដ្ឋប្រជានិតកម្ពុជា ព្រមពេលរំលាយចោលកម្ពុជាប្រជាធិបតេយ្យហើយបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នចតុភាគី ដែលមានសីហនុជាប្រធាន»។ ១០ ឆ្នាំមុននេះ ពួកប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា បានប្រើប្រាស់វិធានការនយោបាយ យោធា សេដ្ឋកិច្ច ការទូត ដើម្បីផ្តួលរំលំ តែគេ

មិនអាចធ្វើបាន ហើយម្តងនេះ គេត្រូវអនុវត្តនូវរបៀប «ផ្តួលរំលំលើតុចរចា»។ នេះជាវិធីតភ្ជាប់រវាងរបស់ដែលគ្មានជាមួយរបស់ដែលមានពិតប្រាកដ ដោយគេធ្វើសម្បទានតាមរបៀបហែកក្រដាសចោល ដើម្បីប្តូរយកការបំផ្លាញនូវវត្ថុធាតុមួយដែលមានពីគល់មកដល់ចុង។ ការពិតរបស់ដែលហៅថា កម្ពុជាប្រជាធិបតេយ្យ បានត្រូវប្រជាជនរំលាយចោល តាំងពីថ្ងៃ ៧ មករា ១៩៧៩ មកម៉្លេះ តែរបស់នេះបានស្ថិតនៅលើក្រដាស ដោយមានការរក្សាពីបរទេស ជារបស់ដែលប្រជាជន និងសកលលោកស្អប់ខ្ពើម ហើយជារបស់គ្មានទឹកដី គ្មានប្រជាជន គឺវាខុសពីកោះតៃវ៉ាន់ ដែលស្ថិតស្ថេរដោយមានប្រជាជនរាប់លាននាក់ ហើយត្រូវគេរំលាយចោលតាមការហែកក្រដាស និងលុបឈ្មោះពីអង្គការសហប្រជាជាតិ តែដាក់ស្តែងតៃវ៉ាន់នៅតែជាតៃវ៉ាន់ដដែល ហើយសហរដ្ឋអាមេរិក និងប្រទេសខាងលិចជាច្រើន ដែលមាននយោបាយចិនពីរ នៅតែរក្សាទំនាក់ទំនងយ៉ាងល្អដដែល។ កម្ពុជាប្រជាធិបតេយ្យបើគេហែកក្រដាសចោល លុបឈ្មោះចេញពីអង្គការសហប្រជាជាតិ គឺចប់ហើយកម្ទាំងសេសសល់គឺជាឧទ្ទាម ដែលគ្មានត្រួតត្រាទឹកដី និងប្រជាជន។ ឯការយកដីថៃជាតំបន់រំដោះកម្ពុជាប្រជាធិបតេយ្យ គឺជារឿងដែលប្រជាជនថៃខ្លួនឯងយល់មិនបាន ចំពោះអំពើរបស់រដ្ឋាភិបាលខ្លួនដែលហ៊ានធ្វើសម្បទានអធិបតេយ្យ ដើម្បីប្តូរយកការស្ថិតស្ថេរខាងនយោបាយ និងយោធានៃកម្ពុជាប្រជាធិបតេយ្យ។ ឯសាធារណរដ្ឋប្រជាមានិតកម្ពុជា មានអត្ថិភាពពិតប្រាកដ ទោះជាគ្មានឈ្មោះនៅអង្គការសហប្រជាជាតិក៏ដោយ ហើយជារបបកើតឡើងពីប្រជាជន និងស្ថិតស្ថេរដោយសារប្រជាជន។ ពួកគេតម្រូវអោយមានការរំលាយព្រម

*ពេលជាមួយគ្នា នូវរបស់ដែលមានពិត និងរបស់ដែលមានតែឈ្មោះ ក្នុងទិសដៅផ្តួលរំលំដោយមិនបាច់ប្រើកម្លាំង។ ពួកគេចេះប្រើប្រាស់ ដែរនូវទ្រឹស្តី «ដំណោះស្រាយនយោបាយមួយអាចរកឃើញ អាស្រ័យ ដោយភាគីទាំងសងខាង ធ្វើសម្បទានទៅវិញទៅមក» ប៉ុន្តែជាក់ស្តែង គេអនុវត្តនូវរបៀបដើរបញ្ច្រាសទិស គឺអោយសាធារណរដ្ឋប្រជាមានិត កម្ពុជា ចាប់ចេញដំណើរពីចំណុចលេខ ១០ ទៅកាន់ចំណុចលេខ សូន្យ ឬហោចណាស់ទៅកាន់ចំណុចលេខ ៣ ឯកម្ពុជាប្រជាធិបតេយ្យ ត្រូវចេញដំណើរពីចំណុចលេខសូន្យ ទៅកាន់ចំណុចលេខ ១០ ឬ ចំណុចលេខ ៧ បានន័យថា ម្ខាងត្រូវបាត់ ម្ខាងត្រូវបាន ពោលគឺវាខុស ពីទ្រឹស្តីនៃសម្បទានទៅវិញទៅមក។ ការទិញទំនិញហើយដែលមិន មែនជាអំណោយទេនោះ ភាពចាំបាច់គេត្រូវអោយប្រាក់ទៅអ្នកលក់ទំ និញ។ ពួកគេមិនមែនមិនដឹងទេថា ដើម្បីមកត្រួតត្រាអំណាចបាននៅ កម្ពុជា ឬនិយាយអោយចំ គឺមកកាន់កាប់រដ្ឋជានីភ្នំពេញ តើគេត្រូវ ចំណាយជីវិតទាហាន ទ្រព្យសម្បត្តិ និងពេលវេលាអស់ប៉ុន្មាន ទើប អាចធ្វើបាន បើត្រូវធ្វើការផ្តួលរំលំតាមផ្លូវយោធា ហើយបើកាន់កាប់ បានហើយតើពួកគេនឹងបន្តខូចខាតប៉ុន្មានទៅទៀត ពីការវាយបក របស់ប្រជាជនយើង ដែលមិនព្រមទទួលយកនូវរបប ប៉ុល ពត ឬរបប ដែលគេមិនត្រូវការ។ យើងដឹងច្បាស់ថា ពួកគេពិតជាដឹងរឿងនេះ ច្បាស់លាស់ ព្រោះអ្នកនយោបាយអស់នោះ មិនល្ងិតល្ងង់ពេកនោះទេ ប៉ុន្តែអាស្រ័យដោយ «ខ្លាតពេក និងល្មោភពេក» ទើបគេលើករឿងនេះ ឡើង ដែលនាំអោយមានភាពទ័លច្រក ក្នុងការស្វែងរកដំណោះ ស្រាយនយោបាយ។ ពួកគេបាននិយាយហើយថា សង្គ្រាមនេះជា*

សង្គ្រាមមិនឈ្នះមិនចាញ់ ហើយមិនអាចផ្តួលរំលំរបបភ្នំពេញតាមផ្លូវយោធាបានឡើយ ដូច្នេះត្រូវសម្រុះសម្រួលតាមផ្លូវនយោបាយ ប៉ុន្តែមកដល់លើតុចរចា គេបែរជាទាមទារនូវអ្វីដែលគេមិនអាចសំរេច បាននៅលើសមរភូមិ ១០ ឆ្នាំកន្លងមក។

យើងបានធ្វើសម្បទាន ហើយត្រៀមខ្លួនធ្វើសម្បទាន ដើម្បីឈានទៅរកការព្រមព្រៀងគ្នា ប៉ុន្តែបើធ្វើសម្បទានតែម្នាក់ឯង គឺមិនស្មើភាព នៅក្នុងដំណោះស្រាយនយោបាយឡើយ។ ចំពោះប្រជាជនយើង បក្សយើង បានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីជីវិត និងការសុខសាន្តរបស់ប្រជាជន។ ប្រជាកសិករត្អូញត្អែរពីបញ្ហាវិភាគទានស្នេហាជាតិ យើងកែប្រែភ្លាម ហើយហ៊ានសុំទោសប្រជាជន ប៉ុន្តែចំពោះដំណោះស្រាយនយោបាយ គឺមិនអាចធ្វើសម្បទានតែម្នាក់ឯងបានឡើយ ព្រោះនេះគឺជាការតស៊ូរវាងបក្សពួកដែលប្រឆាំងគ្នាដោយអាវុធ ហើយជាមួយពួកប្រល័យពូជសាសន៍ និងអ្នកគាំទ្រវា។ បើធ្វើសម្បទានតែម្នាក់ឯង វាមិនខុសពីការអញ្ជើញរបប ប៉ុល ពត អោយមកកាប់សម្លាប់ប្រជាជនសាជាថ្មីនោះឡើយ។ ការធ្វើសម្បទានរបស់បក្ស និងរដ្ឋ យើងមានគោលដៅសំខាន់បំផុត គឺបញ្ចប់ទុក្ខសោករបស់ប្រជាជន ដែលបង្កឡើងដោយសង្គ្រាម បំផ្លិចបំផ្លាញពីកម្លាំងបដិបក្ខ។ យើងសុខចិត្តចរចា ហើយត្រៀមខ្លួនទទួលយកនូវរបបពហុបក្ស គឺវាជាការធ្វើសម្បទានដ៏ធំធេង ដើម្បីប្តូរយកនូវការសុខសាន្តជូនប្រជាជន ដែលកំពុងត្រូវការនូវសុខសន្តិភាព ដើម្បីកសាងប្រទេស និងជីវភាពរស់នៅ។ ពីបក្សមួយកាន់អំណាចម្នាក់ឯង ទៅកាន់របបបក្សច្រើនកាន់អំណាច ឬធ្វើសកម្មភាពក្នុងសង្គម ហើយដែលប្រទេសជាច្រើន ឬបុគ្គលជាច្រើន

ដែលធ្លាប់កាន់អំណាចនៅកម្ពុជាមិនដែលបានធ្វើ គឺជាសម្បទានមួយដ៏ធំធេង ព្រោះប្រទេសជាច្រើនបានខិតខំបង្ក្រាបបក្សជំទាស់ រារាំងមិនអោយពង្រីកតួនាទីក្នុងសង្គម តួយ៉ាងនៅអាស៊ីអាគ្នេយ៍ មានហ្វីលីពីន ភូមា ហើយប្រទេសផ្សេងទៀត ក៏មានភាពប្រហាក់ប្រហែលគ្នាដែរ។ ប្រទេស ដែលមានបក្សនយោបាយជាច្រើន ធ្វើសកម្មភាពដោយច្បាប់បានទទួលស្គាល់ហើយនោះ ក៏នៅតែរកវិធីធ្វើអោយបក្សផ្សេងទៀតចុះខ្សោយ ដើម្បីអំណាចរបស់បក្សខ្លួន ដូចជានៅថៃ បារាំង សហរដ្ឋអាមេរិក។ល។ ពេលឃោសនាបោះឆ្នោតម្តងៗ គេឃើញតែការបន្ទុះបង្អាប់គ្នាលើកតម្កើងបក្សពួករៀងខ្លួន ក្នុងគោលដៅ «ធំ» ដើម្បីខ្លួនក្តាប់បានអំណាច។ នៅកម្ពុជា សីហនុ បានបង្ក្រាបបក្សប្រឆាំងយ៉ាងខ្លាំងក្លា ក្នុងពេលដែលគាត់កាន់អំណាច ដូចជាពួក សឺង ង៉ុកថាញ់ សំ សារី ហ៊ូ នឹម ហ៊ូ យន់ ខៀវ សំផន សាឡុត ស (ប៉ុល ពត) និងបក្សនយោបាយផ្សេងៗទៀត នេះក៏ដើម្បីពង្រឹងនូវអំណាចត្រួតត្រាម្នាក់ឯងដែរ។ មកដល់របប លន់ នល់ ក៏ដូចគ្នា ហើយមកដល់ ប៉ុល ពត មិនចាំបាច់ថាបក្សនយោបាយទេ ទោះកូនក្មេង ឬព្រះសង្ឃ ក៏ត្រូវសម្លាប់ដែរ ។

បើគិតតែផលប្រយោជន៍បក្សនយោបាយសុទ្ធសាធ គឺវានឹងគ្មានរឿងចរចា ឬដំណោះស្រាយនយោបាយឡើយ។ បក្សមួយកាន់អំណាចវាមានភាពងាយស្រួលសំរាប់បក្ស ទាំងនៅក្នុងអង្គការនីតិបញ្ញត្តិ (រដ្ឋសភា ក្រុមប្រឹក្សារដ្ឋ) ទាំងក្នុងអង្គការនីតិប្រតិបត្តិ (ក្រុមប្រឹក្សារដ្ឋមន្ត្រី) ហើយនិងងាយស្រួលក្នុងអង្គការតុលាការទៀតផង ព្រោះអ្នកធ្វើការទាំងអស់ សុទ្ធតែជាបក្ខជននៃបក្សប្រជាជនបដិវត្តកម្ពុជា ។ ប៉ុន្តែដើម្បីផលប្រយោជន៍ប្រជាជន យើងសុខចិត្តចរចា ហើយត្រៀមទទួលយក

ដំណោះស្រាយនយោបាយ ដែលនាំដល់ការធ្វើអោយមានបក្សច្រើន ធ្វើសកម្មភាពក្នុងសង្គម ។

បក្សដទៃទៀត សុទ្ធតែប៉ុនប៉ងអោយខ្លួន បានមកធ្វើសកម្មភាព ក្នុងប្រទេស ចង់ដណ្ដើមអំណាច ដោយមានទីតាំងនៅរដ្ឋធានីភ្នំពេញតែម្ដង។ គេប្រើគ្រប់វិធានការ ដើម្បីសំរេចគោលដៅនេះ ប៉ុន្តែសំរេចមិនបាន។ ឥឡូវនេះ បើគេចង់មកដល់ ដោយមិនបាច់វាយគ្នា ខាងយោធានោះ តើអ្វីដែលគេត្រូវសងអោយយើងវិញ? អ្វីដែលជាការទាមទារកំរិតអប្បរមារបស់យើង គឺត្រូវរំលាយចោលកងទ័ពពួកខ្មែរក្រហម ប៉ុល ពត។ ឯភាគីផ្សេងទៀត គឺអាស្រ័យលើឥរិយាបថរបស់គេចំពោះខ្មែរក្រហម យ៉ាងណា? ការទាមទាររំលាយកងទ័ពខ្មែរក្រហម គឺជាថ្នូរដើម្បីប្ដូរយកពីការមិនមានខាងនយោបាយ នៅក្នុងប្រទេស នៅភ្នំពេញ មកជាមានវិញ។ អ្នកនយោបាយនៃភាគីបដិបក្ខ ត្រូវចេញពីសភាពឃោសនាខ្សឹបខ្សៀវលួចលាក់ បាចខិតប័ណ្ណលួចលាក់ មកជាឃោសនាចំហផ្សាយតាមឧគ្ឃោសនស័ព្ទ តាមកាសែត និងវហូតតាមវិទ្យុ ទូរទស្សន៍ផង ប៉ុន្តែតម្លៃដែលគេត្រូវសង គឺរំលាយចោលកងទ័ពខ្មែរក្រហម ប៉ុល ពត។ ការទាមទាររំលាយចោលកងទ័ព ប៉ុល ពត មិនមែនសំរាប់ផលប្រយោជន៍បក្សប្រជាជនបដិវត្តន៍កម្ពុជាមួយនោះទេ តែជាផលប្រយោជន៍ រួមរបស់ប្រជាជនកម្ពុជាទាំងក្នុងប្រទេស និងក្រៅប្រទេស ជាផលប្រយោជន៍របស់បណ្ដាប្រទេស និងអ្នកស្នេហាយុត្តិធម៌លើសកលលោក ដែលព្រួយបារម្ភពីគ្រោះថ្នាក់នៃរបប ប៉ុល ពត ហើយក៏ជាផលប្រយោជន៍របស់ក្រុម សីហនុ សឺន សាន ផងដែរ។ ប៉ុន្តែយើងមិនយល់ថា ហេតុអ្វីបានជា សីហនុ សឺន សាន ជំទាស់នឹងការដែលយើងទាមទារអោយកំចាត់កងទ័ពខ្មែរក្រហម

ទៅវិញ។

ដើម្បីសំរេចនូវគោលបំណង ផ្តួលរំលំសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅលើតុចរចា គេទាមទារអោយរំលាយចោលភ្លាមនូវរបបនេះ ដោយមិនបាច់រង់ចាំការបោះឆ្នោត ដែលជាការរំលោភយ៉ាងកម្រោលលើសិទ្ធិស្វ័យសំរេចរបស់ប្រជាជនកម្ពុជា និងជាការបើកច្រកសំរាប់ការវិលត្រឡប់របស់ពួក ប៉ុល ពត។ កម្លាំងដ៏មានប្រសិទ្ធភាពរាំងស្កាត់ការវិលត្រឡប់របស់ពួក ប៉ុល ពត គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា មិនមែនក្រុម សីហនុ សឺន សាន នោះឡើយ។ ការទាមទារអោយរំលាយរបបនេះមុនការបោះឆ្នោត មុន ប៉ុល ពត រំលាយចោលកងទ័ព គឺជាការបើកទ្វារសំរាប់ទទួលពួកពេជ្ឈឃាដ អោយមកកាប់សម្លាប់ប្រជាជនខ្លួនវិញ។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលអាស្រ័យដោយប្រជាជនកម្ពុជាបោះឆ្នោតជ្រើសតាំងឡើង គឺមានតែប្រជាជនកម្ពុជាមួយគត់ដែលមានសិទ្ធិគ្រប់គ្រាន់ នឹងរំលាយចោលរដ្ឋាភិបាលតាមការបោះឆ្នោត ហើយមានតែប្រជាជនកម្ពុជាទេ ទើបមានសិទ្ធិគ្រប់គ្រាន់ ក្នុងការជ្រើសរើសប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល រដ្ឋសភា ព្រមទាំងកំណត់ពីរបបនយោបាយរបស់កម្ពុជា។ ពួកអ្នកជ្រកក្រោមផ្លាក «សិទ្ធិស្វ័យសំរេចរបស់ប្រជាជនកម្ពុជា» នាំគ្នាធ្វើនូវអ្វីដែលផ្ទុយពីគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិស្វ័យសំរេចទៅវិញ ដោយចង់បន្ទុបអោយប្រជាជនកម្ពុជានូវរដ្ឋាភិបាលមួយ ដែលប្រជាជនមិនបានបញ្ចេញការអនុម័តិតាមការបោះឆ្នោត។ ពួកគេបានខិតខំបំប៉ោងឡើងនូវពាក្យ «របបគ្រប់គ្រងដែលរៀតណាមបន្តុបឡើង» មើលងាយប្រជាជនរាប់លានដែលបាននាំគ្នាទៅបោះឆ្នោត ហើយគេបែរជាចាត់ទុកថាការបោះ

ឆ្នោតនោះមិនស្របច្បាប់អាស្រ័យដោយមានវត្តមានកងទ័ពវៀតណាម នៅកម្ពុជា។ ក្នុងពេលបង្កើតឡើងនូវទ្រឹស្ដីនេះ ពួកគេភ្លេចគិតដល់រដ្ឋាភិបាលស្របច្បាប់នៅប្រទេសជាច្រើន ដែលបានបោះឆ្នោតដោយមានកងទ័ពអាមេរិក ឬកងទ័ពបរទេស ដូចជាបណ្ដាប្រទេសនៅទ្វីបអាហ្វ្រិកមួយចំនួន ប្រទេសនៅទ្វីបអាមេរិកមួយចំនួន ហើយនៅអឺរ៉ុបខាងលិចស្ទើរតែជាទូទៅក៏មានកងទ័ពអាមេរិក ហើយមានរហូតអាវុធនុយក្លេអ៊ែរ និងមធ្យោបាយសង្គ្រាមទំនើបៗ នៅអាស៊ី ជប៉ុន កូរ៉េខាងត្បូង ហ្វីលីពីន ថៃ សុទ្ធតែមានកងទ័ពអាមេរិក ប៉ុន្តែអ្នកទាំងនោះសុទ្ធតែស្របច្បាប់ ក្នុងពេលដែលប្រទេសទាំងនេះ គ្មានការគំរាមកំហែងពីប្រទេសណាអោយពិតប្រាកដផងនោះ។ នៅកម្ពុជា ក្នុងរបប លន់ នល់ វាបែរជាស្របច្បាប់ទៅកើត ក្នុងពេលដែលកងទ័ពអាមេរិក អាយ៉ងព្រៃនគរចូលមកទន្ទ្រានកាន់កាប់ រួចក៏នាំគ្នាដេញ សីហនុ ចេញពីអង្គការសហប្រជាជាតិ ហើយប្រគល់អោយពួកប្ញូន់អំណាច លន់ នល់ ទៅអង្គុយជំនួសវិញ។ ឯចំពោះសាធារណរដ្ឋប្រជាមានិតកម្ពុជា គេចាត់ទុកជាបញ្ហាផ្សេងទៅវិញ ដោយយោងទៅលើរបបនេះ មិនបានផ្ដល់អ្វី ជាផលប្រយោជន៍អោយគេ។

ឈរលើគោលការណ៍គោរពនូវសិទ្ធិស័យសំរេចរបស់ប្រជាជន និងគោលការណ៍គោរពផលប្រយោជន៍ប្រជាជន ក្នុងដំណោះស្រាយនយោបាយ យើងយល់ព្រមអោយមានរដ្ឋាភិបាលចំរុះមួយក្រោយការបោះឆ្នោត ដោយយកការសំរេចរបស់ប្រជាជនធ្វើជាការកាត់សេចក្ដីជំនួសប្រទេសក្រៅ ដែលចង់បង្កើតរបបមួយលើក្បាលប្រជាជនកម្ពុជា។ ដើម្បីឈានទៅដល់ទិសដៅ គឺត្រូវរក្សាទុកស្ថានភាពបច្ចុប្បន្ននៅកម្ពុជា

*ទាំងនយោបាយ និងយោធា ពោលគឺកម្លាំងណា នៅទីណាគឺនៅទីនោះ បង្កើតឡើងនូវគណៈកម្មការ ឬក្រុមប្រឹក្សាបោះឆ្នោតហើយដំណើរការបោះឆ្នោតដោយមានការត្រួតពិនិត្យ ពីគណៈកម្មការត្រួតពិនិត្យអន្តរជាតិ ដើម្បីជ្រើសរើសរដ្ឋសភា រួចរដ្ឋសភាដាក់អោយប្រើរដ្ឋធម្មនុញ្ញថ្មី និងបង្កើតរដ្ឋាភិបាលថ្មី ហើយរដ្ឋាភិបាលថ្មីនេះជាអ្នកសំរេចរៀបចំកងទ័ពមួយរបស់រដ្ឋកម្ពុជានៅថ្ងៃអនាគត។ ការបោះឆ្នោត ត្រូវធ្វើឡើងបន្ទាប់ពីការដកចេញអស់ពីកម្ពុជា នូវកងទ័ពវៀតណាម និងការបញ្ឈប់ជំនួយអោយកម្លាំងខ្មែរបដិបក្ខ។ ខាងភាគីប្រឆាំងគេលើកឡើងថា បោះឆ្នោតរបៀបនេះមិនស្មើភាពទេ អាស្រ័យដោយសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រួតត្រាទឹកដី និងប្រជាជន។ គេមិនត្រូវទាមទារអោយលើសពីនេះឡើយ ព្រោះទុនគេមានតិច វាយតាមយោធាដណ្តើមមិនបាន។ ការដែលសាធារណរដ្ឋប្រជាមានិតកម្ពុជា ផ្តល់លទ្ធភាពអោយគេមកចូលរួមបោះឆ្នោត វាជាការធ្វើសម្បទានដ៏ធំណាស់ទៅហើយ ហើយវិធានការនេះ វាប្រសើរជាងវិធានការដែលសម្តេច សីហនុ បានធ្វើក្រោយសន្និសីទហ្សឺណែវ ឆ្នាំ ១៩៥៤ ដែលពេលនោះ គាត់ទាមទារអោយរំលាយចោលកងទ័ពនៃគូប្រឆាំងសិន ទើបអោយបក្សនយោបាយចូលរួមបោះឆ្នោតក្រោមរដ្ឋអំណាចរបស់គាត់។ ពេលនេះ យើងគ្រាន់តែទាមទារអោយរក្សាទុកស្ថានភាពដដែល ផ្នែកនយោបាយ និងយោធារហូតដល់ដំណើរការបោះឆ្នោតហើយស្រេច មានន័យថា គេនៅរក្សាបាននូវកម្លាំងនយោបាយ និងយោធាទៀតផង ហើយរក្សាទុកតំបន់ត្រួតត្រារបស់ភាគីដទៃ បើសិនគេមាន។*

*ប៉ុន្តែប៉ុន្មានខែកន្លងមកនេះ ចិន និងថៃ បានខិតខំអនុវត្តនូវ «យុទ្ធ*

សាស្ត្រតភ្ជាប់» ហើយចិនលើកឡើងនូវពាក្យថា របបខ្មែរក្រហមក៏គ្រោះថ្នាក់ របប ហេង សំរិន ក៏គ្រោះថ្នាក់ដែរ ត្រូវកំចាត់ចោលទាំងអស់គ្នា។ ក្នុងឱកាសប្រជុំក្រុមការងាររបស់ការប្រជុំក្រៅផ្លូវការនៅហ្សាការតា ថៃលើកឡើងអំពីវិធានការទប់ស្កាត់នូវអំពើប្រល័យពូជសាសន៍ដោយសំដៅទៅលើរបបពីរផ្សារភ្ជាប់គ្នា គឺទាំង ប៉ុល ពត ទាំង ហេង សំរិន។ សឺន សាន ក៏បានលើកដូចគ្នា នៅអង្គការសហប្រជាជាតិ។ ចិន និងថៃបានដឹងច្បាស់ថា បើទុកសាធារណរដ្ឋប្រជាមានិតកម្ពុជា ពួកខ្មែរក្រហមមិនអាចធ្វើភ្លៀងធ្វើផ្គរបានតាមទំនើងចិត្តឡើយ ហើយចិនក៏ដូចជាថៃ មិនអាចស្តារឡើងវិញនូវឥទ្ធិពល និងផលប្រយោជន៍របស់គេនៅកម្ពុជា តាមបំណងដែលគេចង់បាននោះដែរ។ ទាំងចិន ទាំងថៃសុទ្ធតែចង់បន្ធូរបន្ថយនូវកម្លាំងសង្កត់របស់សាធារណមតិ ដែលទាមទារអោយកំចាត់ចោលពួក ប៉ុល ពត ដោយខិតខំបង្វែរការគាបសង្កត់ខ្លះ មកអោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ក្នុងពេលដែលសាធារណមតិសកលលោក ក៏ដូចជាប្រជាជនកម្ពុជាកំពុងបង្កើនការទាមទារអោយកំចាត់ចោលពួក ប៉ុល ពត នោះ ចិន អាមេរិក ប្រទេសប៉ែកខាងលិច និងអាស៊ាន បានឈានទៅតាមផ្លូវមួយជាមួយគ្នា គឺការប្រើ «សន្ទឹកបៀ សីហនុ» ដើម្បីដោះស្រាយបញ្ហាកម្ពុជា ហើយដើម្បីការពារបាននូវអំណាចរបស់ សីហនុ ដែលកម្លាំងគាត់ខ្សោយជាងគេនោះ ម្យ៉ាងគេទាមទារបញ្ជូនមកកម្ពុជា នូវកងរក្សាសន្តិសុខអន្តរជាតិ ម្យ៉ាងទៀត គេប្រញាប់ប្រញាល់ជួយកសាងកម្លាំងយោធាអោយក្រុម សីហនុ និងសឺន សាន គឺអាមេរិកបានបង្កើនជំនួយដោយមានទាំងជំនួយយោធាផង ។ ចំពោះកងរក្សាសន្តិសុខ ដែលគេ

ទាមទារអោយបញ្ជូនមកកម្ពុជា គឺពួកគេមិនហ៊ានលើកត្រង់ៗថា មក ដើម្បីវាយសាធារណរដ្ឋប្រជាមានិតកម្ពុជាផង រាំងស្កាត់ខ្មែរក្រហមផង ដើម្បីពង្រឹងអំណាចត្រួតត្រា និងការពារអោយ សីហនុ សឺន សាន នោះ ឡើយ ហើយគេឆ្លៀតប្រើប្រាស់ចិត្តសាស្ត្ររបស់សាធារណរដ្ឋប្រជាមា និតកម្ពុជា ដែលបានចាត់ទុក ប៉ុល ពត ជាគ្រោះថ្នាក់ ដោយលើកឡើង ថា «បញ្ជូនមកកម្ពុជា នូវកងរក្សាសន្តិសុខអន្តរជាតិ ដើម្បីរាំងស្កាត់ការ វិលត្រឡប់នៃរបប ប៉ុល ពត បន្ទាប់ពីកងទ័ពវៀតណាមដកចេញ»។ ចេញពីនេះ គេបកស្រាយថា គោលដៅនៃកងរក្សាសន្តិសុខអន្តរជាតិ គឺទីមួយ ដើម្បីរំលាយពួក ប៉ុល ពត ទីពីរ ដើម្បីរាំងមិនអោយមាន សង្គ្រាមរវាងភាគីកម្ពុជា ទីបី ដើម្បីចាត់តាំងការបោះឆ្នោត។ តាមខ្លឹម សារការងារនេះ កងរក្សាសន្តិសុខអន្តរជាតិ គឺជាកងកម្លាំងកាន់កាប់ កម្ពុជា ដែលជាការរំលោភលើសិទ្ធិស្វ័យសំរេចរបស់ប្រជាជនកម្ពុជា ព្រោះការងារនេះ សុទ្ធតែជាកិច្ចការផ្ទៃក្នុងរបស់ប្រជាជនកម្ពុជា បើគេមក ធ្វើការងារនេះ គឺពិតជាគេចង់យកកម្លាំងនេះ ដើម្បីកាន់កាប់ពីលើរដ្ឋាភិ បាលកម្ពុជា។ ហើយការដែលគេលើកឡើងថា កងរក្សាសន្តិសុខអន្តរ ជាតិមកកម្ពុជានេះ គឺដើម្បីរាំងស្កាត់ ប៉ុលពត នោះគឺជារឿងបោក ប្រាស់សាធារណមតិយ៉ាងពេញទី ព្រោះថា បើគេចង់កំចាត់ ប៉ុល ពត មែន ហេតុអ្វីបានជាគេធ្វើសកម្មភាពគាំទ្រដល់ ប៉ុល ពត និងបែរជា ខិតខំធ្វើអោយកម្លាំងប្រឆាំង ប៉ុល ពត ខ្សោយទៅវិញ។ វត្តមានកងទ័ព វៀតណាមនៅកម្ពុជា គឺដើម្បីរាំងស្កាត់ការវិលត្រឡប់របស់ ប៉ុល ពត ហេតុអ្វីបានជាគេនាំគ្នាថ្កោលទោសវៀតណាមទៅវិញ។ សាធារណរដ្ឋ ប្រជាមានិតកម្ពុជា ជាកម្លាំងដ៏សំខាន់ ដែលបានចូលរួមពីគ្រប់ស្រទាប់

ប្រជាជន ក្នុងការប្រឆាំងពួក ប៉ុល ពត ហេតុអ្វីក៏គេនាំគ្នាធ្វើអោយកម្លាំងនេះ ចុះខ្សោយទៅវិញ។ ប្រជាជនកម្ពុជា មានលទ្ធភាពគ្រប់គ្រាន់ ក្នុងការរាំងស្កាត់ការវិលត្រឡប់របស់ ប៉ុល ពត និងធ្វើអោយ ប៉ុល ពត រលំរលាយ ប្រសិនបើប្រទេសក្រៅឈប់ជួយពួកនេះ។ ហេតុអ្វីបានជាគេមិនទុកអោយប្រជាជនកម្ពុជាខ្លាំង និងជួយប្រជាជនកម្ពុជាកំចាត់ ប៉ុល ពត ខ្លួនឯង។ ហើយការជួយនេះ មិនចាំបាច់ចំណាយកម្លាំងច្រើនផង គ្រាន់តែបញ្ឈប់ជំនួយអោយពួក ប៉ុល ពត តែប៉ុណ្ណោះ។ បើវៀតណាមជួយប្រជាជនកម្ពុជា កំចាត់ពួក ប៉ុល ពត ហើយ ហេតុអ្វីមិនលើកទឹកចិត្តអោយធ្វើការងារនេះ។ ការទាមទារអោយដកកងទ័ពបរទេសនៃប្រទេសមួយ ដែលបានមកជួយធ្វើការកិច្ចកំចាត់ ប៉ុល ពត និងការបញ្ជូនមកកម្ពុជា នូវកងទ័ពបរទេសជាច្រើនប្រទេស ដើម្បីកំចាត់ ប៉ុល ពត គឺជារឿងដែលមិនអាចយល់បាន។ បើគេមិនត្រូវការកងទ័ពបរទេសនៅកម្ពុជា ហេតុអ្វីក៏គេទាមទារបញ្ជូនមកកម្ពុជា នូវកងទ័ពបរទេស ដែលមានច្រើនប្រទេសយ៉ាងដូច្នេះ។ ពិតប្រាកដណាស់ គេចង់ប្រើប្រាស់ផ្លាកប្រឆាំង ប៉ុល ពត ដើម្បីបញ្ជូនមកកម្ពុជា នូវកងរក្សាសន្តិសុខអន្តរជាតិ ម្យ៉ាងគឺដើម្បីរក្សាអោយគង់វង្សនូវកម្លាំង ប៉ុល ពត ជៀសវាងនូវការកំចាត់ទាំងស្រុង ម្យ៉ាងគឺដើម្បីវាយយកសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីសំរេចគោលដៅចុងក្រោយគឺធ្វើអោយ សីហនុ សឺន សាន ដណ្តើមបានអំណាចត្រួតត្រា ដែលនាំដល់ការបង្កើតឡើងនូវរបបស្និទ្ធអាមេរិក និងលោកខាងលិចនៅកម្ពុជា។ តាមពត៌មានមកពីមជ្ឈដ្ឋានអ្នកនយោបាយជាន់ខ្ពស់បារាំងថា «អាមេរិកចង់បញ្ជូនមកភ្នំពេញ នូវកងរក្សាសន្តិសុខអន្តរជាតិចំនួន ៧.០០០ នាក់ ដើម្បីការពារ

រដ្ឋាភិបាល សីហនុ»។ ច្បាស់លាស់ណាស់ កងរក្សាសន្តិសុខអន្តរជាតិ មកកម្ពុជា មិនមែនមកដើម្បីកំចាត់ ប៉ុល ពត ឡើយ គឺមកដើម្បីដណ្តើម អំណាចអោយ សីហនុ ហើយមួយផ្នែកទៀតគឺដើម្បីការពារការស្ថិត ស្ថេរនៃកម្លាំង ប៉ុល ពត ស្របតាមយុទ្ធសាស្ត្ររបស់ចិន ដែលបានដក ថយពីដំណាក់កាល ប៉ុល ពត ដណ្តើមម្នាក់ឯង មកកាន់ដំណាក់កាល ការពារកម្លាំងអោយ ប៉ុល ពត តាមរយៈនៃការប្រើប្រាស់កងរក្សាសន្តិ សុខអន្តរជាតិ។ គេខិតខំអនុវត្តយុទ្ធសាស្ត្រអង្គុយលើកំពូលភ្នំមើលខ្លា និងសិង្ហខាំគ្នា។ គ្មានពេលណាដែលអាមេរិក អាស៊ាន ប្រទេសប៉ែកខាង លិច សីហនុ សឺន សាន អនុវត្តវិធានការដាច់ខាត ក្នុងការកំចាត់ ប៉ុល ពត ពិតប្រាកដឡើយ។ គេត្រូវរក្សាការស្ថិតស្ថេរនៃកម្លាំង ប៉ុល ពត ដើម្បីធ្វើជា កម្លាំងទប់ជាមួយកម្លាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា។ គេត្រូវធៀតប្រើប្រាស់ទំនាស់រវាងកម្លាំងទាំងពីរ ដើម្បីគេបានឱកាស ពង្រីងអំណាចអោយ សីហនុ សឺន សាន។ សម្តេច សីហនុ បាននិយាយ នៅក្នុងឱកាសចរចាលើកទី ២ ហ៊ុន សែន-សីហនុ កាលពីខែមករា ១៩៨៨ ថា «បើខ្មែរក្រហមគំរាមកំហែងខ្ញុំ ខ្ញុំនឹងទៅជាមួយឯកឧត្តម ហ៊ុន សែន ប្រឆាំងខ្មែរក្រហមវិញ បើឯកឧត្តម ហ៊ុន សែន គំរាមកំហែង ខ្ញុំ ខ្ញុំនឹងទៅជាមួយខ្មែរក្រហម ប្រឆាំងនឹងឯកឧត្តម ហ៊ុន សែន វិញ»។ នេះក៏ជាវិធីចាប់ត្រីដៃទាំងពីរ ដើម្បីបំរើផ្ទាំងខ្លួន ដែលអាមេរិក អាស៊ាន ប្រទេសប៉ែកខាងលិច ឯកភាពគ្នាដំណើរការក្នុងបច្ចុប្បន្ន និងទៅ អនាគត គេលើកឡើងអំពីកងរក្សាសន្តិសុខអន្តរជាតិ ធ្វើភារកិច្ចរាំង មិនអោយមានសង្គ្រាមរវាងភាគីកម្ពុជា តែពួកគេភ្លេចគិតថា សន្តិភាព នៅកម្ពុជាកើតមានបាន អាស្រ័យដោយភាគីកម្ពុជា ជាអ្នកកំណត់។

ប្រសិនបើបណ្តាភាគីកម្ពុជា ចង់មានសន្តិភាពទាំងអស់គ្នា ត្រូវស្វែងរករូបមន្ត ដើម្បីរាំងស្កាត់កុំអោយមានសង្គ្រាម ប៉ុន្តែប្រសិនបើគេចង់មានសង្គ្រាមវិញនោះ គឺគ្មានអ្នកណាត្រួតត្រាបានឡើយ។ ដូចជា អ៊ីរ៉ង់-អ៊ីរ៉ាក់ អង្គការសហប្រជាជាតិ មិនអាចរារាំងសង្គ្រាមរវាងប្រទេសទាំងពីរនេះបានឡើយ នៅមុនពេលដែលប្រទេសទាំងពីរនេះប្រកាសឈប់ធ្វើសង្គ្រាមប្រឆាំងគ្នាដោយខ្លួនឯង។ នៅលីបង់ ទោះជាកងរក្សាសន្តិសុខអន្តរជាតិ មិនធ្វើការត្រួតត្រាផ្ទៃក្នុងលីបង់ ប៉ុន្តែកងរក្សាសន្តិសុខ ដែលបោះប្រចាំនៅទីនោះទទួលការវាយប្រហារ ធ្វើអោយគ្រោះថ្នាក់ដល់កងរក្សាសន្តិសុខអន្តរជាតិជាច្រើន ហើយក៏មិនអាចបំព្រួញនូវក្របខណ្ឌជម្លោះនៅទីនោះបានដែរ។ នៅកម្ពុជាក៏ដូចគ្នា សន្តិភាពសំរេចលើប្រជាជនកម្ពុជាខ្លួនឯង។ ប្រសិនបើបញ្ជូនចូលមកកម្ពុជា នូវកងរក្សាសន្តិសុខអន្តរជាតិ គឺជាការបន្ថែមអាវុធចូលកម្ពុជា សង្គ្រាមអាចបើកពង្រីកក្របខណ្ឌរបស់វា ហើយអាចនាំដល់ការប្រយុទ្ធគ្នា រវាងកងរក្សាសន្តិសុខជាមួយគ្នាលើទឹកដីកម្ពុជាផង ព្រោះត្រូវមានកងទ័ពប្រទេសជាច្រើន មាននិន្នាការប្លែកៗគ្នា។ ការប្រើប្រាស់កងរក្សាសន្តិសុខអន្តរជាតិ ដើម្បីចាត់តាំង និងត្រួតពិនិត្យការបោះឆ្នោត គឺជាការប្រើប្រាស់កម្លាំងអាវុធ សង្កត់លើសិទ្ធិស្វ័យសំរេចរបស់ប្រជាជនកម្ពុជា។ ដូច្នេះ គ្រប់ភារកិច្ចដែលគេត្រូវធ្វើនៅកម្ពុជា តាមនិយមន័យអោយត្រឹមត្រូវ គឺជា «កងកម្លាំងអន្តរជាតិកាន់កាប់កម្ពុជា»។

ដើម្បីបង្ខំអោយប្រជាជនកម្ពុជាទទួលយក ពួកគេបានស្វះស្វែងទាមទារយកបញ្ហាកម្ពុជា ទៅដោះស្រាយនៅក្នុងសន្និសីទអន្តរជាតិ។ ចុងក្រោយនេះ ខែកក្កដា ១៩៨៨ សីហនុ ស្នើអោយអគ្គលេខាធិការ

អង្គការសហប្រជាជាតិ កោះប្រជុំសន្និសីទអន្តរជាតិ ហើយខែកញ្ញា ១៩៨៨ សីហនុ ស្នើអោយប្រធានាធិបតីបារាំង កោះប្រជុំសន្និសីទអន្តរជាតិ ដើម្បី «ដោះស្រាយ» បញ្ហាកម្ពុជា»។ ចិនស្នើអោយយកបញ្ហាកម្ពុជាពិភាក្សារវាងសមាជិកអចិន្ត្រៃយ៍ទាំងប្រាំប្រទេស នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ នេះគឺជាការដោះស្រាយ ដោយរំលោភលើគោលការណ៍ «បញ្ហាផ្ទៃក្នុងកម្ពុជា ដែលត្រូវដោះស្រាយរវាងភាគីខ្មែរជាមួយគ្នា»។ ធ្វើយ៉ាងនេះ គេងាយស្រួលបង្ខំអោយប្រជាជនកម្ពុជាទទួលយកនូវក្របខ័ណ្ឌដំណោះស្រាយ ដែលគេបង្កើតឡើង។

ចំពោះយើង យើងចាត់ទុកថា រាល់ការត្រួតពិនិត្យអន្តរជាតិសុទ្ធតែឈរលើមូលដ្ឋាននៃការគោរពឯករាជ្យ អធិបតេយ្យរបស់កម្ពុជា និងត្រូវបានកម្ពុជាព្រមព្រៀង។ យើងត្រៀមខ្លួនទទួលយកគណៈកម្មការត្រួតពិនិត្យអន្តរជាតិ ដែលមកធ្វើការកិច្ច តាមការព្រមព្រៀង និងសំរេចពីបណ្តាភាគីកម្ពុជា លើមូលដ្ឋានគោរពឯករាជ្យ អធិបតេយ្យកម្ពុជា។ គេអាចធ្វើការកិច្ចត្រួតពិនិត្យមើលការដកកងទ័ពវៀតណាម ត្រួតពិនិត្យការបញ្ឈប់ជំនួយអោយភាគីខ្មែរបដិបក្ខ ត្រួតពិនិត្យមើលការឈប់បាញ់គ្នា និងចូលរួមជាមួយបណ្តាភាគីកម្ពុជា និងប្រជាជនកម្ពុជា ត្រួតពិនិត្យមើលការបោះឆ្នោត ។ បញ្ហាសំខាន់ គឺត្រូវប្រើប្រាស់នូវសិទ្ធិអំណាចពេញលេញរបស់ប្រជាជន ដើម្បីត្រួតពិនិត្យ។ បញ្ហាសន្និសីទអន្តរជាតិដែលគេត្រូវធ្វើគឺដើម្បី «ធានានូវបណ្តាប្រការដែលបានព្រមព្រៀង» តែមិនមែនជាសន្និសីទដើម្បី «សំរេចកិច្ចព្រមព្រៀងនោះឡើយ»។ ធ្វើយ៉ាងនេះទើបសមស្របនឹងលក្ខការណ៍ «បញ្ហាផ្ទៃក្នុងកម្ពុជា អាស្រ័យដោយប្រជាជនកម្ពុជាដោះស្រាយ បញ្ហាអាស៊ីអាគ្នេយ៍ អាស្រ័យដោយ

ប្រជាជនអាស៊ីអាគ្នេយ៍ដោះស្រាយ»។ សន្និសីទអន្តរជាតិណាមួយ ដែលធ្វើឡើងដោយគ្មានការព្រមព្រៀងគ្នាជាមុន រវាងភាគីដែលមានជំលោះ និងភាគីដែលជាប់ទាក់ទិនទេនោះ វាមិនគ្រាន់តែបរាជ័យប៉ុណ្ណោះទេ ប៉ុន្តែវានឹងឈានទៅរកភាពទ័លច្រក និងការប្រឈមមុខសាជាថ្មី។ ដូច្នេះ វេទិកានៃការប្រជុំក្រៅផ្លូវការនៅហ្សាការតា និងវេទិកាផ្ទៃក្នុងកម្ពុជា គឺជាមូលដ្ឋានដ៏សំខាន់បំផុតសំរាប់កំណត់ជោគជ័យ នៃសន្និសីទអន្តរជាតិ ដែលគេត្រូវតែជំរុញអោយវេទិកាទាំងពីរប្រព្រឹត្តទៅបានល្អ។

និយាយដល់លក្ខការណ៍ បញ្ហាអាស៊ីអាគ្នេយ៍ គឺត្រូវដោះស្រាយដោយប្រជាជនអាស៊ីអាគ្នេយ៍។ ភាពចាំបាច់ គេត្រូវដាក់ការដោះស្រាយបញ្ហាកម្ពុជា ទៅក្នុងក្របខ័ណ្ឌនៃការដោះស្រាយបញ្ហាសន្តិភាពស្ថិរភាពនៅអាស៊ីអាគ្នេយ៍ ហើយបញ្ហារួម និងដោយឡែកនេះ ត្រូវធ្វើដំណើរទៅព្រមគ្នា ឬក៏ត្រូវដោះស្រាយបញ្ហាសន្តិភាព ស្ថិរភាព នៅអាស៊ីអាគ្នេយ៍មុន ដើម្បីបង្កើតនូវជំនឿទុកចិត្ត សំរាប់ធ្វើជាមូលដ្ឋានអោយការដោះស្រាយបញ្ហាកម្ពុជា។ ការដោះស្រាយបញ្ហាកម្ពុជា ដាច់ដោយឡែកពីបញ្ហាតំបន់ ពិតជាមិនអាចនាំមកនូវសន្តិភាពដ៏យូរអង្វែងបានឡើយ។ បទពិសោធន៍នៃការដោះស្រាយបញ្ហាសង្គ្រាមឥណ្ឌូចិនប៉ុន្មានលើកមកហើយ គឺមិនបានបញ្ចប់នូវបញ្ហា ហើយក៏មិនបាននាំមកនូវសន្តិភាពដ៏យូរអង្វែងបានដែរ ព្រោះគេគ្រាន់តែបានចង់ដៃប្រជាជនឥណ្ឌូចិនតែប៉ុណ្ណោះ ឯប្រទេសផ្សេងទៀត នៅក្នុងតំបន់នេះ នៅតែមានសិទ្ធិធ្វើសកម្មភាព ប្រឆាំងបណ្តាប្រទេសនៅឥណ្ឌូចិន ដូចជា ថៃជាដើម ព្រោះគេមិនដែលបានចូលរួម ក្នុងដំណោះស្រាយនយោបាយ

ឡើយ ហើយក៏វានៅតែមានហេតុផល សំរាប់ការមិនទុកចិត្តគ្នា។ ការដោះស្រាយម្តងនេះ គឺត្រូវផ្សារភ្ជាប់នូវបញ្ហាទាំងពីរ បញ្ហាកម្ពុជាក៏ត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃបញ្ហាសន្តិភាព ស្ថិរភាព នៅអាស៊ីអាគ្នេយ៍ ហើយបញ្ហានេះ ត្រូវតែប្រជាជនអាស៊ីអាគ្នេយ៍រួមគ្នាដោះស្រាយ ទើបបង្កើតឡើងនូវមូលដ្ឋាននៃការទុកចិត្តគ្នា ហើយជាមូលដ្ឋានសំរាប់សន្តិភាពដ៏យូរអង្វែងក្នុងតំបន់នេះ។ ប្រសិនបើមានការជឿទុកចិត្តគ្នាហើយ គឺគ្មានប្រទេសណាមួយស្វែងរកឧត្តមភាព ក្នុងការដោះស្រាយបញ្ហាកម្ពុជា ដើម្បីផលប្រយោជន៍ខ្លួន។

រួមសេចក្តីមក ទាំងដំណោះស្រាយរួម ទាំងដំណោះស្រាយតាមផ្នែកសុទ្ធសឹងតែជាបញ្ហាស្មុគស្មាញ ហើយវាងាយទ័លច្រក អាស្រ័យដោយភាគីម្ខាងទៀត នៅតែបង្កប់ទៅដោយឧបាយកលឆ្លលរំលំ ព្រោះអ្វីដែលគេលើកឡើង គឺគ្មានបង្ហាញអំពីភាពទន់ភ្លន់ចង់ដោះស្រាយនោះទេ តែផ្ទុយទៅវិញ គេកំពុងស្វែងរកចំណេញពីការដោះស្រាយតាមផ្លូវនយោបាយ ដើម្បីផលប្រយោជន៍របស់គេ ហើយដែលគោលដៅចុងក្រោយ គឺលុបបំបាត់អោយបាននូវសមិទ្ធផល ដែលប្រជាជនកម្ពុជាខិតខំកសាង ១០ ឆ្នាំកន្លងទៅ។ ប្រការដែលជាឧបសគ្គធំបំផុត គឺបញ្ហាប៉ុល ពត ដែលប្រជាជនកម្ពុជា មិនអាចយោគយល់ ឬមិនអាចអត់អោនអោយបាន ព្រោះវាជាគន្លឹះផ្ទុះនៃសង្គ្រាមស៊ីវិល។ ដូច្នេះ ពីនេះរហូតដល់ចុងឆ្នាំ ១៩៩០ សភាពការណ៍កម្ពុជា ក៏មានលទ្ធភាពជាច្រើនវិវត្តទៅតាមលទ្ធភាព ទីបី គឺលទ្ធភាពគ្មានដំណោះស្រាយនយោបាយ។ ការប្រយុទ្ធគ្នា និងការចរចាគ្នា ត្រូវធ្វើជាបន្ត ប៉ុន្តែមិនអាចរកច្រកចេញបាន តាមផ្លូវនយោបាយឡើយ។ ឆ្នាំ ១៩៩០ កងទ័ពវៀតណាមនឹងដក

ចេញអស់ពីកម្ពុជា គឺបញ្ហាកងទ័ពវៀតណាម ត្រូវបានដោះស្រាយដោយខ្លួនឯង ក្នុងពេលពួក ប៉ុល ពត និងខ្មែរបដិបក្ខនៅសេសសល់ ហើយធ្វើសង្គ្រាមបន្ត។ សង្គ្រាមនៅពេលនេះ ជាសង្គ្រាមប្រឆាំងប្រជាជនកម្ពុជាពិតប្រាកដហើយ។ ពីឆ្នាំ ១៩៧៩-១៩៩០ គេធ្វើសង្គ្រាមប្រឆាំងប្រជាជនកម្ពុជា ជ្រកក្រោមផ្លាកប្រឆាំងវៀតណាម នៅកម្ពុជា តែក្រោយឆ្នាំ ១៩៩០ ពេលកងទ័ពវៀតណាមដកអស់ គេគ្មានហេតុផលអ្វីនឹងធ្វើសង្គ្រាមទៀតឡើយ ហើយបើគេបន្ត គឺត្រូវប្រឆាំងប្រជាជនកម្ពុជាដោយផ្ទាល់តែម្តង។ ប្រទេសក្រៅដែលធ្លាប់ជួយពួក ប៉ុល ពត និងខ្មែរបដិបក្ខដូចគ្នា គឺពេលមុនប្រឆាំងប្រជាជនកម្ពុជា ក្រោមផ្លាកប្រឆាំងវៀតណាម។ ក្រោយឆ្នាំ ១៩៩០ បើគេបន្តជួយពួកនេះ នោះវាជាការជួយធ្វើសង្គ្រាម ដើម្បី «បង្កើតរបប ប៉ុល ពត» ពិតប្រាកដហើយ។ ក្រោយឆ្នាំ ១៩៩០ ប្រសិនបើមានការចរចាបន្តទៀត ក៏នៅសេសសល់តែបញ្ហា ប៉ុល ពត និងការបញ្ឈប់ជំនួយពីខាងក្រៅអោយពួកខ្មែរបដិបក្ខប៉ុណ្ណោះ គ្មានបញ្ហាកងទ័ពវៀតណាម យកទៅដោះស្រាយដូចសព្វថ្ងៃទៀតឡើយ។ តាមលទ្ធភាពទីបីនេះ សង្គ្រាមត្រូវអូសបន្ទាយពេលច្រើនឆ្នាំតទៅទៀត ប៉ុន្តែខ្លឹមសារ និងរូបភាពនៃសង្គ្រាម មានការផ្លាស់ប្តូរ អាស្រ័យខាងភាគីសាធារណរដ្ឋប្រជាមានិតកម្ពុជា គ្មាននៅសល់កងទ័ពវៀតណាមជួយទៀតឡើយ តែគឺនៅសេសសល់ប្រទេសក្រៅជួយពួក ប៉ុល ពត និងខ្មែរបដិបក្ខ ធ្វើសង្គ្រាមប្រឆាំងប្រជាជនកម្ពុជាទៅវិញ។

តាមការប្រមើលមើលមកខាងលើនេះ វាហាក់ដូចជា «ច្រកនៃសង្គ្រាមច្រើនជាងច្រកនៃសន្តិភាព»។ វាពិតជាដូច្នេះ ព្រោះបញ្ហា ប៉ុល ពត មិន

ទាន់បានដោះស្រាយ។ «ប៉ុល ពត ជាច្រកទ្វារនៃសង្គ្រាម ហើយក៏ជាច្រកទ្វារនៃសន្តិភាព» ពោលគឺ បើពួក ប៉ុល ពត មិនត្រូវបានដកអាវុធទេ សង្គ្រាមត្រូវមានជាបន្ត តែទ្រង់ទ្រាយខុសគ្នា បើខ្មែរក្រហមចូលរួមដោះស្រាយ ដោយមានទាំងនយោបាយ និងយោធា សង្គ្រាមនឹងមានទ្រង់ទ្រាយធំ ដែលមិនអាចត្រួតត្រាបាន។ បើខ្មែរក្រហមនៅមានអាវុធតែស្ថិតនៅក្រៅដំណោះស្រាយនយោបាយ ហើយមិនបានការជួយឧបត្ថម្ភពីប្រទេសក្រៅដូចពេលមុន សង្គ្រាមនឹងបន្ត ប៉ុន្តែក្របខ័ណ្ឌសង្គ្រាមនឹងកាន់តែតូចទៅៗ។ សន្តិភាពកើតមានទៅបាន លុះត្រាតែពួក ប៉ុល ពត ត្រូវបានរំលាយចោល នូវអង្គការចាត់តាំងខាងយោធា។

ដោយសារតែមានបញ្ហា ប៉ុល ពត នេះហើយ ដែលតម្រូវអោយប្រជាជនកម្ពុជា បន្តការប្រយុទ្ធ។ ជិត ២០ ឆ្នាំនៃសង្គ្រាម បានធ្វើអោយប្រជាជនធុញទ្រាន់ណាយនឹងសង្គ្រាម ធ្វើអោយប្រទេសត្រូវបំផ្លិចបំផ្លាញដល់ឫសគល់ ហើយគ្មានពេលនឹងកសាង។ ប៉ុន្តែ មិនមែនដោយសារបញ្ហានេះ គេបែរជានាំគ្នាបញ្ឈប់ការប្រយុទ្ធ ហើយសុខចិត្តទទួលយក ប៉ុល ពត មកវិញនោះឡើយ ព្រោះការបន្តការប្រយុទ្ធ វាខូចខាតតិចជាងអំពើប្រល័យពូជសាសន៍ ប៉ុល ពត។ យើងស្អប់ខ្ពើមសង្គ្រាម ប៉ុន្តែត្រូវទទួលយកការធ្វើសង្គ្រាម ព្រោះជាសង្គ្រាមដែលសត្រូវបង្ខំអោយយើងត្រូវធ្វើ បើមិនដូច្នេះទេ គ្មានអ្នកណាស្លាប់ និងឈឺចាប់ជំនួសប្រជាជនកម្ពុជាទេ ពេលដែល ប៉ុល ពត ត្រឡប់មកវិញ។ ពួកអ្នកមិនស្គាល់រសជាតិ ប៉ុល ពត មិនបានដឹងទេថា អ្វីដែលហៅថាការឈឺចាប់ ការស្លាប់ការព្រាត់ប្រាស់ ការអត់ឃ្លាន ការលំបាកវេទនារាប់ម៉ឺនជំពូក។ ពួកគេនោះងាយនឹងស្រមើស្រមៃ ហើយងាយនឹងធ្វើសម្បទានផលប្រយោជន៍

ជាអាយុជីវិតរបស់ប្រជាជនកម្ពុជាទៀតផង។ ការប្រយុទ្ធរបស់យើង មិនមែនជាការនិយមសង្គ្រាមនោះឡើយ ប៉ុន្តែជាសង្គ្រាមដើម្បីសន្តិភាព ដើម្បីការសុខសាន្តរបស់ប្រជាជន ដែលជាសិទ្ធិរស់នៅគ្មានការគំរាមកំហែងពីពួក ប៉ុល ពត។

សង្គ្រាមបន្ត ឯសន្តិភាពហាក់ដូចជានៅឆ្ងាយ ពីប្រជាជនកម្ពុជានៅឡើយ។ ផ្លូវឆ្ពោះទៅរកសន្តិភាព ត្រូវផ្អែកសំខាន់ទៅលើកម្លាំងរបស់ប្រជាជនកម្ពុជា និងការជួយឧបត្ថម្ភពីមិត្តភក្តិ ដែលស្នេហាសន្តិភាព និងយុត្តិធម៌នៅលើសកលលោក។

# ការកែទម្រង់

*១០ ឆ្នាំលើកំណាត់ផ្លូវដែលបានឆ្លងកាត់ យើងកំណត់ច្បាស់ថា មាគ៌ារបស់បក្សពិតជាត្រឹមត្រូវ ទើបនាំមកនូវជ័យជំនះក្នុងការតស៊ូជាមួយខ្មាំងសត្រូវ និងក្នុងការកសាងប្រទេសឡើងវិញ។ យើងមានគុណសម្បត្តិជាច្រើន ក្នុងការដាក់ចេញនូវគោលមាគ៌ានយោបាយ និងការចាត់តាំងអនុវត្តន៍តាមដំណាក់កាលនីមួយៗ ស្របតាមសភាពការណ៍និងលទ្ធភាពនៃកម្លាំងរបស់យើង។ ប៉ុន្តែសភាពការណ៍មានការវិវត្តន៍យ៉ាងឆាប់រហ័ស មិនអាចអោយយើងឈរស្ងៀមមួយកន្លែង លើគោលការណ៍ខ្លះដែលហួសសម័យទៅហើយនោះបានទេ ហើយទាមទារត្រូវមានការកែប្រែលើចំណុច ដែលមិនសមស្របទៅនឹងសភាពការណ៍។ ការប្រើពាក្យកែទម្រង់នៅទីនេះ មិនត្រឹមត្រូវទាំងស្រុងទេ អាស្រ័យយើងមិនទាន់មានសព្ទគ្រប់ នូវបទដ្ឋានដែលទាមទារបំពេញអោយវាគ្រប់ ហើយជាងនេះទៅទៀត យើងធ្វើការកែប្រែលើចំណុចដែលហួសសម័យដោយផ្តើមចេញពីមូលដ្ឋានចាស់ ដើម្បីកែលំអប៉ុន្តែដើម្បីងាយស្រួលស្តាប់ យើងសូមប្រើពាក្យ «កែទម្រង់» បណ្តោះអាសន្នសិន។ ឃើញនូវពាក្យកែទម្រង់ គេអាចមើលឃើញថា សាធារណរដ្ឋប្រជាមានិតកម្ពុជា ប្តេជ្ញាធ្វើដំណើរដោយមិនរង់ចាំដំណោះស្រាយនយោបាយឡើយ។ នាវាត្រូវបន្តដំណើរទៅមុខ តាមផ្លូវដែលបានជ្រើសរើសរួចមកហើយ ប៉ុន្តែអាចផ្ទុកថែមនូវអ្នកដំណើរ ប្រសិនបើគេចង់ជិះ ហើយកែ*

លំអថែមអោយនាវានេះ ធ្វើដំណើរបានលឿនជាងមុន ឯអ្នកធ្លាប់ធ្វើដំណើរលើនាវា ក៏គ្មានការស្រមើស្រមៃរង់ចាំមនុស្សផ្សេងទៀតមកជួយកាច់ចង្កូតដែរ។

ផ្លូវកែទម្រង់ គឺជាក្រឹត្យក្រមសត្យានុម័តិ ជាសំណូមពររួមរបស់ប្រជាជន របស់ថ្នាក់ក្រោម ក៏ដូចជាថ្នាក់មជ្ឈិម ពោលគឺជាការទាមទាររបស់ប្រទេសជាតិ ដែលត្រូវធ្វើដំណើរឈានឡើង។ ក្នុងបញ្ហាកែទម្រង់ មុននឹងឈានទៅកែប្រែលើបញ្ហាផ្សេងទៀត គឺត្រូវគិតពីកត្តានយោបាយជាមុន ដែលនៅទីនេះ បញ្ហាមួយដាក់អោយយើងពិនិត្យពិភាក្សា គឺការវាយតម្លៃ «ដំណាក់កាលបដិវត្តន៍» តើបដិវត្តន៍កំពុងស្ថិតក្នុងដំណាក់កាលណា? ប្រការនេះ មានអត្ថន័យសំខាន់ណាស់ ព្រោះវាជះឥទ្ធិពលទៅលើគោលមាគ៌ាផ្សេងទៀត ហើយដែលសំខាន់គឺ «មាគ៌ាអភិវឌ្ឍសេដ្ឋកិច្ចសង្គម» នេះឯង។ មហាសន្និបាតបក្សលើកទី ៤ និងលើកទី៥ បានកំណត់ដំណាក់កាលបដិវត្តន៍កម្ពុជា ជាដំណាក់កាលអន្តរកាលឈានឡើងសង្គមនិយម។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ កម្មាភិបាលជាន់ខ្ពស់របស់បក្សយើង ក៏បានធ្វើការពិភាក្សាឡើងវិញអំពីដំណាក់កាលបដិវត្តន៍កម្ពុជា ដោយមានមតិលើកឡើងថា «បដិវត្តន៍កម្ពុជា កំពុងស្ថិតនៅក្នុងដំណាក់កាលប្រជាជាតិប្រជាធិបតេយ្យតែប៉ុណ្ណោះ មិនទាន់បានផ្ទេរទៅកាន់ដំណាក់កាលសង្គមនិយមនៅឡើយទេ» ដោយមានហេតុផលថា ពិតមែនតែបានផ្តួលរំលំរបប ប៉ុល ពត ប៉ុន្តែសង្គ្រាមមិនទាន់បានបញ្ចប់ទាំងស្រុងនៅឡើយទេ ហើយសង្គ្រាមនេះ មានការលូកដៃពីពួកចក្រពត្តិវាតទីនិយម និងអានុភាពប្រតិកិរិយាអន្តរជាតិផង ឯករាជ្យកំពុងប្រឈមមុខនឹងការគំរាមកំហែង ដែលតម្រូវអោយ

យើងត្រូវធ្វើសង្គ្រាមការពារមាតុភូមិ។ ជាមួយនោះដែរ ក្នុងខឿនសេដ្ឋកិច្ចជាតិ នៅមានសមាសភាពសេដ្ឋកិច្ចជាច្រើន ហើយកម្លាំងនៃសេដ្ឋកិច្ចរដ្ឋ នៅមានកម្រិតទន់ខ្សោយ។ ជាងនេះទៅទៀត កម្លាំងផលិតកម្មនៅកម្ពុជា ក៏មិនអនុញ្ញាតអោយយើងរៀបចំទូវទំនាក់ទំនងផលិតកម្មសង្គមនិយមបានដែរ។ ការកំណត់ដំណាក់កាលបដិវត្តន៍របស់យើងកន្លងមក ហាក់ដូចជាខ្ពស់ពេក មិនស្របនឹងដំណាក់កាលដែលយើងកំពុងស្ថិតនៅ ប៉ុន្តែការអនុវត្តន៍ជាក់ស្តែង យើងបានខិតខំសម្រួលទៅតាមសភាពការណ៍ខ្លះៗ ហើយដែរ។

ភាពជាក់ស្តែងនៃដំណាក់កាលបដិវត្តន៍ ដែលយើងកំពុងស្ថិតនៅ គឺជា «ដំណាក់កាលការពារមាតុភូមិ និងស្តារឡើងវិញ សេដ្ឋកិច្ចសង្គម ធ្វើអោយមានស្ថិរភាព ដើម្បីបង្កបុព្វបទឈានទៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម នាដើមកំណាត់ផ្លូវនៃសម័យអន្តរកាល» ដែលក្នុងដំណាក់កាលនេះ វាទាមទារនូវកម្មវិធីនយោបាយ ដែលមានលក្ខណៈប្រជាជាតិប្រជាធិបតេយ្យ ដើម្បីប្រមូលគ្រប់កម្លាំងមនុស្ស កម្លាំងប្រាជ្ញា កម្លាំងសម្បត្តិ ធ្វើភារកិច្ចការពារប្រទេស និងស្តារសេដ្ឋកិច្ចសង្គម ហើយដែលការងារនេះ វាទាមទារនូវពេលវេលាយ៉ាងយូរ ទើបអាចសំរេចបាន។ សិទ្ធិសំរេចពីដំណាក់កាលបដិវត្តន៍ ជាសិទ្ធិរបស់មហាសន្និបាតបក្ស ឬសន្និបាតកម្មាភិបាលទូទាំងប្រទេសរបស់បក្ស ជាការល្អណាស់ដែលបក្សយើងបានពិនិត្យឡើងវិញនូវបញ្ហានេះ។

ដើម្បីធ្វើជាមូលដ្ឋានអោយការកែទម្រង់ ក្រៅពីការវាយតម្លៃ និងកំណត់ឡើងវិញនូវមាគ៌ាគោលនយោបាយ សំរាប់គ្រប់ផ្នែកនោះ បញ្ហាប្រជាធិបតេយ្យភាវូបនីយកម្មខាងនយោបាយ ក៏ជាចំណុចគន្លឹះដ៏

សំខាន់មួយ ក្នុងការជួយជំរុញការកែទម្រង់។ ប្រសិនបើគ្មានការពង្រីកបន្ថែមនូវប្រជាធិបតេយ្យ ទៅក្នុងស្ថាប័នគ្រប់ផ្នែក គ្រប់ថ្នាក់ និងគ្រប់ស្រទាប់ប្រជាជននោះ ហើយបើមិនឆ្លើយតបបាននូវសិទ្ធិស្របច្បាប់របស់មនុស្សគ្រប់ៗរូបទេនោះ យើងមិនអាចរកនូវពន្លឺថ្មី ឬគន្លឹះថ្មី សំរាប់នាំប្រទេសឈានទៅមុខបានដែរ។ បក្សយើងជាបក្សរបស់ប្រជាជន ហើយរដ្ឋអំណាចយើង ក៏ជារដ្ឋអំណាចដែលកើតឡើង និងស្ថិតស្ថេរដោយប្រជាជន ដូច្នេះការជឿនលឿនទៅមុខបាន ក៏អាស្រ័យដោយបានការចូលរួមពីមនុស្សទាំងអស់ក្នុងសង្គម។ គប្បីត្រូវអោយ មានវេទិកាប្រជាជន ជួយយោបល់ចំពោះបក្ស និងរដ្ឋអំណាច ក្បាលម៉ាស៊ីនឃោសនារបស់យើង ក៏ត្រូវហ៊ានយកយោបល់របស់ប្រជាជនមកផ្សព្វផ្សាយ។ យើងត្រូវបែងចែក រវាងការឃោសនាបំផ្លិចបំផ្លាញរបស់ខ្មាំងជាមួយនឹងយោបល់របស់ប្រជាជន មហាជនដែលហ៊ាននិយាយការពិតហ៊ានលើកយោបល់ ដើម្បីជួយកសាងបក្ស រដ្ឋអំណាច និងកម្មាភិបាលយើង។ ប៉ុន្មានឆ្នាំកន្លងមក បក្ស និង រដ្ឋយើង បានធ្វើហើយដែរ ប៉ុន្តែមិនទាន់ក្លាយជាចលនាធំទូលាយនៅឡើយ ដែលត្រូវពង្រីកអោយបានខ្លាំងក្លាថែមទៀត។

អំពីរចនាសម្ព័ន្ធគ្រប់គ្រង និងរបៀបធ្វើការងារ ក៏ត្រូវមានការកែលំអទើបអាចរត់ទាន់ការវិវត្តន៍នៃសភាពការណ៍។ ប្រសិនបើយើងបន្តតាមរបបគ្រប់គ្រងរបៀបរដ្ឋបាល និងការិយាល័យនិយម ព្រមជាមួយនឹងរចនាសម្ព័ន្ធបត់បែនច្រើនគន្ទាក់នោះ ការកែទម្រង់លើវិស័យសេដ្ឋកិច្ច ក៏មិនអាចឈានទៅមុខបានឡើយ។ ១០ ឆ្នាំកន្លងមកនេះ យើងបានកសាងក្បាលម៉ាស៊ីនដឹកនាំគ្រប់គ្រង តាំងពីតូចពេក រហូតដល់ធំជ្រុល ហើយ

បត់បែនជាច្រើនផង បន្ថែមទៅដោយរបបការងារប្រមូលផ្តុំ ឱបក្រសោបការិយាល័យនិយម ដែលបានធ្វើអោយដំណើរការជួបភាពយឺតយ៉ាវយ៉ាងខ្លាំង។ យើងគួរតែពិនិត្យកែសម្រួលនូវក្បាលម៉ាស៊ីនដឹកនាំគ្រប់គ្រងឡើងវិញ ធ្វើអោយស្រាលនូវក្បាលម៉ាស៊ីនរដ្ឋបាល។ កន្លងមក បក្ស និងរដ្ឋយើង បានសំរេចរំលាយស្ថាប័នខ្លះរួចមកហើយ ប៉ុន្តែនៅតាមស្ថាប័នមួយចំនួន បានចាត់តាំងអង្គភាពជំនួយការច្រើនពេក នាំដល់អង្គភាពជាច្រើន ធ្វើការងារតែមួយ បង្កើតទម្រង់បែបបទច្រើនជ្រុល នាំអោយរាំងស្ទះដល់ការងារទៅវិញ។ ទម្រង់បែបបទរដ្ឋបាលមានភាពសាំញ៉ាំរាប់ទាំងបែបបទក្នុងអាជីវកម្ម ផលិតកម្មផង ធ្វើអោយប្រជាជន និងមូលដ្ឋានជួបការលំបាកច្រើន។ អំពីសិទ្ធិអំណាច ស្ថាប័នថ្នាក់លើ ឱបក្រសោបច្រើនជ្រុល ក្តាប់តាំងពីក្បាលរហូតដល់កន្ទុយ ដែលធ្វើអោយថ្នាក់ក្រោមគ្មានម្ចាស់ការ ច្នៃប្រឌិត រាំងស្ទះដល់ការងារ និងផលិតកម្ម និងធ្វើអោយថ្នាក់លើរត់តាមការងារប្រចាំថ្ងៃ បោះបង់ចោលការងារដែលមានចរិតជាយុទ្ធសាស្ត្រធំៗ។ ការប្រមូលផ្តុំហួសហេតុរបស់ថ្នាក់លើ ក្នុងសភាពការណ៍ណាមួយអាចសមស្រប ប៉ុន្តែអាស្រ័យដោយការរីកចំរើនធំធាត់នៃស្ថាប័នដឹកនាំថ្នាក់ក្រោម និងជួរកម្មាភិបាល ប្រសិនបើយើងបន្តតាមផ្លូវនេះ នឹងបង្កើតទម្លាប់គ្មានការទទួលខុសត្រូវរបស់ថ្នាក់ក្រោម ពោលគឺមានសភាពការណ៍អ្វីកើតឡើង ថ្នាក់ក្រោមមិនអាចដោះស្រាយអ្វីបានឡើយ គឺមានតែការងារពីរប៉ុណ្ណោះដែលគេត្រូវធ្វើ៖ ទីមួយ រាយការណ៍សុំយោបល់ថ្នាក់លើ ទីពីរ ស្តីបន្ទោសថ្នាក់ក្រោម។ នេះគឺជាទម្លាប់នៃជំងឺកម្មាភិបាលគ្មានការទទួលខុសត្រូវ។ ក្នុងវិស័យសេដ្ឋកិច្ច ដើម្បីឈានទៅធ្វើអាជីវកម្មចំណេញខាត ស្វ័យភិបាលសេដ្ឋ

*កិច្ចបាននោះ ភាពចាំបាច់មួយ គឺត្រូវតែហ៊ានផ្ដល់នូវសិទ្ធិគ្រប់គ្រាន់អោយដល់មូលដ្ឋានអាជីវកម្ម ផលិតកម្មតែម្ដង ទើបអាចដំណើរការទៅបាន។*

*ការកែទម្រង់ក្នុងវិស័យសេដ្ឋកិច្ច គឺជាបញ្ហាបន្ទាន់ ហើយក្ដៅបំផុតនាពេលខាងមុខនេះ។ យើងមិនអាចឈរទ្រឹងលើចំណុចមួយបានឡើយ គឺត្រូវមានជំហានកែប្រែដោយម៉ឺងម៉ាត់បំផុត។ ការកែទម្រង់របស់យើងមានគោលដៅសំខាន់បំផុត គឺ «ការរកដំណោះស្រាយបញ្ចប់ភាពក្រីក្ររបស់ប្រជាជនយើង» គ្មានគោលដៅអ្វីផ្សេងពីនេះឡើយ។ នេះជាបញ្ហាដែលត្រូវពិភាក្សាគ្នាយ៉ាងផុលផុស ប្រកបដោយការតស៊ូទាំងទស្សនៈនិងទាំងវិធីរកដំណើរការ ព្រោះថាក៏នៅមានគំនិតចង់បន្តដំណើរតាមផ្លូវចាស់ដដែល ពិសេសគំនិតនេះ ចាត់ទុកថា ក្នុងការបើកទូលាយសកម្មភាពនៃសេដ្ឋកិច្ចឯកជន និងសេដ្ឋកិច្ចរដ្ឋចំរុះឯកជន គឺជាការបោះបង់ចោលមាគ៌ាសង្គមនិយម ហើយបង្កើតនូវរបបមូលធននិយមនៅកម្ពុជា។ ដំណោះស្រាយរបៀបនេះ គឺគ្មានគំនិតបោះបង់ចោលមាគ៌ាសង្គមនិយមឡើយ ប៉ុន្តែរបៀបដើរទៅតាមសង្គមនិយមយ៉ាងណានោះ ត្រូវតែគិតអោយបានច្បាស់លាស់ ហើយស្របនឹងសភាពការណ៍ជាក់ស្ដែងរបស់កម្ពុជា។ ប្រទេសសង្គមនិយមស្ទើរតែទាំងអស់ដែលធ្វើដំណើរទៅមុនយើង ក៏បានធ្វើការកែទម្រង់អាស្រ័យដោយមានការអភិវឌ្ឍន៍យឺត ដែលតម្រូវអោយគេរកផ្លូវដើរអោយបានលឿនជាង។ សភាពការណ៍កម្ពុជាមានចរិតពិសេសដោយឡែករបស់ខ្លួន មិនអាចធ្វើតាមគំរូពុម្ពរបស់ប្រទេសណាមួយបានឡើយ។ យើងប្រើក្រឹត្យក្រមរួម ប៉ុន្តែក៏ត្រូវអនុលោមតាមសភាពការណ៍នៃប្រទេសខ្លួនដែរ។ យើងបានចេញដំណើរពីបាតដៃទទេ ហើយត្រូវកសាងប្រទេស ក្នុង*

សភាពការណ៍មានសង្គ្រាមផង និងមានសន្តិភាពផង ដូច្នេះយើងត្រូវរកវិធីធ្វើដំណើរអោយសំរេចគោលដៅរបស់ខ្លួន។ ជាទ្រឹស្តីគឺជាការងាយស្រួល ប៉ុន្តែការអនុវត្តន៍នៅជួបការលំបាកច្រើនយ៉ាងណាស់ ព្រោះការសំរេចទិសដៅក្នុងការបញ្ចប់ភាពក្រីក្ររបស់ប្រជាជន គឺជាផ្លូវមួយដ៏វែង មិនអាចសំរេចបានឆាប់ឡើយ ហើយពេលណាមិនទាន់បញ្ចប់បាននូវភាពក្រីក្រនេះ គោលដៅនៃសង្គមនិយម ក៏មិនអាចសំរេចទៅបានដែរ។ ចាស់ទុំធ្លាប់បានប្រៀនប្រដៅថា កុំប្រដៅកូនក្នុងពេលវាឃ្លានបាយ វាមិនស្តាប់យើងឡើយ។ ចំពោះប្រជាជនក៏ដូច្នេះដែរ យើងមិនអាចយកទ្រឹស្តីទៅអប់រំគេ អោយឈានឡើងសង្គមនិយមនៅពេលដែលគេរកបាយហូបមិនបាន គ្មានសម្លៀកបំពាក់នោះបានដែរ ប្រការដែលសំខាន់ គឺត្រូវធ្វើអោយក្រពះឆ្អែត មានសម្លៀកបំពាក់ មុង ភួយ ផ្ទះសម្បែង មធ្យោបាយធ្វើដំណើរ កូនបានរៀនសូត្រ មានពេលកំសាន្តសប្បាយ។ល។ សិន ទើបគេមានជំនឿលើសង្គមនិយម ហើយក៏ជាគោលដៅសង្គមនិយម ហើយក៏មិនមែនមូលធននិយមនោះទេ។ សង្គមនិយម ប៉ុល ពត បានធ្វើអោយប្រជាជនខ្លាចបាក់ស្បាត។ បញ្ហាសង្គមនិយមនៅកម្ពុជា ប្រការដែលគួរភ័យខ្លាច គឺមិនមែនកម្មសិទ្ធិឯកជនលើដីធ្លី ទ្រព្យសម្បត្តិ ផ្ទះសម្បែង រោងច្រក សហគ្រាស មធ្យោបាយផ្សេងទៀតនោះឡើយ ប៉ុន្តែប្រការគួរភ័យខ្លាចនោះ គឺភាពក្រីក្រ ដែលចេះតែអូសបន្លាយគ្មានទីបញ្ចប់ រហូតដល់ប្រជាជនបាត់ជំនឿលើការដឹកនាំរបស់បក្ស និងរដ្ឋ ហើយចូលដៃជាមួយសត្រូវវាយរំលំបក្ស និងរដ្ឋទៅវិញទេ។ ពេលប្រជាជនមានបាន រដ្ឋអំណាចពិតជានឹងត្រូវបានពង្រឹក ខឿនការពារជាតិនឹងត្រូវបានលើកកំពស់ ហើយប្រជាជននឹង

ចូលរួមច្រើនជាង រហូតដល់ការកសាងប្រទេសលើគ្រប់វិស័យ ហើយ បក្ស និងរដ្ឋ ក៏លែងភ័យព្រួយ ពីការអត់ឃ្លានក្នុងប្រជាជនដែរ។ ដើម្បី អោយសេដ្ឋកិច្ចឈានឡើងបាន ចាំបាច់ត្រូវប្រើប្រាស់អោយអស់លទ្ធ ភាពនូវសមាសភាពសេដ្ឋកិច្ចទាំងប្រាំ គឺសេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចសមូហ ភាព សេដ្ឋកិច្ចគ្រួសារ សេដ្ឋកិច្ចឯកជន សេដ្ឋកិច្ចរដ្ឋចំរុះជាមួយឯកជន ហើយត្រូវរៀបចំអោយត្រឹមត្រូវ នូវទំនាក់ទំនងផលិតកម្ម ធ្វើយ៉ាងណា អោយស្របនឹងកម្រិតសមត្ថភាពផលិតកម្ម ទើបអាចទៅមុខបាន។ ប្រជាជនកម្ពុជាភាគច្រើន គឺកសិករ ហើយសេដ្ឋកិច្ចជាតិក៏ត្រូវពឹងផ្អែក លើកសិកម្ម ដូចនេះទាមទារត្រូវកែទម្រង់វិស័យនេះ អោយបានឆាប់ រហ័ស និងខ្លាំងក្លា។ ដូចបានលើកឡើងនូវភាគទី២ នៃសៀវភៅនេះថា យើងរៀបចំមិនទាន់ត្រូវនៅឡើយ ហើយទំនាក់ទំនងសេដ្ឋកិច្ចជាមួយ កសិករ មិនទាន់បានលើកទឹកចិត្តចំពោះការផលិតដែរ សំខាន់គឺកត្តា ថ្លៃ។ យើងត្រូវកែសម្រួលឡើងវិញ នូវការរៀបចំក្រុមសាមគ្គីបង្កបង្កើន ផល អោយស្របនឹងបំណងប្រាថ្នារបស់ប្រជាជន ស្របតាមសមត្ថភាព នៃកម្លាំងផលិតកម្ម ដោយឡែកត្រូវកែប្រែគោលនយោបាយ ស្តីពីការ ប្រើប្រាស់ដីធ្លីកសិកម្ម និងដោយមិនត្រូវភ័យព្រួយអំពីកម្មសិទ្ធិរបស់ ប្រជាកសិករលើដីធ្លីនោះឡើយ គឺធ្វើយ៉ាងណាអោយប្រជាកសិករមាន លំនឹងក្នុងការផលិត ហើយហ៊ានចំណាយទុន និងកម្លាំងពង្រីកដីថ្មីថែ ម។ យើងត្រូវហ៊ានធ្វើវិនិយោគថែមទៀតអោយកសិករ ក្នុងនោះមាន ទាំងការលក់ជូនកសិករនូវត្រាក់ទ័រ ម៉ាស៊ីនបូមទឹក និងសម្ភារៈចាំបាច់ ផ្សេងទៀតផង ដោយមិនខ្លាចចំពោះកសិករមានត្រាក់ទ័រឡើយ ...។ យើងត្រូវហ៊ានជួយអោយប្រជាជនដាំដំណាំឧស្សាហកម្មយូរឆ្នាំ ដូចជា

កៅស៊ូ ម្រេច កាហ្វេ។ល។ ចំពោះចំការកៅស៊ូមានស្រាប់ ហើយមិនទាន់ធ្វើអាជីវកម្ម យើងក៏ត្រូវហ៊ានផ្តល់អោយប្រជាជនធ្វើអាជីវកម្មទាញយកផលដែរ។ ដើម្បីបញ្ចប់នូវការលាក់ផ្ទៃដី ដែលប្រជាជនធ្វើបាន យើងត្រូវតែផ្តល់ដីអោយប្រជាជន ហើយបង្កើតក្រឹត្យច្បាប់ ស្តីពីពន្ធដីធ្លី ជំនួសវិភាគទានស្នេហាជាតិ។ បញ្ហាថ្លៃ ជាគំនាស់ដ៏សំខាន់ ក្នុងការជំរុញផលិតកម្ម ហើយក៏សំដែងចេញនូវទំនាក់ទំនង រវាងរដ្ឋជាមួយកសិករផងដែរ ដែលចាំបាច់ត្រូវធ្វើការកែសម្រួល ក្នុងទិសដៅធ្វើអោយថ្លៃត្រូវនឹងតម្លៃពិត នៃផលិតផលរបស់ប្រជាជន គឺធ្វើយ៉ាងណាធានាអោយបាននូវផលប្រយោជន៍ពិតប្រាកដរបស់កសិករ។ ក្នុងបញ្ហាឧស្សាហកម្ម សិប្បកម្ម ដឹកជញ្ជូន សាងសង់ ត្រូវមានជំហានក្លាហាន ក្នុងការកែប្រែ ហ៊ានប្រគល់សិទ្ធិអោយសហគ្រាស ម្ចាស់ការផលិត និងចរាចរបែងចែក ហើយផលិតផលមួយចំនួនណានោះ ត្រូវផ្តល់សិទ្ធិអោយពេងចក្រ កំណត់ថ្លៃខ្លួនឯង លើមូលដ្ឋានទីផ្សារអាចទទួលយកបាន។ គួរបញ្ចប់នូវស្ថានភាពគ្រប់គ្រងរដ្ឋបាលក្នុងអាជីវកម្ម បញ្ចប់ស្ថានភាពរដ្ឋលូកដៃក្តាប់ តាំងពីក្បាលរហូតដល់កន្ទុយ ដែលនាំអោយសហគ្រាសបាត់ម្ចាស់ការ។ រដ្ឋក្តាប់តែក្បាល ហើយបើជ្រៅបំផុតត្រឹមដងខ្លួនពោលគឺចំពោះសហគ្រាសមួយចំនួន រដ្ឋក្តាប់តែការកំណត់ចំណូលនិងពន្ធដារបង់ចូលថវិការរដ្ឋ។ ចំពោះសហគ្រាសមួយចំនួន ដែលមានផលិតផល ទាក់ទងដល់ការប្រើប្រាស់របស់មនុស្សភាគច្រើននៅក្នុងសង្គម រដ្ឋក្តាប់ថែមទៀតនូវថ្លៃ ឯសហសហគ្រាសខ្លះ ដូចជា បារី ស្រា ទឹកក្រូច។ល។ គួរផ្តល់អោយសហគ្រាសកំណត់ថ្លៃខ្លួនឯង លើមូលដ្ឋានទីផ្សារ អាចទទួលយកបាន ហើយធ្វើអាជីវកម្មមានចំណេញ។

យើងត្រូវហ៊ានបើកទូលាយអោយឯកជនពង្រីក ឧស្សាហកម្ម សិប្បកម្ម សំណង់ស៊ីវិល ដឹកជញ្ជូនអ្នកដំណើរ ឬក៏អោយឯកជនធ្វើចម្រុះជាមួយរដ្ឋ។ រោងចក្រសហគ្រាសមួយចំនួន ដែលរដ្ឋគ្មានលទ្ធភាពធ្វើអាជីវកម្ម ឬធ្វើអាជីវកម្មគ្មានចំណេញ គឺអាចធ្វើចម្រុះជាមួយឯកជនជួលអោយឯកជន ឬអាចលក់អោយឯកជនតែម្តងព្រោះរបៀបមួយណាក៏មានចំណេញជាងទុករោងចក្រអោយនៅស្ងៀម ឬធ្វើអាជីវកម្មខាតដែរ។ ឯការដឹកជញ្ជូនអ្នកដំណើរ យើងត្រូវហ៊ានលើកទឹកចិត្តអោយឯកជនប្រើប្រាស់ទុន កសាងនូវមធ្យោបាយ ឬនាំចូលជាកាណូត កប៉ាល់ រថយន្តដើម្បីបំពេញសេចក្តីត្រូវការ ក្នុងការធ្វើដំណើររបស់ប្រជាជន។ «ប្រការដែលគួរខ្វាចនៅពេលនេះ មិនមែនថៅកែរថយន្ត ឬថៅកែកាណូត កប៉ាល់នោះឡើយ។ ប្រការដែលគួរខ្លាច គឺគ្រោះថ្នាក់អាយុជីវិតប្រជាជន ការលំបាកវេទនា ការយឺតយ៉ាវរបស់ប្រជាជនក្នុងការធ្វើដំណើរ ដែលមកពីខ្វះមធ្យោបាយធ្វើដំណើរទៅវិញទេ»។ រដ្ឋមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងគេ។ ការសាងសង់ស៊ីវិល ក៏ត្រូវលើកទឹកចិត្តអោយប្រជាជនធ្វើ ដើម្បីបំពេញការសាងសង់ ដែលកំពុង និងកើនឡើងនាពេលខាងមុខ។ បញ្ហាថ្លៃ បៀវត្ស ចរាចរបែងចែករូបិយវត្ថុ និងថវិកា នៅតែជាបញ្ហាក្តៅបំផុត សំរាប់ការដោះស្រាយរបស់បក្ស និងរដ្ឋយើង ព្រោះបញ្ហានេះ ស្មុគស្មាញ ហើយពិបាកដោះស្រាយ។ ១០ឆ្នាំកន្លងមក នៅកម្ពុជា បានកកើតឡើងនូវទីផ្សារពីរ និងថ្លៃបី គឺមានទីផ្សាររដ្ឋ ទីផ្សារសេរី ថ្លៃផ្គត់ផ្គង់ ថ្លៃជានាអាជីវកម្ម និងថ្លៃផ្សារសេរី ដែលបង្កើតអោយមានការលំបាកយ៉ាងខ្លាំង ដល់ការគ្រប់គ្រងទីផ្សារ។ ការកែទម្រង់របស់យើង គឺតម្រង់ទិសរកគោលដៅ «ទីផ្សារមួយ ថ្លៃមួយ»

ដែលក្នុងស្ថានភាពនេះ វាមិនទាក់ទងតែត្រឹមថ្ងៃមួយមុខនោះឡើយ តែវាទាក់ទងដល់ការងារហិរញ្ញវត្ថុ ថវិកា រូបិយវត្ថុ និងបៀវត្សផងដែរ។ ការងារហិរញ្ញវត្ថុ ថវិកា រូបិយវត្ថុ បៀវត្ស និងថ្ងៃ គឺជាការងារដាច់ពីគ្នា ប៉ុន្តែវាមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ។ ប្រសិនបើផ្នែកនីមួយៗ អនុវត្តផ្សេងៗពីគ្នា ហើយមិនគិតគូរដល់ចំណងទាក់ទងនេះទេ នោះការអនុវត្តន៍ពិតជាមិនអាចទទួលលទ្ធផលបានល្អឡើយ។

រយៈពេលចុងក្រោយនេះ យើងបានធ្វើការកែសម្រួលអំពីថ្ងៃប្រមូលទិញស្រូវ កសិផល ថ្ងៃលក់សម្ភារៈទំនិញនាំចូល ដោយផ្អែកលើមូលដ្ឋាននៃការកែប្រែអត្រាទូទាត់ផ្ទៃក្នុង ប៉ុន្តែជាទូទៅយើង អាចនិយាយបានថា ថ្ងៃ និងតម្លៃ មិនទាន់សមស្របជាមួយគ្នានៅឡើយទេ ពិតមែនតែបានបំពេញនូវចន្លោះខ្វះ តែវិសមភាពវាងថ្ងៃរដ្ឋ និងថ្ងៃទីផ្សារសេរីនៅមានជាបន្ត ទាំងថ្ងៃទិញពីប្រជាជន និងទាំងថ្ងៃលក់ផលិតផលរបស់រដ្ឋ។ គោលដៅឈានទៅរកទីផ្សារមួយ ថ្ងៃមួយ គឺត្រូវផ្តើមចេញពីការងារថ្ងៃនេះឯង ប៉ុន្តែជំហ៊ានត្រូវឈានយ៉ាងណានោះ ក៏ត្រូវប្រុងប្រយ័ត្នដែរ ព្រោះបញ្ហានេះ វាជះឥទ្ធិពលដល់ថវិកា និងរូបិយវត្ថុ ព្រមទាំងចំពោះជីវភាពរបស់មនុស្សគ្រប់រូប ក្នុងសង្គមទៀតផង ហើយវាក៏ជាគំនាស់ក្នុងផលិតកម្មផងដែរ។ ឋានានុក្រមកំណត់ថ្ងៃ ក៏ត្រូវមានការកែប្រែ ពោលគឺរដ្ឋកំណត់ តែលើមុខទំនិញ មានលក្ខណៈជាយុទ្ធសាស្ត្រមួយចំនួនណានោះបានហើយ ឯមុខទំនិញមួយចំនួនណាដែលមិនជះឥទ្ធិពលខ្លាំងទេ គួរទុកអោយសហគ្រាសកំណត់តែម្តងហើយរត់ឡើង ឬចុះ ទៅតាមសំណូមពររបស់ទីផ្សារ។

បញ្ហាបៀវត្ស ជាបច្ចុប្បន្នភាពមួយ ដែលទាមទារការដោះស្រាយ។

ចាប់តាំងពីឆ្នាំ ១៩៧៩ មក យើងស្ថិតក្នុងស្ថានភាពពីរបែប៖ មុនការចាយវាយប្រាក់ ការឧបត្ថម្ភ (បៀវត្ស) ត្រូវផ្តល់ជាសម្ភារៈ ហើយក្រោយការចាយវាយប្រាក់បៀវត្សត្រូវចែកជាពីរ មួយត្រូវផ្តល់ជាប្រាក់ និងមួយទៀតអាស្រ័យដោយការខ្វះស្ថិរភាពអំពីថ្លៃលើទីផ្សារ ត្រូវបានផ្តល់ជាសម្ភារៈតាមថ្លៃផ្គត់ផ្គង់ ហើយរដ្ឋបំពេញខាតប្រហែល ៣.០០០ លានរៀល ក្នុងមួយឆ្នាំៗ។ កម្មាភិបាល បុគ្គលិក កម្មករ មិនបានមើលឃើញថា សម្ភារៈទាំងនេះជាបៀវត្សឡើយ ហើយការផ្គត់ផ្គង់នេះ ក៏បានបង្កើឡើងនូវការលំបាកយ៉ាងច្រើន ហើយស្មុគស្មាញក្នុងការគ្រប់គ្រងផង។ បច្ចុប្បន្ននេះ កម្លាំងទិញលើទីផ្សារមានស្ថិរភាពបង្គួរ ដែលអាចអោយបញ្ចប់ស្ថានភាពផ្គត់ផ្គង់ទំនិញ ឬក៏បន្ថយមុខទំនិញបណ្តើរៗ ឈានទៅផ្តាច់ទាំងស្រុង ដោយបញ្ចូលប្រាក់ដែលរដ្ឋធ្លាប់បំពេញខាតនេះ ទៅក្នុងបៀវត្សតែម្តង។ ធ្វើបានយ៉ាងនេះ គឺធ្វើអោយកម្មាភិបាល បុគ្គលិក កម្មករ មើលឃើញតម្លៃពិតប្រាកដនៃបៀវត្សរបស់គេ ធ្វើអោយកិច្ចបញ្ជីការបៀវត្សនៅក្នុងថ្ងៃដើម និងសោហ៊ុយចរាចរកិច្ចបញ្ជីការអាជីវកម្មរបស់សហគ្រាស មានភាពប្រាកដប្រជា ឃើញខាតឃើញចំណេញ។ រដ្ឋសល់មុខទំនិញដើម្បីលក់ ប្រមូលប្រាក់មកវិញ ហើយក៏បញ្ចប់បាននូវស្ថានភាពកេងយកទំនិញជារបបផ្គត់ផ្គង់ទៅលក់លើទីផ្សារ ដើម្បីយកចំណេញផងដែរ។

ក្នុងអង្គភាពផលិតកម្មស្វ័យាភិបាលហិរញ្ញវត្ថុ គឺត្រូវអនុវត្តតាមរូបភាពផ្សេង ពិតមែនតែផ្ទេរការផ្គត់ផ្គង់សម្ភារៈ មកជាប្រាក់ដូចគ្នាប៉ុន្តែលើការទទួលផល ត្រូវតែហ៊ានបំផុសប្រយោជន៍របស់បុគ្គល ដើម្បីជំរុញការផលិត។ ប៉ុន្មានឆ្នាំកន្លងមក យើងបានគួបផ្សំយ៉ាងជិតស្និទ្ធ

រវាងផលប្រយោជន៍បី គឺផលប្រយោជន៍រដ្ឋ សមូហភាព និងបុគ្គល ហើយយើងហាក់ដូចជា មើលឃើញផលប្រយោជន៍រដ្ឋ និងសមូហភាពខ្ពស់ពេក ដែលនាំអោយការប្រឡងប្រណាំងផលិតផល របស់បុគ្គលជំរុញទៅមិនរួច។ រយៈពេលចុងក្រោយនេះ យើងបានអនុវត្តរបបបៀវត្សតាមបរិមាណផល តែក៏នៅមានកម្រិតកំណត់ អំពីផលប្រយោជន៍របស់កម្មករដែរ ដូចជាប្រាក់ចំណេញរបស់សហគ្រាសច្រើនយ៉ាងណាក៏ដោយ តែកម្មករបានបន្ថែមជាបៀវត្សមិនលើសពី ៤ ខែ ឬ៦ ខែ ហើយមានរហូតដល់ ១២ ខែ តែបែងចែកជាបេឡាសមូហភាព ក្នុងនោះដែរ។ យើងត្រូវធ្វើដំណើរតាម «របៀបម៉ៅផ្តាច់ ធ្វើបានច្រើនទទួលផលច្រើន»។ ឧទាហរណ៍ ចំពោះកម្មករចំការកៅស៊ូ យើងគួរកំណត់ថា ទឹកជ័រមួយលីត្រស្មើប៉ុន្មានរៀល ឧបមាថា ២ រៀល បើកម្មករចាក់បាន ១០ លីត្រ យើងផ្តល់ប្រាក់អោយ ២០ រៀល តែបើបាន ១០០ លីត្រ ត្រូវផ្តល់ ២០០ រៀលអោយគេ ។ ធ្វើយ៉ាងនេះ នឹងបង្កើតបាននូវចលនាប្រឡងប្រណាំងក្នុងការផលិត ហើយអង្គភាពអាជីវកម្មងាយស្រួលក្នុងការគិតគូរបញ្ជីការផង។ លើមូលដ្ឋាននៃការអនុវត្តន៍បៀវត្ស តាមបរិមាណផលទាំងស្រុងនេះ រដ្ឋអាចម៉ៅផ្តាច់នូវបរិមាណឥណទានមួយ ដល់អង្គភាពផលិតកម្ម ហើយអង្គភាពផលិតយកទៅចាត់ចែងប្រើប្រាស់ ដូច្នេះនឹងបញ្ចប់បាននូវរបៀបគ្រប់គ្រងរដ្ឋបាលក្នុងអាជីវកម្ម បញ្ចប់ស្ថានភាពរដ្ឋ ក្តាប់តាំងពីក្បាលដល់កន្ទុយ ដូចពេលមុន និងធ្វើអោយអង្គភាពម្ចាស់ការ ក្នុងការធ្វើអាជីវកម្មផង។

បញ្ហាចរាចរបែងចែកទំនិញ ការនាំចេញ និងការនាំចូល ក៏ត្រូវមានជំហានកែប្រែដែរ។ រយៈពេលចុងក្រោយនេះ យើងបានកែប្រែមួយចំនួន

ហើយដែរ ប៉ុន្តែក៏ស្ថិតក្នុងដំណាក់កាលសាកល្បង ហើយមានករណីខ្លះ វាផាកពីឆ្វេងទៅស្តាំតែម្តង ដែលចាំបាច់ត្រូវតម្រែតម្រង់ឡើងវិញ។

យើងបានផ្តល់សិទ្ធិអោយសហគ្រាសមួយចំនួន ធ្វើចរាចរផលិតផលដោយខ្លួនឯង ដោយមិនទុកអោយផ្នែកពាណិជ្ជកម្មផ្តាច់មុខដូចពេលមុន ហើយចាត់ទុកពាណិជ្ជកម្ម ជាអ្នកទិញពីសហគ្រាសដូចគេឯងដែរ។ នោះជាទិសដៅឈានទៅបញ្ចប់ស្ថានភាពកកស្ទះទំនិញ ហើយដាក់អោយសហគ្រាស ធ្វើអាជីវកម្មដោយម្ចាស់ការ។

ក្នុងការនាំចេញនាំចូល នាប៉ុន្មានឆ្នាំចុងក្រោយនេះ បរិមាណផលិតផលនាំចេញបានកើនឡើង បន្ថយបាននូវការហូរមាសចេញ ដើម្បីប្តូរយកទំនិញមកវិញ ប៉ុន្តែរដ្ឋមិនទាន់ធ្វើការងារនេះ នៅឡើយ។ ក្នុងពេលមជ្ឈិមឱបមិនជុំ មជ្ឈិមបានចង់ដៃខេត្ត ក្រុង មិនអោយធ្វើ នាំអោយឯកជនធ្ងៀតឱកាសប្រមូលទិញនាំចេញ ដោយងាយស្រួល និងម្យ៉ាងទៀតអាស្រ័យដោយការខុសគ្នារវាងថ្លៃរដ្ឋ និងថ្លៃផ្សារសេរី ធ្វើអោយការប្រមូលទិញរបស់រដ្ឋ ដើម្បីនាំចេញទៅផ្លាស់ប្តូរទំនិញ ជាមួយប្រទេសដែលមានទំនាក់ទំនងពាណិជ្ជកម្មជាមួយកម្ពុជា ត្រូវជួបការលំបាក។ ដើម្បីសម្រួលដល់ ការគ្រប់គ្រងការនាំចេញនាំចូលរបស់ឯកជន រដ្ឋសភា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើការកែប្រែមាត្រា ១៩ នៃរដ្ឋធម្មនុញ្ញ ដែលមុននោះកំណត់ថា «ពាណិជ្ជកម្មក្រៅប្រទេស ស្ថិតក្នុងការគ្រប់គ្រងផ្តាច់មុខរបស់រដ្ឋ» មកជា «ពាណិជ្ជកម្មក្រៅប្រទេស ស្ថិតក្នុងការគ្រប់គ្រង និងចាត់ចែងរបស់រដ្ឋ» ដែលមានន័យថា ផ្តល់លទ្ធភាពអោយឯកជន ធ្វើការនាំចេញនាំចូលតាមការចាត់ចែង និងគ្រប់គ្រងរបស់រដ្ឋ។ ព្រមជាមួយគ្នានេះ មជ្ឈិមក៏បានផ្តល់សិទ្ធិអោយ

ខេត្ត ក្រុង ធ្វើការនាំចេញនាំចូលនូវមុខទំនិញលើសផែនការ និងក្រៅផែនការរបស់រដ្ឋ ក្នុងបំណងបំផុសចលនាបង្កើនការដាំដុះ និងប្រមូលប្រកពទំនិញដើម្បីនាំចេញ បង្កប្រកពទុនសំរាប់មូលដ្ឋាន។ ថ្ងៃប្រមូលទិញទៀតសោត ក៏បានធ្វើការកែប្រែ ដោយរដ្ឋមិនកំណត់ថ្ងៃស្ងាប់ក្រឡានោះដែរ គឺត្រូវរត់តាមថ្ងៃទីផ្សារអន្តរជាតិ ដើម្បីប្រមូលទិញ លើមូលដ្ឋាននាំចេញនាំចូលមានចំណេញ។ ក្រោយពេលបានបើកលទ្ធភាពអោយខេត្ត ក្រុង និងឯកជន យើងសង្កេតឃើញនូវការធ្វើដំណើរពីឆ្វេងតម្រង់ទៅស្តាំ ដោយខេត្ត ក្រុងខ្លះ ចាប់អារម្មណ៍ខ្ពស់ពេក លើការនាំចូលនាំចេញទំនិញ ភ្លេចគិតដល់ការជំរុញផលិតកម្ម ហើយបាតុភាពដណ្តើមគ្នាប្រមូលទិញ ដេញថ្លៃគ្នា ក៏បានចាប់ផ្តើមបង្កការលំបាកដល់ការគ្រប់គ្រងទីផ្សារ។ រដ្ឋបានកំណត់ឡើងវិញនូវគោលការណ៍សំរាប់ខេត្តក្រុង និងឯកជននាំចេញនាំចូលគឺ ទំនិញ ដែលខេត្ត ក្រុង អាចនាំចេញបាន ជាទំនិញលើសផែនការ ក្រោយពេលផ្តល់ជូនមជ្ឈិមរួចរាល់អស់ហើយ និងជាទំនិញក្រៅផែនការ ដែលមជ្ឈិមមិនប្រមូលទិញ ហើយដែលជាទំនិញដែលមានក្នុងក្របខ័ណ្ឌខេត្តខ្លួន ដោយមិនអនុញ្ញាតអោយខេត្តក្រុងមួយ ទៅដណ្តើមទិញនៅខេត្តក្រុងដទៃទៀតឡើយ។ ឯ ឯកជនត្រូវធ្វើសកម្មភាពនៅកន្ទុយ និងនៅក្បាល គឺខេត្តក្រុងខាងក្រោយ អាចប្រើប្រាស់ឯកជនជួយប្រមូលទិញ ហើយនាំចេញតាមខេត្តក្រុងមាត់ច្រក ឬតាមពាណិជ្ជកម្មក្រៅប្រទេស ឯខេត្តក្រុងមាត់ច្រក ប្រើប្រាស់ឈ្មួញឯកជននាំចេញបន្ត ហើយនាំទំនិញមកវិញ ក្នុងករណីដែលខេត្តក្រុងមាត់ច្រក មិនអាចនាំចេញនាំចូល បានអាស្រ័យមកពីសភាពការណ៍នយោបាយ ដែលប្រទេសមួយចំនួនកំពុងហ៊ុំព័ទ្ធ

សេដ្ឋកិច្ចរបស់យើង។

ជញ្ជីងពាណិជ្ជកម្មក្រៅប្រទេសរបស់យើង កំពុងបាត់តុល្យភាពយ៉ាងខ្លាំង ហើយការហូរមាសចេញ ក៏នៅកើតមានជាបន្តបន្ទាប់ ថ្វីត្បិតតែបានថយចុះខ្វះក៏ដោយ ហើយបំណុលបរទេស នឹងបន្តកើនឡើងដែរ។ វិធានការនៅទីនេះ ត្រូវតែជំរុញអោយបានខ្លាំងនូវផលិតកម្ម ហើយជំរុញការបំពាក់នូវមូលដ្ឋានកែច្នៃ ដើម្បីបង្កើនតម្លៃនៃមុខទំនិញសំរាប់នាំចេញ ខិតខំប្រមូលទិញអោយអស់ នូវផលិតផលដែលអាចនាំចេញបាន ដើម្បីបំព្រួញអោយតូចនូវចន្លោះឃ្លាតគ្នា រវាងការនាំចូល និងការនាំចេញ បន្ថយអោយនៅតិចបំផុត នូវការនាំមាសចេញ ទៅប្តូរយកទំនិញពីបរទេស។

នៅមានបញ្ហាជាច្រើនទៀត ដែលត្រូវកែប្រែ ប៉ុន្តែការកែទម្រង់នៅកម្ពុជា មានការខុសប្លែកពីការកែទម្រង់នៅប្រទេសផ្សេងទៀត ពិតមែនតែយើងយល់យ៉ាងច្បាស់ នូវទំនាក់ទំនងរវាង «រួម និងដោយឡែក» ហើយប្រព័ន្ធនយោបាយសេដ្ឋកិច្ចសង្គម ជាតួអង្គឯកភាពមួយ ប៉ុន្តែសភាពការណ៍នៅកម្ពុជា មិនអនុញ្ញាតអោយយើង កែទម្រង់ទាំងស្រុងនោះឡើយ ហើយជាងនេះទៀត យើងត្រូវកែប្រែលើមូលដ្ឋានមានស្រាប់។ ដូច្នេះ ការកែទម្រង់នៅប្រទេសយើង គឺត្រូវមានជំហានកែតាមផ្នែក និងទៅតាមខ្សែទាក់ទងរបស់វា ដែលមានចរិតជាការកែប្រែ នូវចំណុចដែលមិនស្របនឹងសភាពការណ៍ផង និងត្រូវបំពេញបន្ថែមនូវចំណុចដែលមិនទាន់មានផង ពោលគឺការកែទម្រង់ដោយស្ងាត់ស្ងៀម ឬហៅថា ការកែទម្រង់មិនប្រកាស ដែលទាមទារធ្វើផងដកពិសោធន៍ផង ហើយទាមទារនូវការទទួលខុសត្រូវ ហ៊ានគិត ហ៊ានធ្វើ ហ៊ានទទួលខុស

ត្រូវដើម្បីសំរេចទិសដៅបញ្ចប់ភាពក្រីក្ររបស់ប្រជាជន និងនាំប្រទេសឈានឡើង ភាពសម្បូរសប្បាយ។ ក្នុងបញ្ហាសេដ្ឋកិច្ច ចំណុចធំនៃការកែទម្រង់ គឺប្រមូលផ្តុំនៅលើផែនការូបនីយកម្ម គោលនយោបាយគំនាស់និងរចនាសម្ព័ន្ធគ្រប់គ្រងដែលបញ្ហានេះ ទាមទារនូវការលើកឡើងខាងទ្រឹស្តី និងយុទ្ធសាស្ត្រសេដ្ឋកិច្ចអោយស្របនឹងសភាពការណ៍ ព្រមទាំងលទ្ធភាពពិតប្រាកដរបស់ប្រជាជនយើង។ ត្រូវចេញដំណើរពីសេចក្តីត្រូវការ និងការប្រើប្រាស់ ដើម្បីរៀបចំផែនការ អាស្រ័យដោយស្ថានភាពពិតប្រាកដរបស់កម្ពុជា ស្ថិតក្នុងកម្រិតសេដ្ឋកិច្ចទីផ្សារ។ ត្រូវចេញដំណើរពីផលប្រយោជន៍បុគ្គល ដើម្បីបំពេញអោយផលប្រយោជន៍រដ្ឋនិងសមូហភាព។ ផលប្រយោជន៍បុគ្គល ជាផលប្រយោជន៍ស្របច្បាប់ដែលត្រូវចេញពីចលនាប្រឡងប្រណាំងជុំវិញការផលិត ដែលមិនរំលោភទៅលើផលប្រយោជន៍រដ្ឋ និងសមូហភាព ហើយបញ្ហានេះទាក់ទងសំខាន់ទៅនឹងបញ្ហាថ្លៃ និងបៀវត្ស។ រចនាសម្ព័ន្ធគ្រប់គ្រង ត្រូវធ្វើអោយបានស្រាល ហើយទន់ភ្លន់។

សភាពការណ៍នយោបាយវិវត្ត ដោយអនុគ្រោះអោយយើង ប៉ុន្តែនៅតែស្មុគស្មាញ។ បក្ស និងរដ្ឋយើង កំពុងដឹកនាំប្រទេស ក្នុងសភាពការណ៍ចល័ត ដែលទាមទារអោយជួរបក្ខជន កម្មាភិបាល ត្រូវតែមានភាពរឹងប៉ឹងខាងនយោបាយ ដើម្បីម្ចាស់ការលើគ្រប់ស្ថានភាព និងគ្រប់កាលៈទេសៈ។ នាវាត្រូវធ្វើដំណើរបន្តតាមទិសដៅបានកំណត់ពីពេលចេញដំណើរ ប៉ុន្តែនាវាបានត្រូវកែលំអហើយ ដោយបន្ថែមកម្លាំងម៉ាស៊ីនថ្មី ហើយនាវានោះក៏កំពុងឆ្លងកាត់នូវខ្យល់ព្យុះ ដែលបក់បោកយ៉ាងខ្លាំង ហើយត្រៀមដើម្បីចូលចតក៏នៅឆ្ងាយផងដែរ។ យើងសង្ឃឹមថា

*យើងនឹងទៅដល់ទិសដៅ ព្រោះយើងបានឆ្លងកាត់នូវការលំបាកបំផុតរួចស្រេចទៅហើយ (១៩៧៩-១៩៨០) ហើយរាល់ការឆ្លងកាត់របស់យើង ក៏បានបង្ហាញពីសមត្ថភាព និងលទ្ធភាពពិតប្រាកដ របស់ប្រជាជនយើងហើយដែរ ពោលគឺ «ពេលវេលាគាំទ្រយើង អនាគតស្ថិតនៅលើកណ្ដាប់ដៃប្រជាជនកម្ពុជា»។*